# សំឡេងពីមន្ទីរ ស-២១

## ភាពព្រឺខ្លាច និងប្រវត្តិក្នុងគុកសម្ងាត់របស់ ប៉ុល ពត





**ដេវីដ ឆេនដល័រ**

ប្រែសម្រួលជាភាសាខ្មែរដោយ សួ ប៊ុនស៊ូ

◆ **សម្លេងពីមន្ទីរស-២១**

*ភាពព្រឺខ្លាច និងប្រវត្តិគុកសម្ងាត់របស់ ប៉ុល ពត*

◆ និពន្ធដោយ ដេវីដ ឆេនដល័រ ◆ ប្រែសម្រួលជាភាសាខ្មែរដោយ សួ ប៊ុនសូ ◆ ពិនិត្យកែសម្រួលឃ្លោងឃ្លា និងអក្ខរាវិរុទ្ធដោយ ឆាំង យុ, ហ៊ុយ វណ្ណៈ និង ទេព ម៉េងឃាន ◆ ក្រាហ្វិក និងកុំព្យូទ័រដោយ រ៉ា ឆៃរ៉ាន់ និង អឿ រតនា ◆ រចនាក្រប និងតួសៀវភៅដោយ ឆាំង យុ ◆ បោះពុម្ពនៅកម្ពុជាឆ្នាំ២០០៣ ◆ រក្សាសិទ្ធិ ◆

Translation Series No. 3 ◆ Documentation Center of Cambodia

◆ Voice from S-21: *Terror and History in Pol Pot's Secret Prison*
◆ Translated by Bunsou Sour ◆ Edited by Youk Chhang, Huy Vannak and Tep Meng Khean ◆Graphic by Ra Chhayrann and Oeur Ratana ◆ Cover and Book Design by Youk Chhang ◆ Printed in Cambodia 2003 ◆ Copyright ◆

University of California Press
Berkeley and Los Angeles, California

University of California Press, Ltd.
London, England

© 1999 by the Regents of the University of California

Library of Congress Cataloging-in-Publication Data

Chandler, David P.-.

Voices from S-21 : terror and history in Pol Pot's
secret prison / David Chandler.
p. cm.
Includes bibliographical references (p. )
and index.
ISBN 0-520-22005-6 (alk. paper).
1. Torture–Cambodia. 2. Political prisoners–
Cambodia. 3. Political persecution–
Cambodia. 4. Genocide–Cambodia.
5. Cambodia–Politics and
government–1975-79. I. Title.
II. Title: Voices from S-Twenty-one.
HV8599.C16C48 1999
303.6'09596–dc21 99-13924
CIP

Manufactured in the United States of America

08 07 06 05 04 03 02 01 00 99
10 9 8 7 6 5 4 3 2 1

The paper used in this publication meets the
minimum requirements of ANSI/NISO Z39.48-1992
(R 1997) (*Premanence of Paper*). ∞

# មាតិកា


សេចក្ដីថ្លែងអំណរគុណ
អារម្ភកថា

វគ្គទីមួយៈ ការរកឃើញមន្ទីរស-២១ ............ ទំព័រទី១
វគ្គទីពីរៈ ស-២១ ស្ថាប័នស្វ័យត ............ ទំព័រទី១៧
វគ្គទីបីៈ ការជ្រើសរើសត្រូវ ............ ទំព័រទី៤៨
វគ្គទីបួនៈ ការបង្កើតសំណួរ ............ ទំព័រទី៨៩
វគ្គទីប្រាំៈ បន្ទុំឲ្យឆ្លើយ ............ ទំព័រទី១២៥
វគ្គទីប្រាំមួយៈ បរិយាយអំពីមន្ទីរស-២១ ............ ទំព័រទី១៦១

ឧបសម្ព័ន្ធ ............ ទំព័រទី១៧៥

កំណត់សម្គាល់ និង ឯកសារពិគ្រោះ

វគ្គទីមួយៈ ការរកឃើញមន្ទីរស-២១ ............ ទំព័រទី១៧៨
វគ្គទីពីរៈ ស-២១ស្ថាប័នស្វ័យត ............ ទំព័រទី១៨៥
វគ្គទីបីៈ ការជ្រើសរើសត្រូវ ............ ទំព័រទី១៩៦
វគ្គទីបួនៈ ការបង្កើតសំណួរ ............ ទំព័រទី២១៤
វគ្គទីប្រាំៈ បន្ទុំឲ្យឆ្លើយ ............ ទំព័រទី២២៨
វគ្គទីប្រាំមួយៈ បរិយាយអំពីមន្ទីរស-២១ ............ ទំព័រទី២៤០

ចំណាប់អារម្មណ៍របស់អ្នកប្រែសម្រួល ............ ទំព័រទី២៤៦
ប្រវត្តិរូបសង្ខេបរបស់អ្នកប្រែសម្រួល ............ ទំព័រទី២៤៨

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទមានសេចក្តីរីករាយនិងកិត្តិយសដែលស្នាដៃនិពន្ធរបស់ខ្ញុំមានចំណងជើងថា «សំឡេងពីមន្ទីរ ស-២១» ត្រូវបានបោះពុម្ពផ្សព្វផ្សាយយ៉ាងទូលំទូលាយជាភាសាខ្មែរសម្រាប់ប្រិយមិត្តអ្នកអាននិងអ្នកសិក្សាទូទៅ ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមិត្តភក្តិរបស់ខ្ញុំ ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានរ៉ាប់រងនូវការបោះពុម្ពផ្សាយសៀវភៅនេះឡើង និងចំពោះ សួ ប៊ុន ស៊ូ ជានិពន្ធនាយករងទី១ នៃទស្សនាវដ្តីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានបំពេញកិច្ចការនេះយ៉ាងប៉ិនប្រសប់ ។

សៀវភៅដើមជាភាសាអង់គ្លេសមានរាយនាមបុគ្គលជាច្រើនដែលបានជួយខ្ញុំ នៅក្នុងខណៈដែលខ្ញុំកំពុងសរសេរសៀវភៅនេះ ប៉ុន្តែឈ្មោះទាំងនេះមិនមានរាយនៅសៀវភៅជាភាសាខ្មែរទេ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ខ្ញុំសូមបញ្ជាក់ថា បុគ្គលិកនៃមជ្ឈមណ្ឌលឯកសារកម្ពុជានិងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង បានជួយខ្ញុំអស់ពីចិត្តពីថ្លើម កាលពីប៉ុន្មានឆ្នាំកន្លងទៅ ក្នុងពេលដែលខ្ញុំកំពុងតែសិក្សាស្រាវជ្រាវនិងសរសេរសៀវភៅនេះឡើង ។ បុរសនិងស្ត្រីខ្មែរមួយចំនួនទៀតក៏ផ្តល់នូវជំនួយដែលមិនអាចខ្វះបាន ប្រហាក់ប្រហែលនិងគ្នានេះដែរ ពោលគឺអ្នកទាំងអស់បានផ្តល់បទសម្ភាសន៍ដល់រូបខ្ញុំ ។

ខ្ញុំមកដល់ប្រទេសកម្ពុជាដំបូងនៅឆ្នាំ១៩៦០ ហើយចាប់តាំងពីនោះមក ខ្ញុំក៏ក្លាយជាភ្ញៀវផងនិងជាអ្នកសិក្សាជាន់ខ្ពស់ផងទាក់ទងនឹងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ។ ខ្ញុំសូមឧទ្ទិសស្នាដៃនេះជូនចំពោះមិត្តភក្តិក្លើម្រាក់របស់ខ្ញុំទាំងអស់ ទាំងអ្នកដែលនៅរស់និងទាំងអ្នកដែលបានលាចាកលោកយើងនេះទៅហើយ ។

ដេវីដ ឆេនដល័រ

# PREFACE

*In April 1975 armed Cambodian radicals, known to the outside world as the Khmer Rouge, were victorious in a five-year-long civil war. Almost at once, and without explaining their rationale, the Khmer Rouge forcibly emptied Cambodia's towns and cities, abolished money, schools, private property, law courts, and markets, forbade religious practices, and set almost everybody to work in the countryside growing food. We now know that these decisions were made by the hidden, all-powerful Communist Party of Kampuchea (CPK) as part of its plan to preside over a radical Marxist-Leninist revolution. The Khmer Rouge regime of Democratic Kampuchea (DK), led by a former schoolteacher using the pseudonym Pol Pot, was swept from power by a Vietnamese invasion in January 1979. By then, perhaps as many as 1.5 million Cambodians were dead from malnutrition, overwork, and misdiag- nosed and mistreated diseases. At least another 200,000 people, and probably thousands more, had been executed without trial as "class enemies. " Overall, roughly one in five Cambodians died as a result of the regime. Because so many of the victims were ethnic Cambodians, or Khmer, the French author Jean Lacouture coined the term auto-genocide to describe the process.*

*In August 1981, two years after the collapse of the Pol Pot regime, I traveled to Phnom Penh with four academic colleagues. It was the first time in ten years I had been in the city. During our three-day sojourn we were struck by the way that the city and its people seemed to be recovering from their catastrophic experiences in the 1970s, when foreign invasions, a ruinous civil war, and the Khmer Rouge regime had successively swept through Cambodia with typhoon force. The people's courage and resilience in 1981, however, could not diminish the horrors of the Khmer Rouge era.*

*On our second day in Phnom Penh, we were taken to see the Tuol Sleng Museum of Genocidal Crimes, located in a southern section of the city. The museum had been set up by the pro- Vietnamese regime that had replaced the Khmer Rouge. It had been open to the public for about a year and was a prominent feature of government-organized tours for foreign visitors. In prerevolutionary times, we learned; a high school had occupied the site. Under the Khmer Rouge the abandoned school became the headquarters of the regime's internal security police or santebal. This secret facility, known as S-21, was an interrogation center where over fourteen thousand "enemies" were questioned, tortured, and made to confess to counterrevolutionary crimes. All but a handful were put to death. The existence of S-21 was known in the DK era only to the people inside it and to the country's leaders, who were themselves concealed from view.*

*Two Vietnamese photographers had stumbled across the compound in January 1979, in the aftermath of the invasion. They discovered the bodies of "about fifty" recently murdered prisoners, instruments used for torture, and a huge, hastily abandoned archive. It was clear to them that under the Khmer Rouge S-21 had been an important and horrific institution. Within days the site was cleaned up and shown to sympathetic foreign visitors. Over the next few months, under Vietnamese guidance, it was transformed into a museum.*

*On our guided tour we were first taken to small classrooms on the ground floor. We saw metal beds, fetters, and photographs of murdered prisoners taken by the Vietnamese when they had entered the com- pound in 1979. In other ground floor rooms instruments of torture were displayed, alongside paintings by a survivor that depicted prisoners being interrogated, tortured, and killed. Hundreds of enlarged mug shots of prisoners were also posted on the walls.*

*On the second floor we saw the tiny cells assigned to prisoners being questioned and larger rooms where groups of less important captives were held. In a suite of smaller rooms we were shown what remained of S-21's archive. Stacks of documents, some of them several feet high, were piled into glass-fronted cabinets, on tables, and against the walls. The vast majority, it seemed, consisted of typed or handwritten confessions. There were over four thousand. Some covered only a page or two. A few, drawn from high-ranking prisoners, were several hundred pages long. Other documents in the archive included entry and execution records, interrogators' notes, copies of speeches by DK officials, Khmer Rouge periodicals, cadre study notebooks, and biographical data about workers at the prison. We spent a few minutes riffling through the papers, taking desultory notes on the prisoners' "treasonous activities" before emerging, numbed, into the darkening afternoon.*

*Over the next few years, the visit lingered in my mind as other writers, including Elizabeth Becker, Ben Kiernan, and Steve Heder, drew on materials from the archive for their research. In the early 1980s, the human rights activist David Hawk assembled hundreds of documents from S-21 to use as evidence for an unsuccessful campaign to bring the leaders of DK to justice. Throughout the decade, copies of confessions circulated among scholars and journalists interested in the Khmer Rouge. Thanks to the generosity of these people and the cooperation of the museum staff, I used many of these documents for my own research before returning to Cambodia in 1990, when I spent several hours working in the archive, assembling material to be copied.*

*In 1992 and 1993 the S-21 archive was microfilmed under the auspices of Cornell University and the Cambodian Ministry of Culture, which had jurisdiction over the museum. Judy Ledgerwood, John Marston, and Lya Badgley supervised the microfilming at different times. During this period I visited Cambodia four times and kept track of the microfilming project. When the microfilming was complete, the prospect of examining the S-21 archive in depth and at leisure struck me as tempting, and I began to map out an agenda.*

*I hoped initially to use the archive as the basis for a narrative history of opposition to DK. I soon discovered, however, that the truth or falsity of the confessions, along with the innocence or guilt of the people who produced them, could rarely be corroborated. For a narrative history of DK, I realized, I would have to cast a wider net, with no assurance that corroborating documentation for the confessions would ever come to light. On the other hand, the challenge of studying S-21 and its archive on their own terms remained attractive, particularly as a means of entering the collective mentality of the Khmer Rouge and also as a way of coming to grips with a frightening, heavily documented institution. Changing direction in this way soon led me to concentrate on those texts*

*that would help me answer such questions as: How did the prison work? Who were the "enemies" being held? How were interrogations structured? When was torture applied? Was S-21 primarily a "Communist" facility or a "Cambodian" one? Were there foreign models for it? And so on. Between 1993 and 1998 I examined over a thousand confession texts, scanned hundreds more, and read all the administrative materials from the prison that had come to light. These included hundreds of documents that were discovered in 1996 and 1997, after the Cornell project was complete. Over the years I supplemented my readings in the archive with research in secondary literature, looking for comparative insights.*

*This book is the result. Over the years that it took me to write it, I received generous financial support for my research and incurred a multitude of intellectual debts that I am happy to acknowledge.*

*The greatest of these debts, extending over the past thirty-two years, is to my wife, Susan. During our sojourns in Melbourne, Paris, Washington, D.C., and elsewhere, she has shared the ups and downs of my teaching career and the joys and glooms of my research. She has read c successive drafts of everything I've written. Her comments have improved everything she has read. She has accomplished all this with baffling good humor in the midst of her own busy professional life, in the course of raising our three children, and on top of many other interests. This book, like my earlier ones, would never have taken shape without her close reading, her support, and her astute suggestions.*

*Work on the book was formally set in motion when the vice chancellor of Monash University, Professor Mal Logan, underwrote the purchase of a set of S-21 microfilms for me to work with. John Badgley, the curator of the Southeast Asia collection at Cornell University, saw to it that all 210 reels were waiting for me in 1994 when I took up a fellowship at the Woodrow Wilson Center in Washington, D.C. Over the next eight months I familiarized myself with the archive, copied hundreds of confessions, and gave several seminars that helped me to refine my research focus and my conclusions. Back in Australia, the Australian Research Council provided me with a generous grant that defrayed the cost of research assistance and allowed me to copy hundreds of confessions onto paper. In 1995 a fellowship from the Harry Frank Guggenheim Foundation paid for further research assistance and a trip to Cambodia. The fellowship also allowed me to reduce my Monash teaching load for a semester. In March 1996, when I was ready to start writing, a resident fellowship at the Rockefeller Foundation's study center at Bellagio gave Susan and me an unimpeded month to consider how my research might be turned into a book.*

*At every stage of my work I have been favored with excellent libraries, assiduous administrative support, and superb research assistance. Library staff at Monash University and the University of Wisconsin were helpful in tracking down secondary materials. I am particularly grateful for the administrative support provided as the book was being written, first at Monash by Val Campbell and Wendy Perkins, and later at the University of Wisconsin by Danny Streubing and at the University of Oregon by Martina Armstrong.*

*My talented research assistants at the Wilson Center, Thong-Chi Ton Nu and Tim O'Connell, refined the computerized index to the archive and hunted down invaluable secondary materials. For the next three years my research assistant in Australia was Sok Pirun, a survivor of the DK era who had been trained as a historian in Phnom Penh in the 1960s. Pirun gave unstintingly of his time, arranged some fascinating interviews for me, and translated dozens of key documents from the archive. As we worked together, he provided a running commentary on the project and thereby gave me an invaluable entree into the murky thought-world of the Khmer Rouge. Another survivor of the DK regime, Mouth Sophea, took an interest in my work when I was teaching in Madison and helped me over several hurdles of interpretation.*

*Over the years I have been buoyed up by friends and colleagues who have read all or part of the manuscript. These include Sara Colm, May Ebihara, Craig Etcheson, Kate Frieson, Alexander Hinton, Charles F. Keyes, Judy Ledgerwood, Alfred W. McCoy, and Keith W. Taylor. Steve Heder in particular has been unstinting in his help, sending me hundreds of pages of unpublished translations, several unpublished essays, numerous interview transcripts, and invaluable comments on the full text and on specific points. Several of Richard Arant's graceful translations from the S-21 archive have found their way into the book, and I am grateful for his interest in the project. Henri Locard shared his findings about "the Khmer Rouge gulag" with me in 1995-1997, and my more recent discussions with Alexander Hinton about the collective psychology of the Khmer Rouge have helped me to reformulate some of my ideas.*

*In 1994 I came to know Douglas Niven and Chris Riley, two intrepid photojournalists who formed the Photo Archive Group in Phnom Penh to clean, index, and reprint over six thousand photographs-the vast majority of them mug shots-from negatives that they discovered in woeful condition at S-21. Along with their friend Peter Maguire, Doug and Chris provided me with transcripts of interviews they conducted in 1995 and 1996, and Doug arranged several interviews with former workers at S-21 that we conducted together in 1997 and 1998. Additional interview transcripts were kindly provided at various times by Richard Arant, David Ashley, Chhang Youk, Sara Colm, David Hawk, Steve Heder, Alexander Hinton, Ben Kiernan, Nate Thayer, and Lionel Vairon.*

*Soon after I began writing, I learned that the Cambodia Genocide project administered by Yale University had gained access to a range of new materials dating from the Lon Nol period (1970-1975) and the DK era. Thanks to Dr. Timothy Castle in the Office of the DPMO-MIA in the U.S. Department of Defense, I was given a contract to examine these materials to see whether they contained information useful to the MIA program. In 1997 I visited Cambodia three times to review the materials, now housed in the Documentation Center-Cambodia (DC- Cam) under the able supervision of Chhang Youk, whose enthusiastic help in 1997 and 1998 was crucial to DPMO-MIA and to my S-21 project. During these visits, Lach Vorleak Kaliyan, the archivist at the Tuol Sleng Museum, located and copied several hundred pages of materials that had been found at S-21 after the Cornell University microfilming project had been completed.*

*Many other people have been helpful to me along the way, clearing up specific points, making comparative suggestions, and sharing their ideas about the Khmer Rouge.*

*In addition to those named already, and at the risk of offending any- one I might forget to single out, I am happy to acknowledge the help of Norman Aiblett, Susan Aitken, Lya Badgley, Elizabeth Becker, Andy Brouwer, Frederick Brown, Mary Brown Bullock, Timothy Carney, Susan Cook, Robert Cribb, Thomas Cushman, Stephen Dunn, Penny Edwards, Craig Etcheson, Joseph Fraley, Lindsay French, Edward Friedman, Jorg Friedrich, David Garrioch, Christopher Goscha, Bailey Gunther, Eleanor Hancock, Anne Hansen, lem Sokhim, Helen Jarvis, David Jenkins, William Joseph, Ben Kiernan, J. D. Legge, Suzanna Lessard, John Marston, Robin McDowell, Kevin Mclntyre, Paul McNellis, Robert Moeller, Rudolf Mrazek, Seth Mydans, Irina Paperno, Kong Peng, Christophe Peschoux, Craig Reynolds, John Rickard, Michael Schoenhals, Daniel Schwartz, Bruce Sharp, Sok Sin, Larry Stross, Nate Thayer, Serge Thion, Ton-that Quynh-Du, William Turley, Khatarya Um, Lionel Vairon, Walter Viet, Eric Weitz, Thongchai Winachikul, and Yang Lian.*

*My editors, Patrick Gallagher of Allen and Unwin and Reed Malcolm and Cindy Fulton of the University of California Press, have been supportive and enthusiastic. I am also grateful for the comments pre- pared by anonymous readers for the Press and for the inspired and assiduous copyediting of Erika Büky. All but two of the photographs, those by Kelvin Rowley and Carol Mortland, were generously provided by the Photo Archive Group. Gary 5winton, of the Monash Geography Department, prepared the diagram of S-21.*

*Putting the book together, in spite of its horrific subject matter, has been a pleasurable, cooperative effort. Without the copious help I have mentioned it could never have been written.*

*David Chandler*

# អារម្ភកថា

*នៅក្នុងខែមេសា ឆ្នាំ១៩៧៥ ក្រុមយោធាជ្រុលនិយមកម្ពុជាដែលពិភពលោកខាងក្រៅហៅថា «ខ្មែរក្រហម» ទទួលបានជោគជ័យក្នុងផែនការធ្វើសង្គ្រាមប្រាំឆ្នាំរបស់ខ្លួន ។ ក្រោយពីបានជ័យជម្នះភ្លាម ខ្មែរក្រហមបានចាប់ផ្តើមជម្លៀសប្រជាជនចេញពីទីក្រុង លុបបំបាត់រូបិយវត្ថុ បិទទ្វារសាលារៀន មិនឲ្យមានកម្មសិទ្ធិទ្រព្យសម្បត្តិ មិនឲ្យមានតុលាការនិងផ្សារផ្សេ បំបិទសាសនា និងបង្ខំឲ្យប្រជាជនទៅធ្វើការបង្កបង្កើនផលទាំងអស់គ្នានៅតាមជនបទ ដោយមិនប្រាប់ពីហេតុផលអ្វីបន្តិចសោះឡើយ ។ យើងដឹងថា ការសម្រេចចិត្តទាំងនេះត្រូវបានធ្វើឡើងដោយបក្សកុម្មុយនិស្តកម្ពុជាដែលលាក់ខ្លួននិងមានអំណាចបំផុត ។ នេះជាផ្នែកមួយនៃផែនការបក្សកុម្មុយនិស្តក្នុងការគ្រប់គ្រងបដិវត្តន៍ជ្រុលនិយមម៉ាក្ស-លេនីន ។ របបកម្ពុជាប្រជាធិបតេយ្យរបស់ខ្មែរក្រហមដឹកនាំដោយគ្រូបង្រៀនដែលប្រើនាមក្លែងប្ញហស្សនាមថា ប៉ុល ពត ត្រូវបានផ្តួលរំលំពីអំណាចតាមរយៈការចូលមកដល់នៃកងទ័ពវៀតណាម នៅខែមករា ឆ្នាំ១៩៧៩ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានប្រជាជនកម្ពុជាចំនួនប្រមាណមួយលានប្រាំសែននាក់ត្រូវស្លាប់បាត់បង់ជីវិតដោយសារគ្មានអាហារហូបគ្រប់គ្រាន់ ធ្វើការហួសកម្លាំង និងការធ្វើរោគវិនិច្ឆ័យនិងព្យាបាលជំងឺមិនបានត្រឹមត្រូវ ។ យ៉ាងហោចណាស់មានមនុស្ស២០០.០០០នាក់ផ្សេងទៀត និងរាប់ពាន់នាក់ទៀតត្រូវបានសម្លាប់ចោលដោយគ្មានការជម្រះទោសអ្វីឡើយ ដោយចោទប្រកាន់ថាជា«ខ្មាំងវណ្ណៈ» ។ សរុបដោយត្រួសៗមក ក្នុងចំណោមប្រជាជនកម្ពុជាប្រាំនាក់ មានម្នាក់បានបាត់បង់ជីវិតដោយសាររបបនេះ ។ ដោយសារជនរងគ្រោះជាច្រើនជាជនជាតិខ្មែរ អ្នកនិពន្ធបារាំង ហ្សង់ ឡាគូទៀ ក៏បានបង្កើតពាក្យមួយសម្រាប់ហៅអំពើដែលកើតឡើងនៅពេលនោះថា «ប្រល័យពូជសាសន៍ឯង»* (Autogénocide) ។

*នៅក្នុងខែសីហា ឆ្នាំ១៩៨១ ពីរឆ្នាំក្រោយពីការផ្តួលរលំនៃរបប ប៉ុល ពត ខ្ញុំបានធ្វើដំណើរមកទីក្រុងភ្នំពេញជាមួយសហការីផ្នែកសិក្សាស្រាវជ្រាវចំនួនបួនរូប ។ នេះជាលើកទីមួយហើយក្នុងរយៈពេលដប់ឆ្នាំដែលខ្ញុំបានមកស្នាក់នៅទីក្រុងភ្នំពេញ ។ នៅក្នុងអំឡុងពេលស្នាក់អាស្រ័យចំនួនបីថ្ងៃ យើងមានការចាប់អារម្មណ៍ជាខ្លាំង ដោយឃើញទីក្រុងនិងប្រជាជនហាក់ដូចជាបានសុខស្រួលឡើងវិញក្រោយពីមានមហន្តរាយកាលពីទសវត្សរ៍ឆ្នាំ១៩៧០ ដែលកាលនោះមានការលុកលុយរបស់ពួកបរទេស សង្គ្រាមស៊ីវិលប្រកបដោយភាពខ្ទេចខ្ទាំ និងរបបខ្មែរក្រហម ដែលបានបោកបក់មកលើប្រទេសកម្ពុជាដូចព្យុះសង្ឃរា ។ ប៉ុន្តែសេចក្តីក្លាហាននិងការឆាប់រួសរាន់ងើបឡើងវិញរបស់ប្រជាជនកម្ពុជាក្នុងឆ្នាំ១៩៨១មិនអាចកាត់បន្ថយគ្រោះថ្នាក់ដ៏គួរឲ្យព្រឺខ្លាចដែលកើតឡើងនៅសម័យខ្មែរក្រហមបានឡើយ ។*

*នៅថ្ងៃទីពីរនៃការស្នាក់អាស្រ័យនៅទីក្រុងភ្នំពេញ មគ្គុទ្ទេសក៍បាននាំយើងទៅមើលសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងដែលស្ថិតនៅខាងត្បូងទីក្រុងភ្នំពេញ ។ សារមន្ទីរនេះត្រូវបានរៀបចំឡើងដោយរបបកម្ពុជាមួយដែលគាំទ្រដោយវៀតណាមក្រោយពីរបបខ្មែរក្រហមត្រូវផ្តួលរំលំ ។ សារមន្ទីរទួលស្លែង*

បានបើកទ្វារជូនសាធារណជនទូទៅចូលទស្សនាអស់ប្រហែលមួយឆ្នាំហើយ វាគឺជាកន្លែងទេសចរណ៍ដ៏សំខាន់សម្រាប់ភ្ញៀវទេសចរមកទស្សនា ។ តាមយើងដឹង នៅសម័យមុនបដិវត្តន៍ សារមន្ទីរនេះជាទីតាំងវិទ្យាល័យមួយ ។ ក្រោមរបបខ្មែរក្រហម សាលារៀនដែលត្រូវគេបោះបង់ចោលនេះក៏ត្រូវប្រែក្លាយទៅជាមន្ទីរសន្តិសុខសម្ងាត់របស់ប៉ូលិស ឬហៅម្យ៉ាងទៀតថាសន្តិបាល ។ អគ្គភាពសម្ងាត់នេះដែលត្រូវបានស្គាល់ថា «មន្ទីរស-២១» គឺជាកន្លែងសួរចម្លើយ ។ មន្ទីរនេះមាន «ខ្មាំង» ប្រហែលជាង៨ប់បួនពាន់នាក់ត្រូវបានយកមកសួរចម្លើយ ធ្វើទារុណកម្ម និងបង្ខំឲ្យឆ្លើយសារភាពថាបានប្រឆាំងនឹងបដិវត្តន៍ ។ ជនរងគ្រោះភាគច្រើនត្រូវស្លាប់ទាំងអស់ លើកលែងតែមួយចំនួនតូចប៉ុណ្ណោះដែលមានវាសនានៅរស់រានមានជីវិត ។ ក្រៅពីអ្នកធ្វើការនៅក្នុងគុកនេះនិងថ្នាក់ដឹកនាំធំៗដែលលាក់មុខ គ្មានអ្នកណាម្នាក់ដឹងថាមានមន្ទីរស-២១ឡើយ ។

អ្នកថតរូបជនជាតិវៀតណាមពីរនាក់បានប្រទះឃើញទីតាំងនេះដោយចៃដន្យ នៅខែមករា ឆ្នាំ១៩៧៩ ពោលគឺក្រោយពីកងទ័ពវៀតណាមបានចូលមកប្រទេសកម្ពុជា ។ អ្នកថតរូបទាំងពីរនាក់ក៏បានប្រទះឃើញសាកសពទើបតែស្លាប់ថ្មីៗចំនួន «ប្រហែលហាសិបនាក់» ឧបករណ៍ធ្វើទារុណកម្ម និងបណ្ណសារដ៏ច្រើនសន្ធឹកសន្ធាប់ ។ អ្នកទាំងពីរយល់ច្បាស់ថា ក្រោមការគ្រប់គ្រងរបស់របបកម្ពុជាប្រជាធិបតេយ្យ មន្ទីរស-២១ នេះពិតជាស្ថាប័នដ៏សំខាន់និងគួរឲ្យព្រឺខ្លាច ។ ប៉ុន្មានថ្ងៃក្រោយមក ទីតាំងនេះក៏ត្រូវបោសសម្អាត ហើយក៏បើកទ្វារជូនភ្ញៀវទេសចរដែលមានក្តីអាណិតអាសូរចូលមកទស្សនា ។ ពីរបីខែក្រោយមកទៀត ក្រោមការដឹកនាំរបស់វៀតណាម ទីតាំងនេះក៏បានក្លាយទៅជាសារមន្ទីរតែម្តង ។

នៅក្នុងដំណើរកម្សាន្តនេះ មុនដំបូង មគ្គុទ្ទេសក៍បាននាំយើងទៅមើលបន្ទប់តូចៗនៅជាន់ទីមួយជាប់នឹងដី ។ យើងឃើញគ្រែដែក ខ្នោះ និងរូបថតជាច្រើនរបស់អ្នកទោសដែលបាត់បង់ជីវិតទៅហើយ ។ រូបថតទាំងនេះ គឺថតដោយជនជាតិវៀតណាមនៅពេលចូលមកមន្ទីរនេះក្នុងឆ្នាំ១៩៧៩ ។ នៅបន្ទប់ផ្សេងៗទៀតនៃជាន់ផ្ទាល់ដីដដែលនេះ ឃើញមានការតាំងឧបករណ៍សួរចម្លើយ ព្រមទាំងផ្ទាំងគំនូរដែលគូរដោយអ្នកដែលមានវាសនារួចផុតពីសេចក្តីស្លាប់នៅក្នុងគុកនេះ ។ ផាំងគំនូររូបនេះបានរៀបរាប់ពីការសួរចម្លើយ ការធ្វើទារុណកម្ម និងការសម្លាប់អ្នកទោស ។ រូបថតពាក់កណ្តាលខ្លួនពង្រីកធំៗរាប់រយសន្លឹក ត្រូវបានបិទនៅតាមជញ្ជាំង ។

នៅជាន់ទីពីរ យើងឃើញបន្ទប់តូចៗសម្រាប់ដាក់អ្នកទោសដែលត្រូវសួរចម្លើយ និងបន្ទប់ធំសម្រាប់ក្រុមអ្នកទោសដែលមិនសូវសំខាន់ ។ នៅក្នុងបន្ទប់តូចៗជាប់ៗគ្នា យើងឃើញបណ្ណសាររបស់មន្ទីរស-២១ ដែលនៅសេសសល់ ។ ឯកសារដែលតម្រៀបឡើងកម្ពស់រាប់ហ៊ីតត្រូវបានរៀបចំតម្កល់ទុកនៅក្នុងទូកញ្ចក់ នៅលើតុ និង ដាក់ផ្អែកនៅតាមជញ្ជាំង ។ មើលទៅឯកសារភាគច្រើនគឺជាចម្លើយសារភាពដែលជាអក្សរវាយដោយអង្គុលីលេខនិងសរសេរដោយដៃ ។ សរុបទៅ មានចម្លើយសារភាពជាងបួនពាន់ច្បាប់ ។ មានឯកសារចម្លើយសារភាពខ្លះមានតែមួយឬពីរសន្លឹកប៉ុណ្ណោះ ។ ចម្លើយសារភាពមួយភាគតូចជម្រិតចេញមកពីអ្នកទោសដែលជាកម្មាភិបាលជាន់ខ្ពស់ មានរហូតទៅដល់រាប់រយសន្លឹក ។ ឯកសារផ្សេងទៀតមានដូចជា តារាងចូលនិងសម្លាប់ កំណត់សម្គាល់ផ្សេងៗ ឯកសារសុន្ទរកថារបស់កម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ

ទស្សនាវដ្តី សៀវភៅសរសេរដៃដែលកត់ត្រាវគ្គរៀនសូត្រ និងទិន្នន័យប្រវត្តិរូបរបស់អ្នកទោសធ្វើការនៅក្នុងគុក ។ មុននឹងចាកចេញពីមន្ទីរស-២១ នៅពេលរសៀលដែលមានសភាពងងឹតបន្តិចម្តងៗ និងប្រកបដោយភាពតក់ស្លុត យើងបានចំណាយពេលប្រមាណពីរបីនាទី បើកមើលឯកសារត្រួសៗ និងកត់ចំណុចសំខាន់ៗទាក់ទងនឹង "សកម្មភាពក្បត់" របស់អ្នកទោស ។

ប៉ុន្មានឆ្នាំក្រោយមក ការដើរមើលនៅមន្ទីរស-២១ នៅទីទើៗក្នុងចិត្តខ្ញុំ ដោយសារតែអ្នកនិពន្ធដទៃទៀតដូចជា អេលីហ្សាប៊ែត ប៊ែកឃ័រ, ប៊ែន ឃៀរនិន, និង ស៊ីវ ហេដឌ័រ បានយកឯកសារទាំងនេះសម្រាប់ធ្វើការសិក្សាស្រាវជ្រាវរបស់គេដែរ ។ នៅដើមទសវត្សរ៍ឆ្នាំ១៩៨០ សកម្មជន ដេវីដ ហក បានប្រមែប្រមូលឯកសាររាប់រយពីមន្ទីរស-២១ មកប្រើជាភស្តុតាងសម្រាប់យុទ្ធនាការនាំមេដឹកនាំកម្ពុជាប្រជាធិបតេយ្យមកកាត់ទោស ។ ប៉ុន្តែលោកមិនបានសម្រេចគោលបំណងនេះឡើយ ។ នៅក្នុងទសវត្សរ៍នេះ ឯកសារចម្លងចម្លើយសារភាពជាច្រើនបានសាយភាយក្នុងចំណោមអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ និងអ្នកសារព័ត៌មាន ដែលមានចំណាប់អារម្មណ៍លើបញ្ហាខ្មែរក្រហម ។ ដោយសារទឹកចិត្តសប្បុរសរបស់អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់និងអ្នកសារព័ត៌មាន ខ្ញុំក៏បានប្រើប្រាស់ឯកសារទាំងនេះសម្រាប់ការសិក្សាស្រាវជ្រាវរបស់ខ្ញុំមុនពេលត្រឡប់មកកាន់ប្រទេសកម្ពុជាម្តងទៀតនៅឆ្នាំ១៩៩០ ដែលកាលនោះខ្ញុំចំណាយពេលរាប់ម៉ោងដើម្បីរកមើល ប្រមែប្រមូលឯកសារសម្រាប់ចម្លងទុក ។

នៅឆ្នាំ១៩៩២និង១៩៩៣ បណ្ណសារនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ត្រូវបានថតចម្លងតាមម៉ាស៊ីនមីក្រូហ្វីល ក្រោមការជ្រោមជ្រែងពីសំណាក់សាកលវិទ្យាល័យខរណែល និងក្រសួងវប្បធម៌កម្ពុជា ដែលមានសមត្ថកិច្ចថែរក្សាសារមន្ទីរនេះ ។ ចាត់ឌី លិច្ចវ៉ូដ, ចន ម៉ាស្តុង និង លីយ៉ា ប៊ែតជីជាអ្នកមើលការខុសត្រូវ ប៉ុន្តែក្នុងម៉ោងផ្សេងៗគ្នា ។ នៅក្នុងអំឡុងពេលនេះ ខ្ញុំបានធ្វើដំណើរមកប្រទេសកម្ពុជាចំនួនបួនលើក ហើយឃ្លាំមើលគម្រោងការថតចម្លងមីក្រូហ្វីលជានិច្ច ។ នៅពេលដំណើរការថតចម្លងនេះចប់សព្វគ្រប់ហើយ ខ្ញុំកាន់តែមានក្តីសង្ឃឹមថានឹងបានមើលបណ្ណសារមន្ទីរស-២១ឲ្យបានស៊ីជម្រៅ និងតាមសម្រួល ដោយមិនប្រញាប់ប្រញាល់ ហើយខ្ញុំក៏ចាប់ផ្តើមរៀបចំផែនការច្បាស់លាស់ ។

ខ្ញុំសង្ឃឹមថា ដំបូងខ្ញុំនឹងប្រើប្រាស់បណ្ណសារនេះជាមូលដ្ឋានសម្រាប់និយាយរៀបរាប់ប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។ ក៏ប៉ុន្តែបន្តិចក្រោយមក ខ្ញុំក៏នឹកឃើញថា ការពិតឬការមិនពិតនៃចម្លើយសារភាពជាមួយនឹងភាពគ្មានទោសនិងទោសពៃរ៍ដែលផលិតឯកសារទាំងនេះមក តម្រូវមានការពិនិត្យផ្ទៀងផ្ទាត់ច្បាស់លាស់ណាស់ ។ ចំពោះការនិយាយរៀបរាប់បែបប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យវិញ ខ្ញុំដឹងថា ខ្ញុំត្រូវតែក្តោបឲ្យបានកាន់តែច្រើន ទោះជាគ្មានការបញ្ជាក់ពីការធ្វើឯកសារចម្លើយសារភាពក៏ដោយចុះ ។ ប៉ុន្តែផ្ទុយមកវិញ ការសាកល្បងក្នុងការសិក្សាពីមន្ទីរស-២១ និងបណ្ណសាររបស់មន្ទីរនេះដែលប្រើសម្តីសំដៅដើមផ្ទាល់នៅតែមានលក្ខណៈគួរឲ្យចាប់អារម្មណ៍ ជាពិសេសជាមធ្យោបាយសម្រាប់ចូលទៅក្នុងផ្នត់គំនិតរួមរបស់ខ្មែរក្រហម និងក៏ជាមធ្យោបាយសម្រាប់ក្តាប់ស្ថាប័នដែលគួរឲ្យភ័យខ្លាចនិងមានឯកសារយ៉ាងសន្ធឹកសន្ធាប់នេះ ។ ការផ្លាស់ប្តូរទិសដៅតាមផ្លូវនេះមិនយូរប៉ុន្មានក៏នាំខ្ញុំឲ្យផ្តោតសំខាន់ទៅលើឯកសារ

ទាំងនោះ ដែលអាចជួយខ្ញុំឲ្យឆ្លើយសំណួរទាំងនេះបាន÷ «តើគុកនេះមានដំណើរការយ៉ាងដូចម្ដេចខ្លះ? អ្នកណាជា«ខ្មាំង»ដែលត្រូវបានចាប់មកឃុំឃាំងនៅទីនេះ? តើរចនាសម្ព័ន្ធនៃការសួរចម្លើយមានលក្ខណៈយ៉ាងដូចម្ដេច? តើទារុណកម្មត្រូវប្រើនៅពេលណា? តើមន្ទីរស-២១ ជាស្ថាប័នមានចរិតជា «កុម្មុយនិស្ត» ឬមានចរិតជា«ខ្មែរ»? តើមានគំរូពីបរទេសទេ? ។ល។ និង ។ល។ នៅក្នុងចន្លោះឆ្នាំ១៩៩៣ និង១៩៩៨ ខ្ញុំបានពិនិត្យមើលឯកសារចម្លើយសារភាពរាប់ពាន់ច្បាប់ វិភាគ និង មើលចុះមើលឡើងរាប់រយច្បាប់ថែមទៀត និងអានឯកសាររដ្ឋបាលទាំងអស់នៅក្នុងគុកដែលទើបតែរកឃើញនៅឆ្នាំ១៩៩៦និងឆ្នាំ១៩៩៧ ក្រោយពីគម្រោងការរ៉ាប់រងដោយសាកលវិទ្យាល័យខណែលបានបញ្ចប់ ។ ក្នុងអំឡុងឆ្នាំនោះ ខ្ញុំក៏បានអានឯកសារបន្ថែមទៀតជាភាសាទីពីរដើម្បីធ្វើការប្រៀបធៀបឲ្យកាន់តែស៊ីជម្រៅ ។

ដេវីដ ឆេនដល័រ

ភ្នំពេញ ខែសីហា ឆ្នាំ២០០១

**ខគ្គទីមួយ:**

# ការរកឃើញមន្ទីរស-២១

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដែលកំពុងផ្តល់ពន្លឺថ្ងៃដ៏ត្រចះត្រចង់ និង ជំនោរត្រសៀកៗក្នុងរដូវរងានៃប្រទេសកម្ពុជា កងកម្លាំងវៀតណាមប្រដាប់ដោយអាវុធច្រើនស្មុកស្កុះ អមដោយសម្ព័ន្ធមិត្តកម្ពុជាដែលប្រដាប់ដោយអាវុធបន្តិចបន្តួច បានបោះពួយមកដល់ជាយក្រុងភ្នំពេញបន្ទាប់ពីយុទ្ធនាការវាយសម្រុកផ្តាច់ព្រ័ត្រដែលចាប់ផ្តើមនៅថ្ងៃបុណ្យណូអែល ។ អស់រយៈពេលជាងមួយឆ្នាំ មុនព្រឹត្តិការណ៍នេះ វៀតណាមបានប្រឡូកក្នុងសង្គ្រាមជាមួយរបបកម្ពុជាប្រជាធិបតេយ្យ ដែលដើរតាមលទ្ធិម៉ៅដែលបណ្តាប្រទេសលោកខាងលិចហៅថាខ្មែរក្រហម ។ កម្លាំងទ័ពលុកលុយរបស់វៀតណាមជាងមួយសែននាក់រួមទាំងអង្គភាពរថពាសដែក បានសន្ធាប់និងវាយគាំទ្រដោយការទម្លាក់គ្រាប់បែក ជាប្រចាំពីលើអាកាស ។[1]

ការទទួលបានជោគជ័យដ៏ឆាប់រហ័ស ធ្វើឲ្យមេបញ្ជាការកងទ័ពវៀតណាមភ្ញាក់ផ្អើលមិននឹកស្មានដល់ ។ មិនដល់ពីរសប្តាហ៍ក្រោយការប្រយុទ្ធនេះ ប្រទេសកម្ពុជាប្រេះបែកដូចជាពងមាន់ ។ មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ យុទ្ធជនភាគច្រើនរបស់របបនេះ និងប្រជាជនដែលរត់តាមរបបនេះរាប់សែននាក់បានរត់ភៀសខ្លួនឬក៏ត្រូវគៀរចេញពីទីក្រុង ។ ទ័ពលុកលុយបានទទួលការស្វាគមន៍ពីសំណាក់ប្រជាជនស្ទើរតែគ្រប់រូបដែលពុំបានរត់ទៅតាមពួកខ្មែរក្រហម ។ ប្រជាជនទាំងនេះគឺជាប្រជាជនដែលបាក់ស្បាតដោយភាពភ័យរន្ធត់ និងអស់កម្លាំងដោយការគ្មានអាហារបរិភោគគ្រប់គ្រាន់ ការធ្វើការបាក់កម្លាំងនិងដែលរួចផុតពីការសម្លាប់រង្គាលអស់រយៈពេលជិតបួនឆ្នាំ ។ ការស្វាគមន៍ស្រដៀងគ្នានេះ ដែលក្រោយមកត្រូវតបស្នងដោយសោកនាដកម្មវិញនោះគឺបានសម្តែងទទួលពួកខ្មែរក្រហម នៅពេលដែលពួកនេះ ចូលកាន់កាប់ក្រុងភ្នំពេញកាលពីខែមេសា ឆ្នាំ១៩៧៥ ដោយបានបញ្ជាឲ្យប្រជាជនទីក្រុងភ្នំពេញចេញទៅទីជនបទ ហើយប្រែក្លាយឲ្យទៅជាកម្មករធ្វើកសិកម្មទាំងអស់ ។ ក្នុងករណីស្វាគមន៍ទាំងពីរលើកនេះ ប្រជាជនសុទ្ធសឹងតែកំពុងចង់បានសន្តិភាពយ៉ាងខ្លាំង ។[2]

នៅល្ងាចថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងកម្លាំងទ័ពវៀតណាមបានកាន់កាប់ទីក្រុងភ្នំពេញ ។ ក្រៅពីអ្នកទោសសង្គ្រាមប្រមាណពីពីរទៅបីរយនាក់និងប្រជាជនដទៃទៀត រួមមានអ្នកធ្វើការមួយចំនួននៅមន្ទីរស-២១ដែលកំពុងលាក់ខ្លួនរង់ចាំគេចខ្លួននោះ ទីក្រុងភ្នំពេញជាទីក្រុងគ្មានមនុស្សរស់នៅដ៏ស្ងាត់ជ្រងំ ។[3]

បន្ទាប់ពីខ្មែរក្រហមជម្លៀសមនុស្សអស់ពីទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៥ ភ្នំពេញនៅតែជារាជធានីនៃប្រទេសកម្ពុជា ក៏ប៉ុន្តែភ្នំពេញពុំដែលទទួលបានឋានៈជាមជ្ឈមណ្ឌលទីក្រុងមួយនោះទេ ។ បុគ្គលិកការិយាល័យ កងទ័ព និងកម្មកររោងចក្រដែលតាំងនៅក្នុងទីក្រុងភ្នំពេញ ប្រហែលជាមិនដែលមានចំនួនលើសពីប្រាំម៉ឺននាក់ឡើយ ។ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ប្រទេសកម្ពុជាពុំមានហាងទំនិញ ផ្សារ សាលារៀន វត្តអារាម ឬបរិក្ខារសាធារណៈឡើយ លើកលែងតែឃ្លាំងមួយនៅក្នុងរាជធានីសម្រាប់បម្រើអ្នកការទូតប៉ុណ្ណោះ ។ ក្នុងទីក្រុងភ្នំពេញ រោងចក្រ បណ្ណាគារ បន្ទាយកងទ័ព និងការិយាល័យរដ្ឋបាល

ត្រូវបានហ៊ុមព័ទ្ធដោយរបងលួសបន្លាចាក់ស្រេះ ។ ផ្លាកសញ្ញាតាមផ្លូវត្រូវបានលាបថ្នាំពីលើ ហើយរនាំងលួសបន្លាត្រូវបានដាក់រាំងខ្ទប់ផ្លូវជាច្រើនពុំអនុញ្ញាតឲ្យធ្វើចរាចរឡើយ ។ នៅលើដីទំនេរ ពួកខ្មែរក្រហមដាំសុទ្ធតែដើមចេក ។ យានយន្តដែលបោះបង់ចោលនៅឆ្នាំ១៩៧៥ ឡើងច្រែះចាប់គរលើគ្នា រួមទាំងម៉ាស៊ីនត្រជាក់ ម៉ាស៊ីនបោកខោអាវ ទូរទស្សន៍ និងម៉ាស៊ីនអង្គុលីលេខ ។ ក្រដាសបោះចោលរាយប៉ាត់រប៉ាយ រួមទាំងក្រដាសប្រាក់មុនបដិវត្តន៍ ដែលពុំមានតម្លៃអ្វីទាល់តែសោះក្នុងរបបខ្មែរក្រហម ។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ពុំមានឃើញប្រជាជនបុស្សតុពាហនៈអ្វីឡើយ ។ ដូចគ្នានឹងថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ដែរ នៅឆ្នាំ១៩៧៥ រដ្ឋាភិបាលមជ្ឈិមពីមុនបានបាត់អស់រលីង ។ ជាថ្មីម្តងទៀតប្រជាជនកម្ពុជាបានចាប់ផ្តើមពីឆ្នាំសូន្យទៅ ។[៤]

ឥទ្ធិពលនៃមហន្តរាយក្រោមរបបខ្មែរក្រហមមកលើប្រជាជនកម្ពុជាដែលឃ្លាតឆ្ងាយពីប្រទេស ហើយដែលត្រឡប់មកវិញមានទំហំធំធេងហួសពីការស្មានទៅទៀត ។ ជាឧទាហរណ៍ លោក ជ័យ សោភ័ណ ដែលជាជនកុម្មុយនិស្តកម្ពុជា អាយុសែសិបប្រាំពីរឆ្នាំ ធ្លាប់បានប្រយុទ្ធក្នុងសង្គ្រាមតស៊ូប្រឆាំងនឹងអាណានិគមនិយមបារាំងក្នុងអំឡុងទសវត្សរ៍ឆ្នាំ៥០ ។ សោភ័ណ បានរស់នៅក្នុងប្រទេសវៀតណាមចាប់តាំងពីឆ្នាំ ១៩៥៥ ហើយបានទទួលការបណ្តុះបណ្តាលជាអ្នកកាសែតមួយរូប ។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ សោភ័ណ រីករាយឥតឧបមា ដែលបានវិលត្រឡប់មកស្រុកកំណើតរបស់គាត់វិញ ជាមួយកងទ័ពវៀតណាម ។ ក៏ប៉ុន្តែ គាត់មានការតក់ស្លុតស្ទើរតាំងបេះដូងដោយសារអ្វីដែលគាត់បានប្រទះឃើញដែលប៉ុន្មានឆ្នាំក្រោយមក សោភ័ណ បានរំឭកឡើងវិញថាគាត់«ឈរស្រក់ទឹកភ្នែកពេញមួយរសៀល» ។[៥]

ប៉ុន្មានថ្ងៃបន្ទាប់មក កងទ័ពវៀតណាមបានបោះពួយឆ្លងកាត់ទីក្រុងភ្នំពេញ ។ ថ្ងៃទី៨ ខែមករា នៅផ្នែកខាងត្បូងទួលស្វាយព្រៃ អ្នកថតរូបផ្នែកកាសែតជាជនជាតិវៀតណាមពីររូបដែលបានរួមដំណើរក្នុងការលុកលុយនេះ បាននាំមុខសំដៅទៅបរិវេណពិសេសមួយដែលនៅធុំក្លិនដ៏អសោចពីសាកសពកំពុងហើមរលេះរលួយនៅឡើយ ។[៦] ទីកន្លែងដ៏ស្ងាត់ជ្រងំនិងពោរពេញដោយក្លិនស្អុយនេះ ហ៊ុមព័ទ្ធដោយរបងស័ង្កសីបន្តុបពីលើដោយខ្សែលួសបន្លាព័ទ្ធជារាងស្ទើរយ៉ាងចាក់ស្រេះ ។ នៅនឹងរបងទ្វារចូលមានព្យួរបដាពណ៌ក្រហមមួយដែលសរសេរដោយអក្សរពណ៌លឿងជាពាក្យស្លោកភាសាខ្មែរថា «ពង្រឹងស្មារតីបដិវត្តន៍ត្រូវការពារខ្ជួនរបស់យើងប្រឆាំងនឹងយុទ្ធសាស្ត្រនិងល្បិចកលរបស់សត្រូវដើម្បីការពារប្រទេស ប្រជាជន និងបក្ស» ។ កន្លែងនេះពុំមានអត្តសញ្ញាណអ្វីផ្សេងក្រៅពីនេះឡើយ ។[៧]

នៅពេលជ្រៀតចូលទៅក្នុងបរិវេណនេះ អ្នកថតរូបជនជាតិវៀតណាមទាំងពីររូបបានចាប់ភ្លឹកដឹងថាទីធ្លានេះជាបរិវេណរបស់អតីតវិទ្យាល័យដ៏ធំទូលាយ និងចាស់ទ្រុឌទ្រោមមួយដែលមានទំហំប្រវែងបួនរយម៉ែត្រពីខាងកើតទៅខាងលិច និងប្រាំមួយរយម៉ែត្រពីខាងជើងទៅខាងត្បូង ។ បរិវេណគុកទួលស្លែងរួមមានអគារថ្មចំនួនបួនដែលដុសលាងយ៉ាងស្អាត អគារនីមួយៗមានកម្ពស់បីជាន់ដោយមានផ្លូវដើរពីម្ខាងទៅម្ខាងទៀត ។ អគារទីប្រាំដែលជាអគារសង់ពីឈើមានតែមួយជាន់នោះមានមុខបែរទៅទិសខាងលិច ដោយពុះចែកបរិវេណនេះទៅជាទីធ្លាវាលស្មៅពីរដែលមានសភាពដូចគ្នាបេះបិទ ។ នៅផ្នែកខាងក្រោយនៃទីធ្លាមាន

អគារមួយខ្ពស់ជាងគេដែលបែរមុខទៅទិសខាងកើតឆ្ពោះទៅផ្លូវចូលធំ ។ អគារស្រដៀងគ្នានេះ ដែលមានទីតាំងនៅខាងចុងបំផុតជាអគារកំណត់ពីព្រំដែនខាងជើងនិងខាងត្បូងនៃបរិវេណនេះ ។[៨] ការកំណត់នៃបរិវេណនេះ ពុំមានភាពច្បាស់លាស់ទេសម្រាប់អ្នកថតរូបកាសែតវៀតណាមទាំងពីររូបនេះ នាពេលនោះទោះបីជាអគារតែមួយជាន់ដែលមានក្រដាសនិងសម្ភារការិយាល័យនៅភាត់ភាយ ធ្វើឲ្យដឹងថា ពិតជាត្រូវបានប្រើប្រាស់សម្រាប់ការងាររដ្ឋបាលក៏ដោយ ។

នៅតាមបន្ទប់ជាន់ខាងក្រោមនៃអគារដែលនៅចុងខាងត្បូងបំផុត អ្នកថតរូបជនជាតិវៀតណាមបានប្រទះឃើញសាកសពមនុស្សប្រុសមួយចំនួនដែលទើបនឹងត្រូវបានសម្លាប់ថ្មីៗនេះ ។ សាកសពមួយចំនួនមានដាក់ច្រវាក់ទៅនឹងគ្រែដែក ។ សាកសពទាំងនោះស្លាប់ដោយអារ-ក ។ ឈាមដែលនៅដក់លើកម្រាលឥដ្ឋនៅសើមនៅឡើយនាពេលនោះ ។[៩]

សរុបទាំងអស់សាកសពចំនួនដប់បួនត្រូវបានរកឃើញនៅក្នុងបរិវេណនោះ ដែលបញ្ជាក់ថា ទើបតែត្រូវសម្លាប់តែពីរឬបីថ្ងៃមុននេះប៉ុណ្ណោះ ។

នៅបន្ទប់រៀនធំៗនាជាន់ខាងលើនៃអគារខាងលិច ទ័ពវៀតណាមដែលដើរល្បាតបានប្រទះឃើញខ្នោះជើង ខ្នោះដៃ រំពាត់ និងខ្សែច្រវាក់ជាច្រើនគំនរ ។ បន្ទប់ដទៃៗទៀតនៅជាន់ខាងលើត្រូវបានបែងចែកដោយរៀបជញ្ជាំងខណ្ឌធ្វើអំពីឥដ្ឋប្រហោងរនេងរនូង ទៅជាបន្ទប់តូចៗដែលអ្នកទោសត្រូវបានដាក់ខ្នោះជើងភ្ជាប់ទៅនឹងបន្ទប់នេះ ដូចដែលប្រវត្តិវិទូ វីល្លៀម សក្រោះ បានសរសេរថា «ខ្នោះដែកដ៏ធំដែលស្ទើរតែមានទំហំស្មើនឹងយុថ្កាកប៉ាល់» ។ គេសង្គ្រាប់មួយចំនួនមានផ្ទុកទៅដោយលាមកមនុស្ស ។[១០] នៅជាន់ទីបីមានបន្ទប់ដែលធំជាងមុនបន្តិច ហើយដែលត្រូវបានសាងសង់ហ្មត់ចត់ជាង ដោយបន្ទប់នីមួយៗមានជញ្ជាំងនិងទ្វារធ្វើអំពីឈើ ។

អ្នកថតរូបជនជាតិវៀតណាមដែលចូលមកក្នុងបរិវេណនេះ បានថតរូបគ្រប់បន្ទប់ទាំងអស់នៅក្នុងគុកនេះ ដោយថតបន្ថែមនូវរូបសាកសពទាំងនោះផង ។ បន្ទាប់មក អ្នកថតរូបជនជាតិវៀតណាមទាំងពីរ «បានរាយការណ៍ទៅអាជ្ញាធរវៀតណាម» អំពីអ្វីដែលគេទាំងពីរបានឃើញ ។ នៅល្ងាចថ្ងៃដដែលសាកសពទាំងអស់ត្រូវបានដុត «ដើម្បីធ្វើអនាម័យ» នៅទីនោះ ។ រូបថតមួយចំនួនដែលថតបាននៅពេលនោះ ឥឡូវនេះបានព្យួរនៅក្នុងបន្ទប់ដែលសាកសពត្រូវបានប្រទះឃើញពីដំបូង ។

ប្រមាណពីរឬបីថ្ងៃបន្ទាប់មក អាជ្ញាធរវៀតណាមនិងជំនួយការជាជនជាតិកម្ពុជាបានរកឃើញនៅតាមបណ្ដាផ្ទះដែលនៅក្បែរនោះ នូវឯកសារជាភាសាខ្មែររាប់ពាន់សន្លឹក រូបថតដែលថតភ្លាមបានភ្លាមរាប់ពាន់សន្លឹក ហ្វីលមិនទាន់ផ្ដិតរាប់ពាន់ សៀវភៅកំណត់ហេតុរបស់កម្មាភិបាលខ្មែរក្រហមរាប់រយ និងឯកសារបោះពុម្ពផ្សាយរួចរបស់របបកម្ពុជាប្រជាធិបតេយ្យទាំងគំនរៗ ។ នៅរោងជាងមួយក្បែរទ្វារចូលគេបានប្រទះឃើញរូបសំណាកពីក្បាលដល់ត្រឹមស្មាធ្វើពីស៊ីម៉ង់ត៍ ដែលមានទំហំធំជាងរូបមនុស្សពិតទៅទៀត គឺជារូបសំណាកមួយកំណាត់ខ្លួនរបស់ ប៉ុល ពត ដែលទំនងជាឆ្លាក់ចម្លងចេញពីរូបថតមកវិញ ។

ទ័ពវៀតណាមបានប្រទះឃើញដោយចៃដន្យនូវអគាររបស់ខ្មែរក្រហមដ៏សាហាវឃោរឃៅនិងមាន

សារសំខាន់នេះ ។ ឯកសារដែលប្រទះឃើញនៅទីកន្លែងនេះ បានបង្ហាញឲ្យដឹងយ៉ាងឆាប់រហ័សដែរថា បរិវេណសាលានេះត្រូវបានចាត់តាំងបង្កើតក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដោយប្រើឈ្មោះកាត់ហៅថា ស-២១ ។ អក្សរ «ស» ទំនងជាជំនួសឲ្យពាក្យ«សាលា» រីឯលេខ «២១» គឺជាលេខកូដសម្រាប់ «សន្តិបាល» ដែលជាពាក្យខ្មែរ បានមកពីការបញ្ចូលគ្នារវាងពាក្យពីរគឺ សន្តិសុខ និងនគរបាល(ប៉ូលិស) ។ «ស-២១» ឬ «សន្តិបាល» គឺជាឈ្មោះសម្រាប់នគរបាលសន្តិសុខរបស់របបកម្ពុជាប្រជាធិបតេយ្យ ឬ ផ្នែកពិសេស ។[១១]

ប្រមាណពីរឬបីសប្តាហ៍ក្រោយមក ប្រវត្តិនៃមជ្ឈមណ្ឌលឧក្រិដ្ឋកម្មនេះត្រូវបានផ្គុំបញ្ចូលគ្នា ។ នៅដើមទសវត្សរ៍ឆ្នាំ១៩៦០ នៅពេលប្រទេសកម្ពុជាស្ថិតនៅក្រោមការដឹកនាំរបស់ព្រះបាទ នរោត្តម សីហនុ ទីនេះគឺជាវិទ្យាល័យមួយ ។ វិទ្យាល័យនេះមានឈ្មោះថា ពញាយ៉ាត ដែលរឿងនិទានបានដំណាលបន្តមកថាជាស្តេចខ្មែរមួយអង្គដែលមានពាក់ព័ន្ធជាមួយនឹងការបង្កើតទីក្រុងភ្នំពេញ ។[១២] បន្ទាប់ពីទ្រង់ សីហនុ ត្រូវបានផ្តួលរំលំពីអំណាចនៅឆ្នាំ១៩៧០ ដែលព្រឹត្តិការណ៍មួយនេះជាផ្កាភ្លើងបញ្ឆេះសង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជា សាលានេះត្រូវបានផ្លាស់ឈ្មោះដោយដាក់ឈ្មោះតាមសង្កាត់មួយ ដែលនៅក្បែរនោះវិញគឺទួលស្វាយព្រៃ ។ សាលាបឋមសិក្សាដែលនៅជាប់គ្នានោះហៅថាទួលស្លែង ។ ឈ្មោះនេះត្រូវបានប្រើប្រាស់ដើម្បីដាក់ឈ្មោះឲ្យទីធ្លាទាំងមូលនៅឆ្នាំ១៩៨០ បន្ទាប់ពីទីនេះក្លាយទៅជាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ប្រហែលដោយសារតែដើមស្លែងមានផ្លែពុលហើយមើលទៅ ។[១៣]

ឈ្មោះស-២១ ចាប់ផ្តើមឃើញនៅលើឯកសារខ្មែរក្រហមកាលពីខែកញ្ញា ឆ្នាំ១៩៧៥ ។ ក្នុងរយៈពេលប្រាំបួនខែបន្ទាប់ពីពេលនោះ សេវាសន្តិសុខនេះមានវត្តមានរាយប៉ាយតាមអគ្គភាពជាច្រើននៅភ្នំពេញ ដូចជានៅតាខ្មៅជាយក្រុងភ្នំពេញ និងតំបន់២៥ខាងជើងទីក្រុងភ្នំពេញរហូតដល់ខែឧសភា ឬ ខែមិថុនា ឆ្នាំ១៩៧៦ ។[១៤] នៅចុងឆ្នាំ១៩៧៥ យោងទៅតាមអតីតអ្នកយាមគុកម្នាក់ឈ្មោះ គក ស្រស់ ដែលផ្តល់បទសម្ភាសន៍ក្នុងឆ្នាំ១៩៩៧ បានឲ្យដឹងថា សន្តិបាលត្រូវបានដាក់បញ្ចូលឲ្យស្ថិតនៅក្រោមបញ្ជារបស់ កាំង ហ្កិចអ៊ាវ ហៅ ឌុច អតីតគ្រូបង្រៀនម្នាក់ដែលបានទទួលបន្ទុកកិច្ចការសន្តិសុខក្នុងអំឡុងសង្គ្រាមនៅក្នុងអ្វីដែលពួកខ្មែរក្រហមហៅថាភូមិភាគពិសេសស្ថិតនៅខាងជើងទីក្រុងភ្នំពេញ ។ ឌុច បានក្លាយជានាយកមន្ទីរ ស-២១(ទួលស្លែង) ចាប់តាំងពីខែមិថុនា ឆ្នាំ១៩៧៦ ។ ឌុច ជាអ្នកបញ្ជាកិច្ចការមន្ទីរស-២១ រហូតដល់ថ្ងៃដែលកងទ័ពវៀតណាមបានចូលមកដល់ ។[១៥]

ដោយដឹងពីសារសំខាន់ផ្នែកប្រវត្តិសាស្ត្រ និងអំពីតម្លៃផ្នែកឃោសនានៃការរកឃើញរបស់ខ្លួន វៀតណាមបានបិទទ្វារមជ្ឈមណ្ឌលឧក្រិដ្ឋកម្មនេះនិងសម្អាតទីនោះ ហើយដោយមានការជួយជ្រោមជ្រែងពីបុគ្គលិកកម្ពុជា ការពិនិត្យបណ្ណសារដ៏សន្ធឹកសន្ធាប់របស់គុកទួលស្លែងបានចាប់ផ្តើម ។ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៩ អ្នកកាសែតមួយក្រុមមកពីប្រទេសកុម្មុយនិស្តត្រូវបានវៀតណាមបញ្ជូនមកកម្ពុជាដើម្បីយកពត៌មាននិងប្រារព្ធការបង្កើតរដ្ឋាភិបាលកម្ពុជាថ្មីមួយដែលហៅថា សាធារណរដ្ឋប្រជាមានិតកម្ពុជា ។ អ្នកកាសែតទាំងនេះគឺជាអ្នកមកធ្វើទស្សនកិច្ចជាផ្លូវការលើកដំបូងដើម្បីមើលគុកទួលស្លែង ។

លោក ជ័យ សាផុន បានអមដំណើរទស្សនកិច្ចរបស់ក្រុមអ្នកកាសែតទាំងនោះទៅកាន់គុកទួលស្លែង ។ អ្នកកាសែតម្នាក់ក្នុងចំណោមអ្នកកាសែតទាំងនោះដែលជាជនជាតិយូហ្គោស្លាវី ឈ្មោះ មីហ្កែល រីវ៉ូ ក្រោយមកបានសរសេរថា «នៅមានស្នាមឈាមកកនៅលើកម្រាលឥដ្ឋ» ។ ក្លិនដ៏អសោចបានជះកាន់តែខ្លាំងជាងពីមុនទៅទៀត ។ រុយក្បាលខៀវរាប់រយពាន់រោមបន្ទប់ជិត ។ លោក រីវ៉ូ បានបន្ថែមទៀតថា គាត់បានឃើញឯកសារជាច្រើន «ដែលសរសេរជាភាសាសំស្ក្រឹត» និងសៀវភៅក្រហមតូចរបស់ ម៉ៅ សេទុងជាច្រើនក្បាលនៅក្នុងបន្ទប់នៃអ្វីដែលគាត់ហៅថា «ឋាននរក» នោះ ។[១៦]

ក្រោយមក នៅខែកុម្ភៈ ឬមីនា ឆ្នាំ១៩៧៩ (ការចងចាំរបស់គាត់ហាក់ដូចជាពុំសូវច្បាស់) ម៉ៃ ឡាំ វរសេនីយ៍ឯកកងទ័ពវៀតណាមដែលនិយាយភាសាខ្មែរយ៉ាងច្បាស់ ហើយធ្លាប់មានបទពិសោធន៍ឆ្លងកាត់ការសិក្សាផ្នែកច្បាប់ និងសារមន្ទីរ បានមកដល់ទីក្រុងភ្នំពេញ ។ ម៉ៃ ឡាំ ត្រូវបានប្រគល់ជូននូវភារកិច្ចរៀបចំឯកសារនានាក្នុងបណ្ណសារដ្ឋានមួយដែលបានរកឃើញនៅមន្ទីរស-២១ ហើយនិងប្រែក្លាយទីកន្លែងនេះ ទៅជាអ្វីដែលអ្នកស្រាវជ្រាវ ដេវីដ ហក បានហៅថា «សារមន្ទីរនៃសុបិនអាក្រក់របស់កម្ពុជា» ។[១៧] ទិដ្ឋភាពដំបូងនៃការងាររបស់ ម៉ៃ ឡាំ មានសភាពបន្ទាន់ជាងទិដ្ឋភាពទីពីរ ។ កាលណោះ មានក្តីសង្ឃឹមថាឯកសារទាំងឡាយដែលប្រទះឃើញនៅក្នុងគុកទួលស្លែងអាចត្រូវបានយកមកប្រើប្រាស់ជាភ័ស្តុតាងក្នុងការជំនុំជម្រះក្តី ប៉ុល ពត និង អៀង សារី ដែលជារដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ការជំនុំជម្រះក្តីទាំងនេះបានធ្វើឡើងនៅក្នុងទីក្រុងភ្នំពេញ កាលពីខែសីហា ឆ្នាំ១៩៧៩ ។ ទោះបីជាពត៌មានដ៏មានតម្លៃពីមន្ទីរស-២១ ត្រូវបានបញ្ចេញប្រើប្រាស់នៅក្នុងការជំនុំជម្រះក្តីទាំងនោះក៏ដោយ ក៏ឯកសារទាំងនោះពុំបានផ្តល់នូវភ័ស្តុតាងច្បាស់ក្រឡែត ហើយពិតជាមិនអាចទាញយកហេតុផលផ្សេងៗដែលផ្តល់នូវក្តីសង្ឃឹមឲ្យមន្ត្រីវៀតណាមនិងមន្ត្រីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាអាចរកឃើញនោះដែរ ។ មកដល់ពេលនេះពុំមានភ័ស្តុតាងឯកសារដែលភ្ជាប់ ប៉ុល ពត ឬ អៀង សារី ដោយផ្ទាល់ទៅនឹងបទបញ្ជាបោសសម្អាតមនុស្សនៅមន្ទីរស-២១ ត្រូវបានរកឃើញនៅឡើយទេ ទោះបីជាខ្សែសង្វាក់អាជ្ញាធរភ្ជាប់ស-២១ជាមួយនឹងមជ្ឈិមបក្សមានភ័ស្តុតាងបញ្ជាក់យ៉ាងច្បាស់គ្មានមន្ទិលសង្ស័យយ៉ាងណាក៏ដោយ ។

ដោយសារចំណង់ចំណូលចិត្តរបស់គាត់អំពីប្រវត្តិសាស្ត្រ គួបផ្សំនឹងបទពិសោធន៍របស់គាត់ជាមួយនឹងសារមន្ទីរនានា ម៉ៃ ឡាំ បានរៀបចំសារមន្ទីរឧក្រិដ្ឋកម្មសង្គ្រាមរបស់អាមេរិកនៅក្រុងហូជីមិញ និងបង្ហាញពីអំពើឧក្រិដ្ឋដែលបានកើតឡើងនៅមន្ទីរស-២១ ។ ម៉ៃ ឡាំ បានប្រឡូកក្នុងការងាររបស់គាត់ ពោរពេញទៅដោយមោទកភាពនិងភាពសោមនស្សរីករាយ ។ មិនតែប៉ុណ្ណោះ ភាពពិសេសតែមួយគត់របស់ ម៉ៃ ឡាំ គឺជាអ្វីមួយដែលពោរពេញទៅដោយការពេញចិត្តដ៏ខ្លាំងបំផុតចំពោះកម្ពុជានិងប្រជាជនកម្ពុជា ដោយសារបទពិសោធន៍របស់គាត់ធ្លាប់ឆ្លងកាត់ការងារក្នុងប្រទេសកម្ពុជានិងក្នុងសង្គ្រាមឥណ្ឌូចិនលើកទីមួយ បានលើកទឹកចិត្តជំរុញឲ្យគាត់ចាប់អារម្មណ៍យ៉ាងខ្លាំងលើការរៀបចំសារមន្ទីរនេះ ។ គាត់បានប្រាប់អ្នកធ្វើបទសម្ភាសន៍ជាមួយគាត់កាលពីឆ្នាំ១៩៩៤ថា «ដើម្បីយល់ដឹងអំពីឧក្រិដ្ឋកម្មរបស់របប ប៉ុល ពត អៀង សារី

ដំបូងអ្នកគួរតែយល់អំពីប្រទេសកម្ពុជានិងប្រជាជននៃប្រទេសនេះសិន» ។[១៨]

នៅក្នុងការប្រែក្លាយមន្ទីរស-២១ឲ្យទៅជាសារមន្ទីរប្រល័យពូជសាសន៍ ម៉ៃ ឡាំ ចង់រៀបចំអតីតកាលដែលទើបនឹងកើតឡើងថ្មីៗរបស់ប្រទេសកម្ពុជាឲ្យស្របទៅនឹងតម្រូវការនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជានិងអ្នកផ្តល់ដំបូន្មានជាជនជាតិវៀតណាមរបស់របបនេះ ក៏ដូចជាសេចក្តីត្រូវការដើយូរអង្វែងនានារបស់ប្រជាជនកម្ពុជាតាមការប្រមើលមើលរបស់គាត់ ។ ដោយសារតួលេខនៃជនរងគ្រោះ ដែលស្លាប់ក្រោម «របបប្រល័យពូជសាសន៍ ប៉ុល ពត អៀង សារី» គឺជាប្រជាជនកម្ពុជាខ្លួនឯង ពត៌មានដែល ម៉ៃ ឡាំ កំពុងព្យាយាមផ្សព្វផ្សាយ គឺខុសប្លែកគ្នាអំពីពត៌មានដែលគាត់ធ្លាប់បានដឹងនៅក្នុងសារមន្ទីរឧក្រិដ្ឋកម្មសង្គ្រាមរបស់អាមេរិកនៅវៀតណាម ។ ក៏ប៉ុន្តែ ពត៌មានដែលគាត់ចង់ពាំនាំចេញពីសារមន្ទីរទួលស្លែង គឺមានទំហំប្រហាក់ប្រហែលគ្នាដែរ ។ ប្រវត្តិសាស្ត្រដែលគាត់បានផ្តុំបង្កើតឡើងនៅក្នុងការតាំងពិព័រណ៍លើអគារអតីតមន្ទីរស-២១ បានបដិសេធមិនទទួលស្គាល់អត្តសញ្ញាណសង្គមទាំងអស់របស់មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា ហើយបានទាក់ទាញចិត្តនិងអារម្មណ៍ឲ្យអ្នកមើលសារមន្ទីរនេះធ្វើការផ្សារភ្ជាប់រវាងរបបកម្ពុជាប្រជាធិបតេយ្យនិងទួលស្លែង ហើយម្ខាងទៀតធ្វើការផ្សារភ្ជាប់រវាងរបបណាហ្ស៊ីអាឡឺម៉ង់ និងម្ខាងទៀតប្រៀបដូចជាអ្វីដែលលោក សឺជ ធីយ៉ែន ហៅថា «អូស្វីត ដីកំណាចយង់ឃ្នង» ដែលជាជំរំប្រមូលផ្តុំនិងប្រហារជីវិតជនជាតិជ្វីហ្វដ៏ធំ ។ ការប្រៀបធៀបទាំងនេះគឺស័ក្តិសម ពីព្រោះមន្ទីរស-២១ដូចជាជំរំប្រមូលផ្តុំសម្លាប់មនុស្សរបស់ពួកណាហ្ស៊ីដែរ ក៏ប៉ុន្តែការពាក់ព័ន្ធច្បាស់លាស់ច្រើនបន្ថែមទៀតរវាងលទ្ធិណាហ្ស៊ី និង របបកម្ពុជាប្រជាធិបតេយ្យគឺពុំមានភាពជាក់លាក់នោះទេ ទោះបីជាកន្លែងទាំងពីរនេះគួរឲ្យទាក់ទាញអារម្មណ៍ដោយសារភាពប្រហាក់ប្រហែលគ្នាយ៉ាងណាក៏ដោយ ។[១៩]

អ្នករួចជីវិតពីមន្ទីរស-២១ជាជនកម្ពុជាម្នាក់ បានក្លាយជានាយកសារមន្ទីរនៅពេលដែលសារមន្ទីរនេះបានបើកទ្វារនៅឆ្នាំ១៩៨០ គឺលោក អ៊ឹង ប៉ិច ។ អ៊ឹង ប៉ិច បានកាន់តំណែងនេះអស់រយៈពេលជាច្រើនឆ្នាំ ហើយបានធ្វើដំណើរជាមួយ ម៉ៃ ឡាំ ទៅកាន់ប្រទេសបារាំង សហភាពសូវៀត និងអឺរ៉ុបខាងកើត នៅដើមទសវត្សរ៍ឆ្នាំ១៩៨០ ដើម្បីធ្វើទស្សនកិច្ចសារមន្ទីរ និងពិធីតាំងពិព័រណ៍នានាដែលរំឭកពីឧក្រិដ្ឋកម្មរបស់ពួកណាហ្ស៊ី ។ ទោះបីជា ម៉ៃ ឡាំ នៅកម្ពុជារហូតដល់ឆ្នាំ១៩៨៨ ហើយភាគច្រើនធ្វើការនៅទួលស្លែងក៏ដោយ ក៏គាត់លាក់បាំងពីតួនាទីជាទីប្រឹក្សានិងអ្នកជំនាញរបស់គាត់ដែលជាអ្នកមកពីខាងក្រៅដែរ ដើម្បីបង្កើតឲ្យមានការចាប់អារម្មណ៍ថា ការផ្តួចផ្តើមគំនិតក្នុងការរៀបចំសារមន្ទីរនិងរៀបចំប្លង់គឺចេញមកពីស្នាដៃជនរងគ្រោះកម្ពុជាជាជាងចេញមកពីវៀតណាម ។ នេះក៏ជាការចាប់អារម្មណ៍មួយដែលគាត់ព្យាយាមកែតម្រូវនៅក្នុងបទសម្ភាសន៍របស់គាត់នៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ។[២០]

រយៈពេលពីពីរទៅបីខែក្រោយមក ប្រជាជនដែលធ្វើការនៅក្នុងគុកបានកសាងនូវប្រវត្តិសាស្ត្រត្រួសៗអំពីគុកទួលស្លែង ដោយប្រមូលចងក្រងឯកសារបញ្ជីចេញចូល ឯកសារសម្លាប់ របាយការណ៍ធ្វើឡើងដោយអ្នកសួរចម្លើយ និងការចងចាំរបស់អ្នកដែលរួចរស់ជីវិតពីគុកនេះ ។ ចន្លោះខែមេសា ឆ្នាំ១៩៧៥ និងសប្តាហ៍ទីមួយ នៃឆ្នាំ១៩៧៩ អ្នកដែលធ្វើការនៅគុកទួលស្លែងទាំងនោះបានរកឃើញថា

យ៉ាងតិចបំផុតមនុស្សចំនួនដប់បួនពាន់នាក់ រួមទាំងបុរស ស្ត្រី និងកុមារបានត្រូវឃុំឃាំងនៅមន្ទីរស-២១ ។ ដោយសារឯកសារបញ្ជីចេញចូលសម្រាប់រយៈពេលប៉ុន្មានខែ នៅឆ្នាំ១៩៧៨ ពុំមានភាពពេញលេញ ចំនួនអ្នកទោសពិតប្រាកដច្បាស់ជាមានចំនួនច្រើនជាងនេះ ។ ក្នុងចំណោមអ្នកទោសដែលចុះក្នុងឯកសារអ្នកទោសទាំងអស់ លើកលែងតែអ្នកទោសមួយចំនួនតូចដូចជា អ៊ឹង ប៉ិច និងមនុស្សមួយចំនួនទៀតត្រូវបានយកទៅសម្លាប់គ្មានសល់ ។ ការចងចាំរបស់អ្នកដែលរួចពីគុកទួលស្លែងបូកផ្សំនឹងពត៌មានពីអតីតកម្មាភិបាលខ្មែរក្រហមនៅទីនោះ មានតម្លៃមិនអាចកាត់ថ្លៃបានចំពោះការសិក្សានេះ ។[៦១]

មិនតែប៉ុណ្ណោះ ឯកសារពីមន្ទីរស-២១បានបង្ហាញថា អ្នកទោសដែលមានឋានៈតូចទាបភាគច្រើនត្រូវបានដាក់ឃុំឃាំងអស់រយៈពេលពីពីរទៅបីថ្ងៃ រីឯអ្នកទោសដែលសំខាន់ជាងនេះ ព្រមទាំងឥស្សរជនឋានៈទាបជាងនេះបន្តិចដែលត្រូវសង្ស័យអំពីបទល្មើសធ្ងន់ធ្ងរត្រូវបានដាក់ពន្ធនាគាររាប់ខែ ។ អ្នកទោសរាប់ពាន់នាក់ ទោះសំខាន់ឬមិនសំខាន់ក្តីត្រូវឆ្លងកាត់ការសួរចម្លើយ រៀបចំ «ចម្លើយសារភាព» ថាខ្លួនបានប្រព្រឹត្តល្មើសប្រឆាំងនឹងបដិវត្តន៍ ហើយរាយឈ្មោះអ្នកដែលជាប់ពាក់ព័ន្ធ ក្រោមចំណងជើងថា «បណ្តាញក្បត់» ឬ «ខ្សែក្បត់» ដែលជួនកាលមានរាយឈ្មោះរហូតដល់រាប់រយនាក់ ។ អត្ថបទនៃចម្លើយសារភាពមានចំនួនពីមួយទំព័ររហូតដល់រាប់រយទំព័រ ។ ប្រហែលជាមានចម្លើយសារភាព៤.៣០០ដែលត្រូវប្រមូលបានរហូតមកទល់ពេលនេះ រួមទាំងចម្លើយសារភាពរបស់ឥស្សរជនសំខាន់ៗនៃរបបកម្ពុជាប្រជាធិបតេយ្យស្ទើរតែទាំងអស់ដែលត្រូវបានដឹងថាត្រូវធ្វើវិសុទ្ធកម្មដកយកទៅសម្លាប់ចោល ។[៦២]

ចម្លើយសារភាព ការចងចាំរបស់អ្នកដែលនៅរស់ទាំងឡាយ និងឧបករណ៍មានជាប់ស្នាមប្រឡាក់ឈាមមនុស្ស ដែលបានរកឃើញនៅគុកទួលស្លែងបញ្ជាក់ច្បាស់ថា ការធ្វើទារុណកម្មមនុស្សត្រូវបានអនុវត្តយ៉ាងខ្លាំងនៅមន្ទីរស-២១ ។ អ្នកទោសតិចតួចណាស់ក្រោយពីទទួលរងនូវការធ្វើទារុណកម្ម ឬ ការគំរាមកំហែងធ្វើទារុណកម្មបែបនេះ ពុំអាចស៊ូទ្រាំរក្សាការអះអាងថាខ្លួនគ្មានកំហុសបានយូរឡើយ ។ ចាប់តាំងពីពេលដែលអ្នកទោសទាំងនោះចូលមកដល់គុកទួលស្លែងគឺត្រូវបានចាត់ទុកថាជាអ្នកមានទោសរួចស្រេចទៅហើយ និងពាក្យ «អ្នកទោស» ក្នុងភាសាខ្មែរ តាមទំនៀមទម្លាប់តរៀងមកប្រែតាមន័យត្រង់ថា «អ្នកដែលមានទោស» ។ នៅមន្ទីរស-២១ អ្នកទោសប្រុសស្រីត្រូវបានរំពឹងទុកថា នឹងសារភាពអំពីទោសកំហុសជាលាយលក្ខណ៍អក្សរមុនពេលត្រូវយកទៅសម្លាប់ចោល ។ នីតិវិធីព្រៃផ្សៃចម្លែកបែបនេះបានទទួលឥទ្ធិពលមួយចំនួនចេញពីអ្វីដែលគេស្គាល់ថាជាយុត្តិធម៌បដិវត្តន៍ មានឫសគល់នៅក្នុងរបបដឹកនាំផ្តាច់ការ នៅប្រទេសបារាំងក្នុងសតវត្សរ៍ទី១៨ ហើយបានអនុម័តឲ្យប្រើប្រាស់នៅក្នុងការកាត់ក្តីដែលគ្រាន់តែធ្វើយកល្អមើលនាទីក្រុងមូស្គូនៅទសវត្សរ៍ឆ្នាំ១៩៣០ និងចេញពីការកែទម្រង់ដីធ្លីនិងយុទ្ធនាការ«អប់រំកែប្រែ» នៅប្រទេសចិនក្នុងទសវត្សរ៍ឆ្នាំ១៩៤០ និងមួយទសវត្សរ៍ក្រោយមកនៅប្រទេសវៀតណាម ។ ប្រហែលជាដោយសារតែឥទ្ធិពលច្រើនជាន់ថ្នាក់ទាំងនេះហើយ ទើបពុំអាចកំណត់ថា តើមន្ទីរស-២១យកតាមការអនុវត្ត ឬចម្លងតាមប្រទេសណាមួយពិតប្រាកដជាគំរូនោះទេ ។ លើសពីនេះទៅទៀត ភាពធ្ងន់ធ្ងរនៅមន្ទីរស-២១ និងភាពជាក់ស្តែងដែលអ្នកសួរចម្លើយអនុវត្តកិច្ចការនោះបានឆ្លុះបញ្ចាំងឲ្យឃើញពីទំនៀមទម្លាប់

ក្នុងការដាក់ទណ្ឌកម្មមុនសម័យបដិវត្តន៍របស់កម្ពុជា ដែលតាមរយៈទំនៀមទម្លាប់នោះ អ្នកទោសពុំដែលត្រូវបានចាត់ទុកថាគ្មានទោសនោះទេ ហើយទោសពានរាំងប្តូទោសប្រឆាំងនឹងអ្នកដឹកនាំច្បាស់ជាត្រូវផ្តន្ទាទោសដោយឥតមេត្តាឡើយ ។

ទោះបីជាគោលនយោបាយសេដ្ឋកិច្ចសង្គមរបស់របបកម្ពុជាប្រជាធិបតេយ្យ ពុំស៊ីគ្នានឹងក្របខ័ណ្ឌហ្វាស៊ីសណាហ្ស៊ីក៏ដោយ ក៏ទ្រង់ទ្រាយប្រហាក់ប្រហែលគ្នារវាងមន្ទីរស-២១ និងជំរំប្រហារជីវិតរបស់ពួកណាហ្ស៊ី គឺមានសភាពគួរឲ្យភ្ញាក់ផ្អើល ។ ស្នាដៃនិពន្ធនានាដែលពិភាក្សាអំពីមហាឧក្រិដ្ឋកម្មរបស់ពួកណាហ្ស៊ី បានធ្វើឲ្យជ្រួតជ្រាបដ៏ស៊ីជម្រៅក្នុងចិត្តសាស្ត្ររបស់អ្នកធ្វើទារុណកម្ម សមាជិក ឬបុគ្គលិករដ្ឋាភិបាល និងជនរងគ្រោះនៅក្នុងគុក ។ ស្នាដៃនាពេលថ្មីៗបំផុតទាក់ទងទៅនឹងអ្នកធ្វើទារុណកម្មនៅក្នុង «សង្គ្រាមកខ្វក់» នៅប្រទេសអាហ្សង់ទីនក្នុងទសវត្សរ៍ឆ្នាំ១៩៧០ និងដើមទសវត្សរ៍ឆ្នាំ១៩៨០ ក៏បានធ្វើឲ្យយល់ជ្រួតជ្រាបអំពីភាពស្រដៀងគ្នានេះដែរ ។ ឯកសារដែលខ្ញុំយល់ថាមានប្រយោជន៍សម្រាប់ជាគោលដៅក្នុងការប្រៀបធៀបបែបនេះនៅមានជាច្រើនហើយអាចងាយស្រួលចុះបញ្ជីយ៉ាងវែងជាមួយឯកសារទាំងអស់នោះទៀតផង ។[២៣]

ភាពខុសប្លែកគ្នាដ៏គួរឲ្យភ្ញាក់ផ្អើលបំផុតរវាងករណីប្រទេសកម្ពុជានិងអាឡឺម៉ង់ ស្ថិតនៅត្រង់ទំហំនៃការរៀបចំឯកសារដែលពួកខ្មែរក្រហមបានបង្កើតឡើងនៅមន្ទីរស-២១ ។ អ្នកទោសទាំងអស់នៅក្រោមរបបណាហ្ស៊ីនិងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានកាត់ផ្តាច់ស្រឡះពីសិទ្ធិទទួលទម្រង់ណាមួយនៃការការពារដោយច្បាប់ ក៏ប៉ុន្តែអ្វីដែលខុសគ្នាស្ថិតនៅត្រង់ថា អ្នកទោសទាំងឡាយនៅក្នុងជំរំសម្លាប់រង្គាលរបស់ពួកណាហ្ស៊ី គឺត្រូវបានគេបង្ខំជម្រិតយកកម្លាំងពលកម្មរង់ចាំតែពេលប្រហារជីវិតមកដល់ប៉ុណ្ណោះ ។ រីឯមន្ទីរស-២១វិញ អ្នកទោសត្រូវបានប្រព្រឹត្តមកលើហាក់បីដូចជាស្ថិតក្នុងក្របខ័ណ្ឌប្រព័ន្ធច្បាប់មួយ ហើយចម្លើយសារភាពរបស់ពួកអ្នកទោសទាំងនោះគឺប្រៀបដូចជាផ្តល់ភស្តុតាងសម្រាប់តុលាការច្បាប់មួយដែរ ។ នៅត្រង់ទិដ្ឋភាពនេះ អ្នកទោសនៅមន្ទីរស-២១មានសណ្ឋានដូចគ្នានឹងអ្នកប្រឆាំងបដិវត្តន៍ទាំងហ្វូងៗ ដែលត្រូវបានចោទប្រកាន់ដោយពុំមានភស្តុតាងហើយដែលត្រូវយកទៅ «កាត់ទោស» នៅក្នុងអតីតសហភាពសូវៀតនៅទសវត្សរ៍ឆ្នាំ១៩៣០ដែរ ។ ក្រោមរបបណាហ្ស៊ីអាឡឺម៉ង់ អ្នកទោសនយោបាយត្រូវបានយកទៅទុកក្នុងជំរំដាច់ដោយឡែកពីអ្នកទោសដែលជាមុខសញ្ញាត្រូវសម្លាប់ ហើយមិនសូវទទួលទុក្ខទោសខ្លាំងប៉ុន្មានទេ ។ នៅឯមន្ទីរស-២១ អ្នកទោសទាំងអស់ត្រូវបានចោទអំពីបទល្មើសនយោបាយ ហើយអ្នកទាំងនោះ ត្រូវបានយកទៅសម្លាប់ចោលដូចគ្នា ។

ដូចគ្នានឹងជំរំប្រហារជីវិតរបស់ពួកណាហ្ស៊ីនិងមណ្ឌលធ្វើទារុណកម្មនៅអាហ្សង់ទីនដែរ មន្ទីរស-២១ គឺជាគុកដ៏សម្ងាត់មួយ ហើយភាពចាំបាច់ឲ្យមានការលាក់ការណ៍សម្ងាត់នៅមន្ទីរស-២១បានជះឥទ្ធិពលជាច្រើនទៅលើអ្វីដែលបានកើតឡើងនៅក្នុងបរិវេណគុកនោះ ។ វត្តមានរបស់គុកនេះត្រូវបានដឹងតែក្នុងចំណោមអ្នកដែលធ្លាប់បានធ្វើការ ឬត្រូវបានដាក់ពន្ធនាគារ ហើយនិងកម្មាភិបាលជាន់ខ្ពស់មួយក្តាប់តូចហៅថា មជ្ឈិមបក្ស ដែលបានត្រួតពិនិត្យឯកសារនានា យោធា និងអង្គភាពដទៃទៀតដែលត្រូវធ្វើវិសុទ្ធកម្មប៉ុណ្ណោះ ។ អ្នកសួរចម្លើយ ស្មៀនកត់ត្រា អ្នកថតរូប អ្នកយាមនិងចុងភៅនៅក្នុងគុកនេះ ត្រូវបានហាមមិនឲ្យ

រស់នៅឡុកឡំពាក់ព័ន្ធជាមួយអ្នកធ្វើការនៅកន្លែងផ្សេងទេ ហើយបរិវេណនេះមានឈ្មោះល្បីថា ជាកន្លែងដ៏គួរឲ្យភ័យខ្លាចយ៉ាងឆាប់រហ័ស ។ អ្នកធ្វើការនៅរោងចក្រម្នាក់ ដែលកាលណោះធ្វើការនៅក្នុងបរិវេណក្បែរគុកនេះ បានផ្ដល់បទសម្ភាសន៍មួយក្នុងឆ្នាំ១៩៨៩ បានចាត់ទុកមន្ទីរស-២១ថាជា«កន្លែងដែលចូលទៅហើយគ្មានថ្ងៃចេញមកវិញទេ» ។[២៤] អ្នកធ្វើការនៅរោងចក្រក្បែរគុកនេះពុំច្បាស់ថា មានអ្វីកើតឡើងនៅក្នុងនោះឡើយ ក៏ប៉ុន្តែ កាលណោះអ្នកទាំងនោះត្រៀមខ្លួនគិតថា ជាកន្លែងដ៏សាហាវបំផុតរួចទៅហើយ ។ មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាពុំដែលនិយាយអំពីមន្ទីរស-២១ដោយប្រើ ឈ្មោះនេះឡើយ ។ ឆ្នាំ១៩៩៧ នៅពេលដែលអ្នកកាសែតឈ្មោះ ណេត ថាយ័រ សួរ ប៉ុល ពត, ប៉ុល ពត បានបដិសេធថាខ្លួនពុំបានដឹងអំពី«ទួលស្លែង» ទេ ដោយចង់បង្ហាញថា សារមន្ទីរនិងបណ្ណសារដ្ឋាននៅទួលស្លែង គឺជាការប្រឌិតរបស់វៀតណាម ។ ប៉ុល ពត និយាយថា÷

> «ខ្ញុំនៅខាងលើបំផុត ខ្ញុំធ្វើការសម្រេចចិត្តធំៗ» ។ ខ្ញុំចង់ប្រាប់លោកថា ទួលស្លែងគឺជាកន្លែងតាំងពិព័រណ៍របស់វៀតណាម ។ អ្នកកាសែតម្នាក់ធ្លាប់បានសរសេរដូច្នេះ ។ មានការនិយាយគ្រប់គ្នាអំពីទួលស្លែង ទួលស្លែង ទួលស្លែង...នៅពេលដែលខ្ញុំបានឮអំពីទួលស្លែងគឺឮតាមវិទ្យុផ្សាយសំឡេងរបស់សហរដ្ឋអាមេរិក ។ ខ្ញុំបានស្ដាប់ឮចំនួនពីរដង ។[២៥]

ការបើកឲ្យភ្ញៀវចូលទស្សនាមន្ទីរស-២១ ត្រូវបានរៀបចំឡើងមុនដំបូងបង្អស់នៅខែមីនា ឆ្នាំ១៩៧៩ ប៉ុន្តែពេញមួយឆ្នាំបន្ទាប់ពីសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងលេចចេញជារូបរាងឡើង មានតែជនបរទេសប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតឲ្យចូលទស្សនា ពីព្រោះមានឯកសារមួយរបស់ក្រសួងវប្បធម៌ ឃោសនាការនិងពត៌មាននៃសាធារណរដ្ឋប្រជាមានិតកម្ពុជាបានអះអាងថា ទីកន្លែងនេះបើកដំបូងក្នុងបំណង«បង្ហាញភ្ញៀវអន្តរជាតិអំពីឧក្រិដ្ឋកម្មដ៏យង់ឃ្នងរបស់ពួកក្បត់ទីងប្រជាជនខ្មែរ» ។ នៅពេលទន្ទឹមគ្នានេះដែរ លោក ម៉ៃ ឡាំ ព្រមទាំងសហការីរបស់គាត់បានកែប្រែបន្តិចម្ដងៗ ធ្វើឲ្យកន្លែងនេះក្លាយទៅជាសារមន្ទីរមួយ ។ នៅក្នុងខែកក្កដា ឆ្នាំ១៩៨០ បម្រាមមិនឲ្យប្រជាជនកម្ពុជាចូលមើលសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងត្រូវបានដកចេញ ហើយពេលនោះ មានប្រជាជនរាប់ម៉ឺននាក់បានចូលទៅទស្សនាសារមន្ទីរនេះ ។ ភាគច្រើននៃអ្នកទាំងនោះគឺព្យាយាមស្វែងរកបងប្អូនសាច់ញាតិដែលបាត់ខ្លួន ។ ប្រជាជនបានចូលមកទស្សនាបន្តកន្ទុយគ្នានិងផ្ទៀងផ្ទាត់រូបថតពាក់កណ្ដាលខ្លួនដែលដាក់តាំងនៅជាន់ក្រោម ។ ដូចដែលប្រវត្តិវិទូ ជូឌី លិចវូដ បានសរសេរថា «អ្នកដែលមកទស្សនាជាច្រើនចូលមកគឺដើម្បីស្វែងយល់អំពីអត្ថន័យនិងការពន្យល់អំពីថា តើអ្វីខ្លះបានកើតឡើងក្នុងអតីតកាលកន្លងទៅ ។ ការដើរទស្សនានៅទីនោះមិនមែនជាការងាយស្រួលឡើយ ។ អ្នកមកទស្សនាកាលពីឆ្នាំដំបូងនិយាយថា នៅពេលដើរមើលក្នុងសារមន្ទីរមានផ្សុំក្លិនអសោចខ្លាំងណាស់» ។[២៦] ពេលដែលសារមន្ទីរបើកដំបូងមានប្រជាជនកម្ពុជាមកទស្សនាប្រហែលជាសាមសិបពីរពាន់នាក់នៅក្នុងសប្ដាហ៍ទីមួយ ។ នៅខែតុលា ឆ្នាំ១៩៨០ មានប្រជាជនកម្ពុជាប្រហែលជាង

បីរយពាន់នាក់ និងជនបរទេសដប់មួយពាន់នាក់ បានចូលទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។[២៧]

ជានិច្ចកាល ម៉ៃ ឡាំ មានបំណងប្រាថ្នាខ្ពស់ណាស់ចំពោះមន្ទីរស-២១ ។ គាត់ចង់បង្កើតជាសារមន្ទីរមួយនិងរៀបចំជាបណ្ណសារដ្ឋានមួយដែលជាប្រយោជន៍សម្រាប់ប្រជាជនកម្ពុជា និងកុំឲ្យប្រជាជនទាំងអស់ភ្លេចនូវរឿងរ៉ាវទាំងអស់ដែលបានកើតឡើងក្នុងរបប ប៉ុល ពត ។ ព្រឹត្តិការណ៍មួយក្នុងចំណោមព្រឹត្តិការណ៍ដែលមានលក្ខណៈជាឆាកល្ខោនជាងគេរបស់គាត់គឺរូបផែនទីប្រទេសកម្ពុជាដ៏ធំមួយដែលមានតម្រៀបពេញដោយឆ្អឹងលលាដ៍ក្បាលខ្មោចនិងទន្លេដែលត្រូវបានគូរក្នុងលក្ខណៈជាឈាមពណ៌ក្រហម ។ នៅដើមទសវត្សរ៍ឆ្នាំ ១៩៨០ ក្រោយពេលវាលពិឃាតជើងឯកនៃមន្ទីរស-២១ដែលស្ថិតនៅខាងលិចរាជធានីភ្នំពេញ ត្រូវបានជីកគាស់ក្រោមការដឹកនាំរបស់គាត់ ម៉ៃ ឡាំ បានត្រួតពិនិត្យដោយផ្ទាល់នូវការរកកាយយកសាកសពជនរងគ្រោះរាប់ពាន់ រួចហើយគាត់ក៏បញ្ជាឲ្យសង់បូជនីយដ្ឋានឬ (ស្តូប) មួយដែលហ៊ុមព័ទ្ធដោយកញ្ចក់សម្រាប់តម្កល់អដ្ឋិធាតុទាំងអស់ដែលគាស់រួចហើយ ។ ស្តូបនោះពោរពេញទៅដោយលលាដ៍ក្បាលនៃជនរងគ្រោះ ។ នៅពេលនិយាយទៅកាន់អ្នកស្រី សារ៉ាខូម ក្នុងឆ្នាំ១៩៩៥ ម៉ៃ ឡាំ បាននិយាយថា÷

> ខ្ញុំរៀនអស់រយៈពេលប្រាំពីរឆ្នាំ...ទម្រាំតែចេះកសាងសារមន្ទីរនេះឡើង គឺដើម្បីជួយឲ្យប្រជាជនកម្ពុជាដឹងអំពីសង្គ្រាមនិងទិដ្ឋភាពផ្សេងៗទៀតដែលទាក់ទងនឹងឧក្រិដ្ឋកម្មសង្គ្រាម ។ ចំពោះប្រជាជនសាមញ្ញដែលមិនយល់ គឺមានតែសារមន្ទីរនេះហើយដែលអាចជួយគាត់ឲ្យយល់ ។ ថ្វីត្បិតតែប្រជាជនទាំងអស់នោះធ្លាប់បានទទួលរងគ្រោះក្រោមរបប ប៉ុល ពត ក៏ដោយ ក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវម្នាក់ ខ្ញុំនៅតែចង់ឲ្យប្រជាជនកម្ពុជាទាំងនោះទៅទស្សនា"សារមន្ទីរនេះ" ហើយថ្វីត្បិតតែធ្វើឲ្យប្រជាជនកម្ពុជាស្រក់ទឹកភ្នែកក៏ដោយ ។ ទោះបីជាប្រជាជនកម្ពុជាធ្លាប់រងគ្រោះដោយសារសង្គ្រាមក៏ពួកគាត់មិនយល់ពីអ្វីដែលហៅថាសង្គ្រាមដែរ ហើយប្រជាជនជំនាន់ក្រោយៗទៀតក៏នៅតែមិនយល់ ។[២៨]

ប្រវត្តិវិទូ លិចវូដ បានចង្អុលបង្ហាញថា សម្រាប់ប្រជាជនកម្ពុជាទាំងអស់មានបញ្ហាជាច្រើនទាក់ទងនឹង "កសិណបញ្ឆោក" នៃសារមន្ទីរដែលត្រូវបានរៀបចំឡើងដោយជនបរទេស ដើម្បីឆ្លុះបញ្ចាំងពីភាពស្របគ្នារវាង"របបប្រល័យពូជសាសន៍" នៃកម្ពុជាប្រជាធិបតេយ្យជាមួយនឹងរបបណាហ្ស៊ីហ៊ីត្លែរនៃប្រទេសអាល្លឺម៉ង់ ។ ទន្ទឹមគ្នានេះ ភាគច្រើននៃអ្នកដែលនៅរស់រានមានជីវិតដែលធ្លាប់ទទួលរងគ្រោះក្រោមរបបកម្ពុជាប្រជាធិបតេយ្យ អាចនិយាយរៀបរាប់យ៉ាងក្បោះក្បាយឥតមានលំបាកឡើយ ហើយរឿងរ៉ាវទាំងអស់អាចនឹងរៀបរាប់សង្ខេបតាមរយៈការតាំងពិព័រណ៍នៅទួលស្លែងនេះ ។ លទ្ធិណាហ្ស៊ីហាក់ដូចជាគ្រាន់តែជាផ្លាកឈ្មោះមួយដូចជាលទ្ធិដទៃៗទៀតដែលប្រជាជននៅសេសសល់ពីសេចក្តីស្លាប់ដោយសារគ្រោះអាក្រក់ដែលអ្នកនៅរស់បានទទួលរងដូចគ្នា ។ ភាពមិនអើពើរបស់មន្ត្រីកម្ពុជាប្រជាធិបតេយ្យចំពោះជនរងគ្រោះដែលត្រូវបានតាំងពី

បន្ទប់មួយទៅបន្ទប់មួយ ពិតជារំពុកឡើងវិញនូវអនុស្សាវរីយ៍ដ៏ជូរចត់ដល់អ្នកទោសដែលរួចផុតពីសេចក្ដីស្លាប់ទាំងនោះ ។ ការបកស្រាយអំពីរឿងរ៉ាវក្នុងសម័យ ប៉ុល ពត បានក្លាយទៅជារឿងកម្មផលដែលជាឧបសគ្គបណ្ដាលឲ្យមានការចងចាំមិនល្អអំពីប្រវត្តិសាស្ត្រមួយ ប៉ុន្តែប្រជាជនដែលនៅរស់ពិតជាចងចាំយ៉ាងច្រើនឥតគណនានូវអ្វីដែលបានកើតឡើង ហើយអ្វីដែលប្រជាជនគ្រប់រូបនៅចងចាំមានលក្ខណៈដូចគ្នាពីមួយទៅមួយ ។ ចំណុចនេះត្រូវបានលើកឡើងដោយអ្នកចិត្តសាស្ត្របារាំងពីររូបគឺលោក ជីនព្យែរ ហីហ្វែល និង លោក កូលែត ឡង់ជ្រាក់ ដែលធ្វើការនៅជំរំជនភៀសខ្លួននៅក្នុងប្រទេសថៃនាទសវត្សរ៍ឆ្នាំ១៩៨០ ។ លោកទាំងពីរមានប្រសាសន៍ថា÷

> ជានិច្ចកាល អ្នកដែលមានលោកទស្សនៈជឿលើកម្មផល រស់នៅបានស្ងប់សុខស្រួលជាង ព្រោះជំនឿនេះមិនធ្វើឲ្យយើងមានចម្ងល់ច្រើនឬយ៉ាងហោចណាស់ក៏ឲ្យយើងមានចម្លើយនៅក្នុងដៃរួចជាស្រេច ដើម្បីនឹងឆ្លើយថាមកពីកម្មរបស់យើងម្នាក់ៗទើបទទួលវៀរវេរាបែបនេះ ។ ក្នុងទស្សនៈកម្មផលដោយចាត់ទុកថា ខ្មែរក្រហមជាពួកជ្រុលនិយមដ៏ឆ្កួតលីលា និងជាការចាប់កំណើតនៃព្រលឹងបិសាចដែលទទួលខុសត្រូវចំពោះអពមង្គលរបស់ជនជាតិខ្មែរ ធ្វើឲ្យការមើលឃើញបាតុភូតពិតប្រាកដមានការលំបាកស្មុគស្មាញ ប៉ុន្តែគឺជាទស្សនៈមួយដែលប្រជាជនយល់ថាល្អ និងធ្វើឲ្យខ្លួនពេញចិត្ត ។[២៩]

ដោយសារគ្រប់ទ័ណ្ឌទស្សនៈផ្អែកលើកម្មផលនេះ របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានពុះពារយ៉ាងខ្លាំងដើម្បីផ្ដោតអារម្មណ៍របស់ប្រជាជនទៅលើការចងកំហឹងចំពោះបនប្រល័យពូជសាសន៍ដែលកាន់អំណាចពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ ។ តាមការពិត ព្រោះតែរដ្ឋាភិបាលថ្មីផ្អែកទៅលើភាពស្របច្បាប់ដែលថាខ្លួនជាអ្នកបានផ្ដួលរំលំពួកខ្មែរក្រហមនោះ រដ្ឋាភិបាលនេះមិនប្រកាន់យកនូវគោលជំហរផ្ដន្ទាទោសចលនាទាំងមូលឡើយ ព្រោះឥស្សរជនសំខាន់ៗនៃរបបថ្មីភាគច្រើនក៏ជាខ្មែរក្រហមដែរដែលផ្ដាច់ខ្លួនរត់ទៅប្រទេសវៀតណាមនៅឆ្នាំ១៩៧៧ និង១៩៧៨ ។ វត្តមានជាបន្តរបស់ពួកមេដឹកនាំខ្មែរក្រហមព្រមទាំងកូនចៅប្រដាប់អាវុធរបស់ខ្លួនដែលរត់ទៅជ្រកកោននៅតាមព្រំដែនកម្ពុជា-ថៃ បានធ្វើឲ្យវៀតណាមមានហេតុផលដើម្បីរក្សាកម្លាំងទ័ពរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ហើយបណ្ដោយឲ្យសាធារណរដ្ឋប្រជាមានិតកម្ពុជាលាបពណ៌គូបដិបក្ខនយោបាយរបស់ខ្លួនថាជាខ្មែរក្រហមដែរ ។

ដូចបុព្វការីក្នុងរបបមុនៗដែរ អ្នកនាំពាក្យរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានរៀបចំប្រវត្តិសាស្ត្រតម្រូវទៅតាមសេចក្ដីត្រូវការនានាសម្រាប់មួយថ្ងៃៗរបស់ខ្លួនប៉ុណ្ណោះ ។ នៅក្នុងការបង្កើតចលនាកុម្មុយនិស្តកម្ពុជា ចលនានេះគឺជាចលនាបដិវត្តន៍ដ៏បរិសុទ្ធពិតៗ រហូតមកដល់និងរួមទាំងថ្ងៃរំដោះភ្នំពេញនាឆ្នាំ១៩៧៥ផង ដែលកាលណោះចលនានេះបានឡើងមកកាន់កាប់អំណាចក្នុងមួយពព្រិចភ្នែកនិងខ្លាំងក្លាស្ទើរតែមិនអាចពន្យល់បាន ។ ការនិយាយបង្វែរសាច់រឿងនេះបានធ្វើឲ្យរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាមានហេតុផលប្រារព្វពិធីរំពុក «ជ័យជម្នះលទ្ធិសង្គមនិយម» នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ

១៩៧៥ ហើយទន្ទឹមនឹងនោះធ្វើការថ្កោលទោសពួកខ្មែរក្រហមដែលជាអ្នកវាយយកជ័យជម្នះនេះផង ។ វិធីសាស្ត្រក្នុងការរៀបចំប្រវត្តិសាស្ត្ររបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាក៏បានសង្កត់ធ្ងន់ទៅលើមិត្តភាពដ៏យូរអង្វែងរវាងចលនាតស៊ូកម្ពុជា-វៀតណាម និងរបបកម្ពុជានិងវៀតណាមដែលពីមុនមកចំណងមិត្តភាពនេះ ពិបាកនឹងធ្វើបានណាស់នៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសទាំងពីរ ។[៣០]

ការអានអត្ថបទដែលមានជាប់ទាក់ទងយ៉ាងច្រើនអំពីអតីតកាល មានន័យតែចំពោះអ្នកស្មោះត្រង់ចំពោះបក្សតែប៉ុណ្ណោះ ។ ម្យ៉ាងវិញទៀត មានតែចលនាបដិវត្តន៍សុទ្ធសាធមួយប៉ុណ្ណោះដែលធ្វើឲ្យសហរដ្ឋអាមេរិកបរាជ័យ ហើយពេលដែលកង់ប្រវត្តិសាស្ត្រវិលប្រែក្រឡាស់ ពុំមានចលនាបដិវត្តន៍ដែលមានលក្ខណៈឃោរឃៅមកលើប្រជាជនសាមញ្ញ ឬក៏ប្រឆាំងនឹងជនបដិវត្តន៍វៀតណាមទៀតឡើយ ។ ការពន្យល់អំពីហេតុការណ៍ដែលកើតឡើងទាំងអស់នេះគឺមានប្រយោជន៍តិចតួចណាស់សម្រាប់ជនជាតិកម្ពុជាដែលមិនមែនជាជនបដិវត្តន៍ ។ ជនជាតិកម្ពុជាយល់ថា ជាការងាយស្រួលជាងក្នុងការផ្តោតទៅលើការចងចាំរបស់ខ្លួនក្រោមរបប«អាពត» ។ ឧក្រិដ្ឋកម្មដ៏ចម្លែកនិងមិនអាចលើកទោសឲ្យបានរបស់ «អាពត» ពុំមែនដោយសារ ប៉ុល ពត បានតាំងខ្លួនជាជនកុម្មុយនិស្ត ឬ «ហ្វាស៊ីស»នោះទេ ប៉ុន្តែអ្វីដែលសំខាន់បំផុតគឺ ប៉ុល ពត ជាអ្នកដែលទទួលខុសត្រូវចំពោះការបន្តការសម្លាប់ជនជាតិខ្លួនឯង ។ ប្រសិនបើវៀតណាមចង់ហៅ ប៉ុល ពត ថាជាជនហ្វាស៊ីសនោះ ប្រជាជនកម្ពុជានឹងហៅតាមទាំងមិនសូវដឹងថាតើអត្ថន័យនេះស៊ីជម្រៅដល់កម្រិតណាផងទេ ។ ទាក់ទងនឹងបញ្ហានេះ នៅក្នុងកិច្ចសម្ភាសន៍ជាមួយ លីអូនែល វៀរុង កាលពីឆ្នាំ១៩៩៥ អ្នកដែលនៅរស់រានមានជីវិតពីគុកទួលស្លែងម្នាក់ឈ្មោះ ផាន ផនចាន់ ដែលកាលពីជំនាន់ ប៉ុល ពត ជាឧត្តមសេនីយ៍ នៃកងទ័ពកម្ពុជាបាននិយាយថា÷

> បាទ! អ្វីដែលបានកើតឡើងកាលពីជំនាន់ ប៉ុល ពត នោះ គឺការអនុវត្ត «លទ្ធិកុម្មុយនិស្ត» ប៉ុន្តែវាជាប្រភេទ «ហ្វាស៊ីស» ហើយខ្លាំងលើសហ្វាស៊ីសទៅទៀត ។ ជនហ្វាស៊ីសអាល្លឺម៉ង់មិនដែលសម្លាប់ជនជាតិឯងទេ គេសម្លាប់ជនជាតិដទៃដូចជា បារាំង ប៉ូឡូញជាដើម ចំណែក ប៉ុល ពត វិញវាសម្លាប់ជនជាតិឯង អស់បីលាននាក់ ។ ពួកហ្វាស៊ីសមិនធ្វើដូច្នេះឡើយ ។[៣១]

រៀងរាល់ឆ្នាំនៅក្នុង «ទិវាចងកំហឹង» រដ្ឋាភិបាលបានប្រមូលផ្តុំមតិមហាជន ហើយរំពុកឡើងវិញនូវការចងចាំរបស់ខ្លួនចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងឱកាសនោះបាតុកម្មប្រឆាំងនឹង ប៉ុល ពត ត្រូវបានចាត់ចែងឡើងដោយមានការចូលរួមពីសំណាក់សិស្សសាលា មន្ត្រីនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ក្នុងនោះមានការថ្លែងសុន្ទរកថាថ្កោលទោសរបបកម្ពុជាប្រជាធិបតេយ្យ ហើយ លោក វ៉ាន់ ណាត ព្រមទាំងអ្នកដទៃទៀតដែលរួចផុតពីសេចក្តីស្លាប់នៅគុកទួលស្លែង ក៏ត្រូវបានកោះហៅឲ្យមកនិយាយរ៉ាយរ៉ាប់ អំពីរឿងរ៉ាវដែលគាត់ជួបប្រទះនៅក្នុងអតីតមន្ទីរស-២១«គុកទួលស្លែង» ។[៣២]

នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ៨០ អ្នកដែលចូលមកមើលបណ្ណសារដ្ឋានដែលស្ថិតនៅជាន់ទីពីរនៃអគារ

ខាងលិចរបស់គុកទួលស្លែង មានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះឯកសារយ៉ាងច្រើនដែលប្រមូលផ្តុំនៅទីនោះ ។ ភាគច្រើននៃឯកសារទាំងនោះមានកម្រាស់ជាងមួយហ្វូដ (ជាងសាមសិបសង់ទីម៉ែត្រ) ។ ឯកសាររាប់រយដែលជាអត្ថបទវាយអង្គុលីលេខនិងខ្លះជាឯកសារសរសេរដោយដៃ ។ ទូដែលមានកញ្ចក់ពីមុខនៅក្នុងបណ្ណសារដ្ឋាននោះផ្ទុកពេញទៅដោយសៀវភៅសរសេររបស់កម្មាភិបាលដែលមានសរសេរអំពីកំណត់ហេតុប្រជុំសិក្ខាសាលា យោធា និងវគ្គសិក្សាវិជ្ជាពេទ្យ ។ សេចក្តីសង្ខេបនៃចម្លើយសារភាពដែលកិបរួចស្ថិតនៅជាគំនរៗខ្លះមានរហូតដល់រាប់រយសន្លឹក ។ អ្នកសារព័ត៌មានព្រមទាំងអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ត្រូវបានទាក់ទាញចិត្តឲ្យថតចម្លងនូវអត្ថបទចម្លើយសារភាពនិងអត្ថបទផ្សេងៗជាច្រើន ។ នៅទសវត្សរ៍ឆ្នាំ១៩៨០ សកម្មជនសិទ្ធិមនុស្សមួយរូបឈ្មោះ ដេវីដ ហក បានប្រមែប្រមូលសម្រាំងជ្រើសយកអត្ថបទជាច្រើននៅគុកទួលស្លែងដែលផ្តល់នូវភ័ស្តុតាងយ៉ាងក្រាស់ក្រែលអំពីឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ ។[៣៣] ការខិតខំព្យាយាមរបស់លោក ដេវីដ ហក និងអ្នកដទៃផ្សេងទៀតក្នុងការនាំយកមេដឹកនាំកម្ពុជាប្រជាធិបតេយ្យមកកាត់ទោស នៅពេលនោះនិងពេលក្រោយមកត្រូវបានបង្អាក់ដោយសារការសម្របសម្រួលរបស់ប្រទេសថៃ និងការពិចារណាផ្នែកនយោបាយដទៃទៀត ។ គំនិតផ្តួចផ្តើមនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោស មានសន្ទុះម្តងទៀតនៅទសវត្សរ៍ឆ្នាំ១៩៩០ គឺពេលដែលចលនាខ្មែរក្រហមចុះខ្សោយ ។[៣៤]

ក្រោយឆ្នាំ១៩៨៩ ពេលដែលវៀតណាមដកទ័ពចេញពីប្រទេសកម្ពុជា វាសនានៃបណ្ណសារដ្ឋានរួមទាំងសារមន្ទីរទាំងមូលផង មើលទៅដូចជាគ្មានភាពប្រាកដប្រជាឡើយ ។ នៅឆ្នាំ១៩៩១សាកលវិទ្យាល័យខរណែល នៅសហរដ្ឋអាមេរិក ដែលត្រូវបានកត់សម្គាល់ថាមានភាពសម្បូរបែបខាងផ្នែកឯកសារទាក់ទងនឹងប្រទេសអាស៊ីអាគ្នេយ៍នៅបណ្ណាល័យរបស់ខ្លួននោះ បានស្នើសុំធ្វើកាតាឡុក និងថតចម្លងជាហ្វីល (ថតមីក្រូហ្វីល) នូវបណ្ណសារក្នុងគុកទួលស្លែងដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងវប្បធម៌កម្ពុជា ។ កិច្ចការទាំងនេះត្រូវបានបញ្ចប់ក្នុងរយៈពេលពីរឆ្នាំ ។ ឯកសារចម្លងជាមីក្រូហ្វីលមួយច្បាប់ត្រូវបានតម្កល់ទុកនៅសាកលវិទ្យាល័យខរណែល ហើយមួយច្បាប់ទៀតត្រូវបានតម្កល់ទុកនៅឯសារមន្ទីរទួលស្លែង ។

ឯកសារថតចម្លងហើយមាន២១០ថាស «ហ្វីល» រួមទាំងហ្វីលដែលថតម្តងទៀតចំនួនដប់មួយថាស ។ នៅក្នុងដុំឯកសារទាំងអស់នោះគឺមានចម្លើយសារភាពទាំងអស់ដែលរកឃើញនៅនឹងកន្លែងរួមទាំងឯកសារចម្លើយសារភាពរបស់អ្នកទោសជាជនបរទេសទៀតផង ។ ប៉ុន្តែឯកសារនេះត្រូវបានថតចូលហ្វីលដោយឡែក ។ ឯកសារជនបរទេសទាំងនោះមានមិនត្រឹមតែចម្លើយសារភាពរបស់អ្នកទោសជាឈ្លើយសឹកវៀតណាមទេ តែមានទាំងចម្លើយរបស់អ្នកនេសាទត្រីជនជាតិវៀតណាម ថៃ ព្រមទាំងជនស៊ីវិលវៀតណាមដទៃទៀតផង ។ ក្រៅពីនេះមានចម្លើយសារភាពមួយចំនួនតូចរបស់នាវិកជនជាតិអាមេរិកាំង អង់គ្លេស និងអូស្ត្រាលី ដែលត្រូវបានចាប់ខ្លួននៅពេលដែលចូលមកជិតឆ្នេរសមុទ្រកម្ពុជាដែរ ។[៣៥]

ក្នុងចំណោមចម្លើយសារភាពដែលមានព័ត៌មានបញ្ជាក់យ៉ាងច្បាស់នោះ រួមមានចម្លើយសារភាពរបស់អតីតបុគ្គលិកធ្វើការនៅគុកទួលស្លែងចិតសិបប្រាំបួននាក់ ។ មានម្ភៃបួននាក់ជាអ្នកសួរចម្លើយ និងដប់ពីរនាក់ទៀតជាអ្នកធ្វើឯកសារ ។ អ្នកក្រៅពីនោះគឺជាឆ្មាំ ។ ឯកសារទាំងអស់នោះផ្តល់ជាទិន្នន័យប្រវត្តិរូបអំពី

បុគ្គលិកក្មេងៗ ធ្វើការនៅគុកទួលស្លែង ។ ទិន្នន័យទាំងនោះក៏រៀបរាប់បន្ថែមអំពីលក្ខខណ្ឌធ្វើការងារព្រមទាំងការធ្វើទារុណកម្មរបស់ក្រុមខ្លួន ។

ថាសហ៊ីល «មីក្រូហ៊ីល» ដែលបានថតម្លងរួចហើយនោះ ក៏បានផលិតនូវឯកសារមិនមែនជាប្រភេទចម្លើយសារភាពដែលត្រូវបានស្រាវជ្រាវរកឃើញនៅក្នុងគុកទួលស្លែង ។ លើសពីនេះទៀត ថាសហ៊ីលទាំងនោះ ក៏ផ្ទុកនូវកំណត់ត្រាបញ្ជីចេញចូល និងកំណត់ហេតុនៃការសម្លាប់ ចម្លើយសារភាព អត្ថបទ អង្គលីលេខធ្វើឡើងដោយតំបន់ អង្គភាពយោធា និងការិយាល័យរដ្ឋបាលព្រមទាំងសៀវភៅសិក្សាសរសេរដោយដៃទាក់ទងនឹងប្រធានបទជាច្រើនដូចជានយោបាយ របៀបសម្គាល់យន្តហោះ គណិតវិទ្យា វិជ្ជាពេទ្យ កាំភ្លើងធំ និងកាំភ្លើងធុនតូច ។ មិនតែប៉ុណ្ណោះ ឯកសារដែលមិនមែនជាចម្លើយសារភាព រួមមានលក្ខន្តិកៈ បក្សកុម្មុយនិស្តកម្ពុជា សុន្ទរកថា និងទិសបញ្ញាការងារពីមជ្ឈិមបក្សព្រមទាំងទិនានុប្បវត្តិអំពីទ្រឹស្តី ដែលហៅថា «ទង់បដិវត្ត» និង «យុវជនបដិវត្ត» ដែលចែកចាយដល់សមាជិកបក្ស ។ ឯកសារទាំងអស់ត្រូវបានចម្រាញ់ចេញពីគុកទួលស្លែងផ្ទាល់តែម្តង ដែលរួមបញ្ចូលទាំងរបាយការណ៍នៃត្រីមាសទីមួយ ឆ្នាំ១៩៧៧ អក្សរសរសេរដោយអ្នកសួរចម្លើយដែលរៀបរាប់ពីការធ្វើទារុណកម្មចំពោះអ្នកទោស បទបញ្ជាសម្រាប់ឆ្មាំគុក និងចំណាររបស់ «ឌុច» ដែលជាប្រធានគុក«ទួលស្លែងឬមន្ទីរស-២១» និយាយអំពីបញ្ហាជាច្រើន រួមមានការវិភាគរបស់ខ្លួនលើចម្លើយសារភាពនៅក្នុងឯកសារសរសេរដៃមួយ ដែលប្រហែលជាត្រូវបានសរសេរនៅដើមឆ្នាំ១៩៧៨ មានចំណងជើងថា «ផែនការចុងក្រោយ» ។ ឯកសារដែលមិនមែនជាចម្លើយសារភាពដែលផ្តល់ព័ត៌មានដ៏ច្រើនបំផុត ហើយដែលថតចម្លងហើយដោយសាកលវិទ្យាល័យខណែល គឺជាសៀវភៅសិក្សាមួយក្បាលមានកម្រាស់ហាសិបប្រាំទំព័រ ដែលចងក្រងដោយអ្នកសួរចម្លើយនៅឆ្នាំ១៩៧៦ ។ អត្ថបទនេះនឹងត្រូវបានលើកយកមកពិភាក្សាលម្អិតនៅជំពូកទី៥ ។[៣៦]

នៅពេលដែលការថតចម្លងឯកសារត្រូវបានបញ្ចប់នៅឆ្នាំ១៩៩៣ គេគិតថា ថាសហ៊ីលទាំងអស់នោះគឺជាឯកសារសំខាន់ៗដែលនៅសេសសល់ពីគុកទួលស្លែង ។ ប៉ុន្តែនៅឆ្នាំ១៩៩៥ បណ្ណសារដ្ឋានស-២១មួយផ្នែកទៀតនៅក្រសួងមហាផ្ទៃនៃប្រទេសកម្ពុជាត្រូវបានបង្ហាញដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ហៅកាត់ថា «ឌីស៊ី ខេម» ដែលកាលណោះជាសាខាមួយនៃកម្មវិធីសិក្សាពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាបង្កើតឡើងដោយសាកលវិទ្យាល័យយែលក្រោមជំនួយឧបត្ថម្ភរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិកក្នុងគំនិតមួយដើម្បីប្រមែប្រមូលនិងចងក្រងឯកសាររបស់របបកម្ពុជាប្រជាធិបតេយ្យ ។ ឯកសារថ្មីដែលតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហាក់ដូចជាត្រូវបានយកចេញពីបណ្ណសារដ្ឋានរបស់រដ្ឋមន្ត្រីការពារប្រទេសនិងសន្តិសុខជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យ សុន សេន ដែលរួមចំណែកក្នុងការត្រួតពិនិត្យគុកនេះ ។ អត្ថបទចម្លើយសារភាពជាងហាសិប ក្នុងចំណោមឯកសារថ្មីដែលប្រមូលបាននេះមានចំណារសរសេរដោយដៃរបស់ សុន សេន ។ នៅលើក្របមុខនៃឯកសារភាគច្រើនមានសរសេរជាអក្សរវៀតណាមបញ្ជាក់ថា ឯកសារនេះត្រូវបានពិនិត្យពីសំណាក់អាណាព្យាបាលវៀតណាមនៅកម្ពុជានាទសវត្សរ៍ឆ្នាំ១៩៨០ ។

ឯកសារដែលត្រូវបានរកឃើញទាំងនោះមានចម្លើយសារភាពរាប់សិប និងឯកសាររដ្ឋបាលសំខាន់ៗ

មួយចំនួនដែលមិនមាននៅក្នុងបណ្ណសារដ្ឋានស-២១ ដូចជាការប្រជុំជីវភាពស្វ័យទិតៀនរបស់កម្មាភិបាលនៅគុកស-២១ ព្រមទាំងសៀវភៅសរសេរចងក្រងដោយអ្នកសួរចម្លើយថ្នាក់លើ ។ ឯកសាររបស់កម្ពុជាប្រជាធិបតេយ្យដែលគ្មានការទាក់ទងនឹងគុកស-២១ ក៏ត្រូវបានតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ ហើយប្រាកដណាស់ថាឯកសារទាំងនោះនឹងមានសារប្រយោជន៍ចំពោះអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់អំពីរបបកម្ពុជាប្រជាធិបតេយ្យ ។

ឯកសាររាប់រយផ្សេងទៀតនៅគុកស-២១ដែលមិនត្រូវបានថតចម្លងជាមីក្រូហ្វីលនោះ ក៏បានហូរចូលមកមជ្ឈមណ្ឌលឯកសារកម្ពុជាដែរ គឺចាប់តាំងពីឆ្នាំ១៩៩៦មក ។ ឯកសារទាំងនេះរួមមានអត្ថបទផ្សេងៗ កាលវិភាគសួរចម្លើយមួយចំនួន បញ្ជីឈ្មោះអ្នកទោសដែលឈឺ ឯកសារដែលផ្ញើភ្ជាប់ជាមួយអ្នកទោសមកកាន់មន្ទីរស-២១ ហើយនិងសៀវភៅសិក្សាសរសេរដៃជាងពីររយក្បាលទៀត ។ សៀវភៅពីរក្បាលដែលមានសារប្រយោជន៍ពិសេសបំផុត ត្រូវបានរៀបរៀងឡើងក្នុងចន្លោះឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ ដោយប្រធានសួរចម្លើយឈ្មោះ ម៉ម ណៃ ហៅ ចាន់ ជាមួយអ្នកសួរចម្លើយពីរនាក់ទៀតដែលមានឈ្មោះ ក្លែងក្លាយថា ទុយ និង ប៉ុន ។

ម្យ៉ាងវិញទៀត ដំណើរការស្វែងរកឯកសារនៅគុកស-២១បានផ្តើមឡើងនៅខែមករា ឆ្នាំ១៩៧៩ ហើយមកដល់សព្វថ្ងៃក៏នៅតែដំណើរការដែរ ។ ឯកសារដ៏សន្ធឹកសន្ធាប់ដែលមានដល់ឥឡូវនេះ ហាក់ដូចជាមានលក្ខណៈគ្រប់គ្រាន់ហើយ សម្រាប់ការសិក្សាលម្អិតអំពីមន្ទីរស-២១នេះ ។ អ្នកនិពន្ធជនជាតិយូហ្គោស្លាវីម្នាក់ឈ្មោះ មីឡូវ៉ាន ជីឡាស់ បានកត់សម្គាល់ថា «របៀបចាត់ចែងគុក និងរបៀបដែលជនជាប់ឃុំឃាំងត្រូវបានធ្វើបាប បានបង្ហាញឲ្យឃើញរូបភាពពិតនៃសង្គម ជាពិសេសបង្ហាញពីគំនិតនិងរបៀបធ្វើការរបស់អ្នកដែលដឹកនាំសង្គមនោះ» ដែលហាក់ដូចជាចំណាប់អារម្មណ៍ពិសេសមួយមានលក្ខណៈសមស្របគ្នាទៅនឹងមន្ទីរស-២១និងរបបកម្ពុជាប្រជាធិបតេយ្យ ។[៣៧] បើយើងមើលឯកសារទាំងនោះដោយផ្ចិតផ្ចង់ ហើយស្តាប់សម្តីជនរងគ្រោះជាច្រើនដែលរស់នៅយ៉ាងលំបាកវេទនា នោះយើងនឹងអាចយល់ដឹងរឿងអ្វីមួយអំពីខ្លួនឯងផ្ទាល់ ។

នៅខែសីហា ឆ្នាំ១៩៨១ ខ្ញុំបានចំណាយពេលជិតមួយម៉ោងចូលមើលគុកទួលស្លែង ។ ចាប់តាំងពីឆ្នាំ១៩៩០ ខ្ញុំបានវិលត្រឡប់មកមើលសារមន្ទីរនេះជាច្រើនដង ។ ថ្វីត្បិតតែបុរោះបីជាបុគ្គលិកនៅសារមន្ទីរទួលស្លែងទទួលរាក់ទាក់ស្វាគមន៍ក៏ដោយ ក៏ខ្ញុំតែងមានអារម្មណ៍វង្វេងវង្វាន់ដោយសារទីកន្លែងនេះដែរ ។ រាល់ពេលដែលខ្ញុំមកធ្វើទស្សនកិច្ច ខ្ញុំមានអារម្មណ៍រន្ធត់យ៉ាងខ្លាំងដោយសារទិដ្ឋភាពផ្ទុយគ្នាស្រឡះរវាងបរិវេណដែលស្ងប់ស្ងាត់ដែលចាំងជះដោយពន្លឺព្រះអាទិត្យគ្រប់ច្រកល្ហក និងរូបភាពតាំងពិព័រណ៍ដែលគួរឲ្យរន្ធត់ រវាងបន្ទប់រៀនដែលដុសលាងសស្អុសមានកម្រាលឥដ្ឋពណ៌លឿងនិងឧបករណ៍សួរចម្លើយនៅក្នុងនោះ ហើយនិងរវាងក្មេងៗដែលកំពុងរត់លេងខាងក្រៅអគារ និងរូបថតក្មេងៗពាក់កណ្តាលខ្លួនដែលកំពុងត្រូវបានបណ្តើរយកទៅសម្លាប់ចោល ។

នៅឯសារមន្ទីរ ភ្នែកជនរងគ្រោះនៅក្នុងរូបថតដែលគេដាក់តាំង ជាពិសេសភ្នែករបស់ស្ត្រីនិងកូនក្មេង

ហាក់ដូចជាតាមសម្ដីខ្ញុំមិនដាក់ភ្នែក ។ ដោយដឹងនូវអ្វីដែលជនរងគ្រោះមិនបានដឹង អំពីការដែលជនរងគ្រោះម្នាក់ៗកំពុងតែប្រឈមមុខនឹងសេចក្ដីស្លាប់នៅពេលដែលខ្លួនត្រូវគេថតរូបនោះ ធ្វើឲ្យរូបភាពនោះផ្ដល់ឲ្យយើងនូវអារម្មណ៍រន្ធត់ចិត្តស្ទុះអស់ស្មារតី ហើយរូបថតទាំងនោះធ្វើឲ្យយើង ជាពិសេសរូបខ្ញុំផ្ទាល់មានអារម្មណ៍ព្រឺខ្លាចជាងរូបថតមនុស្សស្លាប់ ឬការគូររូបពិពណ៌នាអំពីការធ្វើទារុណកម្មដ៏សាហាវដែលគូរក្រោយឆ្នាំ១៩៧៩ ដោយអ្នកដែលរួចចាកផុតពីសេចក្ដីស្លាប់នៅគុកទួលស្លែងម្នាក់ឈ្មោះ វ៉ាន់ ណាត នោះទៅទៀត ។[៣៨]

ស្ទើរតែគ្រប់ទស្សនកិច្ចរបស់ខ្ញុំ តែងតែមានសត្វសារិកាកែវលោតទៅលោតមករំលងផ្លូវដែលមានរុក្ខជាតិដុះស៊ុបទ្រុបជុំវិញជានិច្ច ។ មាន់រងាវពុស្ទូររំពងជុំវិញ ដុះអ្នកស្រុកលាយឡំនឹងសំឡេងចរាចរនៅលើផ្លូវមហាវិថីមុនីវង្សឮស្ទូររហ៊ឹមៗនៅទិសខាងកើត ឬឮស្ទូរសំឡេងក្មេងអាពាហ៍ពិពាហ៍តាមប្រពៃណីព្រះពុទ្ធសាសនានៅជិតទីតាំងគុកទួលស្លែងនោះនាវដូវប្រាំងទៀតផង ។ សំឡេងនៅដើមទសវត្សរ៍ឆ្នាំ១៩៧០ មានលក្ខណៈខុសគ្នាពីសំឡេងក្នុងអំឡុងនៃការធ្វើទស្សនកិច្ចរបស់ខ្ញុំ ។ កាលណោះរៀងរាល់រាត្រីនៅក្នុងទីក្រុងដែលងងឹតស្ងួនស្ងាត់ជ្រងំ អ្នកធ្វើការនៅក្នុងគុកទួលស្លែងដែលគេដាក់ឲ្យប្រចាំការនៅលើមហាវិថីមុនីវង្ស បានឮសំឡេងមនុស្សដែលកំពុងត្រូវធ្វើទារុណកម្ម ស្រែកឲ្យជួយ ។ មិនតែប៉ុណ្ណោះ អ្នកដែលនៅរស់រានមានជីវិត ព្រមទាំងអ្នកដែលធ្វើការនៅក្នុងគុកក៏បានចែករំលែកនូវការចងចាំរបស់ខ្លួនអំពីការឮសំឡេងស្រែកយំទាំងក្ដីឈឺចាប់នៅពេលរាត្រីដែរ ។

ដោយគេះតែដើរៗជុំវិញសារមន្ទីរ ស្រង់យកពត៌មានពីបណ្ណសារដ្ឋាននៃគុកទួលស្លែង និងដោយស្ដាប់នូវការរ៉ាយរាប់របស់អ្នកដែលនៅរស់រានមានជីវិតនិងអ្នកដែលបម្រើការងារនៅក្នុងគុកនេះ យើងក៏នៅតែអាចឮសំឡេងខ្មោចជាច្រើនកំពុងដង្ហោយហៅដោយទំនួញឈឺចាប់ពីក្នុងគុកនោះឲ្យជួយ ។ សំឡេងជនរងគ្រោះទាំងនោះមានស្ថិតនៅក្នុងសាច់រឿងដែលមានរៀបរាប់បន្តនៅទៀតនេះ ។

**វគ្គទីពីរៈ**

# ស-២១ ស្ថាប័នស្វយ័ត

ក្នុងសៀវភៅរបស់គាត់ក្រោមចំណងជើងថា «សិទ្ធិជ្រកកោន» ដែលមានសេចក្ដីអធិប្បាយដ៏ក្បោះក្បាយ សង្គមវិទូ អេវីង ហ្គូវមិន បានឲ្យនិយមន័យ «ស្ថាប័នស្វយ័ត» ថាជាកន្លែងស្នាក់នៅនិងធ្វើការរបស់មនុស្សមួយក្រុម ដែលត្រូវបានដាក់ឲ្យស្ថិតក្នុងស្ថានភាពដូចគ្នាហើយកាត់ផ្ដាច់ចេញពីសង្គមទាំងមូលមួយរយៈពេល ។ ក្រុមមនុស្សនេះរស់នៅរួមគ្នាក្នុងជីវិតមួយដែលត្រូវបិទជិតឃឹងនិងគ្រប់គ្រងជាផ្លូវការ ។[1] លោក អេវីង បន្តហៅស្ថាប័ននេះថា ជាកន្លែងបង្ខំមនុស្សឲ្យកែប្រែនិងធ្វើការពិសោធន៍តាមបែបធម្មជាតិទៅលើអ្វីៗដែលអាចធ្វើបានចំពោះមនុស្ស ។ ស្ថាប័ននេះរួមមានៈ សាលារៀន វត្តអារាម មន្ទីរពេទ្យអន្តរាគាព យោធា ។ល។និង ។ល។[2]

ក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជាដែលជាស្ថាប័នស្វយ័តដ៏ល្អឥតខ្ចោះ លោក អៀវីង លីហ្វូវីត យល់ថាប្រទេសកម្ពុជាទាំងមូលបានប្រែក្លាយយ៉ាងឆាប់រហ័សទៅជា «បរិយាកាសបិទជិតមួយ» ដែលនៅដាច់ឡែកពីពិភពលោកខាងក្រៅ ។ ប្រទេសជាតិត្រូវគ្រប់គ្រងដោយមនុស្សមួយក្ដាប់តូច ភាគច្រើនជាអតីតគ្រូបង្រៀនដែលងប់ងុលនឹងនយោបាយ ។ អ្នកទាំងនេះយល់ថាការត្រួតត្រា ការដាក់ទោសនិងការកែប្រែមនុស្សដែលនៅក្រោមការគ្រប់គ្រងរបស់ខ្លួនគឺជាភារកិច្ចយូរអង្វែង ។ កម្មាភិបាលទទួលបន្ទុកស-២១ទាំងអស់ស្ថិតក្រោមការត្រួតពិនិត្យរបស់មជ្ឈិមបក្ស ។ ស្រដៀងគ្នានេះដែរ កម្មាភិបាលទាំងនេះត្រូវបានបិទបាំងពីភ្នែកអ្នកខាងក្រៅ ហើយក្នុងនាមជាសមាជិកកងវរសេនាធំឯករាជ្យ កម្មាភិបាលស-២១ទាំងនេះធ្វើការក្រោមរបៀបរបបជាវិន័យយោធា ។ មន្ទីរស-២១ មជ្ឈិមបក្ស បក្សកុម្មុយនិស្តកម្ពុជា ក៏ដូចជារដ្ឋកម្ពុជាប្រជាធិបតេយ្យ អាចត្រូវបានយល់ថាជា «កន្លែងបង្ខំមនុស្សឲ្យកែប្រែ» កាន់តែច្រើនឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ ។

តាមការឲ្យនិយមន័យរបស់លោក អេវីង ស-២១គឺជារូបភាពដ៏អាក្រក់បំផុតមួយនៃស្ថាប័នស្វយ័ត ។ បេសកកម្មរបស់ស-២១ គឺការពារមជ្ឈិមបក្ស ។ មួយផ្នែក ស-២១បានបំពេញបេសកកម្មនេះដោយការកាប់សម្លាប់អ្នកទោសទាំងអស់ និងមួយផ្នែកទៀតដោយការប្ដូរជីវប្រវត្តិផ្ទាល់ខ្លួនរបស់អ្នកទោសទាំងនោះទៅតាមតម្រូវការនិងការសង្ស័យផ្សេងៗរបស់បក្ស ។ ការត្រួតពិនិត្យជីវប្រវត្តិ លើអ្នកទោស និងលើបុគ្គលិកក្នុងស-២១ មានលក្ខណៈតឹងតែងនិងមាន«វិន័យ»សាំញ៉ាំទៀតផង ។ លក្ខណៈបែបនេះអនុញ្ញាតឲ្យអ្នកមើលការខុសត្រូវអាចត្រួតត្រា និងដឹកនាំការកែប្រែអ្នកទោសទាំងនោះបានយ៉ាងមានប្រសិទ្ធភាព ។[3]

មន្ទីរស-២១មានផ្នែកស៊ើបអង្កេត ផ្នែកតុលាការនិងផ្នែកប្រឆាំងចារកម្ម ។ ឯកសារខ្លះហៅស-២១ថាជា«ក្រសួង» ឯកសារខ្លះទៀតហៅស-២១ ថាជា «មន្ទីរ»ទៅវិញ ។ ស្ថាប័នសន្តិសុខនៃប្រទេសកុម្មុយនិស្តដែលមានលក្ខណៈដូចសន្តិបាលនៃប្រទេសកម្ពុជារួមមាន ភ្នាក់ងារសម្ងាត់នៃអតីតសហភាពសូវៀត *(NKVD)* ប៉ូលិសសម្ងាត់នៃអតីតអាល្លឺម៉ង់ខាងកើត *(Stasi)* និងភ្នាក់ងារសម្ងាត់នៃប្រទេសចិន *(CCEG)* ។ មន្ទីរស-២១

ក៏មានលក្ខណៈប្រហាក់ប្រហែលការិយាល័យសហព័ន្ធស៊ើបអង្កេតរបស់អាមេរិក(*FBI*) និងប៉ូលិសសម្ងាត់(*MI5*) របស់អង់គ្លេសដែរ ។ ដោយពិតទៅ ប្រទេសភាគច្រើននៃសតវត្សរ៍ទី២០ សុទ្ធតែមានស្ថាប័នសន្តិសុខជាតិរបស់ខ្លួនរៀងៗខ្លួន ។ ខុសពីស្ថាប័នសន្តិសុខជាតិនៃប្រទេសដទៃ ស-២១ពុំបានពង្រាយភ្នាក់ងាររបស់ខ្លួនទៅតាមទីជនបទ ឬទៅក្រៅប្រទេសនិងពុំមានការិយាល័យរៀបចំគោលនយោបាយកណ្តាលឡើយ ។ ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៦ គ្រប់មុខការនៃស-២១ត្រូវបានបំពេញស្ទើរតែទាំងអស់នៅទួលស្លែង ។ ដោយហេតុផលទាំងនេះហើយដែលខ្ញុំសម្រេចយកឈ្មោះមន្ទីរស-២១ ឈ្មោះសន្តិបាលនិងទួលស្លែងមកប្រើជំនួសគ្នាទៅវិញទៅមក ។

កម្ពុជាប្រជាធិបតេយ្យពុំមានក្រមច្បាប់និងប្រព័ន្ធតុលាការទេ ។ ថ្វីបើបេសកកម្មនិងភារកិច្ចអ្នកធ្វើការនៅស-២១ពុំមានចែងក្នុងច្បាប់ក៏ពិតមែន ប៉ុន្តែយើងអាចសង្កេតឃើញថា បេសកកម្មនិងភារកិច្ចទាំងនេះមានលក្ខណៈប្រហាក់ប្រហែលនឹងបេសកកម្មនិងភារកិច្ចរបស់ប៉ូលិសសម្ងាត់សូវៀត ដែលមានចែងក្នុងច្បាប់ចុះខែកុម្ភៈ ឆ្នាំ១៩៣៦ដែរ ។ តាមច្បាប់នេះ ប៉ូលិសសម្ងាត់សូវៀតមានភារកិច្ច «លាតត្រដាងនិងប្រឆាំងរាល់និន្នាការ និងការវិវឌ្ឍន៍ដែលប្រឆាំងនឹងរដ្ឋ ហើយត្រូវចាត់គ្រប់វិធានការដែលខ្លួនយល់ថាចាំបាច់ និងមានប្រសិទ្ធភាពដើម្បីសម្រេចគោលដៅនេះ» ។[៨]

បើនិយាយឲ្យកាន់តែច្បាស់ជាងនេះទៅទៀត ស-២១ មានលក្ខណៈជាកន្លែងសម្រាប់សួរចម្លើយ និងធ្វើទារុណកម្ម ជាជាងកន្លែងសម្រាប់ឃុំឃាំងមនុស្ស ។ ទោះបីជាអ្នកទោសត្រូវបានឃុំឃាំងនិងធ្វើទណ្ឌកម្មនៅទីនោះក៏ដោយ ប៉ុន្តែពុំមាននរណាម្នាក់ធ្លាប់ត្រូវបានដោះលែងឡើយ ។ ស-២១ត្រូវបានប្រើប្រាស់ក្នុងគោលដៅចម្បងសម្រាប់តែបញ្ជូនមនុស្សទៅរកសេចក្តីស្លាប់ប៉ុណ្ណោះ ។ មនុស្សពីរនាក់ដែលមាននាទីគ្រប់គ្រងសន្តិបាល តែងរាយការណ៍ផ្ទាល់ជូនក្រុមអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យដែលគេស្គាល់ថាមជ្ឈិមបក្ស ឬក្បាលម៉ាស៊ីនសម្រាប់សមាជិកបក្ស និងជាអង្គការលើអង្គការ ឬបងខាងលើសម្រាប់អ្នកមិនមែនជាសមាជិក ។ មជ្ឈិមបក្សជាខួរក្បាលរបស់ប្រទេសជាតិទាំងមូល ។ សមាជិកមជ្ឈិមបក្សត្រូវបានផ្លាស់ប្តូរជារឿយៗ លើកលែងតែសមាជិកដែលមានឋានៈខ្ពស់បំផុតដូចជា ប៉ុល ពត នួន ជា តាម៉ុក សុន សេន និង ខៀវ សំផន ជាដើម ដែលបានរក្សាសមាជិកភាពរបស់ខ្លួនពេញមួយរបបនោះ និងរហូតដល់ទសវត្សរ៍ឆ្នាំ១៩៩០ ។ សមាជិកកំពូលទាំងនោះមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធបំផុតជាមួយប្រតិបត្តិការរបស់ស-២១ ។[៩]

## ការរក្សាការសម្ងាត់នៅក្នុងមន្ទីរស-២១

ពួកមេដឹកនាំកម្ពុជាប្រជាធិបតេយ្យបានផ្តល់អាទិភាពខ្ពស់បំផុតដល់ការងាររបស់ស-២១ ក្នុងការការពារក្បាលម៉ាស៊ីនមជ្ឈិមបក្សរបស់ខ្លួន ។ អនុលេខាធិការបក្សកុម្មុយនិស្តកម្ពុជា នួន ជា (បងធំទី២) បានពន្យល់គណៈប្រតិភូដាណឺម៉ាកមួយក្រុមដែលមានសមានចិត្តនឹងកម្ពុជាប្រជាធិបតេយ្យ ហើយដែលបានមកបំពេញទស្សនកិច្ចនៅខែកក្កដា ឆ្នាំ១៩៧៨ ថា «យើងត្រូវតែការពារក្បាលម៉ាស៊ីនដឹកនាំឲ្យបាន ទោះជាត្រូវលះបង់

អ្វីក៏ដោយ ។ ប្រសិនបើយើងបាត់បង់សមាជិកតែនៅសល់អ្នកដឹកនាំយើងអាចបន្តយកជ័យជម្នះបាន... ។ ការបាត់បង់សមាជិក២០០ឬ៣០០នាក់មិនអាចប្រៀបនឹងការបាត់បង់មេដឹកនាំពីរឬបីនាក់បានទេ ។ យើងសុខចិត្តបាត់បង់សមាជិក២០០ឬ៣០០នាក់ តែយើងមិនឲ្យបាត់បង់មេដឹកនាំពីរបីនាក់ឡើយ ។ បើពុំដូច្នេះទេ បក្សនឹងគ្មានអ្នកដឹកនាំ និងពុំអាចដឹកនាំការប្រយុទ្ធបានឡើយ» ។[៦] នាដើមឆ្នាំ១៩៧៨ ព្រឹត្តិបត្រផ្សព្វផ្សាយទ្រឹស្តីរបស់បក្ស «ទង់បដិវត្ត» ក៏បានបង្ហាញអំពីគោលជំហរដូចគ្នានេះដែរ ដោយបានសរសេរក្នុងបទវិចារណកថារបស់ខ្លួនថា «អន្តរាយរបស់មជ្ឈិមបក្សជាអន្តរាយធំណាស់... ។ យើងត្រូវការពារក្បាលម៉ាស៊ីនដឹកនាំឲ្យបានដាច់ខាត ។ បើសិនយើងអាចការពារបាន គឺយើងអាចការពារអ្វីៗបានទាំងអស់» ។[៧]

អត្ថិភាពនៃមន្ទីរស-២១ ទីតាំងមជ្ឈិមបក្ស និងអត្តសញ្ញាណនៃអ្នកធ្វើការនៅក្នុងនោះត្រូវបានបិទបាំងយ៉ាងជិតឈឹងក្នុងអំឡុងពេលនោះ ។ ក្នុងពេលពិភាក្សាជាមួយប្រតិភូដាណឺម៉ាក នួន ជា បានបញ្ជាក់ថា «កិច្ចការសម្ងាត់គឺសំខាន់ណាស់ ។ យើងលែងប្រើពាក្យ «ស្របច្បាប់» និង «មិនស្របច្បាប់»ទៀតហើយ ។ យើងប្រើពាក្យ «សម្ងាត់» និង «ចំហ» វិញ ។ កិច្ចការសម្ងាត់មានសារសំខាន់សម្រាប់អ្វីៗទាំងអស់ដែលយើងធ្វើ... ។ មានតែការសម្ងាត់ទេដែលធ្វើឲ្យយើងអាចគ្រប់គ្រងស្ថានការណ៍បាននិងយកឈ្នះសត្រូវដែលមិនដឹងថាយើងជានរណា» ។[៨] ក្នុងស-២១ សម្ងាត់គឺសំខាន់ជានិច្ច ។ នៅពាក់កណ្តាលឆ្នាំ១៩៧៦ មានអ្នកទោសម្នាក់បានរៀបចំគម្រោងការលួចរត់ចេញពីស-២១ ។ ឯកសារសិក្សាដែលបានធ្វើឡើងនៅក្នុងគុកនោះ បានពិពណ៌នាព្រឹត្តិការណ៍នេះដោយប្រកាសអាសន្នថា÷

> «ការសម្ងាត់ត្រូវបានគេទម្លាយហើយ និងការសម្ងាត់ដែលយើងបានបិទបាំងក្នុងរយៈពេលបីឬបួនខែចុងក្រោយនេះត្រូវបានគេដឹងអស់ ។ នៅពេលដែលគ្មានការសម្ងាត់ សន្តិបាលអាចនឹងរលាយបាត់រូបរាង ព្រោះពាក្យនេះបាត់អស់នូវអត្ថន័យរបស់វាហើយ... ។ ប្រសិនបើអ្នកទោសរត់រួច ពួកគេមុខជានឹងនិយាយអំពីការសារភាពរបស់ខ្លួនប្រាប់អ្នកដទៃ ។ ការសម្ងាត់របស់សន្តិបាលអាចត្រូវបានគេទម្លាយត្រង់ចំណុចដែលមិនគួរនឹងធ្លាយ» ។[៩]

ការសម្ងាត់ត្រូវបានថែរក្សាក្នុងស-២១ដោយការពារមិនឲ្យអ្នកខាងក្រៅមកជិត ការបណ្តេញអ្នករស់នៅជិតនោះចេញ ការកំហិតការចែកចាយឯកសារដែលបានចងក្រង ការដុតបំផ្លាញក្រដាសឯកសារជំនួសឲ្យការគ្រាន់តែគ្រវាត់វាចោល ការបិទមុខអ្នកទោសនៅពេលនាំពីកន្លែងមួយទៅកន្លែងមួយ និងការហាមឃាត់ការទាក់ទងគ្នារវាងក្រុមអ្នកសួរចម្លើយនិងក្រុមធ្វើឯកសារ និងការទាក់ទងរវាងក្រុមទាំងពីរនេះជាមួយបុគ្គលិកដែលមានឯកសិទ្ធិបន្តិចបន្តួច ។ អ្នកយាមត្រូវបានហាមឃាត់មិនឲ្យជជែកជាមួយអ្នកទោស ហើយអ្នកទោសត្រូវបានហាមឃាត់មិនឲ្យជជែកគ្នាឡើយ ។ អ្នកទោសដែលមានឋានៈខ្ពស់ត្រូវបានឃុំនិងសួរចម្លើយក្នុងអគារដោយឡែក ។ ការសួរចម្លើយស្ទើរតែទាំងអស់ត្រូវបានធ្វើឡើងនៅអគារខាងកើត ព្រោះជាកន្លែងដែលអ្នកទោសដទៃទៀតនិងបុគ្គលិកមិនអាចស្តាប់ឮ ។ ឯកសារនៅមន្ទីរស-២១មួយច្បាប់ ចុះ

ខែកញ្ញា ឆ្នាំ១៩៧៦ ដែលមានបញ្ជីឈ្មោះអ្នកយាមយប់និងថ្ងៃបានធ្វើការកត់សម្គាល់ថា អ្នកយាមមិនត្រូវបានអនុញ្ញាតឲ្យចូលក្នុងបន្ទប់សួរចម្លើយតាមអ្នកសួរចម្លើយឬ «បើកបង្អួចមើលខ្លាំង» ដែលកំពុងតែត្រូវសួរចម្លើយទេ។ រឿងដែលឃោរឃៅបំផុតនោះគឺគេរក្សាការសម្ងាត់របស់ស-២១ដោយការសម្លាប់អ្នកទោសស្ទើរតែទាំងអស់ ។[១០]

មានតែបុគ្គលិកឬអ្នកទោសជាឥស្សរជនមួយក្តាប់តូច និងកម្មាភិបាលទទួលបន្ទុកកិច្ចការសន្តិបាលប្រចាំតំបន់និងភូមិភាគប៉ុណ្ណោះ ដែលដឹងពីអត្ថិភាពស-២១ ។ នៅពេលនិយាយខ្លីៗទៅកាន់កម្មាភិបាលក្រោមបង្គាប់ ប៉ុល ពត នួន ជា សុន សេន និង តាម៉ុក នៅឆ្នាំ១៩៧៨ មានឈ្មោះថា (បងទីមួយរហូតដល់បងទីបួន) បានចាត់ទុកអ្នកដែលខ្ទួនសួរចម្លើយ និងអ្នកដែលឆ្លើយសារភាពប្រព្រឹត្តបទល្មើសប្រឆាំងបដិវត្តន៍ថាជាខ្មាំងទីមួយ ។ មេដឹកនាំទាំងបួនពុំដែលនិយាយដល់ស-២១ ឬសន្តិបាលដោយចំឈ្មោះឡើយ ។

គ្មានឯកសារភ័ស្តុតាងដែលនៅសេសសល់ណាមួយអាចប្រាប់យើងថាសន្តិបាលត្រូវបានបង្កើតឡើងជាផ្លូវការនៅពេលណា ដោយហេតុអ្វី ដោយអ្នកណា និង ក្រោមមាគ៌ាដឹកនាំបែបណានោះទេ ។ បុព្វអង្គភាពនៃស-២១គឺមានក្នុងជួរកងទ័ពខ្មែរក្រហមក្នុងអំឡុងពេលសង្គ្រាមស៊ីវិលនៃប្រទេសកម្ពុជា (១៩៧០-១៩៧៥) ។ បុព្វអង្គភាពផ្ទាល់នៃស-២១ប្រហែលជាធ្វើប្រតិបត្តិការក្នុងតំបន់២៥ខាងជើងរដ្ឋធានីពីឆ្នាំ១៩៧៣ដល់ឆ្នាំ១៩៧៥ ។ នៅសម័យនោះ មនុស្សពីរនាក់ដែលពាក់ព័ន្ធយ៉ាងជិតស្និទ្ធនឹងប្រតិបត្តិការនោះគឺ សុន សេន ហៅបង៨៩ ហៅ ខៀវ (១៩៣០-១៩៩៧) និងអតីតគ្រូបង្រៀនម្នាក់ដែលជាកម្មាភិបាលថ្នាក់ក្រោមរបស់គាត់ទទួលបន្ទុកកិច្ចការសន្តិសុខឈ្មោះ កាំង ហ្គេចអ៊ាវ ហៅ ឌុច (កើតក្នុងអំឡុងឆ្នាំ១៩៤២) ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សុន សេន ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការពារប្រទេស និងសន្តិសុខជាតិ ។ សន្តិបាលជាការទទួលខុសត្រូវរបស់គាត់មួយដែរ ។ ចំណែក ឌុច វិញ ជាមេបញ្ជាការស-២១ផ្ទាល់ និងជាអ្នករាយការណ៍ជូន សុន សេន ។

## បុគ្គលិកនៅស-២១

ស-២១មានអង្គភាពធំៗបីៈ អង្គភាពសួរចម្លើយ អង្គភាពរៀបចំឯកសារ និង អង្គភាពការពារ ។ អង្គភាពរងទទួលបន្ទុករូបថតប្រតិបត្តិការក្រោមចំណុះអង្គភាពឯកសារ ។ អង្គភាពរងដទៃទៀតប្រតិបត្តិការក្រោមចំណុះអង្គភាពការពារដែលជាអង្គភាពធំជាងគេនៅក្នុងស-២១រួមមានៈ អង្គភាពរងទទួលបន្ទុកយាមអ្នកទោស អង្គភាពរងទទួលបន្ទុកបញ្ជូនអ្នកទោសចូលគុកនិងយកទៅសម្លាប់ អង្គភាពរងទទួលបន្ទុកផ្តល់សេវាពេទ្យបឋម និងអង្គភាពរងទទួលបន្ទុកភ័ស្តុភារ ។

សៀវភៅទូរស័ព្ទផ្ទៃក្នុងដែលមានសែសិបប្រាំមួយឈ្មោះ ជាមគ្គុទ្ទេសក៍សំខាន់ក្នុងទំនាក់ទំនងជាមួយកម្មាភិបាលកំពូលៗនៅស-២១ ។ សៀវភៅនេះត្រូវបានរៀបចំឡើងមុនខែវិច្ឆិកា ឆ្នាំ១៩៧៨ គឺមុនពេលអ្នកសួរចម្លើយម្នាក់ដែលមានឈ្មោះក្នុងសៀវភៅនោះគឺ ជា ម៉ៃ ត្រូវបានចាប់ខ្លួន ។[១១] សៀវភៅនេះមានឈ្មោះកម្មាភិបាលក្រុមក្តៅនៃអង្គភាពសួរចម្លើយចំនួនម្ភៃបួននាក់ កម្មាភិបាលនៅក្នុងអង្គភាពឯកសារចំនួន

បួននាក់ កម្មាភិបាលនៅក្នុងផ្នែកផ្សេង (រដ្ឋបាល) ចំនួនប្រាំនាក់ និងកម្មាភិបាលនៅក្នុងក្រុមពុំមានឈ្មោះដែលប្រហែលជាអ្នកសួរចម្លើយដែរចំនួនប្រាំមួយនាក់ ។

ក្នុងសៀវភៅទូរស័ព្ទ ងារដែលនៅពីមុខឈ្មោះនីមួយៗមានលក្ខណៈស្របនឹង «ប្រព័ន្ធបីលំដាប់ថ្នាក់» ។ «ប្រព័ន្ធបីលំដាប់ថ្នាក់» ជាប្រព័ន្ធមួយដែលគេប្រើក្នុងបក្សកុម្មុយនិស្តកម្ពុជា ។ តាមប្រព័ន្ធនេះសមាជិកបក្សឡើងឋានៈជាបន្តបន្ទាប់ពីសមាជិកសម្ព័ន្ធយុវជនកុម្មុយនិស្តកម្ពុជាទៅជាសមាជិកត្រៀម និងពីសមាជិកត្រៀមទៅជាសមាជិកពេញសិទ្ធិ ។ ឈ្មោះនៅក្នុងសៀវភៅទូរស័ព្ទត្រូវបានតម្រៀបទៅតាមវ័យ ។ ដំបូងជាឈ្មោះពេញចំនួនប្រាំបីដែលពុំមានដាក់ឋានៈពីមុខ ។ បន្ទាប់មកជាឈ្មោះចំនួនដប់ដែលមានដាក់រហស្សនាម «បង» ពីមុខ ។ រីឯប្រភេទចុងក្រោយ គឺសម្រាប់អ្នកដែលមានអំណាចធំជាងគេបំផុត ។ ទោះជា ឌុច មានអាយុត្រឹមតែជាងសាមសិបឆ្នាំក្តី ឯកសារមួយចំនួនបានផ្តល់នូវការគោរពចំពោះគាត់ខ្លាំងណាស់ដោយហៅគាត់ថា «តាឌុច» ។

ដោយបានរំដោះផុតពី«វណ្ណៈជិះជាន់»នាអតីតកាល សមាជិកបក្សកុម្មុយនិស្តកម្ពុជា និងបុគ្គលិកក្នុងគុកត្រូវបានដាក់ឲ្យគោរពតាមបទបញ្ញត្តិផ្សេងៗ ដែលការគោរពនេះមានភាពសាំញ៉ាំទៅតាមឋានានុក្រមនិងពិបាកយល់ដូចបទបញ្ញត្តិដែលយើងបានជួបប្រទះក្នុងសាលានៅថ្ងៃដំបូង ឬក្នុងពេលដែលទើបបួសជាព្រះសង្ឃ ។ នេះជាការប្រដូចដ៏ស័ក្តិសម ព្រោះ ឌុច និងសហការីរបស់គាត់ក្នុងអង្គភាពសួរចម្លើយធ្លាប់ធ្វើជាគ្រូបង្រៀនជាច្រើនឆ្នាំ ហើយបុគ្គលិកក្នុងគុកនេះស្ទើរតែទាំងអស់ជាក្មេងប្រុសជំទង់ដែលកាលពីសម័យមុនបដិវត្តន៍ វ័យនេះជាវ័យដែលត្រូវបួសជាសង្ឃ ។ លើសពីនេះទៅទៀតអ្នកមើលការខុសត្រូវគុកនេះត្រូវបានចាត់ទុកថា ជាអាណាព្យាបាលដែលគេត្រូវតែគោរពស្តាប់បង្គាប់ដោយឥតតវ៉ាដូចបព្វជិតព្រះពុទ្ធសាសនាដែរ ។ វិន័យរបស់ស-២១គឺយកការទន្ទេញបទបញ្ញត្តិទាំងឡាយជាមូលដ្ឋាន ។ វិន័យនេះនាំឲ្យមានការគោរពដ៏ខ្ពង់ខ្ពស់ និងការស្តាប់បង្គាប់ដោយឥតតវ៉ាចំពោះរដ្ឋអំណាច ។

ឋានានុក្រមនៃឈ្មោះក្នុងសៀវភៅទូរស័ព្ទបង្ហាញឲ្យឃើញថា ឌុច និងជំនិតរបស់គាត់ទាំងប៉ុន្មាន ពុំមានបំណងឬថាពុំមានលទ្ធភាពទាត់ចោលនូវការចាត់ថ្នាក់និងការគោរពរបស់សង្គមខ្មែរមុនបដិវត្តន៍ ដែលបដិវត្តន៍បានសន្យាថា បំផ្លាញចោលនោះទេ ។ ថ្នាក់ក្រោមពួកនេះក៏ពុំមានបំណងឲ្យរឿងបែបនេះកើតឡើងដែរ ។ អតីតអ្នកយាមម្នាក់ឈ្មោះ គក ស្រស់ បាននិយាយថា «ឌុច បានប្រាប់ខ្ញុំថា ខ្ញុំធ្វើការងារល្អ ។ ខ្ញុំក៏មានអារម្មណ៍ថាគាត់ចូលចិត្តខ្ញុំនិងជឿជាក់យ៉ាងប្រាកដថា ខ្ញុំនឹងមានជីវិតរស់នៅតទៅទៀត ព្រោះខ្ញុំត្រូវបានថ្នាក់លើសរសើរ» ។[១២]

យើងអាចធ្វើការពិនិត្យមើលអំពីការរស់នៅនិងអត្តចរិតដែលមានការគាបសង្កត់ផ្លូវចិត្តពីឋានានុក្រមរបស់ សុន សេន និង ឌុច មុនពេលដែលអ្នកទាំងពីរក្លាយជាអ្នកកាន់កាប់អង្គភាពផ្សេងៗក្នុងគុក ។

## សុន សេន

ក្នុងឆ្នាំ១៩៧៥ សុន សេន ជាបុរសម្នាក់រាងស្គម ពាក់វ៉ែនតាម៉្ញូប មានវ័យចំណាស់សែឬាយឆ្នាំ ដូច រដ្ឋមន្ត្រីក្រសួងការបរទេសរបស់របបកម្ពុជាប្រជាធិបតេយ្យ អៀង សារី ដែរ ។ សុន សេន កើតនៅក្នុង សហគមន៍កម្ពុជាក្រោមនៅក្នុងទឹកដីវៀតណាមខាងត្បូងដែលនៅទីនោះឪពុកម្ដាយរបស់ សុន សេន ជាម្ចាស់ ដីដែលមានជីវភាពសម្បូរធូរធារ ។ បន្ទាប់ពីផ្លាស់មកនៅទីក្រុងភ្នំពេញតាំងពីនៅវ័យកុមារ សុន សេន បានធ្វើ ឲ្យអ្នកផងចាប់អារម្មណ៍គាត់គ្រប់គ្នាដោយសារទេពកោសល្យក្នុងការរៀនសូត្ររបស់គាត់ ។ សុន សេន បាន ទទួលអាហារូបករណ៍ទៅសិក្សានៅប្រទេសបារាំងនៅក្នុងឆ្នាំ១៩៥០ គឺភ្លាមៗបន្ទាប់ពី សាឡុត ស ដែល ក្រោយមកត្រូវបានស្គាល់ថាជា (ប៉ុល ពត) ដែលបានទទួលអាហារូបករណ៍ដូចគ្នា ។ ជានិស្សិតសិក្សា អំពីទស្សនវិជ្ជានិងប្រវត្តិវិទ្យានៅទីក្រុងប៉ារីស សុន សេន បានចូលរួមនៅក្នុងបក្សកុម្មុយនិស្តបារាំងជាមួយ សាឡុត ស អៀង សារី និងនិស្សិតខ្មែរជាច្រើននាក់ទៀត ។ នៅពេលត្រឡប់មកមាតុភូមិវិញក្នុងឆ្នាំ១៩៥៦ សុន សេន បានចាប់ផ្ដើមអាជីពជាគ្រូបង្រៀន ហើយបានចូលរួមចំណែកនៅក្នុងចលនាកុម្មុយនិស្តកម្ពុជា សម្ងាត់ ។ នៅដើមទសវត្សរ៍ឆ្នាំ ១៩៦០ សុន សេន បានក្លាយទៅជានាយកការិយាល័យសិក្សានៃវិទ្យាស្ថាន គរុកោសល្យដែលជាផ្នែកមួយនៃសាកលវិទ្យាល័យភ្នំពេញ ។ សុន សេន ត្រូវបានបណ្ដេញចេញពីមុខ តំណែងនេះនៅឆ្នាំ១៩៦២ ដោយសារគាត់មានទស្សនៈប្រឆាំងនឹងស្ដេច សីហនុ ប៉ុន្តែត្រូវបានអនុញ្ញាតឲ្យ បន្តការបង្រៀនតទៅទៀត ។

ក្នុងឆ្នាំ១៩៦៣ បន្ទាប់ពី សាឡុត ស ត្រូវបានតែងតាំងជាលេខាបក្សកុម្មុយនិស្តដែលត្រូវបានរៀបចំ ឡើងវិញ សុន សេន បានចូលរួមជាមួយនឹង សាឡុត ស ជាសមាជិកគណៈកម្មាធិការមជ្ឈិម ដែលទើបតែ រុះរើរៀបចំសាជាថ្មី និងនៅលាក់មុខនៅឡើយ ។ ក្នុងឆ្នាំ១៩៦៤ សុន សេន ត្រូវបានបំពាក់បំប៉ន សតិអារម្មណ៍ឲ្យចេញពីរាជធានីដោយលាក់ខ្លួននៅក្នុងឃ្លុបខាងក្រោយនៃរថយន្តរបស់អ្នកការទូតចិនមួយរូប ហើយបានទៅចូលរួមជាមួយ សាឡុត ស និងសមាជិកកុម្មុយនិស្តមួយចំនួនតូចនៅក្នុងមូលដ្ឋានយោធា កុម្មុយនិស្តវៀតណាមដែលត្រូវបានស្គាល់ថាជា«មន្ទីរ១០០» ។ មន្ទីរនេះត្រូវរើចុះរើឡើងឆ្លងកាត់តាម ព្រំដែនកម្ពុជា-វៀតណាម អាស្រ័យទៅតាមការប្រែប្រួលនៃសភាពការណ៍សង្គ្រាមនៅវៀតណាម ។[១៣]

រហូតដល់ខែមេសា ឆ្នាំ១៩៧៥ ទើប សុន សេន បានត្រឡប់មកភ្នំពេញវិញ ។ ក្នុងរយៈពេលដប់ពីរឆ្នាំ នៅក្នុងព្រៃម៉ាគី សុន សេន បានចងមិត្តភាពជាមួយនឹងបុរសស្ត្រីជាច្រើន ដែលក្រោយមកបានក្លាយជា សមាសភាពមជ្ឈិមបក្ស ហើយភាគច្រើននៃអ្នកទាំងនោះគឺជាមនុស្សដែល សុន សេន ធ្លាប់បានស្គាល់នៅឯ ប្រទេសបារាំង ។ នៅពេលដែលការតស៊ូប្រដាប់អាវុធប្រឆាំង សម្ដេច សីហនុ ផ្ទុះឡើងនៅក្នុងឆ្នាំ១៩៦៨ សុន សេន បានក្លាយទៅជាមេបញ្ជាការក្នុងសមរភូមិប្រយុទ្ធ ។ ក្រោយនោះបន្តិច សុន សេន ក៏បានបង្ហាញ អំពីទេពកោសល្យរបស់គាត់នៅក្នុងប្រតិបត្តិការយោធានៅក្នុងសមរភូមិ ។ នៅត្រឹមដើមឆ្នាំ១៩៧២ សុន សេន បានក្លាយជាប្រធានអគ្គសេនាធិការ ។ សហសេវិករបស់ សុន សេន នៅក្នុងបក្ស ជួនកាលយល់ថា គាត់ជាមនុស្សដាច់ខាតនិងមានទស្សនៈដូចពួក«គហបតី»[១៤] ក៏ប៉ុន្តែនៅក្នុងខែសីហា ឆ្នាំ១៩៧៥ សុន សេន

ត្រូវបានប្រគល់ឲ្យទទួលខុសត្រូវលើកិច្ចការការពារនិងសន្តិសុខរបស់ប្រទេសកម្ពុជាទាំងមូល ។

ការទទួលខុសត្រូវថ្មីរបស់ សុន សេន រួមមានសន្តិបាល ។ សុន សេន ត្រួតពិនិត្យដំណើរការនានានៅក្នុងសន្តិបាលយ៉ាងជិតដល់បំផុត ។ សុន សេន បានអាននិងចារលើចម្លើយសារភាពជាច្រើនដែលធ្វើឡើងនៅក្នុងគុកនៃមន្ទីរស-២១ ហើយបានរៀបចំវគ្គសិក្សាសម្រាប់កម្មាភិបាលមន្ទីរស-២១ ដែលក្នុងនោះ សុន សេន បានពិភាក្សាពីគោលដៅនៃមន្ទីរស-២១ អំពីការសួរចម្លើយនិងការប្រើប្រាស់មធ្យោបាយធ្វើទារុណកម្មទៀតផង ។ ក្នុងចំណោមវគ្គសិក្សាទាំងនោះ មានសៀវភៅកំណត់ហេតុចំនួនបីដែលរៀបរៀងដោយកម្មាភិបាលនៅមន្ទីរស-២១ ត្រូវបានរកឃើញនិងបន្សល់ទុកដល់សព្វថ្ងៃ ។ សៀវភៅកំណត់ហេតុទាំងបីនោះបានបង្ហាញថា ចំណាប់អារម្មណ៍របស់ សុន សេន អំពីបញ្ហាប្រវត្តិសាស្ត្រដែលមានបណ្តុះនៅក្នុងចិត្តគំនិតរបស់គាត់កាលពីគាត់នៅប្រទេសបារាំង នៅតែបន្តរហូតដល់ពេលដែលគាត់ក្លាយជាមន្ត្រីជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ មិនខុសពីប្រជាជនកម្ពុជាជាច្រើនដែលបានកើតនៅប្រទេសវៀតណាមទេ សុន សេន ហាក់ដូចជាឆាប់មានទស្សនៈប្រឆាំងនឹងវៀតណាមយ៉ាងមុតស្រួច ។[១៥]

ឯកសារជាច្រើនដែលមានប្រសគល់ចេញពីមន្ទីរស-២១ ហើយដែលផ្ញើទៅកាន់មជ្ឈិមបក្សត្រូវបានឆ្លងកាត់ដៃ សុន សេន ហើយកំណត់ហេតុរាប់សិបទៀតដែលចារទៅឲ្យ សុន សេន និងធ្វើឡើងដោយ ឌុច ត្រូវបានបន្សល់ទុកដល់សព្វថ្ងៃនេះ ។ ការឆ្លើយតបរបស់ សុន សេន ជាច្រើនក៏បានបន្សល់ទុកមកដល់ពេលនេះដែរ ។ ឯកសារទាំងនេះបានបង្ហាញយ៉ាងលម្អិតអំពីការចាប់អារម្មណ៍ដែលជិតជាប់នៅក្នុងផ្នត់គំនិតនិងភាពជ្រុលនិយមនៃបដិវត្តន៍ដែលកំពុងមានសន្ទុះយ៉ាងខ្លាំងក្លា ។ យុន យ៉ាត ហៅ សមមិត្ត អាត ដែលជាប្រពន្ធរបស់ សុន សេន និងជាអតីតគ្រូបង្រៀនម្នាក់ដែរ បានធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹង សុន សេន ហើយធ្លាប់បានពិនិត្យចម្លើយសារភាពមួយចំនួនក្នុងចំណោមចម្លើយសារភាពទាំងនោះ ។ នៅក្នុងឆ្នាំ ១៩៧៥ និង១៩៧៦ សុន សេន បានប្រឹងប្រែងធ្វើការយ៉ាងខ្លាំង ដើម្បីកៀងគរអង្គភាពដែលមានមូលដ្ឋាននៅតាមតំបន់នានាដែលទើបបានឈ្នះសង្គ្រាមស៊ីវិលដាក់បញ្ចូលទៅក្នុងកងទ័ពជាតិតែមួយ ។ នៅក្នុងឆ្នាំ ១៩៧៧-១៩៧៨ សុន សេន ជាអ្នកទទួលខុសត្រូវក្នុងការប្រយុទ្ធជាមួយប្រទេសវៀតណាម ហើយគ្រប់គ្រងលើការធ្វើវិសុទ្ធកម្មកម្មាភិបាលដែល«មិនស្មោះត្រង់»នៅភូមិភាគបូព៌ា ។ នៅក្នុងប៉ុន្មានខែចុងក្រោយ មុនពេលរបបនេះត្រូវផ្តួលរំលំ គឺនៅពេលដែលសង្គ្រាមបានធ្លាក់ដល់សភាពដុនដាបយ៉ាងខ្លាំងនោះ សុន សេន ខ្លួនឯងក៏ធ្លាក់នៅក្រោមការសង្ស័យដែរ ។ ប្រសិនបើការលុកលុយដោយទ័ពវៀតណាមត្រូវបានពន្យារពេលម្តេះសមពេលនោះ សុន សេន ប្រហែលជាត្រូវបានជម្រុះចោលដោយ«បង១ខាងលើ» និងដោយស្ថាប័នដែលគ្មានវិប្បដិសារីរបស់គាត់បាត់ទៅហើយ ។[១៦] ក៏ប៉ុន្តែ សុន សេន បានរក្សាគុណភាពរបស់គាត់ឲ្យនៅនឹងបាន ហើយនៅក្នុងឆ្នាំ១៩៧៩ បានបន្តមុខនាទីជាមេបញ្ជាការកងកម្លាំងយោធាខ្មែរក្រហមដដែលបន្ទាប់ពីចលនានេះទទួលបរាជ័យ ។ បន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុងប៉ារីសនៅក្នុងឆ្នាំ១៩៩១ សុន សេន បានបង្ហាញមុខជា«តំណាងផ្លូវការ»នៃចលនាខ្មែរក្រហម ក៏ប៉ុន្តែនៅពេលដែលថ្នាក់លើរបស់គាត់សម្រេចធ្វើពហិការមិនចូលរួមក្នុងការបោះឆ្នោតដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិ សុន សេន ក៏បាត់

ស្រមោលពីក្រសែភ្នែកសាធារណជន ។ សុន សេន ពុំបានទទួលឋានៈជារដ្ឋមន្ត្រីក្រសួងការពារជាតិដូចកាលពីមុនឡើយ ។ នៅក្នុងករណីដ៏សាហាវបំផុតមួយនៃការស្វែងរកយុត្តិធម៌ក្រៅផ្លូវច្បាប់ សុន សេន និងប្រពន្ធរបស់គាត់ យុន យ៉ាត បានត្រូវប្រហារជីវិតក្រោមបញ្ជារបស់ ប៉ុល ពត នៅក្នុងតំបន់ភាគខាងជើងប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៩៧ ដោយចោទប្រកាន់ថាជា "ភ្នាក់ងារចារកម្ម" បម្រើឲ្យរបបភ្នំពេញ ។[១៧]

## ឌុច

កាំង ហ្គិចអ៊ាវ (ហៅ ឌុច) មេបញ្ជាការមន្ទីរស-២១ពេញមួយរយៈពេលនៃដំណើរការរបស់មន្ទីរនេះបានកើតក្នុងអំឡុងឆ្នាំ១៩៤២ នៅក្នុងត្រកូលគ្រួសារខ្មែរកាត់ចិនក្រីក្រមួយនៅក្នុងស្រុកកំពង់ចិន (ស្រុកស្ទោង) ខេត្តកំពង់ធំ ។ ដូចជា សុន សេន ដែរ ឌុច បានធ្វើឲ្យគេចាប់អារម្មណ៍ថា ជាក្មេងម្នាក់ដែលមានសមត្ថភាពខ្ពស់ផ្នែកបញ្ញា ។ តាមបទសម្ភាសន៍ជាមួយនឹងម្តាយរបស់ កាំង ហ្គិចអ៊ាវ នៅក្នុងឆ្នាំ១៩៨០ គាត់បានប្រាប់ឲ្យដឹងថា ខួរក្បាលកូនប្រុសរបស់គាត់គឺ "ជាប់តែនឹងសៀវភៅជានិច្ច" ។ ដោយមានការជួយជ្រោមជ្រែងពីអ្នកមានឥទ្ធិពលម្នាក់នៅក្នុងស្រុក កាំង ហ្គិចអ៊ាវ បានទទួលអាហារូបករណ៍ទៅសិក្សានៅវិទ្យាល័យព្រះស៊ីសុវត្ថិ ។ ក្នុងការប្រឡងបាក់ឌុបទូទាំងប្រទេសនៅក្នុងឆ្នាំ១៩៥៩ កាំង ហ្គិចអ៊ាវ បានជាប់លេខពីរក្នុងមុខវិជ្ជាគណិតវិទ្យា ។ មិត្តរួមថ្នាក់របស់ កាំង ហ្គិចអ៊ាវ ម្នាក់បានរំឭកឡើងវិញថា ក្នុងសម័យនោះ កាំង ហ្គិចអ៊ាវ គឺជាយុវជនវ័យក្មេងដែលប្រកាន់ខ្ជាប់នូវភាពខស្សាហ៍ព្យាយាមដោយពុំមានចាប់អារម្មណ៍ទៅលើការកម្សាន្តអ៊ីផ្សេង ឬលើបញ្ហានយោបាយទាល់តែសោះ ។[១៨]

ពីរបីឆ្នាំបន្ទាប់មកទៀត កាំង ហ្គិចអ៊ាវ បានចាប់យកអាជីពជាគ្រូបង្រៀនមុខវិជ្ជាគណិតវិទ្យានៅវិទ្យាល័យខេត្តកំពង់ធំ ។ សិស្សម្នាក់ក្នុងចំណោមអតីតសិស្សរបស់ កាំង ហ្គិចអ៊ាវ ទាំងអស់ ក្រោយមកបានរំឭកថា "កាំង ហ្គិចអ៊ាវ ត្រូវបានគេទទួលស្គាល់ចំពោះភាពច្បាស់លាស់ក្នុងការបង្រៀន ហាក់បីដូចជាគាត់ផ្តិតចម្លងនូវអត្ថបទទាំងមូលចេញពីខួរក្បាលរបស់គាត់ដាក់នៅលើក្តារខៀន" ។ សហការីម្នាក់ដែលរួមអាជីពជាគ្រូបង្រៀនផ្នែកជីវវិទ្យានៅឯវិទ្យាល័យនោះដែរ គឺជាមនុស្សម្នាក់ដែលមានរូបរាងខ្ពស់ស្រឡះជាងគេឈ្មោះ ម៉ម ណៃ (ហៅ ចាន់) ។ ក្នុងអំឡុងពេលប៉ុន្មានឆ្នាំក្រោយមកនៅពេលដែលបុរសទាំងពីរនេះបានក្លាយជាសមាជិកនៃបក្សកុម្មុយនិស្តកម្ពុជា កាំង ហ្គិចអ៊ាវ បានហៅ ម៉ម ណៃ មកធ្វើជាប្រធានអង្គភាពសួរចម្លើយនៅឯគុកនៃមន្ទីរស-២១ ។ កាំង ហ្គិចអ៊ាវ និង ម៉ម ណៃ ត្រូវបានដឹងតាមរយៈឯកសារដែលបានបន្សល់ទុកថាជាគ្រូបង្រៀនដែលមានលក្ខណៈសម្បត្តិឈ្លាសវៃ ម៉ឹងម៉ាត់ និងបានលះបង់ទាំងស្រុងទៅលើការងារ ។ លក្ខណៈទាំងនេះហើយដែលអ្នកទាំងពីរបានពាំនាំជាមួយនឹងខ្លួនទៅបម្រើគោលដៅផ្សេងនៅពេលដែលអ្នកទាំងពីរធ្វើការជាមួយគ្នានៅក្នុងគុក ។[១៩]

ក្នុងឆ្នាំ១៩៦៤ កាំង ហ្គិចអ៊ាវ បានទទួលមុខតំណែងនៅវិទ្យាស្ថានគរុកោសល្យបន្ទាប់ពី សុន សេន ចាកចេញទៅ ។ យោងទៅតាមសម្តីរបស់លោក នេត ប៊ុនអន ដែលជាមិត្តរួមថ្នាក់របស់ កាំង ហ្គិចអ៊ាវ នៅឯវិទ្យាល័យព្រះស៊ីសុវត្ថិ យុវជនវ័យក្មេងដែលពូកែខាងគណិតវិទ្យារូបនេះត្រូវបានអូសទាញឆ្ពោះទៅរក

លទ្ធិកុម្មុយនិស្តដោយនិស្សិតចិនមួយក្រុម ដែលបានចូលមកសិក្សាអក្សរសាស្ត្រខ្មែរនៅឯសាកលវិទ្យាល័យភ្នំពេញ ។ នៅឯសាកលវិទ្យាល័យ កាំង ហ្គិចអ៊ាវ មានការចាប់អារម្មណ៍និងទទួលការអប់រំនយោបាយដោយបុរសស្ត្រីវ័យក្មេងៗដែលសម្បូណ៌ទៅដោយទស្សនៈនិងការយកចិត្តទុកដាក់ដ៏ស្រួចស្រាល់ទៅលើលទ្ធិកុម្មុយនិស្ត ។ កាំង ហ្គិចអ៊ាវ មើលឃើញថា បុរសស្ត្រីវ័យក្មេងទាំងនោះនឹងដើរតួនាទីដ៏សំខាន់ក្នុងទំនាក់ទំនងកម្ពុជា-ចិន នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនិងបន្តពីរបបនេះទៅទៀត ។[២០]

បន្ទាប់ពីចាកចេញពីវិទ្យាស្ថានគរុកោសល្យ កាំង ហ្គិចអ៊ាវ បានបង្ហាត់បង្រៀនមួយរយៈខ្លីនៅឯវិទ្យាល័យជើងព្រៃនៅក្នុងខេត្តកំពង់ចាម ។ នៅទីនោះ គាត់បានណែនាំយ៉ាងហោចណាស់សិស្សម្នាក់ក្នុងចំណោមសិស្សរបស់គាត់ឈ្មោះ គី សុខហ៊ី ឲ្យចូលទៅក្នុងចលនាបដិវត្តន៍ ហើយក្រោយមកគាត់ក៏ត្រូវចាប់ខ្លួនដោយកងកម្លាំងប៉ូលិសរបស់ស្តេច សីហនុ ពីបទចោទប្រកាន់ថាជាជនកុម្មុយនិស្ត ។ កាំង ហ្គិចអ៊ាវ បានជាប់ឃុំដោយពុំមានការជំនុំជម្រះទោសអស់រយៈពេលជាច្រើនខែ ដែលជានីតិវិធីធម្មតាមួយសម្រាប់អ្នកទោសនយោបាយក្នុងជំនាន់នោះ ។ ក៏ប៉ុន្តែ គាត់បានរិះរកមធ្យោបាយដោយជោគជ័យក្នុងការដោះខ្លួនចេញពីគុកតាមរយៈការធ្វើអន្តរាគមន៍ពីអ្នកអាណាព្យាបាលរបស់គាត់កាលពីកុមារភាព ។ មិនយូរប៉ុន្មាន បន្ទាប់ពីសម្តេច សីហនុ ត្រូវផ្តួលរំលំពីអំណាច កាំង ហ្គិចអ៊ាវ ហៅ ឌុច បានរត់ចូលព្រៃម៉ាគី ។

នៅដើមទសវត្សរ៍ឆ្នាំ១៩៧០ កាំង ហ្គិចអ៊ាវ ដែលត្រូវបានស្គាល់ថាជា ឌុច បានទទួលខុសត្រូវផ្នែកសន្តិសុខនៅតំបន់៣៣ ភាគខាងជើងទីក្រុងភ្នំពេញ ។ លោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ ដែលជាអ្នកជំនាញផ្នែកជាតិពន្ធត្រូវបានចាប់ខ្លួនដោយពួកទ័ពព្រៃកុម្មុយនិស្តនៅក្នុងតំបន់៣៣នេះ ក្នុងអំឡុងឆ្នាំ១៩៧០ ។ ឌុច ធ្លាប់បានសួរចម្លើយលោក ហ្វ្រង់ស្វ័រ ម្តងហើយម្តងទៀតសាចុះសាឡើងអស់រយៈពេលពីរខែ ដោយចោទប្រកាន់លោក ហ្វ្រង់ស្វ័រ ថាជាភ្នាក់ងារសេ.អ៊ី.អា ហើយបានបង្ខំឲ្យគាត់សរសេរជីវប្រវត្តិលម្អិតជាច្រើនលើកមុនពេលដោះលែង ។ លោក ហ្វ្រង់ស្វ័រ បានរួចចេញមកដោយមានការតក់ស្លុតចំពោះភាពឯប់ឯុលរបស់ឌុច ។ នៅក្នុងទស្សនៈរបស់លោក ហ្វ្រង់ស្វ័រ «ឌុច ជឿថា ជនទាំងឡាយណាដែលមានទស្សនៈផ្សេង គឺជាជនក្បត់និងជាជនភូតភរ ។ ឌុច ខ្លួនឯងគឺជាអ្នកវាយអ្នកទោសដែលមិនព្រមប្រាប់នូវការពិត» ។[២១]

ក្នុងឆ្នាំ១៩៧៣ ឌុច បានផ្លាស់មកតំបន់២៥ ភាគខាងជើងទីក្រុងភ្នំពេញវិញ ។ ថ្នាក់លើរបស់ ឌុច ឈ្មោះ សុក ធួក (ហៅ វ៉ន វ៉េត) គឺជាយុទ្ធិកជនកុម្មុយនិស្ត ចាប់តាំងពីទសវត្សរ៍ឆ្នាំ៥០មកម្ល៉េះ ។ សុក ធួក ត្រូវបានប្រហារជីវិតនៅមន្ទីរស-២១ក្នុងឆ្នាំ១៩៧៨ ។ នៅក្នុងឆ្នាំ១៩៧៣ សុន សេន ជាអនុ របស់ សុក ធួក ទទួលបន្ទុកកិច្ចការយោធា ។ បន្ទាប់ពីការប្រហារជីវិត សុក ធួក, ឌុច ប្រហែលជាបានទទួលការចាប់អារម្មណ៍ចូលចិត្តយ៉ាងខ្លាំងពីសំណាក់ សុន សេន ។ ក្នុងរយៈកាលបំពេញការងារកន្លងមក ឌុច បានទទួលបទពិសោធន៍ខាងបញ្ហាសន្តិសុខបានយ៉ាងច្រើន ។ ពុំមានភស្តុតាងបង្ហាញថា ឌុច ធ្លាប់ធ្វើដំណើរទៅបរទេស ឬទទួលការបណ្តុះបណ្តាលណាមួយពីអ្នកជំនាញបរទេសទេ ។ នៅចន្លោះឆ្នាំ១៩៧២ និងឆ្នាំ១៩៧៣ ឌុច ប្រហែលជាជួយបង្កើតនូវសញ្ញាណនៃ“ខ្មែរក្បត់” ។ នៅក្នុងចន្លោះពេលនោះ កិច្ចប្រតិបត្តិការសម្ងាត់មួយត្រូវបានបង្កើតឡើងដោយពួកខ្មែរក្រហមដើម្បីធ្វើវិសុទ្ធកម្មក្រុមដែលហៅថា ខ្មែរហាណូយ (ខ្មែរដែល

មកពីភាគខាងត្បូងនៃប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧០ បន្ទាប់ពីការនិរទេសខ្លួនឯងទៅប្រទេសវៀតណាមខាងជើងអស់រយៈពេលជាច្រើនឆ្នាំក្នុងរូបភាពជួយបដិវត្តន៍) ។ សមាជិកខ្មែរក្រុមនេះរាប់រយនាក់ត្រូវបានចាប់ខ្លួនជាសម្ងាត់និងយកទៅសម្លាប់ចោលក្នុងឆ្នាំ១៩៧៣ បន្ទាប់ពីវៀតណាមដកទ័ពរបស់ខ្លួនទាំងស្រុងចេញពីកម្ពុជា ។ សមាជិកនៅសេសសល់ពីរ-បីនាក់បានសម្រេចជោគជ័យក្នុងការគេចខ្លួនទៅប្រទេសវៀតណាមបន្ទាប់ពីការជាប់ឃុំឃាំង ហើយសមាជិកដទៃទៀតត្រូវបានចាប់ខ្លួនបន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥ ។ សមាជិកភាគច្រើននៃក្រុមនេះត្រូវបានចាប់ខ្លួននៅក្នុងភូមិភាគពិសេស ។ ភាពដាច់ខាត និងភាពគ្មានមេត្តានៃយុទ្ធនាការធ្វើវិសុទ្ធកម្មនេះមានការទាក់ទងគ្នាជាមួយនឹងរបៀបគ្រប់គ្រងរដ្ឋបាលរបស់ ឌុច ដែរ ។ តាមពិត យុទ្ធនាការនេះបង្ហាញអំពីដំណើរដូចគ្នាដែលប្រព្រឹត្តទៅនៅមន្ទីរស-២១ ។[២២]

កិច្ចការសន្តិបាលត្រូវបានផ្ទេរនិងផ្លាស់មករដ្ឋធានីភ្នំពេញ បន្ទាប់ពីខ្មែរក្រហមទទួលបានជ័យជម្នះក្នុងខែមេសា ឆ្នាំ១៩៧៥ ប៉ុន្តែអស់រយៈពេលជាច្រើនខែក្រោយមក អង្គភាពនេះបានស្ថិតនៅក្រោមឈ្មោះមន្ទីរ១៥ ។ ចំណាររបស់ ឌុច ទំនងជាមាននៅលើឯកសារជាច្រើនដែលមានប្រភពចេញមកពីមន្ទីរនេះ ។[២៣] ឯកសារដំបូងបំផុតដែលភ្ជាប់ ឌុច ទៅនឹងមន្ទីរស-២១ មានកាលបរិច្ឆេទតាំងពីខែតុលា ឆ្នាំ១៩៧៥ តរហូតមក ។ នៅក្នុងរយៈពេល៦ខែបន្ទាប់មកទៀត ឌុច បានចែករំលែកពេលវេលារបស់ខ្លួនដើម្បីធ្វើការគ្រប់គ្រងមន្ទីរសន្តិបាលមួយនៅតាខ្មៅ ភាគខាងត្បូងទីក្រុងភ្នំពេញ និងមណ្ឌលសួរចម្លើយជាច្រើនទៀត ដែលនៅរាយពាសពេញទូទាំងទីក្រុងភ្នំពេញ ។ មន្ទីរសន្តិបាលនៅតាខ្មៅឈ្មោះថា ស-២១ខ មានទីតាំងនៅក្នុងបរិវេណមន្ទីរពេទ្យវិកលចរិត (ពេទ្យឆ្កួត) តែមួយគត់របស់ប្រទេសកម្ពុជា ។[២៤]

ជាអ្នកគ្រប់គ្រងមន្ទីរស-២១ ឌុច បានខំប្រឹងប្រែងធ្វើការយ៉ាងសកម្មដើម្បីគ្រប់គ្រងរាល់កិច្ចការទាំងអស់របស់មន្ទីរនេះ ។ បទពិសោធន៍និងសភាវគតិឈ្លាសវៃដែលបានបណ្តុះតាមរយៈការបង្រៀន បានជួយសម្រួលកិច្ចការរបស់ ឌុច យ៉ាងខ្លាំង ។ ឌុច ធ្លាប់ធ្វើកិច្ចការចុះបញ្ជី កត់ត្រាផ្សេងៗ ដាក់ចេញនូវចម្លើយដោះស្រាយបញ្ហាទាំងឡាយ ទទួលការគោរព និងដាក់វិន័យអប់រំមនុស្សជាច្រើនក្រុម ។ ឌុច បានកំណត់ខ្លួនឯងនិងអ្នកនៅក្រោមបង្គាប់ឲ្យប្រឹងធ្វើការយ៉ាងខ្លាំង ។ ហ៊ឹម ហ៊ុយ ដែលជាអតីតអ្នកយាមនៅមន្ទីរស-២១ បានរំឭកឡើងវិញថា «ឌុច ជាមនុស្សខ្លាំង ច្បាស់លាស់ និយាយអីធ្វើហ្នឹង ។ ជារឿយៗ ឌុច ធ្វើឲ្យបុគ្គលិកនៅក្នុងមន្ទីរស-២១ភ័យខ្លាចញ័រខ្លួន» ។ នៅពេលដែលសួរថាតើ ឌុច ជាមនុស្សមានចរិតយ៉ាងដូចម្តេច កងការពារម្នាក់បានឆ្លើយថា «មនុស្សយ៉ាងម៉េចអ្ហែះ? ឌុច គឺជ្រុលហួសហេតុតែម្តង» ។ នៅក្នុងគំនិតរបស់កងការពាររូបនេះ ភាពសាហាវឃោរឃៅបំផុតនៃឧក្រិដ្ឋកម្មរបស់ ឌុច គឺមិនមែនដោយសារ ឌុច ជាអ្នកនៅពីលើការបញ្ជាឲ្យយកអ្នកទោសចំនួនប្រមាណដប់បួនពាន់នាក់ទៅសម្លាប់នោះទេ ប៉ុន្តែភាពដ៏សាហាវបំផុតគឺពេលដែល ឌុច អនុញ្ញាតឲ្យអ្នកនៅក្រោមបង្គាប់យកប្អូនថ្លៃរបស់ខ្លួនពីរនាក់ ទៅដាក់នៅមន្ទីរស-២១ និងយកទៅសម្លាប់ចោល ។ អតីតកងការពារគុកនេះ បានរំឭកឡើងវិញថា «ឌុច មិនដែលសម្លាប់អ្នកណាដោយផ្ទាល់ទេ» ប៉ុន្តែជួនពេលខ្លះ ឌុច បើកឡានទៅវាលពិឃាតនៅជើងឯក ដើម្បីពិនិត្យមើលការប្រហារជីវិតនៅទីនោះដោយផ្ទាល់ខ្លួនឯងតែម្តង ។[២៥]

សំណួរនិងចំណារជាច្រើនដែលសរសេរយ៉ាងស្អាតដោយ ឌុច ដោយប៊ិកពណ៌ក្រហម ត្រូវបានឃើញនៅលើចម្លើយសារភាពជាវៀយៗ ។ ជាញឹកញាយ ចំណារនិងការចោទសួរដែល ឌុច ធ្វើឡើងច្រើនតែកែតម្រូវឬបញ្ជាក់ការសង្ស័យទៅលើអ្វីដែលអ្នកទោសបានសារភាព ជូនយោបល់ឲ្យវាយដំធ្វើទារុណកម្ម និងជំរុញឲ្យអ្នកសួរចម្លើយជីកឫសជីកគល់រក«ការពិត»ដែលអ្នកទោសបានលាក់ ។ មិនតែប៉ុណ្ណោះ ឌុច បានធ្វើសេចក្តីសង្ខេបលើឯកសារចម្លើយសារភាពមួយចំនួនដោយបានចង្អុលបង្ហាញពីខ្សែបណ្តាញដែល ឌុច ក្តាប់បានពីចម្លើយសារភាពមុនៗ ហើយជូនយោបល់ឲ្យធ្វើការតាមដានខ្សែបណ្តាញនោះ ។ សេចក្តីរៀបរាប់សង្ខេបដែលត្រូវបានសរសេរឡើងនៅក្នុងឆ្នាំ១៩៧៨ មានចំណងជើងថា «ផែនការចុងក្រោយ» មានបំណងចងក្រងនូវចម្លើយសារភាពក្នុងរយៈកាលប្រាំពីរឆ្នាំកន្លងមក ដើម្បីបង្ហាញអំពីការសមគំនិតក្នុងទ្រង់ទ្រាយធំនិងយូរអង្វែងដែលពាក់ព័ន្ធទៅនឹងសហរដ្ឋអាមេរិក សហភាពសូវៀត តៃវ៉ាន់ និងវៀតណាម ។ ដូចក្នុងករណីលោក ជេម ជេសុីស អាន់គ្លេថុន នៃក្រុមសេ.អុី.អា ឌុច បានព្យាយាមតាំងខ្លួនប្រើប្រាស់គំនិតនេះក្នុងការស្រាវជ្រាវរកជនបង្កប់ក្នុងអង្គការ ។ ជាអ្នកគណិតវិទ្យា ឌុច ចូលចិត្តយកមកធ្វើជាគំរូនូវអ្វីដែលខ្លួនគិតថាសមហេតុសមផល ។ «ផែនការចុងក្រោយ» គឺជាសៀវភៅគំរូមួយ របស់ ឌុច ។[៧៦]

ឌុច រស់នៅក្បែរមន្ទីរស-២១ជាមួយប្រពន្ធនិងកូនតូចៗពីរនាក់ ។ ឌុច ស្ថិតនៅមន្ទីរស-២១រហូតដល់ល្ងាចថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ នៅពេលដែល ឌុច ដើរចេញពីក្រុងភ្នំពេញហើយក៏បាត់ស្រមោលរហូតដល់ពេលថ្មីៗនេះ ។ ក្នុងឆ្នាំ១៩៩៦ ឌុច លែងនៅក្នុងចលនាខ្មែរក្រហមទៀតហើយ ។ ឌុច បានជួបជាមួយនឹងក្រុមផ្សព្វផ្សាយសាសនាគ្រិស្តជនជាតិអាមេរិកនៅភាគពាយ័ព្យប្រទេសកម្ពុជា ហើយក៏ក្លាយខ្លួនជាអ្នកប្រតិបត្តិសាសនាគ្រិស្តម្នាក់ ។ ឌុច ធ្វើការជាអ្នករៀបចំសណ្តាប់ធ្នាប់នៅមន្ទីរពេទ្យមួយកាលពីខែមេសា ឆ្នាំ១៩៩៩ នៅពេលដែលអ្នកកាសែតម្នាក់បានរកឃើញអត្តសញ្ញាណពីអតីតកាលរបស់គាត់ ។ ក្រោយមក ឌុច ត្រូវបានសម្ភាសដោយអ្នកកាសែតអាមេរិកាំង ណេត ថាយ័រ ហើយក៏បាននិយាយជាចំហអំពីអតីតកាលរបស់ខ្លួនមុនពេលដែលត្រូវចាប់ខ្លួនដោយកងកម្លាំងនគរបាលជាតិកម្ពុជា និងយកមកដាក់ពន្ធនាគារ នៅទីក្រុងភ្នំពេញ ។[៧៧]

## ជំនួយការរបស់ ឌុច

អនុប្រធានរបស់ ឌុច នៅមន្ទីរស-២១គឺ ឃឹម វ៉ាត (ហៅ ហ៊ី) ជាយុទ្ធជនម្នាក់មានអាយុប្រហែលម្ភៃប្រាំឆ្នាំ ដែលបានបម្រើជាប្រធានអង្គភាពការពាររបស់មន្ទីរស-២១ស្របពេលដែល ឌុច ជាប្រធានស្ថាប័ននេះ ។ ហ៊ី បានកើតនិងធំដឹងក្តីនៅព្រែកតូចភាគខាងត្បូងរាជធានីភ្នំពេញ ហើយបានចូលបដិវត្តន៍តាំងពីវ័យជំទង់នៅក្នុងឆ្នាំ១៩៦៦ ។ នៅក្នុងកងពលទី១១ (ក្រោយមកប្រែក្លាយទៅជាកងពលលេខ៧០៣) ហ៊ី បានបាត់បង់ភ្នែកម្ខាងនៅក្នុងការប្រយុទ្ធមួយ ។ ហត្ថលេខារបស់ ហ៊ី ត្រូវបានឃើញនៅលើបញ្ជីនាំអ្នកទោសចូលនិងបញ្ជីយកទៅសម្លាប់ជាច្រើន ។ ក្នុងឆ្នាំ១៩៧៨ ជារឿយៗ ហ៊ី បានធ្វើការរួមគ្នាជាមួយនឹង ចាន់ ដើម្បីសួរចម្លើយឈ្លើយសឹកជាជនជាតិវៀតណាម ។ ហ៊ី ជាមនុស្សកាចសាហាវដែលធ្វើឲ្យអ្នក

នៅក្រោមបង្គាប់របស់ខ្លួនមានការខ្លាចរអាជាខ្លាំង ។ គក ស្រស់ ដែលជាអតីតអ្នកយាមម្នាក់ក្នុងចំណោមអ្នកយាមនៅមន្ទីរស-២១ បានរំឭកថា៖

> ខ្ញុំមានការភ័យខ្លាច ហ៊ី យ៉ាងខ្លាំង ។ នៅពេលដែលខ្ញុំមើលមុខវា ហ៊ី មើលទៅកាចមែនទែន ។ ប្រសិនបើ ហ៊ី ចេញសេចក្តីណែនាំដល់យើងហើយយើងធ្វើខុស ហ៊ី មកវាយតប់យើងផ្ទាល់ដៃតែម្តង ។ ប្រសិនបើយើងនិយាយអ្វីខុស វានឹងវាយយើង ។ យើងត្រូវតែប្រយ័ត្ននៅពេលដែលយើងនិយាយ អ្វីដែលយើងនិយាយត្រូវតែនិយាយឲ្យចំចំណុច ។ ខ្ញុំដឹងថា ហ៊ី គឹងរ៉ឹងខ្លាំងណាស់ ដូច្នេះ ខ្ញុំតែងតែមានការប្រយ័ត្នប្រយែងជានិច្ច ។[២៨]

គ្មានឯកសារបញ្ជាក់អំពីការផ្លាស់ប្តូរនិងមុខនាទីរបស់ ហ៊ី បន្ទាប់ពីឆ្នាំ១៩៧៩ទេ ។ អនុរបស់ ហ៊ី ឈ្មោះ ប៉េង ក៏ចេញមកពីស្រុកដូចគ្នានឹង ហ៊ី ដែរ ហើយបានធ្វើជាយុទ្ធជនជាមួយនឹង ហ៊ី នៅក្នុងកងពលលេខ ៧០៣ ។ ប៉េង ជាកូនកាត់ខ្មែរ-ចិន កើតនៅក្នុងឆ្នាំ១៩៥០ ។ នៅមន្ទីរស-២១ ប៉េង ជាបញ្ជាការលើអ្នកយាម ។ មិនតែប៉ុណ្ណោះ ប៉េង ជាអ្នកកត់ត្រាចំនួនអ្នកទោសចេញចូលបញ្ជូនទៅដាក់នៅតាមបន្ទប់តូចធំនៅក្នុងគុកទៀតផង ។ យោងតាមសម្តី ខៀវ ល ជាអតីតអ្នកយាមថា ប៉េង «កាន់សោគ្រប់បន្ទប់ទាំងអស់» ។ ប៉េង ធ្វើរបាយការណ៍ទៅឲ្យ ឌុច ដែលជាអ្នកសម្រេចថាតើត្រូវសួរចម្លើយ ធ្វើមិនដឹង មិនឮ ឬក៏យកទៅសម្លាប់ចោល ។ ប៉េង រួមដំណើរជាមួយ ឌុច នៅក្នុងពេលដែល ឌុច ដើរមើលគុកហើយបំពេញនាទីជាអង្គរក្សរបស់ ឌុច ថែមទៀតផង ។ វ៉ាន់ ណាត ខ្លាច ប៉េង ខ្លាំងណាស់ ។ វ៉ាន់ ណាត ហៅ ប៉េង ថាជា «មេឃាតករវ័យក្មេងដ៏សាហាវ» រហូតដល់គាត់ពុំហ៊ានមើលមុខរបស់ ប៉េង ផង ។ នៅក្នុងចម្លើយជាសាក្សីរបស់ អ៊ឹង ប៉ិច ពេលដែលតុលាការកាត់ទោស ប៉ុល ពត អៀង សារី នៅក្នុងឆ្នាំ១៩៧៩ គាត់បានហៅ ប៉េង ថាជាមនុស្ស «សាហាវព្រៃផ្សៃ» ជាពាក្យពុំដែលបានប្រើសម្រាប់និយាយដល់បុគ្គលិកដទៃទៀតនៃមន្ទីរស-២១ នៅក្នុងតុលាការនេះទេ ។ ប៉េង ហាក់ដូចជាត្រូវបានបញ្ចុះឋានៈនៅក្នុង ឆ្នាំ១៩៧៨ នៅពេលដែលភារកិច្ចរបស់ ប៉េង ត្រូវប្រគល់ទៅ ហ៊ឹម ហ៊ុយ វិញ ។ ប៉ុន្តែយោងទៅតាម គក ស្រស់ ថា ប៉េង បានរួចរស់ជីវិតផុតពីការវាយលុករបស់កងទ័ពវៀតណាម ហើយបានស្លាប់នៅភាគនិរតីប្រទេសកម្ពុជានៅទសវត្សរ៍ឆ្នាំ១៩៨០ ។[២៩]

បន្ទាប់ពី ឌុច, ហ៊ី និង ប៉េង មនុស្សដ៏សំខាន់បំផុតនៅមន្ទីរស-២១ប្រហែលជា ចាន់ ដែលជាប្រធានអង្គភាពសួរចម្លើយ ។ ក្រៅពីកិច្ចការជាគ្រូបង្រៀនរបស់ ចាន់ នៅក្នុងទសវត្សរ៍ឆ្នាំ៥០ យើងពុំបានដឹងអ្វីផ្សេងទៀតអំពីជីវិតរបស់ ចាន់ មុនពេលនេះឡើយ ។ ការដែល ចាន់ និយាយភាសាវៀតណាមបានយ៉ាងរអិលដែលកម្រនឹងមាននៅក្នុងចំណោមជនកម្ពុជាបង្ហាញថា ចាន់ កើតនិងធំដឹងក្តីនៅប្រទេសវៀតណាម ។ ចាន់ មកដល់មន្ទីរស-២១ជាមួយនឹង ឌុច នៅក្នុងឆ្នាំ១៩៧៥ ហើយធ្វើការនៅទីនោះរហូតដល់ពេលកងទ័ពវៀតណាមលុកលុយចូលមក ។ ឆ្នាំ១៩៩០ ចាន់ នៅធ្វើការជាមួយនឹងខ្មែរក្រហមជាអ្នកសួរចម្លើយដដែល ។ អ្នកកាសែតឈ្មោះ ណេត ថាយ័រ ដែលបានឃើញ ចាន់ សួរចម្លើយអ្នកទោសនៅពេលនោះ

រំពុកថា ចាន់ «មានចរិតមើលទៅគួរឲ្យខ្លាចបំផុត» ដែលគាត់មិនដែលបានជួបប្រទះពីមុនមក ។ មន្ត្រីអង្គការសហប្រជាជាតិបានប្រទះឃើញ ចាន់ ម្តងទៀតនៅក្នុងឆ្នាំ១៩៩៦ ។ ពេលនោះ ចាន់ ធ្វើការដូចជាពាក់កណ្តាលចូលនិវត្តន៍ មានតួនាទីជាអ្នកថែសួននៅផ្សារមួយ ។[៣០]

អនុប្រធានរបស់ ចាន់ គឺអតីតគ្រូបង្រៀនគណិតវិទ្យាម្នាក់ឈ្មោះ ទង់ សេងហ៊ន ហៅ ប៉ុន ជាកូនខ្មែរកាត់ចិនមកពីតំបន់២៥ ដែលធ្វើការនៅក្រោម ឌុច នៅក្នុងអំឡុងសង្គ្រាមស៊ីវិល ។ ទង់ សេងហ៊ន បានធ្វើការបម្រើឲ្យសន្តិបាលតាំងតែពីខែកក្កដា ឆ្នាំ១៩៧៥ មកម្ល៉េះ ។ នៅក្នុងអង្គប្រជុំស្វ័យទិតៀនមួយនាមន្ទីរ ស-២១កាលពីខែធ្នូ ឆ្នាំ១៩៧៦ ប៉ុន បានថ្លែងពីការស្អប់ខ្ពើមជីវប្រវត្តិវណ្ណៈ «អនុធនកណ្តាល» របស់ខ្លួន ហើយសារភាពថា ជារឿយៗខ្លួនតែងតែ«អត្តទត្តបុគ្គល»នៅក្នុងការគិតគូរ និងសារភាពទៀតថា ដោយសារតែខ្លួនប្រឹងប្រែងធ្វើការលើបញ្ហាសន្តិបាលច្រើនពេក រហូតដល់ពុំបាន«កសាងខ្លួន» ឬក៏រៀនសូត្រឲ្យបានច្រើនពី«មហាជន» ។ ឯកសារនោះបញ្ចប់ទៅវិញដោយមានកសិណសាក្សីដ៏កក់ក្តៅអំពីការងាររបស់ ប៉ុន នៅឯមន្ទីរស-២១ ពីសំណាក់ ចាន់ និង ឌុច ។[៣១]

ប៉ុន ជាអ្នកសួរចម្លើយអ្នកទោសសំខាន់ៗជាច្រើនរួមមាន កែវ មាស ណៃ សារ៉ាន់ ហ៊ូ នឹម ទីវ អុល និង កោក ឆាយ ។ ឯកសារជាច្រើនទៀតដែលចុះហត្ថលេខាដោយ ប៉ុន ភ្ជាប់ជាមួយនឹងការសួរចម្លើយ ទាំងនេះច្រើនស្នើសុំឲ្យធ្វើទារុណកម្មឲ្យបានខ្លាំង ។ នៅក្នុងកិច្ចប្រជុំស្វ័យទិតៀនជារៀងរាល់ពីរសប្តាហ៍ម្តង ដែលធ្វើឡើងនៅក្នុងមន្ទីរស-២១នៅឆ្នាំ១៩៧៨ បុគ្គលិកនៅទីនេះអះអាងថា «ខ្លួនខ្លាច» ប៉ុន ដែលរិះគន់ខ្លួនឯងពីមូលហេតុដែលពុំបាន «ដើរតាមមហាជន» ។ ពាក្យ «មហាជន» នេះប្រហែលជាពាក្យប្រើជំនួសឲ្យ របៀបផ្តាច់ការពីថ្នាក់លើមកថ្នាក់ក្រោមរបស់ ប៉ុន ។[៣២]

ក្រុមឯកសារមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងក្រុមសួរចម្លើយក្រោមការដឹកនាំរបស់ សួស ធី ដែលជាអតីតកងទ័ពមានអាយុប្រមាណម្ភៃប្រាំឆ្នាំប៉ុណ្ណោះ នៅក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ ។ សួស ធី មកពីស្រុកដូចគ្នាជាមួយនឹង ហ៊ី និង ប៉េង ដែរ ។ សួស ធី បាន «ចូលបដិវត្តន៍»នៅក្នុងខែសីហា ឆ្នាំ១៩៧១ ។ សួស ធី បានធ្វើការជាមួយ ហ៊ី នៅក្នុងកងពលលេខ៧០៣ មុនពេលចូលមកធ្វើការនៅមន្ទីរស-២១ នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៥ ។ នៅក្នុងប្រវត្តិរូបស្វ័យទិតៀនផ្ទាល់ខ្លួន សួស ធី បានអះអាងថា ខ្លួនបានក្លាយជាជនបដិវត្តន៍មួយរូបក៏ដោយសារខ្លួន «ខឹងសម្បាចំពោះពួកចក្រពត្តិ ពួកមានអភ័យឯកសិទ្ធិនិងពួកមូលធនដែលបានជិះជាន់កេងប្រវ័ញ្ចប្រជាជនក្រីក្រ» ។ សួស ធី បានសារភាពថា ក្នុងចំណោម«កង្វះខាតរបស់ខ្លួនគឺ សួស ធី ចូលចិត្តទៅមើលកុន ចូលចិត្តសើច ឈ្លោះជាមួយបងប្អូន និងឆាប់ខឹង» ប៉ុន្តែ សួស ធី និយាយថា គុណធម៌របស់ខ្លួនគឺ«មានសុឆន្ទៈធ្វើគ្រប់កិច្ចការទាំងអស់ដើម្បីបម្រើបក្ស» ។ សួស ធី បានរួចរស់ជីវិតរហូតមកដល់ទសវត្សរ៍ឆ្នាំ១៩៩០ ។ ក្នុងឆ្នាំ១៩៩០ អ្នកកាសែតបានជួបសម្ភាសជាមួយ សួស ធី ចំនួនពីរដង ។ នៅពេលដែលត្រូវសួរថា មានការ«សោកស្តាយ»ឬទេ ដែលមកធ្វើការនៅមន្ទីរស-២១ សួស ធី ឆ្លើយថា ខ្លួនមានការសោកស្តាយជាខ្លាំងចំពោះការកាប់សម្លាប់មនុស្សភាគច្រើនជាកុមារនិងស្ត្រី ។ «តាមពិត មនុស្សមួយចំនួនពុំមានកំហុសអ្វីទាល់តែសោះ» ។ ចំណុចមួយទៀតនៅក្នុងបទសម្ភាសន៍នោះសួស ធី ច្រើននិយាយយ៉ាង

ជាងបទសម្ភាសន៍លើកមុន ។ សួស ធី និយាយថា «នៅពេលដែលគេឲ្យការងារអ្នកឯងធ្វើ អ្នកឯងត្រូវតែធ្វើ» ។[៣៣]

នៅក្នុងចំណាត់ប្រភេទ «ដាច់ដោយឡែក» ក្នុងសៀវភៅទូរស័ព្ទមានឈ្មោះ «បងហ៊ុយ» ក៏ត្រូវបានចុះនៅក្នុងបញ្ជីសៀវភៅទូរស័ព្ទនោះរួមជាមួយ ឌុច, ប៉ុន និង ចាន់ ដែរ ។ បុរសពីរនាក់មានឈ្មោះដូចគ្នាគឺ «ហ៊ុយ» ធ្វើការនៅមន្ទីរស-២១ ក្នុងឆ្នាំ១៩៧៨ ។ ហ៊ុយ ដែលនៅក្នុងសៀវភៅទូរស័ព្ទនេះប្រហែលជា ហ៊ឹម ហ៊ុយ ជាកសិករ «ថ្នាក់កណ្តាលក្រោម» ដែលពិពណ៌នាដោយខ្លួនឯងថាមកពីតំបន់២៥ និងបានក្លាយជាយុទ្ធជនខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧២ ។ ការសន្និដ្ឋានបែបនេះដោយសារ ហ៊ឹម ហ៊ុយ បានសរសេរនៅក្នុងប្រវត្តិរូបស៊ើបទិតៀនរបស់គាត់ផ្ទាល់ថា «ខ្លួនខ្មីមរអើមមូលធននិយមនិងពួកមានអភ័យឯកសិទ្ធិ» ។ ដោយធ្វើការនៅក្រោម ហ៊ី, ហ៊ឹម ហ៊ុយ បានទទួលរងរបួសនៅក្នុងការវាយលុកចុងក្រោយមកលើក្រុងភ្នំពេញ ។ ហ៊ឹម ហ៊ុយ បានចូលមកធ្វើការនៅមន្ទីរស-២១ នៅដើមឆ្នាំ១៩៧៧ ជាកងការពារ ហើយនៅក្នុងឆ្នាំ១៩៧៨ ហ៊ឹម ហ៊ុយ ជាអ្នកទទួលខុសត្រូវក្នុងការកត់ត្រាឯកសារអ្នកទោសចូលមកក្នុងមន្ទីរស-២១ និងអ្នកទោសដែលយកទៅសម្លាប់នៅជើងឯកដែលពីមុនជាភារកិច្ចរបស់ ប៉េង ។ នៅចុងឆ្នាំ១៩៧៨ ហ៊ុយ ជាអ្នកទទួលខុសត្រូវបញ្ជាសន្តិសុខនៅក្នុងគុកក្នុងលំដាប់ទីប្រាំបួទីប្រាំមួយនៅក្នុងខ្សែសង្វាក់នៃបទបញ្ជា ។ ហ៊ឹម ហ៊ុយ ធ្លាប់បានប្រាប់លោក ភីធ័រ ម៉ាយៀ (ដែលជាអ្នកស្រាវជ្រាវម្នាក់) ថា «គេសម្លាប់ប្រធានៗធំដទៃទៀត ហើយគេដំឡើងឋានៈខ្ញុំ» ។[៣៤]

នៅក្នុងបទសម្ភាសន៍ជាច្រើនជាមួយនឹងអ្នកកាសែតនិងអ្នកស្រាវជ្រាវជាន់ខ្ពស់ ចាប់តាំងពីឆ្នាំ១៩៨៥ មក ហ៊ឹម ហ៊ុយ បានសារភាពថា ខ្លួនបានដឹកអ្នកទោសជាច្រើនឡានទៅកាន់ជើងឯក និងបានសម្លាប់អ្នកទោសមួយចំនួន (នៅទីនោះ) ។ ហ៊ឹម ហ៊ុយ អះអាងថា បន្ទាប់ពីឆ្នាំ១៩៧៩ ខ្លួនត្រូវបានចាប់ដាក់គុកអស់រយៈពេល «មួយឆ្នាំ» ពីបទល្មើសទាំងអស់នេះ ។ ក៏ប៉ុន្តែ វ៉ាន់ ណាត ជាជនរងគ្រោះដែលរួចរស់ជីវិតពីមន្ទីរស-២១ នៅចាំថា ហ៊ុយ ជាសមាជិកដ៏ «សាហាវបំផុត» ក្នុងក្រុមប្រហារជីវិតដែលអមដំណើរតាមអ្នកទោសទៅជើងឯក ។ ជនរងគ្រោះដែលរួចរស់ជីវិតម្នាក់ទៀតនិយាយថា ហ៊ុយ ទទួលខុសត្រូវចំពោះការស្លាប់របស់អ្នកទោស «រាប់រយនាក់» ។ ការយល់ឃើញបែបនេះត្រូវបានបន្ថែមដោយ ញ៉ែម អេន និងបុគ្គលិកដទៃទៀតនៃមន្ទីរស-២១ ដែលបានជួបសម្ភាសជាមួយអ្នកកាសែតអង់គ្លេសម្នាក់នៅក្នុងទីក្រុងភ្នំពេញកាលពីឆ្នាំ១៩៩៧ ។ នៅក្នុងបទសម្ភាសន៍ជាច្រើន ហ៊ុយ បានបញ្ជាក់អំពីវិប្បដិសារីរបស់ខ្លួនជារឿយៗ ដោយនិយាយថា «ខ្ញុំពុំមានអារម្មណ៍ថាធ្វើការនៅមន្ទីរស-២១ ជាអ្វីដែលឪពុកម្តាយរបស់ខ្ញុំចង់ឲ្យខ្ញុំធ្វើនោះទេ» ។[៣៥]

ហ៊ុយ ទីពីរនៅមន្ទីរស-២១គឺ នុន ហ៊ុយ ហៅ «ហ៊ុយខ្ពស់» ឬ «ហ៊ុយស្រែ» ។ ហ៊ុយ ទីពីរនេះមើលការខុសត្រូវមន្ទីរ២៤ ជាការដ្ឋានគុកនៅព្រៃសដែលជាសាខានៃមន្ទីរស-២១ ។ នៅក្នុងការដឹកនាំមន្ទីរស-២១ ហ៊ុយខ្ពស់ គឺជាមនុស្សដ៏សំខាន់ម្នាក់ ។ ជាឧទាហរណ៍ ក្នុងឆ្នាំ១៩៧៦ ហ៊ុយខ្ពស់ ជាអ្នកមើលការខុសត្រូវវគ្គសិក្សាមួយចំនួនសម្រាប់សមាជិកក្រុមយុវជនកុម្មុយនិស្តកម្ពុជាដែលធ្វើការនៅមន្ទីរ២៤នេះ ។

ប្រពន្ធរបស់ ហ៊ុយខ្ពស់ ឈ្មោះ ប្រុក ខឿន ដែលជា «សមាជិកពេញសិទ្ធិ» នៃបក្សកុម្មុយនិស្តកម្ពុជា ធ្វើការពាក់កណ្តាលម៉ោងជាអ្នកសួរចម្លើយនៅគុកមន្ទីរស-២១ ។ ទាំងពីរនាក់ប្តីប្រពន្ធនេះត្រូវបានចាប់ខ្លួននៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ ។ ញ៉ែម អេន អះអាងថា ហ៊ុយខ្ពស់ ត្រូវបានចាប់ខ្លួនពីបទល្មើសផ្លូវភេទ (ខុសសីលធម៌) ប៉ុន្តែចម្លើយសារភាពរបស់ ហ៊ុយខ្ពស់ ពុំបាននិយាយអំពីបទល្មើសនោះឡើយ ។[៣៦]

## អ្នកសួរចម្លើយ

នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៦ ក្រុមអ្នកសួរចម្លើយមានយ៉ាងតិចដប់មួយក្រុម ដែលមួយក្រុមៗមានសមាជិកចំនួនប្រាំមួយនាក់ ។ មកដល់ពាក់កណ្តាលឆ្នាំ១៩៧៧ ក្រុមសួរចម្លើយត្រូវបង្រួញមកត្រឹមដប់ក្រុម ដែលក្នុងមួយក្រុមមានសមាជិកប្រាំមួយនាក់ ។ ក្រោយមកក៏បំបែកជាក្រុមតូចៗដែលមានសមាជិកបីនាក់ និងមានអ្នកមើលការខុសត្រូវតែម្នាក់ ។ ក្រុមនីមួយៗមានប្រធានម្នាក់ អនុប្រធានម្នាក់ជាអ្នកវិភាគឯកសារនិងសមាជិកម្នាក់ទៀត ហើយប្រព័ន្ធនេះត្រូវបានប្រើប្រាស់ជាទូទៅ ទាំងក្នុងសាខាបក្ស និងអង្គការផ្សេងៗទៀតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ មនុស្សទីបីដែលជួនកាលត្រូវបានចាត់ទុកជាឆ្មាំនោះអាចជាមនុស្សដែលទទួលការចាត់តាំងឲ្យមកធ្វើទារុណកម្ម ។ នៅត្រឹមឆ្នាំ១៩៧៨ អ្នកសួរចម្លើយភាគច្រើនធ្វើការនៅក្នុងក្រុមក្តៅដែលចាត់តាំងដោយអ្នកសួរចម្លើយជាន់ខ្ពស់ឈ្មោះ ពូ ដែលមិនទាន់មាននរណាម្នាក់ដឹងប្រវត្តិរូបនៅឡើយ ។ នៅក្នុងឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧ មានក្រុមសួរចម្លើយមួយក្រុមទៀតហៅថា «ក្រុមរង» (ក្រុមសួរស្ងួត) ដែលសមាជិករបស់ក្រុមនេះមិនត្រូវបានអនុញ្ញាតឲ្យធ្វើទារុណកម្មអ្នកទោសឡើយ ។ ក្រុមក្តៅនៅក្នុងចម្លើយសារភាពត្រូវបានហៅថា «ក្រុមកាច» ។ ក្រុមនេះមានសិទ្ធិធ្វើទារុណកម្មអ្នកទោសបាន ។ នៅឆ្នាំ១៩៧៨ តាមចម្លើយសារភាពនានាគ្មាននិយាយពី «ក្រុមស្ងួត» ឡើយ ប៉ុន្តែប្រហែលជាត្រូវដូរមកជាក្រុម«ត្រជាក់»ក៏មិនដឹង ។ «ក្រុមអង្កៀម» ដែលមានសមាជិកប្រាំបីនាក់ក្រោមការចាត់តាំងរបស់ឈ្មោះ ប្រាក់ ណន គឺជាអ្នកសួរចម្លើយមានបទពិសោធន៍ចាត់ចែងការងារណាដែលមានលក្ខណៈតឹងរ៉ឹងនិងសំខាន់ ។[៣៧]

នៅក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ យ៉ាងហោចណាស់ហាក់ដូចជាមានអ្នកសួរចម្លើយភេទស្រីម្នាក់ពោលគឺឈ្មោះ ប្រុក ខឿន ដែលជាប្រពន្ធរបស់ ហ៊ុយ ។ ប្រុក ខឿន មកពីក្រុម២៥ ហើយចាត់ទុកខ្លួនគាត់ថាជា «កសិករកណ្តាលថ្នាក់ក្រោម» ។ ខឿន បានសរសេរថា គាត់ចូលបដិវត្តន៍នៅឆ្នាំ១៩៧២ ដោយសារតែខ្លួនមានកំហឹងចំពោះ«ពួកវណ្ណៈកាន់អំណាចដែលជិះជាន់និងមើលងាយកសិករក្រ» ។ ក្រោយពីត្រូវបានផ្ទេរមកធ្វើការនៅមន្ទីរស-២១ និងក្រោយពីរៀបការជាមួយនឹង «ហ៊ុយស្រែ» ខឿន បានសារភាពថា បានធ្វើទារុណកម្មអ្នកទោសជាច្រើននាក់«ទាល់តែធ្វើការលែងកើត» ។ ក្រៅពីនេះក៏ប្រហែលជាមានអ្នកសួរចម្លើយភេទស្រីដទៃទៀត ។ អ៊ឹង ប៉ិច បានចាំឈ្មោះមនុស្សម្នាក់ដែលគាត់តែងតែ ដាក់ងារថា «អាយក្ស» ហើយឯកសារបានសរសេរថា គុន ជាប្រពន្ធរបស់កម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហម ដែលត្រូវចាប់ខ្លួនដំណាលគាត់(អ៊ឹង ប៉ិច) ហើយដែលត្រូវបានសួរចម្លើយដោយស្ត្រីពីរនាក់ឈ្មោះលី និង ខុន ។ ប៉ុន្តែបើតាម

កិច្ចសម្ភាសន៍ជាមួយឈ្មោះ គក ស្រស់ បានឲ្យដឹងថា គ្មានអ្នកសួរចម្លើយភេទស្រីទេ ។[៣៨]

ភាគច្រើននៃអ្នកសួរចម្លើយនិងអ្នកធ្វើឯកសារ ធ្លាប់បានចូលរួមធ្វើសង្គ្រាមក្នុងអំឡុងឆ្នាំ១៩៧០-១៩៧៥ ដោយបម្រើការជានិរសាដែលជាការងារប្រកបដោយគ្រោះថ្នាក់និងគួរឲ្យគោរព ។ អ្នកសួរចម្លើយទាំងនេះច្រើនតែរៀននៅតាមសាលាបឋមសិក្សា ឬតាមវត្តអារាម ប្រហែលជាពីរបីឆ្នាំដើម្បីគ្រាន់តែអាចចេះចងចាំ ចេះគោរព និងចេះសរសេរប៉ុណ្ណោះ ។ ទាំងនេះគឺជាលក្ខណៈចាំបាច់សម្រាប់ធ្វើការនៅមន្ទីរ ស-២១ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការផ្លាស់ប្តូរពីការសិក្សាទៅការងារសង្គ្រាមនៅមន្ទីរស-២១ ដែលជាកន្លែងឲ្យតម្លៃទៅលើសតិអារម្មណ៍នយោបាយនោះ ពិតជាមានលក្ខណៈពិបាកណាស់សម្រាប់ក្មេងៗ ដូចដែលអតីតអ្នកសួរចម្លើយឈ្មោះ ម៉ា ម៉េងឃាង បានសារភាពថា៖

> គិតច្រើនពិបាកណាស់ ។ អ្នកឯងនឹងអស់កម្លាំងមែនទែននៅមន្ទីរស-២១ ហើយអ្នកនឹងឈឺក្បាលមិនខាន ហើយក្រៅពីនោះគឺជាការងារនយោបាយ ។ ធ្វើការនៅទីនោះមិនមែនជាការងាយស្រួលឡើយ ។ វាខុសពីការធ្វើស្រែនិងដាំដំណាំឬក៏ការធ្វើការនៅតាមរោងចក្រ ។ មិនដឹងជាដល់ថ្ងៃណាចប់ឡើយ ។ បើ"គ្រូវ"ក៏អ្នកឯងមិនដឹង ។ ប៉ុន្តែបើធ្វើស្រែវិញ អ្នកឯងដឹងថា មានគ្រាប់ពូជនិងមិនមានហើយនៅរោងចក្រអ្នកឯងដឹងថាម៉ាស៊ីនដើរឬមិនដើរ ។[៣៩]

ការងារសម្រាប់អ្នកសួរចម្លើយមានរយៈពេលវែងណាស់ ហើយគួរឲ្យអស់កម្លាំងទៀតផង ។ ការសួរចម្លើយប្រព្រឹត្តទៅរហូតដល់យប់ជ្រៅ ។ អ្នកសួរចម្លើយមិនពេញចិត្តចំពោះលក្ខខណ្ឌការងារដែលស្ថិតក្នុងការបង្កិតបង្កំបែបនេះឡើយ ហើយនិយាយថា បើប្រៀបធៀបទៅឃើញថាខុសគ្នាច្រើនណាស់ទៅនឹងសេរីភាពដែលខ្លួនធ្លាប់ទទួលបានកាលពីសង្គ្រាមស៊ីវិល ។[៤០]

## អ្នកធ្វើឯកសារ

សៀវភៅលេខទូរស័ព្ទមានឈ្មោះអ្នកធ្វើឯកសារចំនួនដប់បួននាក់ ប៉ុន្តែវាមិនមានអ្វីគួរឲ្យឆ្ងល់ឡើយ គឺនៅមានឈ្មោះច្រើនជាងនេះទៀត ហើយអ្នកដែលមានឈ្មោះនៅក្នុងតារាងនេះប្រហែលជាមើលការខុសត្រូវក្រុមឯកសារដែលមានសមាជិកបីៗនាក់ ។ ក្រុមឯកសារនេះទទួលខុសត្រូវខាងចម្លងឯកសារចម្លើយសារភាពចេញពីខ្សែអាត់ ឯកសារអត្ថលិខិត រៀបចម្លើយសារភាពសង្ខេបនិងចងក្រងឯកសារ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលឡើយ ដោយសារតែទាំងអស់គ្នាដឹងច្បាស់អំពីផលវិបាកនៃការ"បះបោរ" នោះកំហុសខាងកត់ត្រាស្ទើរតែគ្មានកើតឡើងទាល់តែសោះ ។ ផលវិបាកជាក់ស្តែងនៅក្នុងឆ្នាំ១៩៧៦និងឆ្នាំ១៩៧៨ យ៉ាងហោចណាស់មានបុគ្គលិកចំនួនដប់នាក់ត្រូវបានចាប់ខ្លួន សួរចម្លើយនិងធ្វើទារុណកម្មទាល់តែស្លាប់ ។ អ្នកទាំងដប់នាក់នោះសារភាពថាខ្លួន"ខ្ជិល"រៀបចំឯកសារ "ក្លែងបន្លំ" "ធ្វើឲ្យខូចម៉ាស៊ីន" និងវាយធ្វើបាបអ្នកទោសទាល់តែស្លាប់ ពេលដែលខ្លួនជួយសួរចម្លើយ ។[៤១]

ក្រុមថតរូបនៅមន្ទីរស-២១ស្ថិតនៅក្រោមការចាត់ចែងរបស់ សួស ធី ។ សមាជិកនៅក្នុងក្រុមនេះ មានមុខងារថតរូបអ្នកទោសពេលបញ្ជូនមកដល់ភ្លាម អ្នកទោសដែលស្លាប់ក្នុងលក្ខណៈជាឈ្លើយសឹកនិង អ្នកទោសសំខាន់ៗផ្សេងៗទៀតក្រោយពីត្រូវបានសម្លាប់ ។ តាមសម្តីរបស់ ញ៉ែម អេន ដែលធ្វើការនៅ ក្នុងក្រុមរូបថតនេះបានឲ្យដឹងថា រូបថតប្រភេទនេះ (រូបថតអ្នកទោសដែលត្រូវអារ-ក) គឺថតដោយក្រុម កម្មាភិបាលដែលត្រូវបានជ្រើសជាពិសេស ហើយរូបថតមួយច្បាប់ត្រូវបញ្ជូនឲ្យ«បងថ្នាក់លើ» ។ ក្រុម ថតរូបនេះក៏ផលិតរូបថតបុគ្គលិកប្រើក្នុងប័ណ្ណសម្គាល់ខ្លួនដែរ ។ រូបថតជាង៦.០០០សន្លឹក ដែលថតដោយ ក្រុមថតរូបនេះនៅរក្សារូបរាងមកដល់សព្វថ្ងៃ ។ រូបថតពាក់កណ្តាលខ្លួនជាច្រើនរយសន្លឹកដែលត្រូវបាន ជ្រើសរើសនិងពង្រីកដោយជាងថតរូបមកពីប្រទេសអាឡឺម៉ង់ខាងកើតក្នុងឆ្នាំ១៩៨១ ត្រូវបានបិទជាប់ នឹងជញ្ជាំងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងតាំងពីឆ្នាំ១៩៨០ មកម្ល៉េះ ។[៤២]

ក្រុមថតរូបបានប្រើប្រាស់ម៉ាស៊ីនថត ហ្វីល ក្រដាស និងសារធាតុគីមីសម្រាប់ផ្តិត ដែលពួកខ្លួនរក ឃើញតាមកន្លែងនានានៅក្នុងទីក្រុង ។ ញ៉ែម អេន ដែលផ្តាច់ខ្លួនពីខ្មែរក្រហមនៅឆ្នាំ១៩៩៦ ត្រូវបានអ្នក កាសែតសម្ភាសជាច្រើនលើកច្រើនសា ។ អេន ជាក្មេងអ្នកស្រែចម្ការម្នាក់មកពីខេត្តកំពង់ចាមដែលចូលធ្វើ ជាខ្មែរក្រហមក្នុងឆ្នាំ១៩៧០ ពេលខ្លួនមានអាយុដប់ឆ្នាំ ។ អេន ត្រូវបានជ្រើសរើសឲ្យទៅរៀនវិជ្ជាថតរូប នៅប្រទេសចិនក្នុងឆ្នាំ១៩៧៥-១៩៧៦ ហើយក្រោយមក ក៏មកធ្វើការនៅមន្ទីរស-២១ ។ មានខ្មែរ ចំនួនប្រាំនាក់ធ្វើការជាមួយ អេន ហើយម្នាក់ក្នុងចំណោមអ្នកទាំងនោះត្រូវបានបោសសម្អាត ។ អេន ខ្លួនឯង ផ្ទាល់ក៏ត្រូវស្ថិតក្រោមការសង្ស័យកាលពីរដូវវស្សាឆ្នាំ១៩៧៧ ដោយខ្លួនបានលេងវិទ្យុនិងថតរូបមិនបានល្អ ហើយបទល្មើសទាំងនេះគាត់ទើបរំឭកឡើងវិញម្ភៃឆ្នាំក្រោយមក ។ រូបថតមួយក្នុងចំណោមរូបថតទាំងអស់ ដែលគាត់បានថត និងត្រូវបានផ្តិតកាលពីគាត់ទៅទស្សនកិច្ចនៅប្រទេសចិនកាលពីខែតុលា ឆ្នាំ១៩៧៧ ជារូបរបស់ «បងធំទី១» ដែលមានស្នូកពណ៌នៅត្រង់ផ្នែកខាងលើភ្នែកម្ខាង ។ ចាន់ បានចោទ អេន ថាបានធ្វើ ឲ្យរូបថតនេះខូចក្នុងបំណងមើលងាយ ប៉ុល ពត ហើយពេលនោះ អេន ក៏ត្រូវបញ្ជូនទៅមន្ទីរកែប្រែដែល ស្ថិតនៅព្រៃស ។ អេន និយាយថា នៅដើមឆ្នាំ១៩៧៨ គាត់ក៏ត្រូវដោះលែងមកវិញ ។ ក្រោយមកទើប ចាន់ ឃើញស្នាមឆែបមួយកន្លែងនៅលើហ្វីលដើម ។[៤៣]

## ឆ្មាំសន្តិសុខ

ក្រុមការពារដែលមិនកត់ចូលទៅក្នុងសៀវភៅទូរស័ព្ទគឺជាក្រុមដែលធំជាងគេបង្អស់នៅគុកទួលស្លែង ។ នៅឆ្នាំ១៩៧៨ ក្រុមនេះមានសមាជិកចំនួន១៦៩នាក់ ។ ក្នុងចំណោមសមាជិកទាំងអស់មាន១២៧នាក់ ត្រូវបានទុកនៅកន្លែង ហើយអ្នកសល់ពីនោះដែលនៅក្បែរនឹងគុកពិសេសត្រូវបានចាត់តាំងទៅភាគខាង ត្បូងដែលជាកន្លែងកម្មាភិបាលជាន់ខ្ពស់ ។ ក្នុងឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧ ពួកសន្តិសុខត្រូវបានចែកចេញ ជាក្រុមយាមប្រាំមួយក្រុម ដែលក្នុងក្រុមនីមួយៗត្រូវយាមបួនម៉ោងក្នុងមួយថ្ងៃ ។ ប៉ុន្តែមកដល់ឆ្នាំ១៩៧៨ សន្តិសុខធ្វើការក្នុងក្រុមដែលមានសមាជិកដប់នាក់ត្រូវយាមប្រាំបីម៉ោង ។ កងសន្តិសុខទាំងអស់ត្រូវធ្វើតាម

បទបញ្ជាទូទៅមួយដែលមានសាមសិបចំណុច សរសេរឡើងដើម្បីឲ្យសន្តិសុខប្រុងប្រយ័ត្ននិងមិនឲ្យទាក់ទងជាមួយអ្នកទោស ។ បទបញ្ជាទាំងនោះបានតម្រូវឲ្យសន្តិសុខគុកមើលកុំឲ្យអ្នកទោសរត់រួច កាន់អាវុធ ធ្វើអត្តឃាត ឬនិយាយគ្នា ។[៤៤]

ឆ្មាំសន្តិសុខមិនត្រូវបានអនុញ្ញាតឲ្យជជែកលេងជាមួយអ្នកទោស សុំស្គាល់ឈ្មោះ ឬវាយអ្នកទោសឡើយ ប៉ុន្តែបើតាមសម្តីសារភាពរបស់អតីតឆ្មាំគុកម្នាក់បានឲ្យដឹងថាៈ «ប្រសិនបើអ្នកឯងកំពុងយាមពេលយប់ អ្នកឯងអាចវាយអ្នកទោសបានបើគ្មានអ្នកណាឃើញ» ។ គក ស្រស់ បាននិយាយថា ពេលឆ្មាំត្រូវហាមមិនឲ្យវាយអ្នកទោសនោះមានតែអ្នកវាយអ្នកទោសធ្ងន់ធ្ងរប៉ុណ្ណោះដែលត្រូវទទួលទណ្ឌកម្ម ។ លើសពីនេះទៀត «បើសិនអ្នកទោសមិនធ្វើតាមបញ្ជាយើង យើងអាចមានសិទ្ធិវាយបាន» ។ ចំពោះការជជែកគ្នាធម្មតាវិញ គក ស្រស់ បន្តថា÷

> យើងអាចនិយាយលេងជាមួយអ្នកទោស ប៉ុន្តែមិនអាចអាណិតអ្នកទោសទេ ។ មានអ្នកខ្លះបានសុំឲ្យយើងដោះលែង ប៉ុន្តែបើយើងធ្វើដូច្នេះយើងពិតជាត្រូវចូលជំនួសអ្នកដែលយើងដោះលែងនោះមិនខាន ។ អ្នកទោសខ្លះនិយាយថា «ខ្ញុំមិនបានធ្វើអ្វីខុសទេ ហេតុអ្វីបានជាអង្គការនាំខ្ញុំមកដាក់នៅទីនេះទៅវិញ?» ។ ពេលនោះខ្ញុំមិនដឹងជាធ្វើយ៉ាងម៉េចទេ ។ ខ្ញុំក៏បានប្រាប់អ្នកទោសទៅវិញថា ខ្ញុំខ្លាចណាស់ មិនហ៊ានជួយទេ ។[៤៥]

ឆ្មាំគុកក៏ត្រូវបានហាមមិនឲ្យមើល ឬលួចមើលការសួរចម្លើយដែរ ហើយត្រូវតែចាំជានិច្ចថា «ពេលយាម ឆ្មាំទាំងអស់មិនត្រូវលួចស្តាប់ ឬអង្គុយ ឬផ្អែកនឹងជញ្ជាំងទេ ។ ឆ្មាំត្រូវតែដើរមើលជុំវិញ ហើយពិនិត្យអ្វីៗគ្រប់យ៉ាងដោយប្រុងប្រយ័ត្នបំផុត» នេះជាបទបញ្ជាផ្ទៃក្នុងរបស់មន្ទីរស-២១ ។ ឆ្មាំគុកកម្រនឹងបានដេកពេញភ្នែកណាស់ ។ នៅក្នុងរបាយការណ៍ស្វ័យទិតៀន ឆ្មាំគុកភាគច្រើនបានរៀបរាប់ថា ខ្លួន«ងងុយដេកណាស់» ហើយនេះគឺជាកំហុសយ៉ាងធំប៉ះពាល់ដល់ការងាររបស់ខ្លួន ។ ការងាររាល់ថ្ងៃដែលត្រូវការយកចិត្តទុកដាក់ រួមមានការដឹកជញ្ជូនអាវុធ គ្រាប់រំសេវនិងដោះដូរច្រវាក់ខ្នោះឃ្នាងនិងសោគុក ។ លើសពីនេះក៏មានការផ្ទេរអ្នកទោសពីបន្ទប់របស់ខ្លួនទៅកន្លែងសួរចម្លើយនិងទៅជើងឯកដោយរថយន្តដែលប្រព្រឹត្តទៅប្រកបដោយលក្ខណៈប្រទាក់ក្រឡាសាំញ៉ាំ ។[៤៦]

បទបញ្ជាសម្រាប់ឆ្មាំគុកបានហាមមិនឲ្យមានអំពើមនុស្សធម៌ឡើយ ។ គោលជំហរនិងសតិអារម្មណ៍ខ្ពស់ត្រូវតែមានដាច់ខាតចំពោះអ្នកដែលទទួលខុសត្រូវនៅក្នុងក្រុម ។ ឯកសារស្វ័យទិតៀនមួយដែលរៀបចំឡើងនៅក្នុងមន្ទីរស-២១ កាលពីឆ្នាំ១៩៧៧ បានចោទប្រកាន់ឆ្មាំគុកមួយចំនួនថា «នាំគ្នាសើចនៅពេលទំនេរ» និង «ខ្វះគោលជំហរបដិវត្តន៍» ។ បទល្មើសដដែលៗនេះត្រូវបានរៀបរាប់នៅក្នុងប្រវត្តិស្វ័យទិតៀនដែលឆ្មាំគុកបានរៀបចំពីពេលមួយទៅពេលមួយ ព្រមទាំងមាននៅក្នុងចម្លើយសារភាពរបស់ឆ្មាំមួយចំនួន ។[៤៧] ញ៉ែម អេន បានរំឭកអំពីការលេងសើចសប្បាយរបស់ខ្លួនជាមួយអ្នកធ្វើការជាមួយគ្នាក្នុងក្រុម

ថតរូប ចំណែក គក ស្រស់ បាននិយាយអំពីចំណងមិត្តភាពដែលខ្លួនបានបង្កើតក្នុងរយៈពេលធ្វើការបីឆ្នាំនៅក្នុងគុក ។

## ល្បាចមួយនៅមន្ទីរស-២១

កាលពីដំបូង បទបញ្ជាសម្រាប់ឆ្មាំនៅមន្ទីរស-២១ មានលក្ខណៈមិនសូវជាតឹងតែងទេ ។ របាយការណ៍អំពីការឃោមការមសរសេរនៅខែតុលា ឆ្នាំ១៩៧៦ ដែលមានពត៌មានប្រហាក់ប្រហែលនេះដែរ គឺជាឯកសារតែមួយគត់ដែលកត់ត្រានូវការសន្ទនាគ្នារវាងឆ្មាំគុកនិងអ្នកទោស ។ របាយការណ៍នេះ បង្ហាញពីការទាក់ទងគ្នាធម្មតារវាងអ្នកទោសនិងឆ្មាំគុកព្រមទាំងកត់ត្រានូវឧទាហរណ៍មួយចំនួនស្ដីអំពីសេចក្ដីក្លាហាននិងការប្រឆាំងមានះរបស់អ្នកទោសនៅក្នុងចម្លើយសារភាពរបស់ខ្លួនដែលធ្វើឡើងដោយសារការធ្វើទារុណកម្ម[៤៨] ÷

### សេចក្ដីសង្ខេបដែលត្រូវបញ្ជូនទៅបងទទួលខុសត្រូវខាងក្រុមឆ្មាំ

#### I. ឆ្មាំគុកផ្ទៃក្នុង

##### ក) សកម្មភាពរបស់ខ្មាំង

◆ នៅអគារ «ក» បន្ទប់លេខ៥ អ្នកទោសឈ្មោះ ពុន សុផល បានប្រាប់ឆ្មាំថាមូសខាំខ្លាំងណាស់ ។

◆ នៅបន្ទប់លេខ៤ បន្ទប់តូចលេខ៣ អ្នកទោសឈ្មោះ ង៉ៃ យេត និយាយថាមិនបានដេកលក់ស្រួលទេក្នុងចន្លោះពេលថ្ងៃលិចដល់ម៉ោងពីរព្រឹក ។

◆ នៅបន្ទប់ក្រោមជណ្ដើរផ្នែកខាងលិច អ្នកទោសដែលដេកមិនលក់បានលួចមើលឆ្មាំនិងខ្សែភ្លើងញឹកញាប់ណាស់ ។

◆ នៅបន្ទប់ទី៥ បន្ទប់តូចលេខ៤ អ្នកទោសឈ្មោះ សុខ ហឿន ហៅ ហម បានរុញតុក្រសួរក្តុងក្តាំងដោយគ្មានប្រាប់ឆ្មាំ ។

◆ នៅបន្ទប់ទី៣ បន្ទប់តូចលេខ៤ អ្នកទោសឈ្មោះ ឃឹម គឿង និយាយរំខាននៅពេលដែលសមមិត្តយើងកំពុងចែកបបរថា ខ្លួនមិនទាន់បានហូបអ្វីឡើយ ហើយទើបតែមកពីធ្វើការងារ ។ ប៉ុន្តែតាមពិតវាមិនបានធ្វើការអ្វីទេ ព្រោះខ្នោះនៅជាប់ដៃវានៅឡើយ ។

◆ នៅផ្ទះបាយបន្ទប់លេខ៦ បន្ទប់តូចលេខ៣ មានអ្នកទោសចំនួន៤នាក់ឈ្មោះ ម៉ៅ ហុង, យូ ណន, ពុន លាង និង ឌី សុម៉ាត បានព្យាយាមបំបាក់សោរគ់ ។ អាម្នាក់នោះនិយាយថា «នេះមិនមែនជាកន្លែងអង្គការទេ ទីនេះជាកន្លែងផ្ទាល់ខ្លួន» ។ ម៉ៅ ហុង និយាយថា «កន្លែងនេះហើយដែលអង្គការបានចាប់ខ្ញុំ ហើយជាកន្លែងដែលខ្ញុំពិតជាស្លាប់ ពីព្រោះអង្គការនេះមានសមាសភាពជាពួកចោរព្រៃ» ។ នេះគឺជាសម្ដីរបស់ ម៉ៅ ហុង ដែលនិយាយទៅកាន់ឆ្មាំម្នាក់របស់យើង ។

◆ នៅអគារ«ខ» បន្ទប់លេខ៥ បន្ទប់តូចលេខ១០ ពេលដែលឆ្មាំគុកឲ្យអ្នកទោសឈ្មោះ សំ សារ៉ាវុធ សណ្តូកជើង អ្នកទោសនោះនិយាយថាវាមិនអាចដើររួចទេ ប៉ុន្តែពេលដែលឆ្មាំគុកចេញបាត់ វាក៏ដើរឈរឡើង ។

**ខ) កងវរសេនាតូចៗរបស់គុក**

កងវរសេនាតូចៗចំនួនបីនិងចម្ការដែលមានគុកនៅព្រៃស បានដំណើរការក្រោមការឧបត្ថម្ភគាំទ្រពីកងការពារ ។ នៅក្នុងក្រុមមួយមាន«អ្នកចាប់ចង»ចំនួនប្រាំបីនាក់ ពេលខ្លះហៅថា«និរសា» និងមានសមាជិកដប់នាក់នៅក្រុមផ្នែកយានយន្ត ។ តាមសម្តីរបស់ ញ៉ែម អេន បានឲ្យដឹងថា អ្នកចាប់ចងបានបណ្តើរអ្នកទោសពីជនបទទៅកាន់មន្ទីរស-២១ រួចហើយក៏សម្លាប់អ្នកទោសទាំងអស់ចោលភ្លាម រួមទាំងកម្មាភិបាលសំខាន់ៗដែលត្រូវសម្លាប់ ហើយយកមកកប់ចោលនៅក្បែរគុកនោះ ។ ការចងចាំរបស់ ញ៉ែម អេន ត្រូវបានបញ្ជាក់បន្ថែមដោយ គក ស្រស់ ។ នៅឆ្នាំ១៩៧៧ ឈ្មោះ ហ៊ីម ហ៊ុយ បានចូលធ្វើការនៅក្នុងកងនេះ ហើយទទួលបាននូវកេរ្តិ៍ឈ្មោះគួរឲ្យភ័យខ្លាចក្នុងចំណោមបុគ្គលិកដទៃទៀត ។ ក្រុមផ្នែកយានយន្តបានដឹកអ្នកទោសមួយក្រុមមកកាន់មន្ទីរស-២១ ហើយនាំយកអ្នកផ្សេងទៅសម្លាប់ចោលនៅបឹងជើងឯក ។

ក្រុមសេដ្ឋកិច្ចមានសមាជិកម្ភៃប្រាំមួយនាក់ដែលជាផ្នែកមួយនៃក្រុមការពារបានផ្តល់ជាអាហារហូបចុក និង សេវាផ្នែកគុកដល់ឆ្មាំគុក អ្នកសួរចម្លើយនិងអ្នកទោស ។ សមាជិកពីរនាក់ជាជាងកាត់សក់ និងប្រាំនាក់ដទៃទៀតទទួលខុសត្រូវខាងចិញ្ចឹមមាន់ ទា ទន្សាយ ជ្រូក និងដាំបន្លែនៅក្នុងបរិវេណគុក ។ ចំពោះ «អ្នកប្រមូលលាមក» នៅក្នុងក្រុមបានជួយសង់វាស់វែងនិងធ្វើការផ្នែកប្រព័ន្ធលូទឹកស្អុយផ្សេងៗ ។ ឆ្មាំនឹងត្រូវទទួលភារកិច្ចខាងលើទាំងនេះបើសិនជាខ្លួនប្រព្រឹត្តបទល្មើសធម្មតាមិនធ្ងន់ធ្ងរ ។[៥៥] លាមកត្រូវបានប្រមែប្រមូលដោយបន្ទុយកទៅធ្វើជី ។

មានបុគ្គលិកសេដ្ឋកិច្ចចំនួនប្រាំពីរនាក់ជាអ្នករៀបចំនិងចែកចាយអាហារដល់មនុស្សនៅក្នុងគុក ដែលមានចំនួនជាមធ្យមជាងមួយពាន់នាក់ឬក៏លើសពីនេះនៅចុងឆ្នាំ១៩៧៧និងដើមឆ្នាំ១៩៧៨ ។ មានបុគ្គលិកប្រាំមួយនាក់ផ្សេងទៀត បានធ្វើការងារប្រហាក់ប្រហែលគ្នានេះដែរចំពោះអ្នកសួរចម្លើយរាប់រយនាក់ និងបុគ្គលិកផ្នែកឯកសារ ហើយជាងសាមសិបនាក់ទៀតមើលខុសត្រូវឆ្មាំចំនួនប្រហែលពីររយនាក់ ។ នៅក្នុងរបាយការណ៍របស់ ឌុច ទាក់ទងនឹងការងារគុកក្នុងរយៈពេលបីខែដំបូងនៃឆ្នាំ១៩៧៧ បានសរសេរថា ខ្លួនបានចាត់តាំងឲ្យមានបណ្តាញតាមដានចំនួនប្រាំពីរដើម្បីរកមើលមាន់ទាដែលងាប់នៅក្នុងបរិវេណគុក ហើយពីរបណ្តាញទៀតធ្វើរបាយការណ៍អំពីអ្នកទោសដប់បួននាក់ដែលស្លាប់ដោយទារុណកម្ម ។ នៅក្នុងកន្លែងដែលហ៊ុមព័ទ្ធដោយកញ្ចក់នៃមន្ទីរស-២១ សត្វទាត្រូវបានកាន់ទុកលើសពីមនុស្សស្លាប់ទៅទៀត ។[៥៦]

ស្រូវរបស់មន្ទីរស-២១ឬប្រហែលជារបស់ក្រុមផ្សេងៗទៀតនៅក្នុងទីក្រុង ត្រូវបានដាំនៅព្រៃស ។ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ អ្នកដែលធ្វើខុសតិចតួចទាំងប្រុសទាំងស្រី ត្រូវបានដឹកពីអគ្គភាពរោងចក្រ និងការដ្ឋានជាច្រើននៅក្នុងទីក្រុងភ្នំពេញមកដាក់នៅគុកទួលស្លែង ។ យោងតាមឯកសារ

ដែលរៀបចំដោយ "ហ៊ុយស្រែ" នៅដប់ខែដំបូងនៃឆ្នាំ១៩៧៧ អ្នកទោសជាងពីរពាន់នាក់ ត្រូវបាននាំយកមកព្រៃស ។ ក្នុងនោះមានមួយរយកៅសិបពីរនាក់ដែលភាគច្រើនមានអាយុក្រោមម្ភៃឆ្នាំ បានស្លាប់ដោយសារជំងឺ ហើយមានប៉ែតសិបនាក់ផ្សេងទៀតរត់រួចពីគុក ។ ក្រោយមកក៏ត្រូវចាប់ខ្លួនបានចំនួនម្ភៃប្រាំពីរនាក់បញ្ជូនមកមន្ទីរស-២១វិញ ។ អ្នកទោសដែលនៅសល់ទាំងប៉ុន្មាន ប្រហែលជាត្រូវបញ្ជូនមកមន្ទីរស-២១តាមក្រោយជាបណ្តើរៗ ដែលក្នុងនោះក៏មានឈ្មោះ ញ៉ែម អេន និង ហ៊ីម ហ៊ុយ ដែរ ហើយអ្នកទាំងពីរនេះក៏ត្រឡប់មកកាន់ការងាររបស់ខ្លួនវិញក្រោយពីទទួលការដាក់ទោសមួយរយៈខ្លីនៅព្រៃស ។[៥១]

អន្តរាគមន៍ការពាររបស់ ហ៊ី ក៏មានភារកិច្ចមើលការខុសត្រូវការងារបុគ្គលិកពេទ្យចំនួន១៥នាក់ ដែលមើលព្យាបាលអ្នកទោសមានជំងឺដោយសារការវាយសួរចម្លើយ បិទមុខរបួសឲ្យអ្នកដែលមានរបួសធ្ងន់ធ្ងរ និងធ្វើសេចក្តីបញ្ជាក់អំពីការស្លាប់ ។ ពេទ្យម្នាក់ឈ្មោះ ភួង ជិវី ហៅ ភឿន បានតូញត្អែរនៅក្នុងចម្លើយសារភាពរបស់ខ្លួនថា នៅក្នុងមន្ទីរស-២១ មានបុគ្គលិកពេទ្យដែលបានហាត់រៀនជំនាញត្រឹមត្រូវតែបីនាក់ប៉ុណ្ណោះសម្រាប់ព្យាបាលអ្នកទោសរាប់ពាន់នាក់ ។ គាត់បន្តថា មិនអាចទៅរួចទេក្នុងការព្យាបាលអ្នកទោសក្នុងចំនួនច្រើនបែបនេះ ហើយមានអ្នកទោសច្រើនណាស់បានស្លាប់ ។ បុរសម្នាក់ដែលទទួលខុសត្រូវខាងផ្នែកពេទ្យឈ្មោះ ដេង ទ្រី ដែលក្រោយមកត្រូវចាប់ខ្លួន បន្ទាប់មកបានសារភាពនូវកំហុសប្រហាក់ប្រហែលគ្នានេះដែរនៅក្នុងសម័យប្រជុំស៊ុយទិតៀននាឆ្នាំ១៩៧៧ ដែលកាលនោះ ទ្រី ត្រូវបានចោទថា"មិនជឿពេទ្យបដិវត្តន៍" ។ ឯកសារនៅគុកទួលស្លែងបានសរសេរថា អ្នកទោសមួយចំនួនបានកើតជំងឺគ្រុនចាញ់ រាករូសស្គមរីងរៃ និងទទួលការធ្វើទុក្ខបុកម្នេញ ។ នៅក្នុងឯកសារមួយដែលមានរាយឈ្មោះមនុស្សចំនួនម្ភៃមួយនាក់ត្រូវស្លាប់ក្នុងរយៈពេលដ៏ខ្លីនោះ បានសរសេរថា មានប្រាំនាក់ស្លាប់ដោយ "របួស" និងម្នាក់ទៀតស្លាប់ដោយអំពើ"ទារុណកម្ម"ប្រកក្បាលនឹងថង់កៅស៊ូឲ្យថប់ដង្ហើម ។ មានអ្នកទោសចំនួនហាសិបពីរនាក់ ត្រូវបាននិយាយថាស្លាប់ដោយ"ជំងឺ"ក្នុងរវាងខែមេសានិងខែកញ្ញា ឆ្នាំ១៩៧៦ ជាពេលដែលគុកនេះដាក់មនុស្សចំនួនជិត៣០០នាក់ក្នុងមួយលើកៗ ។ សៀវភៅរបស់គម្មាភិបាលមួយក្បាលដែលសរសេរនៅឆ្នាំ១៩៧៧ បានសរសេរថា មានមនុស្សស្លាប់ចំនួន៣០នាក់នៅក្នុងខែកក្កដា ៨៨នាក់ នៅខែសីហា ៤៩នាក់នៅខែតុលា និង៦៧នាក់នៅខែវិច្ឆិកា ។ ជាសរុបមានអ្នកស្លាប់ចំនួន២៣៤នាក់ក្នុងរយៈពេលជាងបួនខែ ។ ភាគច្រើននៃអ្នកដែលស្លាប់ទាំងអស់គឺដោយសារការរងរបួស ការខ្វះជីវជាតិ និងការធ្វើទារុណកម្ម ។ រូបថតសាកសពជាច្រើននៅក្នុងបណ្ណសារដ្ឋានបានបង្ហាញឲ្យឃើញថា អ្នកទាំងនោះត្រូវស្លាប់ដោយសារកង្វះចំណីអាហារដ៏ធ្ងន់ធ្ងរបំផុត ។[៥២]

មានសៀវភៅសរសេរអំពីផ្នែកវេជ្ជសាស្ត្រជាច្រើនត្រូវបានរកឃើញនៅមន្ទីរស-២១ ប៉ុន្តែពុំមានដាក់ឈ្មោះគ្រូបង្រៀន សិស្ស និងមេរៀនឲ្យបានច្បាស់លាស់ទេ ។ កូនសៀវភៅសរសេរអាចដាក់ក្នុងហោប៉ៅបាន មានសរសេរថា ជួនកាល ពិសោធន៍ប្លែកៗត្រូវបានធ្វើឡើងដោយបុគ្គលិកពេទ្យ ដូចជាបង្ហូរឈាមអ្នកទោសរហូតទាល់តែស្លាប់ និងដាក់សាកសពទៅក្នុងអាងទឹកហើយរង់ចាំមើលថាតើយូរប៉ុនណាទើបសាកសពនោះអណ្តែតឡើង ។ នៅកន្លែងផ្សេងៗទៀតតាមជនបទ ជួនកាល មានការធ្វើពិសោធន៍វះកាត់

ដែលមានគ្រោះថ្នាក់ដល់ជីវិតទៅលើអ្នកទោសដែលត្រូវធ្វើឲ្យសន្លប់ដើម្បីធ្វើជាមេរៀនកាយវិភាគសាស្ត្រជាក់ស្តែង ដើម្បីបង្រៀនកម្មាភិបាលពេទ្យខ្មែរក្រហម ។ ពិសោធន៍បែបនេះអាចកើតមាននៅក្នុងមន្ទីរ ស-២១ ហើយមិនមែនជាការភ្ញាក់ផ្អើលឡើយ ប្រសិនបើរបាយការណ៍ទាំងនោះមិននៅសល់ទេនោះ ។[៥៣]

## ប្រវត្តិរបស់បុគ្គលិកមន្ទីរស-២១

តើមនុស្សធ្វើការនៅក្នុងអង្គភាពនានានៅក្នុងមន្ទីរស-២១ជាមនុស្សប្រភេទណា? ឌុច ចាន់ និង ប៉ុន ជាជនជាតិខ្មែរកាត់ចិន ។ ស្ថិតក្នុងវ័យសាមសិបឆ្នាំ ទាំងបីនាក់នោះធ្លាប់ធ្វើជាគ្រូបង្រៀន ។ អ្នកសួរចម្លើយជាន់ខ្ពស់ផ្សេងទៀត ឈ្មោះ បូ និង ទុយ ប្រហែលមានប្រវត្តិប្រហាក់ប្រហែលនេះដែរ ។ ភាគច្រើននៃអ្នកដែលស្ថិតនៅក្រោមបញ្ជារបស់អ្នកខាងលើនេះគឺសុទ្ធសឹងតែជាជនជាតិខ្មែរ ដែលមកពីតំបន់ជនបទដាច់ស្រយាល ។ មុនពេលចូលបដិវត្តន៍ក្នុងសង្គ្រាមស៊ីវិល បុគ្គលិកភាគច្រើននៅមន្ទីរស-២១ គឺជាសិស្សសាលាបឋមសិក្សា សាមណេរ ឬក៏អ្នកជួយសម្រាលការងារស្រែចម្ការឪពុកម្តាយរបស់ខ្លួន ។ មានមួយចំនួនតូចប៉ុណ្ណោះដែលរស់នៅទីក្រុងឬក៏ស៊ីឈ្នួលគេ ។

ក្នុងចំណោមបុគ្គលិកធ្វើការនៅមន្ទីរស-២១ចំនួន១៦៦នាក់ ដែលបានបំពេញប្រវត្តិរូបនៅក្នុងឆ្នាំ១៩៧៦ពេលដែលខ្លួនមកធ្វើការនៅក្នុងគុក មានបុគ្គលិក៤៤នាក់សរសេរថាខ្លួនជា“កសិករក្រីក្រ” ៩៩នាក់ជា “កសិករកណ្តាលថ្នាក់ក្រោម” ១៦នាក់ជា“កសិករកណ្តាល” ១នាក់ជា“កម្មករ” ហើយ៦នាក់ទៀតជា“វណ្ណៈអនុធន” ។ ប្រាំនាក់ចុងក្រោយពេលដែលចូលក្នុងជួរបដិវត្តន៍គឺជាសិស្សសាលាធម្មតា ។ ចំណែកម្នាក់ទៀតជាគ្រូបង្រៀន ។ ដោយឲ្យមានបុគ្គលិកប្រុសច្រើនជាងបុគ្គលិកស្រី ប្រវត្តិរបស់អ្នកធ្វើការនៅមន្ទីរ ស-២១ ដូចគ្នាទៅនឹងរចនាសម្ព័ន្ធវណ្ណៈនៅក្នុងសង្គមខ្មែរនៅជនបទមុនបដិវត្តន៍ដែរដែលក្នុងសង្គមនោះគ្រួសារភាគច្រើនមានកម្មសិទ្ធិដីធ្លី ហើយត្រូវបានចាត់ទុកជា“កសិករកណ្តាល” ។[៥៤]

ខ្មែរក្រហមក៏ដូចដៃគូរបស់ខ្លួននៅក្នុងលទ្ធិ ម៉ៅ របស់ចិន គឺឲ្យតម្លៃទៅលើការគ្មានបទពិសោធន៍ និងអវិជ្ជា ដោយចូលចិត្តអ្នកដែលមានលក្ខណៈដូចក្នុងឃ្លាមួយរបស់ ម៉ៅ និយាយថា “ក្រហើយស្អាតស្អំ” ជាងជនពុករលួយ នាយទុន ឬអ្នកដែលបានរៀនសូត្រជ្រៅជ្រះ ។ ដោយមានការសរសើរចំពោះគំនិត “ក្រហើយស្អាតស្អំ”នេះ ម៉ៅ បានអះអាងថា “ក្រដាសសសុទ្ធគ្មានទទួលនូវបន្ទុកអ្វីឡើយ ហើយអក្សរ ឬគំនូរស្អាតៗអាចត្រូវបានសរសេរឬគូរនៅលើក្រដាសសនោះ” ។ នៅក្នុងប្រទេសកម្ពុជា “បង១ថ្នាក់លើ” ជាអ្នកទទួលខុសត្រូវខាងធ្វើចំណារនៅលើក្រដាសនោះ ហើយ“បង១”ដែលមើលការខុសត្រូវនៅក្នុងគុកនឹងស៊ាំក្នុងការគោរពបញ្ជាដែលភាគច្រើនចម្លងមកពីការរៀនសូត្រជ្រៅជ្រះរបស់ខ្លួននៅតាមសាលារៀននោះ មានការពេញចិត្តណាស់ក្នុងការចម្លងគំនិតរបស់ខ្លួនទៅឲ្យអ្នកផ្សេងទៀត ។ អ្នកទាំងនោះបានជ្រើសរើសមនុស្សដែលមានការហ៊ឹកហ៊ឺនតិចតួចនិងមានការគោរពឱនលំទោនមកធ្វើជាអ្នកធ្វើការនៅក្រោមបញ្ជារបស់ខ្លួន ។[៥៥] ឌុច ចាន់ ហ៊ា និង ប៉ុន ពិតជា“បង១” ដែលមានវ័យចំណាស់ជាងកូនចៅភាគច្រើនរបស់ខ្លួនក្នុងចំណោមអ្នកចូលធ្វើការទាំងអស់ដែលបំពេញបែបបទធ្វើការនៅមន្ទីរស-២១ នៅឆ្នាំ១៩៧៦ មានតែម្តប្រាំនាក់

ប៉ុណ្ណោះដែលមានអាយុលើសពីម្ភៃប្រាំឆ្នាំ ។ ម្ភៃនាក់ស្ថិតនៅក្រោមអាយុដប់ប្រាំបីឆ្នាំ ។ មួយរយប្រាំបីនាក់មានអាយុចន្លោះដប់ប្រាំបីនិងម្ភៃពីរឆ្នាំ ។ គក ស្រស់ ដែលមានអាយុម្ភៃប្រាំឆ្នាំពេលមកដល់មន្ទីរស-២១ បាននិយាយថាអ្នកដែលត្រូវបានជ្រើសរើសមកធ្វើការងារនៅមន្ទីរស-២១នាពាក់កណ្ដាលឆ្នាំ១៩៧៧ មានវ័យក្មេងជាងអ្នកដែលត្រូវបានជ្រើសរើសមកធ្វើការកាលពីដំបូងយ៉ាងច្រើន ។

អ្នកធ្វើការថ្នាក់ក្រោមស្ទើរតែទាំងអស់នៅក្នុងគុកសុទ្ធតែមានវ័យក្មេងៗហើយនៅលីវ ។ តាមប្រវត្តិសាស្ត្រពិភពលោក បុរសជាភេទងាយនឹងត្រូវបានបួរទម្លាប់ និងងាយបួរទម្លាប់ដោយខ្លួនឯងណាស់ក្នុងការចាប់យកអាជីពថ្មីជាមួយអ្នកដទៃដែលមានវ័យប្រហាក់ប្រហែលគ្នា ។ ការហាមប្រាមក្នុងការធ្វើដំណើរ ការបម្រើយោធា ជីវិតផ្នែកសាសនា ការឆក់ប្លន់ ការធ្វើព្យុហយាត្រា ការធ្វើការងារជាអ្នកស៊ីឈ្នួល និងការសិក្សានៅសាកលវិទ្យាល័យ គឺជាសញ្ញាណនៃការឆ្លងកាត់ពីវ័យកុមារមកវ័យពេះដឹងខុសត្រូវ ។ នៅក្នុងបដិវត្តន៍កម្ពុជាមានស្ត្រីក្មេងៗជាច្រើនពាន់នាក់ក៏ត្រូវបាន«រំដោះ»ឲ្យធ្វើជាយុទ្ធជន កម្មាភិបាល និងថ្នាក់ដឹកនាំស្រុក ជាឋានៈដែលស្ត្រីខ្មែរមិនដែលគិតដល់កាលពីមុនបដិវត្តន៍ ។ ជនជាតិកម្ពុជាក្មេងៗដែលច្បាំងគ្នាដោយដៃទាំងពីរ ជក់ចិត្តក្នុងការធ្វើសង្គ្រាមណាស់ ។ ក្នុងខណៈដែលយុទ្ធជនជាច្រើនត្រូវឃុំខ្លួននៅមន្ទីរស-២១ និងដកហូតឋានៈដោយសារតែខ្លួននឹកឪពុកម្ដាយ អ្នកទោសម្នាក់បានបញ្ជាក់ក្នុងចម្លើយសារភាពរបស់ខ្លួនថា «ខ្ញុំចូលបដិវត្តន៍ដោយសារខឹងនឹងឪពុកម្ដាយខ្ញុំ» ។ អ្នករួចរស់ជីវិតពីសម័យកម្ពុជាប្រជាធិបតេយ្យជាច្រើននាក់ដែលឥឡូវនេះស្ថិតក្នុងវ័យពាក់កណ្ដាលសាមសិបឆ្នាំ ពេញចិត្តចំពោះសេរីភាពរបស់ខ្លួនក្នុងការធ្វើដំណើរជុំវិញប្រទេសក្នុងនាមជាកងកុមារវ័យជំទង់ ដូចជាករណីឆ្មាំក្រហមរបស់ម៉ៅ នៃប្រទេសចិនដែរ ។[៩៦]

អ្នកធ្វើការនៅមន្ទីរស-២១ភាគច្រើនបាន«ចូលបដិវត្តន៍»ក្នុងវ័យក្មេងបំផុត ។ ញ៉ែម អេន ចូលបដិវត្តន៍តាំងពីអាយុដប់ឆ្នាំម្ល៉េះ ។ ប្រាំមួយឆ្នាំក្រោយមក ពេលដែលគាត់ចូលមកមន្ទីរស-២១ គាត់បានធ្វើការជាមួយមនុស្សដែលមានវ័យប្រហែលគាត់ជាច្រើននាក់ ។ រូបថតរបស់អ្នកដែលពេញចិត្តនឹងខ្លួនឯងកុមារវ័យជំទង់ ដែលមានពាក់មួកកន្ដឹបចិនញញឹមពព្រាយត្រូវបានព្យួរលម្អតាមជញ្ជាំងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ចំពោះភាគច្រើននៃកុមារទាំងនោះយល់ថា អង្គការគឺជាឪពុកម្ដាយរបស់ខ្លួន ។ កុមារទាំងនោះ ត្រូវបានអង្គការចម្រាញ់តាមបញ្ជារបស់«បង១» ឲ្យមានភាពសាហាវយង់ឃ្នង ។[៩៧]

ក្មេងជំទង់ៗបានទទួលនូវកេរ្តិ៍ឈ្មោះល្បីនៅក្នុងប្រទេសជាច្រើនខាងភាពងាយទទួលការបត់បែន គំនិតនិយម ការស្រេកឃ្លានសុំការអនុញ្ញាតនិងកាយវិការឃោរឃៅរបស់ខ្លួន ។ និយាយទៅកាន់ ហ៊ីលីព ហ្គូរីក ក្នុងឆ្នាំ១៩៩៦ ចិត្តវិទូមួយរូបឈ្មោះ រីឆាដ ម៉ូលីកា បានវែកញែកអំពីអ្នកធ្វើសឹកជាតិហ៊ូទូនៅប្រទេសរ៉ាន់ដា ដែលមានអាយុនិងប្រវត្តិប្រហាក់ប្រហែលគ្នានឹងក្រុមធ្វើការងារនៅមន្ទីរស-២១ដែរ ។ «តាមគំនិតខ្ញុំ ចិត្តសាស្ត្ររបស់ក្មេងមិនស្មុគស្មាញដល់ថ្នាក់នោះឡើយ ហើយអ្នកដែលប្រព្រឹត្តអំពើឃោរឃៅភាគច្រើនក្នុងសភាពបែបនេះគឺជាស្ត្រីភេទក្មេងៗ ។ នៅលើផែនដីយើងនេះ មនុស្សដែលគ្រោះថ្នាក់បំផុតគឺស្ត្រីភេទដែលមានវ័យក្មេងៗ ពីព្រោះក្មេងទាំងនោះងាយនឹងឆ្លើយតបនឹងអំណាចដែលបញ្ជាទៅលើខ្លួននិងរង់ចាំតែ

ទទួលការអនុញ្ញាតប៉ុណ្ណោះក្នុងការធ្វើអ្វីមួយ ។ ក្រុមស្ត្រីក្មេងៗទាំងនេះត្រូវបានលើកទឹកចិត្តចំពោះការបញ្ចូលខ្លួនទៅក្នុងប្រព័ន្ធឋានានុក្រម ហើយមានជំនឿថាខ្លួនកំពុងតែកសាងឋានសួគ៌នៅលើផែនដី ។ ក្មេងៗមានគំនិតនិយមណាស់ ហើយអំណាចគឺជាអ្នកធ្វើឲ្យក្មេងទាំងនោះរងគ្រោះ» ។[៥៨]

បញ្ហាដែលកើតឡើងចំពោះក្មេងៗនៅគុកទួលស្លែងគឺបណ្តាលមកពីក្មេងទាំងនោះ «ក្រីក្រហើយស្អាតស្អំ» ។ ការប្រឡូកជាមួយវិន័យបដិវត្តន៍ដោយមិននិយាយដល់គំនិតម៉ាក្ស-ឡេនីន គឺកើតឡើងក្នុងលក្ខណៈជាការជំរុញជាសង្ខេបនិងគ្មានសណ្តាប់ធ្នាប់ ។ អ្វីដែលក្មេងទាំងនោះធ្លាប់បានរៀនតាមរយៈវគ្គសិក្សាផ្សេងៗ គឺមិនអាចធានាបាននូវទម្លាប់ធ្វើការងារល្អទេ ។ ចំពោះមនុស្សមានវ័យចំណាស់ជាង ពិបាកនឹងទប់ទល់នូវថាមពលពិតៗរបស់ក្មេងៗទាំងនោះដែលមានផលប្រយោជន៍ចំពោះបដិវត្តន៍ណាស់ ។ នៅក្នុងអំឡុងពេលខ្លីមួយក្រោមរបបកម្ពុជាប្រជាធិបតេយ្យ មានក្មេងទាំងប្រុសទាំងស្រីជាច្រើននាក់មិនអាចទទួលការអប់រំបាន ដូចដែលអ្នកនាំពាក្យរបស់បក្សបានកត់សម្គាល់ដោយក្តីសោកស្តាយនៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីកាលពីឆ្នាំ១៩៧៥ថា÷

> និយាយអំពីក្មេងៗដែលមិនមានការហ្វឹកហាត់ ក្មេងទាំងនោះមានការស្មោះត្រង់ អារម្មណ៍ផ្តោតមូលនិងវាងវៃ ។ ទាំងនេះគឺជាចំណុចខ្លាំងរបស់ក្មេងៗ ។ ចំពោះកន្លះខាតផ្សេងៗ បងប្អូនក្មេងៗរបស់យើងនៅលេងច្រើនណាស់ វប្បធម៌របស់គាត់នៅខ្សោយហើយមិនចេះអក្សរ និងមិនចេះដោះស្រាយរាល់ការលំបាកដែលកើតឡើងពីការងាររបស់ខ្លួនឡើយ ។[៥៩]

ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវផ្តួលរំលំ អៀង សារី បានធ្វើការពន្យល់អំពីប្រវត្តិមហន្តរាយរបស់កម្ពុជាប្រជាធិបតេយ្យទៅកាន់អ្នកកាសែតអាមេរិកាំងឈ្មោះ ហេនរី ខាម ថា «យើងមិនបានជ្រើសរើសបុគ្គលិករដ្ឋឲ្យបានត្រឹមត្រូវ» ។ អៀង សារី បាននិយាយទាំងមិនស្មោះត្រង់ថា «យើងបានបាត់បង់ការគ្រប់គ្រងខ្លះ» ។ អៀង សារី ព្យាយាមបញ្ចៀសមិននិយាយថា កម្ពុជាប្រជាធិបតេយ្យ «ជ្រើសរើសបុគ្គលិក» របស់ខ្លួនពីមជ្ឈដ្ឋានអ្នកដែលមានការអប់រំទាបបំផុតនៅក្នុងស្រុក ហើយបណ្តេញអ្នកដែលកំពុងតែធ្វើការចេញ ព្រមទាំងសម្លាប់មនុស្សរស់ជាច្រើនពាន់នាក់ដោយគ្មានរកហេតុផលផងទេ ។[៦០]

មានអ្នកធ្វើការនៅមន្ទីរស-២១ តិចណាស់ដែលអាចស្ថិតនៅក្នុងភាពជាជនបដិវត្តន៍យូរគ្រាន់បើ ។ មានតែម្ភៃប្រាំបួននាក់ប៉ុណ្ណោះដែលបានបំពេញបែបបទបុគ្គលិកកាលពីឆ្នាំ១៩៧៦ ថា បានចូលបដិវត្តន៍មុនឆ្នាំ១៩៧៣ ពេលដែលកងទ័ពវៀតណាមដកថយពីកម្ពុជា និងពេលដែលយុទ្ធនាការទម្លាក់គ្រាប់បែកអាមេរិកាំងស្កាត់ពួកខ្មែរក្រហមនៅទីក្រុងភ្នំពេញ ។ បុគ្គលិកចំនួនហាសិបប្រាំបីនាក់បានចូលបដិវត្តន៍នៅក្នុងឆ្នាំនោះ សែសិបបីនាក់ចូលក្នុងឆ្នាំ១៩៧៤ និងសែសិបពីរនាក់ចូលពីរបីខែមុនឆ្នាំ១៩៧៥ ។ ប្រាំនាក់ចុងក្រោយបានចូលក្រោយពីការវាយបែកទីក្រុងភ្នំពេញ ។ វគ្គសិក្សាដែលបុគ្គលិកម្នាក់ៗត្រូវទទួលមុនពេលចូលបម្រើការនៅមន្ទីរស-២១ គឺវគ្គសិក្សានយោបាយដែលមានរយៈពេលពីរសប្តាហ៍ធ្វើឡើងនៅ

សាលាបច្ចេកទេសមួយនៅតាខ្មៅ ក្រុម២៥ បង្រៀនដោយ «បងទុយ» ដែលក្រោយមកបានធ្វើជាអ្នកសួរចម្លើយនិងគ្រប់គ្រងរដ្ឋបាលនៅឯមន្ទីរស-២១ ។

ចំពោះប្រជាជនជាច្រើនទៀត សាលានោះគឺជាកន្លែងទីមួយដែលខ្លួនបានជួបជុំគ្នារៀនសូត្រនូវអ្វីដែលទើបតែបង្កើតថ្មីសុទ្ធសាធ ។ ប្រសិនបើវគ្គសិក្សាតាំងពីសម័យកម្ពុជាប្រជាធិបតេយ្យជាមាគ៌ាបង្ហាញផ្លូវមែននោះ ម៉េះសមអ្នកដែល គីម ទុយ បង្រៀន ប្រហែលជាបានស្តាប់នូវបទទទួលទោសនាមជំរុញទឹកចិត្តឲ្យចងចាំនូវពាក្យស្លោកនានា និងរៀបចំជីវប្រវត្តិផ្ទាល់ខ្លួនមិនខាន ។ សិស្សអាចបានដើរពីកន្លែងមួយទៅកន្លែងមួយដោយច្រៀងចម្រៀងបដិវត្តន៍ ។ អ្នកទាំងនោះប្រហែលជាត្រូវបានអនុញ្ញាតឲ្យដេកតែមួយស្រឡេតប៉ុណ្ណោះ ។ ដូចជាសមាជិកដែលទើបតែបានចុះឈ្មោះថ្មីៗនៃចលនាសាសនាអ៊ីចឹងដែរ សិក្ខាកាមទាំងអស់ត្រូវតែចេញពីសាលាដោយមានការផ្តោតអារម្មណ៍និងមានគំនិតភ្លឺស្វាង ។[៦១]

ក្រុមអ្នកធ្វើការនៅក្នុងមន្ទីរស-២១ ហាក់ដូចជាមានភាពស្អិតល្មួតណាស់ ។ ក្នុងចំណោមអ្នកដែលបានបំពេញប្រវត្តិរូបហើយមានបុរសចំនួនមួយរយមួយនាក់ និង ស្ត្រីចំនួនសាមសិបពីរនាក់បានកើតនិងត្រូវបានចិញ្ចឹមនៅតំបន់២៥ស្ថិតនៅខាងត្បូងទីក្រុងភ្នំពេញ ម្ភៃប្រាំបួននាក់ទៀតមកពីតំបន់៣១ បីនាក់មកពីតំបន់៣២ ដប់បីនាក់មកពីតំបន់៣៣ដែលនៅភូមិភាគឦសានទាំងមូល ហើយមានម្នាក់មកពីតំបន់៤១ដែលស្ថិតនៅភាគខាងជើង ។ អ្នកទាំងនោះត្រូវបានដកមកពីអង្គភាពទ័ពដែលបញ្ជូនមកទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៥ ។

តំបន់២៥មានប្រជាជនរស់នៅច្រើនហើយធូរធារទៀត ។ នៅទីនោះមានប្រជាជនរស់នៅជាច្រើនពាន់នាក់ រួមទាំងជនជាតិចិននិងខ្មែរកាត់ចិនដែលធ្វើចម្ការយកភោគផលទៅលក់នៅទីផ្សារ មានអ្នកទីរួមខេត្តនិង មួយភាគធំទៀតជាខ្មែរសុទ្ធសាធដែលធ្វើស្រែចម្ការ ។ ក្នុងទសវត្សរ៍ឆ្នាំ៦០ តំបន់នេះត្រូវបានតំណាងដោយ ខៀវ សំផន ដែលមានប្រជាប្រិយក្នុងចំណោមអ្នកបោះឆ្នោតនិងបានឃោសនាប្រជាជនឲ្យចូលបក្សកុម្មុយនិស្តដែលបង្កើតឡើងដោយលួចលាក់ ។ ហ៊ឹម ហ៊ុយ បានរំឭកឡើងវិញថា «នរណាក៏ស្រឡាញ់ ខៀវ សំផន ដែរនៅតំបន់នោះ» ។ បួនឆ្នាំក្រោយពីការរត់ចូលព្រៃម៉ាគីនៅឆ្នាំ១៩៦៧ ពេលដែលមានមនុស្សជាច្រើនគិតថា ខៀវ សំផន បានស្លាប់បាត់ទៅហើយនោះ ខៀវ សំផន បានក្លាយជាសមាជិកដ៏សំខាន់មួយរូបនៃមជ្ឈិមបក្ស ។ ពេលចុះចូលជាមួយរដ្ឋាភិបាលភ្នំពេញក្នុងឆ្នាំ១៩៩៨ ខៀវ សំផន គឺជាអ្នកដែលរស់រានមានជីវិតគួរឲ្យខ្លាចនិងគួរឲ្យស្អប់ខ្ពើមជាទីបំផុត ។[៦២]

សរុបមក អ្នកធ្វើការនៅមន្ទីរស-២១ សុទ្ធតែស្ថិតក្នុងវ័យស្របាលគ្នា មានបទពិសោធន៍ប្រហាក់ប្រហែលគ្នានិងមកពីប្រភពដើមដូចគ្នា លើកលែងតែ «បងៗធំៗ» ដែលភាគច្រើនជាបញ្ញវន្តកំប៉ិកកំប៉ុកតែប៉ុណ្ណោះ ។ អ្នកទាំងនោះក៏មានលក្ខណៈសម្បត្តិប្រហាក់ប្រហែលនឹងអ្នកដែលជាប់ឃុំឃាំងនៅក្នុងគុកដែរ ។

## អ្នកទោសនៅមន្ទីរស-២១

អ្នកទោសនៅមន្ទីរស-២១ មានចំនួនមិនទៀង ជួនតិច ជួនច្រើន ។ នេះបង្ហាញពីការធ្វើវិសុទ្ធកម្មដែលកើតមានទូទាំងកម្ពុជាប្រជាធិបតេយ្យចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៦មក ។ ចំណុចនេះនឹងមានរៀបរាប់ក្នុងវគ្គទី៣ ។ ចំនួនអ្នកទោសក្នុងឆ្នាំ១៩៧៧មានប្រហែល១.៥០០នាក់ ។ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំដដែលនោះ មន្ទីរសន្តិសុខបានឃុំឃាំងអ្នកទោសចំនួន១.២៤២នាក់ ក្នុងនោះមានស្ត្រី១០៥នាក់ ។ ប្រហែលជាពេលនោះហើយដែល ញ៉ែម អេន ឃើញគេដឹកអ្នកទោសទាំងឡានៗចូលមកមន្ទីរស-២១ ហើយដឹកយកទៅសម្លាប់ភ្លាមដោយមិនទាន់ទាំងបានថតរូប ឬសួរចម្លើយផង ពីព្រោះតែអ្នកទោសទាំងនោះមិនសំខាន់ហើយមន្ទីរសន្តិសុខគ្មានកន្លែងដាក់ ។[៦៣]

មានពេលខ្លះមន្ទីរស-២១ មានអ្នកទោសតែពីរ-បីរយនាក់ប៉ុណ្ណោះ ។ ក្នុងឆ្នាំ១៩៧៥ មានមនុស្សតិចជាង២០០នាក់ត្រូវបានឃុំខ្លួនដោយសន្តិបាល ។ ចំនួនអ្នកទោសកើនឡើងដល់១.៦២២នាក់ក្នុងឆ្នាំ១៩៧៦ ដែលបីភាគបួននៃអ្នកទោសទាំងនោះត្រូវបានចាប់ខ្លួនក្នុងរវាងខែឧសភា ជាពេលដែលមានការធ្វើវិសុទ្ធកម្មខ្លាំងក្លា និងជាពេលដែលអគារនៅទួលស្លែងត្រូវបានចាប់ផ្តើមប្រើប្រាស់រហូតដល់ចុងឆ្នាំ ។ នាឆ្នាំ១៩៧៧ ពេលដែលមន្ទីរភូមិភាគនានារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យត្រូវទទួលចលនាវិសុទ្ធកម្មយ៉ាងហោចណាស់មានមនុស្សចំនួន៦.៣០០នាក់ត្រូវបានចាប់ខ្លួន ។ មានថ្ងៃខ្លះមានមនុស្សជាង៣០០នាក់ត្រូវបានចាប់ដាក់គុក ។[៦៤]

ចាប់ពីពាក់កណ្តាលខែកុម្ភៈដល់ពាក់កណ្តាលខែមេសា ឆ្នាំ១៩៧៧ មានប្រជាជនទាំងស្រីទាំងប្រុសចំនួន១.២៤៩នាក់ត្រូវបានបញ្ជូនចូលគុកក្នុងអំឡុងពេលនៃចលនាវិសុទ្ធកម្មនៅភូមិភាគឧត្តរនិងពាយ័ព្យ ។

ក្នុងឆ្នាំ១៩៧៨ នៅលើរូបថតរបស់អ្នកទោសមានផ្លាកឈ្មោះ លេខរៀងសម្គាល់តាមខែចូលរបស់អ្នកទោស ។ តាមឯកសារនៃការនាំអ្នកទោសចូល ទោះបីជាមិនសូវពេញលេញក្តី តែបង្ហាញថា យ៉ាងហោចណាស់មានអ្នកទោសចំនួន៤.៣៥២នាក់បានចូលមកមន្ទីរសន្តិសុខស-២១ ក្នុងឆ្នាំ១៩៧៨ ។ មានតែអ្នកទោសចំនួន៥៩នាក់ប៉ុណ្ណោះដែលត្រូវបានកត់ចូលក្នុងបញ្ជីខែឧសភា ទោះជាលេខរៀងរូបថតពាក់កណ្តាលខ្លួនរបស់អ្នកទោសទាំងនោះឡើងដល់៧៩១ក៏ដោយ ។ ថ្វីដ្បិតតែមានចន្លោះជាច្រើននៅក្នុងឯកសាររូបថតឆ្នាំ១៩៧៨ក៏ដោយ ប៉ុន្តែបើផ្ទៀងផ្ទាត់ជាមួយរបាយការណ៍នាំមនុស្សចូលប្រចាំខែ លើកលែងតែខែឧសភា និង ខែសីហាដែលនៅសល់រូបថត ឃើញថាមានតួលេខខ្ពស់បំផុតដែលមានភាពប្រហាក់ប្រហែលគ្នា ។ ខ្ញុំបានបន្ថែមតួលេខ៧៣២នាក់ទៀតទៅក្នុងបញ្ជីស្នាមនាំចូលខែឧសភា ដើម្បីឲ្យចំនួននេះឡើងដល់៥.០៨៤នាក់តាមចំនួនសរុបប៉ាន់ស្មានក្នុងឆ្នាំ១៩៧៨ ។

ចំនួននាំចូលពីខែមេសាដល់ខែមិថុនា បង្ហាញអំពីវិសុទ្ធកម្មនៅភាគនិរតីនៃប្រទេសកម្ពុជា ។ នៅត្រឹមចុងឆ្នាំ១៩៧៨ ចំនួនអ្នកទោសបានធ្លាក់ចុះយ៉ាងខ្លាំង ។ នៅខែធ្នូ ឆ្នាំ១៩៧៨ បើតាមចំណាររបស់ ហ៊ុយ ផ្ញើទៅ ឌុច បានបញ្ជាក់ឲ្យដឹង មានអ្នកទោសចំនួន២៧៩នាក់នៅក្នុងគុកធំ (ប្រហែលអគារធំនៅផ្នែកខាងលិច) និង ៤៥នាក់ទៀតដែលច្បាស់ជាឈ្លើយសឹកជនជាតិវៀតណាម ហើយមាន៣៣នាក់ទៀតនៅក្នុង «គុក

ពិសេស» ។ នៅពេលជាមួយគ្នានោះដែរ មានអ្នកទោស «កំពុងធ្វើការ» ចំនួន១៤នាក់ផ្សេងទៀត ដែលក្នុងចំនួននេះមានបុរស៧នាក់បានរត់ចេញរួចពីការឃុំឃាំងនៅមន្ទីរស-២១ ។ ទោះជាចំនួនអ្នកទោសដែលរាយក្នុងបញ្ជីនៅទីនេះមានតែ១៣.២០៦នាក់ក៏ដោយ ប៉ុន្តែផ្អែកទៅលើចន្លោះប្រហោងនៅក្នុងទិន្នន័យបញ្ជាក់ថា ចំនួនអ្នកទោសប៉ាន់ស្មានរវាងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ អាចមានប្រហាក់ប្រហែល ១៤.០០០នាក់ ។[៦៥]

ភាគច្រើននៃអ្នកទោសនៅមន្ទីរស-២១ គឺសុទ្ធតែជាក្មេងប្រុសជនជាតិភាគតិច មកពីជនបទដាច់ស្រយាល ។ ក្មេងៗទាំងនោះមានតម្លៃសង្គមនិងសញ្ញាតិមិនខុសពីអ្នកដែលឃុំឃាំងខ្លួនឡើយ ។ ប៉ុន្តែមានករណីខ្លះប្រជាជនដែលត្រូវចាត់ទុកជា «ខ្មាំងវណ្ណៈ» ឬក៏ «ប្រជាជនថ្មី» និងអ្នកដែលសង្ស័យថា បានប្រព្រឹត្តកំហុសតូចតាចត្រូវបានចាប់ឃុំឃាំងក្នុងគុកនានានៅតាមខេត្ត ។[៦៦] ក្នុងចំណោមអ្នកទោសទាំងអស់មានតែ២៣៨នាក់ ឬ៦,៤ភាគរយប៉ុណ្ណោះជាស្ត្រីភេទ ដែលបន្សល់ទុកចម្លើយសារភាពមកដល់សព្វថ្ងៃនេះ ។ ភាពខុសប្លែកគ្នាអាចពន្យល់បញ្ជាក់បានតាមរយៈការពិតជាក់ស្តែងដែលថា មានស្ត្រីតិចជាងបុរសដែលបម្រើក្នុងផ្នែកទ័ពតាមអង្គភាពសន្តិបាល ហើយមានភាគតិចណាស់ដែលមានតួនាទីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ដូច្នេះមានពេលខ្លះស្ត្រីទាំងនោះត្រូវបានចោទថាប្រឆាំងបដិវត្តន៍ ហើយក៏ត្រូវជាប់ទោសតែម្តង ។ ប៉ុន្តែច្បាស់ណាស់ថា ស្ត្រីនៅក្នុងគុកមានចំនួនច្រើនជាងចំនួនចម្លើយសារភាពដែលបន្សល់ទុក ។ យើងដឹងថា ប្រពន្ធរបស់អ្នកទោសរាប់សិបនាក់ដែលមានឋានៈខ្ពស់ៗ ព្រមទាំងម្តាយរបស់អ្នកទាំងនោះ ត្រូវបានឃុំឃាំងនិងសម្លាប់ចោលនៅក្នុងមន្ទីរសន្តិសុខស-២១ ដោយគ្មានការសួរចម្លើយឡើយ ។ម្យ៉ាងវិញទៀត ស្ត្រីអ្នកទោសទាំងនោះ រួមមានអ្នកកាន់តំណែងខ្ពស់ៗដូចជា ប្រធានស្រុក ប្រធានរោងចក្រ អ្នកកាន់តំណែងផ្នែករដ្ឋបាល មន្ទីរពេទ្យ កម្មាភិបាលយោធា ព្រមទាំងឧបដ្ឋាយិកានិងអ្នកដាំបាយដែលជាតំណែងប្រពៃណីរបស់ស្ត្រីខ្មែរផង ។[៦៧]

អ្នកទោសប្រហែល៥០០នាក់ ឬ ១០ភាគរយនៃចំនួនអ្នកទោសសរុបដែលចម្លើយសារភាពរបស់ខ្លួនមាននៅមកដល់សព្វថ្ងៃនេះ ធ្លាប់កាន់មុខតំណែងទទួលខុសត្រូវនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្នកទាំងនេះ ខ្ញុំរួមបញ្ចូលទាំងលេខានយោបាយតាមផ្នែកនិងជំនួយការមេបញ្ជាការវរសេនាធំនិងកងពលកម្មាភិបាលកាន់កាប់សហគ្រាសរដ្ឋដូចជា ក្រសួងការបរទេស ក្រសួងព័ត៌មាន ក្រសួងឧស្សាហកម្មនិងក្រសួងពាណិជ្ជកម្ម ។[៦៨] សាមសិបនាក់នៃអ្នកដែលត្រូវបានបោសសម្អាតម្តងៗ គឺជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស ។ ទោះបីអ្នកទោសទាំងអស់ទទួលវាសនាដូចៗគ្នាក៏ដោយ ក៏ប៉ុន្តែអ្នកទោសដែលមានមុខតំណែងផ្សេងៗនៅមន្ទីរសន្តិសុខស-២១ ច្រើនតែទទួលរបបពិសេសមួយជាញឹកញយ ។ គក ស្រស់ បានរំឭកថា កម្មាភិបាលដែលជាប់ឃុំឃាំងនៅក្នុងគុកដែលហៅថា «គុកពិសេស» គ្មានធ្វើអ្វីទេ ដេកចាំតែទទួលរបបដូចបុគ្គលិកទូទៅដែរ ។ គក ស្រស់ បន្ថែមថា ក្រោយពេលសួរចម្លើយនិងធ្វើទារុណកម្មរួចហើយអ្នកទោសត្រូវបានផ្តល់ទឹកនិងបិទរបួសឲ្យដោយបុគ្គលិកពេទ្យនៅមន្ទីរស-២១ ហើយទុកពេលឲ្យសរសេរចម្លើយសារភាពរបស់ខ្លួនឲ្យកាន់តែ«សុក្រឹត»ឡើង ។ ដោយសង្ឃឹមថានឹងបានផ្អាកឬបន្ថយការធ្វើទារុណកម្ម និងទទួលការដោះលែង មានកម្មាភិបាលជាន់ខ្ពស់ជាច្រើនបានសម្រេចចិត្តសហការនិងខំសរសេរចម្លើយសារភាពរាប់រយទំព័រ ។ គក

ស្រស់ និយាយថា សន្តិសុខដែលត្រូវបានចាត់តាំងឲ្យមើលការខុសត្រូវអ្នកទោសជាកម្មាភិបាលជាន់ខ្ពស់ សុទ្ធតែត្រូវបានជ្រើសរើសជាពិសេសមកពីអង្គភាព ។ ការយកចិត្តទុកដាក់ជាពិសេសដែលកម្មាភិបាលបានទទួលអាចស្តែងឲ្យឃើញផ្នែកខ្លះតាមរយៈការសម្តែងនូវការគោរពចំពោះកម្មាភិបាល ដែលមានឋានៈខ្ពស់ៗ ប៉ុន្តែវាប្រហែលជាមានទាក់ទងជាមួយនឹងតម្រូវការរបស់មជ្ឈិមបក្សដែរបានជាអ្នកទោសកម្មាភិបាលទាំងនោះត្រូវបានថែទាំឲ្យមានសុខភាពល្អសម្រាប់សរសេរចម្លើយសារភាពឲ្យសមហេតុសមផល ។[៦៩]

គ្មានចម្លើយសារភាពណាមួយនិយាយអំពីជីវិតប្រចាំថ្ងៃនៅក្នុងគុក ឬ ការទាក់ទងរបស់អ្នកទោសឡើយ ។ ដូច្នេះហើយបានជាប្រភពមកពីមន្ទីរសន្តិសុខស-២១ ខ្វះជាងប្រភពដែលយើងអាចពិគ្រោះសិក្សាអំពីហាយនភាព ឬ «សង្គ្រាមកខ្វក់» នៅអាហ្សង់ទីនឬក៏ជំរុំកសាងខ្លួននៅចិនទិនសូវៀត មិនត្រឹមតែដោយសារអ្នកនៅរស់រានមានជីវិតនៅទីនោះមានចំនួនច្រើនទេ ប៉ុន្តែដោយសារភាពសម្ងាត់និង«វិន័យ» របស់មន្ទីរសន្តិសុខស-២១ ដែលបិទការទាក់ទងរវាងអ្នកទោសនិងអ្នកទោស ព្រមទាំងរារាំងយើងមិនឲ្យដឹងពីអ្វីដែលត្រូវបានផលិតឡើងនៅក្នុងបរិវេណនោះផង លើកលែងតែចម្លើយសារភាព អនុស្សាវរណៈនិងប្រវត្តិរូបសង្ខេបរបស់យុទ្ធជនប៉ុណ្ណោះ ។ លើសពីនេះទៀត មន្ទីរសន្តិសុខស-២១ មិនមានលក្ខណៈដូចជំរុំរបស់ណាហ្ស៊ីឡើយ ។ មន្ទីរនេះមាន«ភាពគួរឲ្យទុកចិត្តណាស់» ។ ការប្រព្រឹត្តិល្អចំពោះអ្នកទោសដែលមានឋានៈខ្ពស់ៗ មិនរាប់បញ្ចូលការអនុញ្ញាតឲ្យទៅស្និទ្ធស្នាលជាមួយអ្នកទោសឯទៀតឡើយ ។ ផ្ទុយទៅវិញ បើតាមឃ្លាមួយរបស់ ហ៊ុល ហ្វៃក សហ្សុត ថា អ្នកទោសទាំងនោះ «ស្ថិតនៅក្នុងភពបាតសង្គមមួយ ពោលគឺពិភពនៃទុក្ខសោកវេទនានិងភាពគ្មានឈ្មោះ» ។[៧០]

ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៦ ពេលដែលមន្ទីរសន្តិសុខស-២១ ពង្រីកខ្លួន អ្នកទោសដែលទទួលការសួរចម្លើយយ៉ាងខ្លាំងក្លា ប៉ុន្តែមិនរហូតដល់ឃុំឃាំងនៅក្នុង«គុកពិសេស»នោះ គឺត្រូវបានដាក់នៅក្នុងបន្ទប់ដែលមានបណ្តោយប្រវែងពីរម៉ែត្រ និងទទឹងប៉ែតសិបសង់ទីម៉ែត្រស្ថិតនៅក្នុងថ្នុកដែលមានរងើកភ្លើងព័ទ្ធជុំវិញ ហើយត្រូវដាក់ខ្នោះជើងជាប់ទៅនឹងកម្រាលឥដ្ឋ ។ អ្នកទោសមិនសូវសំខាន់ដូចជា វ៉ាន់ណាត ត្រូវបានដាក់នៅក្នុងបន្ទប់ធំនៅជាន់ទីពីរនៃបរិវេណនោះដោយដាក់ «ត្រង់ជាជួរនិងដាក់ខ្នោះកជើងភ្ជាប់ទៅនឹងចុងបន្ទប់» ។[៧១]

អ្នកទោសស្ត្រីនិងបុរសត្រូវបានបំបែកពីគ្នា ។ ស្ត្រីដែលមានកូនតូចអាចនៅជាមួយកូន ចំណែកប្តីរបស់ស្ត្រីនោះត្រូវបានយកទៅសួរចម្លើយ ហើយសមាជិកគ្រួសារត្រូវបាននាំយកទៅសម្លាប់ចោល ។ ឯកសាររាត់រាយបង្ហាញឲ្យដឹងថា ជាញឹកញាប់ ប្រពន្ធនិងកូនត្រូវទុកនៅមន្ទីរស-២១រយៈពេលខ្លីបំផុត (ពេលខ្លះពីរថ្ងៃ) មុននឹងកាត់ទោស ហើយមានឯកសារមួយបានបញ្ជាក់ថា នៅដើមខែកក្កដា ឆ្នាំ១៩៧៧ មានអ្នកទោសចិតសិបប្រាំនាក់ត្រូវជាកូនរបស់អ្នកទោសដែលត្រូវយកទៅសម្លាប់នោះត្រូវបានយកទៅកម្ទេចនៅឯព្រៃស ។ តាមចម្លើយសារភាពរបស់បុគ្គលិកធ្វើការនៅក្នុងគុកបានឲ្យដឹងថា អ្នកទោសភេទស្រីត្រូវបានទទួលរងទុក្ខបុកម្នេញនិងរំលោភបំពានយ៉ាងឃោរឃៅ ។ ជាពិសេសអ្នកទោសភេទស្រីជាជនជាតិវៀតណាមងាយទទួលរងនូវការវាយប្រហារណាស់ ។[៧២]

ភាពឯកោ កង្វះអាហារ និងភាពស្អប់ស្អាត់ គឺជាលក្ខណៈសំខាន់ក្នុងការបំបាក់អ្នកទោសដើម្បីសួរ

ចម្លើយ ដូចដែលលោក ហ្វូខល បាននិយាយថា «ភាពឯកោ គឺជាលក្ខណៈចម្បងសម្រាប់ឲ្យអ្នកទោសសារភាព» ។[៨៣] អ្នកទោសក្រោកតាំងពីម៉ោង៥ព្រឹក ។ ក្រោយពីភ្ញាក់ទាំងពពឹមពពើមភ្លាម អ្នកទោសត្រូវបានបញ្ជាឲ្យហាត់ប្រាណ ធ្វើកាយសម្ព័ន្ធទាំងជាប់ខ្នោះច្រវាក់ ។ ម្ភៃឆ្នាំក្រោយមក វ៉ាន់ ណាត បានរំឭកអំពីការធ្វើកាយសម្ព័ន្ធកាលនៅពេលនោះថា÷

យើងឮសំឡេងបញ្ជា «ពួកឯងទាំងអស់គ្នាក្រោកឡើង!» ។ ពេលខ្ញុំក្រោកអង្គុយ ខ្ញុំឃើញក្មេងប្រុសម្នាក់អាយុប្រហែលដប់បីឆ្នាំឈរនៅលើខ្សែភ្លើងដែលរុំធ្វើជាផ្លូវមានប្រវែងប្រហែលមួយម៉ែត្រ ។

ក្មេងនោះក៏សួរថា «ហេតុអីក៏អ្នកឯងដេកអីចឹង? ជិតភ្លឺហើយណា! កុំខ្ជិលពេកហាត់ប្រាណខ្លះទៅ» ។

មានអ្នកទោសម្នាក់សួរទៅវិញថា «តើឲ្យខ្ញុំហាត់ប្រាណយ៉ាងម៉េចបង?» ក្មេងនោះតបវិញថា «កុំល្ងង់ពេកអាកញ្ចាស់ឆ្កួត ។ ម៉េចមិនទៅយកធុងកើបអាចម៍ដាក់ក្រោមដែករនុក ហើយលោតទាំងអស់គ្នាទៅ» ។

ពេលនោះអ្នកទោសទាំងអស់ក៏ធ្វើតាមការណែនាំ ហើយសំឡេងខ្នោះនិងធុងឮសូរទ្រហឹងពេញបន្ទប់ ។ ខ្ញុំបានសាកលោតពីរដងជាមួយនឹងគេឯងដែរ ។ តើធ្វើម៉េចនឹងលោតទៅកើត បើជើងម្ខាងជាប់ខ្នោះហើយជើងម្ខាងទៀតលោតនោះ?[៨៤]

អ្នកដែលត្រូវសួរចម្លើយត្រូវបានយកទៅរៀនសូត្របីវគ្គក្នុងមួយថ្ងៃ ចាប់ពីម៉ោង៧ព្រឹកដល់ថ្ងៃត្រង់ ពីម៉ោង១ថ្ងៃដល់ម៉ោង៦ល្ងាច និងពីម៉ោង៨យប់ដល់ពាក់កណ្ដាលអធ្រាត្រ ។ អ្នកដែលនៅខាងក្រោយមិនអនុញ្ញាតឲ្យជជែកគ្នាឡើយ បើចង់បត់ដៃបត់ជើងទាល់តែប្រាប់សន្តិសុខសិនទើបបាន ។[៨៥] អ្នកទោសទាំងហ្វូងៗនៅបន្ទប់ធំត្រូវបានទទួលការ«ងូតទឹកឲ្យ»ក្នុងរវាងបីបួនថ្ងៃម្ដង ដោយបាញ់ទឹកនឹងទុយោតាមបង្អួច ។ រីឯចំណីអាហារវិញគឺមានតែបបរាវកក្កុកពីរបីស្លាបព្រាលាយជាមួយត្រកួននិងស្លឹកចេកប៉ុណ្ណោះ ។ អ្នកទោសត្រូវបានអនុញ្ញាតឲ្យហូបពីរពេល គឺពេលព្រឹកនៅម៉ោងប្រាំបីម្ដង និងពេលយប់នៅម៉ោងប្រាំបីម្ដងទៀត ។ មិនយូរប៉ុន្មាន អ្នកទោសក៏ចាប់ផ្ដើមស្រកទម្ងន់និងកើតជំងឺរាករូស ស្គម ហើមជើង និងកើតរោគសើស្បែកជាច្រើនប្រភេទទៀត ។ នៅពេលដែលកម្លាំងចុះខ្សោយ ជំងឺក៏ឆ្លងរាលដាលពីអ្នកទោសម្នាក់ទៅម្នាក់ទៀត ។ មានអ្នកទោសជាច្រើននាក់ត្រូវស្លាប់មុនពេលយកទៅសួរចម្លើយ ហើយអ្នកខ្លះទៀតស្លាប់ក្រោយពីការសួរចម្លើយដោយមិនទាន់ត្រូវបានយកទៅសម្លាប់ទេ ។ ប្រសិនបើស្លាប់នៅពេលយប់ សាកសពនឹងត្រូវទុកដល់ពេលព្រឹក ពួកខ្មែរក្រហមមិនយកសាកសពទៅណាភ្លាមទេ ។ ភាពផ្ទុយគ្នារវាងការធ្វើបាបអ្នកទោសដូចសត្វធាតុនិងសេចក្ដីសង្ឃឹមថានឹងបានទទួលចម្លើយសារភាពលម្អិត គឺជាវប្បធម៌របស់មន្ទីរសន្តិសុខ ស-២១ ហើយបញ្ហានេះមិនទាន់ត្រូវបានដោះស្រាយឡើយ ។ តើការយកចិត្តទុកដាក់ប្រកបដោយមនុស្សធម៌ នឹងនាំទៅដល់«ចម្លើយសារភាពមានលក្ខណៈពិតជាងនេះដែរឬទេ? គ្មានពេលដឹងអំពីបញ្ហានេះទេ ប៉ុន្តែ

ការយកចិត្តទុកដាក់ប្រកបដោយមនុស្សធម៌មិនដែលកើតមានឡើយ ។ ចំពោះគំនិតរបស់អ្នកគ្រប់គ្រង គឺមិនមែនជាការចាំបាច់ឡើយក្នុងការធ្វើឲ្យអ្នកទោសមានសុខភាពរឹងប៉ឹង ។

បន្ទាប់ពីរយៈពេលមួយខែនៃការឃុំឃាំង វ៉ាន់ ណាត និយាយថា÷

> ក្រោយពីពេលវាបង្អត់អាហារយូរថ្ងៃ យើងមិនអាចដើររួចឡើយ សូម្បីតែក្រោកឈរក៏មិនរួចផង ពេលនោះយើងមិនអាចប្រឆាំងនឹងពួកវាបានទេ នៅក្នុងចិត្តយើងគ្មានកម្លាំងណានឹងប្រឆាំងឡើយ ។ អ្វីៗបាត់បង់អស់ទៅហើយ ។ យើងដេកចាំតែថ្ងៃស្លាប់ប៉ុណ្ណោះ ។[៧៦]

ជារៀងរហូតមក ស្ថានភាពសម្រាប់អ្នកទោសបានប្រែប្រួលទៅតាមចំនួននិងកម្រិតនៃការភ័យខ្លាចរបស់មជ្ឈិមបក្ស ។ នៅក្នុងឆ្នាំ១៩៧៥ មុនពេលដែលសន្តិបាលផ្លាស់មកទួលស្លែង និងមុនពេលដែលប្រតិបត្តិការចាប់ផ្តើមមានលក្ខណៈសម្ងាត់ អ្នកទោសជាច្រើនត្រូវបានដោះលែងហើយបញ្ជូនទៅមន្ទីរកសិកម្មនៅព្រៃស ឬអ្នកខ្លះទៀតត្រូវត្រឡប់ទៅអង្គភាពចាស់របស់ខ្លួនវិញ ។[៧៧] ក្រោយមកទៀត មានអ្នកទោសមួយចំនួនដូចជា អ៊ឹង ប៉ិច និង រុយ នាគង់ ត្រូវបានដោះលែងពីខ្នោះហើយឲ្យទៅធ្វើការដូចធម្មតានៅតាមជាយគុក ។ នាដើមឆ្នាំ១៩៧៨ មានអ្នកទោសភេទប្រុសរាប់សិបនាក់ក្នុងនោះរួមមានទាំង វ៉ាន់ ណាត និងអ្នកផ្សេងៗដែលនៅរស់រានមានជីវិតត្រូវបាន ឌុច ឈ្លបសួរនិងចាត់តាំងឲ្យគូររូបនិងឆ្លាក់ធ្វើរូបសំណាក ប៉ុល ពត ។ នៅខែចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ គឺនៅពេលដែលសភាពការណ៍វាយប្រយុទ្ធគ្នាជាមួយនឹងវៀតណាមកាន់តែធ្ងន់ធ្ងរទៅ ប៉ុល ពត បែរជាមានគំនិតចង់បង្កើតរូបសំណាករបស់ខ្លួនឲ្យដូចជាមគ្គុទ្ទេសក៍ឯទៀតៗនៅជុំវិញខ្លួនមាន ម៉ៅ សេទុង និង គីម អ៊ីលស៊ុង ជាដើម ។ «ការជឿទុកចិត្ត» នៅមន្ទីរស-២១ត្រូវបានប្រមូលផ្តុំដើម្បីបង្កើតជាវិមានសមរម្យមួយ ។ និយាយជាមួយលោក ដេវីដ អាស្លូលី នៅក្នុងឆ្នាំ១៩៩៥ វ៉ាន់ ណាត បានរំឭកថា÷

> នៅទីបញ្ចប់យើងត្រូវតែរៀបចំគូសប្លង់វិមានបដិវត្តន៍មួយ ។ គំរូប្លង់ត្រូវបានយកទៅឲ្យ នួន ជា ហើយ នួន ជា ក៏យល់ស្រប បន្ទាប់មករូបនេះនឹងត្រូវបញ្ជូនទៅ ប៉ុល ពត មួយថ្នាក់ទៀត ។ វិមាននោះដូចជាវិមាននៅប្រទេសចិននិងប្រទេសកូរ៉េដែរ ដោយមានរូប ប៉ុល ពត នៅពីមុខ លើកដៃស្តាំទៅលើ ដៃឆ្វេងកាន់សៀវភៅក្រហមមួយក្បាលដែលសរសេរពីកិច្ចការបដិវត្តន៍ ។ នៅក្នុងប្លង់នោះ ប៉ុល ពត គឺជាឥស្សរជនដែលត្រូវបានពិពណ៌នាថាជាមនុស្សពិសេសម្នាក់ ហើយនៅពីក្រោយ ប៉ុល ពត មានប្រជាជនជាច្រើននាក់លើកដៃ បង្ហាញពីការរីកចម្រើនរបស់បដិវត្តន៍ដោយមានកាន់ពូថៅ កាំបិត កាំភ្លើង និងរ៉ុក្កែត បេ-៤០ ។ ឌុច និយាយថា គម្រោងគឺចង់វាយកម្ទេចវិហារនៅវត្តភ្នំ និងជំនួសដោយវិមាននេះ ។ ប្រសិនបើវៀតណាមមិនបានចូលមកឈ្លានពានទេនោះ ខ្ញុំគិតថាប្រហែលជានឹងកើតឡើងមែន ។[៧៨]

ចំពោះអ្នកទោសជាង៥ម៉ឺនពាន់នាក់ទាំងប្រុសទាំងស្រី និងក្មេងតូចៗដែលត្រូវបានឃុំខ្លួននៅក្នុងមន្ទីរសន្តិសុខស-២១យល់ថា គ្មានការតស៊ូបដិវត្តន៍ណាមួយដែល«មានការពារពីទៅនិងការពារ»ឡើយ ។ រាល់ថ្ងៃរាល់ខែ អ្នកទោសទាំងនោះរស់នៅក្នុងបន្ទប់រង់ចាំតែសេចក្តីស្លាប់ប៉ុណ្ណោះ ។ ការតស៊ូរបស់អ្នកទោសទាំងនោះ មិនបានបញ្ចប់ដោយភាពរុងរឿងឡើយ ប៉ុន្តែគឺបញ្ចប់ដោយលលាដ៍ក្បាលរបស់ខ្លួនដែលត្រូវកម្ទេចទាំងរទេះៗនៅឯវាលពិឃាតជើងឯក ។

**ខណ្ឌទីបី:**

# ការជ្រើសរើសសត្រូវ

មន្ទីរសន្តិសុខស-២១ គឺជាស្ថាប័នពេញលេញមួយដែលមានបេសកកម្មស្វែងរកចម្លើយ និងកម្ទេចខ្មាំងរបស់មជ្ឈិមបក្ស ។ បើយោងតាមការហូរចូលនៃចំនួនអ្នកទោសនិងចំនួនអ្នកទោសដែលត្រូវបានសម្លាប់ មន្ទីរសន្តិសុខស-២១ប្រហែលជាស្ថាប័នដ៏មានប្រសិទ្ធភាពបំផុតនៅក្នុងប្រទេសកម្ពុជា ។ បើគិតពីការសង្កត់ធ្ងន់របស់បក្សឲ្យការពារខ្មាំងវិញ មន្ទីរនេះក៏នៅតែមានសារសំខាន់ដែរ ។ ទ្រឹស្តីនៃរបបកម្ពុជាប្រជាធិបតេយ្យជឿថាមានខ្មាំង ហើយការតាមដានរកខ្មាំងគឺជាធាតុផ្សំមួយមុខយ៉ាងសំខាន់ក្នុងការអនុវត្តជាក់ស្តែងរបស់ខ្លួន ។ ដោយសារតែអ្នកដឹកនាំកម្ពុជាដើរតាមលទ្ធិម៉ៅ «ខ្មាំង»ដែលប្រឆាំងនឹងបដិវត្តន៍ត្រូវបានបង្កើតជាបន្តបន្ទាប់ ហើយការបោសសម្អាតក៏ចាំបាច់ត្រូវតែធ្វើជាបន្តបន្ទាប់ដែរ ដើម្បីធានាសន្តិសុខដល់មជ្ឈិមបក្សនិងរក្សាភាពស្អាតស្អំនិងការពង្រីកកម្លាំង ។[១] បើដូចនេះពាក្យថា «ខ្មាំង» ច្បាស់ជាមាននៅគ្រប់កន្លែង ។ «ការបោសសម្អាត»ខ្មាំងមិនចេះចប់ឡើយ ។ ការកសាងនិងការពារប្រទេសត្រូវមានការរួមដៃគ្នា ។ ដូចដែលទិសស្លោករបស់បក្សកុម្មុយនិស្តកម្ពុជាបានចែងថា «ដៃម្ខាងបង្កបង្កើនផល ដៃម្ខាងវាយខ្មាំង» ។[២]

ចំពោះ ប៉ុល ពត និងដៃដើងរបស់ខ្លួន មិត្តនិងសត្រូវគឺជា «ទំនាស់ស្លាប់រស់» ។ ក្នុងការបែងចែកនេះ ប៉ុល ពត បានស្រង់សម្តីរបស់ ម៉ៅ សេទុង ដែលនិយាយនៅឆ្នាំ១៩៥៧ថា «ចំពោះការដោះស្រាយត្រឹមត្រូវនៃទំនាស់ក្នុងជួរប្រជាជន» ម៉ៅ សេទុង បានចាត់ទុក «ការកម្ចាត់ខ្មាំងបដិវត្តន៍» ថាជាឧទាហរណ៍នៃ «ទំនាស់ទី១» (ពោលគឺទំនាស់រវាងខ្មាំងនិងយើង) ។[៣]

មួយឆ្នាំក្រោយមក នៅក្នុងសុន្ទរកថារយៈពេលប្រាំម៉ោងដែលនិយាយអំពីអត្ថិភាពរបស់បក្សកុម្មុយ-និស្តកម្ពុជា ប៉ុល ពត បាននិយាយថា÷

> *នៅក្នុងសង្គមកម្ពុជា មានទំនាស់ស្លាប់រស់ដូចជាសត្រូវដែលជាខ្សែបង្កប់របស់ចក្រពត្តិនិងបនប្រតិ-កិរិយាបរទេស ។ ពួកនេះនៅតែបង្កប់ជាមួយយើង ប្រព្រឹត្តនូវអំពើវិទ្ធង្សនាផ្សេងៗប្រឆាំងនឹងបដិវត្តន៍...ខ្មាំងប្រភេទនេះមានមួយចំនួនតូចទេគឺប្រហែល១ឬ២ភាគរយប៉ុណ្ណោះ ក្នុងចំណោមប្រជាជនយើងទាំងអស់ ។*

តាមគំនិតរបស់ ប៉ុល ពត ក្នុងចំណោមប្រជាជនកម្ពុជាចំនួនប្រាំពីរលាននាក់ យ៉ាងច្រើនមាន ១៤០.០០០នាក់ (២ភាគរយ) ប៉ុណ្ណោះជាខ្មាំងពិតប្រាកដរបស់របបនេះ ។ ប៉ុល ពត បន្ថែមថា «ទំនាស់ជាមួយពួកទាំងនេះត្រូវតែដោះស្រាយតាមវិធីដែលយើងដោះស្រាយជាមួយខ្មាំងដទៃទៀតដែរ» ។ វិធានការទាំងនេះរួមមាន «និយាយលួងឲ្យស្រួលស្តាប់» និង«អប់រំ» ខ្មាំងមួយចំនួន ហើយនៅសល់ពីនោះព្យាយាម«ធ្វើកុំឲ្យមានបញ្ហា» ។ ចុងក្រោយ ប៉ុល ពត ស្នើឲ្យ«បំបែកនិងកម្ទេចមនុស្សមួយចំនួនតូច ពោលគឺ

អ្នកដែលប្រឆាំងបដិវត្តន៍ដាច់ខាតនិងអ្នកដែលចូលដៃជើងជាមួយខ្មាំងបរទេសប្រឆាំងនឹងជាតិខ្លួនឯង ប្រជាជនខ្លួនឯង និងបដិវត្តន៍» ។[៤] ដូចដែល ប៉ុល ពត បាននិយាយដូច្នេះដែរ មានប្រជាជនចំនួនរាប់ពាន់នាក់ត្រូវបានសួរចម្លើយ ធ្វើទារុណកម្មនិងសម្លាប់ចោលនៅមន្ទីរស-២១ ។

កម្ពុជាប្រជាធិបតេយ្យបានបែងចែកខ្មាំងជាពីរពួក គឺខ្មាំងខាងក្នុងនិងខ្មាំងខាងក្រៅដូចដែល ស្តាលីន និង ម៉ៅ បានធ្វើដែរ ។[៥] ខ្មាំងខាងក្រៅមានមហាអំណាចដឹកនាំដោយសហរដ្ឋអាមេរិកដែលប្រឆាំងនឹងសង្គមនិយមនិង«ពួកសេរីនិយម» ឬ «ពួកវាតទីនិយម» ដូចជាសហភាពសូវៀត វៀតណាម និង សម្ព័ន្ធមិត្ត ។ ប៉ុល ពត និងបក្សពួកច្រើនតែនិយាយថា ការបំផ្លាញប្រទេសកម្ពុជាមានសារសំខាន់ណាស់ចំពោះខ្មាំងទាំងនេះដែលតាមរយៈនេះពួកវានឹងមានលទ្ធភាពសម្រេចគោលបំណងរបស់វា ។ ដូចគ្នានេះដែរ ឯកសារដែលថែរក្សាទុកនៅមន្ទីរស-២១នៅខែមីនា ឆ្នាំ១៩៧៦ បានប្រមើលមើលថា កងកម្លាំងវៀតណាមខាងត្បូងនិងវៀតណាមកុម្មុយនិស្តដែលត្រូវបណ្តេញចេញពីតំណែង កំពុងតែសហការរីករាយជាមួយគ្នានៅក្នុងប្រទេសវៀតណាម ដើម្បីផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យដោយសហការជាមួយប្រទេសថៃនិងក្រុមកងនាវាចរទី៧របស់អាមេរិក ។[៦] ប្រាំមួយខែក្រោយមកមានឯកសារមួយទៀតនៅមន្ទីរសន្តិសុខស-២១ ដែលដកស្រង់ពត៌មានអំពីអតីតយុទ្ធជនរបប លន់ ណុល ដែលទទួលការហ្វឹកហាត់នៅសហរដ្ឋអាមេរិក បានសរសេរអំពីអង្គការសន្ធិសញ្ញាអាស៊ីភាគអាគ្នេយ៍មួយដែលមានតៃវ៉ាន់ កូរ៉េខាងត្បូង ឥណ្ឌូនេស៊ី និងវៀតកុងជាសមាជិក គោលគំនិតនយោបាយចម្បងរបស់អង្គការនេះគឺចង់កម្ទេចកម្ពុជាប្រជាធិបតេយ្យ ។[៧] នៅឆ្នាំ១៩៧៨ នួន ជា មន្ត្រី ជាន់ខ្ពស់ទីពីររបស់មជ្ឈិមបក្សបានប្រាប់ដល់ភ្ញៀវជាជនជាតិដាណឺម៉ាកថា÷

> គឺថា...អ្នកណាក៏ដឹងដែរថាសហរដ្ឋអាមេរិកមានផែនការចង់ប្តូរអំណាចពីយើងប្រាំមួយថ្ងៃក្រោយពីការរំដោះភ្លាម ។ គម្រោងការនេះមានការចូលរួមពីសំណាក់សហរដ្ឋអាមេរិក កា.ហ្សេ.បេ និងវៀតណាម ។ ក្រុមនេះបម្រុងវាយព្រមគ្នាពីខាងក្នុងនិងខាងក្រៅ ។ ប៉ុន្តែយើងបានកម្ចាត់ផែនការនេះទាន់ ។[៨]

ខ្មាំងខាងក្រៅងាយស្រួលសម្គាល់ណាស់ ។ ពួកនេះត្រូវបានឃាត់ខ្លួនត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្នដោយកងការពារនិងមិត្តភក្តិមហាអំណាច ។ ដូចដែល ប៉ុល ពត បាននិយាយទៅកាន់កម្មាភិបាលរបស់ខ្លួន នៅក្នុងឆ្នាំ១៩៧៧ថា «ប្រទេសចិនអាចជួយកម្ចាត់សត្រូវរបស់យើង ។ មានមិត្តដូចជាចិននេះពិតជាល្អណាស់» ។[៩]

ក៏ប៉ុន្តែក្រុមប្រឆាំងផ្ទៃក្នុងរបស់របបនេះពិបាកសម្គាល់ណាស់ ។ មានគ្រោះថ្នាក់ជាងខ្មាំងខាងក្រៅ ។ ចំណែកអ្នកដែលធ្វើសកម្មភាពចេញមុខមិនបង្កជាគ្រោះថ្នាក់អ្វីឲ្យលេចធ្លោនោះទេ» ។ សមាសភាពទាំងនេះរួមមានប្រជាជន«ថ្មី» ឬ «១៧មេសា» ដែលត្រូវបានជម្លៀសចេញពីទីក្រុងនានា កាលពីឆ្នាំ១៩៧៥ និងប្រជាជនទាំងប្រុសទាំងស្រីនៅសល់ពីសង្គមចាស់ដែលមានដើមកំណើតនិងប្រវត្តិរូបប៉ះពាល់ដល់បដិវត្តន៍ ។ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនប្រភេទនេះរាប់សែននាក់ត្រូវស្ថិតនៅក្រោមការឃ្លាំមើល

យ៉ាងប្រុងប្រយ័ត្ននៅតាមជនបទហ្នឹកបញ្ជូនទៅសាលាអប់រំដែលមានលក្ខណៈមិនខុសពីគុកប៉ុន្មានឡើយ ហើយនៅទីនោះមានមនុស្សរាប់ពាន់នាក់ត្រូវបាត់បង់ជីវិត ។[១០]

## ខ្មាំងផ្ទៃក្នុង

អ្វីដែលធ្វើឲ្យបក្សមានការព្រួយបារម្ភជាងគេនោះគឺខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ។ ទោះបីជាប្រជាជនទាំងនេះបានចូលបម្រើបដិវត្តន៍ក៏ដោយ ប៉ុន្តែឥឡូវកំពុងតែក្បត់នឹងបដិវត្តន៍វិញ ។ នៅក្នុងខែមេសា ឆ្នាំ១៩៧៥ នួន ជា បានវាយប្រហារខ្មាំងប្រភេទនេះជាចំហក្នុងឱកាសនិយាយជាមួយកម្មាភិបាលបក្ស ។[១១] ពីរបីខែក្រោយមក បទវិចារណកថានៅក្នុងសៀវភៅទង់បដិវត្តប្រកាសថា ខ្មាំងផ្ទៃក្នុងបាន«ព្យាយាមផ្លាស់ប្តូរពណ៌សម្បុររបស់បដិវត្តន៍» ។[១២]

> នៅឆ្នាំ១៩៧៨ បទវិចារណកថាមួយនៅក្នុងទិនានុប្បវត្តិបានសរសេរប្រឆាំងនឹងអ្នកដែលកាន់ផ្ទាកបដិវត្តន៍បណ្តោះអាសន្នក្លែងខ្លួនធ្វើជាអ្នកបដិវត្តបង្កប់ខ្លួន ដើម្បីកសាងកម្លាំងនៅក្នុងជួរបដិវត្តន៍និងបំផ្លាញបដិវត្តន៍ពេលដែលបដិវត្តន៍យើងចុះខ្សោយ មិនក្តៅ ឬមិនប្រយុទ្ធដាច់ខាត នៅពេលដែលបណ្តាញផ្ទៃក្នុងឬពេលដែលយើងកាត់ផ្តាច់ពីមហាជន ។ ប៉ុន្តែឥឡូវនេះ ពេលកម្លាំងបដិវត្តន៍ប្រមូលផ្តុំគ្នាមានអំណាចខ្លាំងក្លា ពេលដែលបណ្តាញសម្ងាត់ក្បាក់រពុកដល់ចំណុចនេះ ខ្មាំងបង្កប់ផ្ទៃក្នុងលែងអាចលាក់ខ្លួនទៀតហើយ ទោះជាខ្មាំងទាំងនោះសំខាន់យ៉ាងណាក៏ដោយ ។ គ្រប់សកម្មភាពស្ងប់ស្ងាត់ការពារខ្លួននិងបិទមុខដែលសំដៅកម្ទេចបដិវត្តន៍ត្រូវបានមហាជនមើលឃើញយ៉ាងច្បាស់ហើយអាចកម្ទេចតែម្តងគឺអស់ ។[១៣]

នៅជិតចុងបញ្ចប់នៃរបបនេះ ពេលនិយាយជាមួយ ដេន នួន ជា បានកត់សម្គាល់ថា «យើងមិនព្រួយបារម្ភអំពី...ការឈ្លានពានដោយយោធាពីខាងក្រៅទេ ។ យើងបារម្ភបំផុតគឺខ្មាំងផ្ទៃក្នុង» ។[១៤] ការឈ្វេចរកខ្មាំងផ្ទៃក្នុងចេះតែបន្តជ្រៅទៅៗ ស្មុគស្មាញទៅៗ និងពិបាកជាងការ«កម្ទេច»ជនក្បត់ទៅទៀត ។ គំនិតកេងប្រវ័ញ្ច ចំណង់ចំណូលចិត្ត និងអាកប្បកិរិយារបស់ពួកគហបតី ត្រូវបានគិតថាមានកប់យ៉ាងជ្រៅនៅក្នុងមនសិការរបស់ប្រជាជនគ្រប់រូប ហើយនេះគឺជាដើមគំនិតរបស់ ប៉ុល ពត ដែលដើរតាម ស្តាលីន និង ម៉ៅ ។ នៅឆ្នាំ១៩៧៧ ប៉ុល ពត បានប្រកាសថា «យើងទាំងអស់គ្នាបាននាំមកជាមួយនូវសារជាតិវណ្ណៈពីសង្គមចាស់ដែលបានចាក់ឫសយ៉ាងជ្រៅតាំងពីជំនាន់មុនៗ» ។ គំនិតទាំងនេះត្រូវតែកម្ទេចមុននឹងសម្រេចគោលដៅសង្គមនិយម ។ មួយឆ្នាំមុននេះ អ្នកនិពន្ធសៀវភៅទង់បដិវត្តម្នាក់បាននិយាយថា÷

> ចំពោះសមាជិកបក្សនិងកម្មាភិបាលបក្សយើងត្រូវតែជម្រុះចោលរបស់អ្វីក៏ដោយឲ្យតែជារបស់វណ្ណៈជិះជាន់ ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ជីវភាព ទស្សនៈ មនោសញ្ចេតនា ទំនៀមទម្លាប់ វប្បធម៌ ដែលស្ថិត

> នៅក្នុងខ្លួនយើង ទោះតិចឬច្រើនក៏ដោយ ។[១៥]

ក្នុងការបោសសម្អាតជនក្បត់និងប្រជាជនកុំឲ្យមានគំនិត«គហបតី» សន្តិបាល បានធ្វើការយ៉ាងទូលំទូលាយ គ្មានដែនកំណត់និងគ្មានមេត្តា ។ ដូចដែលពាក្យស្លោករបស់កម្ពុជាប្រជាធិបតេយ្យបាននិយាយថា «ការចាប់ខ្លួនមនុស្សដប់នាក់ដោយច្រឡំប្រសើរជាងច្រឡំដោះលែងមនុស្សម្នាក់ដែលមានកំហុស» ។[១៦]

ពេលដែលត្រូវបានរកឃើញ ចាប់ខ្លួននិងយកទៅមន្ទីរស-២១ ជនសង្ស័យរបស់មជ្ឈិមបក្សបានក្លាយទៅជា «ជនមានកំហុស» គឺមានកំហុសដោយសារខ្លួនត្រូវបានចាប់ចងមិនមែនដោយសារខ្លួនបានប្រព្រឹត្តកំហុសនោះទេ ។ អ្នកទោសត្រូវទទួលរងនូវអំពើអមនុស្សធម៌យ៉ាងទាន់ហន់និងដាច់ខាតដូចដែល លន់ ណុល ចាត់ទុកអ្នកប្រឆាំងនឹងខ្លួនជា«ទមិឡ»ដែរ ។ សហសភាសហរដ្ឋអាមេរិកចាត់ទុកជនកុម្មុយនិស្តកម្ពុជា «មិនមែនជាអាមេរិកាំង» ដូចដែល ប៉ុល ពត និងបក្សពួកចាត់ទុកខ្មាំងផ្ទៃក្នុងថាជាជនបរទេសនិងមិនស្អាតស្អំអីចឹងដែរ ។ ខ្មាំងផ្ទៃក្នុងអាចនាំឲ្យមានគ្រោះថ្នាក់ធំណាស់ ។ នៅក្នុង «គម្រោងចុងក្រោយ» ឌុច បានធ្វើការប្រៀបធៀបយុទ្ធសាស្ត្ររបស់ខ្មាំងផ្ទៃក្នុងទាំងនោះទៅនឹង «សត្វខ្មូតនៅក្នុងឈើ ឬប្រេងដែលជ្រាបនិងប្រៀបធៀបទៅនឹងដង្កូវឬមេរោគដែលកើតចេញមកពីសេ.អ៊ី.អា វៀតណាម និងអ្នកដទៃទៀតក្នុងការវាយប្រហារប្រជាជនបដិវត្តក្លាហាន» ។[១៧]

នៅពេលដែលមនុស្សម្នាក់មានជំងឺ អ្នកនោះច្បាស់ជាចម្លងជំងឺទៅអ្នកដទៃទៀតមិនខាន ។ បើមិនក្តិចបណ្តូលវាទេ នោះការប្រឆាំងបដិវត្តន៍នឹងរាលដាលកាន់តែខ្លាំងឡើងៗយ៉ាងប្រាកដ ។ នៅក្នុងខែធ្នូ ឆ្នាំ ១៩៧៦ ប៉ុល ពត បាននិយាយសន្ទត់ធ្ងន់ទៅលើកម្មាភិបាលបក្សកុម្មុយនិស្តកម្ពុជាដោយលើកពីមនោគមវិជ្ជាដែលទាក់ទងនឹងបច្ចេកទេសពេទ្យបន្តិចបន្តួចថា÷

> យើងមិនអាចមើលឃើញវាច្បាស់ទេ ។ មានជំងឺត្រូវតែពិនិត្យឲ្យបានច្បាស់ ។ ពីព្រោះកម្តៅនៃការធ្វើបដិវត្តប្រជាជននិងធ្វើបដិវត្តប្រជាធិបតេយ្យ វាមិនស្មើនឹងការតស៊ូរបស់ប្រជាជននិងការតស៊ូវណ្ណៈឡើយ...យើងខំស្វែងរកមេរោគនៅក្នុងបក្សប៉ុន្តែមិនបានជោគជ័យ ។ នៅក្នុងបក្ស ជួរទ័ពនិងក្នុងជួរប្រជាជនយើងនឹងអាចរកឃើញមេរោគចង្រៃនោះ ។ វានឹងត្រូវបានកម្ចាត់ចេញដោយសារធាតុពិតរបស់បដិវត្តន៍ ។[១៨]

ដូចនៅក្នុងសម្តីផ្សេងទៀតរបស់ ប៉ុល ពត ដែរ សម្តីមួយឃ្លានេះមានលាយឡំដោយការសន្និដ្ឋាន ការមិនទុកចិត្តគ្នានិងគំនិតសង្ស័យទុកមុន ។ គំនិតនេះមិនបានកំណត់ឲ្យច្បាស់អំពី«សារជាតិពិត»របស់បដិវត្តន៍ មិនបានពន្យល់អំពីទំហំនៃជំងឺប៉ុនណា ឬសំខាន់បំផុតមិនបានបង្ហាញឲ្យឃើញថា បក្សពិតជាមានកម្លាំងក្បត់សម្ងាត់បង្កប់មែនឬក៏យ៉ាងណាទេ ។ ប៉ុន្តែសម្តីនេះនិយាយយោងរបៀបមិនច្បាស់និងពិបាកយល់ដល់ការ «ឃ្លាំមើលនៅអំឡុងពេលដប់ឆ្នាំចុងក្រោយ» ។

## ការធ្វើវិសុទ្ធកម្មក្នុងឆ្នាំ១៩៧៥

វិសុទ្ធកម្ម [ការបោសសម្អាត] ដែលធ្វើឡើងដោយមជ្ឈិមបក្ស និងអនុវត្តនៅមន្ទីរសន្តិសុខស-២១ អាចចែកចេញជាពីរដំណាក់កាលធំៗ ។ ដំណាក់កាលទីមួយគឺចាប់ផ្តើមឡើងពីខែកញ្ញា ឆ្នាំ១៩៧៥ ដល់ខែកញ្ញា ឆ្នាំ១៩៧៦ ។ ដំណាក់កាលទីពីរគឺបន្តរហូតមកដល់ថ្ងៃដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ មនុស្សដែលជាមុខសញ្ញាក្នុងការធ្វើវិសុទ្ធកម្មលើកទីមួយគឺប្រជាជនស៊ីវិលនិងយុទ្ធជនមានស័ក្តិធំៗរបស់របប លន់ ណុល ។ ជាលទ្ធផលប្រជាជនរាប់ពាន់នាក់ត្រូវបានប្រមូលយកទៅសម្លាប់ចោល ។ ផ្ទុយទៅវិញ នៅក្នុងប្រទេសវៀតណាម ប្រជាជនជំពូកនេះត្រូវបានបញ្ជូនទៅកន្លែងអប់រំកសាងខ្លួនដែលនៅទីនោះមានប្រជាជនជាច្រើនត្រូវស្លាប់និងរាប់ម៉ឺននាក់បានលេចមុខមកសាជាថ្មី ។ អំពើមនុស្សឃាតក្នុងឆ្នាំ១៩៧៥ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដូចជាការអប់រំកសាងខ្លួននៅប្រទេសវៀតណាមដែរ គឺធ្វើឡើងតាមបញ្ជាពីថ្នាក់លើដាច់ខាត ។ តាមចម្លើយសារភាពរបស់ ជៅ ចាន់ នៅឆ្នាំ១៩៧៧ បានឲ្យដឹងថា៖

> ក្រោយពីប្រទេសទាំងមូលត្រូវបានរំដោះ អង្គការបានផ្តើមអនុវត្តនូវការកម្ទេចមន្ត្រីចាប់ពីឧត្តមសេនីយ៍ចុះមកដល់វរសេនីយ៍ទោ ព្រមទាំងភ្នាក់ងារ សន្តិសុខ ប៉ូលិស តម្រួតយោធា និងរដ្ឋការប្រតិកិរិយាជាបន្តបន្ទាប់ ។[១៩]

ការសម្លាប់មនុស្សនេះបានធ្វើឲ្យសង្គ្រាមស៊ីវិលរីកកាន់តែធំនិងបង្ហាញពីអំពើឃោរឃៅទៀតផង ។ គំរូប្រវត្តិសាស្ត្រនៃសង្គ្រាមស៊ីវិលអាចរកបាននៅសហភាពសូវៀតក្រោយឆ្នាំ១៩១៧ នៅប្រទេសចិនក្នុងអំឡុងឆ្នាំ១៩៤៩-៥០ និងនៅប្រទេសវៀតណាមក្នុងឆ្នាំ១៩៥៤ ។ ទាំងនេះគឺជាការចង្អុលបញ្ជាក់តាមយោបល់របស់លោក ណាម ឆមស្គី និង អេដវ៉ាដ ហ៍រម៉ែន ។ នៅក្នុងប្រទេសបារាំងក៏ដូចជាប្រទេសកម្ពុជាដែរ កំហឹងរបស់ប្រជាជន អំណាចកំហឹងរបស់ជនរងគ្រោះ ព្រមទាំងកង្វះការធានាពីអំពើយុត្តិធម៌ផង បានរួមបង្កជាអំពើមួយដែលហួសពីដែនសមត្ថកិច្ចរបស់តុលាការទៅទៀត រួមទាំងការសម្លាប់ពេញទឹកពេញដីផង ។[២០]

នៅក្នុងប្រទេសកម្ពុជា យុទ្ធនាការសម្លាប់មនុស្សនៅខែមិថុនា ឆ្នាំ១៩៧៥ ត្រូវបានកាត់បន្ថយដោយមជ្ឈិមបក្ស ។ ក្រោយនោះបន្តិចដំណើរការតាមលិខិតស្នាមដែលគ្រប់គ្រងដោយសន្តិបាលទាក់ទងនឹងចំណាត់ការប្រឆាំងនឹង«ខ្មាំង» ត្រូវបានអនុវត្តខ្លាំងឡើងៗជាលំដាប់ ។ ចាប់ពីខែតុលា ឆ្នាំ១៩៧៥ ជនដែលត្រូវសង្ស័យថាប្រឆាំងនឹងបដិវត្តន៍លែងត្រូវបានសម្លាប់ភ្លាមៗទៀតហើយ ប៉ុន្តែបែរជាត្រូវយកមកសួរចម្លើយនិងតម្រូវឲ្យសរសេរចម្លើយសារភាពរបស់ខ្លួនសិនទើបចាត់ការជាក្រោយ ។ អ្នកទោសទាំងអស់រួមទាំងមន្ត្រីរបប លន់ ណុល ជនជាតិខ្មែរដែលសិក្សានៅបរទេស អ្នករត់ចោលជួរ មនុស្សដែលមានពុតត្បុត ជនជាតិខ្មែរដែលមានទំនាក់ទំនងខ្សែរយៈជាមួយរបបធីវគីនៅក្នុងក្រុងសៃហ្គន និងប្រជាជនដែលហៅថាខ្មែរហាណូយដែលត្រូវមជ្ឈិមបក្សសង្ស័យនិងត្រូវបានបោសសម្អាតដោយបក្សកុម្មុយនិស្តកម្ពុជា តាំងពីឆ្នាំ

១៩៧២មក ។[៦១]

នៅក្នុងឆ្នាំ១៩៧៦ ពេលដែលការធ្វើវិសុទ្ធកម្មឡើងខ្លាំងដល់កម្រិតកំពូលហើយនោះ ខ្មែរក្រហមបានប្រឹងប្រែងយ៉ាងពេញទំហឹងក្នុងការពង្រីកអំណាចរបស់ខ្លួននៅក្នុងប្រទេសនិងកសាងកិត្តិស័ព្ទរបស់ខ្លួននៅលើឆាកអន្តរជាតិ ។ នៅខែមករា រដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យត្រូវបានផ្សព្វផ្សាយជាសាធារណៈ ។ នៅខែមេសា ការបោះឆ្នោតមួយត្រូវបានរៀបចំឡើង រដ្ឋាភិបាលកណ្តាលត្រូវបានបង្កើតហើយវិធានការផ្សេងៗក៏ត្រូវរៀបចំឡើងដើម្បីបង្កើតកងទ័ពជាតិ ។ វិទ្យុភ្នំពេញបានប្រកាសថា «កម្មករពេងចក្រចម្ការកៅស៊ូ» ឈ្មោះ ប៉ុល ពត ដែលគ្មាននរណាម្នាក់ស្គាល់ឈ្មោះក្រៅពីបក្សនោះគឺជានាយករដ្ឋមន្ត្រីថ្មី ។ នៅខែឧសភា សន្តិបាលបានផ្ទេរប្រតិបត្តិការរបស់ខ្លួនមកទួលស្លែងវិញ ។ មិនបានយូរប៉ុន្មានផង រលកនៃវិសុទ្ធកម្មលើកទីពីរក៏ចាប់ផ្តើម ។

ដោយសារតែទួលស្លែងជាគុកនយោបាយដ៏ធំនៅក្នុងទីក្រុងភ្នំពេញ ប្រភេទជនរងគ្រោះដែលរៀបរាប់ខាងលើត្រូវបានបន្តនាំចូលក្នុងគុកនេះដើម្បីសួរចម្លើយនិងសម្លាប់ ប៉ុន្តែបើតាម អាលីហ្សាប៊ែត ប៊ែកឃ័រ និយាយថា «ឥឡូវនេះ បក្សបានប្តូរពីការកម្ទេចពួកគហបតីមកកម្ទេចពួកមាននិន្នាការគហបតីនៅក្នុងបក្សវិញ ។ ការផ្លាស់ប្តូរនេះបានបណ្តាលឲ្យមានរបបមួយដែលពោរពេញដោយក្តីវង្វេង ហើយដែលបន្តរហូតមកដល់ពេលដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ» ។ ដូច ហាណាស អារ៉េន បានបញ្ចេញទស្សនៈរបស់គាត់ថា «ទាល់តែក្រោយពេលដែលខ្មាំងពិតៗត្រូវបានកម្ទេចអស់និងមានការចាប់ផ្តើមស៊ើបរកមុខសញ្ញាខ្មាំង ទើបគ្រប់គ្នាដឹងថាមានរបបផ្តាច់ការមែន» ។[៦២]

## រលកវិសុទ្ធកម្មលើកទីពីរ

ការតាមរកខ្មាំងត្រូវបានបង្កើនល្បឿនតាមរយៈព្រឹត្តិការណ៍ពីរដែលធ្វើឲ្យរំជួលនិងមានអាថ៌កំបាំងមិនអាចពន្យល់បាន ។ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៦ មានការផ្ទុះអាវុធមួយនៅទីក្រុងសៀមរាបស្រប ពេលដែលប្រជាជនមើលឃើញយន្តហោះរបស់បរទេសកំពុងតែហោះហើរពីលើទីនោះដែរ ។ នៅដើមខែមេសា មានការផ្ទុះដោយចៃដន្យមួយនៅក្នុងក្រុងភ្នំពេញ ចំពោះ ប៉ុល ពត ព្រមទាំងអ្នកដែលធ្វើការនៅក្បែរខ្លួន ហាក់បីដូចជាគិតថា វាជាការផ្ទុះរដ្ឋប្រហារដ៏ពេញទំហឹងមួយ ។ ពិតណាស់ ព្រឹត្តិការណ៍ដែលកើតឡើងពីរលើកនេះនៅតែមិនមានលក្ខណៈច្បាស់លាស់នៅឡើយ ។

ជាទូទៅ របបកម្ពុជាប្រជាធិបតេយ្យបានទម្លាក់កំហុសអំពីការផ្ទុះនេះទៅលើ «ភ្នាក់ងារសេ.អ៊ី.អា» ដែលការចោទនោះធ្វើឡើងនៅចុងឆ្នាំ១៩៧៨ ដោយចោទថា ការផ្ទុះទៅលើកងទ័ពកម្ពុជាប្រជាធិបតេយ្យនៅក្នុងទីក្រុងនេះជាសកម្មភាពរបស់វៀតណាម ។ ថ្នាក់ដឹកនាំបក្សបានសង្ស័យថា កុយ ធួន ហៅ ឃួន លេខាភូមិភាគឧត្តរមានការពាក់ព័ន្ធក្នុងរឿងផ្ទុះនៅខេត្តសៀមរាប ។ ថ្នាក់ដឹកនាំបក្សក៏មានការសង្ស័យចំពោះលេខាភូមិភាគបូព៌ាដែលជាយុទ្ធជនដើងចាស់ឈ្មោះ សោ ភឹម ហៅ សូ វណ្ណា ថាជាអ្នកនាំបង្កការផ្ទុះគ្រាប់នៅក្នុងរាជធានីដែរ ។ ជនទាំងពីរនាក់នេះនៅតែទទួលភារកិច្ចដដែល ទោះជាមួយរយៈពេលខ្លីក្រោយពីការផ្ទុះ

កុយ ធួន ត្រូវបានកោះហៅមកភ្នំពេញដើម្បីមើលការខុសត្រូវខាងពាណិជ្ជកម្មជាមួយបរទេស និងសួរចម្លើយអំពីកំហុសសីលធម៌ក៏ដោយ ។ នៅថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៧៦ ជិតមួយសប្តាហ៍ក្រោយពីការផ្ទុះនៅក្នុងទីក្រុងភ្នំពេញ កុយ ធួន ត្រូវបាននាំយកមកឃុំនៅក្នុងគុកក្នុងសាលាពិសេសជិតព្រះបរមរាជវាំងស្ថិតនៅមិនឆ្ងាយប៉ុន្មានពីអគារដែលមានឆ្នាំយ៉ាងកកកុញការពារ«បងធំៗ»ស្នាក់នៅ ។ នៅក្នុងខែឧសភានិងខែមិថុនា រលកវិសុទ្ធកម្មទីពីរបានចាប់ផ្តើមឡើងដូចការគ្រោងទុក ។[២៣]

ក្នុងការបង្ហាញពីលំដាប់លំដោយនៃការធ្វើវិសុទ្ធកម្មទាំងនេះដោយប្រើទិន្នន័យបានមកពីចម្លើយសារភាព ដែលធ្វើឡើងជាបន្តបន្ទាប់ ខ្ញុំមិនបានប្រកាន់ជំហរថា តើចម្លើយសារភាពនោះមានលក្ខណៈពិតឬថាអ្នកទោសមានកំហុសឬអត់យ៉ាងណានោះទេ ។ ដោយសារតែការសម្រេចចិត្តទាំងនេះអាចធ្វើឲ្យមេដឹកនាំដែលស្វែងរកប្រវត្តិរូបគួរឲ្យទុកចិត្តរបស់អ្នកដែលប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យខកចិត្តនោះ ខ្ញុំត្រូវតែបង្ហាញនូវហេតុផលរបស់ខ្ញុំដែរ[២៤] ៖

ហេតុផលទីមួយ ដោយគ្មានការបញ្ជាក់អះអាងពីប្រភពផ្សេងៗមាន«ការពិត» តិចតួចណាស់នៅក្នុងចម្លើយសារភាព លើកលែងតែប្រវត្តិរូបផ្ទាល់ខ្លួនដែលអាចយកធ្វើជាការពិតបាន ។ យើងមិនអាចសម្រេចថា ក្រោមការធ្វើទារុណកម្ម តើអ្នកទោសព្រមសារភាពពីការពិត និយាយអ្វីដែលអ្នកសួរចម្លើយឲ្យនិយាយ និយាយអ្វីដែលអ្នកសួរចម្លើយចង់ស្តាប់ ឬប្រឌិតការពិតពាក់កណ្តាលកុហកពាក់កណ្តាលលាយជាមួយគំនិតស្រមើស្រមៃពាក់កណ្តាល ឬយ៉ាងណានោះទេ ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏យើងនៅតែអាចសន្និដ្ឋានបានថាភាគច្រើននៃចម្លើយសារភាពរបស់អ្នកទោសគឺមិនត្រឹមតែប្រឌិតឡើងឲ្យសមទៅតាមអ្វីដែលថ្នាក់ដឹកនាំនៅមន្ទីរសន្តិសុខស-២១យល់ថាសមរម្យតាមការចង់បានរបស់មជ្ឈិមបក្សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងថាការនិយាយរឿងជាខ្សែសង្វាក់និងការសន្ទនាដោយអំពើក្រេវក្រោធ ជួនកាលត្រូវបានផ្សំធ្វើជាចម្លើយសារភាពទៀតផង ។[២៥]

ហេតុផលទីពីរ គឺមានឯកសារតិចតួចណាស់ដែលនៅសេសសល់ស្តីអំពីការសម្រេចចិត្តធ្វើឡើងដោយមជ្ឈិមបក្សទាក់ទងនឹង«ខ្មាំង» ។ យើងគ្រាន់តែដឹងថា ដៃជើងរបស់អ្នកទោសត្រូវបានតាមដានចាប់ខ្លួនរួចហើយ និងបានប្រព្រឹត្តកំហុសឆ្គងផ្សេងៗព្រមទាំងស្ថិតនៅក្រោមការសង្ស័យ ប៉ុន្តែយើងពិបាកកំណត់ណាស់ថា ហេតុអ្វីបានជាអ្នកទោសត្រូវចាប់ខ្លួន ។ ចំពោះអ្នកទោសថ្នាក់ទាប ទំហំនៃ «បទឧក្រិដ្ឋ» គឺដូចគ្នានឹងបក្ខពួកដែលខ្លួនសេពគប់ដែរ ។ ផ្ទុយមកវិញ អ្នកទោសដែលមានឋានៈខ្ពស់ៗត្រូវបានបង្ខំឲ្យឆ្លើយថាបានរៀបចំផែនការផ្តួលរំលំឬធ្វើវិទ្ធង្សនាប្រឆាំងនឹងបដិវត្តន៍ ដោយបង្កើតជាបក្សប្រឆាំងប៉ុនប៉ងធ្វើឃាតថ្នាក់ដឹកនាំឬរិះគន់នយោបាយរបស់មជ្ឈិមបក្ស ។ វាពិបាកកំណត់ណាស់ថា តើការសមគំនិតពិតជាមានលក្ខណៈច្បាស់លាស់មែនឬអ្នកសមគំនិតពិតជាត្រូវបានចុចឈ្មោះពិតប្រាកដមែនដែរឬអត់ ។

ទោះបីជាគ្មានតុលាការឬចៅក្រមក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ តែការកាត់ទោសត្រូវផ្អែកលើចម្លើយសារភាពសង្ខេបៗ ។ ច្បាស់ជាងនេះទៀតផ្អែកលើប្រភេទភស្តុតាងដែលប្រមូលឲ្យចៅក្រមត្រួតពិនិត្យតាមប្រព័ន្ធយុត្តិធម៌ប្រទេសបារាំងត្រូវបានអនុវត្តនៅក្នុងប្រទេសកម្ពុជា ។ ចម្លើយសារភាពត្រូវបាន

រៀបចំនៅមន្ទីរសន្តិសុខស-២១ ជូន«ចៅក្រម»មជ្ឈិមបក្សដែលគ្មានអ្នកណាស្គាល់មុខ ។ ដោយសារតែភាពមិនចេះខុសដែលអះអាងដោយមជ្ឈិមបក្សនិងភាពសម្ងាត់នៅជុំវិញមន្ទីរសន្តិសុខស-២១ លទ្ធភាពនៃកំហុស ភាពគ្មានទោសនិងការដោះលែងគឺមិនត្រូវបានរាប់បញ្ចូលផងទេ ។

លើសពីនេះទៀត ការប្រើពាក្យ «មានទោស» ឬ «មិនមានទោស» ចំពោះអ្នកទោសនៅមន្ទីរស-២១ គឺមិនត្រឹមត្រូវឡើយ ។ ការប្រើពាក្យទាំងនេះផ្តល់នូវភាពស្របច្បាប់នៃប្រព័ន្ធយុត្តិធម៌មួយចំពោះគម្រោងការដ៏គួរឲ្យស្អប់ខ្ពើម ដែលតាមរយៈគម្រោងការនេះ អ្នកទោសទាំងអស់ទោះបីជាបានប្រព្រឹត្តអ្វីក៏ដោយមុនពេលដែលខ្លួនរៀបនិយាយត្រូវបានផ្តន្ទាទោសដល់ជីវិតរួចជាស្រេច ។ ដំណើរការធ្វើឡើងនៅមន្ទីរសន្តិសុខស-២១ ពេលខ្លះហាក់ដូចជាមានលក្ខណៈដូចគ្នានឹងដំណើរការរបស់ រ៉េត ឃ្វីន នៅក្នុងរឿង «អាលីស អ៊ិនវ៉ុនដ័រលែន» និងរឿងប្រលោមលោករបស់ កាហ្វកា ដែលមានចំណងជើងថា «ការជំនុំជម្រះក្តី» ដែរ ។ ម្យ៉ាងទៀត អ្នកដែលមាន «កំហុស» ច្បាស់ក្រឡែតប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ អាចសមតែ (បើផ្អែកការយល់ឃើញពីខាងក្រោយ) ជាវីរបុរសពិតៗ ចំណែកឯជនរងគ្រោះជា «ជនស្លូតត្រង់គ្មានកំហុស» ដែលប្រឆាំងហើយសមគំនិតជាមួយនឹងមាគ៌ាដឹកនាំនិងការអនុវត្តជាក់ស្តែង មិនគួរចាំបាច់ផ្តល់កិត្តិយសថាជាពលរដ្ឋគោរពច្បាប់ដោយរបបមួយដែលធ្វើការបោសសម្អាតទាំងកំហុសតាមរយៈប្រព័ន្ធតុលាការឡើយ ។ នៅក្នុងពិភពពេញទៅដោយការជ្រួលច្របល់នៃរបបកម្ពុជាប្រជាធិបតេយ្យក៏ដូចបដិវត្តន៍បារាំងនិងប្រទេសអឺរ៉ុបដែលត្រូវកាន់កាប់កាលពីសង្គ្រាមលោកលើកទីIIដូច្នោះដែរ ភាពមានទោសនិងភាពគ្មានទោសតែងតែទទួលឥទ្ធិពលដោយសារការឡើងចុះពីអំណាចរបស់ថ្នាក់ដឹកនាំ ។

ការឆ្លើយតបផ្សេងគ្នារបស់ប្រជាជនបារាំងចំពោះការកាន់កាប់របស់អាល្លឺម៉ង់ក្នុងសង្គ្រាមលោកលើកទីII បង្ហាញឲ្យឃើញពីការប្រៀបធៀបយ៉ាងមានប្រយោជន៍ទៅនឹងព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាដោយពាក្យផ្សេងៗគ្នាដូចជា «អាត្មានិយម» «ជាតិនិយម» និង «ការក្បត់» ដែលអំពើទាំងនេះអាស្រ័យថា តើអ្នកណាខ្លះធ្វើបដិវត្ត ហើយនៅកន្លែងណា ពេលណា និងដល់កម្រិតណា ។ បើធ្វើការប្រៀបធៀបឲ្យជ្រៅជាងនេះទៀត ឃើញថាព្រឹត្តិការណ៍ទាំងនេះបានកើតមានឡើងចំពោះកម្មាភិបាលបក្សកុម្មុយនិស្តកម្ពុជាក្រោយឆ្នាំ១៩៧៧ ឬក៏មុននេះ ដែលដឹកនាំគាំទ្រដោយបរទេស (វៀតណាម) ឬក៏បដិវត្តន៍របៀបវៀតណាមនាំឲ្យមានការលួចឆក់ ភាពរាលដាលនៃទុរ្ភិក្ស និងអំពើឃោរឃៅមិនរើសមុខនិងគ្មានព្រំដែននៃកម្ពុជាប្រជាធិបតេយ្យ ។ នៅត្រឹមឆ្នាំ១៩៧៨ មានប្រជាជនកម្ពុជារាប់ពាន់នាក់ដែលត្រូវបន្ទយការបាត់បង់របស់ខ្លួន បានត្រូវដាក់ឲ្យស្ថិតនៅក្រោមអំណាចរបស់វៀតណាមនិងលទ្ធភាពនៃការគ្រប់គ្រងថ្មី ។ តាំងពីដើមមកហាក់ដូចគ្មាននរណាម្នាក់យល់ថា កម្ពុជាប្រជាធិបតេយ្យមានការដឹកនាំគម្រក់ឡើយ ។ ក្នុងករណីប្រហាក់ប្រហែលគ្នានេះ មានពលរដ្ឋបារាំងតិចណាស់ដែលបានប្រឆាំងនឹងប៉េតាំង(ក្រុម) ក្នុងឆ្នាំ១៩៤០ ប៉ុន្តែក្រោយមកនៅឆ្នាំ១៩៤៣ ពលរដ្ឋបារាំងជាច្រើនបានបែរមកប្រឆាំងនឹងប៉េតាំងវិញ ។ ប៉ុន្តែនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនាឆ្នាំ១៩៧៧ និង១៩៧៨ អ្នកចុះចូលនឹងរបបកម្ពុជាប្រជាធិបតេយ្យបានត្រូវដាក់ទោសដោយរដ្ឋាភិបាលដែលយល់ថាអ្នកទាំងនោះបានរត់ចូលមកខាងអ្នកឈ្នះវិញ ។

ការធ្វើវិសុទ្ធកម្មក្នុងភូមិភាគបូព៌ានៃប្រទេសកម្ពុជានៅឆ្នាំ១៩៧៨ ក្នុងគោលបំណងបំបាត់ការប្រឆាំងតវ៉ានិងទប់ស្កាត់កុំឲ្យប្រជាជនរត់ទៅប្រទេសវៀតណាមកាន់តែច្រើនឡើងៗនោះ បានបង្កឲ្យមានផលប៉ះពាល់ដល់ការប្រឆាំងរបស់អ្នកដែលនៅរស់រានមានជីវិតដោយមិនដឹងខ្លួន ។ អ្នកដែលបានរួចផុតពីការធ្វើវិសុទ្ធកម្ម ដូចជាមេដឹកនាំសំខាន់ៗ ហេង សំរិន ជា ស៊ីម និង ស ខេង ក៏បានចូលរួមជាមួយ "ខ្មែរហាណូយ" ដែលរួចខ្លួននិងអ្នកចុះចូលតាំងពីមុនមកមួយចំនួនទៀតដើម្បីបង្កើតជារបបមួយចាប់ផ្តើមគ្រប់គ្រងប្រទេសក្រោយពីមានការឈ្លានពានលុកលុយរបស់វៀតណាម ។

ហេតុផលចុងក្រោយគឺថាអំពើឃោរឃៅគួរឲ្យភ្ញាក់ផ្អើលនៃរបបកម្ពុជាប្រជាធិបតេយ្យប្រឆាំងនឹងប្រជាជនខ្លួនឯងដែលត្រូវបានចងក្រងនៅបណ្ណសារដ្ឋានរបស់មន្ទីរសន្តិសុខស-២១ បានរួមបញ្ចូលនូវភាពអាចមានដែលថាក្នុងករណីណាមួយនោះ ប៉ុល ពត និងដៃដើងមានភ័ស្តុតាងបញ្ជាក់អំពីការសមគំនិតផ្តួលរំលំរបបដែលខ្លួនដឹកនាំ ។ ដូច ស៊ីវ ហេដឌ័រ មានប្រសាសន៍យ៉ាងដូច្នោះដែរថា មានចម្លើយសារភាពច្រើនណាស់ដែលមានបញ្ជាក់ត្រង់ចំណុចនេះ ទោះបីជាគ្មានការអះអាងថាវាពិតក៏ដោយ ហើយវាជាការខុសឆ្គងមួយក្នុងការចាត់ទុកអ្នកទាំងអស់នៅមន្ទីរស-២១ សុទ្ធតែជា "ជនគ្មានកំហុស" គ្មានពាក់ព័ន្ធក្នុងការរួមគំនិតពីព្រោះចម្លើយសារភាពរបស់ខ្លួននិយាយពីអ្វីដែលមិនសមហេតុផលដោយសារតែរបបដែលខ្លួនរស់នៅនោះវាអាក្រក់ ឬដោយសារតែអ្នកទោសទាំងនោះត្រូវបានធ្វើទុក្ខបុកម្នេញឃោរឃៅព្រៃផ្សៃខ្លាំងពេក ។

## មូលហេតុដែលនាំឱ្យមានបណ្ណសារ

ដោយទុកនូវសំណួរស្តីអំពីយុត្តិធម៌ ការពិតភាពគ្មានទោសនិងភាពមានទោសដោយឡែក យើងចាំបាច់ត្រូវសួរថា ហេតុអ្វីបានជាបណ្ណសារមន្ទីរស-២១ មានឯកសារសន្ទឹកសន្ធាប់ម្ល៉េះ ហើយហេតុអ្វីបានជាបណ្ណសារនេះត្រូវបានថែរក្សាទុក បើឯកសារទាំងនោះសុទ្ធតែជាឯកសារសម្ងាត់ភាគច្រើនសុទ្ធតែមិនពិត ហើយអ្នកទោសទាំងអស់ត្រូវបានសម្លាប់នោះ ។

យើងដឹងថា របបកម្ពុជាប្រជាធិបតេយ្យបានចងក្រងជាឯកសារទុកយ៉ាងច្រើនសន្ធឹកសន្ធាប់លើសពីការគិតរបស់អ្នកសង្កេតការណ៍កាលពីទសវត្សរ៍ឆ្នាំ៨០ទៅទៀត ហើយគ្មានអ្នកក្រៅណាអាចមានឱកាសប្រើប្រាស់ឯកសារទាំងនោះដោយងាយឡើយ លើកលែងតែឯកសារនៅគុកទួលស្លែងប៉ុណ្ណោះ ។ នៅពេលនោះដោយមានការចាប់អារម្មណ៍នឹងបណ្ណសារនៅមន្ទីរស-២១ ដ៏សម្បូរហូរហៀរនិងប្រហែលជាប្រភពនៃឯកសារដើមដែលនិយាយពីរបបកម្ពុជាប្រជាធិបតេយ្យ យើងក៏ជឿជាក់ថាឯកសារដទៃៗទៀតរបស់របបនេះ ប្រសិនបើនៅមានវាពិតជាមិនខុសគ្នានឹងរូបភាពទូទៅដែលស្តែងចេញតាមរយៈការរៀបរាប់របស់អ្នកនៅរស់រានមានជីវិតឡើយ ។[២៦] ប៉ុន្តែចាប់តាំងពីឆ្នាំ១៩៩៤មក ឯកសារកម្ពុជាប្រជាធិបតេយ្យរាប់សែនសន្លឹករួមមានឯកសារនិយាយអំពីមន្ទីរស-២១ ត្រូវបានរកឃើញ ។ ភាគច្រើននៃឯកសារទាំងនេះត្រូវបានផ្ទេរដោយរដ្ឋាភិបាលកម្ពុជាទៅឲ្យកម្មវិធីសិក្សាអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ដែលចាត់ចែងដោយសាកលវិទ្យាល័យយែល ។ ឯកសារផ្សេងៗទៀតត្រូវបានរកឃើញនៅមន្ទីរស-២១ផ្ទាល់ក្រោយពីថត

ចម្លងដោយឧបករណ៍អេឡិចត្រូនិករួចកាលពីឆ្នាំ១៩៩៣ ។[២៧]

ឯកសារទាំងនេះភាគច្រើនសុទ្ធតែជាឯកសារវាយអង្គុលីលេខ ហើយជាច្រើនផ្សេងទៀតជាឯកសារចម្លង ។ សំឡេងរបស់ម៉ាស៊ីនវាយអក្ខរទឯកសារ (អង្គុលីលេខ) ចាស់ៗនៅក្នុងអគារទ្រុឌទ្រោមស្ថិតនៅរាយប៉ាយគ្មានសណ្តាប់ធ្នាប់ ប្រហែលជាសំឡេងមួយបញ្ជាក់ពីសកម្មភាពរបស់មនុស្សនៅទីក្រុងភ្នំពេញ ។ មិនតែប៉ុណ្ណោះ យើងដឹងទៀតថាឯកសារច្រើនគរដូចភ្នំរបស់របបកម្ពុជាប្រជាធិបតេយ្យដែលឥឡូវនេះត្រូវបានអ្នកសិក្សាជាន់ខ្ពស់យកមកប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវរបស់ខ្លួន គឺគ្រាន់តែជាឯកសារមួយភាគនៃឯកសារដែលបានផលិតឡើងកាលពីសម័យនោះប៉ុណ្ណោះ ។ មានឯកសារជម្រើសដ៏ក្រាស់ក្រែលផ្សេងទៀត នៃរបបកម្ពុជាប្រជាធិបតេយ្យដែលមិនទាន់បានយកមកប្រើប្រាស់មានស្ថិតនៅក្នុងប្រទេសកម្ពុជានិងប្រទេសវៀតណាមនៅឡើយ ។[២៨]

ដូច្នេះបណ្ណសារនៅមន្ទីរស-២១ ពិតជាមិនមែនធម្មតា ទាំងចំនួននិងផ្នែកបច្ចេកទេស ។ ប៉ុន្តែហេតុអ្វីបានជាខ្មែរក្រហមចម្រាញ់យកចម្លើយសារភាពដ៏វែងគ្បោះក្បាយពីមនុស្សដែលខ្លួនបានថ្កោលទោសអស់មួយជីវិត ហើយរៀបចំឯកសារទុកក្រោយពីអ្នកទោសត្រូវបានសម្លាប់ចោលហើយនោះ? ។ លទ្ធភាពទីមួយបើតាមចម្លើយដ៏ច្រើនលើសលប់របស់បុគ្គលិកធ្វើការនៅមន្ទីរស-២១ បង្ហាញច្បាស់ណាស់ថា ខ្លួនមិនចង់ឲ្យអ្នកត្រួតត្រានៅពីលើខ្លួនខឹង ទោះជាត្រូវលះបង់អ្វីក៏សុខចិត្តដែរ ។ ដើម្បីឲ្យមានសុវត្ថិភាពចំពោះខ្លួនឯងបុគ្គលិកនៅមន្ទីរស-២១របស់ខ្មែរក្រហមបានចាត់ការចំពោះ«ខ្មាំង»របស់របបខ្លួនយ៉ាងហ្មត់ចត់តាមតែអាចធ្វើទៅបាន ហើយរក្សានូវឯកសារទាំងអស់ជាភ័ស្តុតាងដើម្បីបញ្ជាក់ថាខ្លួនពិតជាបានធ្វើការយ៉ាងសកម្ម ។ លទ្ធភាពទីពីរ ប្រហែលជាការពិតដែរដែលថាអ្នកគ្រប់គ្រងគុកដែលមានជំនឿស៊ប់ទៅលើរបបកម្ពុជាប្រជាធិបតេយ្យអន្ទះសាចង់ដឹងពីអំពើក្បត់ចំពោះ «បក្សជាទីស្រឡាញ់របស់ខ្លួន» ហើយសង្ឃឹមថានឹងបានដឹងស៊ីជម្រៅថែមទៀតចំពោះផែនការរបស់អ្នកប្រឆាំងនឹងបដិវត្តន៍ ។ លទ្ធភាពទីបី អ្នកទោសចេះតែឆ្លើយសារភាពប៉ាតណាប៉ាតណី ដើម្បីរួចខ្លួនឬបង្អាក់ការធ្វើទារុណកម្មនិងការយកជីវិតរបស់ខ្លួន ។ លទ្ធភាពចុងក្រោយ គឺហាក់ដូចជាច្បាស់ណាស់ថា សុន សេន និងអតីតគ្រូបង្រៀនផ្សេងទៀតដែលចាត់ចែងការងារនៅក្នុងគុក ចង់គ្រប់គ្រងប្រតិបត្តិការសន្តិសុខដោយប្រុងប្រយ័ត្ន ដើម្បីឲ្យអន្តរជាតិទទួលស្គាល់របបកុម្មុយនិស្តរបស់ខ្លួន និងដើម្បីបំពេញបំណងខ្លួនឯងផ្ទាល់តែម្តង ។

ការពន្យល់ហេតុផលទាំងនេះពិតជាអាចជួយបង្ហាញផ្លូវ ប៉ុន្តែការឲ្យយោបល់ដែលផ្តល់អត្ថប្រយោជន៍មួយដោយលោក ស្ទីវ ហេដឌ័រ កាលពីយូរណាស់មកហើយគឺថាបណ្ណសារនេះបានប្រមូលផ្តុំដើម្បីផ្តល់ឲ្យមជ្ឈិមបក្សនូវឯកសារដើមសរសេរដោយដៃយ៉ាងច្រើនក្រាស់ក្រែលស្តីអំពីប្រវត្តិរបស់បក្ស ។[២៩] ពត៌មានលម្អិតស្តីអំពីការសមគំនិតក្បត់ អាចកាត់បន្ថយនូវការអន្ទះសាចង់ដឹងចង់យល់របស់ ប៉ុល ពត ព្រមទាំងបក្ខពួកដែលធ្លាប់ជាអ្នកក្បត់ចំពោះអ្វីដែលកំពុងកើតឡើងនៅក្រោយខ្នងក្នុងពេលបក្កប់ខ្លួនក្នុងទសវត្សរ៍ឆ្នាំ១៩៥០ លាក់ខ្លួននៅទសវត្សរ៍ឆ្នាំ១៩៦០ និងចល័តខ្លួនក្នុងអំឡុងសង្គ្រាមស៊ីវិល ។ លើសពីនេះទៅទៀត ដោយសារតែអ្នកទោសទាំងអស់ដែលត្រូវឃុំខ្លួននៅក្នុងគុក ចុងបញ្ចប់ត្រូវបាន«កម្ទេច»គ្មានសល់ ។ ចម្លើយ

សារភាពរបស់អ្នកទោសទាំងអស់មិនត្រឹមតែបានបញ្ជាក់ពីឧក្រិដ្ឋកម្មរបស់ខ្លួនទេ តែថែមទាំងបញ្ជាក់ពីអំណាចនិងរឿងរ៉ាវសព្វបែបយ៉ាងរបស់បក្សទៀតផង ។ ដូចអត្ថបទប្រវត្តិសាស្ត្របក្សដែរ ចម្លើយសារភាពទាំងអស់បានប្រាប់មេដឹកនាំបក្សឲ្យដឹងអំពីចំណុចខ្មាំងដឹកប្រឆាំងនឹងបក្សដែលធ្វើឲ្យប្រវត្តិជ័យជម្នះរបស់បក្សកាន់តែមានលក្ខណៈដូរផង់ឡើង ។ គំរូដែល ប៉ុល ពត និងអ្នកធ្វើការជុំវិញគាត់កំពុងតែធ្វើគឺដើរតាមប្រវត្តិសាស្ត្ររបស់បក្សកុម្មុយនិស្តសហភាពសូវៀតដែលបោះពុម្ពកាលពីឆ្នាំ១៩៣៩ ។ នៅក្នុងឯកសារនោះមានខ្លឹមសារជាច្រើនមានលក្ខណៈស្រដៀងគ្នាទៅនឹងអ្វីដែលបានអនុវត្តនៅប្រទេសបារាំងដែរ ។ ឯកសារប្រវត្តិសាស្ត្របក្សនេះមានរៀបរាប់ពីព្រឹត្តិការណ៍នៃជ័យជម្នះរបស់ ស្តាលីន ទៅលើខ្មាំងផ្ទៃក្នុងរបស់បក្សថែមទៀត ។[៣០]

តាមលក្ខណៈចិត្តសាស្ត្រ ការអានចម្លើយសារភាពនិងរបាយការណ៍សម្ងាប់មនុស្ស និងការមើលរូបថតរបស់ខ្មាំងដែលត្រូវសម្លាប់ច្បាស់ជាធ្វើឲ្យ «បង១ ថ្នាក់លើ»មានអារម្មណ៍មុតមាំក្នុងចិត្តមួយអន្លើមិនខាន ។ មិនខុសពីមេដឹកនាំផ្តាច់ការផ្សេងៗទៀតឡើយ ប៉ុល ពត និងបក្ខពួកជឿជាក់ថាខ្លួនបានត្រូវហ៊ុមព័ទ្ធដោយខ្មាំងសត្រូវដែលសមគំនិតក្នុងការផ្តួលរំលំខ្លួន ។ អ្នកទោសនៅមន្ទីរស-២១បានក្លាយទៅជាកម្មវត្ថុនៃគំនិតរវើរវាយរបស់បង១ថ្នាក់លើ ហើយបានធ្វើឲ្យសុបិនរបស់បង១ទាំងនោះក្លាយជាការពិតក្នុងរយៈពេលយូរល្មមគ្រប់គ្រាន់ដើម្បីញ៉ាំងឲ្យជឿថាសត្រូវរបស់ខ្លួនកំពុងតែត្រូវបានបង្ក្រាបហើយ ។ ដោយការដឹកនាំប្រទេសពោរពេញទៅដោយអំពើភេរវកម្ម មេដឹកនាំកម្ពុជាប្រជាធិបតេយ្យហាក់ដូចជាបន្ទាបខ្លួនឯងដូចអ្វីដែល អែង ដែល បានធ្វើការកត់សម្គាល់ទៅលើសម្តីរបស់ ម៉ាក្ស កាលពីខែកញ្ញា ឆ្នាំ១៨៧០ ក្នុងអំឡុងនៃការកាន់កាប់ទីក្រុងប៉ារីសថា «យើងយល់ថារបបដែលពោរពេញទៅដោយអំពើភេរវកម្មជារបបដឹកនាំរបស់មនុស្សមួយក្រុមដែលបង្កឲ្យមានអំពើភេរវកម្ម ។ ប៉ុន្តែផ្ទុយមកវិញ នេះជាការគ្រប់គ្រងរបស់អ្នកដែលទទួលការបំភិតបំភ័យដោយអំពើភេរវកម្មផ្ទាល់របស់ខ្លួន ។ *La Terreur* មានន័យថា អំពើឃោរឃៅមិនចាំបាច់ប្រព្រឹត្តឡើងដោយអ្នកដែលត្រូវបានបំភិតបំភ័យ» ។[៣១]

អ្នកសួរចម្លើយនៅមន្ទីរស-២១មានរបៀបធ្វើការដូចអ្នកព្យាបាលរោគដែលហាត់រៀនមិនដិតដល់ដោយដឹកគាស់ឆ្អឹះឆ្អៀល«អតីតកាល»ដែលកប់បាត់របស់អ្នកទោស ដូចអ្នកព្យាបាលរោគពិនិត្យតាមដានជំងឺឆ្កួតដូច្នោះដែរ ។ អ្នកជំងឺដែលលើកយកមកនិយាយនៅទីនេះមិនមែនជាអ្នកទោសដូចដែលអ្នកខ្លះគិតឡើយ ទោះបីជាមានការកែទម្រង់របៀបសួរចម្លើយតាមរបៀបចិនខ្លះក៏ដោយ ។ ប៉ុន្តែអ្នកជំងឺ ប្រយ៉ាងហោចណាស់អ្នកដែលទទួលផលពីការព្យាបាលជំងឺគឺអ្នកនៅក្នុងជួរមជ្ឈិមបក្ស ដែលភាពអន្ទះសានិងកំហឹងរបស់ខ្លួនបានរួមបង្កឡើងដោយអ្នកទោសនិងឧក្រិដ្ឋកម្មរបស់អ្នកទោសដែលត្រូវបានជំរុញឲ្យខំ«ចងចាំ»និងសារភាពចេញមក ។ នៅពេលដែលខ្មាំងត្រូវបានកម្ទេចទាំងខ្សែៗនៅមន្ទីរស-២១ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យអាចគិតថា ខ្លួនជាអ្នកធ្វើត្រូវនិងត្រូវបានធានា ។ ប៉ុន្តែទន្ទឹមនឹងនោះដែរ ខ្មាំងមួយក្រុមផ្សេងទៀតបានបន្តសកម្មភាពរបស់ខ្លួនកាន់តែខ្លាំងឡើងៗ ។

ដំណើរការសួរចម្លើយដែលធ្វើឡើងនៅមន្ទីរស-២១មានលក្ខណៈសំខាន់និងគ្រោះថ្នាក់ប្រហាក់ប្រហែល

និងការផ្សៀងផ្ទាត់ផ្នែកចិត្តសាស្ត្រដែរ ។ ដោយដើរតួជាប្រភពសំខាន់ចំពោះប្រវត្តិសាស្ត្រច្បាប់ដែលមិនទាន់សរសេរ និងជាឧបករណ៍សម្រាប់ព្យាបាលរោគដែលមានសារសំខាន់សម្រាប់មជ្ឈិមបក្ស ការសួរចម្លើយ និងចម្លើយសារភាពបានផ្តល់ដល់មជ្ឈិមបក្សនូវអ្វីដែលចិត្តវិទូឈ្មោះ ដូណាល់ ស្ពេនស៍ ហៅថា “ការពិតដែលចេញមកពីការរៀបរាប់តាមវគ្គតាមស្នើ” ។ របៀបសួរចម្លើយ និង ការឆ្លើយសារភាពមានលក្ខណៈដូចជា មេដឹកនាំនយោបាយនិងប្រហែលជាដូចមនុស្សទូទៅដែរ ។[៣២] ប៉ុន្តែទំនាក់ទំនងរវាងចម្លើយសារភាពទៅនឹងគំនិតផ្ទុយរបស់ ស្ពេនស៍ “ការពិតជាប្រវត្តិសាស្ត្រ”មិនអាចបញ្ជាក់ឲ្យបានច្បាស់ឡើយ ទើបតែពេលដែលបណ្ណសាររបស់កម្ពុជាប្រជាធិបតេយ្យត្រូវបានស្រាវជ្រាវរកឃើញឬពេលដែលអតីតសមាជិករបស់បក្សនិយាយចេញមក ទើបការពិតនៃទំនាក់ទំនងនេះត្រូវបានបញ្ជាក់ច្បាស់ ។ ទន្ទឹមនឹងនេះ ការអានចម្លើយសារភាពបាននាំយើងទៅដល់ដំណើរគិតគូររបស់របបប្រកាន់គំនិតចាស់គំរិលមួយដែលធ្លាប់ត្រូវបានធ្វើឲ្យភ័យខ្លាចនិងធ្វើឲ្យមានការភ័យខ្លាច មានគំនិតដាច់ខាតពោរពេញដោយល្បិចកលខ្ពស់និងស្ថិតក្រោមការគំរាមកំហែងឥតឈប់ឈរ ។ ចម្លើយសារភាពបានធ្វើឲ្យដឹងនូវការរៀបរាប់អំពីការភ័យខ្លាចដែលចេះតែកើនឡើងជាលំដាប់និងការគិតមមៃរបស់មជ្ឈិមបក្ស ក្នុងខណៈដែលយុវជនយុវនារីដែលពោរពេញដោយគំនុំនិងគំនិតហួសវិស័យបានតស៊ូយ៉ាងស្វិតស្វាញក្នុងការថែរក្សាជាតិមួយប្រកបដោយជំហរធ្វើសង្គ្រាមសមូហភាវូបនីយកម្មសម្រេចឯករាជ្យម្ចាស់ការផ្នែកសេដ្ឋកិច្ច បង្ក្រាបការខ្វែងគំនិតនិងការផ្តុំមជ្ឈការទៅលើអំណាចរបស់ខ្លួន ។

## ព្រឹត្តិការណ៍ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៦

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ កិច្ចប្រជុំមួយដែលរៀបចំឡើងដោយមជ្ឈិមបក្សបានបង្កើតជំហានជាច្រើនក្នុងគោលបំណង“កម្ទេច(មនុស្ស) ខាងក្នុងនិងខាងក្រៅជួរ” ។ ជំហានទាំងនេះបង្ហាញពីការគ្រប់គ្រងទៅលើ“ការកម្ទេច”ខ្លាំង ការធ្វើឲ្យអង្គការមានលក្ខណៈសមរម្យ“ដើម្បីពង្រឹងអំណាចរបស់រដ្ឋយើង” ។ អង្គការនៅទីនេះគឺមានការទទួលខុសត្រូវចំពោះមជ្ឈិមបក្ស ។...សេចក្តីយោងពីខាងដើមដែលនៅមានលក្ខណៈអាថ៌កំបាំងនៅឡើយ មានភាពខ្វះចន្លោះ មិនគ្រប់គ្រាន់ដូចដែលអ្នកស្រាវជ្រាវបានធ្វើឡើយ ក្នុងការបង្ហាញភ័ស្តុតាងចោទប្រកាន់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យពីបទធ្វើមនុស្សឃាតយ៉ាងធំដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងរបបកាន់កាប់របស់ខ្លួន ។

កិច្ចប្រជុំនោះក៏បានលើកបញ្ហាមួយចំនួនមកពិភាក្សា ដូចជាការរុញ សម្តេច សីហនុ ចេញពីតួនាទីជាប្រមុខរដ្ឋ ការបិទវិហារកាតូលិកនៅក្នុងទីក្រុងភ្នំពេញ ប្រវត្តិរបស់បក្ស ផែនការសេដ្ឋកិច្ច ថ្ងៃឈប់សម្រាកជាផ្លូវការ និងអង្គការចាត់តាំងរបស់រដ្ឋាភិបាល ។ បើយកមកអានពេលនេះ អ្នកអានពិតជាដឹងនូវភាពគ្មានសណ្តាប់ធ្នាប់របស់របបមួយដែលទើបតែឡើងកាន់អំណាច ហើយដែលមេដឹកនាំរបស់របបនេះកំពុងតែរង់ចាំពង្រីកនិងផ្សព្វផ្សាយជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ របស់ខ្លួនទៅលើ“អាមេរិក” ឲ្យប្រជាជនទូទាំងប្រទេសបានដឹងពុ ។[៣៣]

បីថ្ងៃក្រោយមក នៅពេលព្រលឹមស្រាងៗ មានគ្រាប់បែកផ្ទុះនៅជិតព្រះបរមរាជវាំង ហើយមានការបាញ់កាំភ្លើងដាក់សារមន្ទីរជាតិដែលស្ថិតនៅក្នុងក្រុងភ្នំពេញ ។ សារមន្ទីរជាតិនិងព្រះបរមរាជវាំងស្ថិតនៅមិនឆ្ងាយប៉ុន្មានពីបរិវេណអគារដែលមានការយាមកាមយ៉ាងប្រុងប្រយ័ត្នដែល "បង១ថ្នាក់លើ" ចូលមកនៅដោយសម្ងាត់នោះទេ ។ ប៉ុន្តែការផ្ទុះនោះមិនមានភ័ស្តុតាងច្បាស់ណាមួយបញ្ជាក់ពីការបាត់បង់ជីវិតខូចខាតសម្ភារ ឬក៏សកម្មភាពក្បត់ឡើយ ។ មូលហេតុដែលនាំឲ្យកើតព្រឹត្តការណ៍នេះឡើងមិនទាន់មានលក្ខណៈច្បាស់លាស់ទេ ប៉ុន្តែ"បង១ថ្នាក់លើ"យល់ថា វាជារឿងមួយធ្ងន់ធ្ងរជាទីបំផុត ។ នៅក្នុងថ្ងៃដដែលសម្តេច សីហនុ បានត្រៀមខ្លួនលាលែងពីតំណែងជាប្រមុខរដ្ឋ ។ កងទ័ពសំណាងអាក្រក់ដែលបានចោលគ្រាប់បែក គ្មានបានដឹងអ្វីដែលកើតឡើងនៅខាងក្រោយខ្លួនឡើយ ។ មេដឹកនាំប្រទេសដែលប្រាស់ប្រាល់នៅមិនស្រណុកយល់ថា ឧបទ្ទវហេតុនេះជាសញ្ញាបង្ហាញពីការធ្វើរដ្ឋប្រហារ ។ ពេលនោះអ្នកចោលគ្រាប់បែកត្រូវបានចាប់ខ្លួនក្នុងអំឡុងពេលមួយសប្តាហ៍ហើយកាសែរុតថតចម្លើយសារភាពរបស់ជនដែលត្រូវបានចាប់ខ្លួន រួមទាំងចំណាររបស់ ឌុច ត្រូវបានបញ្ជូនជាបន្ទាន់ទៅឲ្យមជ្ឈិមបក្ស ។[៣៨]

ជនល្មើសដែលចាប់បានគឺជាកងទ័ពក្នុងកងពលលេខ១៧០ ដែលជាកងពលមួយបំបែកចេញពីកងពលលេខ១ ក្រោយខែមេសា ឆ្នាំ១៩៧៥ និងដែលជ្រើសរើសទ័ពពីភូមិភាគបូព៌ាក្នុងអំឡុងពេលសង្គ្រាមស៊ីវិល ។ នៅពេលផ្ទុះគ្រាប់បែកនោះ កម្លាំងកងពល១៧០ឈរជើងនៅជាយក្រុងភ្នំពេញជាកន្លែងដែលកងទ័ពត្រូវបានចាត់តាំងឲ្យទៅធ្វើស្រែ ដែលកងទ័ពភាគច្រើនយល់ថាជាការផ្សារអន់ ។

ដោយធ្វើតាមបញ្ជារបស់មន្ទីរសន្តិសុខស-២១ ដែលសហការជាមួយនឹងសន្តិសុខជុំវិញនោះ ជនល្មើសត្រូវបានបង្ខំឲ្យរៀបរាប់ឈ្មោះមេកោយរបស់ខ្លួន ។ មិនយូរប៉ុន្មានជនសង្ស័យក៏និយាយពាក់ព័ន្ធទៅដល់ ចាន់ ចក្រី ដែលជាកងទ័ពនៅភូមិភាគបូព៌ានិងជាអតីតព្រះសង្ឃ ។ ចក្រី មាននាទីជាស្នងការនយោបាយកងពលលេខ១៧០ ។ ក្រៅពីមុខងារនេះ ចក្រី ដែលមានអាយុសាមសិបបីឆ្នាំ ក៏មានតួនាទីជាអនុលេខាសេនាធិការជាតិដែលទើបតែបង្កើតថ្មីក្រោមការគ្រប់គ្រងរបស់ សុន សេន ។[៣៩]

ចក្រី ធ្លាប់បានរត់ចោលជួរយ៉ាងហោចណាស់មួយដងដែរ ។ កាលពីឆ្នាំ១៩៧៥ ចក្រី ត្រូវបានតាមដានដោយបក្សកុម្មុយនិស្តកម្ពុជា ។ មកដល់ថ្ងៃទី១៩ ខែឧសភា ក៏ត្រូវចាប់ខ្លួនបញ្ជូនមកមន្ទីរសន្តិសុខស-២១ ដែលនៅទីនោះ ចក្រី ត្រូវបានពាក់ផ្លាកលេខរ៉ូម៉ាំង I ជាលេខ "ខ្សែមេៗ" របស់អ្នកដែលត្រូវចោទថាជាជនក្បត់ ដែលមានចំនួនរហូតដល់ទៅម្ភៃនាក់នៅចុងឆ្នាំ១៩៧៥ ។ នៅក្នុងរយៈពេលបួនខែនៃការសួរចម្លើយរបស់អង្គការ ចក្រី បានឆ្លើយថាមានពាក់ព័ន្ធជាមួយនឹងរដ្ឋាភិបាល លន់ ណុល និងខ្មែរសេរី ជាកងទ័ព និងជាចលនាប្រឆាំង សម្តេច សីហនុ ដែលមានមូលដ្ឋាននៅវៀតណាមខាងត្បូង រហូតមកដល់ឆ្នាំ១៩៧៥ ។ ក្រៅពីនេះ ចក្រី បាននិយាយថា ខ្លួនមានផែនការធ្វើឃាត សម្តេច សីហនុ និងដាក់ថ្នាំបំពុល "បង១ថ្នាក់លើ" ។ ក្រោយពីមានការចាប់ខ្លួន ចក្រី រួចមក លី វ៉ាយ អនុលេខាកងពលលេខ១៧០ (លេខ II) ត្រូវបានចាប់បញ្ជូនមកមន្ទីរសន្តិសុខស-២១ ។ នៅក្នុងចម្លើយសារភាពរបស់ខ្លួន លី វ៉ាយ និយាយទាំងមិនច្បាស់លាស់ថា ខ្លួន "ចង់បង្កអសន្តិសុខនៅក្នុងទីក្រុងភ្នំពេញ" ។ ចំណែកឯ ចក្រី វិញ និយាយពាក់ព័ន្ធដល់

លី ផេន (លេខ**IV**) ស្នងការនយោបាយកងទ័ពភូមិភាគបូព៌ា រស់ ភួង នៅកងពលលេខ១៧០ (លេខ**VII**) និង សួស នៅ ហៅ ឈូក (លេខ**VIII**) ដែលជាលេខាតំបន់២៤ ភូមិភាគបូព៌ា ។ លី ផេន ត្រូវបានចាប់ខ្លួននៅខែមិថុនា ឆ្នាំ១៩៧៦ រស់ ភួង នៅខែកក្កដា និង ឈូក នៅខែសីហា ។

ឈូក គឺជាមនុស្សរបស់លេខាភូមិភាគឈ្មោះ សោ ភឹម ដែលជាអ្នកបដិវត្តជាន់ខ្ពស់ធ្លាប់ធ្វើការជិតដិតជាមួយនឹងមជ្ឈិមបក្ស ប៉ុន្តែត្រូវបានសង្ស័យរួចទៅហើយថាក្បត់ ពីព្រោះគាត់មានទំនាក់ទំនងជាមួយកម្មាភិបាលវៀតណាមកាលពីទសវត្សរ៍ឆ្នាំ១៩៥០ ។ សោ ភឹម ពេលនោះជាគណៈកម្មាធិការសន្តិសុខកងទ័ពដែលត្រូវបានចោទថាបានចេញនយោបាយវិសុទ្ធកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។[៣៦]

ចម្លើយសារភាពរបស់ ឈូក ត្រូវនឹងអ្វីដែលមជ្ឈិមបក្សចង់បាន ពីព្រោះ ឈូក មានទំនាក់ទំនងជាមួយនឹង សោ ភឹម ។ នៅក្នុងសេចក្តីដកស្រង់មួយចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៦ ពាក្យប្រឌិតមានលក្ខណៈដូចបណ្តសារដែរនោះ សរសេរថា សោ ភឹម បានរៀបចំសួរចម្លើយខ្លួន ។ យើងដឹងតាមរយៈចម្លើយសារភាពរបស់ ភួង កាលពីឆ្នាំ១៩៧៨ថា ការចាប់ខ្លួន ឈូក កាលពីឆ្នាំ១៩៧៦ ត្រូវបានពន្យារពេលរហូតដល់ពេល សោ ភឹម ត្រឡប់មកពីបេសកកម្មនៅប្រទេសចិនវិញ ដូចនេះការសួរចម្លើយត្រួសៗអាចត្រូវបានធ្វើឡើង ។ សេចក្តីដកស្រង់មានដូចខាងក្រោម÷

> នៅក្នុងដំណាក់កាលទីពីរដែលបក្សបានសួរចម្លើយខ្ញុំដោយប្រើទារុណកម្ម (ឈូក សរសេរ) ខ្ញុំបាននិយាយអំពីការណែនាំរបស់ បងភឹម ដោយយល់ស្របធ្វើការចោទប្រកាន់ទៅលើឈ្មោះ កែវ មាស ។ អង្គការនៅតែមិនជឿខ្ញុំទៀត ព្រោះខ្ញុំមិនបានផ្តល់ចម្លើយពិតប្រាកដច្បាស់លាស់អំពីសកម្មភាពក្បត់ ។ ខ្ញុំមិនដឹងថា តើនរណាខ្លះនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍របស់មជ្ឈិមបក្សក្បត់ទេ ។ ខ្ញុំមិនដឹងថា តើមានប៉ុន្មាននាក់ក្បត់...ហើយក៏មិនដឹងថាគេបានធ្វើអ្វីដែរ ។ ខ្ញុំនិយាយពាក់ព័ន្ធដល់ កែវ មាស ប៉ុន្តែមិនដឹងថាគាត់នៅទីណាឡើយ ។ ខ្ញុំឆ្លើយដាក់វៀតណាមយ៉ាងលម្អិត តែសុទ្ធតែជាការប្រឌិតទាំងអស់ ។ សភាពរបស់ខ្ញុំចេះតែយ៉ាប់ទៅៗ ព្រោះអង្គការបានឲ្យខ្ញុំវែកមុខថ្នាក់ដឹកនាំរបស់អង្គការចាត់តាំង ។ ខ្ញុំបានព្យាយាមធ្វើការវាយតម្លៃនិងថ្លឹងថ្លែងរឿងពីរ÷ តើអ្នកណាខ្លាំងជាង...ក្រុមរបស់ខ្ញុំឬក៏បក្ស? ...ខ្ញុំប្រកាន់ខ្ជាប់នូវជំនឿជាក់ថា ទោះជាសន្តិសុខអប់រំខ្ញុំនិងជជីកសួរខ្ញុំយ៉ាងណាក៏ដោយ ក៏ខ្ញុំអាចលាក់បាំងនូវមនុស្សក្បត់របស់ ភឹម ដែរ ខ្ញុំនិយាយត្រឡប់ចុះត្រឡប់ឡើងធ្វើឲ្យពាក់ព័ន្ធដល់ក្រុមហាណូយ ក្រុមប្រឆាំងនិងក្រុមតូចៗផ្សេងទៀត ។ ក៏ប៉ុន្តែដោយសារមានការវិភាគរបស់បក្ស បក្សមិនព្រមទទួលយកនូវរបាយការណ៍របស់ខ្ញុំទេ ដោយនិយាយថារបាយការណ៍ទាំងអស់មិនច្បាស់ ហើយក៏ឲ្យខ្ញុំសរសេរម្តងទៀត ។ នេះជាពាក្យរបស់បក្សលើកឡើងចុងក្រោយដែលសុំឲ្យខ្ញុំពិចារណាឡើងវិញ ។ ពេលនោះ...ទោះជាខ្ញុំត្រូវបាត់បង់ជីវិតក៏ខ្ញុំត្រូវតែប្តេជ្ញាចិត្ត ឆ្លើយនឹងសំណួររបស់បក្សដោយស្មោះត្រង់ ស្តីពីអំពើក្បត់របស់ សោ ភឹម...ខ្ញុំសូមសន្យាថានឹងដើរតាមបក្សដាច់ខាត ។[៣៧]

## ការធ្វើវិសុទ្ធកម្មទៅលើកម្មាភិបាលថ្នាក់ខ្ពស់ក្នុងឆ្នាំ១៩៧៦

អ្នកក្រៅពី សោ ភឹម ដែល ឈូក បានឆ្លើយដាក់ ក៏មានកម្មាភិបាលជាន់ខ្ពស់មួយចំនួនទៀត ដូចជា ណៃ សារ៉ាន់ ហៅ យ៉ា (លេខIX) លេខាភូមិភាគឦសាន កែវ មាស (លេខX) ជនបដិវត្តន៍ជើងចាស់ ដែលឥឡូវនេះត្រូវបានឃុំខ្លួន និង នង សួន ហៅ ជ័យ (លេខXII) ដែលកំពុងបម្រើការជាលេខាខាងកសិកម្មរបស់កម្ពុជាប្រជាធិបតេយ្យ ។ អ្នកទាំងអស់នេះមិនមានអ្នកណាប្រាប់ថា បក្សមានការសង្ស័យលើខ្លួនឡើយ ហើយចេះតែធ្វើការជាធម្មតា ។ នៅក្នុងខែកក្កដានិងខែសីហា បក្សកុម្មុយនិស្តកម្ពុជាបានរៀបចំការប្រជុំមួយដើម្បីឲ្យសមាជិកបក្សយល់ជ្រួតជ្រាបអំពីផែនការបួនឆ្នាំដែលហៀបនឹងចេញប្រកាសជាផ្លូវការនៅក្នុងខែកញ្ញា ។ នៅក្នុងខែកញ្ញា ណៃ សារ៉ាន់ និង កែវ មាស ត្រូវបាននាំយកមកមន្ទីរសន្តិសុខស-២១ ។ នង សួន ត្រូវចាប់ខ្លួននៅដើមខែវិច្ឆិកា ។[៣៨]

មនុស្សទាំងបីនាក់នេះមានលក្ខណៈដូចគ្នាច្រើនណាស់ ។ ក្រៅពីអាយុស្របាលគ្នា អ្នកទាំងបីស្ទើរតែគ្មានអ្វីដូច ប៉ុល ពត ឡើយ ។ ទាំងបីនាក់បានចូលរួមចលនាប្រឆាំងនឹងបារាំងក្នុងឆ្នាំ១៩៤៥ និងឆ្នាំ១៩៤៦ ។ អ្នកទាំងបីបានរៀនអំពីលិទ្ធិម៉ាក្ស-ឡេនីន ពីកម្មាភិបាលកុម្មុយនិស្តវៀតណាម ឬពីជនជាតិខ្មែរដែលទៅរៀនសូត្រនៅប្រទេសវៀតណាម ។ គ្មានអ្នកណាម្នាក់ក្នុងចំណោមអ្នកទាំងបីបានទៅរៀននៅប្រទេសបារាំងឡើយ ។ មិនដូចបងធំទីមួយនិងទីពីរទេ នង សួន និង កែវ មាស បានចេញធ្វើសកម្មភាពជាចំហកាលពីទសវត្សរ៍ឆ្នាំ៥០ ។ ណៃ សារ៉ាន់បង្រៀននៅសាលាជាមួយ សាឡុត ស ។ កែវ មាស បានឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រប្រឆាំងពីរលើក ចំណែកឯ នង សួន ត្រូវបានចាប់ដាក់គុកដោយរាជការ សម្តេចសីហនុ នៅឆ្នាំ១៩៦២ ។ អ្នកទាំងពីរនេះបានចូលជាគណៈកម្មាធិការមជ្ឈិមបក្សនៅខែកញ្ញា ឆ្នាំ១៩៦០ ជាមួយនឹង សាឡុត ស ដែលខ្លួនស្គាល់ជិតដិត ។ នៅឆ្នាំ១៩៦៣ ណៃ សារ៉ាន់ និង កែវ មាស បានចូលធ្វើការជាមួយ ប៉ុល ពត និងមនុស្សមួយក្តាប់តូចនៅក្នុងមន្ទីរ១០០ ដែលជាមូលដ្ឋានវៀតណាមនៅតាមព្រំដែនកម្ពុជា-វៀតណាម ។ អ្នកទាំងពីររស់នៅទីនោះរហូតដល់ឆ្នាំ១៩៦៥ ។ ចាប់ពីពេលនោះមក ណៃ សារ៉ាន់ នង សួន កែវ មាស ក៏បែកផ្លូវផ្សេងពីគ្នា ។ នង សួន ត្រូវបានដោះលែងពីគុកនៅក្នុងឆ្នាំ១៩៧០ ហើយចូលបម្រើបដិវត្តក្នុងព្រៃម៉ាគីនៅជិតភ្នំពេញ ណៃ សារ៉ាន់ ក្លាយជានាយយុទ្ធជននៅភូមិភាគឦសាន រីឯ កែវ មាស ធ្វើការនៅទីក្រុងប៉េកាំងនិងហាណូយតំណាងឲ្យរដ្ឋាភិបាលរណសិរ្សរួបរួមជាតិនិរទេស ។ ពេលដែលត្រឡប់មកដល់ប្រទេសកម្ពុជាវិញនៅឆ្នាំ១៩៧៥ កែវ មាស ដែលប្រហែលជាត្រូវបានសង្ស័យថាជាអ្នកគាំទ្រវៀតណាមត្រូវបានឃុំឃាំងក្នុងផ្ទះមិនឲ្យចេញទៅណា ។

នៅឯមន្ទីរសន្តិសុខស-២១ កែវ មាស ណៃ សារ៉ាន់ និង នង សួន ត្រូវបានចោទប្រកាន់ថា បានបង្កើត «បក្សពលករកម្ពុជា» ដើម្បីបង្អាប់ប្រឆាំងនឹងបក្សកុម្មុយនិស្តកម្ពុជា ។ ការបង្កើត «បក្សពលករកម្ពុជា» មានន័យថា ជាអំពើក្បត់របស់សមាជិកបក្សកុម្មុយនិស្តកម្ពុជាក្រោយពី ប៉ុល ពត បានឡើងកាន់មជ្ឈិមបក្សកាលពីឆ្នាំ១៩៦០ ។ នៅក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ «បក្ស» ប្រឆាំងបានក្លាយជាចំណុចក្តៅក្នុងការចោទប្រកាន់ដូចដែលឃើញនៅមន្ទីរសន្តិសុខស-២១ស្រាប់ ។ បក្សគឺជាចំណុចដែលអាចធ្វើចលនាបាន

ហើយ «បក្សពលករកម្ពុជា» តំណាងឲ្យពាក្យពីរម៉ាត់គត់ «សេ.អ៊ី.អា» ឬ «កា.ហេ្វ.បេ» ។ ដោយសារតែបក្សកុម្មុយនិស្តកម្ពុជាត្រូវបានយល់ថាជាប្រភពខ្មាំងអចិន្ត្រៃយ៍ មេដឹកនាំរបស់បក្សនេះត្រូវបាននិយាយថានៅមានសកម្មភាពនៅឡើយ ។ ឧទាហរណ៍នៅខែកក្កដា ឆ្នាំ១៩៧៨ ជិតពីរឆ្នាំក្រោយពី កែវ មាស ត្រូវបានចាប់ខ្លួននិងសម្លាប់ចោល និងមួយខែក្រោយពី សោ ភឹម សម្លាប់ខ្លួនឯង ប៉ុន បានសរសេរនៅក្នុងសៀវភៅកំណត់ហេតុរបស់ខ្លួនថា «ការស្វែងរកមេៗរបស់បក្សពលករកម្ពុជាគឺសំខាន់ណាស់» ។

ប៉ុន្តែគួរឲ្យអស់សំណើចដែលអ្នកទោសមានតួនាទីធំៗជាច្រើនធ្លាប់ដឹងច្បាស់ថា នៅក្នុងឆ្នាំ១៩៦០ បក្សរបស់ ប៉ុល ពត បានយកឈ្មោះបក្សពលករកម្ពុជាមកដាក់ជាឈ្មោះរបស់បក្សខ្លួន ។ ទោះបីជាការប្ដូរឈ្មោះនេះប្រហែលជាត្រូវបានអនុម័តយល់ព្រមដោយវៀតណាមក៏ដោយ ប៉ុន្តែគ្មានភ័ស្តុតាងបញ្ជាក់ច្បាស់ថា បក្សប្រឆាំងដែលប្រើឈ្មោះនេះត្រូវបានបង្កើតឡើយ ។ ផ្ទុយទៅវិញ បក្សនេះត្រូវបានស្គាល់ថាជាបក្សពលករកម្ពុជារហូតមកដល់ពាក់កណ្ដាលឆ្នាំ១៩៦៦ ពេលនោះ ប៉ុល ពត ក៏ប្ដូរឈ្មោះដោយសម្ងាត់ម្ដងទៀតថា «បក្សកុម្មុយនិស្តកម្ពុជា» វិញ ។[៣៩]

ទោះបីជាមានភាពផ្ទុយគ្នាដូច្នេះក៏ដោយ ក៏គំនិតដែលថា កែវ មាស បានបង្កើតបក្សបង្កប់មានឈ្មោះថា «បក្សពលករកម្ពុជា» នៅតែមាននៅឡើយក្នុងឆ្នាំ១៩៧៨ ពេលដែល វ៉ន វេត ឧបនាយករដ្ឋមន្ត្រីត្រូវបានចាប់ខ្លួន ។ នៅក្នុងចម្លើយសារភាពរបស់ខ្លួន វ៉ន វេត បានសរសេរថា÷

> បក្សប្រឆាំង «ត្រូវបានដាក់បញ្ចូលគ្នា ដោយមានជំនួយពីវៀតណាមដែលមានឈ្មោះ កែវ មាស ជាអ្នកបង្កើតដើម្បីឲ្យវៀតណាម អាចកសាងកម្លាំងនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ។ ក្រុមសេ.អ៊ី.អា បានចូលរួមជាមួយបក្សនេះ ។ តាមរូបភាពខាងក្រៅមើលទៅហាក់ដូចជារបស់វៀតណាម តែតាមការពិត...វាជារបស់សេ.អ៊ី.អា ។ ក្នុងការដឹកនាំការងារវាមានទម្រង់ជាបក្សកុម្មុយនិស្តកម្ពុជា» ។[៤០]

កែវ មាស និង ណៃ សារ៉ាន់ ត្រូវបានចាប់ខ្លួននៅពេលមានចលាចលមួយ ដែលចាប់ផ្ដើមនៅខែសីហា ឆ្នាំ១៩៧៦ គឺពេលដែលផែនការបួនឆ្នាំរបស់បក្សកុម្មុយនិស្តកម្ពុជាត្រូវបានលើកយកមកពិភាក្សានៅក្នុងកិច្ចប្រជុំថ្នាក់កម្មាភិបាល និងនៅពេលជិតដល់ខែតុលា ដែលពោរពេញទៅដោយភាពចម្រូងចម្រាស់អំពីរឿងថ្ងៃបង្កើតបក្សកុម្មុយនិស្តកម្ពុជាដែលអនុវត្តដោយមជ្ឈិមបក្ស ហើយដែលត្រូវបានដោះស្រាយទៅតាមគំនិតរបស់ ប៉ុល ពត ។ បើពិនិត្យទៅលើរឿងទាំងអស់នេះ ព្រឹត្តិការណ៍ទាំងឡាយដែលបានកើតឡើងនិងការចាប់ខ្លួនគឺជាចំណុចរបត់មួយនៅក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជាប្រជាធិបតេយ្យនិងមន្ទីរសន្តិសុខ ស-២១ ។ នៅចុងឆ្នាំនោះ ជាលទ្ធផលការប្រកាសរបស់មជ្ឈិមបក្សបានក្លាយជាមានលក្ខណៈទុទិដ្ឋិនិយមនិងភាពប្រទូសរ៉ាយ ។ នៅដើមឆ្នាំ១៩៧៧ វិសុទ្ធកម្មបានឡើងដល់ក្បាលម៉ាស៊ីនដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជា ។ ដោយហេតុផលនេះ ដំណើរវិវត្តនៃព្រឹត្តការណ៍ដែលកើតឡើងចាប់ពីខែសីហាដល់ខែតុលា ឆ្នាំ១៩៧៦ ត្រូវតែរៀបរាប់ឲ្យបានលម្អិត ។

ចាប់ពីថ្ងៃទី២១ដល់ថ្ងៃទី២៣ ខែសីហា កម្មាភិបាលបក្សកុម្មុយនិស្តកម្ពុជាបានប្រមូលផ្តុំគ្នានៅភ្នំពេញ ដើម្បីទទួលការណែនាំត្រួសៗស្តីអំពី«ផែនការបួនឆ្នាំក្នុងការកសាងសង្គមនិយមលើគ្រប់វិស័យ» ដែលមានកម្រាស់១១០ទំព័រ ចងក្រងកាលពីដើមខែសីហា ។ ផែនការនោះបានស្នើឲ្យមានការសម្រុកបង្កបង្កើនផល ដើម្បីធ្វើការនាំចេញនូវកសិផលផ្សេងៗ ជាពិសេសស្រូវ ដើម្បីទិញគ្រឿងម៉ាស៊ីនបម្រើផ្នែកកសិកម្ម និងបន្ទាប់មកពេលដែលភោគផលកើនឡើង គឺសម្រាប់ឧបត្ថម្ភផ្នែកកសិកម្មទៀត ។ ដើម្បីជម្នះរាល់ឧបសគ្គទាំងឡាយ មជ្ឈិមបក្សបានពឹងផ្អែកទៅលើបដិវត្តន៍ដែលត្រូវរំពឹងថានឹងមានដំណើរការទូទាំងសង្គមកម្ពុជា ការធ្វើសមូហភាវូបនីយកម្មទៅលើមធ្យោបាយផលិតកម្ម និងការប្រើអំណាចដែលបានមកពីជ័យជម្នះខ្មែរក្រហម កាលពីខែមេសា ឆ្នាំ១៩៧៥ ។ គំនិតយល់ឃើញមិនទាន់ចេញជាសាច់ការឡើយ ។ ផែនការដែលមិនទាន់ទទួលបានលទ្ធផលនៅលើទីផ្សារពិភពលោកនៅឡើយនោះមិនបានយកចិត្តទុកដាក់ចំពោះប្រភេទដីឬក៏ប្រភពទឹកនៅទូទាំងប្រទេសកម្ពុជាឡើយ ហើយមើលរំលងចំណុចខ្វះខាតរបស់ពលករ សម្ភារនិងបសុសត្វ ។ ជាពិសេសបំផុតនោះគឺផែនការបួនឆ្នាំដែលបានលើកឡើងនោះមិនបានទទួលស្គាល់ថា ប្រជាជនភាគច្រើនអស់កម្លាំង នឿយណាយក្រោយពីសង្គ្រាមប្រាំឆ្នាំកន្លងមក ហើយមានប្រជាជនខ្លះពិបាកនឹងរកបាយហូបគ្រប់គ្រាន់ផងទេ ។ តែផ្ទុយទៅវិញ មជ្ឈិមបក្សបានសន្និដ្ឋានថា ប្រជាជនស្ទើរតែគ្រប់រូបបានរៀបចំខ្លួនរួចជាស្រេច ដោយមានសមត្ថភាព និងចង់ផលិតស្រូវឲ្យបានច្រើនជាអតិបរមា ។[៤១]

ក្នុងន័យនយោបាយ ផែនការនេះបានផ្តល់ឲ្យ ប៉ុល ពត និងបក្ខពួកនូវឱកាសក្នុងការក្តាប់កង់ប្រវត្តិសាស្ត្រនិងបង្ហាញពីភាពបរិសុទ្ធព្រមទាំងកម្លាំងរបស់បដិវត្តន៍កម្ពុជាចំពោះសម្ព័ន្ធមិត្តនិងខ្មាំងខាងក្រៅរបស់ខ្លួន ។ សៀវភៅសរសេរដែលរៀបចំដោយកម្មាភិបាលមន្ទីរសន្តិសុខស-២១ និយាយថា មជ្ឈិមបក្សមានការជឿជាក់យ៉ាងខ្លាំងថាបដិវត្តន៍កម្ពុជាទទួលជោគជ័យខ្លាំងក្លាបំផុតនៅក្នុងប្រវត្តិសាស្ត្រពិភពលោក ។ ផែនការបួនឆ្នាំគឺជាឯកសារគោលនយោបាយដ៏លម្អិតរបស់បក្សកុម្មុយនិស្តកម្ពុជា ។ មេដឹកនាំបក្សប្រហែលជាសង្ឃឹមថានឹងបានបង្ហាញគម្រោងផែនការនេះនៅក្នុងខួបកំណើតបក្សដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៣០ ខែកញ្ញា គឺនៅពេលដែលមេដឹកនាំបក្សសង្ឃឹមថានឹងប្រកាសឲ្យដឹងនូវអត្ថិភាពរបស់បក្សកុម្មុយនិស្តកម្ពុជា ។

នៅក្នុងសម្តីសង្កត់ធ្ងន់ៗរបស់ ប៉ុល ពត ក្នុងអង្គប្រជុំនៅខែសីហា ទាក់ទងនឹងផែនការនេះ ភាសាពន្យល់នៅដើមដំបូងស្តាប់ទៅហាក់ដូចជាបញ្ឆោតពីស្វ័យភាពនៃផែនការរបស់ខ្លួន ។

ស្រាប់តែ ប៉ុល ពត បានលើកយកបញ្ហាសំខាន់មួយមកនិយាយថា «ពួកខ្មាំងនៅខាងកើត និងនៅខាងលិច» (វៀតណាមនិងថៃ) ជាមូលហេតុនៃការប្រុងប្រយ័ត្ននិងការគំរាមកំហែងរបស់យើង ។ ប៉ុល ពត មិនបាននិយាយអំពីរឿងខ្មាំងផ្ទៃក្នុងឡើយ ។

មរណភាពដែលហួសពីការស្មានរបស់ ម៉ៅ សេទុង នៅថ្ងៃទី៩ ខែកញ្ញា បានបង្កឲ្យមានភាពមិននឹងនរនៅក្នុងមជ្ឈិមបក្ស ។ អតីតកម្មាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យម្នាក់បានប្រាប់លោក ស៊ីវ ហេដឺរ កាលពីឆ្នាំ១៩៨០ថា «ក្រោយពី ម៉ៅ សេទុង ស្លាប់ទៅ មានការព្រួយបារម្ភនៅក្នុងប្រទេសកម្ពុជា... ប្រជាជនមានការភ័យខ្លាចថាភាពច្របូកច្របល់វឹកវរនៅក្នុងប្រទេសចិនអាចប៉ះពាល់ដល់សាមគ្គីភាពរវាង

ប្រទេសយើងនឹងប្រទេសចិន» ។[៤២] នៅថ្ងៃទី១៨ ខែកញ្ញា នៅពេលប្រារព្ធពិធីបុណ្យរំលឹកដល់ ម៉ៅ សេទុង ដែលធ្វើឡើងនៅទីក្រុងភ្នំពេញ ប៉ុល ពត បានសារភាពលើកដំបូងជាសាធារណៈថា ប្រទេសកម្ពុជាកំពុងត្រូវបានដឹកនាំដោយបក្សម៉ាក្ស-លេនីន ។ ប៉ុល ពត បានលើកសរសើរដល់សំណេររបស់ ម៉ៅ «ស្ដីអំពីការដោះស្រាយត្រឹមត្រូវចំពោះបញ្ហាទំនាស់ក្នុងចំណោមប្រជាជន» ។ នៅក្នុងឱកាសនោះដែរ ឯកអគ្គរដ្ឋទូតប្រទេសចិន ស៊ុន ហាវ បានកត់សម្គាល់ថា ម៉ៅ បានឈានដល់ «ការសន្និដ្ឋានជាលក្ខណៈវិទ្យាសាស្ត្រថា សូម្បីតែនៅក្នុងបក្សកុម្មុយនិស្តក៏នៅមានពួកគហបតីដែរ» ។ នេះជាជំនឿបដិវត្តន៍ដ៏សំខាន់មួយរបស់ប្រទេសចិន ដែលត្រូវបានប្រើប្រាស់សម្រាប់បន្តធ្វើការបោសសម្អាតសមាសភាពមិនល្អតទៅទៀត ។[៤៣]

## ការលាលែងពីតំណែងរបស់ ប៉ុល ពត

នៅថ្ងៃទី២០ ខែកញ្ញា ប៉ុល ពត បាន «លាលែងពីតំណែង» ជានាយករដ្ឋមន្ត្រី ដោយសារបញ្ហាសុខភាព ។ ការលាលែងនេះត្រូវបានប្រកាសតាមវិទ្យុភ្នំពេញមួយសប្ដាហ៍ក្រោយពីថ្ងៃលាលែងពិតប្រាកដ ។ សេចក្ដីប្រកាសបានបន្តទៀតថា មុខតំណែងរបស់ ប៉ុល ពត ត្រូវបានជំនួសដោយ នួន ជា (បងលេខពីរ) ដែលទទួលកាន់កាប់មុខតំណែងនេះតាំងពីឆ្នាំ១៩៦៣មកម្ល៉េះ និងត្រូវបន្ទរហូតដល់ផុតស្រមោលរបស់ ប៉ុល ពត កាលពីឆ្នាំ១៩៩៧ ។ ការលាលែងពីតំណែងរបស់ ប៉ុល ពត ប្រសិនជាកើតមានឡើងពិតមែនអាចមកពីបញ្ហាសុខភាព ព្រោះ ប៉ុល ពត លាប់ជំងឺគ្រុនចាញ់ និងមានជំងឺអាសន្នរោគក្នុងពេលតែមួយ ឬក៏អាចថាពីព្រោះ ប៉ុល ពត មានការភ័យខ្លាចការធ្វើឃាតលើខ្លួននិងចង់លាក់ខ្លួនផង ។ ប៉ុន្តែមើលទៅហាក់ដូចជាថា ប៉ុល ពត មិនដែលលាឈប់ពីតំណែងឡើយ ហើយការប្រកាសជាសាធារណៈបែបនេះ គឺប្រហែលមានបំណងចង់កម្ចាត់ខ្មាំងផ្ទៃក្នុងនិងវែកមុខជនផ្សេងៗទៀតប៉ុណ្ណោះ ។ ការទាញហេតុផលបែបនេះហាក់ដូចជាសមហេតុសមផលដោយសារថាទាំង នួន ជា និង តាម៉ុក មិនបានចាំពីរឿងនេះឡើយនៅពេលធ្វើកិច្ចសម្ភាសន៍ជាមួយនឹង ណេត ថាយ័រ នៅក្នុងឆ្នាំ១៩៩៧ ។[៤៤]

ណៃ សារ៉ាន់ ត្រូវបានចាប់ខ្លួននៅថ្ងៃដែល ប៉ុល ពត លាលែងពីតំណែង ។ កែវ មាស ត្រូវបានចាប់ខ្លួនប្រាំថ្ងៃបន្ទាប់ពីពេលលាលែងនោះ ។ តាមរយៈវគ្គសិក្សាដែលធ្វើឡើងនៅពេលប្រហែលគ្នានេះ ដែលប្រហែលជាជាន់ពេលគ្នាជាមួយនឹងបុណ្យរំលឹកខួបរបស់បក្ស មានលេចឡើងនូវឯកសារសង្ខេបដែលគួរឲ្យចង់ដឹងចង់ឃើញមួយមានចំណងជើងថា«សេចក្ដីសង្ខេបលទ្ធផលនៃវគ្គសិក្សាឆ្នាំ១៩៧៦» ។ អត្ថបទនេះរួមមានកំណត់ហេតុកត់អំពីសម្ដីរបស់អ្នកនាំពាក្យរបស់បក្សដូចជាពិបាកយល់ជាងសម្ដីរបស់ ប៉ុល ពត ដែលនិយាយអំពីផែនការបួនឆ្នាំ ។ ឯកសារនេះមាននិយាយអំពីការសង្ស័យនិងពត៌មានទាក់ទងដល់ការចាប់ខ្លួនជនទាំងពីរនេះ ។[៤៥]

សម្ដីរបស់ ប៉ុល ពត កាលពីខែសីហា បានលើកឡើងពីបញ្ហាខ្មាំងខាងក្រៅ រីឯ «សេចក្ដីសង្ខេបកាលពីខែកញ្ញា» និយាយពីគ្រោះថ្នាក់របស់ «អន្តការនិងភ្នាក់ងារ» របស់មហាអំណាចដែល «លួចជ្រៀតចូលលាក់ខ្លួននៅក្នុងជួរបដិវត្តន៍យើង» ។ សម្ដីនេះបានឆ្លុះបញ្ចាំងពីការថ្លែងសុទ្ធរកថាកាលពីខែធ្នូដែលមានការ

សោកស្តាយចំពោះ«ជំងឺនៅក្នុងជួរបក្ស» ។ លើសពីនេះក៏មានប្រើឃ្លាថ្មីមួយទាក់ទងនឹងទំនាស់វណ្ណៈនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរ ដែលអ្នកថ្លែងសុន្ទរកថានោះនិយាយថា អាច«មានលក្ខណៈស្រួចស្រាល់... មិនអាចដោះស្រាយ ជួរចត់ តឹងតែង និងស្លាប់រស់...នៅពេលអនាគត» ។[៨៦]

## ណៃ សារ៉ាន់ «អាយ៉ា»

របបពោរពេញទៅដោយកំហឹងដែលចាប់ផ្តើមតាំងពីខែកញ្ញាទៅ ប្រហែលមានការពាក់ព័ន្ធទៅនឹងអ្វីដែលបណ្តាលឲ្យ កែវ មាស, ណៃ សារ៉ាន់ និងអ្នកទោសផ្សេងទៀតឆ្លើយសារភាពនៅមន្ទីរស-២១ ។ ជាការពិបាកណាស់ក្នុងការកំណត់ថា តើមានអ្នកទោសណាខ្លះបានចូលរួមនៅក្នុងផែនការក្បត់នោះ ទោះបីជាឯកសារនៅសេសសល់នៅឯមន្ទីរស-២១ដែលនិយាយអំពីអ្នកទាំងនេះមានលក្ខណៈគួរឲ្យសង្ស័យថា មានលក្ខណៈមិនគ្រប់គ្រាន់និងអាចប្រមែប្រមូលចងក្រងក្រោយឆ្នាំ១៩៧៩ ដើម្បីលាក់បាំងភ័ស្តុតាង សមគំនិតជាមួយវៀតណាមយ៉ាងណាក៏ដោយ ។ ឯកសារទាំងនោះអាចបកស្រាយបន្តិចបន្តួចតែប៉ុណ្ណោះ ចំពោះការសង្ស័យមិនទុកចិត្តដែលហាក់ដូចជាកើតមានទៅលើមេដឹកនាំនានាចាប់ពីពេលនោះមក ។

ចម្លើយសារភាពរបស់ ណៃ សារ៉ាន់ មានតែសាមសិបមួយសន្លឹកប៉ុណ្ណោះដែលបានមកពីការសួរចម្លើយចំនួនប្រាំពីរលើក ។ កំណត់សម្គាល់ឬចំណារប្រើពាក្យធ្ងន់ៗរបស់ ប៉ុន ផ្ញើទៅ ឌុច និង ឌុច ផ្ញើទៅ ណៃ សារ៉ាន់ ជាការបន្ថែមទៅលើឯកសារស្តួចស្តើងនេះ ។[៨៧] ឧទាហរណ៍ នៅថ្ងៃទី២៣ ខែកញ្ញា ប៉ុន បានរាយការណ៍ទៅ ឌុច ថាខ្លួនបានវាយ ណៃ សារ៉ាន់ នឹងរំពាត់ផ្តៅនិងខ្សែភ្លើង ។ នៅក្នុងកំណត់សម្គាល់មួយមានបួនទំព័រសរសេរឲ្យអ្នកទោសមើលនៅថ្ងៃបន្ទាប់នោះ ឌុច បានបញ្ជាក់ប្រាប់ ណៃ សារ៉ាន់ ថា÷

> «បងគិតមើល» បងជាមនុស្សដែលអង្គការមានជំនឿទុកចិត្តយ៉ាងខ្លាំង ពីព្រោះបងជាអ្នកនៅជិតដិតនឹងអង្គការនិងចលនាបដិវត្តន៍កម្ពុជាយើង ប្រៀបទៅនឹងអ្នកដទៃទៀតដែលអង្គការបានចាប់ខ្លួនហើយ ។ អង្គការបានបញ្ជាក់ថា បងមិនអាចលាក់បាំងនូវអ្វីដែលកើតឡើងពីអតីតកាលទេ ។ អង្គការដឹងអស់ហើយ អ្វីដែលអាក្រក់ ។ បងមិនអាចភូតភរ ឬទម្លាក់កំហុសទៅលើអ្នកដទៃឡើយ...អង្គការ...មានគំនិតច្បាស់លាស់អំពីមនុស្សដែលចចេសរឹងរូស ។

ពីរថ្ងៃបន្ទាប់មក ឌុច សរសេរទៅ ប៉ុន ថា «ប្រសិនបើ ណៃ (សារ៉ាន់) បន្តលាក់ខ្សែក្បត់វាទៀត... សម្លាប់វាចោលភ្លាមកុំទុកឲ្យនៅលេងល្បែងជាមួយនឹងបក្សទៀត» ។ ការធ្វើទារុណកម្មចេះតែបន្តហើយ ប៉ុន ក៏សរសេរទៅ ឌុច វិញថា÷

> ពេលល្ងាចខ្ញុំបានសុំបង ឌុច ធ្វើទាំងធម៌ក្តៅនិងធម៌ត្រជាក់ ។ ក្រោយពីបានទទួលការអនុញ្ញាតហើយ ល្ងាចបន្តិចខ្ញុំក៏ចូលទៅវាយវាដោយប្រាប់វាឲ្យរៀបចំខ្លួននៅម៉ោង៨ឬ៩ ដើម្បីទទួលទារុណកម្មបន្ត ។

> នៅប្រហែលម៉ោង១០យប់ ខ្ញុំបានចូលទៅក្នុងរៀបចំធ្វើទារុណកម្មដោយដៃទទេ ។ IX (ណៃ សារ៉ាន់) ចាប់ផ្ដើមឆ្លើយសារភាពហើយឲ្យយើងចាំសង្ខេបអ្វីដែលគាត់ប្រុងប្រៀបនឹងរាយការណ៍ ។ យើងបានបញ្ជាក់ថា ចូរសរសេរជាខ្សែសង្វាក់សកម្មភាពក្បត់ពីដើមដល់ចប់ ។

## កែវ មាស

ការប្រឈមមុខគ្នារវាង ប៉ុន និង ណៃ សារ៉ាន់ ងាយស្រួលនឹងប្រមើលឃើញណាស់ ។ ប៉ុន្តែ «ដំណើររឿងជាប្រព័ន្ធ» នៃសកម្មភាពរបស់គាត់មិនមាននៅសល់ឡើយ ទោះគាត់បានសរសេរឬមិនបានសរសេរក៏ដោយ ។ ចម្លើយសារភាពចំនួនកៅសិបប្រាំមួយសន្លឹកដែលសរសេរដោយដៃគាត់នៅក្នុងបណ្ណសារមន្ទីរ ស-២១ មានសំបុត្រមួយចំនួនដែល កែវ មាស បានសរសេរទៅឲ្យ ប៉ុល ពត កាលពីមួយរយៈកន្លងមក ។[៤៧] សំបុត្រជាច្រើនមានចំណាររបស់ ឌុច «កុំសង្ខេប» ។ នេះបង្ហាញថា សំបុត្រទាំងអស់មិនដែលត្រូវបានយកចេញពីគុកទេ ។ ឯកសាររបស់ កែវ មាស ក៏មានសំណួររបស់ ប៉ុន ដែលចុះហត្ថលេខាថា «សន្តិបាល» ព្រមទាំងចំណារមានលក្ខណៈឃោរឃៅរបស់ ឌុច ទាមទារពត៌មានការពិនិត្យសាឡើងវិញ និងចាត់ការសាជាថ្មី ។[៤៨] ទោះបីជាមានការគាបសង្កត់ធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ក៏ កែវ មាស នៅតែបន្តជំទាស់ថា ខ្លួនពិតជាគ្មានកំហុសទេ ។ កែវ មាស មានបទពិសោធន៍ស្ទើរតែសាមសិបឆ្នាំក្នុងការពិភាក្សាតឹងសរសៃកអំពីលទ្ធិកុម្មុយនិស្ត ហើយនៅក្នុងសំបុត្ររបស់គាត់ផ្ញើទៅ ប៉ុល ពត កែវ មាស និយាយថាគាត់តស៊ូដើម្បីជីវិត ។ កែវ មាស បានសរសេរថា «ការចោទប្រកាន់នេះគួរឲ្យចង់សើច» ។ «គេមិនយល់អំពីខ្ញុំទេ ។ ខ្ញុំដឹង ហើយគ្មានធ្វើអ្វីដូចដែលគេចោទប្រកាន់ខ្ញុំឡើយ» ។

ទាក់ទងនឹងបុណ្យខួបរបស់បក្ស កែវ មាស សរសេរនៅថ្ងៃទី២៩ ខែកញ្ញា គឺមួយថ្ងៃមុនប្រារព្ធពិធីនេះថា៖

> គំនិតគឺគាំទ្រឆ្នាំ១៩៥១ ។ បើមានអ្នកណាចង់ដើរផ្លូវផ្សេងខ្ញុំមិនទៅទេ ។ ខ្ញុំនឹងជំទាស់ ហើយប្រកាន់ខាងក្រុមប្រជាជន ។ កាសែតប្រជាជនគឺជាអង្គការច្បាប់របស់បក្សម៉ាក្ស-លេនីនដែលបង្កើតឡើងនៅក្នុងឆ្នាំ១៩៥១ ។

## តើកំណើតបក្សនៅថ្ងៃណា?

ជំហររបស់ កែវ មាស អំពីបញ្ហាវំពុកខួបមានការប្រឆាំងគ្នាយ៉ាងធំមួយទៅនឹងគំនិតរបស់បក្សកុម្មុយនិស្តកម្ពុជាដែលបានលាក់បាំងអស់រយៈពេលជាច្រើនឆ្នាំមកហើយ ។ ដែលត្រូវដោះស្រាយឲ្យស្របតាមគំនិត ប៉ុល ពត ។ ទំនាស់នេះត្រូវបានសម្គាល់ដោយវែងន្យនៅក្នុងកិច្ចប្រជុំមជ្ឈិមបក្សធ្វើឡើងនៅថ្ងៃទី៣០ ខែមីនា ថា «ដាក់ថាកំណើតរបស់បក្សគឺឆ្នាំ១៩៦០ ។ កុំប្រើឆ្នាំ១៩៥១...សូមកែឲ្យច្បាស់» ។[៥០]

បញ្ហាដែលគ្រោះថ្នាក់នៅក្នុងការទាញហេតុផលតាមពាក្យមួយម៉ាត់ៗ គឺបញ្ហាដឹកនាំរបស់បក្សនិង

ទំនាក់ទំនងរបស់កម្ពុជាជាមួយនឹងប្រទេសវៀតណាម ។ ចាប់ពីឆ្នាំ១៩៦០ដល់ឆ្នាំ១៩៧៥ ពិធីបុណ្យរំឭកខួបរបស់បក្សកុម្មុយនិស្តកម្ពុជាត្រូវបានប្រារព្ធធ្វើឡើងនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៥១ ពោលគឺជាថ្ងៃដែលមានឆ្នាំប្រឡំបល់មិនច្បាស់លាស់ ។ ឆ្នាំ១៩៦០ជាឆ្នាំដែលមានកិច្ចប្រជុំនៅទីក្រុងភ្នំពេញដើម្បីបង្កើតបក្សពលករកម្ពុជា ចំណែកឯឆ្នាំ១៩៥១ជាឆ្នាំបង្កើតបក្សប្រជាជនបដិវត្តន៍ខ្មែរក្រោមការជំរុញរបស់ប្រទេសវៀតណាម ។[៥១]

កម្មាភិបាលបក្សកុម្មុយនិស្តកម្ពុជា ដែលរត់ពីភូមិភាគបូព៌ាទៅចុះចូលខាងវៀតណាមនៅឆ្នាំ១៩៧៨ បានរាយការណ៍ថា មានការរៀបចំប្រារព្ធខួបបក្សលើកទី២៥ តាំងពីពាក់កណ្តាលខែកញ្ញា ឆ្នាំ១៩៧៦ម្ល៉េះ ។ ប៉ុន្តែនៅពេលកំពុងរៀបចំ

> យើងក៏ទទួលសារមួយពីរដ្ឋអំណាចថ្នាក់លើបញ្ជាឲ្យយើងផ្អាកការរៀបចំសិន ។ បន្ទាប់មកទៀតមានការណែនាំមកពីមន្ទីរមជ្ឈិមប្រាប់យើងថា បក្សត្រូវបានបង្កើតឡើងនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ ។ អ្នកណាដែលបានចូលបក្សមុនថ្ងៃនោះ គួរតែគិតគូរខ្លួនឯងមិនមែនសមាជិកបក្សទេ ហើយប៉ុន្មានឆ្នាំដែលខ្លួនបានចូលរួមជាមួយបក្សមុនថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ គឺចាត់ទុកជាមោឃៈ ។ បើអ្នកណាយល់ព្រមគណៈមជ្ឈិមបក្សនឹងទទួលយក ។ បើមិនដូច្នេះទេ ជននោះនឹងត្រូវបញ្ជូនទៅកន្លែងអប់រំ ។[៥២]

នៅក្នុងទស្សនាវដ្តីចេញផ្សាយសម្រាប់ខែកញ្ញារបស់បក្សកុម្មុយនិស្តកម្ពុជាមានឈ្មោះថា «យុវជនយុវនារីបដិវត្ត» មានអត្ថបទមួយនិយាយអំពីការអបអរសាទរចំពោះបុណ្យខួបលើកទី២៥របស់បក្ស ហើយអត្ថបទមួយនៅក្នុងទស្សនាវដ្តីទង់បដិវត្តច្បាប់ចេញផ្សាយសម្រាប់ខែកញ្ញា-ខែតុលាបានប្រកាសថា បក្សកុម្មុយនិស្តកម្ពុជាត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦០ ពីព្រោះ «យើងបានប្តូរលេខឆ្នាំថ្មី» ។ អ្នកនិពន្ធអត្ថបទនេះសរសេរថា មូលហេតុនៃការប្តូរនេះដោយសារ

> អង្គការបដិវត្តន៍បានសម្រេចចិត្តថា ចាប់ពីពេលនេះតទៅយើងត្រូវតែរៀបចំប្រវត្តិសាស្ត្ររបស់បក្សឲ្យស្អាតនិងល្អឥតខ្ចោះស្របតាមនយោបាយឯករាជ្យម្ចាស់ការរបស់យើង ។[៥៣]

សារនេះបានបង្ហាញឲ្យឃើញជំហានមួយទៀតនៃការប្រើអំណាចរបស់ ប៉ុល ពត និងបរិវារ ។ ដោយសារអត្ថបទទស្សនាវដ្តីទាំងពីរតែងតែត្រូវបានត្រួតពិនិត្យយ៉ាងហ្មត់ចត់និងភាគច្រើនសរសេរដោយ ប៉ុល ពត និង នួន ជា ដូច្នេះលទ្ធភាពនៃការខ្វែងគំនិតគ្នារវាងទស្សនាវដ្តីទាំងពីរច្បាប់មើលទៅមិនអាចកើតឡើងទេ ។ ទស្សនាវដ្តីយុវជនយុវនារីបដិវត្តបានចេញផ្សាយក្នុងគោលបំណងល្បួងក្រុម«១៩៥១» ដែលប្រឆាំងនឹងបក្សឲ្យចេញមកបង្ហាញមុខជាចំហ ដើម្បីងាយស្រួលក្នុងការកម្ទេច ។ ចំណែកឯទស្សនាវដ្តី

ទង់បដិវត្ត គឺបង្ហាញអំពីការគិតពិចារណារបស់មជ្ឈិមបក្ស ។

នៅដើមខែវិច្ឆិកា នង សួន ដែលជាមិត្តរបស់ នួន ជា និង ប៉ុល ពត ត្រូវបានចាប់ខ្លួននៅពេលដែលគាត់ទើបចុះពីយន្តហោះមកពីបំពេញបេសកកម្មនៅប្រទេសចិន ។ នៅមន្ទីរស-២១ មុនដំបូង នង សួន បានឆ្លើយថាគាត់មិនបានធ្វើអ្វីខុសទេ តែក្រោយពីការសួរចម្លើយបីសប្តាហ៍មក នង សួន ក៏ព្រមឆ្លើយហើយសរសេរថា÷

> ខ្ញុំគឺជាសត្វកណ្តៀរស៊ីរូងផ្ទៃក្នុង...និងបំផ្លាញបក្សតាមមធ្យោបាយដែលខ្ញុំអាចធ្វើទៅបាន ។ ទោះបីជាបក្សអប់រំនិងលត់ដំខ្ញុំយ៉ាងណា ក៏ខ្ញុំមិនបោះបង់នូវបំណងខ្មៅងងឹតនិងកខ្វក់របស់ខ្ញុំដែរ...ខ្ញុំចង់បង្ហាញខ្លួនចំពោះមុខអង្គការបក្សដើម្បីទទួលទោសកំហុសដ៏ធ្ងន់ធ្ងរតាមកម្រិតទោសដែលខ្ញុំបានប្រព្រឹត្តក្នុងគោលបំណងក្បត់បក្ស ។ ធ្វើដូច្នេះទើបបក្សអាចពង្រឹងពង្រីកជួរបក្សនិងឈានទៅរកការកសាងសង្គមបែបកុម្មុយនិស្តបាន ។[៨៨]

## ការបោសសម្អាតអ្នកការទូតនិងបញ្ញវន្ត

នៅខែធ្នូឆ្នាំ១៩៧៦ នៅពេលដែល ប៉ុល ពត ថ្លែងសុន្ទរកថាដែលមានចំណងជើងថា “ជំងឺនៅក្នុងបក្ស” មជ្ឈិមបក្សបានសម្រេចចិត្តថានឹងរក្សាការសម្ងាត់នៃអត្ថិភាពរបស់បក្សកុម្មុយនិស្តកម្ពុជាកុំឲ្យអ្នកក្រៅដឹងនិងរៀបចំផែនការបួនឆ្នាំ ។ មូលហេតុដែលនាំដល់ការសម្រេចចិត្តនៅក្នុងកិច្ចប្រជុំនេះគឺដោយសារមាន “ឯកសារអនាមិកនិយាយថា ខ្មាំងបាននឹងកំពុងព្យាយាមវាយយើងដោយប្រើប្រាស់គ្រប់វិធី” ។ នេះប្រហែលជាការនិយាយយោងទៅដល់ចម្លើយសារភាពដែលស្រង់មកពីមន្ទីរស-២១ ។ នៅក្នុងពេលដំណាលគ្នានេះដែរ ទោះបីជាឯកសារខ្លះមានការខុះចន្លោះនិងមានបញ្ជាក់មូលហេតុមិនច្បាស់លាស់ក៏ដោយ ប៉ុន្តែមជ្ឈិមបក្សប្រហែលជាសម្រេចចិត្តក្នុងការប្រកាសភាពប្រទូសរ៉ាយជាមួយនឹងវៀតណាម ។ នៅដើមឆ្នាំ១៩៧៧ កម្ពុជាប្រជាធិបតេយ្យបានធ្វើការវាយលុកចូលយ៉ាងសាហាវនៅតាមព្រំដែនកម្ពុជា-វៀតណាម នៅភូមិភាគបូព៌ានិងភូមិភាគនិរតី ។ នៅក្នុងការវាយប្រហារនេះ ជនស៊ីវិលរាប់រយនាក់ត្រូវបានសម្លាប់រង្គាល ប៉ុន្តែប្រទេសទាំងពីរមិនបានផ្សព្វផ្សាយជាសាធារណៈឡើយ ។[៨៩]

នៅពេលកម្ពុជាប្រជាធិបតេយ្យរៀបចំខ្លួនធ្វើសង្គ្រាម បក្សកុម្មុយនិស្តកម្ពុជាក៏បានបោសសម្អាតបុគ្គលិកការទូតនិងបុគ្គលិកធ្វើការនៅក្រសួងការបរទេសដែលត្រូវបានសង្ស័យថាជា“អ្នកគាំទ្រសូវៀត” ឬ “អ្នកគាំទ្រវៀតណាម”ដែរ ។ ជនរងគ្រោះសំខាន់ៗមានដូចជា ឯកអគ្គរដ្ឋទូតរបស់កម្ពុជាប្រជាធិបតេយ្យប្រចាំនៅប្រទេសវៀតណាមឈ្មោះ សៀន អាន និង ហាក់ សៀងឡាយនី មន្ត្រីក្រសួងការបរទេសដែលត្រូវបានចោទប្រកាន់ថា បានបង្កើតបក្សកុម្មុយនិស្តមួយទៀតនៅក្នុងទសវត្សរ៍ឆ្នាំ៦០ ដោយមានការជួយជំរុញពីប្រទេសសូវៀត ។ នៅមានអ្នកការទូតជាច្រើនរូបទៀតត្រូវបានប្រមូលផ្តុំ ។ ចំណាត់វិធានការដាក់ទណ្ឌកម្មទាំងអស់នេះក៏បង្ហាញអំពីការមិនទុកចិត្តរបស់បក្សចំពោះអ្នកដែលមានការហ្វឹកហាត់ជំនាញច្បាស់លាស់ និង

មានលំនៅដ្ឋានស្ថិតនៅក្រៅប្រទេសឬអ្នកដែលមានការទាក់ទងជាមួយនឹងបុគ្គលដែលមិនមែនជាខ្មែរ ។[៩៦]

ការបោសសម្អាតក៏បានបង្ហាញអំពីយុទ្ធនាការប្រឆាំងនឹងអ្នកចេះដឹងនៅក្នុងជួរបក្សដែលមានកម្លាំងខ្លាំងនៅពាក់កណ្តាលឆ្នាំ១៩៧៧ ។ នៅក្នុងខែកុម្ភៈ បញ្ញវន្តពីររូបគឺលោក កុយ ធួន និង តូច ភឿន ត្រូវបាននាំយកមកដាក់នៅមន្ទីរស-២១ ។ ទាំងពីររូបនេះគឺជាសមាជិកគណៈមជ្ឈិមបក្សនៃបក្សកុម្មុយនិស្ត និងជាកម្មាភិបាលដំបូងក្នុងជួរបក្សនេះដែលត្រូវបានបោសសម្អាត ។ មុខសញ្ញាសន្តិបាលបន្ទាប់គឺកម្មាភិបាលកងទ័ពនិងកម្មាភិបាលស៊ីវិលធ្វើការនៅភូមិភាគឧត្តរជាកន្លែងដែល កុយ ធួន ធ្វើជាលេខារហូតដល់ដើមឆ្នាំ១៩៧៦ ព្រមទាំងអ្នកចេះដឹងដទៃទៀតនៅក្នុងបក្សកុម្មុយនិស្តកម្ពុជាដែលជាប់ពាក់ព័ន្ធជាមួយនឹងអ្នកទោសទាំងពីរនាក់នេះ ។ នៅក្នុងអត្ថន័យ «ផែនការចុងក្រោយ» បុគ្គលដែលជាមុខសញ្ញាទាំងអស់នេះគឺជា«អ្នកដែលបន្លំខ្លួនជ្រៀតចូលទៅក្នុងបដិវត្តន៍និងពង្រីកខ្លួនដើម្បីស៊ើបការណ៍» ។[៩៧]

កុយ ធួន កើតនៅក្នុងឆ្នាំ១៩៣៣ ហើយចូលរៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិនៅក្នុងឆ្នាំ១៩៤៩ ។ ក្រោយពីបញ្ចប់ការសិក្សា កុយ ធួន បានចាប់យកអាជីពជាគ្រូបង្រៀន ។ នៅឆ្នាំ១៩៥៩ឬឆ្នាំ១៩៦០ ដោយមានការបញ្ចុះបញ្ចូលពីសំណាក់ ទីវ អុល ដែលធ្វើគ្រូបង្រៀនជាមួយគ្នាមានទំនាក់ទំនងដូចជាបងប្អូន កុយ ធួន ក៏ជឿស្កប់ទៅលើមនោគមវិជ្ជាបដិវត្តន៍ ។ ដោយមានការធានាពីគ្រូបង្រៀនម្នាក់ទៀតឈ្មោះ សុន សេន ពេលនោះ កុយ ធួនក៏បានចូលជាសមាជិកបក្សកុម្មុយនិស្តកម្ពុជា ។ នៅក្នុងឆ្នាំ១៩៦០ កុយ ធួន ធ្វើការជាមួយ ខៀវ សំផន មួយរយៈខ្លីនៅសារព័ត៌មានប្រចាំសប្តាហ៍ឈ្មោះ «អ៊ុបស៊ែរវ៉ាទ័រ» ។ កុយ ធួន បានរត់ចូលព្រៃម៉ាគីក្រោយពីបង្រៀនសិស្សអស់មួយរយៈនៅក្នុងខេត្តកំពង់ចាម ដែលនៅទីនោះគាត់បានកសាងកម្លាំងមួយចំនួនដូចជា សួស វ៉ាស៊ី ហៅ ឌឿន និងអ្នកផ្សេងៗទៀតចូលក្នុងបក្ស ។ នៅក្នុងអំឡុងពេលសង្គ្រាមស៊ីវិល កុយ ធួន ជាជនសកម្មនៅក្នុងភូមិភាគឧត្តរដែលនៅទីនោះគាត់បានទទួលកេរ្តិ៍ឈ្មោះជាអ្នកមានស្រីច្រើននិងជាអ្នករស់នៅស្អាតស្អំ ។ នៅក្នុងអត្ថន័យ «ផែនការចុងក្រោយ» ក្រុមដែលនៅកៀកៗនឹង កុយ ធួន បានបង្កើតបរិយាកាសសន្តិភាពនិយមហ៊ឺហាសប្បាយ យកសិល្បៈនិងយកស្រ្តីជាការសប្បាយ...បង្កជាមុខមាត់ បុណ្យស័ក្តិ និងមានទំនាក់ទំនងជាមួយខ្មាំង» ។[៩៨]

ចម្លើយសារភាពយ៉ាងលម្អិតក្បោះក្បាយនិងមានរបៀបរៀបរយរបស់កុយ ធួន បានឆ្លើយដាក់មនុស្សផ្សេងទៀតជាច្រើនរយនាក់ ។ បុគ្គលទាំងនេះរួមបញ្ចូលទាំងមន្ត្រីជាន់ខ្ពស់របស់បក្ស កម្មាភិបាលកងទ័ពនិងស៊ីវិលដែលធ្លាប់ធ្វើការជាមួយគាត់នៅក្នុងភូមិភាគឧត្តរ ព្រមទាំងបក្ខពួកដែលធ្វើការជាមួយគ្នា នៅគណៈពាណិជ្ជកម្ម ។ ចម្លើយសារភាពរបស់ កុយ ធួន ក៏មានពាក់ព័ន្ធដល់ក្រុមគ្រូបង្រៀនមួយក្រុមដូចជា រដ្ឋមន្រ្តីក្រសួងព័ត៌មានឈ្មោះ ហ៊ូ នឹម គណៈមន្ទីរ៨៧០ ឈ្មោះ សួស វ៉ាស៊ី, ភោគ ឆាយ អតីតរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឈ្មោះ ហ៊ូ យន់ (បោសសម្អាតនៅក្នុងឆ្នាំ១៩៧៥) និងអ្នកណែនាំ កុយ ធួន ឲ្យចូលបក្ស ឈ្មោះ ទីវ អុល ដែលធ្វើការជាមួយ ហ៊ូ នឹម នៅក្នុងឆ្នាំ១៩៧៧ ។ កុយ ធួន ក៏បាននិយាយពាក់ព័ន្ធដល់ប្រពន្ធរបស់ ទីវ អុល ឈ្មោះ ឡេង ស៊ីមហាក់ ដែរ ប៉ុន្តែ ស៊ីមហាក់ មិនទាន់ត្រូវបានចាប់ខ្លួននៅឡើយទេ នៅក្នុងរយៈពេលប្រាំមួយខែបន្ទាប់ពីការចាប់ខ្លួនប្តីរបស់នាង ។ នៅចុងបញ្ចប់នៃចម្លើយសារភាពមានរាយឈ្មោះ «កម្លាំងក្បត់»

នៅក្នុងភូមិភាគឧត្តរ ពាយ័ព្យ ផែកំពង់សោម និងភ្នំពេញ ។[៥៩]

នៅក្នុងចម្លើយសារភាព កុយ ធួន ត្រូវបានបង្ខំឲ្យនិយាយបន្ទាប់អាជីពរបស់ខ្លួនហើយបកអាក្រាតអ្នកដែលធ្លាប់ធ្វើការជាមួយគ្នាលើកលែងតែអ្នកដែលធ្វើការនៅមជ្ឈិមបក្ស ។ មិត្តភក្តិជាច្រើននាក់ទៀត ក៏ក្លាយជាមុខសញ្ញាថ្មីរបស់បក្សដែរ ។ ការបោសសម្អាតបក្ខពួករបស់ កុយ ធួន បានចាប់ផ្តើមក្រោយការចាប់ខ្លួន កុយ ធួន តែបន្តិចប៉ុណ្ណោះ ។ ក្រោយពីមានការបញ្ចេញយោបល់របស់អ្នកស្រី ឡូរ៉ា សាំម័រ លោកស្ទីវ ហេដឌ័រ បានហៅមិត្តភក្តិរបស់ កុយ ធួន ទាំងអស់ថាជា «សកម្មជនប្រជាធិបតេយ្យ» ហើយចាត់ទុកថាជា «អតីតអនុធនថ្នាក់ក្រោម» ដែលទាក់ទងជាមួយនឹង សុន សេន ដោយផ្ទាល់ប្រឆាំងមរយៈ កុយ ធួន ។ លោកហេដឌ័រ រកឃើញលក្ខណៈប្រឆាំងមានចរិតដូចៗគ្នាចំពោះនយោបាយរបស់ ប៉ុល ពត នៅក្នុងសម័យខ្មែរក្រហម ក្នុងចំណោមក្រុមរបស់ កុយ ធួន ដែលលើកឡើងខាងលើ ។[៦០]

ការឃុំខ្លួន កុយ ធួន បានធ្វើឡើងស្របជាមួយនឹងការផើបបះបោរដ៏ខ្លាំងក្លាប្រឆាំងនឹងរបបដែលដួលរលំនៅជីក្រែងជិតខេត្តសៀមរាបនៅក្នុងខែមីនា ។ ជនភៀសខ្លួនដែលបានរត់ទៅប្រទេសថៃ ក្រោយមកបានរាយការណ៍ថាមានការបះបោរនៅគ្រប់ទីកន្លែងក្នុងភូមិភាគឧត្តរ និងការផ្លាស់ប្តូរកម្មាភិបាលថ្នាក់មូលដ្ឋាន ហើយជំនួសដោយកម្មាភិបាលមកពីភូមិភាគនិរតីវិញ ។ ជនសង្ស័យនៅភូមិភាគឧត្តរនិងកងកម្លាំងយោធានៅក្នុងតំបន់មានជាអាទិ៍ដូចជាកងពលធំលេខ៣១០ និងកងពលលេខ៤៥០ ត្រូវបានបោសសម្អាតស្ទើរគ្មានសល់ ។ បណ្ណសារនៅមន្ទីរស-២១ មានផ្ទុកនូវចម្លើយសារភាពជាងបីរយរបស់បុគ្គលនៅក្នុងអង្គភាពទាំងពីរនេះ ហើយឯកសារចំនួន១.១៧៨សន្លឹកមានលាយឡំជាមួយនឹងឯកសារទាក់ទងនឹងយុទ្ធជននៅក្នុងកងពលធំលេខ៣១០ ដែលមានលើកឡើងនៅគ្រប់ចម្លើយសារភាព ។ គ្រាន់តែនៅក្នុងខែមីនា ឆ្នាំ១៩៧៧ប៉ុណ្ណោះ មានមនុស្សចំនួនប្រមាណ១.០៥៩នាក់បានមកដល់មន្ទីរស-២១ ។ បុគ្គលច្រើនលើសលប់នៃចំនួននេះគឺសុទ្ធតែមានទំនាក់ទំនងជាមួយនឹងភូមិភាគឧត្តរ ។[៦១]

នៅក្នុងការសួរចម្លើយ កុយ ធួន អ្នកសួរចម្លើយបានរិះរកវិធីប្រឌិតទំនាក់ទំនងជាច្រើនជាមួយនឹងមនុស្សដែលត្រូវបានបោសសម្អាតរួចហើយ ។ អ្នកទោសឈ្មោះ កុយ ធួន បានសារភាពថា បានជួបជាមួយភ្នាក់ងារសេ.អ៊ី.អារបស់អាមេរិកដែលប្រកាសខ្លួនថាជា «ហ៊ីឃ្លី» និង «សឺរូទី» បានជួបជាមួយ «ភ្នាក់ងារ» វៀតណាម និងបក្ខពួកជនជាតិខ្មែរមិនមែនកុម្មុយនិស្តតាំងពីទសវត្សរ៍ឆ្នាំ១៩៦០ ក្នុងអំឡុងពេលសង្គ្រាមស៊ីវិល ។[៦២]

កុយ ធួន ធ្វើឲ្យអ្នកសួរចម្លើយពិបាកស្តាប់និងចាប់បាននូវអ្វីដែលគាត់និយាយណាស់ ។ នៅថ្ងៃទី២ ខែមីនា ឌុច បានសរសេរសំបុត្រមួយមកគំរាម កុយ ធួន ។ នៅចុងបញ្ចប់ ឌុច សរសេរថា÷

> ហេតុអ្វីបានជាឯងមានជំនឿខ្លាំងក្លាដល់ម្ល៉ឹង? ពួកសេ.អ៊ី.អា វៀតណាមនិងខ្មែរសេរីសុទ្ធតែមានក្លិនអសោចអស់ហើយ ហើយកម្លាំងរបស់វាត្រូវបានធ្វើឲ្យបែកខ្ញែកដោយសារការវាយប្រហារមួយដែលឯងមិនដែលនឹកស្មានដល់ ។ ចំពោះបញ្ហានេះ ឯងមិនទាន់បានរាយការណ៍ឲ្យបានត្រឹមត្រូវនៅឡើយទេ ។ នេះជាបញ្ហាដែលឯងកំពុងតែគេច ។

ពីរថ្ងៃក្រោយមក កុយ ធួន បានសរសេរចម្លើយដោយគ្មានមូលដ្ឋានច្បាស់លាស់មួយដើម្បីឆ្លើយតបទៅនឹងការទាមទារនេះ ។ មួយខែក្រោយមកគឺមុនពេលគាត់ត្រូវបានយកទៅសម្លាប់ កុយ ធួន បានរៀបរាប់ឈ្មោះមនុស្សរាប់រយនាក់ព្រមទាំងលម្អិតសកម្មភាពក្បត់របស់គាត់ផ្ទាល់និងរបស់អ្នកដទៃទៀតយ៉ាងល្អិតល្អន់ ។

ចម្លើយសារភាពរបស់ កុយ ធួន ជាកញ្ចក់ឆ្លុះបញ្ចាំងអំពីដំណើររឿងផ្លូវការរបស់បក្ស ។ នៅគ្រប់ចំណុចទាំងអស់ដូចជា «គម្រោងការ» គ្មានបានការក្នុងការធ្វើឃាត ប៉ុល ពត «ប្រមូលកម្លាំង» បង្កើតបក្សប្រឆាំង ប្រមូលជំនួយនិងការគាំទ្រពីប្រទេសថៃ អាមេរិកាំង និងវៀតណាម ប្រមូលកម្លាំងទ័ពរបស់ខ្លួន និង «បង្កឲ្យមានភាពច្របូកច្របល់» ដោយបើកឲ្យមានឡើងវិញនូវកម្មសិទ្ធិបុគ្គល គឺគ្មានន័យអ្វីទាំងអស់ ។ «សកម្មភាពក្បត់»របស់ កុយ ធួន ដែលអាចមានលក្ខណៈគ្រប់គ្រាន់ធ្វើឲ្យប៉ះពាល់និងកម្ទេចរបបកាន់អំណាចមិនមានឥទ្ធិពលទៅលើកម្ពុជាប្រជាធិបតេយ្យឡើយ ។ ប៉ុន្តែផ្ទុយមកវិញ ភាពគ្មានអំណាចនិងចម្លើយសារភាពគ្មានមូលដ្ឋានច្បាស់លាស់របស់ កុយ ធួន អាចផ្តល់ជាភ័ស្តុតាងថែមទៀតដែលបង្ហាញឲ្យឃើញប្រផ្នូលនៅថ្ងៃអនាគតរបស់បក្ស ។

ដោយមានអត្ថន័យដូចអត្ថបទនៅក្នុងឯកសារទង់បដិវត្ត វគ្គសិក្សានៅមន្ទីរស-២១ នៅពេលនេះអាចទាញសេចក្តីសន្និដ្ឋានថា ការចាប់ខ្លួន កុយ ធួន និងទិន្នន័យនៅក្នុងចម្លើយសារភាពរបស់គាត់បានកាត់បន្ថយភាពតានតឹងនៅក្នុងប្រទេសយ៉ាងច្រើន ។ អ្នកសួរចម្លើយថ្នាក់លើម្នាក់ឈ្មោះ ទុយ បានសរសេរថា÷

> នៅក្នុងតំបន់ខត្តរចាស់ មុនពេលដែលបញ្ហា «ខ្សែ» និង «បណ្តាញ» របស់ កុយ ធួន ត្រូវបានដោះស្រាយរួច មានបញ្ហាកើតឡើងជាច្រើនទាក់ទងនឹងការការពារ កសាងនិងបញ្ហាផ្សេងៗដែលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជន ។ ក្រោយពី «ខ្សែ» អាកុយ ធួន ចេញមុខច្បាស់ (ចលនាបដិវត្តន៍) អាចឈានទៅមុខគ្រប់វិស័យ ។[៦៣]

ពីរសប្តាហ៍ក្រោយពីការចាប់ខ្លួនរបស់ កុយ ធួន ឈ្មោះ ឌឿន ត្រូវបាននាំយកមកដាក់នៅមន្ទីរស-២១ ។ ឌឿន ដែលធ្លាប់ធ្វើការយ៉ាងជិតស្និទ្ធជាមួយ ធួន នៅក្នុងអំឡុងសង្រ្គាមស៊ីវិលបានឡើងជំនួស កុយ ធួន ធ្វើជាលេខាផ្នែកពាណិជ្ជកម្មយ៉ាងឆាប់រហ័ស ។ នៅឆ្នាំ១៩៧៥ ឌឿន បានក្លាយជាប្រធានរដ្ឋបាលនៃមន្ទីរ-៨៧០របស់គណៈមជ្ឈិម ។ នៅក្នុងចន្លោះឆ្នាំ១៩៧៦-៧៧ ឌឿន បានជួបជាមួយនឹង កុយ ធួន ជាញឹកញាប់ដើម្បីពិភាក្សាកិច្ចការក្រសួងពាណិជ្ជកម្ម ។ រាល់ជំនួបជាមួយ កុយ ធួន សុទ្ធតែមានការអនុញ្ញាតពីថ្នាក់លើជាមុន ប៉ុន្តែនៅពេល ឌឿន ត្រូវបានចាប់ខ្លួន រាល់កិច្ចជួបពិភាក្សាទាំងអស់កើតមានតែម្តងម្កាលនិងក្នុងលក្ខណៈជាការឃុបឃិតប៉ុណ្ណោះ ។ ក្នុងខណៈដែល «ទោសកំហុស» របស់បុគ្គលទាំងពីរនាក់អាចបណ្តាលមកពីការសង្ស័យរបស់មជ្ឈិមបក្ស លទ្ធភាពនៃការឃុបឃិតច្បាស់លាស់រវាងមិត្តចាស់ពីរនាក់នេះដែលម្នាក់ជាអ្នកមានភក្តីភាពជាមួយនឹងមជ្ឈិមបក្សនិងម្នាក់ទៀតជាអ្នករក្សាការពង្រីក «បណ្តាញ» របស់ខ្លួន

នៅតាមជនបទ មិនអាចគិតថាមិនសំខាន់នោះទេ ។[៦៤]

ដោយនឹករកអ្វីដែលជាបទល្មើសរបស់ខ្លួន ឡឿន បាននិយាយថា ខ្លួនបានរត់ចោលជួរពេលប្រយុទ្ធនៅក្នុងសង្គ្រាមស៊ីវិល បំផុសកូនចៅឲ្យ“បាត់បង់ជំនឿទៅលើបដិវត្តន៍” និងដាំដំណាំដោយគ្មានការអនុញ្ញាត ។ ឡឿន បានបន្តសារភាពថា បានទាក់ទងយ៉ាងសកម្មជាមួយនឹងកម្មាភិបាលជាច្រើននៅសម័យសង្គ្រាម (ស៊ីវិល) និងប៉ុនប៉ងប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ ។

នៅក្នុងចំណោមអ្នកទោសដែលត្រូវបានចាប់ខ្លួនមកដល់ពេលនេះលើកលែងតែ ណៃ សារ៉ាន់ ឈ្មោះ ឡឿន គឺជាអ្នកធ្វើការនៅកៀកនឹងមជ្ឈិមបក្សជាងគេបង្អស់ ហើយគាត់ត្រូវបានដឹងថាមានតួនាទីសំខាន់នៅពេលដែលតួនាទីនេះត្រូវបានចូលមកជំនួសដោយ ខៀវ សំផន ដែលជាគណៈប្រធានរដ្ឋមានតែឈ្មោះរបស់កម្ពុជាប្រជាធិបតេយ្យ ។ វាអាចជាការពិតដូចដែលលោក ស្ទីវ ហេដឌ័រ បានទាញហេតុផលថា ខៀវ សំផន បានដើរតួនាទីយ៉ាងសំខាន់ក្នុងការទម្លាក់ ឡឿន ចេញពីតំណែង ។ ខៀវ សំផន ជាអ្នកបានទទួលផលប្រយោជន៍ច្រើនជាងគេ ។[៦៥] ចម្លើយសារភាពរបស់ កុយ ធួន ក៏និយាយពាក់ព័ន្ធដល់ ហ៊ូ នឹម ហៅ ភាស់ ដែលជារដ្ឋមន្ត្រីក្រសួងពត៌មាននិងឃោសនាការនិងជាជំនួយការរបស់ ខៀវ សំផន ជាយូរណាស់មកហើយដែរ ។ ហ៊ូ នឹម ត្រូវបានចាប់ខ្លួននៅក្នុងខែមេសា ឆ្នាំ១៩៧៧ ។[៦៦] ហ៊ូ នឹម ជាកូនកសិករក្រខ្សត់កើតនៅឆ្នាំ ១៩៣០ ក្នុងខេត្តកំពង់ចាម ។ គាត់រៀនជាមួយ ខៀវ សំផន (មិនបានរៀនជាមួយ សាឡុត ស ទេ) នៅក្នុងខេត្តកំពង់ចាម ។ ហ៊ូ នឹម ទៅសិក្សានៅប្រទេសបារាំងចាប់ពីឆ្នាំ១៩៥៥ ដល់ ឆ្នាំ១៩៥៧ នៅពេលដែល ខៀវ សំផន កំពុងស្ថិតនៅប្រទេសបារាំង មុនពេលមកកាន់តំណែងក្នុងជួររដ្ឋាភិបាលនៅទីក្រុងភ្នំពេញ ។ ហ៊ូ នឹម បានបម្រើការនៅក្នុងសភាជាតិរបស់របប សីហនុ ជាមួយនឹង ខៀវ សំផន និង ហ៊ូ យន់ រហូតដល់ថ្ងៃមួយដែលសម្តេចមានព្រះទ័យក្រេវក្រោធចំពោះការនិយាយចេញមុខគាំទ្រគំនិតរបស់ចិន ។ ដោយសារមានការគំរាមចាប់ខ្លួន នៅក្នុងឆ្នាំ១៩៦៧ ហ៊ូ នឹម បានរត់កៀសខ្លួនចេញពីទីក្រុង ។ ពេលនោះ ហ៊ូ យន់ និង ខៀវ សំផន ក៏រត់ទៅបន្តបន្ទាប់គ្នា ។ អស់រយៈពេលជាច្រើនឆ្នាំមិនមានលេចឮដំណឹងពីបុគ្គលទាំងបីរូបនេះឡើយ ។ អ្នកគាំទ្ររបស់អ្នកទាំងបីនឹកស្មានថាមេដឹកនាំរបស់ខ្លួនស្លាប់បាត់ទៅហើយ ។ ចាប់ពីពេលនោះមកអ្នកទាំងបីត្រូវបានហៅថា “ខ្មោចទាំងបី” ។

ក្រោយរដ្ឋប្រហារខែមីនា ឆ្នាំ១៩៧០ភ្លាម ខ្មោចទាំងបីបានលេចមុខជាថ្មីតាមរយៈរលកធាតុអាកាសវិទ្យុអំពាវនាវកៀងគរប្រជាជនឲ្យក្រោកឡើងតស៊ូ ។ នៃអំឡុងពេលសង្គ្រាមស៊ីវិលអ្នកទាំងបីបានកាន់កាប់មុខតំណែងក្នុង “គណៈរដ្ឋមន្ត្រី” នៅក្នុងរដ្ឋាភិបាលរណសិរ្សរួបរួមជាតិដោយបង្កើតឡើងនូវទម្រង់ដឹកនាំក្លែងក្លាយមួយដែលទាត់ចោលអ្នកកាន់អំណាចពិតប្រាកដនៅក្នុងមជ្ឈិមបក្ស ។

ហ៊ូ នឹម គឺជាអ្នកបដិវត្តដាច់ខាតមួយរូប ។ សូម្បីតែមកដល់មន្ទីរស-២១ហើយក៏ដោយ ក៏គាត់នៅតែរៀបចំខ្លួនដើម្បីទទួលយកនូវបញ្ជារបស់បក្សដែរ ។ នៅក្នុងសំណេរផ្ទាល់ដៃរបស់គាត់ ហ៊ូ នឹម បានរៀបរាប់អំពីសកម្មភាពប្រឆាំងនឹងបដិវត្តន៍ ប៉ុន្តែដោយសារអាជីពជាអ្នកបដិវត្តរបស់គាត់ត្រូវបានលេចឮសុសសាយពេក ភាគច្រើននៃសកម្មភាពក្បត់របស់គាត់ដែលត្រូវចោទឡើងបានក្លាយជាកត្តាអត្តនោម័តិនិងមាន

ចរិតគហបតី ។

អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ជាតិហុល្លង់ម្នាក់ឈ្មោះលោក ប៊ីរ យ៉ូវ បានអះអាងថា នៅក្នុងចម្លើយសារភាពរបស់ ហ៊ូ នឹម មានការបង្ហើបថា គាត់មានការជំទាស់ខ្លះចំពោះនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជា ហើយបានដឹងការជំទាស់ពីមនុស្សដទៃទៀត ។ យោងតាមសម្ដីរបស់ ប៉ែន យៀរនិន បានឲ្យដឹងថា ហ៊ូ នឹម បានស្នើឲ្យប្រើរូបិយប័ណ្ណឡើងវិញនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។[៦៧] នៅក្នុងចម្លើយសារភាពរបស់ខ្លួន ហ៊ូ នឹម និយាយថា រស់ ញឹម ដែលជាលេខាភូមិភាគពាយ័ព្យបានរិះគន់នយោបាយ«ម្ចាស់ការដោយប្រើកម្លាំងពលកម្មជាមូលដ្ឋាននិងប្រើគ្រឿងចក្រជាទ្រង់ទ្រាយតូច»របស់មជ្ឈិមបក្ស ។ ហ៊ូ នឹម និយាយថា សោ ភឹម ក៏មានទស្សនៈប្រឆាំងប្រហាក់ប្រហែលគ្នានេះដែរ ។ រស់ ញឹម បានរិះគន់ថា ការតស៊ូប្រដាប់អាវុធនៅក្នុងភូមិភាគពាយ័ព្យក្នុងទសវត្សរ៍ឆ្នាំ៦០ ដែលចាប់ផ្ដើមឡើងពីការបះបោរដោយឯកឯងជាទ្រង់ទ្រាយតូចនៅសំឡូតនៅក្នុងឆ្នាំ១៩៦៧ ហើយដែលត្រូវវាយបង្ក្រាបយ៉ាងឃោរឃៅ មិនឃើញមានកត់ចូលនៅក្នុងប្រវត្តិរបស់បក្សឡើយ ។[៦៨]

ចម្លើយសារភាពរបស់ ហ៊ូ នឹម បានបង្ហាញអំពីការចាប់ខ្លួនដែលរាលដាលយ៉ាងរហ័សទៅដល់ភូមិភាគពាយ័ព្យ ។ តាមពិតការបោសសម្អាតគឺបណ្ដាលមកពីវិបត្តិខ្វះស្បៀងអាហារដែលឃាយឺមកលើភូមិភាគពាយ័ព្យ ជាកន្លែងដែលមានប្រជាជនជម្លៀសមកថ្មីៗពីទីក្រុងនានារាប់ពាន់នាក់ត្រូវស្លាប់ដោយការខ្វះជីវជាតិអាហារគ្រប់គ្រាន់និងការធ្វើការបាក់កម្លាំង និងជាកន្លែងដែលមានការចែករបបអង្ករនិងធញ្ញជាតិមិនគ្រប់គ្រាន់តាមការកំណត់និងផែនការបួនឆ្នាំរបស់បក្ស ។ ហេតុនេះហើយបានជាបណ្ដាលឲ្យមានគ្រោះទុរ្ភិក្សកើតឡើង ។ ការបោសសម្អាតបានក្លាយទៅជាករណី «ទទួលថ្នបាក់» របស់បក្សដែលកម្មវិធីរបស់ខ្លួនមិនអាចទទួលបានជោគជ័យឡើយ ប្រសិនបើមានអ្នកខ្លះអនុវត្តតាមផ្លូវផ្សេងនោះ ។ តាមរយៈសម្ដីរបស់ រស់ ញឹម ដែលដកស្រង់ចេញពីចម្លើយសារភាពរបស់ ហ៊ូ នឹម បានបញ្ជាក់ថា÷

> នៅឆ្នាំ១៩៧៦ បក្សបានចាត់តាំងឲ្យយើងសម្រេចផែនការបង្កបង្កើនផលស្រូវក្នុងមួយហិកតាឲ្យបានបីតោន...ចំពោះភូមិភាគពាយ័ព្យវិញ...បក្សបានចាត់តាំងឲ្យសម្រេចបានបួនតោនក្នុងមួយហិកតា...តើទៅម៉េចរួច បើមិនដោះស្រាយបញ្ហាម៉ាស៊ីននោះ? យើងធ្វើមិនបានទេ ។ នេះមិនមែនជាកំហុសរបស់ខ្ញុំទេ វាជាកំហុសរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ។[៦៩]

ដើម្បីឲ្យ ហ៊ូ នឹម អាចសរសេរប្រយោគចុងក្រោយនៅក្នុងចម្លើយសារភាពរបស់ខ្លួន ទោះជាមានការទម្លាក់កំហុសទៅលើអ្នកដទៃក៏ដោយគឺវាត្រូវការសេចក្ដីក្លាហានមិនធម្មតាមួយ ។ នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៧ ហ៊ូ នឹម បានសរសេរនៅក្នុងចម្លើយសារភាពជាលើកចុងក្រោយរបស់គាត់ថា÷

> អស់រយៈពេលជាងម្ភៃឆ្នាំហើយដែលខ្ញុំបានបន្ទាបខ្លួនបម្រើសកម្មភាពខ្លាំង ។ ទម្លាប់កម្មសិទ្ធិទ្រព្យ

> សម្បត្តិឯកជនដែលបានបំពាក់មកលើខ្ញុំដោយវណ្ណៈសក្តិភូមិនាយទុន និងពួកចក្រពត្តិបានគ្របសង្កត់ និងបង្ខំខ្ញុំឲ្យក្លាយជាភ្នាក់ងារខ្មាំង ។ ខ្ញុំបានបម្រើ...ភ្នាក់ងារសេ.អ៊ី.អា និងចក្រពត្តិអាមេរិកដែលមកដល់ឥឡូវនេះត្រូវវាយឲ្យបរាជ័យយ៉ាងអាម៉ាស់និងបានទទួលវាសនាដូចសព្វថ្ងៃនេះ ។ ខ្ញុំបានទទួលការអប់រំពីបក្សអស់រយៈពេលមួយខែកន្លះកន្លងទៅហើយ ។ ខ្ញុំគ្មានអ្វីពឹងពាក់ទេ មានតែបក្សកុម្មុយនិស្តកម្ពុជាតែមួយគត់ ។ សូមបក្សមេត្តាទុកជីវិតឲ្យខ្ញុំផង ។ ជីវិតខ្ញុំគឺអាស្រ័យលើបក្សទាំងស្រុង ។

នៅចុងខែមេសា ឆ្នាំ១៩៧៧ សៀត ឆែ ត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១ បន្ទាប់ពី ហ៊ូ នឹម ។ សៀត ឆែ បានដាក់ជំនួស ចាន់ ចក្រី ឲ្យធ្វើជាអគ្គសេនាធិការនៅក្នុងឆ្នាំ១៩៧៦ ក្រោយពីបានធ្វើជាលេខាតំបន់២២នៅភូមិភាគបូព៌ា ។ នៅទីនោះដោយសារ ឆែ ត្រូវបានស្គាល់ជាទូទៅថាជាមនុស្សរបស់ ប៉ុល ពត គាត់ប្រហែលជាមនុស្សដែលត្រូវរំពឹងថាជាអ្នកតាមដាន សោ ភឹម និងកម្មាភិបាលដទៃទៀត ។ ឆែ សិក្សាថ្នាក់ក្រោម សាឡុត ស នៅសាលាចំរើនវិជ្ជានៅទសវត្សរ៍ឆ្នាំ១៩៥០ ។ សៀត ឆែ ត្រូវបាននាំចូលក្នុងចលនាបក្សកុម្មុយនិស្តដោយ សាឡុត ស និងប្រពន្ធឈ្មោះ ខៀវ ប៉ុណ្ណារី ។ ឆែ បានអមដំណើរ សាឡុត ស ទៅកាន់មន្ទីរ១០០ កាលពីឆ្នាំ១៩៦៣ ហើយជួយមើលថែជំងឺគ្រុនចាញ់ និងជំងឺតម្កាត់ផ្សេងៗទៀតឲ្យ សាឡុត ស ។ ប៉ុន្តែនៅត្រឹមឆ្នាំ១៩៧៧ ប្រហែលដោយសារ ឆែ មានការពាក់ព័ន្ធជាមួយនឹងខាងភូមិភាគបូព៌ា និងអ្នកបេះដូងកាលពីជំនាន់គាត់ធ្វើការនៅក្នុងជួរបក្សដែលត្រូវបានបោសសម្អាតរួចហើយបានជាកេរ្តិ៍ឈ្មោះរបស់ ឆែ សាបសូន្យទៅវិញ ។ ដូចសម្តីរបស់ ឆែ នៅក្នុងចម្លើយសារភាពរបស់គាត់ដែរថា មើលទៅប្រហែលជាសមាជិកបក្សមានការច្រណែនឈ្នានីសនឹងមុខតំណែងខ្ពស់របស់គាត់បានជានាំឲ្យមានបញ្ហានេះ ។ ការចាប់ខ្លួនរបស់ ឆែ ជាការបញ្ជាក់ច្បាស់ថា ភក្តីភាពជាមួយនឹងបក្សកុម្មុយនិស្តកម្ពុជាមិនអាចក្លាយជាផ្លូវមានមុខពីរដាច់ខាត ។ កាន់តែច្បាស់ជាងនេះទៀត ដោយសារតែ ឆែ ត្រូវបានរំពឹងគិតថា បានក្បត់នឹងការទុកចិត្តរបស់បក្សឬប្រហែលដូចដែលគាត់បានអះអាងស្រាប់ថា គាត់គ្មានកំហុសនិងនៅតែសង្ឃឹមថានឹងទទួលបានការយោគយល់អត់ឱនឲ្យ ការសួរចម្លើយទៅលើរូប ឆែ កាន់តែមានលក្ខណៈធ្ងន់ធ្ងរ ។ ជាងនេះទៅទៀត នៅមុនពេលការចាប់ខ្លួនបន្តិចតែប៉ុណ្ណោះ ឆែ បានធ្វើការយ៉ាងជិតដិតជាមួយនឹង សុន សេន ។ ដើម្បីចៀសវាងការនិយាយពាក់ព័ន្ធដល់ខ្លួន អតីតគ្រូរបស់ ឆែ ប្រហែលជាមិនចង់ជំរុញឲ្យមានការសួរចម្លើយទេ ។

មិនខុសពី កែវ មាស ទេ សៀត ឆែ បានព្យាយាមផ្ញើចំណារកំណត់សម្គាល់របស់ខ្លួនពីមន្ទីរស-២១ ទៅកាន់«បងៗថ្នាក់លើ» ។ ការពិតដែលថាឯកសារនេះនៅសល់នៅឡើយបញ្ជាក់ថា សំបុត្រទាំងនេះមិនដែលត្រូវបានយកចេញពីគុកឡើយ ។ ប៉ុន្តែឋានៈខ្ពស់របស់ ឆែ ប្រហែលជាធ្វើឲ្យ ឌុច និងអ្នកធ្វើការជាមួយមិនហ៊ានកម្ទេចឯកសារនេះចោល ។ ឯកសារទាំងនេះមានសារសំខាន់ក្នុងការទុកទាំងដុលរបៀបនេះ ។[៩០]

នៅក្នុងសំបុត្រមួយក្នុងចំណោមសំបុត្រទាំងអស់ដែលសរសេរនៅក្រោយពេលចាប់ខ្លួនឆែ បាន បដិសេធចំពោះការចោទប្រកាន់មកលើខ្លួន ។ បីថ្ងៃក្រោយមក ឆែ បានសរសេរទៅកាន់ «បង៨៩» សុន សេន ថា÷

> បងអើយខ្ញុំមានការឈឺចាប់ខ្លាំងណាស់! នៅក្នុងមួយជីវិតខ្ញុំ ខ្ញុំមិនដែលជួបប្រទះនូវការឈឺចាប់

របៀបនេះឡើយ! នៅពេលដែលកូនស្រីរបស់ខ្ញុំជាប់គុករបស់ខ្មាំង (លន់ ណុល) ខ្ញុំគិតថាវាជាការធម្មតាទេចំពោះការតស៊ូរវាងខ្មាំងនឹងយើង! ប៉ុន្តែឥឡូវដល់ពេលខ្ញុំត្រូវជាប់ឃុំឃាំងនៅក្នុងគុកបដិវត្តន៍ ខ្ញុំមិនយល់ទេ ។ វាច្របូលច្របល់ពិបាកយល់ណាស់ ។ ប៉ុន្តែនៅចុងបញ្ចប់ខ្ញុំអាចមើលឃើញច្បាស់ថា គឺពួកសេ.អ៊ី.អា ពួកវៀតណាមលេបទឹកដី និងពួកធ្វើការជាមួយកា.ហ្សេ.បេ ដែលនាំឲ្យខ្ញុំជាប់គុកបដិវត្តន៍បែបនេះ ។

សៀត ឆែ ប្រាប់ សុន សេន ថា "ពួកក្បត់បីនាក់" បានបង្ខូចកេរ្តិ៍ឈ្មោះគាត់ ។ ឆែ បញ្ជាក់ថា គាត់បាន "រៀបរាប់រឿងរ៉ាវលម្អិតជូនអង្គការអស់ហើយតាមរយៈមន្ទីរស-២១" ។ ដោយមានការទាក់ទងដោយផ្ទាល់ជាមួយនឹង "បង១ថ្នាក់លើ" ឆែ សង្ឃឹមថានឹងអាចសម្រួលស៊ុំរូចខ្លួនបាន ។ ប៉ុន្តែបន្ទាប់មកនៅក្នុងកំណត់សម្គាល់មួយ ឆែ សរសេរថា "ខ្ញុំដឹងអំពីកន្លែងនេះ ហើយមិនប្រាប់ក៏ដឹងដែរ គឺពេលចូលមកដល់មន្ទីរស-២១ហើយមានមនុស្សភាគតិចណាស់ដែលអាចរួចខ្លួន ពោលគឺមានតែចូលគ្មានវិលវិញជាច់ខាត ។ បងអើយ! បើសិនជាអ៊ីចឹងមែននោះ ខ្ញុំគ្មានផ្លូវទេ" ។

ការអន្ទះអន្ទែងរបស់ ឆែ សុំក្តីមេត្តា ហាក់ដូចជាការបញ្ជាក់ច្បាស់អំពីការពិតនឹងអាចកើតឡើងចំពោះគាត់ដូចដែលយើងឃើញស្រាប់តាមរយៈការឆ្លើយតបវិញប្រកបដោយលក្ខណៈឃោរឃៅរបស់ ឌុច ។ សៀត ឆែ មានការភ័យខ្លាចខ្លាំងណាស់ ។ គាត់ដឹងខ្លួនថា គាត់នឹងត្រូវរងនូវទារុណកម្មជាក់ជាមិនខានឡើយ ។ ឆែ បានសរសេរថា៖

នៅក្នុងមន្ទីរស-២១មួយរយៈមក អ្នកធ្វើការនៅក្នុងគុកមិនទាន់បានប្រើមធ្យោបាយអ្វីមកលើរូបខ្ញុំទេ ។ ខ្ញុំគ្រាន់តែជាប់ខ្នោះប៉ុណ្ណោះ ។ អ្នកធ្វើការនៅទីនេះយកចិត្តទុកដាក់នឹងខ្ញុំណាស់ ។ តាមសម្តីរបស់អ្នកទទួលខុសត្រូវខ្ញុំ ប្រហែលប្រាំទៅប្រាំពីរថ្ងៃខាងមុខ ខ្ញុំនឹងចូលដល់ដំណាក់កាលទីពីរ ពោលគឺដំណាក់កាលរងទារុណកម្ម ។

បងជាទីស្នេហា! ខ្ញុំដឹងខ្លួនថា ពេលនេះខ្ញុំចប់ហើយ ។ ទោះបីជាសមមិត្តយកខ្ញុំទៅវៃដំច្រំធាក់វាយបំបាក់ជើងដៃ ក៏នៅតែមិនមានចម្លើយលើសពីនេះទៀតដែរ ។ មានតែការបង្ខូរឈាមនិងលាមក ឬក៏ការស្លាប់បាត់បង់ជីវិតតែប៉ុណ្ណោះ ។

សូមបងមេត្តាជួយសង្គ្រោះខ្ញុំឲ្យទាន់ពេលវេលា ។ ទោះបីជាខ្ញុំស្លាប់ ក៏ខ្ញុំនៅតែស្មោះស្ម័គ្រចំពោះបក្សរហូតដល់ចុងបញ្ចប់ ។

បើសិនជាបងមិនជួយខ្ញុំទេ ប្អូនប្រាកដជាត្រូវស្លាប់មិនខាន! ហើយខ្ញុំនឹងស្លាប់ដោយដៃរបស់ខ្ញុំផ្ទាល់មិនឲ្យសន្តិសុខបក្សកម្ទេចខ្ញុំទេ...ដើម្បីការពារកិត្តិយសឲ្យសន្តិសុខបក្សក្នុងការកម្ទេចខ្មាំង... ។

នេះជាពេលចុងក្រោយហើយ...សូមបងជួយប្អូនឲ្យបានទាន់ពេលផង ។ ខ្ញុំសុខចិត្តមកធ្វើស្រែជាមួយប្រពន្ធកូនខ្ញុំនៅក្នុងសហករណ៍វិញ ។ មិនចង់បានមុខតំណែងអ្វីទេ ។ បងមិនបាច់គិតពីរឿងហ្នឹង

ទេ...ជួយសង្គ្រោះខ្ញុំឲ្យមានជីវិតផង ។

នៅក្នុងការឆ្លើយតបវិញតាមរយៈសំបុត្រដែលសរសេរក្រោយពីពេលដែល ឆែ ត្រូវបានធ្វើទារុណកម្ម ឌុច បានធ្វើការពិចារណាទៅលើការអះអាងរបស់អ្នកទោសម្នាក់នេះដែលថា ខ្លួនត្រូវបានបក្សពួកក្បត់ឆ្លើយដាក់ ។ ឌុច សរសេរថា «ការលាបពណ៌មនុស្សឲ្យក្លាយជាពណ៌ខ្មៅ គឺជាល្បិចរបស់ខ្មាំង ។ ប៉ុន្តែ បក្សកុម្មុយ-និស្តកម្ពុជាដឹងច្បាស់ណាស់អំពីលទ្ធភាពក្នុងការតាមដាន និងទប់ទល់ល្បិចបែបនេះ» ។ ឌុច បន្តទៀតថា

តាមការសង្កេតតាមប្រវត្តិសាស្ត្ររបស់ខ្ញុំរហូតមក ខ្ញុំមិនដែលឃើញកម្មាភិបាលណាមួយរងគ្រោះដោយសារតែល្បិចលាបពណ៌ឲ្យខ្មៅបែបនេះទេ ។ បក្សមិនបារម្ភអំពីបញ្ហានេះសោះ ។ និយាយឲ្យស្រួលស្តាប់គឺថាមិនដែលមានកម្មាភិបាលណាម្នាក់ចូលមកសន្តិបាលដោយសារការលាបពណ៌ខ្មៅឡើយ...តើបងយល់យ៉ាងណាដែរចំពោះបញ្ហានេះ?

ពិនិត្យទៅលើបញ្ហា តើបញ្ហានេះកើតឡើងដោយសារតែបក្សកុម្មុយនិស្តត្រូវបានបោកប្រាស់ដោយសារខ្មាំងលាបពណ៌ឲ្យបងឯងឬក៏ដោយសារបងមិនត្រង់នឹងបក្ស ។ តើបងយល់យ៉ាងម៉េចដែរ? សូមបងគិតនិងដោះស្រាយបញ្ហានេះ ។ នៅពេលយើងយល់ស្របគ្នាយើងនឹងធ្វើការទាំងអស់គ្នា ។

សៀត ឆែ មានការពិបាកក្នុងការដោះស្រាយបញ្ហានេះ ។ នៅក្នុងខែកក្កដា ឌុច ដឹងអំពីបញ្ហានេះ ។ នៅក្នុងអ្វីដែលជាឯកសារដ៏សាហាវជាងគេបង្អស់នៅក្នុងបណ្ណសារនៅមន្ទីរស-២១នោះ អ្នកសួរចម្លើយឈ្មោះទុយ បានសរសេរទៅកាន់ សៀត ឆែ ថា÷

សរសេរអំពីសកម្មភាពខុសសីលធម៌ជាមួយកូនឲ្យបានលម្អិត ពីព្រោះតាមគោលជំហរមហាជន កំហុសនេះត្រូវបានមើលឃើញច្បាស់ណាស់ ។ កុំបដិសេធអី ។ កុំឲ្យឈឺខ្លួនថែមទៀតដោយសារតែបញ្ហាតូចតាចនេះ ។

មនុស្សដែលមានការពាក់ព័ន្ធគឺកូនស្រីតែមួយរបស់ សៀត ឆែ ដែលទើបតែមានអាយុម្ភៃឆ្នាំ ។ នាងបានក្លាយជាជនបដិវត្តរួចហើយ ។ សៀត ឆែ បានបដិសេធការចោទប្រកាន់នេះ ហើយទទូចថាកូនស្រីជាទីស្រឡាញ់របស់ខ្លួនគឺពិតជានៅបរិសុទ្ធល្អណាស់ ។ មានរបស់អ្វីម្យ៉ាង ហាក់ដូចជាបានជ្រៀតចូលទៅក្នុងខ្លួនរបស់ ឆែ ក្រោយពីគាត់ត្រូវបានយាយីខាងផ្នែកអារម្មណ៍ ។ ចាប់ពីពេលនោះរហូតមកដល់ថ្ងៃដែល ឆែ ត្រូវបានសម្លាប់ ឆែ មិនបានសរសេរសំបុត្រទៀតឡើយ ។ ក៏ប៉ុន្តែចម្លើយសារភាពរបស់ ឆែ ពាក់ព័ន្ធអ្នកធ្វើការជាមួយខ្លួនរាប់សិបនាក់ ។

## ការបោសសម្អាតនៅភូមិភាគពាយ័ព្យ

នៅក្នុងអំឡុងឆ្នាំ១៩៧៧ ប្រហែលជាពេលដែលត្រូវប្រឈមមុខនឹងលទ្ធផលចម្រុះនៃការពង្រីកផ្នែកកសិកម្មដែលស្ថិតនៅក្នុងគម្រោងផែនការបួនឆ្នាំ ហើយប្រហែលដោយសារការប្រើពត៌មានដែលស្រង់ចេញមកពីចម្លើយសារភាពផ្ដើមកពីមន្ទីរស-២១ បានជាធ្វើឲ្យ ប៉ុល ពត ផ្ដោតជាសំខាន់ទៅលើការតាមដានកម្មេចខ្មាំងរបស់អង្គការច្រើនជាងទៅលើការអភិវឌ្ឍន៍សេដ្ឋកិច្ច ។ ផែនការបួនឆ្នាំហាក់ដូចជាត្រូវបានបោះបង់ចោលយ៉ាងស្ងាត់ស្ងៀម ។[៧១]

នៅក្នុងខែមេសា និងខែឧសភា ឆ្នាំ១៩៧៧ សន្តិបាលបានងាកទៅរកភូមិភាគឧត្តរវិញ ដែលនៅទីនោះកម្មាភិបាលកងទ័ពនិងស៊ីវិលត្រូវបានចោទប្រកាន់ថាបានធ្វើអំពើវិទ្ធង្សនាទៅលើវិស័យសេដ្ឋកិច្ចរបស់បដិវត្តន៍ ដោយបង្កឲ្យមានការលំបាកទៅលើប្រជាជនដើម្បីធ្វើឲ្យសីលធម៌ធ្លាក់ចុះនិងធ្វើឲ្យគ្មានជំនឿទៅលើបដិវត្តន៍ ។ នៅក្នុងឆ្នាំ១៩៧៧ ដោយសារមានការប្រមូលផលបានតិច កម្លាំងពលកម្មមិនមានការបំពាក់សម្ភារគ្រប់គ្រាន់ និងមិនមានអាហារគ្រប់គ្រាន់ ការចែកអង្ករពីភូមិភាគពាយ័ព្យមិនបានទៅដល់ទីក្រុងភ្នំពេញឡើយ ។ កម្មាភិបាលនៅក្នុងភូមិភាគត្រូវបានចោទប្រកាន់ថា បានប្រមូលផលទុកបុបំផ្លាញភោគផលក្នុងគោលបំណងបង្អត់អាហារប្រជាជននៅក្រោមការគ្រប់គ្រងរបស់ខ្លួនដោយអនុញ្ញាតឲ្យប្រជាជនដទៃទៀតភៀសខ្លួនទៅជនបទ ផ្ដល់ទឹកដីកម្ពុជាទៅឲ្យប្រទេសថៃ រួមជាមួយនិរទេសជនជាតិខ្មែរដើម្បីធ្វើគម្រោងការក្បត់ និងចោទថាបានលក់ស្រូវទៅឲ្យថៃ ។[៧២]

នៅក្នុងសម័យបដិវត្តន៍ ភូមិភាគពាយ័ព្យគឺជាឃ្លាំងបាយរបស់ប្រជាជនកម្ពុជាទូទាំងប្រទេសដែលជាតំបន់ផលិតស្រូវសំខាន់បំផុតសម្រាប់ការនាំចេញ ។ នៅក្នុងសង្គ្រាមលោកលើកទីII មួយភាគធំនៃភូមិភាគនេះ គឺស្ថិតនៅក្នុងការគ្រប់គ្រងរបស់ប្រទេសថៃ ហើយដោយមានការលើកទឹកចិត្តពីសំណាក់ប្រទេសថៃផង ។ ភូមិភាគនេះបានក្លាយទៅជាមូលដ្ឋានបង្អែករបស់ខ្មែរឥស្សរៈប្រឆាំងនឹងបារាំងនៅចុងទសវត្សរ៍ឆ្នាំ១៩៤០ ។ នៅក្នុងឆ្នាំ១៩៦៧ ការបះបោរប្រឆាំងនឹងកងទ័ព សីហនុ បានកើតឡើងនៅក្នុងអតីតមូលដ្ឋានរបស់ខ្មែរឥស្សរៈនៅសំឡូត ។ ការបះបោរនេះនាំឲ្យមានការបង្ក្រាបយ៉ាងធ្ងន់ធ្ងរនិងបណ្ដាលឲ្យមនុស្សរាប់ពាន់នាក់ត្រូវបាត់បង់ជីវិត ។ ការតស៊ូប្រដាប់អាវុធប្រឆាំងនឹង សម្ដេច សីហនុ បានចាប់ផ្ដើមនៅក្នុងភូមិភាគនេះតែម្ដង គឺនៅខែកុម្ភៈ ឆ្នាំ១៩៦៨ ។ ប៉ុន្តែនៅក្នុងអំឡុងពេលនៃសង្គ្រាមស៊ីវិល មួយភាគធំនៃតំបន់នេះស្ថិតនៅក្នុងដៃរបស់របបក្រុងភ្នំពេញ ។[៧៣]

ក្រោយឆ្នាំ១៩៧៥ ចំនួនប្រជាជននៅភូមិភាគពាយ័ព្យត្រូវថែម«ប្រជាជនថ្មី»ដែលត្រូវជម្លៀសពីក្រុងភ្នំពេញ ខេត្តបាត់ដំបងនិងក្រុងនានាទៀត ។ កម្មាភិបាលបក្សកុម្មុយនិស្តកម្ពុជានៅភូមិភាគពាយ័ព្យដូចជាគ្មានបទពិសោធន៍ខាងផ្នែករដ្ឋបាលទេ ហើយភាគច្រើនខ្វះទំនាក់ទំនងជាមួយមូលដ្ឋានផង ។ ប៉ុន្តែផ្ទុយមកវិញ ក្រុមរបស់កម្មាភិបាលទាំងនេះ ដែលធ្វើការនៅភូមិភាគនានាមានព្រំប្រទល់ជាប់ប្រទេសវៀតណាម បានទទួលការហ្វឹកហ្វឺនបដិវត្តអស់ជាច្រើនឆ្នាំ ហើយគ្រប់គ្រងនយោបាយរហូតក្រោយឆ្នាំ១៩៧០ ។ កម្មាភិបាលជាច្រើននាក់ដែលទទួលខុសត្រូវភូមិភាគពាយ័ព្យក្នុងឆ្នាំ១៩៧៥និង១៩៧៦ ជាគ្រូបង្រៀន មាន

ជាអាទិ៍ដូចជា ខែក ប៊ិន ហៅ ស៊ូ ជាដើម ដែលធ្វើជាលេខាប្រជាជនតំបន់៤ ហើយដែលត្រូវបោសសម្អាតនៅក្នុងឆ្នាំ១៩៧៧ ឬជាអតីតយុទ្ធជនមិនសូវចេះអក្សរមកពីភូមិភាគផ្សេងទៀត ។ ក្នុងករណីខ្លះ «ប្រជាជនថ្មី» ត្រូវបានដាក់ឲ្យទទួលខុសត្រូវ ប៉ុន្តែប្រជាជនទាំងនេះត្រូវបានចាត់ទុកថាជាអ្នកបំផ្លិចបំផ្លាញទៅវិញ ដោយសារតែធាតុវណ្ណៈនិងសកម្មភាពកាលពីមុនមករបស់ខ្លួន ។ ទស្សនាវដ្ដី«ទង់បដិវត្ត» បានបញ្ជាក់នៅក្នុងខែតុលា ឆ្នាំ១៩៧៧ថា «សហករណ៍ដែលគ្រប់គ្រងដោយវណ្ណៈភាពមិនល្អគ្មានអង្ករស៊ីទេ» ។ អត្ថបទនេះសរសេរថា ត្រូវតែទម្លាក់កំហុសទៅលើ «សមាសភាពមិនល្អ» ។[៧៤] ក៏ប៉ុន្តែលេខាភូមិភាគពាយ័ព្យឈ្មោះ មូល សម្បត្តិ (ហៅ រស់ ញឹម) គឺជាអ្នកបដិវត្តដើងចាស់ដែលមានកំណើតកើតជា និងបានកសាងខ្លួននៅភូមិភាគនេះ ។[៧៥] មិនខុសពី សោ ភឹម នៅភូមិភាគបូព៌ាទេ នៅក្នុងអំឡុងសង្គ្រាមស៊ីវិល សម្បត្តិ មិនទៅណាពីភូមិភាគនេះឡើយ ។ អ្វីដែល ប៉ុល ពត និងអ្នកធ្វើការនៅក្បែរខ្លួនគាត់មិនចូលចិត្តភូមិភាគពាយ័ព្យ គឺថាមេដឹកនាំរបស់ភូមិភាគនេះមិនសូវមានឯកភាពជាមួយព្រឹត្តិការណ៍ហើយមានទំនាក់ទំនងជាមួយនឹង សោ ភឹម តាមរយៈចំណងអាពាហ៍ពិពាហ៍របស់កូនអ្នកទាំងពីរ ។ ដោយសារ សម្បត្តិ មានប្រជាប្រិយភាពខ្លាំងពេក មជ្ឈិមបក្សក៏ផ្អាកចាប់ខ្លួនគាត់អស់រយៈពេលជាច្រើនខែ ។

នៅក្នុងភូមិភាគពាយ័ព្យតែមួយមានទិដ្ឋភាពខុសៗផ្សេងៗពីគ្នាទៅតាមតំបន់ ។ នៅក្នុងតំបន់ផលិតស្រូវសំខាន់ដែលស្ថិតនៅតំបន់៣ ជាទូទៅប្រជាជនមានអង្ករហូបគ្រប់គ្រាន់ហើយការសម្លាប់មនុស្សបានកើតមានតិចតួចតែប៉ុណ្ណោះ ។ នៅតំបន់ដែលមានរបាយប្រជាជនរស់នៅតិចពោលគឺតំបន់១ តំបន់៤ តំបន់៥ និងតំបន់៦ «ប្រជាជនថ្មី» ត្រូវបានចាត់តាំងឲ្យកាប់ឆ្ការព្រៃដែលជាជម្រកជំងឺគ្រុនចាញ់ ។ ជីវភាពរស់នៅរបស់ប្រជាជននៅតំបន់នេះមានលក្ខណៈធ្ងន់ធ្ងរជាងតំបន់៣ ហើយចំនួនមនុស្សស្លាប់បណ្ដាលមកពីជំងឺតម្កាត់និងកង្វះជីវជាតិអាហារមានកម្រិតខ្ពស់បំផុតក្នុងចំណោមតំបន់ផ្សេងៗទៀតនៃរបបកម្ពុជាប្រជាធិបតេយ្យ ។[៧៦] នៅក្នុងការបង្កើតគម្រោងផែនការបួនឆ្នាំ ប៉ុល ពត និងអ្នកធ្វើការនៅជិតខ្លួនបានផ្ដោតក្ដីសង្ឃឹមទៅលើភូមិភាគពាយ័ព្យដែលសង្ឃឹមថានឹងផលិតភោគផលកសិកម្មបាន៣០ភាគរយនៃផលជាតិប្រចាំឆ្នាំ ។ មជ្ឈិម-បក្សសង្ឃឹមថា «ប្រជាជនថ្មី» នៅភូមិភាគនេះដែលភាគច្រើនមិនធ្លាប់ធ្វើស្រែនឹងអាចបំពេញកិច្ចការ ដែលជាក្ដីសង្ឃឹមមិនប្រាកដប្រជារបស់របបកម្ពុជាប្រជាធិបតេយ្យគឺសម្រេចឲ្យបានផលស្រូវបីតោនក្នុងមួយហិកតា ។[៧៧]

នៅពាក់កណ្ដាលឆ្នាំ១៩៧៦ ខៀវ ធីរិទ្ធ (អៀង ធីរិទ្ធ) ដែលជាប្រពន្ធរបស់ អៀង សារី និងជាប្អូនថ្លៃស្រីរបស់ ប៉ុល ពត បានចុះទៅភូមិភាគពាយ័ព្យ ហើយមានការព្រួយបារម្ភចំពោះអ្វីដែលគាត់បានឃើញផ្ទាល់នឹងភ្នែក ។ ខៀវ ធីរិទ្ធ បាននិយាយទៅកាន់ អេលីហ្សាប៊ែត ប៊ែកឃ័រ នៅក្នុងឆ្នាំ១៩៨០ថា «ស្ថានការណ៍ពិតជាមិនធម្មតាទេ ។ ប្រជាជនគ្មានផ្ទះសម្បែងជ្រកកោនហើយសុទ្ធតែមានជំងឺតម្កាត់ទៀតផង» ។ ចំពោះស្ថានការណ៍ធ្ងន់ធ្ងរនេះ ខៀវ ធីរិទ្ធ មិនបានទម្លាក់កំហុសទៅលើខ្សែសង្វាក់បញ្ជារបស់មជ្ឈិមបក្សទេតែបែរជាប្រាប់ ប៊ែកឃ័រ ហើយប្រហែលជាបានប្រាប់ ប៉ុល ពត ដែរថា «មានពួកសមាសភាពមិនល្អលួចជ្រៀតចូលទៅក្នុងជួរយើង» ។[៧៨]

«សមាសភាពមិនល្អ» ម្នាក់ក្នុងចំណោមសមាសភាពទាំងអស់ប្រហែលជាឈ្មោះ ភោគ ឆាយ ថ្នាក់ដឹកនាំតំបន់ដែលត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៨ និងត្រូវទម្លាក់កំហុសអំពីបញ្ហាដែលកើតឡើងនៅក្នុងភូមិភាគនេះ÷

> ខ្ញុំបានណែនាំឲ្យបំផ្លាញផលស្រូវដោយឲ្យប្រូតស្រូវមិនទាន់ទុំ ។ នៅពេលបោកបែនក៏មានការណែនាំឲ្យបំផ្លាញដែរ ។ ខ្ញុំបានចាត់តាំងឈ្មោះ ឆើត ឲ្យដុតស្រូវនៅក្នុងស្រែ...ហើយផលស្រូវដែលប្រមូលបានក៏ដុតចោលមិនតិចដែរ ។ ខ្ញុំបានប្រាប់កម្លាំងនៅស្រុកទាំងអស់ថា មានចោរនិងប្រជាជនថ្មីជាអ្នកដុតស្រែស្រូវនេះ ។ គោលបំណងរបស់ខ្ញុំគឺបង្កភាពច្របូកច្របល់នៅក្នុងចំណោមប្រជាជនមូលដ្ឋាននិងប្រជាជនថ្មី ។ សភាពការណ៍នេះបានបន្ទុចបង្អាក់ផែនការ(បួនឆ្នាំ) របស់បក្ស... ។ នៅពេលកំពុងបង្កបង្កើនផលគឺត្រូវបំផ្លាញសម្ភារប្រើប្រាស់សម្រាប់បង្កបង្កើនផលនិងប្រមូលផល ។ ក្រៅពីនោះ កម្លាំងប្រចាំលេខាស្រុកត្រូវបានណែនាំឲ្យបង្អត់បាយប្រជាជន ឲ្យប្រជាជនហូបបបរដើម្បីឲ្យប្រជាជនទៅសុំអង្ករ ។[៧៩]

នៅក្នុងខែមេសា និងខែឧសភា ឆ្នាំ១៩៧៧ កម្មាភិបាលមកពីភូមិភាគពាយ័ព្យត្រូវបានចាប់ផ្ដើមនាំយកមកមន្ទីរស-២១ ។ មានអ្នកខ្លះមានទំនាក់ទំនងជាមួយនឹង «អ្នកចេះដឹង» ហើយអ្នកខ្លះទៀតត្រូវបានបោសសម្អាតដោយសារខ្លួនធ្វើការបំផ្លាញផែនការបួនឆ្នាំ ។[៨០] នៅដំណាច់ឆ្នាំ១៩៧៧ លេខានិងអ្នកជំនួយការទាំងអស់នៅតំបន់ទាំងប្រាំពីរក្នុងភូមិភាគពាយ័ព្យត្រូវបានបោសសម្អាត ហើយប្រជាជនរាប់សែននាក់ត្រូវបានសម្លាប់ចោល ។ មុនដំណាច់ឆ្នាំ ប្រជាជនមូលដ្ឋានជាច្រើនពាន់នាក់ (ពោលគឺអ្នកដែលមិនបានរស់នៅក្រោមការគ្រប់គ្រងរបស់ លន់ណុល ក្នុងពេលសង្គ្រាមស៊ីវិល) ត្រូវបាននាំយកមកពីភូមិភាគនិរតីទៅភូមិភាគពាយ័ព្យតាមរថភ្លើង ។ ប្រជាជននៅភូមិភាគបស្ចិមនិងនិរតីត្រូវបានដឹកយកទៅជាបន្តបន្ទាប់តាមក្រោយ ហើយស្រុកទាំងឡាយនៅក្នុងភូមិភាគពាយ័ព្យត្រូវបានកម្មាភិបាលខ្មែរក្រហមទាំងនេះបោសសម្អាត និងផ្លាស់អ្នកដឹកនាំ«ដែលគ្មានភក្ដីភាព»ចេញ ។ នៅតាមស្រុកខ្លះ កម្មាភិបាលរៀបចំឲ្យមានការហូបបាយរួម ដាក់ការងារយ៉ាងធ្ងន់ឲ្យប្រជាជនធ្វើនៅតាមជនបទ ។ ការបោសសម្អាតនិងនយោបាយឃោរឃៅរបស់អ្នកមកដល់ថ្មីបណ្ដាលឲ្យជនភៀសខ្លួនរាប់រយនាក់នាំមកនិយាយប្រាប់អ្នកកាសែតនិងអ្នកការទូតនៅក្នុងប្រទេសថៃ ។[៨១]

ពេញមួយឆ្នាំ១៩៧៧ ទំនាក់ទំនងរវាងកម្ពុជាប្រជាធិបតេយ្យនិងវៀតណាមបានធ្លាក់ចុះ ដោយសារតែវៀតណាមបដិសេធមិនព្រមចរចាអំពីបញ្ហាព្រំដែនទៅតាមលក្ខខណ្ឌរបស់កម្ពុជាប្រជាធិបតេយ្យ ។ កម្ពុជាប្រជាធិបតេយ្យបានបង្កើនការគាបសង្កត់ទៅលើប្រទេសវៀតណាមតាមរយៈការផ្សព្វផ្សាយតាមរលកធាតុអាកាសឃោសនាប្រឆាំងនឹងវៀតណាមនិងការវាយលុកតាមព្រំដែន ។ នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៧ ឯកអគ្គរដ្ឋទូតវៀតណាមប្រចាំនៅកម្ពុជាប្រជាធិបតេយ្យឈ្មោះ ផាន់ វ៉ាន់បា បាននិយាយជាមួយ

ប៉ុល ពត ដោយលើកយកបញ្ហាទាក់ទងនឹងការអះអាងដែលថារបបកម្ពុជាប្រជាធិបតេយ្យចង់ «វាយយកវិញ» នូវទឹកដីនៅភាគខាងត្បូងប្រទេសវៀតណាមដែលប្រជាជនកម្ពុជាហៅថា «កម្ពុជាក្រោម» ។ ប៉ុល ពត បានឆ្លើយតបទៅវិញថា «នេះមិនមែនជាគោលបំណងពិតប្រាកដរបស់យើងទេ ។ បញ្ហាគឺថាយើងមានខ្មាំងនៅក្នុងជួរយើង» ។ ការឆ្លើយតបរបស់ ប៉ុល ពត ជាការជំទាស់ទៅនឹងការវិភាគមួយដែលថាតើ«ខ្មាំងនៅក្នុងជួរយើង»ជាមនុស្សដែលចង់វាយវៀតណាម ឬជាមនុស្សដែលធ្វើឲ្យ ប៉ុល ពត វាយប្រហារវៀតណាម? ហើយតើធ្វើម៉េចទើបវៀតណាមនឹងអាចកំណត់បានអំពីបំណងពិតប្រាកដរបស់កម្ពុជា?[៨២]

## សង្គ្រាមជាមួយវៀតណាម

នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៧ នៅក្នុងសុន្ទរកថាមួយផ្សាយតាមរលកធាតុអាកាសវិទ្យុជាតិកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត បានប្រកាសនិងរំឭកដល់តួនាទីរបស់បក្សកុម្មុយនិស្តកម្ពុជានៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ។ ការសម្រេចចិត្តរបស់ ប៉ុល ពត ក្នុងការបើកចំហមុខបក្សកុម្មុយនិស្តកម្ពុជា ប្រហែលជាមានការបង្ខំពីប្រទេសចិន ដែលហៀបនឹងមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ។ សុន្ទរកថារបស់ ប៉ុល ពត ត្រូវបានផ្សាយតាមរលកវិទ្យុថ្ងៃទី៣០ ខែកញ្ញា ជួនពេលនឹងបុណ្យរំឭកខួបលើកទី១៧នៃការបង្កើតបក្សដែរ ។ នៅពេលនោះ ប៉ុល ពត បានទៅដល់ទីក្រុងប៉េកាំងរួចទៅហើយ ។ នៅក្នុងការថ្លែងសុន្ទរកថានោះ ប៉ុល ពត បាននិយាយដល់ «ពួកប្រតិកិរិយាមួយក្តាប់តូច» ដែលកំពុងតែបង្កប់ខ្លួននៅក្នុងកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែមិនបានរៀបរាប់ឈ្មោះនិងមិនបានកត់សម្គាល់ដោយមានលក្ខណៈសុទិដ្ឋិនិយមសមតាមឱកាសនោះឡើយ ។ ស្របពេលនោះដែរ កម្លាំងប្រដាប់អាវុធនៅភូមិភាគបូព៌ាបានចាប់ផ្តើមការវាយប្រហារស្ទាត់ៗទៅលើប្រទេសវៀតណាម ។[៨៣]

នៅចុងខែតុលា ពោលគឺមួយរយៈខ្លីក្រោយពីការវិលត្រឡប់របស់ ប៉ុល ពត មកពីប្រទេសចិនវិញ កងទ័ពវៀតណាមបានវាយប្រហារយ៉ាងធ្ងន់ធ្ងរមកលើប្រទេសកម្ពុជា ។ កងទ័ពវៀតណាមស្ថិតនៅក្នុងទឹកដីកម្ពុជា ម្តុំខេត្តស្វាយរៀងរហូតដល់ដំណាច់ឆ្នាំ ហើយវៀតណាមបានកេណ្ឌអ្នកទោសរាប់រយនាក់ (មួយចំនួនធំប្រហែលជាអ្នកដែលរត់ចេញពីប្រទេសកម្ពុជា) ទៅក្នុងប្រទេសវៀតណាម នៅពេលដែលប្រតិបត្តិការរបស់ខ្លួនត្រូវបានបញ្ចប់ ។ ប្រទេសទាំងពីរមិនបានផ្សព្វផ្សាយជាសាធារណៈអំពីជម្លោះនេះឡើយ ប៉ុន្តែមុនពេលដែលកងទ័ពវៀតណាមដកចេញពីកម្ពុជានៅដើមខែមករា ឆ្នាំ១៩៧៨ភ្លាម កម្ពុជាប្រជាធិបតេយ្យក៏បានកាត់ផ្តាច់ទំនាក់ទំនងការទូតជាមួយនឹងទីក្រុងហាណូយ ។ បន្តិចក្រោយមក មជ្ឈិមបក្សក៏បានប្រកាសជ័យជម្នះជាផ្លូវការរបស់ខ្លួន ។ ប៉ុល ពត បានចុះទៅដល់មន្ទីររបស់ សោ ភឹម នៅឃុំសួង ដើម្បីប្រារព្ធពិធីនេះ ។ ប៉ុល ពត បានអំពាវនាវអ្នកចូលរួមស្តាប់ទាំងអស់ឲ្យធ្វើសង្គ្រាមតាមគ្រប់មធ្យោបាយប្រឆាំងនឹងវៀតណាម ដោយរំឭកឡើងវិញនូវឯកសារបក្សទំនាស់មួយមានចំណងជើងថា «មតិបំភ្លឺរបស់៨៧០» ដែលចេញផ្សាយនៅក្នុងខែនោះ ។ ឯកសារនេះបានប្រៀបធៀបកងទ័ពវៀតណាមទៅនឹង «ស្វាដែលស្រែកចេចចាចនៅក្នុងព្រៃ» ហើយបានសង្កត់ធ្ងន់ថា ប្រសិនបើយុទ្ធជនខ្មែរម្នាក់អាចសម្លាប់វៀតណាមចំនួន

សាមសិបនាក់នោះ យើងនឹងឈ្នះដោយងាយ ។[៨៤] បន្ទាប់មកទៀត នៅក្នុងខែដដែលនេះដែរ ប៉ុល ពត បានលើកឡើងថា «កំហឹងជាតិនិងកំហឹងវណ្ណៈ» គឺជាអាវុធនៅក្នុងការតស៊ូ ។ នៅក្នុងសៀវភៅកំណត់ហេតុរបស់ ទុយ និង ប៊ុន ប៉ុល ពត បាននិយាយទៅកាន់អ្នកគាំទ្រខ្លួនកាលពីថ្ងៃទី១៧ ខែមករា ថា «ពេលវៃវៀតណាម បើអ្នកឯងវៃជើង វាមិនអាចវារបានទេ ។ ប្រសិនបើវៃដៃ វានៅតែអាចដើរបានដដែល» ។[៨៥] ប៉ុល ពត បានទុកឲ្យអ្នកចូលរួមស្តាប់កំណត់ថា តើជើងនៅទីណា ដៃនៅទីណា ។

គំនិតជាតិនិយមដែលផ្អែកទៅលើជាតិសាសន៍ បានក្លាយជាមូលដ្ឋាននៃការឃោសនារបស់កម្ពុជាប្រជាធិបតេយ្យ ហើយ «ខ្មាំង» ដែលយកមកដាក់នៅក្នុងមន្ទីរស-២១ នៅក្នុងឆ្នាំ១៩៧៨ ភាគច្រើនលើសលប់គឺត្រូវបានចោទប្រកាន់ថាជាអ្នកសមគំនិតជាមួយនឹងវៀតណាម ។ សុន សេន និងលេខាភូមិភាគកណ្តាល (អតីតភូមិភាគឧត្តរ) ឈ្មោះ កែ ពក ដែលត្រូវបានបញ្ជូនទៅភូមិភាគបូព៌ានៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៧ ឲ្យទៅមើលការខុសត្រូវចំពោះការប្រយុទ្ធគ្នា ត្រូវបានស្នើឲ្យស្ថិតនៅទីនោះដើម្បីរៀបចំកម្លាំងប្រដាប់អាវុធឡើងវិញ និងបោសសម្អាតអ្នកណាដែលត្រូវបានគិតថាបាន «ខុបត្តម្ភ» ដល់វៀតណាម ។ នៅត្រឹមខែកុម្ភៈ វៀតណាមបានរៀបចំផែនការសម្ងាត់ដើម្បីផ្តួលរំលំកម្ពុជាប្រជាធិបតេយ្យទាំងតាមវិធីផ្ទៃក្នុងនិងតាមវិធីប្រើកម្លាំង ។ គ្មានភស្តុតាងណាមួយបញ្ជាក់ថា មជ្ឈិមបក្សដឹងអំពីការសម្រេចចិត្តនេះឡើយ ។ ប៉ុន្តែសុបិនដ៏អាក្រក់ ពោលគឺការដែលថាវៀតណាមនឹងលេបទឹកដីកម្ពុជាបាននឹងកំពុងក្លាយទៅជាការពិត ។[៨៦]

នៅពាក់កណ្តាលឆ្នាំ១៩៧៨ «ខ្មាំង» ដែលជាមុខសញ្ញារបស់មជ្ឈិមបក្ស គឺជាមនុស្សដែលត្រូវចោទជារឿយៗថា «ក្បាលយួនខ្លួនខ្មែរ» ។ ចំណែកឯនៅមន្ទីរស-២១ វិញ អ្នកទោសចចេសរឹងរូសមួយចំនួនត្រូវបានបង្ខំឲ្យថ្វាយបង្គំរូបគំនូរដែលមានក្បាលហូជីមិញ ។[៨៧] «អ្នកក្បត់» ភាគច្រើនត្រូវបានគិតថាមកពីភូមិភាគបូព៌ា ជាកន្លែងដែលការវាយប្រហាររបស់វៀតណាមបានទទួលជោគជ័យ ហើយជាកន្លែងដែលកម្មាភិបាលជើងចាស់ រាប់ពី សោ ភឹម ចុះក្រោមមានប្រវត្តិទាក់ទងជាមួយនឹងវៀតណាមចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៥០មក ។[៨៨]

សោ ភឹម ជាមនុស្សមានប្រជាប្រិយមួយរូបនៅក្នុងភូមិភាគនេះ ។ គាត់ក្លាយជាជនកុម្មុយនិស្តចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៥០មកម្ល៉េះ ។ ទោះបីជាមានការងាយស្រួលជាមួយនឹងលទ្ធិម៉ាក្ស-ឡេនីនដែលគាត់បានយល់យ៉ាងច្បាស់ក៏ដោយ ក៏ សោ ភឹម នៅដឹអក់មិនដាក់ឲ្យអនុវត្តនូវចំណុចផ្សេងៗដែលមាននៅក្នុងនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជាដែរ ដូចជាការហូបបាយរួមនៅក្នុងតំបន់នេះជាដើម ។

នៅតាមតំបន់មួយចំនួន សោ ភឹម បានអនុញ្ញាតឲ្យប្រជាជនស្លៀកពាក់ខោអាវរបស់ខ្លួន ប្រើប្រាស់ខោអាវសេរី គឺមិនមែនខោអាវឯកសណ្ឋានជាកសិករឡើយ ។ នៅក្នុងខែធ្នូ ឆ្នាំ១៩៧៨ ពោលគឺក្រោយពីការធ្វើអត្តឃាតរបស់ សោ ភឹម ជាច្រើនខែមក ឧបនាយករដ្ឋមន្ត្រី សុក ធួក (ហៅ វ៉ន វ៉េត) បានសារភាពថាបាននិយាយទាក់ទងគ្នាជាមួយ សោ ភឹម នៅក្នុងឆ្នាំ១៩៧៧ ជាពេលដែលអ្នកទាំងពីរត្រូវបានចោទប្រកាន់ថាជាសមាជិកបក្សពលករកម្ពុជាប្រឆាំងនឹងបក្សកុម្មុយនិស្ត÷

គាត់បានប្រាប់ខ្ញុំអំពីសភាពការណ៍ល្អនៅភូមិភាគបូព៌ា ។ បក្សពលករកម្ពុជាបានកសាងខ្លួនឯងនៅតាមជួរកងទ័ពនិងប្រជាជន ។ សហករណ៍ត្រូវបានបង្កើតរួចហើយ ប៉ុន្តែការប្រមូលផលមានលក្ខណៈរគាត់រគាយ ហើយមានការរស់នៅជាឯកជនតាមការទាមទាររបស់ប្រជាជនដែលមិនចង់ហូបរួម ពីព្រោះធ្វើដូច្នេះគឺមានការខ្ជះខ្ជាយសព្វបែបយ៉ាង ។ ប្រសិនបើប្រជាជន...រស់នៅជាលក្ខណៈឯកជន ដូចជានៅប្រទេសចិន ប្រជាជនច្បាស់ជាមានការសប្បាយចិត្តខ្លាំងណាស់ ។[៨៩]

វ៉ន វេត បន្តទៀតថា «គំនិតចង់ដើរតាមគំរូសង្គមនិយមរបស់ចិនត្រូវបានផ្សព្វផ្សាយក្នុងចំណោមប្រជាជន...ជាពិសេសនៅក្នុងភូមិភាគបូព៌ា ភូមិភាគពាយ័ព្យ និង ភូមិភាគនិរតី ។ យុទ្ធនាការឃោសនាត្រូវបានចាប់ផ្តើមនៅចុងឆ្នាំ១៩៧៧ ពោលគឺជាពេលដែលជនជាតិកម្ពុជាបានចាប់ផ្តើមឲ្យអាទិភាពទៅលើការកសាងសង្គមនិយម» ។

រវាងខែមីនា និងខែឧសភា ឆ្នាំ១៩៧៨ នៅពេលដែលការវាយប្រហាររប៉េះរប៉ោះប្រឆាំងនឹងវៀត-ណាមនៅមិនទាន់ចប់នៅឡើយនោះ មជ្ឈិមបក្សក៏បន្តការបោសសម្អាតនៅក្នុងភូមិភាគបូព៌ាទៀត ។ សោ ភឹម ហាក់ដូចជាដឹងអ្វីដែលកំពុងកើតឡើង ប៉ុន្តែមិនអាចបង្កើនអំណាចឬប្រមូលកម្លាំងដើម្បីតស៊ូប្រឆាំងឡើយ ។[៩០]

នៅក្នុងខែមីនា សោ ភឹម មានជំងឺក្រពះនិងរមាស់ ។ ដោយដឹងថា ខ្លួនជាមុខសញ្ញារបស់មជ្ឈិមបក្ស សោ ភឹម បានចំណាយពេលមួយចំនួនដើម្បីដើរក្រឡឹងមើលនៅពេទ្យ១៧មេសាស្ថិតនៅក្នុងទីក្រុងភ្នំពេញ មុនពេលជិះរថភ្លើងទៅភូមិភាគពាយ័ព្យជាមួយនឹងលេខាតំបន់ឈ្មោះ រស់ ញឹម ។

នៅថ្ងៃទី២៥ ខែមីនា ក្នុងខណៈដែល សោ ភឹម កំពុងតែសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យ ឬប្រហែលជាចុះពិនិត្យមើលភូមិភាគពាយ័ព្យ លេខាតំបន់បស្ចិមឈ្មោះ ជូ ជេត ហៅ ស៊ី ត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរ ស-២១ ។ នៅក្នុងចំណោម រស់ ញឹម និង សោ ភឹម, ជូ ជេត គឺជាអ្នកមុខអ្នកការចាប់តាំងពីមុនសម័យបដិវត្តន៍របស់ ប៉ុល ពត មកម្ល៉េះ ។ អ្នកធ្វើការជាមួយ ជូ ជេត នៅក្នុងជួរបក្សកុម្មុយនិស្តកម្ពុជាតាំងពីពេលនោះមកដូចដែលយើងឃើញស្រាប់ ត្រូវបានបោសសម្អាតនៅក្នុងឆ្នាំ១៩៧៦ ។ ជូ ជេត ហាក់ដូចជាអ្នកបដិវត្តដែលមានភក្តីភាពមិនចង់ទទួលយកនូវការឃោសនារបស់របបនេះ ហើយមានការព្រួយបារម្ភចំពោះសុខទុក្ខរបស់ប្រជាជន ។ ប្រពន្ធរបស់ ជេត ឈ្មោះ អ៊ឹម ណន បានកាន់មុខតំណែងដ៏សំខាន់ពោលគឺ ជាលេខាបក្សតំបន់៣២នៅភូមិភាគឧត្តរ ។ ទាំងពីរនាក់ប្តីប្រពន្ធត្រូវបានចាប់ខ្លួនក្នុងពេលជាមួយគ្នា ។ នៅក្នុងចម្លើយសារភាពរបស់ខ្លួន ណន និយាយថា ជាអ្នកដាំបាយឲ្យ ប៉ុល ពត នៅក្នុងមន្ទីរ១០០ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ហើយបានព្យាយាមជាច្រើនលើកក្នុងការបំពុល ប៉ុល ពត ប៉ុន្តែមិនបានសម្រេច ។[៩១]

ពេលនោះមជ្ឈិមបក្សក៏បានចេញបញ្ជាឲ្យធ្វើការបោសសម្អាតជាទ្រង់ទ្រាយធំនូវកម្មាភិបាលនៅភូមិភាគបូព៌ា នៅក្នុងខែមេសា ឆ្នាំ១៩៧៨ ហើយមានកម្មាភិបាលជាច្រើននាក់ត្រូវបានចាប់បញ្ជូនមកមន្ទីរ ស-២១ ។ បើតាមការស្មាន អ្នកទោសទាំងអស់ត្រូវសម្លាប់ដោយមិនមានការសួរចម្លើយអ្វីទាំងអស់ ។[៩២] ការបោសសម្អាតត្រូវបានធ្វើឡើងដោយសមាជិកជាន់ខ្ពស់របស់បក្សកុម្មុយនិស្តកម្ពុជា ដឹកនាំដោយ ស៊ុន

សេន និងគាំទ្រដោយកងកម្លាំងពោរពេញទៅដោយភក្ដីភាពដែលពង្រាយពីភូមិភាគនិរតីនិងភូមិភាគកណ្ដាល ក្រោមការគ្រប់គ្រងរបស់ កែ ពក ។

នៅពាក់កណ្ដាលខែឧសភា ឆ្នាំ១៩៧៨ កែ ពក បានហៅកម្មាភិបាលជាន់ខ្ពស់នៅភូមិភាគបូព៌ា រាប់ពី សោ ភឹម ចុះមកក្រោមរហូតដល់ថ្នាក់វរសេនាតូចមកប្រជុំនៅមន្ទីររបស់ សោ ភឹម នៅឃុំសួង ដែលកាន់កាប់ដោយ កែ ពក និងមានការពង្រីកមូលដ្ឋានទ័ពដោយមានរថក្រោះនិងកងទ័ពថ្មើរជើងមកពីភូមិភាគផ្សេងៗផង ។ ដោយដឹងថានេះជាការដាក់អន្ទាក់ សោ ភឹម បានបដិសេធមិនព្រមទៅចូលរួមប្រជុំឡើយ ។ អ្នកដែលទៅចូលរួមប្រជុំទាំងប៉ុន្មានត្រូវបានចាប់ខ្លួនទាំងអស់ ហើយមានអ្នកខ្លះត្រូវសម្លាប់នៅនឹងកន្លែងតែម្ដង ។ មេបញ្ជាការកងពលធំនិងលេខាតំបន់២០, ២១ និង ២២ ត្រូវបានប្រមូលបញ្ជូនមកមន្ទីរស-២១ ។ ប៉ុន្មានថ្ងៃក្រោយមក កែ ពក បានបញ្ជូនសំបុត្រកោះហៅ សោ ភឹម មកប្រជុំ ។ កូនចៅដែល សោ ភឹម បញ្ជូនឲ្យទៅសួរបញ្ជាក់ពីគោលបំណងពិតប្រាកដរបស់ កែ ពក ត្រូវបានចាប់ខ្លួនម្ដងមួយៗ ។ នៅពេលមិនឃើញកូនចៅរបស់ខ្លួនត្រឡប់មកវិញ សោ ភឹម ក៏ចាប់ផ្ដើមសង្ស័យ ។ ដោយមិនអាចឬមិនចង់ជឿថា ប៉ុល ពត ស្ថិតនៅក្រោយការវាយប្រហារទាំងនេះ សោ ភឹម គិតថា សុន សេន និង កែ ពក ជាអ្នកក្បត់ ។

នៅថ្ងៃទី២៥ ខែឧសភា កែ ពក បានធ្វើការវាយប្រហារពីឃុំសួងទៅលើអគ្គភាពភូមិភាគបូព៌ាដែលប្រឆាំងជំទាស់នឹងខ្លួន ។ កែ ពក ត្រូវបានវាយតបតមកវិញ ហើយក្រោយមកបានហៅថាជាការបះបោរប្រឆាំងនឹងការកាន់កាប់អំណាចរបស់កម្ពុជាប្រជាធិបតេយ្យ ។ នៅថ្ងៃទី៣១ ខែឧសភា សោ ភឹម ក៏សម្រេចចិត្តមកជួប ប៉ុល ពត នៅភ្នំពេញដើម្បីប្រាប់ពីបុព្វហេតុរបស់ខ្លួន ។ នៅពេលមកដល់ជ្រោយចង្វារដែលនៅទល់មុខនឹងទីក្រុងភ្នំពេញ និងបានបញ្ជូនដំណឹងឲ្យដឹងអំពីការមកដល់របស់គាត់ មានកងកម្លាំងជាច្រើនត្រូវបានបញ្ជូនតាមកាណូតមកពីភ្នំពេញដើម្បីរកចាប់ខ្លួន សោ ភឹម ។ ពេលនោះ សោ ភឹម ក៏រត់គេចខ្លួនតាមរថយន្តម៉ាកហ្សីប មួយគ្រឿងរួចចូលលាក់ខ្លួននៅក្នុងវត្តមួយ ។ នៅពេលទន្ទឹមគ្នានេះដែរ ខ្មាំងក្រុមទាហានបក្សជាច្រើនដែលបញ្ជូនមកពីទីក្រុងភ្នំពេញបានទម្លាក់ខិត្តប័ណ្ណនៅទូទាំងភូមិភាគ ដោយហៅ សោ ភឹម ថាជាជនក្បត់ ហើយឲ្យយុទ្ធជនទាំងអស់ទម្លាក់អាវុធចុះ ។ បីថ្ងៃក្រោយមក នៅពេលដែលកង៣០០ដែលត្រូវបានជ្រើសរើសតាមមូលដ្ឋាន ហៀបនឹងមកចាប់គាត់ សោ ភឹម ក៏បានបាញ់សម្លាប់ខ្លួនឯង ។[៩៣]

ការប្រយុទ្ធគ្នារវាងកងកម្លាំងប្រដាប់អាវុធរដ្ឋាភិបាល និងអគ្គភាពភូមិភាគបូព៌ាចេះតែបន្តទៅអស់ជាច្រើនសប្ដាហ៍ ហើយនៅពេលនោះកម្មាភិបាលភូមិភាគបូព៌ាជាច្រើននាក់រួមទាំងមេបញ្ជាការកងពល ហេង សំរិន (ដែលក្រោយមកក្លាយជាគណៈប្រធានរដ្ឋ) បានរត់ទៅជ្រកកោននៅក្នុងប្រទេសវៀតណាម ដែលនៅទីនោះ កម្មាភិបាលទាំងអស់នោះបានរួមគ្នាកសាងជាកម្លាំងទ័ពមកវាយលុកចូលប្រទេសកម្ពុជាវិញ ។ នៅខែមិថុនា និង ខែកក្កដា នៅក្នុងអ្វីដែលលោក ស៊ីវ ហេដឌ័រ បានហៅថា "ការបោសសម្អាតដោយមិនរើសមុខនៅក្នុងជួរបក្សកងទ័ពនិងប្រជាជនធម្មតា" កងកម្លាំងប្រដាប់អាវុធដែលគាំទ្ររដ្ឋាភិបាលបានសម្លាប់រង្គាលមនុស្សរាប់ពាន់នាក់នៅក្នុងភូមិភាគបូព៌ា ។ នៅក្នុងការផ្ទុះឡើងនូវអំពើឃោរឃៅជាទ្រង់ទ្រាយធំនិងជាលក្ខណៈប្រព័ន្ធដែលឧបត្ថម្ភគាំទ្រដោយរដ្ឋាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ កងកម្លាំងប្រដាប់អាវុធ

បានសម្លាប់ប្រជាជនទាំងគ្រួសារៗ ដែលត្រូវសង្ស័យថាជាអ្នកលាក់បាំងនិងផ្តល់ជម្រកដល់«ពួកក្បត់» ។ កងកម្លាំងរដ្ឋាភិបាលបានជម្លៀសជនស៊ីវិលរាប់ម៉ឺននាក់ពីភូមិភាគបូព៌ា ហើយប្រាប់ប្រជាជនថានឹងរកកន្លែងថ្មីឲ្យនៅ ។ ប្រជាជនភាគច្រើនត្រូវបានសម្លាប់នៅតាមផ្លូវខ្លះនិងនៅពេលទៅដល់ខ្លះ ភូមិភាគនិរតីជាភូមិភាគដែលបញ្ជូនកម្មាភិបាលមកធ្វើការបោសសម្អាតភូមិភាគបូព៌ាយ៉ាងច្រើនលើសលប់ ។ មានអ្នកខ្លះមកតាំងទីលំនៅនៅភូមិភាគពាយ័ព្យ ។ ខែកញ្ញា ឆ្នាំ១៩៧៨ ភូមិភាគបូព៌ាត្រូវបាន «បោសសម្អាត» ។[៩៤]

## ការបោសសម្អាតចុងក្រោយបង្អស់

ខែចុងក្រោយរបស់កម្ពុជាប្រជាធិបតេយ្យ គឺនៅពេលដែលមានការប៉ុនប៉ងពោរពេញដោយក្តីអស់សង្ឃឹមពីសំណាក់របបនេះក្នុងការស្វែងរកការគាំទ្រផ្នែកយោធាពីប្រទេសចិន និងបង្វែកផ្នែកនយោបាយពីប្រទេសមិនមែនកុម្មុយនិស្តនានា នៅក្នុងខណៈដែលរបបនេះកាត់បន្ថយទិដ្ឋភាពឃោរឃៅរបស់ខ្លួន ។ ការបោសសម្អាតចេះតែបន្ត ប៉ុន្តែមិនសូវជាខ្លាំងក្លាប៉ុន្មានទេ ។ នៅក្នុងដំណើរការបោសសម្អាតនេះ កន្លងមក មុខសញ្ញាដែលត្រូវបោសសម្អាតគឺបុគ្គលដែលមិនគួរឲ្យទុកចិត្ត ។ អ្នកទោសត្រូវបានយកមកដាក់មន្ទីរស-២១ ដោយចាប់មកពីផ្លូវរថភ្លើង រោងចក្រនិងសូម្បីតែអ្នកមកពីភូមិភាគនិរតីដែលមានភក្តីភាពក៏ចាប់ដែរ ។ ភូមិភាគនិរតីជាកន្លែងរបស់ «បញ្ញវន្ត» ឈ្មោះ តាម៉ុក ដែលមានការផ្តោតយ៉ាងហ្មត់ចត់និងស្អប់ជនបរទេសធ្វើជាមេបញ្ជាការអស់រយៈពេលជាច្រើនឆ្នាំ ។ មកដល់ឆ្នាំ១៩៧៨ កម្មកររោងចក្រត្រូវបានចាប់បញ្ជូនមកមន្ទីរស-២១ ជាមួយនឹងឈ្លើយសឹកវៀតណាមជាច្រើនរយនាក់ ។ វ៉ន វ៉េត ដែលជាឧបនាយករដ្ឋមន្ត្រីនិងជាអ្នកធ្វើការជាមួយនឹង តាម៉ុក យូរណាស់មកហើយ និង ចេង អន ដែលជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកផ្នែកឧស្សាហកម្មក៏ត្រូវបានបោសសម្អាតដែរ គឺនៅក្នុងខែវិច្ឆិកា ដោយត្រូវបានចោទប្រកាន់ពីបទរៀបចំគម្រោងផែនការក្បត់ធ្វើរដ្ឋប្រហារ និងប្រមែប្រមូលកម្មកររោងចក្រដែលជាអតីតយុទ្ធជន ។ ក្រុមយុវជនក្មេងៗដែលមានការរៀបចំត្រឹមត្រូវ ឥឡូវក្លាយទៅជាសំបុកជនក្បត់យ៉ាងធំ ។

នៅខែធ្នូ ការសង្ស័យបានធ្លាក់មកលើ សុន សេន ដែលត្រូវឲ្យធ្វើជាលេខាភូមិភាគបូព៌ាបន្ថែមពីលើការកិច្ចមួយចំនួនទៀតក្រោយពី សោ ភឹម ធ្វើអត្តឃាត ។ សុន សេន ប្រហែលជាត្រួតពិនិត្យគ្រប់គ្រងប្រតិបត្តិការនៅមន្ទីរស-២១ មិនសូវបានម៉ាំទាំនិងជិតដល់ដូចសព្វមួយដងទេ ដោយសារតែការទទួលខុសត្រូវថ្មីៗទាំងនេះព្រមទាំងទទួលបន្ទុកវាយជាមួយវៀតណាមផង ។ សុន សេន ធ្លាប់បានធ្វើការយ៉ាងជិតដិតជាមួយនឹង វ៉ន វ៉េត តាំងពីមានសង្គ្រាមស៊ីវិលមកម្ល៉េះ ហើយភ័ស្តុតាងរាយប៉ាយនានាបានបង្ហាញថា អ្នកទាំងពីរនេះអាចនឹងកំពុងគិតធ្វើរដ្ឋប្រហារការពារខ្លួនឯងប្រឆាំងនឹងមជ្ឈិមបក្សទៀតផង ។ ការឈ្លានពានរបស់វៀតណាមនិងការដួលរលំនៃកម្ពុជាប្រជាធិបតេយ្យប្រហែលជាបានជួយសង្គ្រោះជីវិតសុន សេន ។[៩៥]

បើគ្មានអន្តរាគមន៍បែកពីធម្មតារបៀបនេះទេ ម្ល៉េះគ្មានយន្តការណាមួយនៅមន្ទីរស-២១ ឬនៅក្នុងមជ្ឈិមបក្សអាចបញ្ឈប់ឬរារាំងដំណើរការ «បោសសម្អាត» ឡើយ ។ រាល់បទបញ្ជាឲ្យធ្វើរបៀបនេះ គឺសុទ្ធតែ

ចេញមកពី «បងថ្នាក់លើ» ទាំងអស់ ។ មកដល់ប៉ុន្មានខែចុងក្រោយនៃឆ្នាំ១៩៧៨ គ្មានឃើញបទបញ្ជាធ្លាក់ចុះមកទៀតទេ ។ នៅពេលដែលអ្នកទោសជាមុខសញ្ញាទូទៅកាន់តែមានចំនួនថយចុះ មនុស្សដែលជាមុខសញ្ញាបន្ទាប់គឺកម្មាភិបាលជាន់ខ្ពស់ ។ នៅពេលស្ថានការណ៍នៅទូទាំងប្រទេសកាន់តែដុនដាបទៅៗ ការសង្ស័យបានកើតមានកាន់តែខ្លាំងនៅក្នុងជួរថ្នាក់លើរបស់បក្ស ហើយនៅពេលដែលការវាយប្រហារជាមួយវៀតណាមមានលទ្ធផលមិនល្អ គឺត្រូវតែមានអ្នកទទួលថ្មបាក់ជាពុំខាន ។ ជាក់ស្តែងនៅពេលមនុស្សថ្នាក់ក្រោមនៃបក្សកុម្មុយនិស្តកម្ពុជាត្រូវបានកម្ចាត់ចោល ការសង្ស័យមកលើឥស្សរជនជាន់ខ្ពស់ចេះតែកើនជាលំដាប់ ។ សូម្បីតែ តាម៉ុក និងកម្មាភិបាលមកពីភូមិភាគនិរតីស្ថិតនៅក្រោមបញ្ជារបស់ តាម៉ុក ក៏ស្ថិតនៅក្រោមការតាមដានដែរនៅក្នុងអំឡុងសប្តាហ៍ចុងក្រោយនៃការបញ្ចប់របបនេះ ។ តើអ្នកណានឹងចូលខ្លួនមកទៀត? តើការធ្វើទុក្ខបុកម្នេញនឹងត្រូវបញ្ចប់នៅកន្លែងណា? ការបោសសម្អាតទាំងអស់បង្កើតបានជាគំនិតមួយគួរឲ្យញាក់សាច់ៈ តើធ្វើយ៉ាងដូចម្តេចទើបអាចដឹងឲ្យប្រាកដថា ខ្មាំងលាក់មុខត្រូវបានរកឃើញនោះ? បក្សកុម្មុយនិស្តដែលមានទ្រង់ទ្រាយធំ មានបទពិសោធន៍ច្រើននិងមានការទុកចិត្តលើខ្លួនឯងថា អាចមានលទ្ធភាពចាត់ចែងការបោសសម្អាតនៅពេលដែលការបោសសម្អាតនេះពិបាកគ្រប់គ្រង ។ កិច្ចខិតខំប្រឹងប្រែងដែលមានការយឺតយ៉ាវទាក់ទងនឹងបញ្ហានេះត្រូវបានធ្វើឡើងនៅប៉ុន្មានខែចុងក្រោយក្នុងឆ្នាំ១៩៧៨ នៅពេលដែលចំនួនអ្នកទោសដែលត្រូវនាំចូលមកមន្ទីរស-២១ធ្លាក់ចុះយ៉ាងខ្លាំង ។ ក៏ប៉ុន្តែ មជ្ឈិមបក្សនៅតែមានអារម្មណ៍ថាមានខ្មាំងនៅជុំវិញខ្លួន ។ មានភស្តុតាងគ្រប់គ្រាន់មកពីមន្ទីរស-២១បញ្ជាក់ករណីនេះៈ បេសកកម្មរបស់សន្តិបាល គឺបញ្ជាក់ច្បាស់លាស់អំពីការសង្ស័យដ៏អាក្រក់បំផុតរបស់មជ្ឈិមបក្ស ។ ក្រោយពីការលុកលុយរបស់វៀតណាមនៅក្នុងអំឡុងឆ្នាំ១៩៧៧-៧៨ និងការបោសសម្អាតនៅក្នុងភូមិភាគបូព៌ា មជ្ឈិមបក្សត្រូវបានរំខានដោយសារការភ័យខ្លាច និងការប្រញាប់ប្រញាល់ខ្លាចយឺតពេល ។

របបដែលពោរពេញទៅដោយភេរវកម្មនិងបដិវត្តន៍មិនចេះចប់ (នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ) ត្រូវការខ្មាំងមកធ្វើជាចំណីជាបន្តបន្ទាប់ ។ នៅពេលដែលខ្មាំងទាំងនេះបង្កប់ជាក្រុមតូចមួយនៅក្នុងបក្សនយោបាយដែលគ្មានបទពិសោធន៍ និងមិនអាចចែកដាច់ពីប្រជាជនភាគច្រើននៃប្រជាជនទាំងអស់ក្នុងការប៉ុនប៉ងបោសសម្អាតខ្មាំងទាំងអស់របស់ខ្លួនអាចជះឥទ្ធិពលប្រកបដោយគ្រោះថ្នាក់ ។ ដូចជា ឌុច និងបក្ខពួកដែលធ្វើអ្វីតាមការបញ្ជាអ៊ីចឹងដែរ ពោលគឺអ្នកទាំងនេះបានធ្វើឲ្យអន្តរាយដល់ប្រសិទ្ធភាពផ្នែកកងទ័ពរបស់កម្ពុជា រំសាយរចនាសម្ព័ន្ធរដ្ឋបាលរបស់ប្រទេសនិងកម្ទេចបក្ស ។ ក្បាលម៉ាស៊ីនដែលត្រូវសម្លាប់នៅមន្ទីរស-២១ បានប្រព្រឹត្តទៅឥតឈប់ឈរដោយសារការសង្ស័យ និងមិនទុកចិត្តគ្មានព្រំដែនរបស់មជ្ឈិម-បក្ស ។ ការកែទម្រង់ស្មាក់ស្មើរ ត្រូវបានធ្វើឡើងនៅឆ្នាំ១៩៧៨ ដែលជាការលើកលែងទោសប្រកាសដោយ ប៉ុល ពត និងការកាត់បន្ថយការធ្វើទារុណកម្មនៅមន្ទីរស-២១ ។[៩៦] ឥស្សរជនជាន់ខ្ពស់បំផុតរបស់បដិវត្តន៍ត្រូវបានចាប់ខ្លួននៅពេលដែលបក្សត្រូវការកម្មាភិបាលដែលមានបទពិសោធន៍ ដើម្បីបង្កើតជារណសិរ្សរួបរួមជាតិមួយក្នុងជម្លោះជាមួយនឹងវៀតណាម ។ នៅចុងឆ្នាំ១៩៧៨ ថ្នាក់ដឹកនាំរបស់បក្សនៅតាមភូមិភាគភាគច្រើនបានដួលរលំហើយ តាម៉ុក ក៏កាន់មុខតំណែងបញ្ជាការនៅក្នុងភូមិភាគជាច្រើន

ក្នុងពេលតែមួយ ។

នៅពេលដែលវៀតណាមធ្វើការវាយលុកចូលមកនៅចុងខែធ្នូ ឆ្នាំ១៩៧៨ គណៈកម្មាធិការមជ្ឈិមបក្សនៃបក្សកុម្មុយនិស្តកម្ពុជាត្រូវបានកម្ចាត់ ។ លើកលែងតែ តាម៉ុក មួយចេញ ក្រៅពីនោះលេខាភូមិភាគដែលធ្វើការតាំងពីមុនមក ព្រមទាំងអ្នកដែលមកជំនួសភាគច្រើនត្រូវបានបោសសម្អាតទាំងអស់ ហើយចំពោះអ្នកគ្រប់គ្រងស្ទើរតែគ្រប់រោងចក្រ និងមន្ទីរពេទ្យរដ្ឋព្រមទាំងកម្មាភិបាលយោធារាប់រយនាក់ទៀតក៏ទទួលវាសនាដូចគ្នានេះដែរ ។ នៅចុងឆ្នាំ១៩៧៨ គ្មានបុគ្គលមានបទពិសោធន៍គ្រប់គ្រាន់សម្រាប់ដឹកនាំប្រទេសទេ ហើយក៏គ្មានមេដឹកនាំកងទ័ពសម្រាប់រៀបចំឲ្យមានប្រព័ន្ធការពារមាំទាំដែរ ។ នៅឆ្នាំ១៩៩៧ មុី ម៉ាន់ ដែលធ្លាប់ធ្វើជាជនកុម្មុយនិស្ត បានរំឭកអំពីរបបនោះប្រាប់លោក ស្ទីវ ហេដឌ័រ ថា "ម្នាក់ៗគិតតែពីចោទគ្នាទៅវិញទៅមកថា អ្នកនេះក្បត់ អ្នកនោះក្បត់ ហើយគ្មានអ្នកណាម្នាក់ដឹងថាមានអ្វីកើតឡើងពិតប្រាកដឡើយ" ។[៩៨]

នៅក្នុងខែកក្កដា ឆ្នាំ១៩៩៧ នៅពេលដែល ប៉ុល ពត ត្រូវបានកាត់ទោសនៅឯមូលដ្ឋានអន្លង់វែង (ដែលជាការគួរឲ្យអស់សំណើចចំពោះទោសឧក្រិដ្ឋរបស់ ប៉ុល ពត គឺការបញ្ជាឲ្យសម្លាប់ សុន សេន) មានអ្នកចោទប្រកាន់ម្នាក់ក្នុងចំណោមអ្នកចោទប្រកាន់មួយចំនួនទៀតបានស្តីបន្ទោស ប៉ុល ពត ថា បានជំរុញឲ្យមានការមិនទុកចិត្តជាទូទៅនៅក្នុងចំណោមអ្នកដើរតាមខ្លួន ។ ទោះបីជាការចោទប្រកាន់បានផ្តោតសំខាន់តែទៅលើទសវត្សរ៍ឆ្នាំ១៩៩០ក៏ដោយ ក៏ប៉ុន្តែ ការប្រើពាក្យច្បាស់ៗតាមរយៈការយល់ឃើញក្រោយពីមានហេតុការណ៍កើតឡើង បានបង្ហាញចេញនូវឥទ្ធិពលប្រកបដោយហាយនភាពមួយចំនួននៅក្នុងមន្ទីរ ស-២១ដូចតទៅនេះ÷

> ប៉ុល ពត យល់ថា ខ្មាំងសត្រូវគឺជាសាច់ស្អុយរលួយ ជាសាច់ហើមប៉ោង ។ សត្រូវនៅជុំវិញ ។ សត្រូវនៅពីមុខ សត្រូវនៅពីក្រោយ សត្រូវនៅខាងជើង សត្រូវនៅខាងត្បូង សត្រូវនៅខាងលិច សត្រូវនៅខាងកើត សត្រូវនៅគ្រប់ទិសទី សត្រូវមកពីទិសទាំងប្រាំបីប្រាំបួនទិស រុំជុំជិតគ្មានកន្លែងដកដង្ហើម ។ ប៉ុល ពត បានឲ្យយើងពង្រឹងស្មារតី ពង្រឹងគោលជំហរ ពង្រឹងហើយពង្រឹងទៀត រួមទាំងវិធានការសម្លាប់មនុស្សក្នុងជួរខ្លួនឯង...សូម្បីតែអ្នកតស៊ូនៅក្នុងជួរតែមួយនៅក្នុងចលនានេះក៏យ៉ាងដូច្នោះដែរ ។[៩៨]

នៅចន្លោះឆ្នាំ១៩៧៥ និងការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ "ខ្មាំង" រាប់សែននាក់ត្រូវបានចាប់ខ្លួន និងសម្លាប់ចោលនៅទូទាំងប្រទេស ។ យ៉ាងហោចណាស់មានមនុស្សចំនួនមួយម៉ឺនបួនពាន់នាក់ត្រូវបានឃុំខ្លួន សួរចម្លើយ ធ្វើទារុណកម្ម និង សម្លាប់ចោលដោយសន្តិបាល ។ ប្រសិនបើការវាយលុករបស់វៀតណាមត្រូវបានពន្យារពេលនោះ ម៉ូះសមដំណើរការបំផ្លិចបំផ្លាញនៅមន្ទីរស-២១ មិនអាចទាយទុកបានទេ ។ "កង់ប្រវត្តិសាស្ត្រ" ចេះតែវិលទៅមុខជាន់អ្នករាល់គ្នា ហើយមិនអាចទប់បានឡើយ ។ មិនតែប៉ុណ្ណោះអ្នកសួរចម្លើយនៅគុកទួលស្លែងដែលត្រូវបានចាប់ខ្លួននៅពេលនោះបានត្អូញត្អែរនៅក្នុងចម្លើយសារភាពរបស់ខ្លួនថា "ប្រសិនបើអង្គការគិតតែពីចាប់អ្នកណាក៏ចាប់ដូច្នេះ តើបានអ្នកណាធ្វើបដិវត្ត?" ។[៩៩]

## គុកទួលស្លែង (ស-២១)




អគារ A-D : កន្លែងឃុំឃាំងអ្នកទោសរួម      អគារ E : រដ្ឋបាល និងឯកសារ



*សារមន្ទីរឧក្រិដ្ឋកម្មប្រល័យ ពូជសាសន៍ទួលស្លែង*



*កាំង ហ្គិចអ៊ាវ ហៅឌុច*





ហ៊ឹម ហ៊ុយ



ហ៊ឹម ហ៊ុយ



កុយ ធួន






121




259


14-5-78



វាលពិឃាតបឹងជើងឯក



ញ៉ែម អេន : អ្នកថតរូបអ្នកទោសនៅគុកទួលស្លែង (ស-២១)

**ចត្តថីបួនៈ**

# ការបង្កើតសំណួរ

នៅខែមករា ឆ្នាំ១៩៧៨ ហេង ណាត ហៅ វ៉ាន់ ណាត ដែលជាវិចិត្រករអាជីពនៅខេត្តបាត់ដំបង ត្រូវចាប់ខ្លួននិងសួរចម្លើយអស់រយៈពេលជាច្រើនថ្ងៃ មុននឹងដាក់ឈ្មោះបញ្ជូនមកមន្ទីរស-២១ ។ ក្នុងឆ្នាំ ១៩៧៨ វ៉ាន់ ណាត មិនដឹងថា ហេតុអ្វីបានជាគាត់ត្រូវចាប់ខ្លួនឡើយ ។ មកទល់សព្វថ្ងៃនេះក៏គាត់នៅតែមិនទាន់ដឹងនៅឡើយ ។ និយាយទៅកាន់អ្នកស្រាវជ្រាវឈ្មោះ សារ៉ាខូម ក្នុងឆ្នាំ១៩៩៥ វ៉ាន់ ណាត បានរំឭកដល់ការសួរចម្លើយលើកទីមួយដូចតទៅ÷

អ្នកសួរចម្លើយបានសួរខ្ញុំថា «តើមានបញ្ហាអ្វីបានជាគេចាប់អ្នកឯងមក?» ។

ខ្ញុំមិនដឹងដែរ ។

«អង្គការមិនមែនមិនដឹងអីទេ ។ អង្គការមិនដែលចាប់មនុស្សដែលគ្មានកំហុសទេ ។ ឥឡូវគិតម្តងទៀត ។ តើអ្នកឯងធ្វើអ្វីខុស?»

ខ្ញុំឆ្លើយថា «ខ្ញុំមិនដឹងទេ» ។[១]

អ្នកទោសជាច្រើននាក់ផ្សេងទៀតនៅមន្ទីរស-២១ ត្រូវបានបង្ខំឲ្យពន្យល់ហេតុផលនៃការចាប់ខ្លួន និងមូលហេតុដែលធ្វើឲ្យខ្លួនមានកំហុស ។ ហ៊្វូស្ត ខេ និយាយនៅក្នុងសំណេររបស់ខ្លួនថា អ្នកទាំងនោះមិនមែនត្រូវចោទប្រកាន់ដោយសារខ្លួនមានកំហុសទេ ប៉ុន្តែមានកំហុសដោយសារការចោទប្រកាន់ ។ សំណួរគឺធ្វើឡើងដើម្បីដាក់ឲ្យអ្នកទោសស្ថិតនៅក្នុងគ្រោះថ្នាក់និងភាពមិនទីងន ប៉ុន្តែអ្នកសួរចម្លើយខ្លួនឯងជាញឹកញាប់ពិតជាចង់ដឹងមែននិងមានចិត្តស្មោះត្រង់ ។ អ្នកសួរចម្លើយជឿជាក់ថា អ្នកទោសមានកំហុស ប៉ុន្តែមិនដឹងថាបទល្មើសអ្វីដែលខ្លួនត្រូវរកឲ្យឃើញទេ ។ សំណួរទីមួយដែលលំបាកសម្រាប់អ្នកសួរចម្លើយនិងអ្នកឆ្លើយដូចរៀបរាប់ខាងលើ គឺទាក់ទងនឹងបច្ចេកទេសក្នុងការសួរចម្លើយដែលប្រើដោយមន្ត្រីនគរបាលនៅគ្រប់ទីកន្លែង ហើយសូម្បីតែរបបកុម្មុយនិស្តមួយចំនួនក៏យកវិធីសាស្ត្រនេះមកប្រើប្រាស់ដែរ ។[២] ដូចជានៅក្នុងសហភាពសូវៀតនិងប្រទេសចិនដែលប្រកាន់លទ្ធិកុម្មុយនិស្ត «ទោស» ដែលថាអ្នកទោសបានលាក់បាំងគឺកើតចេញពីគំនិតរបស់អ្នកចោទប្រកាន់តែប៉ុណ្ណោះ ។ ភារកិច្ចរបស់អ្នកសួរចម្លើយគឺធ្វើឲ្យស្របតាមសាលក្រមរបស់បក្ស ដោយដកស្រង់នូវចម្លើយសារភាពមានលក្ខណៈពេញលេញ ។ ឯកសារទាំងនេះដែលត្រូវបានរៀបចំសព្វគ្រប់ហើយបានក្លាយជាអត្ថបទប្រវត្តិសាស្ត្រដែលប្រហែលជាបង្ហាញពីទំនាក់ទំនងនៃ «គោលបំណង» របស់អ្នកទោសទៅនឹងកំហុសធ្ងន់ធ្ងរផ្សេងៗ ការយកចិត្តទុកដាក់របស់បុគ្គលិកនៅមន្ទីរស-២១ និងអ្នកប្រាជ្ញទ្រង់ញាណនៃបក្ស ។

ក្រៅពីគំរូកុម្មុយនិស្តទាំងនេះ ក៏មានបច្ចេកទេសប្រហាក់ប្រហែលគ្នាមួយចំនួនទៀតរវាងបច្ចេកទេស

ដែលប្រើប្រាស់នៅមន្ទីរស-២១ និងបច្ចេកទេសប្រើនៅក្នុងការជម្រះក្ដីនាសតវត្សរ៍ទី១៧ នៅប្រទេសអេស្ប៉ាញ របបកាន់កាប់នៅប្រទេសបារាំងដែលពោរពេញទៅដោយភេរវកម្មនៅក្នុងទសវត្សរ៍ឆ្នាំ១៧៩០ និងកាន់តែប្រហាក់ប្រហែលជាងនេះទៀតគឺនៅក្នុងដំណាក់កាល «បុរាណវត្ថុវិទ្យា» នៃចិត្តវិភាគរបស់ ហ្វ្រើដ ។ ហ្វ្រើដ បានកត់សម្គាល់ទៅលើចំណុចមួយក្នុងចំណោមចំណុចដែលមានលក្ខណៈដូចគ្នាទាំងប៉ុន្មាននេះ ។ សរសេរទៅកាន់មិត្តភក្ដិរបស់គាត់ឈ្មោះ វីល ហេមវ្ល៉េស នៅក្នុងខែមករា ឆ្នាំ១៨៩៧ ហ្វ្រើដ បានសួរថា «ហេតុអ្វីបានជាចម្លើយសារភាពក្រោមការ (ធ្វើទារុណកម្ម) ក្រោមការសួរចម្លើយមានលក្ខណៈដូចគ្នាម្ល៉េះទៅនឹងការប្រាស្រ័យទាក់ទងគ្នារបស់អ្នកជំងឺដែលខ្ញុំព្យាបាលជំងឺផ្លូវចិត្ត» ។

ចម្លើយទៅនឹងសំណួររបស់ ហ្វ្រើដ អាចស្ថិតនៅក្នុងទំនាក់ទំនងដែលមានភាពទុកចិត្តនិងលម្អៀងតែម្ខាងរបស់ពៅក្រម អ្នកសួរចម្លើយ និង អ្នកវិភាគជាច្រើននាក់ចំពោះអ្នកទោសនិងអ្នកជំងឺ ។ ជាងនេះទៅទៀតជាញឹកញយអ្នកវិភាគនិងអ្នកសួរចម្លើយអះអាងថាបានដឹងនូវអ្វីដែលខ្លួនកំពុងតែស្វែងរក ចំណែកឯអ្នកជំងឺនិងអ្នកទោសវិញមិនដឹងថា អ្វីទៅដែលត្រូវ«លាក់បាំង»ទេ ។ វីរបុរសមួយរូបក្នុងចំណោមវីរបុរសនានារបស់ ហ្វ្រើដ គឺបុរាណវិទូឈ្មោះ ហេន រិកឆ្លីមែន ដែល «ដឹង» អំពីទីតាំងរបស់ទីក្រុងត្រ័រ ហើយនៅពេលដែលជីកទៅឃើញថាត្រឹមត្រូវដូចគាត់ថាមែន ។[៣] គួបផ្សំជាមួយនឹងការគាបសង្កត់ផ្សេងៗទៀត រួមទាំងការសួរចម្លើយផង អ្នកសួរចម្លើយយ៉ាងស្ទាត់ជំនាញនៅមន្ទីរស-២១ អាចអន្ទោកអន្ទោលការចងចាំដែលមានទំនាក់ទំនងបន្តិចបន្តួចប្ដុក៏គ្មានទៅនឹង «ការពិតជាប្រវត្តិសាស្ត្រ» ។ នៅក្នុងករណីខ្លះ អ្នកទោសចេះតែផ្សំផ្សំបង្កើតការចងចាំឡើងដើម្បីតម្រូវចិត្តអ្នកសួរចម្លើយនិងដើម្បីបញ្ជាក់ថា អ្វីដែលនិយាយចេញនេះគឺពិតជាត្រឹមត្រូវឥតក្លែងបន្លំ ។ បញ្ហាស្មុគស្មាញផ្សេងៗ ការចងចាំ «ដែលត្រូវបានទឹកឃើញឡើងវិញ» និងការផ្ទេរពេលនោះក៏លេចចេញជារូបរាងឡើង ។[៤]

នៅមន្ទីរស-២១ មានអ្នកទោសមួយចំនួនមានជំនឿថា ខ្លួនឯងពិតជាមានកំហុសពីបទប្រឆាំងនឹងបដិវត្តន៍ ។ នេះគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេ ពីព្រោះនៅក្រោមសភាពតឹងតែងដូចដែល រីឆាត អហ្វស៊ី និង អ៊ីថាន វិតធ័រ បានសរសេរនៅក្នុងបរិបទផ្សេងទៀតគឺ «យើងមានបំណងចង់បង្កើតរឿង«ហេតុនិងផល» ចេញពីជីវិតយើងហើយ...នៅពេលដែលយើងគ្មានលទ្ធភាពធ្វើបែបនេះ យើងនឹងងាយទទួលរងបំផុតនូវការឲ្យយោបល់ពីអ្នកដទៃ» ។ នៅពេលជាមួយគ្នានេះដែរដូចដែលមានជំនឿសុសសាយនៅក្នុងសហភាពសូវៀតនាទសវត្សរ៍ឆ្នាំ១៩៣០ ការប្រឆាំងនឹងបដិវត្តន៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមិនមែនជាសកម្មភាព ប៉ុន្តែជា «សភាពនៃចិត្តដែលចេញមកពីគំនិតរបស់រដ្ឋ» ។[៥] និយាយម្យ៉ាងវិញទៀត ការពិតទោះបីជាអ្នកទោសធ្វើអ្វីក៏ដោយ ក៏ខ្លួនត្រូវតែបង្ខំចិត្តយល់ព្រមជាមួយនឹងការទាញសន្និដ្ឋានរបស់បក្សដែលថា ខ្លួនមានកំហុសដោយសារត្រូវបានចាប់ខ្លួនដែរ ។ ដូចដែល ស៊ុយ ឆេងហួត ជាអតីតកម្មករអគ្គិសនីនិយាយដោយស្មោះត្រង់នៅចុងបញ្ចប់នៃចម្លើយសារភាពរបស់គាត់ថា÷

ខ្ញុំមិនមែនជាសេ.អ៊ី.អាទេ ។ ខ្ញុំឆ្លើយថា សេ.អ៊ី.អា នៅពេលប្រឈមមុខនឹងទោសកំហុសរបស់ខ្ញុំ ។

> ខ្ញុំសូមឲ្យអង្គការសម្លាប់ខ្ញុំចោលចុះ ពីព្រោះខ្ញុំមិនដើរតាមបដិវត្តន៍...ខ្ញុំសមតែស្លាប់ ពីព្រោះអង្គការធ្លាប់តែទុកចិត្តមកលើខ្ញុំ ។ ខ្ញុំមិនចង់រស់ទៀតទេ មិនចង់តវ៉ាជាមួយនឹងអង្គការអ៊ីទេ គឺធ្វើនេះដើម្បីរកយុត្តិធម៌ ។ ប៉ុន្តែខ្ញុំសូមប្រកាសថា នៅក្នុងចិត្តខ្ញុំ ខ្ញុំមិនដែលក្បត់អង្គការទាល់តែសោះ ។ ខ្ញុំសូមឆ្លើយថាខ្ញុំមានកំហុស...ដោយសារពេលនេះខ្ញុំជិតដល់ពេលស្លាប់ហើយ ។ ជយោ! បដិវត្តន៍ដ៏រុងរឿង! ជយោ! អង្គការបដិវត្តន៍ ។[៦]

កិច្ចខិតខំប្រឹងប្រែងរបស់បក្សក្នុងការជម្រិតយកចម្លើយសារភាពថាមានកំហុស មិនមែនតែងតែទទួលបានផលជានិច្ចនោះទេ ។ ឈ្មោះ ស្បូវ ហិន (ហៅ អឿន) ដែលជាលេខាកងពលលេខ៣១០ ត្រូវបានចាប់ខ្លួននៅក្នុងខែឧសភា ឆ្នាំ១៩៧៧ ។ ក្រោយពីសារភាពថា ខ្លួនបានលាក់កន្ទុយមិនបដិវត្តន៍ចំពោះបញ្ហាគ្រួសារនិងមិនស្មោះត្រង់ចំពោះអង្គភាពទ័ពដោយលះបង់អាទិភាពរបស់ជាតិ ហិន បានស្ថិតក្នុងសភាពគួរឲ្យគ្រោះថ្នាក់បំផុត៖

> ខ្ញុំត្រូវរាយការណ៍ពីផែនការធ្វើរដ្ឋប្រហារផ្តួលរំលំបក្ស ។ នៅក្នុងជីវិតបដិវត្តន៍របស់ខ្ញុំ អស់រយៈពេលដប់ប្រាំបួនឆ្នាំនេះ ខ្ញុំបានបំពេញភារកិច្ចចាត់តាំងក្នុងនាមជាជនកុម្មុយនិស្ត ។ ខ្ញុំរៀបចំខ្លួនជាស្រេចក្នុងការលះបង់...ជីវិត ដើម្បីរំដោះវណ្ណៈនិងជាតិខ្ញុំ ។ នៅក្រោមការដឹកនាំរបស់បក្ស ខ្ញុំបានកែប្រែខ្លួនម្តងហើយម្តងទៀត...ខ្ញុំគ្មានអ្វីលាក់បាំងចំពោះបក្សទេ ។ ខ្ញុំមិនដែលមានគំនិតចង់ធ្វើរដ្ឋប្រហារប្រឆាំងនឹងបក្សឡើយ ។ ខ្ញុំយល់ថា នេះជារឿងគ្មានសមហេតុផលអ្វីបន្តិចសោះ ពីព្រោះខ្ញុំមិនដែលមានគំនិតបែបនេះ ទាល់តែសោះ...ខ្ញុំមានការសោកស្តាយណាស់ ដែលខ្ញុំមិនដឹងមុនថា ខ្ញុំនឹងត្រូវបានចាប់ខ្លួនដូចពេលនេះ ។ បើខ្ញុំដឹងមុន ម៉្លេះខ្ញុំឆ្លើយពីភក្តីភាពរបស់ខ្ញុំចំពោះបក្សទៅហើយ ។ ប៉ុន្តែពេលនេះវាហួសពេលទៅហើយ ។ ខ្ញុំជាប់ឃ្នោះនៅមន្ទីរស-២១ហើយ ។[៧]

ស្បូវ ហិន ត្រូវជាប់ឃ្នោះគំនិតថា គ្មានការងើបប្រឆាំងនឹងរដ្ឋអំណាចបក្សបានឡើយ ទោះបីជា (ឬជាពិសេស) នៅពេលនេះបក្សបានទទួលពត៌មានសុទ្ធតែមិនពិត ហើយធ្វើឲ្យតែពីរោះស្តាប់ក៏ដោយ ។ នៅពេលបញ្ចប់ចម្លើយសារភាពរបស់ខ្លួនដោយប្រយោគមួយឃ្លាថា«មានតែបក្សទេដែលដឹងពីប្រវត្តិខ្ញុំ» ស្បូវ ហិន បាននិយាយថា ខ្លួនគ្មានកំហុសទេ ហើយបានទទួលស្គាល់សិទ្ធិរបស់បក្សក្នុងការដាក់កំហុសមកលើខ្លួន ។[៨]

អស់រយៈពេលជាច្រើនថ្ងៃខែក្រោយមក អ្នកសួរចម្លើយនៅមន្ទីរស-២១ បានវាយលុកទៅលើរាងកាយ ចិត្តគំនិត និង ប្រវត្តិសាស្ត្រ ដោយថែមថយ និងប្រឹងប្រែងការចងចាំដើម្បីឲ្យស៊ីគ្នាជាមួយនឹងការចោទប្រកាន់ដែលរៀបចំទុកជាស្រេច និងធ្វើឲ្យចេញរូបរាងជាចម្លើយសារភាព ។ អ្នកទោសនិងអ្នកសួរចម្លើយធ្វើការដូចជាកីឡាករសកលហាត់វាយខ្យល់ដូច្នេះដែរ ដោយអ្នកសួរចម្លើយព្យាយាមទាញយក «ការពិត» (ទាំងគ្មានបញ្ជាក់ថាវាជាអ្វីផង) ហើយអ្នកទោសព្យាយាមចាក់ខ្សែស្របតាម ឬក្នុងករណីជាច្រើន (ប៉ុន្តែ

មិនដឹងករណីមួយណា) ដើម្បីបន្វែងដានអ្នកសួរចម្លើយដោយលាក់កំបាំងឬផ្លាស់ប្តូររឿងរ៉ាវរបស់ខ្លួន ។

អ្នកសួរចម្លើយត្រូវបានឲ្យធ្វើការបញ្ចុះបញ្ចូលនិងគំរាមបំភ័យអ្នកទោស លុះត្រាតែអ្នកទោសបញ្ចេញនូវឯកសារមួយដែលស៊ីគ្នាជាមួយនឹងការដឹងព្ធរបស់បក្សចំពោះ«បទល្មើស» របស់ខ្លួន និងការអានរបស់បក្សលើប្រវត្តិរបស់ខ្លួនដែលម្តងអឺចេះម្តងអឺចុះ ។

តាមរបៀបស្រមើស្រមៃដែលពិបាកយល់នៅក្នុងស្នាដៃរបស់ ម៉ីឡែន ឃូនដេរ៉ា «ការដាក់ទណ្ឌកម្មតែងតែត្រូវបានធ្វើឡើងដើម្បីជម្រិតយកចម្លើយសារភាពថា ខ្លួនពិតជាមានកំហុស» ។[៩] ដូចនេះអ្នកទោសត្រូវតែលាយឡំបញ្ចេញបញ្ចូលឬទប់នូវអ្វីដែលខ្លួននៅចាំបានច្បាស់លាស់ ដើម្បីផ្សំផ្គុំឲ្យចេញជាចម្លើយសារភាពមួយដែលជាតម្រូវការរបស់អ្នកសួរចម្លើយ ។ ចំពោះអ្នកសួរចម្លើយ និង អ្នកទោសក៏ដូច្នេះដែរ អាឡិចសាន់ឌ័រ សូលហ្សិន នីតស៊ីន បានសរសេរថា ដំណើរការរបៀបនេះបង្កើតបានជា «ការលេងសូលីទែរដ៏អស្ចារ្យមួយដែលមានក្បួនលេងមិនងាយយល់សម្រាប់អ្នកលេងល្បែងនេះ» ។ បើយើងបកស្រាយន័យធៀបនេះមកវិញគឺថា មជ្ឈិមបក្សបានលាក់កំបាំងក្បួនច្បាប់ផ្សេងៗ ហើយអ្នកសួរចម្លើយត្រូវបានជំរុញឲ្យធ្វើសំណួរសម្រាប់ទម្លាក់កំហុសនៅក្នុងផ្លូវមួយដែលថា «ខ្មាំងមិនអាចក្តាប់គោលបំណងរបស់យើងបានទេ» ។ មិនមែនជាការគួរឲ្យភ្ញាក់ផ្អើលទេ គឺការដេញដោលសួររបៀបនេះ ប្រៀបបាននឹងល្បែង «ដែលសួរមនុស្សខ្វាក់អំពីពណ៌របស់វត្ថុ» យ៉ាងដូច្នោះដែរ ។[១០]

មើលទៅមានអ្នកទោសជាច្រើននាក់ត្រូវបានចាប់ខ្លួន ដើម្បីបង្ខំឲ្យក្បត់នឹងអ្នកនៅពីលើខ្លួន ។ អ៊ីចឹងហើយ បានជាកម្មាភិបាលជាច្រើននាក់ដែលបានចាប់ខ្លួននៅឆ្នាំ១៩៧៦ ត្រូវបានសួរចម្លើយដើម្បីកសាងសំណុំរឿងចោទប្រកាន់លេខាភូមិភាគបូព៌ាឈ្មោះ សោ ភឹម ហើយនៅឆ្នាំ១៩៧៨ ឈ្មោះ ឃាង ស៊ុម ហាន (ហៅ ប៉ុត) ត្រូវបានអ្នកសួរចម្លើយគាបឲ្យឆ្លើយដាក់ សុន សេន ។[១១]

អ្នកទោសទាំងអស់នៅមន្ទីរស-២១ ភាគតិចណាស់ដែលមិនត្រូវសម្លាប់ មិនមែនត្រឹមតែដោយសារខ្លួនត្រូវបានចោទប្រកាន់ថាមានកំហុសទេ តែដោយសារអត្ថិភាពនៃគុកនេះ ទីតាំងនិងគោលបំណងរបស់គុកដែលត្រូវរក្សាឲ្យស្ថិតក្នុងភាពសម្ងាត់ជានិច្ច ។ ការចាំបាច់ក្នុងការថែរក្សាការសម្ងាត់សំខាន់ណាស់ ដូចនេះអ្នកទោសមិនដែលបានរួចខ្លួនឡើយ ។[១២]

អ្នកទោសត្រូវបាននាំមកកាន់មន្ទីរស-២១ ដោយមូលហេតុច្រើនយ៉ាងដូចជា÷ ពីព្រោះអ្នកទោសទាំងនោះត្រូវបានឆ្លើយដាក់តាមរយៈចម្លើយសារភាពរបស់អ្នកទោសដទៃ ដោយសារមេបញ្ជាការអង្គភាពខ្លួនត្រូវបានសង្ស័យថាជា «ខ្មាំង» ឬដោយសារតែមានការសង្ស័យពីខាងសន្តិសុខភូមិភាគ ។ ចម្លើយសារភាពរបស់ ហ៊ូ នឹម បង្ហាញថា ជួនកាល «ខ្មាំង» ត្រូវបានរកឃើញក្នុងពេលប្រជុំស្វ័យទិតៀនថ្នាក់កម្មាភិបាលដែលធ្វើឡើងដោយទៀងទាត់ ។ «ខ្មាំង» ត្រូវបញ្ជូនចេញមកកាន់មន្ទីរស-២១ ក្រោយពីសួរចម្លើយទាំងបង្ខំឲ្យឆ្លើយសារភាពពីអំពើក្បត់របស់ខ្លួន ។[១៣]

ការដែលអ្នកទោសត្រូវជ្រើសរើស គោះប្រជុំ ប្រមូលផ្តុំ និងបញ្ចេញទៅមន្ទីរស-២១របៀបណានោះ មិនមានលក្ខណៈច្បាស់លាស់ឡើយ ហើយទំនាក់ទំនងរដ្ឋបាលរវាងមន្ទីរស-២១ និង «សាលាអប់រំ»

ក៏យ៉ាងដូច្នេះដែរ ពាក្យថា «គុក» មិនត្រូវបានប្រើនៅគ្រប់ទីកន្លែងទូទាំងប្រទេសទេ ប៉ុន្តែយើងដឹងថា គ្រប់តំបន់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យសុទ្ធតែមានមន្ទីរសន្តិបាលរបស់ខ្មែរក្រហម ដែលរៀបចំឡើងមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងមន្ទីរស-២១ដែរ ។ មន្ទីរទាំងនេះបានរាយការណ៍ទៅលេខាភូមិភាគ តែមិនរាយការណ៍ទៅមន្ទីរស-២១ ឬ មជ្ឈិមបក្សនៅភ្នំពេញទេ ។ ក្រៅពីចម្លើយសារភាព យើងនៅដឹងបន្តិចបន្តួចដែរអំពីភ័ស្តុតាងជាសំណេរដែលត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ចាប់មនុស្ស ឬធ្វើឡើងសម្រាប់អ្នកសួរចម្លើយធ្វើការនៅគុក ។ សំណួរតិចណាស់ដែលអ្នកទោសភាគច្រើនបានឆ្លើយបង្ហាញថាមានការចងក្រងឯកសារមួយចំនួនតូចដែលអមជាមួយអ្នកទាំងនោះទៅកាន់មន្ទីរស-២១ ។[១៤]

ជាទូទៅ អ្នកធ្វើការថ្នាក់ក្រោមត្រូវបានចោទប្រកាន់ដោយសមាជិករបស់ខ្លួននៅក្នុងជួរទ័ពនិងអន្តភាពបង្កបង្កើនផល ដែលបានប្រព្រឹត្តសកម្មភាពមិនល្អ ឬ ដោយការចាប់ខ្លួនអ្នកនៅពីលើ ។ ប៉ុន្តែអ្នកទោសដែលត្រូវបានសួរចម្លើយយ៉ាងយូរត្រូវតែឆ្លើយអំពីទោសកំហុសក្បត់របស់ខ្លួន ក៏ដូចជាការពាក់ព័ន្ធជាមួយអ្នកដទៃ ។ ទោសកំហុសភាគច្រើនមានលក្ខណៈមិនគួរឲ្យជឿទាល់តែសោះ ។

នៅក្នុងចម្លើយសារភាពរបស់ខ្លួន អ្នកទោសតែងតែតម្រូវឲ្យឆ្លើយដាក់អ្នកធ្វើការជិតដិតជាមួយខ្លួន ។ «ខ្សែក្បត់» ដែលមាននៅស្ទើរគ្រប់ចម្លើយសារភាព មានរហូតដល់រាប់រយដោយបង្កើតបានជាចំណាប់អារម្មណ៍មួយពីការសមគំនិតដ៏ធំ និងទូទាំងប្រទេស ។ នេះគឺជាអ្វីដែល ឌុច និងអ្នកនៅថ្នាក់លើតែងតែមាននៅក្នុងគំនិត ។ ស្ទីវ ហេដឌ័រ កត់សម្គាល់ថា «លោកទស្សនៈនៃចម្លើយសារភាពរបស់(មន្ទីរស-២១) រួមទាំងបុគ្គលដែលកំពុងតែឆ្លើយសារភាព គឺអ្នកនៅពីលើដែលបញ្ចុះបញ្ចូលឲ្យបុគ្គលនោះក្បត់បដិវត្តន៍និងអ្នកនៅខាងក្រោមដែលបុគ្គលនេះបញ្ចុះបញ្ចូលឲ្យក្បត់នឹងបដិវត្តន៍» ។ អ្វីៗគ្រប់យ៉ាងគឺត្រូវបានមើលឃើញជាខ្សែសង្វាក់និងកម្លាំង ។[១៥] មានអ្នកទោសតិចណាស់ដែលសារភាពថា បានធ្វើការសម្រេចចិត្តដោយខ្លួនឯង ។ តែផ្ទុយទៅវិញអ្នកទោសជាទូទៅច្រើនឆ្លើយថា ត្រូវបានលង់ចូលប្រក្បត់បដិវត្តន៍ដោយសារអ្នកមានបុណ្យស័ក្តិខ្ពស់ដែលពូកែខាងវោហារនិងពូកែរាក់ទាក់ ។ ឧទាហរណ៍ជាក់ស្តែង ឈ្មោះ អែម ជឿន បានពុការនិយាយអំពីការខកខានរបស់បដិវត្តន៍ក្នុងការបញ្ចេញសម្ភារប្រើប្រាស់ឲ្យបានសំបូរគ្រប់គ្រាន់ ។ មួយឆ្នាំក្រោយមក ជឿន បានសារភាពថា «ខ្ញុំបានពុការនិយាយរបៀបនេះច្បាស់ណាស់ ។ ខ្ញុំខឹងនឹងបក្ស ហើយក៏ចាប់ផ្តើមបំផ្លាញបក្ស» ។[១៦] ហាក់ គីមឈាង ដែលធ្លាប់ត្រូវគ្រូបង្រៀនវាយកាលពីក្មេងនិយាយថា គាត់ត្រូវបាន «ភ្នាក់ងារសេ៊ីបការណ៍ចិន» ជ្រើសរើសនៅថ្ងៃត្រង់នៅពេលនោះតែម្តងនៅពេលដែលខ្លួនកំពុងយំ ហើយយុវតី គីម ភួង ក៏ត្រូវបានទាក់ទាញឲ្យចូលធ្វើសកម្មភាពក្បត់ក្រោយពីមានការរៀបរាប់អំពីកម្មសិទ្ធិដែលខ្លួននឹងទទួលបានពីការគាំទ្រ «សេរីភាព» ។[១៧]

ជារឿយៗ អ្នកនាំចូលបដិវត្តន៍ ក្រោយមកក៏ត្រូវចោទប្រកាន់ថាបានជំរុញឲ្យអ្នកដែលខ្លួនបាននាំចូលឲ្យក្បត់នឹងបដិវត្តន៍ ។ ប្រហែលជាដោយសារត្រូវបានបំភ័យនិងមានការឈឺចាប់ អ្នកទោសជាច្រើនបានក្បត់អ្នកដែលនាំខ្លួនចូលបក្សដោយរំពឹងទុកថា ពត៌មាននេះគឺជាអ្វីដែលអ្នកសួរចម្លើយចង់បានបំផុត ។ កង្វះសមត្ថភាពរបស់របបនេះដែលបញ្ចូលសុទ្ធតែ«ខ្មាំង» មកធ្វើការនៅក្នុងជួរបក្សកុម្មុយនិស្តកម្ពុជាមិន

ដែលត្រូវបានលើកយកមកនិយាយឡើយ ។ ប៉ុន្តែ ការរៀបរាប់តាមដំណើរដើមទងនូវការក្បត់តាមរយៈចម្លើយសារភាព គឺមានបំណងសង្កត់ធ្ងន់ទៅលើចរិតសមគំនិតនៃសង្គមនៅក្រោមបក្សនិងកាត់បន្ថយ ព្រមទាំងធ្វើឲ្យគ្រោះថ្នាក់ដល់សកម្មភាពបដិវត្តពិតៗរបស់អ្នកទោសឬអតីតបក្ខពួករបស់អ្នកទោសទាំងនោះ ។

នៅក្នុងទម្រង់ការនេះ បុរស ស្ត្រីជាច្រើនដែលបានលះបង់ជីវិតដើម្បីបុព្វហេតុបដិវត្តន៍ ដែលរួមទាំងអ្នកធ្លាប់ធ្វើការជិតដិតជាមួយ ប៉ុល ពត ជាច្រើននាក់ទៀត ត្រូវបានបង្ខំឲ្យឆ្លើយសារភាពអំពីការពាក់ព័ន្ធរបស់ខ្លួនតាំងពីយូរណាស់មកហើយជាមួយសេ.អ៊ី.អា ។ អ្នកទោសម្នាក់ឈ្មោះ រ៉េ បូ យ៉ាងហោចណាស់បានដឹងអំពីអ្វីដែលខ្លួនត្រូវឆ្លើយៈ «ខ្ញុំជាជនក្បត់តាំងពីថ្ងៃដែលខ្ញុំបានចូលបដិវត្តន៍ដល់ថ្ងៃដែលខ្ញុំត្រូវបានចាប់ខ្លួន» ។ តើវាអាចទៅជារឿងផ្សេងបានដែរឬទេ? នៅក្រោមក្រសែភ្នែករបស់មជ្ឈិមបក្ស អ្នកណាចូលបដិវត្តន៍ដោយស្មោះត្រង់មិនអាចក្បត់បដិវត្តន៍វិញទេ ។ បញ្ច្រាសមកវិញ អ្នកដែលក្បត់បដិវត្តន៍មិនអាចស្មោះត្រង់បានទេ ។[១៨]

«ចំណុចខ្វះខាត» នៅក្នុងចម្លើយសារភាពនៅមន្ទីរស-២១ ត្រូវបាន ឌុច និងអ្នកធ្វើការជាមួយយល់ថា មិនមែនជាភស្តុតាងបង្ហាញថា អ្នកទោសមិនចាំអ្វីនោះទេ តែយល់ថា ជាឱកាសដែលអ្នកទោសប៉ុនប៉ងលាក់បាំងការពិតទៅវិញ ។ ភាពរួញរាឬមិនច្បាស់លាស់ធ្វើឲ្យអ្នកសួរចម្លើយមានការស្មុគស្មាញ ហើយក៏ចាត់ទុកជាភស្តុតាងបញ្ជាក់ពីកំហុសរបស់អ្នកទោសតែម្តង ។ តាមពិតភាគច្រើន ភាពឯកា ការដេកមិនលក់ ទារុណកម្ម និង ការភ័យខ្លាចបានធ្វើឲ្យអ្នកទោសច្របូកច្របល់ក្នុងចិត្ត ទទួលឥទ្ធិពល ឬ ទទួលរងនូវអំពើទាំងពីររួចទៅហើយ ។[១៩]

វិធីសាស្ត្រទាំងពីរនេះត្រូវបានអ្នកសួរចម្លើយនៅមន្ទីរស-២១ យកមកប្រើប្រាស់ដូចៗគ្នា ដើម្បីជម្រិតយកលទ្ធផលចុងក្រោយត្រូវបានហៅថា «ធ្វើនយោបាយ» និង «ដាក់ទារុណកម្ម» ដែលត្រូវលើកយកមកពិភាក្សានៅក្នុងវគ្គទី៥ ។ «ធ្វើនយោបាយ» មានន័យថា ចោទប្រកាន់អ្នកទោសដោយសួរសំណួរ និងបញ្ចុះបញ្ចូលថា បក្សបានដឹងកំហុសរបស់អ្នកទោសរួចហើយ ។ សៀវភៅរៀនសូត្រឆ្នាំ១៩៧៦ បានសរសេរដំណើរការសួរចម្លើយដែលមានប្រាំពីរចំណុច÷

១) ទីមួយស្រង់យកព័ត៌មានពីវា ។

២) បន្ទាប់មកប្រមូលចំណុចឲ្យបានច្រើនដើម្បីសង្កត់ឲ្យជាប់និងកុំឲ្យវាចេញរួច ។

៣) សង្កត់ដោយឃោសនានយោបាយ ។

៤) គាបសួររបៀបប្រមាថ ឬធ្វើឲ្យខឹង ។

៥) ធ្វើទារុណកម្ម ។

៦) ពិនិត្យសាឡើងវិញ និងវិភាគចម្លើយដើម្បីសួរសំណួរបន្ថែម ។

៧) ពិនិត្យសាឡើងវិញនិងវិភាគចម្លើយដើម្បីរៀបចំជាឯកសារ ។[២០]

ចំណុចចាប់ផ្តើមនិងបញ្ចប់ រំឭកអំពីដំណើរការរបស់នគរបាលនៅគ្រប់ទីកន្លែងទាំងអស់ ប៉ុន្តែបញ្ហាកើតឡើងនៅត្រង់ចំណុចទី២ដល់ទី៥ ។ ភាពខុសគ្នារវាង «ឃោសនានយោបាយ» និង «សួររបៀបប្រមាថឬធ្វើឲ្យខឹង» ហើយកម្រិតរវាង «ការគាបសង្កត់»និង«ទារុណកម្ម» មិនកំណត់ច្បាស់លាស់ទេ ។ ការធ្វើអំពើអមនុស្សធម៌ទៅលើអ្នកទោស ទំនាក់ទំនងអំណាចមិនស្មើនៅមន្ទីរស-២១ ការសម្របតាមវប្បធម៌របស់អ្នកទោស និងភាពបន្ទាន់ដែលធ្វើឡើងនៅពេលធ្វើទារុណកម្មបានធ្វើឲ្យមានអំពើឃោរឃៅក្នុងទ្រង់ទ្រាយធំ ។ អស់រយៈពេលយ៉ាងយូរមុនពេលធ្វើទារុណកម្ម ការសួរចម្លើយត្រូវធ្វើឡើងជាប្រចាំដោយការទាត់ធាក់វាយតប់ ។ អតីតឆ្មាំគុកម្នាក់ឈ្មោះ គក ស្រស់ បានរំឭកថា ជារឿយៗអ្នកទោសមាន«ឈាមដោកខ្លួន» នៅពេលនាំចូលទៅក្នុងបន្ទប់តូចវិញ ហើយរូបថតពាក់កណ្តាលខ្លួនរបស់អ្នកទោសជាច្រើនបង្ហាញឲ្យឃើញអំពីការវាយដំប្រំធាក់ ។ ការសង្កេតឃើញរបស់ គក ស្រស់ ក៏មិនខុសគ្នានឹងសម្តីរបស់អ្នកដែលមានវាសនារស់ចាកផុតពីសេចក្តីស្លាប់នៅមន្ទីរស-២១ ឈ្មោះ ផាន ថនចាន់ ដែរ ។[២១]

ទាក់ទងនឹងការ «ធ្វើនយោបាយ» វាមិនខុសគ្នាអ្វីទៅនឹងរបៀបដែលត្រូវបានធ្វើនៅវៀតណាមកាលពីទសវត្សរ៍ឆ្នាំ១៩៥០ទេ ។ នៅក្នុងយុទ្ធនាការកែទម្រង់ដីធ្លីធ្វើឡើងដោយរដ្ឋាភិបាលកុម្មុយនិស្តដែលទើបលើកបន្តុបថ្មី អ្វីដែលហៅថាក្បួន «ទ្រុយបុក» ត្រូវបានយកមកប្រើក្នុងការស្រង់យកចម្លើយពី «ម្ចាស់ដី» នៅតាមជនបទដែលត្រូវបានចោទប្រកាន់ ។ ពាក្យថា «ទ្រុយបុក» ដែលសម្រាយមកថា «សួរអង្កៀម» ពិពណ៌នាអំពីដំណើរការដែលត្រូវបានយកមកប្រើនៅក្នុងការ «ធ្វើនយោបាយ» នៅមន្ទីរស-២១ និងកន្លែងសួរចម្លើយផ្សេងៗទៀត ។[២២]

ទម្រង់នៃការគាបសង្កត់តាមរយៈពាក្យសម្តីដែលត្រូវបានប្រើគឺពិបាកយល់ណាស់ ។ ស្ទើរតែគ្រប់ចម្លើយសារភាព សំណួររបស់អ្នកសួរចម្លើយត្រូវលុបចោល ។ ការសួរចម្លើយប្រភេទនេះដែលត្រូវបានលើកឡើងយ៉ាងច្បាស់ដោយអ្នកនិពន្ធ អារន្ធ ឡុនដុន, សូលហេ្សនីតស៊ីន, ហ្សាកូបូ ទីមឺម៉ាន និងអ្នកនិពន្ធដទៃទៀត មិនបានយកមកសរសេរឡើយ ។

ជាងនេះទៅទៀត មកដល់ពេលនេះគ្មានកិច្ចសម្ភាសន៍ជាមួយនឹងអ្នកសួរចម្លើយណាម្នាក់នៅឡើយទេ ហើយក៏គ្មានអ្នកនៅរស់ចាកពីសេចក្តីស្លាប់ពីមន្ទីរស-២១ ណាម្នាក់ត្រូវបានសួរចម្លើយយ៉ាងយូរដែរ ប៉ុន្តែយើងដឹងថាមានឥស្សរជនមួយចំនួនត្រូវបានសួរចម្លើយនៅមន្ទីរស-២១ រាប់សិបដងក្នុងរយៈពេលជាច្រើនខែ ។ នៅក្នុងអំឡុងពេលនេះ ទំនាក់ទំនងរវាងអ្នកសួរចម្លើយនិងអ្នកទោសជាមួយនឹងទម្រង់នៃការសួរចម្លើយត្រូវតែកើនឡើងដូចដែលចម្លើយសារភាពសំខាន់ៗមួយចំនួនដូចជារបស់ ណៃ សារ៉ាន់ បញ្ជាក់ស្រាប់ តែទំនាក់ទំនងទាំងនេះមិនមាននៅបណ្ណសារឡើយ ។ ករណីលើកលែងមួយដែលបញ្ជាក់ពីវិន័យក្នុងការសួរចម្លើយ គឺចម្លើយសារភាពរបស់ឈ្មោះ ចុង វ៉ាន់ ជាសមាជិកបក្សដែលត្រូវបានចាប់ខ្លួននៅខែកញ្ញា ឆ្នាំ១៩៧៧ ។ ចុង បាននិយាយអំពីការសួរចម្លើយចំពោះខ្លួនថា÷

ពេលដែលខ្ញុំមកដល់មន្ទីរស-២១ដំបូង មានតំណាងម្នាក់ធ្វើការនៅមន្ទីរសន្តិសុខបានមកសួរខ្ញុំ ។ ម្នាក់

នោះបានចោទប្រកាន់ខ្ញុំថាជាសេ.អ៊ី.អា តាមការឆ្លើយដាក់ពីអ្នកដទៃ ។ នៅចំណុចនោះ ខ្ញុំគ្រប់គ្រងខ្លួនឯងលែងបាន ហើយនិយាយថា មិនពិតទេ ។ វាបន្តទៀតថា បើឯងថាទេ វ៉ៃទាល់តែចេញហ្នឹង! ។

ក្នុងការចាប់ផ្តើម ខ្ញុំបានសរសេរលម្អិតអំពីសកម្មភាពក្បត់បដិវត្តន៍មកដល់បច្ចុប្បន្ន ។ ពេលដែលខ្ញុំសរសេរហើយ គំណាងមន្ទីរសន្តិសុខនិយាយថា ម៉េចបានអញមិនឃើញប្រវត្តិក្បត់បន្តិចសោះអីចឹង?

ខ្ញុំក៏ឆ្លើយតបវិញថា «ពីព្រោះខ្ញុំមិនបានធ្វើអ្វីខុសទេ» ។

ពេលនោះតំណាងនោះនិយាយថា «បើឯងនិយាយថាទេនឹងត្រូវព្រនង់មិនខាន» ។ ខ្ញុំក៏សួរទៅវិញថា តើខ្ញុំអាចសរសេរតាមការពិតបានទេ ។

តំណាងតបវិញថា «បើឯងសរសេរពីសកម្មភាពក្បត់ជាការល្អ» ។

ខ្ញុំដឹងថា ពេលនេះខ្ញុំពិតជាទទួលទារុណកម្មជាមិនខានឡើយ ដូច្នេះខ្ញុំសម្រេចចិត្តសរសេររឿងប្រឌិតអំពីសកម្មភាពក្បត់របស់ខ្ញុំ ។ ខ្ញុំសរសេរថា ខ្ញុំក្បត់តាំងពីឆ្នាំ១៩៧០មកម្ល៉េះ ហើយសរសេរអំពីការពាក់ព័ន្ធរបស់ខ្ញុំជាមួយនឹង នង សួន នៅពេលដែលយើងនៅជាមួយគ្នានៅ...ឱរ៉ាល់ ។

ខ្ញុំបានរៀបរាប់ឈ្មោះសមមិត្តមួយចំនួនដែលធ្វើសកម្មភាពបដិវត្តជាមួយខ្ញុំនៅឆ្នាំ១៩៧៦ ។ បន្ទាប់មក តំណាងមន្ទីរសន្តិសុខឲ្យខ្ញុំបញ្ជាក់អំពីដំណើររឿងរបស់ខ្ញុំផ្ទាល់ដោយនិយាយថា «តើសកម្មភាពក្បត់ពេលដែលឯងនៅទីក្រុងមានអ្វីខ្លះ?» ។

ខ្ញុំក៏ឆ្លើយថា «អត់មានទេ» ។

តំណាងមន្ទីរសន្តិសុខនិយាយថា «បើឯងមិនឆ្លើយទេចាំទទួលរំពាត់ខ្សែភ្លើងទៅ!»

នៅពេលឮថាទារុណកម្ម ខ្លួនខ្ញុំចាប់ផ្តើមញ័រចំប្រប់ ។ ពេលនោះខ្ញុំក៏ចាប់ផ្តើមសរសេររឿងប្រឌិតតែម្តងទៅ ។[២៣]

ប៉ុន្មានខែមុននេះ សៀត ឆែ (ហៅទុំ) បានសរសេរកំណត់សម្គាល់មួយច្បាប់ទៅកាន់សន្តិបាលដែលជាការផ្តល់នូវចិត្តសាស្ត្រមួយទៀតរបស់អ្នកទោសនៅដំណាក់កាលមុនពេលសួរចម្លើយ និងទារុណកម្ម (មើលវគ្គទី៣) ។ សៀត ឆែ ជឿជាក់ថា ខ្លួនត្រូវបានចោទប្រកាន់ខុសទំនង ហើយថា ឌុច នឹងអនុញ្ញាតឲ្យធ្វើការទាក់ទងដោយផ្ទាល់ជាមួយនឹង «បងៗថ្នាក់លើ» ជាសំណើដែល ឌុច បានដុសខាត់ម្តងហើយម្តងទៀត ។ កំណត់សម្គាល់ចុះថ្ងៃទី៨ ខែឧសភា បានលាតត្រដាងអំពីសភាពរេរាមិននឹងនៅក្នុងចិត្តរបស់ ឆែ ។[២៤]

នៅល្ងាចថ្ងៃទី៧-៨ ខែឧសភា ឆ្នាំ១៩៧៧ ចិត្តខ្ញុំស្ថិតនៅក្នុងសភាពមួយមិននឹងនរហូតមិនដឹងថានិយាយយ៉ាងម៉េចទេ ។ ខ្ញុំមើលមិនឃើញផ្លូវសម្រាប់អនាគតសោះឡើយ ។ ខ្ញុំបានអង្វរបក្សថា នៅពេលនេះសូមក្តីអាណិតកូនរបស់ខ្ញុំផង ។

[ទាំងនេះជា] ការវិវឌ្ឍន៍នៃចិត្តគំនិតរបស់ខ្ញុំ ។ ដំណាក់កាលទី១ៈ នៅក្នុងអំឡុងពេលក្រោយពីបក្ស

បានចាប់ខ្ញុំ រហូតមកដល់ខែឧសភា ឆ្នាំ១៩៧៧ គឺជាការសរសេររបាយការណ៍ទៅលើចំណុចដែលអង្គការចង់ឲ្យពន្យល់ ។ ដោយប្រើរបាយការណ៍ទាំងនោះខ្ញុំសង្ឃឹមថា អង្គការនឹងសាកសួរនិងស៊ើបអង្កេតនៅតាមមូលដ្ឋានដែលខ្ញុំធ្លាប់ប្រឡូកនិងធ្វើការស្រាយបំភ្លឺសម្ដីរបស់ខ្ញុំ ។ ខ្ញុំសង្ឃឹមថា ក្រសួងសន្តិបាលដែលជាក្រសួងទទួលខុសត្រូវនិងតាមដាន នឹងបញ្ជាក់ផ្ទៀងផ្ទាត់ឯកសារទាំងនេះព្រមទាំងយកសេចក្ដីសង្ខេបនេះដាក់ជូនអង្គការ ។ បង្កើតមូលដ្ឋានកំហុសធំតូចរបស់ខ្ញុំ ហើយយកចិត្តទុកដាក់ចំពោះខ្ញុំផង ។

ដំណាក់កាលទី២៖ ចាប់ពីល្ងាចថ្ងៃទី៤ ខែឧសភា មកដល់ថ្ងៃនេះ ខ្ញុំបានទទួលរងទារុណកម្មគ្រប់បែបយ៉ាងតាមដំណើរការរបស់សន្តិបាល ។ គំនិតរបស់សន្តិបាលគឺថា គ្មានមធ្យោបាយណាដែលថាខ្ញុំមិនមែនជាជនក្បត់នោះទេ ។

ដូចនេះដោយដឹងនូវជំហរនេះ កម្រិតនៃទារុណកម្មកាន់តែកើនឡើងជាលំដាប់ ធ្វើឲ្យអារម្មណ៍ខ្ញុំប្រែប្រួលឡើងចុះយ៉ាងខ្លាំង ។ ខ្ញុំគ្មានផ្លូវត្រូវចេញរួចទេ រាត្រីនោះខ្ញុំមានអារម្មណ៍ដូចខាងក្រោមនេះ÷

១) ប្រសិនបើខ្ញុំសារភាពថាក្បត់មិនដឹងជាត្រូវសរសេរអំពីសកម្មភាពក្បត់ជាមួយបក្សពួកប្រកបដោយហេតុផលនិងតាមលំដាប់លំដោយយ៉ាងម៉េចទេ បើខ្ញុំមិនបានក្បត់ផងនោះ ។ នេះជារឿងមួយ ។ រឿងមួយទៀត បើខ្ញុំសរសេរដូចនេះដោយគិតអំពីជំហរខ្ញុំចំពោះបក្សចាប់តាំងពីថ្ងៃ២៦ ខែឧសភា (១៩៥៩) និងចំពោះបងទីមួយ«ប៉ុល ពត» ដែលខំចិញ្ចឹមបីបាច់ខ្ញុំតាំងពីតូចរហូតមក ហើយសរសេរតាមការធ្វើទារុណកម្មនោះ ខ្ញុំធ្វើទៅមិនរួចទេ! ។

២) គិតចុះគិតឡើង ខ្ញុំឃើញផ្លូវដ៏ល្អមួយគឺសេចក្ដីស្លាប់...ការស្លាប់មួយពព្រិចភ្នែកដែលអាចចាកផុតពីការឈឺចាប់...ហើយនៅជាមួយបក្សលុះដល់ទីបញ្ចប់ ។ ប៉ុន្តែ មើលទៅគ្មានផ្លូវស្លាប់មួយពព្រិចភ្នែកទេ ។ គ្មានផ្លូវចេញទេ...ខ្ញុំខ្លាចការធ្វើទារុណកម្មនិងសេចក្ដីស្លាប់ណាស់ ។ បើខ្ញុំពាក់ព័ន្ធជាមួយជនក្បត់មែន ខ្ញុំនឹងប្រាប់អង្គការភ្លាម ហើយបានចាកផុតពីការធ្វើទារុណកម្មភ្លាម ។

៣) ក្រោយពីគិតសាចុះសាឡើងហើយគ្មានផ្លូវចេញ ព្រឹកនេះខ្ញុំខំសរសេរឲ្យអង្គការដឹងអំពីការវិវឌ្ឍន៍របស់អារម្មណ៍ខ្ញុំ និងអាណិតខ្ញុំ ។ សំណូមពរចុងក្រោយនេះ គឺដើម្បីសុំឲ្យអង្គការពន្យារពេលធ្វើទារុណកម្មនិងពិចារណាម្ដងទៀតនូវសក្ខីកម្មរបស់ជនក្បត់បីនាក់ដែលចោទប្រកាន់មកលើខ្ញុំ ។ អ្នកទាំងបីនាក់នេះចេះតែប្រឌិតទេ ។ ខ្ញុំដឹងថាច្បាស់ជាមានមតិផ្ទុយគ្នានៅក្នុងរឿងនិងបញ្ហាសំខាន់មួយចំនួនមិនខាន ។

អ្នកទោសត្រូវបានជំរុញឲ្យផ្ទៀងផ្ទាត់ជាមួយចម្លើយសារភាពពីមុនៗ ហើយធ្វើឲ្យមានការជំពាក់ជាក់វិនជាមួយអ្នកដែលត្រូវបានចាប់ខ្លួននិងសម្លាប់ចោលរួចហើយ ។ ប្រហែលជាអាចទៅរួចដែរ ដែលថាអ្នកទោសឋានៈខ្ពស់ៗត្រូវបានប្រគល់នូវចម្លើយសារភាពផ្សេងទៀតមកឲ្យអាន ។ ពោលគឺថា ប្រសិនបើអ្នកទោស«ក»ឆ្លើយថាបានចូលរួមគំនិតប្រព្រឹត្តអំពើទុច្ចរិត នោះចម្លើយសារភាពរបស់ឈ្មោះ«ក» ហាក់

ដូចជាមានលក្ខណៈពិត ប្រសិនបើឈ្មោះនេះទទួលស្គាល់ថាគាត់ពិតជាសមគំនិតកាលពីអតីតកាលជាមួយឈ្មោះ «ខ» «គ» និង«ឃ»ដែលគេចាប់ខ្លួន និងយកទៅសម្លាប់ចោលប៉ុន្មានខែមុនមែន ។ ជាក់ស្តែង បែន ឆែ ដែលត្រូវបានសួរចម្លើយនៅភូមិភាគបូព៌ាកាលពីខែមិថុនា ឆ្នាំ១៩៧៧ មុនពេលនាំមកមន្ទីរស-២១នោះ ត្រូវបានជំរុញឲ្យរៀបរាប់ឈ្មោះ «មនុស្សម្នាក់ដែលអង្គការចាប់ខ្លួនរួចហើយ» ។ បែន ឆែ និយាយថា អ្នកសួរចម្លើយ «បន្តទៀតថា អ្នកណាដែលខ្ញុំអាចនឹកឃើញថាត្រូវគេចាប់ខ្លួនរួចហើយនៅតំបន់ឬភូមិភាគណាមួយក៏បាន ពេលនោះខ្ញុំអាចនិយាយថា អ្នកទាំងនោះគឺពិតជាខ្សែរយៈរបស់ខ្ញុំទាំងអស់» ។[២៥]

ជាទូទៅសម្រាប់អ្នកធ្វើការនៅមន្ទីរស-២១ «ការធ្វើនយោបាយ»វាពិបាកជាងវាយដំអ្នកទោសទៅទៀត ។ បញ្ហាមួយគឺថា «បង១ថ្នាក់លើ» ដែលជាអ្នកទទួលចម្លើយសារភាពមិនអាចសុំយោបល់បានឡើយ ។ ជាងនេះទៀត អ្នកសួរចម្លើយមានការហ្វឹកហាត់តិចតួចណាស់ ហើយពត៌មានក៏មិនសូវបានទទួលទៀត ។ អ្នកទោសតែងតែភ័យខ្លាច ប៉ុន្តែកម្រចេះជួយគ្នាណាស់ ។ ជាក់ស្តែងសំណេរនៅក្នុងសៀវភៅកំណត់ហេតុទុយ ប៉ុន និយាយថា ទំនាក់ទំនងរវាងអ្នកទោសនិងអ្នកសួរចម្លើយមានលក្ខណៈតំរាមកំហែងជាប់ជានិច្ច ហើយមិនអាចសម្របសម្រួលគ្នាបានទេ ក្នុងពេលដែលអំពើហិង្សាត្រូវបានស្នើឡើងហើយនោះ ។ «ចំពោះបញ្ហាសួរចម្លើយខ្មាំងអំពីចំណុចខ្លាំងរបស់វា គឺថាយើងមិនដឹងរឿងវាទេ ដូច្នេះវាអាចនិយាយអ្វីក៏បានស្រេចតែវាចង់និយាយ» ។ «ចំណុចខ្សោយរបស់វា គឺថាវានៅក្នុងដៃរបស់យើង» ។[២៦]

ម្នាក់ៗធ្វើការនៅក្នុងគុក សុទ្ធតែត្រូវហ៊ុមព័ទ្ធដោយភាពឆេវឆាវតាមជំហររបស់បក្សចំពោះ«ខ្មាំង» ។ សៀវភៅកំណត់ហេតុឆ្នាំ១៩៧៦ សរសេរច្បាស់ៗថា÷

> បក្សមានការប្រែប្រួលជាញឹកញាប់ ។ បក្សប្តូរអ្នកទោសឲ្យទៅសួរចម្លើយគ្មានគំរូបែបបទច្បាស់លាស់ទេ ។ បក្សចេញពីក្រុមមួយទៅក្រុមមួយទៀត ហើយជួនកាលប្តូរភារកិច្ចរបស់យើងទៀតផង ។ បក្សក៏បានផ្លាស់ប្តូរវិធីសាស្ត្រធ្វើឯកសារសួរចម្លើយ ធ្វើនយោបាយ ឃោសនា ទារុណកម្ម ។ យើងត្រូវរៀបចំខ្លួនសម្របតាមសភាពការណ៍ឆ្ពោះទៅជំរុញចលនាបីគោនក្នុងមួយហិកតា ។[២៧]

អ្នកសួរចម្លើយនៅមន្ទីរស-២១ តែងតែទទួលសេចក្តីណែនាំយ៉ាងដូច្នេះឯង ។ តើអ្នកសួរចម្លើយធ្វើម្តេចនឹងមានអារម្មណ៍ស្រណុកក្នុងចិត្ត ឬមានសមត្ថភាពគ្រប់គ្រាន់នៅក្នុងខណៈដែលទទួលបញ្ជាឲ្យ «លោតផ្លោះបង្កបង្កើនផលឲ្យបានបីតោនក្នុងមួយហិកតា?» ។ ឈ្មោះ សូ កាង អតីតលេខាតំបន់៣៧ នៅភូមិភាគបស្ចិម និយាយត្រង់ចំណុចនេះខ្លីតែច្បាស់នៅក្នុងចម្លើយសារភាពរបស់គាត់ថា «ប្រសិនបើថ្នាក់លើផ្លាស់ប្តូរអ្វីៗគ្រប់យ៉ាងភ្លាមៗយ៉ាងដូច្នេះ តើឲ្យអ្នកនៅខាងក្រោមតាមម្តេចនឹងទាន់ទៅ» ។[២៨]

ការទទូចរបស់បក្សថា ទ្រឹស្តីមិនឈ្នះការអនុវត្តន៍ មានឥទ្ធិពលក្នុងការធ្វើមិនដឹងមិនឮចំពោះអ្វីៗដែលមានពីមុន និងធ្វើឲ្យអ្វីៗដែលបក្សបានធ្វើ ឬមាននៅក្នុងគំនិតមានភាពស្របច្បាប់ ។ មានតែថ្នាក់ដឹកនាំទេដែលចៀសផុតពីការស្តីបន្ទោស និងផ្លាស់ប្តូរទិសដៅដោយសេរី ។ កម្មាភិបាលខ្មែរក្រហមម្នាក់និយាយទៅកាន់

លោក ស្ទីវ ហេដឌ័រ នៅក្នុងកិច្ចសម្ភាសន៍ធ្វើឡើងនៅតាមព្រំប្រទល់ថៃកាលពីឆ្នាំ១៩៨០ថា÷

> កម្មាភិបាល រឿងអ្វីក៏ដោយក៏ទម្លាក់កំហុសលើគេដែរ ។ គេនិយាយអ្វីៗតាមសភាពជាក់ស្តែង ប៉ុន្តែគេជាអ្នកដែលសន្និដ្ឋានអ្វីដែលជាសភាពជាក់ស្តែង ហើយមានពេលខ្លះបង្កើតសភាពជាក់ស្តែងនេះក៏មាន ។[២៩]

ប្រហាក់ប្រហែលគ្នានេះដែរ សៀវភៅកំណត់ហេតុវគ្គសិក្សាឆ្នាំ១៩៧៦ បានប្រាប់អ្នកសួរចម្លើយឲ្យ «ស្វែងរកនិងកម្ទេចជំហរ»ជឿ ឬមិនជឿអ្វីដែលខ្មាំងបានឆ្លើយ ប៉ុន្តែឲ្យបន្ត«ជឿទាំងស្រុងមកលើបក្សទាក់ទងនឹងបញ្ហាខ្មាំង» ។ វាមិនអាចទៅរួចទេ ព្រោះមិនដឹងថា ជំហររបស់មជ្ឈិម «ទាក់ទងបញ្ហាខ្មាំង» ត្រូវបានលាក់មិនមានអ្នកណាដឹងនោះ ។ អ្នកសួរចម្លើយក៏ត្រូវបានប្រាប់ឲ្យចាត់ការនូវអ្វីដែលអ្នកទោសនិយាយ «ចេញពីជំហរចម្រើន និងជំហរមិនចម្រើន, ពីជំហរបដិវត្តទៅជំហរមិនបដិវត្ត» ។ ជំហរនេះធ្វើឲ្យមេៗអ្នកសួរចម្លើយមានអារម្មណ៍សេរីក្នុងការប្រើល្បិចដើម្បីឲ្យបានអ្វីមួយ ហើយបើកចំហឲ្យអ្នកសួរចម្លើយផ្ទាល់ទម្លាក់កំហុសលើអ្នកទោសដោយសេរី ។ អ្នកសួរចម្លើយត្រូវបានជំរុញឲ្យប្រើទារុណកម្ម និងការឃោសនានៅក្នុងកម្រិតណាមួយដែលមិនឲ្យមើលឃើញច្បាស់ ។

នៅពេលខ្លះ សូម្បីតែ សុន សេន និង ឌុច ក៏មិនដឹងថា ត្រូវចាប់ផ្តើមដោយរបៀបណាដែរ ។ ឧទាហរណ៍ជាក់ស្តែង នៅពេលសរសេរសំបុត្រទៅកាន់ ឌុច នៅខែតុលា ឆ្នាំ១៩៧៧ សុន សេន លើកឡើងថា ឲ្យអ្នកទោសធ្វើអ្វីស្រេចតែគេនឹកឃើញ អាច«ធ្វើឲ្យមនុស្សទាំងអស់ពាក់ព័ន្ធ» ។ សុន សេន បន្ថែមទៀតថា÷

> ក្នុងករណីខ្លះ គ្រប់ចម្លើយត្រូវពិនិត្យសាឡើងវិញដោយប្រុងប្រយ័ត្ន ពីព្រោះមានអ្នកខ្លះវាយប្រហារយើងដូចជាមន្ត្រីធំៗជាដើម ។ អ្នកខ្លះវាយប្រហារឲ្យយើងដឹង ។ ចំណែកឯអ្នកខ្លះទៀតមានការភ័យខ្លាច ហើយមិនហ៊ាននិយាយទេ ។[៣០]

សៀវភៅកំណត់ហេតុវគ្គសិក្សានៅមន្ទីរស-២១ ដែលសរសេរនៅឆ្នាំ១៩៧៨ និយាយថា ខ្មាំងជាច្រើនគឺបង្កប់នៅជាប់ជាមួយមន្ទីរនេះតែម្តង÷

> ការងារសម្រិតសម្រាំងខ្មាំងក្នុងមន្ទីរស-២១ មិនទាន់ដោះស្រាយបាននៅឡើយទេក្នុងចំណោមយុទ្ធជន ឬ កម្មាភិបាល ។ យោធារបស់យើងរៀនសូត្រពីបក្ស ប៉ុន្តែពេលចេញពីរៀនទស្សនៈ គ្មានការផ្លាស់ប្តូរអ្វីសោះ ។ នៅតែញបៗចំពោះបង១ដដែល ។ ពេលគេសម្តុត មិនហ៊ានសម្រាកទេ ហើយមិនហ៊ានសើច ។ ទោះបីជាមានខ្មាំងនៅជុំវិញខ្លួនក៏ដោយ ក៏មិនខំតាមដានវែកមុខដែរ ។[៣១]

ទំនាស់គំរាមកំហែងលើកឡើងនៅក្នុងសៀវភៅនេះច្បាស់ជារំខានដល់អ្នកដែលបានអាននិងពុពីចម្ងាយ

មិនខាន ។ តើធ្វើម្តេចទើបឲ្យអ្នកធ្វើការនៅមន្ទីរស-២១ឯករាជ្យ, មិនរណប ឬមានការសង្ស័យបាន បើអ្នកទាំងនេះស្តាប់បង្គាប់អ្នកនៅពីលើខ្លួនមិនឃ្លាតមួយឃ្លាណាសោះនោះ? បើអ្នកទាំងនោះ «សម្រាកលំហែ» ឬ «ញញឹម» តើមានអ្វីកើតឡើង? តើការវាយប្រហារមកលើ ឌុច, ប៉ុន, និង ចាន់ ជាទម្លាប់ប្រចាំថ្ងៃឬ? តើខ្មាំងដែលចេះមើលឃើញគ្រប់កន្លែងមានដែលរកឃើញជាក់ស្តែងដែរឬទេ?

អ្នកធ្វើការនៅមន្ទីរស-២១ ត្រូវជួបប្រទះឯកសារបែបនេះ និងភាពមិនទៀងទាត់នៃជីវិតពោលគឺបាត់មិត្តភក្តិញាតិសន្តាននិងអ្នកធ្វើការជាមួយជាបន្តបន្ទាប់ ។ ដូចដែល គក ស្រស់ និយាយទៅកាន់ ឌូក្លាស នីវិន ថា÷

> ខ្ញុំចេះតែបាត់មនុស្សដែលធ្វើការជាមួយខ្ញុំជារឿយៗ ។ មានថ្ងៃមួយពេលធ្វើការជាមួយគ្នា សុខៗស្រាប់តែគេមកយកទៅ ។ អ្នកទាំងនោះស្លាប់អស់ ។ ខ្ញុំឆ្ងល់ណាស់មិនដឹងជាហេតុអ្វី ។ ខ្ញុំគិតថាថ្ងៃនេះជាវេនអ្នកទាំងនោះហើយ ។ ខ្ញុំមិនដឹងថា ថ្ងៃស្អែកមានអ្វីកើតឡើងទេ ។[៣២]

អ្នកធ្វើការនៅមន្ទីរស-២១ម្នាក់ៗត្រូវបានជំរុញឲ្យមានការសង្ស័យគ្នាទៅវិញទៅមកដូចដែល ហ៊ឹម ហ៊ុយ បាននិយាយទៅកាន់ ភីតធើ ម៉ាឃ្យៀរ ថា «យើងទាំងអស់គ្នាគិតតែពីតាមដានគ្នាទៅវិញទៅមក» ។ ម្នាក់ៗគិតតែពីមើលបំណាំគ្នាទៅវិញទៅមកគ្រប់ជ្រុងជ្រោយ ។ គ្រួសារទុកម្តុំ មិត្តភាពផ្តល់សន្តិសុខតិចតួចណាស់ ឬ គ្មានផងហើយសិទ្ធិអាចត្រូវដកយកនៅពេលណាក៏បាន ។ គ្រប់សកម្មភាពទាំងអស់សុទ្ធតែជារឿងនយោបាយ ។ ប្រទេសជាតិកំពុងតែមានសង្គ្រាមជាមួយខ្មាំងខាងក្រៅ ចំណែកឯសង្គមជាតិកំពុងតែមានសង្គ្រាមជាមួយខ្លួនឯង ហើយបក្សកំពុងមានសង្គ្រាមជាមួយនឹង «ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង» រីឯប្រជាជនកំពុងធ្វើសង្គ្រាមជាមួយនឹងកំហុសរបស់ខ្លួន ។ រដ្ឋអំណាចនិងភាពស្របច្បាប់របស់អង្គការមិនមានអ្វីគួរឲ្យសង្ស័យ ប៉ុន្តែតាមគោលការណ៍របស់អង្គការគឺថា មានមនុស្សបង្កប់ក្នុងអង្គការដែលខិតខំរិះរកមធ្យោបាយកម្ទេចរដ្ឋអំណាចនេះ ។ បើគិតតាមន័យខ្មាំង គឺមានទាំងមិនស្គាល់ឈ្មោះទាំងស្គាល់ឈ្មោះ មើលឃើញនិងមើលមិនឃើញ នៅខាងក្នុងនិងខាងក្រៅមន្ទីរស-២១ ។ អតីតកម្មាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យម្នាក់បាននិយាយប្រាប់ ស៊ីវ ហេងឌ័រ កាលពីឆ្នាំ១៩៨០ ដោយនិយាយថា «នៅក្នុងជំនាន់កម្ពុជាប្រជាធិបតេយ្យមនុស្សមានសតិអារម្មណ៍មិនស្រួលទេ ។ ម្នាក់ៗខ្លាចធ្វើខុសដោយមិនដឹងខ្លួន ឬ ត្រូវអ្នកដទៃចង្អុលមុខ ។ យើងចេះតែញញឹមៗទៅ តែតាមពិតតឹងចិត្តណាស់» ។[៣៣]

ចម្លើយសារភាពដែលនៅសេសសល់ពីមន្ទីរស-២១ មានលក្ខណៈផ្សេងៗគ្នា ទាំងប្រវែង ទាំងភាពពេញលេញ និង ប្រយោជន៍ ។ តាមការប៉ាន់ស្មានត្រួសៗឃើញថា មានបួនភាគរយនៃចម្លើយសារភាពដែលបានថតចម្លងចូលម៉ាស៊ីនមីក្រូហ្វីល និងមួយភាគតូចដែលតម្កល់ទុកនៅបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺមួយច្បាប់មានមិនលើសពីបីទំព័រឡើយ ។ ចម្លើយទាំងនេះ ភាគច្រើនត្រូវបានសរសេរឡើងក្រោយពេលដែលអ្នកទោសត្រូវបានបញ្ជូនមកដល់មន្ទីរស-២១ភ្លាមមុនពេលយកទៅសួរចម្លើយ ។

ជាទូទៅ ចម្លើយសារភាពមានទិន្នន័យប្រវត្តិរូបតាមលំដាប់លំដោយពីដើមដល់ចប់ និងមិនមាននិយាយអំពីទោសកំហុសឡើយ ។ នៅក្នុងករណីខ្លះ ក្រដាសទិន្នន័យត្រូវបានពិនិត្យនិងចារថា «គ្មានប្រយោជន៍ទេ បោះវាចោលទៅ» ។ តាមរយៈឯកសារដែលសេសសល់ ការបញ្ជាឲ្យ «បោះចោល» អាចនិយាយយោងដល់អ្នកទោសផ្ទាល់តែម្តង ។ «បោះចោល» គឺជាពាក្យសម្រាប់សម្រាលន័យដែលប្រើនៅមន្ទីរស-២១ ជំនួសឲ្យពាក្យ «សម្លាប់» ។[៣៤] ចម្លើយសារភាពចំនួន២.០១៣ច្បាប់ ក្នុងចំណោមចម្លើយសារភាពដែលថតចម្លងចូលម៉ាស៊ីនមីក្រូហ្វីល ឬស្មើនឹងពាក់កណ្តាលឯកសារបណ្ណសារដែលថតចម្លងរួចហើយដែលបានមកក្រោយពីការសួរចម្លើយមួយដង និងឯកសារចម្លើយសារភាពដែលនៅសល់ ក្រៅពីនោះត្រូវបានសរសេរចេញដោយកម្មាភិបាលជាលក្ខណៈកែសម្រួលបន្តបន្ទាប់ ដែលជួនកាលមានសរសេររហូតរាប់សប្តាហ៍ ឬរាប់ខែទម្រាំតែរួចរាល់ ។ ចម្លើយសារភាពភាគច្រើនរបស់បណ្ណសារដែលថតចម្លងរួចហើយ និងតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានកម្រាស់ពីដប់ទៅសែសិបសន្លឹក ។ អ្នកទោសដែលខ្ញុំហៅថា «កម្មាភិបាល» ដែលមានអាយុលើសពីសាមសិបឆ្នាំនិងមាននាមក្លែង ច្រើនតែសរសេរចម្លើយសារភាពរបស់ខ្លួនរាប់រយសន្លឹកឯណោះ ។[៣៥]

ដោយពេលវេលាចេះតែរំកិលទៅមុខ ទ្រង់ទ្រាយនិងសភាពដើមរបស់ឯកសារចម្លើយសារភាពក៏បានផ្លាស់ប្តូរទៅតាមនោះដែរ ។ ឯកសារមួយចំនួនត្រូវបានសរសេរឡើងដោយអ្នកទោស ហើយឯកសារដែលសរសេរឡើងនៅមុននេះបន្តិច គឺជារបស់អ្នកទោសផងនិងអ្នកសួរចម្លើយផង ប៉ុន្តែចម្លើយសារភាពដែលសរសេរដោយដៃភាគច្រើនត្រូវបានចម្លងចេញពីខ្សែអាត់ថតសំឡេងឬកំណត់ហេតុផ្សេងៗដោយអ្នកសួរចម្លើយនិងអ្នកធ្វើការនៅក្នុងគុក ។ គ្មានខ្សែអាត់ថតសំឡេងណាមួយដែលប្រហែលជាមានទាំងសំណួរផងនៅសេសសល់ឡើយ ។ ចម្លើយសារភាពមួយចំនួនគឺជាសេចក្តីព្រាងលើកទីមួយដែលមានការថែមថយកែសម្រួលដោយអ្នកទោស អ្នកផ្ញើឯកសារ ឬកម្មាភិបាលជាន់ខ្ពស់ ។ ជួនកាលសេចក្តីព្រាងមួយចំនួននៅមានសល់ដោយវាយជាអង្គុលីលេខរួចជាស្រេច ចំណែកមួយចំនួនទៀតមានចំណារថា «កុំប្រើ» ឬ «កុំសង្ខេប» ដែលប្រហែលជាមិនដែលត្រូវបានយកចេញពីគុកឡើយ ។ អត្ថបទចម្លើយសារភាពពីឆ្នាំ១៩៧៦ រួមមានសំណួរដែលសរសេរឡើងដោយដៃអ្នកសួរចម្លើយផ្ទាល់ដូចជា ឌុច[៣៦] បានសរសេរពីរលើក សួរទៅអ្នកទោស ។ ប៉ុន្តែ ស្ទើរតែគ្រប់សំណួរនិងការឲ្យជាយោបល់ទាំងអស់មិនមាននៅសេសសល់ទាល់តែសោះ ។

នៅត្រឹមឆ្នាំ១៩៧៨ ចម្លើយសារភាពភាគច្រើនត្រូវបានវាយអង្គុលីលេខទាំងអស់ ។ ចម្លើយសារភាពជាច្រើនត្រូវបានផ្ញើជាច្រើនច្បាប់ហើយកិបចូលគ្នាជាសៀវភៅស្តើង ។ យើងដឹងតាមរយៈសៀវភៅសរសេររបស់ ឌុយ, ប៉ុន ថា នៅត្រឹមឆ្នាំ១៩៧៨ ចម្លើយសារភាពសំខាន់ៗចំនួនប្រាំមួយច្បាប់ត្រូវបានរៀបចំជាធម្មតា ។ មានពីរច្បាប់ត្រូវបានផ្ញើទៅកាន់«អង្គការ» ហើយនៅសល់ពីនោះត្រូវបានផ្ញើទៅឲ្យអតីតអង្គភាពការងាររបស់គុក ឲ្យមន្ទីរសន្តិសុខគុក និងដៃគូដែលជាមន្ទីរពាក់ព័ន្ធនៅតាមភូមិភាគ ។ ឯកសារទីប្រាំមួយត្រូវបានថែរក្សាទុកនៅបណ្ណសារនៃមន្ទីរស-២១ ។[៣៧]

ចម្លើយសារភាពមុនៗជាច្រើននៅមន្ទីរស-២១ គឺជាបណ្តុំរបាយការណ៍នគរបាលកម្ពុជាមុនបដិវត្តន៍ ។

ដោយប្រើប្រាស់ប្រព័ន្ធនៃការសួរសំណួរផ្ទាល់មាត់របស់បារាំង ឯកសារទាំងនេះមានកត់ត្រាការផ្តើមគំនិតរបស់អ្នកទោសដែលជាទូទៅជាការប្រកាសចោទប្រកាន់ខ្លួនឯង ។ ចម្លើយសារភាពជាច្រើនទៀតបានធ្វើឡើងទៅតាមលក្ខណៈពិសេសនៃសម័យអាណានិគមបារាំងដូចជា សរសេរកាលបរិច្ឆេទដោយអក្សរមិនមែនដោយលេខជាដើម ។ល ។ ចម្លើយសារភាពភាគច្រើននៅមន្ទីរស-២១ ត្រូវបានបញ្ជាក់ដោយការចុះហត្ថលេខា ឬ ផ្តិតមេដៃនិងមានចុះថ្ងៃខែដោយអ្នកទោសនៅលើសន្លឹកនីមួយៗ ។ នៅពេលដែលអ្នកសួរចម្លើយសរសេរចេញជាចម្លើយសារភាព តែងតែមានការបញ្ជាក់ដោយអ្នកទោសនិងចុះហត្ថលេខាបញ្ជាក់មួយទៀតដោយបុគ្គលិកឯកសារដែលមានវត្តមាននៅពេលសួរចម្លើយ ។ ទម្រង់លម្អិតរបស់ចម្លើយសារភាព និងឯកសារផ្សេងៗបង្ហាញថា ឌុច និងសហការីមានមោទកភាពចំពោះភាពហ្មត់ចត់ ភាពទំនើបនិងប៉ិនប្រសប់របស់ខ្លួនណាស់ ។ បុគ្គលិកនៅមន្ទីរស-២១ ចង់ឲ្យមន្ទីរនេះក្លាយទៅជាកន្លែងសួរចម្លើយគំរូនិងចាត់ទុកខ្លួនឯងជាអ្នកជំនាញការសន្តិសុខពិតៗ ។[៣៨]

យើងដឹងតិចតួចណាស់អំពីដំណើរការសួរចម្លើយទៅលើអ្នកទោសនៅពេលមកដល់ ឬ អំពីរបៀបដែលអ្នកសួរចម្លើយត្រូវនិយាយប្រាប់សង្ខេបៗពីមួយថ្ងៃទៅមួយថ្ងៃ ប៉ុន្តែទម្រង់ផ្សេងៗដែលទាក់ទងទៅនឹងអ្នកទោសដប់ប្រាំបួននាក់ក្រោមការសួរចម្លើយនៅក្នុងខែសីហា កញ្ញា និង ខែធ្នូ ឆ្នាំ១៩៧៦ ដែលទម្រង់មួយផ្នែក ត្រូវបានរកឃើញ បង្ហាញឲ្យដឹងអំពីដំណើរការទាំងអស់នេះ ។[៣៩] សំណួរជាគោលគឺសួររកឈ្មោះពិតរបស់អ្នកទោស ឈ្មោះប្រែ អង្គភាពធ្វើការ និងខ្សែបណ្តាញ ។ ក្រោយមកក៏ចេញជាសេចក្តីសង្ខេតសរសេរដោយដៃ ដាក់សំណួរដែលត្រូវបានសួររួចហើយនៅថ្ងៃនោះ ហើយដាក់សំណួរមួយចំនួនទៀតសម្រាប់សួរនៅពេលក្រោយមកទៀត ។ ចំពោះអ្នកទោសជាច្រើននាក់ ទម្រង់បែបបទនៃការសួរចម្លើយលើអ្នកទោសម្នាក់ៗដែលនៅសល់គឺមានរហូតទៅដល់ប្រាំមួយដងជាប់ៗគ្នា ។ កំណត់ត្រារបស់អ្នកសួរចម្លើយអំពីសុខភាពរបស់អ្នកទោស (មានប្រាំនាក់ «ខ្សោយ» ហើយបីនាក់ទៀត «ធម្មតា») គឺបង្ហាញថា អាចមាន ឬ គ្មានការធ្វើទារុណ-កម្ម (នៅក្នុងករណីនេះគ្មានទេ) ហើយកត់សម្គាល់អំពីសភាពខ្នោះឃ្នាងអ្នកទោសនិងសោសម្រាប់ចាកចេញ ។ មានករណីមួយ អ្នកសួរចម្លើយសង្កេតឃើញថា អ្នកទោសបានសរសេរចម្លើយសារភាពរបស់ខ្លួន រហូតទៅដល់ដប់ទំព័រមុនថ្ងៃសួរចម្លើយទៅទៀត ។[៤០]

នៅចុងឆ្នាំ១៩៧៦ ឯកសារចម្លើយសារភាពភាគច្រើននៅមន្ទីរស-២១ មានបួនផ្នែកផ្សេងគ្នាដែលនៅសល់រហូតមកដល់ការដួលរលំនៃរបបនេះ តែមានការកែប្រែខ្លះៗ ។ នៅក្នុងផ្នែកទីមួយអ្នកទោសបានរៀបរាប់ពី «រឿងរ៉ាវជីវិត» ប្រាប់ឈ្មោះញាតិសន្តាននិងបក្ខពួក ហើយរាយឈ្មោះអង្គភាពដែលខ្លួនបានធ្វើការ ។ ប្រវត្តិរូបផ្ទាល់ខ្លួនទាំងនេះ ជាទូទៅមានរៀបរាប់ពីក្រោមនូវផ្នែកមួយដែលដាក់ថា «ប្រវត្តិសកម្មភាពក្បត់» ឬ «ប្រវត្តិនយោបាយ» របស់ខ្ញុំដែលមានរៀបរាប់តាមលំដាប់លំដោយ ។ ផ្នែកទីបីដែលដាក់ថា «ផែនការ» បានរៀបរាប់អំពីអ្វីដែលអ្នកទោសអាចធ្វើបាន ប្រសិនបើមិនត្រូវបានចាប់ខ្លួន ។ ចម្លើយសារភាពភាគច្រើនបញ្ចប់ទៅដោយតារាងរាយឈ្មោះបក្ខពួក ឬ «ខ្សែ» ក្បត់របស់អ្នកទោសដែលមានបញ្ជាក់ប្រាប់ពីកន្លែងលាក់ខ្លួនទៀតផង ។ នៅក្នុងករណីខ្លះ «ខ្សែ» រួមមានឈ្មោះអ្នកដែលត្រូវបានរៀបរាប់

នៅក្នុងចម្លើយសារភាពទោះជាអ្នកនោះបានស្លាប់ហើយក៏ដោយ ។

ប្រវត្តិរូបផ្ទាល់ខ្លួនត្រូវបានរៀបចំឲ្យសរសេរតាមរបៀបកុម្មុយនិស្តពិសេស ។[៤១] មុនឆ្នាំ១៩៧៥ ការរៀបរាប់ដំណើរដើមទងអំពីប្រវត្តិផ្ទាល់ខ្លួនកម្រមានណាស់នៅក្នុងប្រទេសកម្ពុជា ហើយរបៀបសរសេរក៏មិនមានលក្ខណៈពិសេសដែរ ។ ប៉ុន្តែនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដូចនៅក្នុងប្រទេសកុម្មុយនិស្តផ្សេងៗទៀត ការរៀបរាប់ប្រវត្តិរូបផ្ទាល់ខ្លួនដែលមានទាំងស្វ័យទិតៀនរបស់សមាជិកបក្ស ត្រូវបានរើសយកមកម្តងហើយម្តងទៀតផ្ទៀងផ្ទាត់និងទុកជាឯកសារ ។ ការសរសេរប្រវត្តិរូបនិងការយកមកប្រើប្រាស់យូរៗម្តងជាឯកសារបង្ហាញផ្លូវ ហាក់ដូចជាមានសារសំខាន់ណាស់នៅក្នុងបក្សកុម្មុយនិស្តចិននិងវៀតណាមជាងនៅកន្លែងផ្សេងៗទៀត ។ ការអនុវត្តរបៀបនេះត្រូវបានយកមកប្រើប្រាស់យ៉ាងទូលំទូលាយនៅប្រទេសចិនក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៤០ ។[៤២]

នៅប្រទេសកម្ពុជាប្រវត្តិស្វ័យទិតៀនត្រូវបានលើកឡើងនៅក្នុងការ «ប្រជុំជីវភាព» ធម្មតា ។ អ្នកមិនមែនកុម្មុយនិស្តជាច្រើនបានជួបប្រទះបែបបទនេះជាលើកដំបូងពេលដែលខ្លួនត្រូវបានជម្លៀសចេញពីទីរួមខេត្តនិងទីក្រុងនៅក្នុងខែមេសា ឆ្នាំ១៩៧៥ ហើយឲ្យសរសេរនៅតាមចំណុចត្រួតពិនិត្យតាមផ្លូវធ្វើដំណើរ ។ នៅពេលដែលដំណើរការនេះបានក្លាយទៅជាទម្លាប់ទូទាំងប្រទេសនៅឆ្នាំ១៩៧៦ ប្រជាជនត្រូវបានឲ្យដាក់ឈ្មោះសមាជិកគ្រួសារនិងអ្នកធ្វើការជាមួយ រៀបរាប់ពីធាតុវណ្ណៈដើម សកម្មភាពនយោបាយនិងកត់សម្គាល់ពីចំណុចខ្លាំងនិងចំណុចខ្សោយរបស់ខ្លួន ។ ចុងក្រោយអ្នកចូលរួមប្រជុំជីវភាពទាំងអស់ត្រូវបានឲ្យបញ្ចេញយោបល់ដើម្បីកែប្រែខ្លួននិងអាកប្បកិរិយាតាមវិធីផ្សេងៗ ។[៤៣]

ការបើកកកាយរឿងខ្លួនឯងនេះដែលមានបញ្ឈាក់នៅក្នុងសង្គមសម្ងាត់ជាច្រើន គឺក្នុងគោលបំណងធ្វើវិសុទ្ធកម្មអ្នកចូលរួមក្រុម ពង្រឹងសាមគ្គីភាពនៅក្នុងក្រុម និងបង្ហាញពីការកត់សម្គាល់និងប្រុងប្រយ័ត្នរបស់អង្គការ ។ ចំពោះសមាជិកបក្សវិញ បក្សបានជំនួសអង្គការ ។ ដេវីដ អាប់ធ័រ និង ថូនី សៃ បានរៀបរាប់អំពីបទពិសោធន៍នៃស្វ័យទិតៀននៅក្នុងប្រទេសចិនដែលលែងកាន់លទ្ធិម៉ៅថា «បុគ្គលម្នាក់ៗចាប់ផ្តើមនិយាយឡើង គឺអំពីកំហុសនិងភាពសៅហ្មងរបស់ខ្លួន ហើយការលើកលែងមិនបោសសម្អាតចំពោះអំពើទាំងនេះជាការសំខាន់ណាស់ដែលនាំទៅដល់ការភ្ញាក់រឭក មិនត្រឹមតែសម្រាប់អ្នកឡើងនិយាយនេះទេ ប៉ុន្តែសំខាន់សម្រាប់សមូហភាពទាំងមូលតែម្តង ក្រែងលោថ្ងៃក្រោយទៅមានភាពល្អក់កករ ។ គំនិតមិនល្អនាំឲ្យល្អក់កករ និងវិសុទ្ធកម្មត្រូវបានកែតម្រង់តាមកន្លែងខ្លះប៉ុណ្ណោះគឺមិនធ្វើជាទូទៅទេ» ។[៤៤] ដូច្នេះប្រវត្តិរូបទាំងនេះដែលត្រូវបានចម្រាញ់ចេញមក ក៏អាចយកទៅប្រើប្រាស់ជាភ័ស្តុតាងពាក់ពន្ធ័កំហុស ឬសម្រាប់តម្លើងឋានៈដែរ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មនុស្សម្នាក់ៗសុទ្ធតែត្រូវបានជម្រះទោសឥតឈប់ឈរ ។ ភាពគួរឲ្យទុកចិត្តអាចចុះថយ ប្រសិនបើពត៌មាននៅក្នុងប្រវត្តិរូបត្រូវបានរកឃើញថា មិនពេញលេញ ខុស «ស្មុគស្មាញ» ឬ មិនត្រឹមត្រូវ ។ ផ្ទុយមកវិញ ប្រវត្តិរូបដែល «ល្អ» ដែលមានធាតុវណ្ណៈដើម «ល្អ» និងសកម្មភាពគួរឲ្យសរសើរ អាចនាំដល់ការបញ្ចូលជាសមាជិកភាពរបស់បក្ស ចាត់តាំងការងារប្រសើរជាងមុន និងពង្រឹងសន្តិសុខផ្ទាល់ខ្លួន ។ គក ស្រស់ បាននិយាយថា គាត់បានឡើងឋានៈនៅក្នុងជួរបក្ស

(គាត់បានក្លាយជាសមាជិកបក្សពេញសិទ្ធិនៅឆ្នាំ១៩៧៨) ដោយសារគាត់ធ្វើការងារសកម្ម និងមាន «ប្រវត្តិរូបល្អ» ។ ញ៉ែម អេន អ្នកថតរូបនៅមន្ទីរស-២១ ក៏បានអះអាងប្រហាក់ប្រហែលគ្នានេះដែរ ។[៨៥]

នៅដំណាក់កាលនោះ ប្រវត្តិរូបត្រូវបានសរសេរឲ្យស្របតាមតម្រូវការរបស់បក្ស គឺសរសេរដោយផ្ទៀងផ្ទាត់ជាមួយនឹងប្រវត្តិបក្សចាប់ពីពេលផ្ដើមសរសេរ និងផ្ទៀងផ្ទាត់ជាមួយនឹងតម្រូវការជាយុទ្ធសាស្ត្រដែលចេះតែផ្លាស់ប្ដូរឥតឈប់ឈរ ។ វគ្គសិក្សានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានបញ្ជាក់អំពីសារសំខាន់នៃការរៀបចំប្រវត្តិរូបឲ្យបាន «ស្អាត» ហើយអ្នកអានទស្សនាវដ្ដី «ទង់បដិវត្ត» ត្រូវបានព្រមានថាកុំឲ្យទាក់ទងជាមួយនឹងមនុស្សដែលមានប្រវត្តិរូបស្មុគស្មាញ ។ មួយរយៈក្រោយមក នៅឆ្នាំដដែលនៅពេលនិយាយថា ខ្មាំងនៅក្នុងជួរបក្សគឺជា «មេរោគ» ប៉ុល ពត បានប្រាប់ទៅកូនចៅរបស់ខ្លួនថា «ប្រវត្តិរូបជីវិតត្រូវតែល្អនិងសមស្របតាមតម្រូវការរបស់យើង» ។[៨៦]

កម្មាភិបាលជាន់ខ្ពស់បានជ្រើសរើសយកប្រវត្តិរូបមួយចំនួនរបស់កូនចៅនៅក្រោមបញ្ជាមកមើល ។ នួន ជា បានសម្ដែងនូវការសោកស្ដាយរបស់ខ្លួនដែលមិនសូវបានយកចិត្តទុកដាក់ក្នុងរឿងនេះថា÷

> ចំណុចខ្វះខាតរបស់ខ្ញុំ គឺថាខ្ញុំមិនបានតាមដានឯកសារប្រវត្តិរូបរបស់បក្ស និងសមាជិកស្នូលឲ្យបានលម្អិត ហើយចាត់វិធានការបោសសម្អាតនៅក្នុងជួរបក្សទេ ។ ខ្ញុំមើលតែសកម្មភាពទូទៅរបស់គេប៉ុណ្ណោះ ខ្ញុំមិនអាចក្ដាប់ធាតុដើមដែលមានសារសំខាន់របស់គេទេ ខ្ញុំមិនបានជីកឫសជីកគល់រឿងគ្រួសារគេ ។ នេះធ្វើឲ្យខ្មាំងមានឱកាសយ៉ាងងាយ ក្នុងការជ្រៀតចូលស៊ីរូងផ្ទៃក្នុងបក្ស ។[៨៧]

នៅឆ្នាំ១៩៧៧ ប្រជាជនកម្ពុជារាប់សែននាក់ក៏ដូចជាសមាជិកបក្សបានសរសេរប្រវត្តិរូបផ្ទាល់ខ្លួន ។ មានរាប់ពាន់នាក់បានសរសេរប្រវត្តិរូបលើសពីមួយ ។ មានប្រវត្តិរូបចំនួនជាងពីររយច្បាប់ដែលរៀបចំដោយបុគ្គលិកមន្ទីរស-២១ នៅសេសសល់ក្នុងទម្រង់ជាសៀវភៅស្ដើងដែលត្រូវបានយកមកប្រើប្រាស់នៅទូទាំងប្រទេស ។ សៀវភៅប្រវត្តិរូបស្ដើងទាំងនេះមានបញ្ជីសំណួរដែលដូចគ្នាទៅនឹងផ្នែកប្រវត្តិរូបនៅក្នុងចម្លើយសារភាពហើយទម្រង់សំណួរនៅក្នុងសៀវភៅនេះបង្កើតបានជាមូលដ្ឋានសម្រាប់ការសួរចម្លើយជាច្រើន ។

បញ្ជីសំណួរបើកចំហដោយសួរអំពីឈ្មោះសាមីជន ឈ្មោះបដិវត្តប្រសិនបើមាន ថ្ងៃ-ខែ-ឆ្នាំកំណើត ទីកន្លែងកំណើត ភេទ ជនជាតិ ឬជាតិពន្ធ និងរៀបការ ឬនៅលីវ ។ ចំណុចបន្ទាប់ទៀតដែលនិយាយពី «របររកស៊ីនិងវណ្ណៈភាពដើមមុនពេលចូលបដិវត្តន៍» ត្រូវបានយកមកប្រើដើម្បីកំណត់វណ្ណៈភាព ។ ប្រជាជនរស់នៅទីក្រុងមុនបដិវត្តន៍ដែលស្គាល់ថាជា «ប្រជាជនថ្មី» ក្រោយឆ្នាំ១៩៧៥ ត្រូវបានចាត់ចូលប្រភេទជា «អ្នករាជានិយម» «មូលធននិយម» ឬ «អនុធន» ។ ប៉ុន្តែចំណាត់ថ្នាក់វណ្ណៈសម្រាប់ប្រជាជនជនបទវិញ គឺនិយាយអំពីទ្រព្យសម្បត្តិជាសម្ភារដែលត្រូវបានគិតតាមមូលដ្ឋានដីធ្លីដែលមានសម្ភារសម្រាប់សង់ផ្ទះ ចំនួនសមាជិកក្នុងបន្ទុក និងចំនួនបសុសត្វ ដូចជា គោ រទេះ និងសម្ភារធ្វើស្រែចម្ការដែលគ្រួសារនេះមាន ។

ជាក់ស្តែង សួស ធី ប្រធានក្រុមផ្ទៀងកសារនៅមន្ទីរស-២១ សរសេរនៅក្នុងប្រវត្តិរូបខ្លួនថា "កសិករថ្នាក់កណ្តាល" ចំណែកឯ ហ៊ឹម ហ៊ុយ ដាក់ថា "កសិករកណ្តាលថ្នាក់ក្រោម" ។[៣៨] នៅក្នុងចម្លើយសារភាពតែងតែភ្លេចនិយាយអំពីវណ្ណៈភាព ប្រហែលដោយសារធាតុវណ្ណៈ "ល្អ" ត្រូវបានលុបបំបាត់ ឬ ធាតុវណ្ណៈ "អាក្រក់" លេចឡើងតាមរយៈសកម្មភាពក្បត់របស់អ្នកទោស ។[៣៩]

មុនឆ្នាំ១៩៧៥ មានប្រជាជនមួយចំនួនតូចដែលស្ថិតនៅក្រោចលនាកុម្មុយនិស្តសម្ងាត់បានធ្វើការវិភាគធាតុវណ្ណៈ ។ ប៉ុន្តែភាគច្រើននៃអ្នកទាំងនេះបានធ្វើការបែងចែងជាទូទៅថា អ្នកណាខ្លះត្រូវស្ថិតនៅក្នុងក្រុម"អ្នកមាន" "អ្នកមធ្យម" និង "អ្នកក្រ" ទៅតាមក្រុមមនុស្សដែល"ប្រើ" "អ្នកជា" និង "អ្នកបម្រើ" ។[៤០]

សក្តានុពលបដិវត្តនិងតម្លៃខាងក្នុងរបស់ជនជាតិកម្ពុជា ត្រូវបានគិតថា ជាការបង្ហាញឲ្យឃើញពីធាតុវណ្ណៈ ។ អ្នកដែលមានធនធានតិចតួចមាន "ដំណើររឿងជីវិត" យ៉ាងល្អបំផុតហើយប្រហែលជាមានឋានៈខ្ពស់ទៀតផង ។ ផ្ទុយទៅវិញ អ្នកដែលមានទំនាក់ទំនងឬកម្មសិទ្ធច្រើនគឺមានប្រវត្តិរូប "ស្មុគស្មាញ" ហើយក្លាយជាសត្រូវដ៏ធំ ។ ធាតុវណ្ណៈរបស់ "បងៗថ្នាក់លើ" ត្រូវបានលាក់យ៉ាងជិតមិនឲ្យអ្នកណាដឹងឡើយ ។ ភាគច្រើននៃអ្នកទាំងនោះលើកលែង តាម៉ុក ចេញដែលជាករណីពិសេសសុទ្ធតែមានប្រភពចេញមកពីស្រទាប់អនុធន ។ បងៗថ្នាក់លើបានរៀបចំប្រវត្តិរូបស៊ុយទិតៀនដោយខ្លួនឯង ប៉ុន្តែដោយសារខ្លួនបានដឹកនាំប្រទេសសម្រេចបានជ័យជម្នះនៅឆ្នាំ១៩៧៥ ជាការច្បាស់ណាស់ អ្នកទាំងនោះក៏លុបបំបាត់ចោលនូវស្នាមទុយ៍សរបស់ខ្លួនកាលពីអតីតទាំងអស់ ។ នៅក្នុងការស្វែងរកការត្រាស់ដឹងដែលមានរយៈពេលមួយជីវិត តាមជាក់ស្តែង បងៗថ្នាក់លើបានទៅដល់ក្បែរៗនៃព្រះនិព្វានដែលជាកន្លែងត្រាស់ដឹងដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះពុទ្ធ (ដែលខ្លួនឯងបានមើលងាយមើលថោកនោះ) ។ មិនខុសពីសាវ័ករបស់ព្រះពុទ្ធទេ បងៗថ្នាក់លើត្រូវបានផ្តល់គ្រឿងបរិក្ខារសម្រាប់ជួយអ្នកដទៃឲ្យឈានដល់ព្រះនិព្វានដូចគ្នា ។ នៅក្នុងន័យនេះវាជាការចាប់អារម្មណ៍ដែរ ដែល ហូ ជីមិញ ជ្រើសរើសរហស្សនាមខ្លួនឯងថា អ៊ឹហូ នៅឆ្នាំ១៩៤៣ មុនពេលចូលបញ្ជា "រំដោះ" ប្រទេសវៀតណាម ។

សំណួរបន្ទាប់មកទៀតនោះគឺសួរឲ្យអ្នកទោសឆ្លើយរាយឈ្មោះសមាជិកនៅក្នុងជួរ"អង្គការនយោបាយមិនបដិវត្តន៍" ។ បុគ្គលិកមន្ទីរស-២១ ដែលខ្ញុំបានមើលបញ្ជីសំណួរនោះសរសេរថា"គ្មាន" ។ ប៉ុន្តែអ្នកទោសត្រូវបានជំរុញឲ្យឆ្លើយនៅត្រង់ចំណុចនេះ ដើម្បីសារភាពថាមានទំនាក់ទំនងជាមួយនឹងរបប លន់ ណុល ជាមួយគណបក្សដែលប្រឌិតឡើង ឬដែលបាត់ស្រមោលទៅហើយនិងជាមួយភ្នាក់ងារសម្ងាត់បរទេសផ្សេងៗទៀត ។ សំណួរបន្ទាប់មកទៀត គឺថា តើចូលបដិវត្តន៍នៅពេលណា? ។ ដំណើរការនេះតាមការស្មានប្រហែលមានពិធីសច្ចាប្រណិធានចំពោះមុខអង្គការនិងសម្តែងពីបំណងចង់កាន់អាវុធផងក៏មិនដឹង ។ នៅក្នុងសំណួរស្ទើរតែទាំងអស់និងចម្លើយសារភាពភាគច្រើន ពាក្យថា ចូលបដិវត្តន៍គឺដូចគ្នាទៅនឹងចូលធ្វើកងទ័ពខ្មែរក្រហមក្នុងចន្លោះឆ្នាំ១៩៧០ - ១៩៧៥ដែរ ។ ក្រោយពេលកត់ត្រាកាលបរិច្ឆេទរួចហើយ បុគ្គលិកធ្វើការនៅមន្ទីរស-២១ និងអ្នកទោសមានឋានៈតូចតាចបានដាក់ឈ្មោះអ្នកដែលធានាខ្លួនឲ្យចូលបម្រើការងារ[បដិវត្ត] ។ ជាទូទៅ អ្នកធានាច្រើនតែជាអ្នកធ្វើការនៅតាមភូមិឃុំ ឬកម្មាភិបាលយុទ្ធជន ។

សំណួរបន្ទាប់មកទៀតគឺទុកចន្លោះឲ្យសរសេរអំពី «មូលហេតុចូលបដិវត្តន៍» ។ នៅក្នុងចម្លើយសារភាពចំណុចនេះតែងតែត្រូវភ្លេចបំពេញ ។ ប៉ុន្តែផ្ទុយទៅវិញ បន្ទាប់ពេល «ចូលបដិវត្តន៍» បន្តិចក្រោយមក អ្នកទោសភាគច្រើនតែងសារភាពថា បានចូលបម្រើ សេ.អ៊ី.អា ឬអង្គការបរទេសផ្សេងទៀត ។ ប៉ុន្តែមិនគួរឲ្យជឿសោះថា ពិធីបញ្ចូលសេ.អ៊ី.អា ដែលអ្នកទោសបានរៀបរាប់ប្រាប់មានលក្ខណៈដូចគ្នាទៅនឹងប្រការផ្សេងៗដែលចែងនៅក្នុងលក្ខន្តិកៈបក្សក្នុងការចូលបម្រើបក្សកុម្មុយនិស្តកម្ពុជា ។ អ្នកទោសនៅចាំថាធ្លាប់បានស្បថសច្ចាប្រណិធាន និងគោរពទង់ជាតិនៅចំពោះមុខអ្នកធានារបស់ខ្លួន ។ ដោយសារមានការបង្ខំឲ្យខ្លួនសារភាពថាបានចូលបម្រើអ្វីដែលខ្លួនមិនធ្លាប់ឮទាល់តែសោះនោះ អ្នកទោសបានត្រឹមតែនិយាយប្រាប់អំពីជំហាននយោបាយតែមួយមុខប៉ុណ្ណោះ ដែលអ្នកទោសមួយចំនួន (ឬអ្នកសួរចម្លើយខ្លួន) ធ្លាប់បានធ្វើកន្លងមក ។[៩១]

អ្នកទោសមួយចំនួនដែលមានវ័យចំណាស់ៗបន្តិចបាននិយាយថា សេ.អ៊ី.អា គឺជាអង្គការរបស់អាមេរិក ។ អ្នកទោសទាំងនោះអះអាងថា ធ្លាប់បានជ្រើសរើសឲ្យបម្រើអង្គការនេះដោយជនជាតិអាមេរិកកាំងផ្ទាល់ ហើយថា ធ្លាប់បានទទួលប្រាក់ខែជាប្រាក់ដុល្លារច្រើនៗទៀតផង ។ ការអះអាងផ្សេងៗទៀតក៏មានលក្ខណៈដូចគ្នានេះដែរ ។ ជាក់ស្តែងឈ្មោះ ដៃ ឌី ដែលត្រូវបានចាប់ខ្លួននៅភូមិភាគឧត្តរក្នុងខែមិថុនាឆ្នាំ១៩៧៦ បានពិពណ៌នាត្រួសៗអំពីប័ណ្ណសំគាល់ខ្លួន ។ ដៃ ឌី និយាយថា ប័ណ្ណនេះគាត់បានទទួលកាលពីក្នុងសម័យ លន់ ណុល ដែលមានចុះហត្ថលេខាពី «ប្រធានសេ.អ៊ី.អា» ប្រចាំនៅទីក្រុងភ្នំពេញឈ្មោះ ចន ដេវីន ។[៩២] អ្នកទោសម្នាក់ទៀតនិយាយថា ខ្លួនធ្លាប់ត្រូវបានជ្រើសរើសដោយជនជាតិអាមេរិកាំងម្នាក់ឈ្មោះ «កេនណេឌី» នៅទសវត្សរ៍ឆ្នាំ១៩៦០ ហើយបានសារភាពថា គ្រូបង្រៀនរបស់ខ្លួនមួយរូបក្នុងចំណោមគ្រូបង្រៀនវិទ្យាល័យជាច្រើនទៀតពោលគឺ អៀង ធីរិទ្ធ (ដែលក្លាយជាប្រពន្ធរបស់ អៀង សារី តាំងពីឆ្នាំ១៩៥២) ជាភ្នាក់ងារសេ.អ៊ី.អា ។ ការចោទប្រកាន់ដ៏ចម្លែកនេះធ្វើឲ្យ ឌុច ដែលកំពុងតែអានបានចារសម្គាល់នៅគែមចម្លើយនោះថា៖ «តើ អៀង ធីរិទ្ធ ជាប្រពន្ធរបស់អ្នកណា? តើឯងមានភ័ស្តុតាងអ្វីមកបញ្ជាក់?» ។[៩៣]

អ្នកទោសម្នាក់ទៀតដែលគ្រាន់តែដឹងថា «សេ.អ៊ី.អា» មានន័យផ្ទុយពីកម្ពុជាប្រជាធិបតេយ្យនោះបាននិយាយថា ពាក្យកាត់របស់ សេ.អ៊ី.អា មានន័យថា «មានហូបគ្រប់គ្រាន់» ។ អ្នកផ្សេងទៀតអះអាងថា អ្នកជ្រើសរើសឲ្យចូលសេ.អ៊ី.អាបាននិយាយប្រាប់ថា «នៅជាមួយសេ.អ៊ី.អានឹងមានស្រី ស្រា ល្បែង ផ្សារផ្សេ ផ្ទះថ្ម និង ម៉ូតូជិះ» ឬថា ក្រោយពីពេលចូលសេ.អ៊ី.អានឹង «អាចដើរហើរដោយសេរី ពីព្រោះគ្មានវិន័យអ្វីទេ» ។ និយមន័យដែលបក្សកុម្មុយនិស្តអាចទទួលយកបានគឺចេញពីមាត់របស់ ពេញ សុភាព ត្រូវជាកូនស្រីរបស់ សុក ធួក (ហៅ វ៉ន វ៉េត) ជាកម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនិស្តកម្ពុជា ។ សុភាពត្រូវបានចាប់ខ្លួនជាមួយឪពុកនៅឆ្នាំ១៩៧៨ ។ សុភាព បាននិយាយរំឭកដល់សម្ដីរបស់ម្ដាយដែលនិយាយប្រាប់ខ្លួនថា «សេ.អ៊ី.អា គឺជាអ្នកដែលបង្កប់ស៊ីរូងផ្ទៃក្នុងបក្ស» ។[៩៤]

លោក ស៊ីវ ហេងឌ័រ បានមានប្រសាសន៍ថា នៅក្នុងចម្លើយសារភាពនៅមន្ទីរស-២១ «ពាក្យដូចជា

សេ.អ៊ី.អា និង កា.ហ្សេ.បេ...ជាទូទៅមានន័យថាខ្មាំង ។ កាលណាអ្នកឯងនិយាយថា អ្នកណាម្នាក់ជា សេ.អ៊ី.អា អ្នកឯងមិនចង់និយាយថា ម្នាក់នោះជាសមាជិករបស់អង្គការសេ.អ៊ី.អាឡើយ ប៉ុន្តែគឺចង់និយាយថា ម្នាក់នោះជាខ្មាំងទៅវិញ» ។ ស្រដៀងគ្នានេះដែរ នៅក្នុងបដិវត្តវប្បធម៌នៅប្រទេសចិនវាមិនសំខាន់ត្រង់ថា ខ្មាំងត្រូវហៅថាយ៉ាងម៉េចនោះទេ ឲ្យតែអ្នកនោះត្រូវបានសង្គមប្រកាសមិនទទួលស្គាល់និងថ្កោលទោសយ៉ាងស័ក្តិសិទ្ធិទៅជាការគ្រប់គ្រាន់ហើយ ។ ឯកសារកាលពីជំនាន់នោះសរសេរថា «ដើម្បីចោទអ្នកណាម្នាក់ ត្រូវយកចំណុចទាំងអស់នេះមកប្រើ៖ ស្តាំនិយមជ្រុល ឆ្វេងនិយមជ្រុល ប្រឆាំងនឹងបដិវត្តន៍ សមាសភាពមិនល្អ ភ្នាក់ងារសូវៀត ភ្នាក់ងារអាមេរិក ភ្នាក់ងារKMT ជាដើម ។ល ។[៩៥] ក្នុងលក្ខណៈប្រហាក់ប្រហែលគ្នានេះដែរ លីន វ៉ៃ បានទាញហេតុផលថា «វិធានការនានាក្នុងការចោទប្រកាន់បុគ្គល» គឺជាផ្នែកមួយនៃនយោបាយរបស់ចិននៅក្នុងបដិវត្តវប្បធម៌ដែលនាំឲ្យមានអំពើឃោរឃៅជាទ្រង់ទ្រាយធំ ។ ការយល់ឃើញជម្រៅរបស់ លីន វ៉ៃ អាចស្របនឹងករណីរបស់កម្ពុជាប្រជាធិបតេយ្យ ដែលក្នុងរបបនេះអ្នកណាក៏ដោយឲ្យតែត្រូវបានចោទថាជា «ខ្មាំង» គឺត្រូវនាំយកមកមន្ទីរស-២១ ឬសម្លាប់នៅនឹងកន្លែងតែម្តង ដោយគ្មានបញ្ជាក់មូលហេតុអ្វីទាំងអស់ ។[៩៦]

នៅក្នុងការភ្ជាប់អ្នកដែលត្រូវចោទប្រកាន់ទៅនឹងភ្នាក់ងារស៊ើបការណ៍សម្ងាត់បរទេសនានា អ្នកសួរចម្លើយនៅមន្ទីរស-២១ បានធ្វើតាមគន្លងវិធានការផ្សេងៗដែលធ្លាប់អនុវត្តនៅសហភាពសូវៀតកាលពីទសវត្សរ៍ឆ្នាំ១៩៣០ដែរ ។ កាលនោះ អ្នកទោសត្រូវបានចោទប្រកាន់ថា ធ្វើការឲ្យភ្នាក់ងារស៊ើបការណ៍សម្ងាត់បរទេសក្នុងគោលបំណងផ្តួលរំលំរបបដឹកនាំដោយ ស្តាលីន ។ ពលរដ្ឋសូវៀតដែលមានភក្តីភាពមិនអាចគិតថានឹងប្រឆាំងរបបនេះទេ ប៉ុន្តែអ្នកដែលហ៊ានប្រឆាំងត្រូវបានចាត់ទុកថា «មិនមែនជាប្រជាជនសូវៀត»ទេ ។[៩៧] នៅប្រទេសកម្ពុជា អ្នកដែលត្រូវចោទថាក្បត់នឹងបដិវត្តន៍ ក៏ត្រូវអង្គការគិតថា «មិនមែនជាខ្មែរ» ដែរ ។ សុន្ទរកថារបស់ ប៉ុល ពត ដែលថ្លែងកាលពីខែធ្នូ ឆ្នាំ១៩៧៧ បញ្ជាក់ថា៖

> យើងបាន [កម្ទាត់] ខ្សែបង្កប់អន្តរជាតិហើយ ។ ខ្សែធំៗទាំងបីនោះគឺ សេ.អ៊ី.អារបស់អាមេរិក កា.ហ្សេ.បេរបស់សូវៀត និងខ្សែយួនលេបទឹកដី ។ បណ្តាញចារកម្មទាំងនេះបានបង្កប់ក្នុងជួរបក្ស កងទ័ព និងមហាជនរបស់យើងជាងម្ភៃឆ្នាំមកហើយ ។[៩៨]

នៅឆ្នាំ១៩៩៧ ប៉ុល ពត បានប្រាប់ទៅអ្នកកាសែតឈ្មោះ ណេត ថាយ័រ ថា «ភ្នាក់ងារវៀតណាម» ជាអ្នកទទួលខុសត្រូវចំពោះការស្លាប់ភាគច្រើនស្ទើរតែទាំងអស់ដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជា-ធិបតេយ្យ ។ តើក្រៅពីយួនមានអ្នកណា បើបក្សយើងមានបំណងបរិសុទ្ធជាខ្មែរពិតៗមានចិត្តស្មោះត្រង់ ហើយបក្សមានគំនិតផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រនោះ ។[៩៩]

វគ្គបន្តមកទៀតដែលនិយាយអំពីប្រវត្តិរូប មានសំណួរជាច្រើនដែលសួររក «ចំណុចខ្លាំង» និង «ចំណុចខ្សោយ» ។ នៅក្នុងចម្លើយសារភាព «ចំណុចខ្លាំង» មិនឃើញមានទេ ប៉ុន្តែ «ចំណុចខ្សោយ» ត្រូវបានកត់

ចូលក្នុង «ប្រវត្តិសកម្មភាពក្បត់» ។[៦០] «ប្រវត្តិសកម្មភាពក្បត់» នោះ មិនត្រឹមតែកត់ចូលនូវសកម្មភាពរបស់អ្នកទោសតែប៉ុណ្ណោះទេ ថែមទាំងមានរបាយការណ៍អំពីការសន្ទនាទៀតផង ដែលក្នុងនោះមាននិយាយត្អូញត្អែរអំពីជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ភាគច្រើននៃការត្អូញត្អែរនេះបង្ហាញឲ្យឃើញអំពីការរិះគន់ចំពោះកម្ពុជាប្រជាធិបតេយ្យរបស់អ្នកដែលបានរួចរស់រានមានជីវិតពីរបបនោះ ។ ការរិះគន់ទាំងនោះ រៀបរាប់អំពីជាតិមួយដែលប្រជាជនរបស់ខ្លួនត្រូវបានញាំញីដោយភាពក្រីក្រ គ្មានអាហារហូបគ្រប់គ្រាន់ ស្លៀកពាក់ខោអាវរហែករយ៉ៃ និងធ្វើការជាទម្ងន់ រស់នៅក្រោមការឃ្លាំមើលនិងការគំរាមកំហែងជាប់ជាប្រចាំ គ្មានការទុកចិត្តគ្នា រស់នៅក្រោមវិន័យតឹងរ៉ឹងហួសប្រមាណ គ្មានសិទ្ធិសេរីភាពដើរហើរ ។

អ្វីដែលអ្នកទោសនឹកឃើញជាងគេប្រហែលជា «សុភមង្គល» ហើយមើលទៅ ។ សុភមង្គលជាស្ថានភាពមួយពិបាកយល់និងពិបាកស្មានដែលកើតឡើងនៅក្នុងជីវិតគ្រួសារ ដូចជាការមានហូបចុកគ្រប់គ្រាន់ និងសេរីភាពក្នុងការដើរហើរទៅកន្លែងណាដែលខ្លួនពេញចិត្តជាដើម ។ ការនឹកអាឡោះអាល័យនេះក៏មានផលប៉ះពាល់ដល់អ្នកធ្វើការនៅក្នុងគុកដែរ ។ នៅពេលដែលអ្នកទោសម្នាក់ឈ្មោះ យស់ ធឿន ត្អូញត្អែរថានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ «យើងរស់នៅដូចសត្វជាប់ទ្រុង» ហើយ ហ៊ុយ សាវ៉ន ធ្វើការប្រៀបធៀបបដិវត្តន៍ដូច «រស់នៅក្នុងគុក» អ្នកធ្វើការនៅក្នុងគុកដែលកត់ត្រាការចោទប្រកាន់ប្រាកដជាបាត់មាត់ដូចគេចុកអ៊ីចឹង ។ ការនិយាយរបៀបនេះបានលេចឡើងក្រោយមកទៀតនៅក្នុងចម្លើយសារភាពរបស់អ្នកធ្វើការនៅក្នុងគុកផ្ទាល់តែម្តង ។[៦១]

អ្នកទោសភាគច្រើនជាយុវជនវ័យក្មេងដែលស្គាល់ពិភពលោកយើងនេះតិចតួចបំផុត ។ ជាក់ស្តែងគ្រប់ឯកសារចម្លើយសារភាពដែលខ្ញុំបានពិនិត្យ មិនឃើញមាននិយាយអំពីនយោបាយរបស់កម្ពុជាប្រជា-ធិបតេយ្យ ដូចជាការបិទទ្វារសាលា និងសារពត៌មាន ការដកហូតអំណាចរបស់អ្នកមាន និងអ្នកដែលចេះដឹងការលុបបំបាត់មិនឲ្យមានតុលាការ និងការបោះឆ្នោត ឬការជម្លៀសពីទីក្រុងដោយបង្ខំផងទេ ។ ចម្លើយសារភាពបីដែលខ្ញុំបានអាន មាននិយាយត្អូញត្អែរអំពីការគាបសង្កត់ទៅលើសាសនា ប៉ុន្តែមានបង្ហាញការសោកស្តាយចំពោះការបាត់បង់ពិធីបុណ្យប្រពៃណីផ្សេងៗជាងបាត់បង់ឱវាទរបស់ព្រះពុទ្ធ ។ អ្នកដែលសោកស្តាយចំពោះការបាត់បង់យសស័ក្តិ មុខមាត់ និងកិត្តិយសមិនសោកស្តាយចំពោះការបាត់បង់ឬការអាម៉ាស់មុខរបស់អ្នកមានបុណ្យស័ក្តិខ្ពង់ខ្ពស់ ឬការបំផ្លិចបំផ្លាញគហបតីកម្ពុជាឡើយ ។ ប៉ុន្តែផ្ទុយទៅវិញ អ្នកទោសដែលសោកស្តាយចំពោះការបាត់បង់សិទ្ធិបានសារភាពថា ខ្លួនចង់បានសិទ្ធិនេះសម្រាប់ខ្លួនឯងផ្ទាល់ដែរ ។[៦២]

អ្នកទោសបានត្អូញត្អែរជាញឹកញយអំពីវិន័យតឹងតែងនៅក្នុងជីវិតបដិវត្តន៍នេះ ។ អ្នកទោសនិយាយថា រស់នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យខ្លួនមិនអាច «ដើរទៅណាមកណាតាមចិត្ត» «ដើរលេងជាមួយគ្រួសារនិងមិត្តភក្តិ» បានទេ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យអ្នកទោសត្រូវធ្វើការដោយមានការបង្ខំពីមុខពីក្រោយ ។ ណុប នួន អតីតអ្នកសួរចម្លើយបាននិយាយថា «អង្គការបញ្ជាយើងវ៉ៃវក់ដូចជាគោក្របីអ៊ីចឹង» ហើយ គីម ជឿង រំពុកទាំងជូរចត់ថា «យើងរស់នៅក្រោមការដឹកនាំរបស់គេ ។ អ្នកឯងត្រូវការអនុញ្ញាតធ្វើនេះធ្វើនោះ...នៅអំឡុងពេលសង្គ្រាមឆ្នាំ១៩៧០ - ១៩៧៥ យើងធ្វើទ័ពក៏ជួបប្រទះការលំបាក

ដែរ ។ នៅក្នុងសមរភូមិប្រយុទ្ធស្លាប់រស់ យើងមិនដែលគិតរឿងលំបាកអ្វីទេ ពីព្រោះនៅទីបញ្ចប់យើងចង់បានសេរីភាពនិងភាពសប្បាយរីករាយ ។ ប៉ុន្តែជាលទ្ធផលនៅពេលសង្គ្រាមចប់ អ្វីៗគ្រប់យ៉ាងនៅតែបន្តពិបាករហូតគ្មានពេលធូរស្រាលឡើយ» ។[៦៣]

អ្នកទោសជាច្រើននឹកឃើញដល់ពេលដែលខ្លួនធ្លាប់មានសេរីភាពក្នុងការសម្រេចចិត្តធ្វើអ្វីដែលខ្លួនត្រូវធ្វើបន្ទាប់មកទៀត ។ នៅក្នុងខណៈដែលខ្លួនដឹងថា «អស់សេរីភាព» នៅក្នុងកិច្ចប្រជុំនយោបាយ ហើយត្រូវបានភ្ជាប់ទៅនឹងសកម្មភាពអាក្រក់របស់ខ្លួនជាមួយអាមេរិកនោះ អ្នកទោសភាគច្រើនបានរំឭកឡើងវិញយ៉ាងពេញចិត្តនូវសេរីភាពផ្ទាល់ខ្លួនដែលខ្លួនធ្លាប់មាននៅមុនពេលមានសង្គ្រាមស៊ីវិល ។ ព្រំ យ៉ុន បានរៀបរាប់ពីជីវិត «ប្រឆាំងបដិវត្តន៍»ដូចតទៅនេះ÷ «ខ្ញុំចង់ហូបអីក៏បាន ចង់ធ្វើអ្វីក៏ធ្វើទៅ ចង់ដើរទៅណាក៏ដើរទៅ» ។ អ្នកទោសម្នាក់ទៀតនិយាយថា «កាលពីសង្គមចាស់គ្មានការសម្ងាត់អ្វីឡើយ បើអ្នកឯងមានលុយអ្នកឯងសប្បាយហើយ» ។ អ្នកទោសទីបីសារភាពថា មាន«កំហុស» ក្នុងការ «បំផុសឲ្យប្រជាជនស្រឡាញ់សុភមង្គលដែលខ្លួនធ្លាប់មានកាលពីមុន» ។[៦៤]

អ្នកទោសក៏នឹកអាល័យដែរដល់ការរស់នៅសុខដុមរមនាជាមួយសាច់ញាតិ បងប្អូន និងមិត្តភក្តិ ។ មានអ្នកខ្លះស្តាយមិនបានលេងល្បែង រាំវែក ល្ខោន ភាពយន្ត ស្រី ស្រា ដូចកាលពីមុនដែលជាអំពើមួយត្រូវបានហាមប្រាមនិងកាត់បន្ថយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការសោកស្តាយទាំងនេះកើតឡើងជាញឹកញយនៅក្នុងចម្លើយសារភាពរបស់អ្នកទោសវ័យក្មេងៗដែលនិយាយថា ខ្លួននិយាយអ្វីដែលខ្លួនគិតថា អ្នកសួរចម្លើយចង់ស្តាប់ ។ មើលទៅប្រហែលជាមិនពិតទេដែលថា ភាគច្រើននៃអ្នកទោសវ័យក្មេងធ្លាប់បានរីករាយនឹងពេលវេលាកាលពីមុន មានលុយ ឬពេលសប្បាយក្លាយជាអ្នកលេងល្បែង អ្នកផឹកស៊ីស្រីញីអូនបង ពីព្រោះអំពើទាំងអស់នេះគ្រាន់តែជាការស្រមៃរបស់អ្នកទោសតែប៉ុណ្ណោះ ។ អ្នកទោសប្រហែលជាស្មានដល់នូវកម្រិត «ទោស» ដែលចេញពីអំពើដូចរៀបរាប់មកនេះ ។[៦៥] នៅពេលឲ្យសរសេរសកម្មភាព «ប្រឆាំងបដិវត្តន៍» អ្នកទោសចេះតែប្រឌិតរឿងផ្សេងៗដូចជាថា ធ្លាប់បានរួមភេទ និយាយលេងសើចលេងបៀ និងផឹកស្រា ជាដើម ។ អ្នកទោសភេទស្រីត្រូវបានលួងឲ្យឆ្លើយថាធ្លាប់មានទំនាក់ទំនងជាមួយរឿងនេះជាច្រើនដង ។ អ្នកទោសបុរសត្រូវឈរពេញមួយយប់ៗ ។

អ្នកទោសជាច្រើនសម្តែងនូវការអាឡោះអាល័យជាទូទៅចំពោះជីវិតរបស់ខ្លួនមុនសម័យបដិវត្តន៍ ។ ការត្អូញត្អែររបៀបនេះបានលេចឡើងជារឿយៗ ហើយដូចៗគ្នានៅក្នុងឯកសារនានាដែលសរសេរឡើងតាមខែនីមួយៗផ្សេងគ្នា ។ វាហាក់ដូចជាថា ច្បាប់ដើមដែលមើលទៅមានលក្ខណៈសមរម្យជាចម្លើយសារភាព ត្រូវបានអ្នកសួរចម្លើយ ឬអ្នកធ្វើការខាងឯកសារស្រង់ចេញជាអត្ថបទដោយមិនខ្វល់អំពីអ្វីដែលអ្នកទោសបានធ្វើឬនិយាយឡើយ ។ វាអាចជាការពិតដែលថា ចម្លើយសារភាពរបស់អ្នកទោសមានឋានៈតូចតាចជាច្រើននាក់ត្រូវបានអ្នកធ្វើការខាងឯកសារស្រាក់ចូលគ្នាដោយមិនចាំបាច់សួរចម្លើយច្រើនឡើយ នៅពេលដែលទម្រង់ទូទៅនៃ «កំហុស» និងអ្វីដែលបង្កើតជាការត្អូញត្អែរអាចទទួលយកបានចេញជារូបរាងច្បាស់ហើយនោះ ។ ជាក់ស្តែងអតីតអ្នកសួរចម្លើយឈ្មោះ ឈឹម ឈុន បានសារភាពនៅក្នុងចម្លើយ

របស់ខ្លួនថា "ខ្ញុំគ្រាន់តែសរសេរដំណើររឿង (របស់អ្នកទោស) ណាដែលងាយសរសេរ ។ ប្រសិនបើដំណើររឿងមានទំនាក់ទំនងស្មុគស្មាញពេក ហើយពិបាកសរសេរខ្ញុំគូសវាត់វាចោល" ។[៦៦]

ទោះជាមានទង្វើរបៀបនេះក៏ដោយ ក៏ចម្លើយសារភាពដែលបញ្ជាក់អំពីការខ្វះខាតចំពោះបដិវត្តន៍ តែងតែមានលក្ខណៈស្មោះត្រង់ខុសពីធម្មតា ។ ឧទាហរណ៍ជាក់ស្តែង នៅក្នុងខែកក្កដា ឆ្នាំ១៩៧៧ ឈិន ជាប អតីតភាពធ្វើយុទ្ធជននៅក្នុងកងពលធំ៣១០ បានរំឮកនូវកិច្ចសន្ទនាមួយជាមួយមិត្តរបស់គាត់ម្នាក់ ។

ឈុន នៅកងពល៣១០ ធ្វើឲ្យខ្ញុំមើលឃើញថា បដិវត្តន៍ខ្មៅងងឹតទាំងអស់ ។ ឈុន និយាយថា ធ្វើបដិវត្តន៍សព្វថ្ងៃនេះពិបាកណាស់ហើយច្របូកច្របល់ទៀតផង ទាំងការស្លៀកពាក់ ទាំងការហូបចុក មិនដែលគ្រប់គ្រាន់ម្តងណាទេ ។ ឈុន និយាយទៀតថា "ការលំបាកនៅពេលមានសង្គ្រាម វាគ្រប់គ្រាន់ទៅហើយ ប៉ុន្តែនៅពេលសង្គ្រាមចប់រឹតតែពិបាកលើសមុនទៅទៀត ។ គ្មានពេលសម្រាកទេ ។ បើធ្វើការប្រៀបធៀបទៅឃើញថា ពួកវាប្រើយើងដូចជាគោក្របីអីចឹង ប៉ុន្តែមិនឲ្យស៊ីស្មៅទេ ។ មិនតែប៉ុណ្ណោះសោត អ្នកឯងមិនអាចរស់នៅកន្លែងដែលអ្នកឯងចង់រស់នៅទេ គ្មានសេរីភាពអ្វីទាំងអស់ អ្នកឯងដើរសូម្បីតែមួយជំហានក៏មិនបានដែរបើគ្មានការអនុញ្ញាត ។ សព្វថ្ងៃនេះយើងរស់នៅគ្មានសប្បាយទេ ។ គ្មានការលេងសើច...ប៉ុន្តែ ផ្ទុយទៅវិញ បើយើងក្រឡេកមើលទៅសង្គមចាស់កាលនោះឪពុកម្តាយយើងធ្វើការមែន តែមិនយ៉ាប់ណាស់ណាទេ ហើយគាត់មិនដែលខ្វះអាហារហូបចុកឡើយ គឺយើងរស់នៅដោយសប្បាយមានឯករាជ្យនិងដោយសុខស្រួលទៀតផង ។ បើយើងចង់ធ្វើអ្វីធ្វើទៅ គ្មានអ្នកណាឃាត់អ្នកណាឃាំងទេ បើចង់ចាយវាយក៏បានព្រោះយើងមានលុយ ។[៦៧]

មុននេះមួយខែ ឌិត គង់ ដែលធ្លើយុទ្ធជនដូច ឈុន ដែរ បានរំឮកឡើងវិញថា÷

កាលពីខែកុម្ភៈ ឆ្នាំ១៩៧៦ ស៊ុង បានប្រាប់ខ្ញុំថា បើសិនជាអ្នកឯងធ្វើបដិវត្តន៍សង្គមនិយម ហូបមិនឆ្អាញ់ទេ ហើយអ្នកឯងធ្វើការក៏ឥតមានពេលសម្រាកដែរ ពោលគឺធ្វើរហូតទាល់តែដួលនៅនឹងកន្លែង ។ អ្នកឯងធ្វើការទាំងយប់ទាំងថ្ងៃគ្មានពេលសម្រាកសូម្បីតែបន្តិចក៏គ្មានដែរ អ្នកឯងគ្មានសិទ្ធិសេរីភាពទាល់តែសោះ ។ ធ្វើបដិវត្តគឺហូបបបរទាំងព្រឹកទាំងថ្ងៃហើយការហូបចុកនោះមិនគ្រប់គ្រាន់ទៀត ។ ទៅណាមកណាត្រូវមានសំបុត្រអនុញ្ញាត ។ ចេញចូលត្រូវមានវិន័យត្រឹមត្រូវ ។ នៅពេលដែលអ្នកឯងធ្វើបដិវត្តសង្គមនិយម គ្មានប្រាក់ខែ គ្មានបុណ្យស័ក្តិ គ្មានស្រី គ្មានស្រា គ្មានល្បែងគ្មានឡានជិះទេ ។ អ្នកឯងត្រូវដើររហូត ទៅណាក៏ដើរដែរ ។[៦៨]

មានចម្លើយសារភាពមួយចំនួនបានធ្វើការប្រៀបធៀបរវាងវាសនារបស់យុទ្ធជនកម្ពុជាក្រោយជ័យជម្នះខែមេសា ឆ្នាំ១៩៧៥ ជាមួយនឹងទាហានវៀតណាមនៅក្នុងរយៈពេលក្រោយនោះបន្តិច ។ នៅ

ប្រទេសវៀតណាមអតីតយុទ្ធជនត្រូវបានអនុញ្ញាតឲ្យសម្រាកនិងទៅលេងគ្រួសារសាច់ញាតិ ។ ប៉ុន្តែចំណែកនៅប្រទេសកម្ពុជាវិញ យុទ្ធជនត្រូវបានបង្ខំឲ្យទៅធ្វើស្រែភ្លាម ។ វ៉ាន់ ឃឿន និយាយថា «នៅប្រទេសដទៃទៀតគេរៀងរាល់ឆ្នាំមួយខែគេសម្រាកហើយ ។ ចំណែកយើងវិញរវល់រហូតគ្មានពេលសម្រាកទេ» ។[69] ព្រាំ ភនបានធ្វើការកត់សម្គាល់ថា «នៅពេលឈ្នះសង្គ្រាម កងទ័ពវៀតណាមមានសម្លៀកបំពាក់និងហូបចុកគ្រប់គ្រាន់» ។ គំនិតនេះត្រូវបានលើកយកមកនិយាយដោយ នន ណាល់ ដែលបានសរសេរថា «អ្នកជិតខាង [វៀតណាម] ក៏រៀបចំពួកបក្រពត្តិដូចតែយើងអ៊ីចឹងដែរ ប៉ុន្តែគេមានហូបគ្រប់គ្រាន់» ។ ការនិយាយប្រៀបធៀបផ្សេងទៀតជាមួយនឹងវៀតណាម ទោះបីជាមិនបានស្តែងចេញឲ្យឃើញក៏ដោយ ក៏វាច្បាស់ក្រឡែតដែរ ។[70]

ជូ នី យុទ្ធជនវរសេនាធំលេខ៨១១ បានប្រើប្រាស់ព័ត៌មានដែលប្រមូលយកមកពីវគ្គសិក្សារបស់បក្សកុម្មុយនិស្តកម្ពុជាដើម្បីឆ្លុះបញ្ចាំងអំពីបដិវត្តន៍កម្ពុជាក្នុងផ្លូវអាក្រក់ ។ នៅក្នុងចម្លើយរបស់ខ្លួន នីបានបាត់តាំងមតិវិទ្ធង្សនារបស់ខ្លួនចំពោះកម្មាភិបាលថ្នាក់លើមួយរូបដោយ នី បានដកស្រង់សម្តីកម្មាភិបាលនោះ ដែលនិយាយថា÷

> «យុទ្ធជននៅវៀតណាមមិនធ្វើស្រែដូចយើងទេ ។ យុទ្ធជនគេសប្បាយរីករាយ និងដើរហើរដោយសេរីតាមតែខ្លួនចង់ ។ គេមានហូបចុកគ្រប់គ្រាន់ ខុសពីយើងដែលគ្មានអ្វីហូបទាល់តែសោះ ។ តាមពិតយុទ្ធជនវៀតណាមក៏ធ្វើបដិវត្តដូចជាយើងដែរ ប៉ុន្តែមានតែសំបកខាងក្រៅប៉ុណ្ណោះ ។ នៅខាងក្នុងគេមិនសប្បាយចិត្តនឹងផ្លូវសង្គមនិយមនេះទេ ពីព្រោះ [សង្គមនិយម] គ្មានផ្លូវណាឲ្យប្រជាជនរស់បានទេ ។ គេមានការភ្ញាក់រលឹកតស៊ូប្រឆាំងនឹងបដិវត្តន៍គ្មានឈប់ឈរ ។ ព្រោះគេយល់ថា គេមិនអាចធ្វើទៅមុខបាន ។ នេះមិនទាន់អស់ទេ ។ និយាយពីសូវៀតម្តង ។ នៅប្រទេសសូវៀតដែលមានបដិវត្តន៍សង្គមនិយមយូរហើយ មកដល់ពេលនេះគេមិនទាន់ចាប់ផ្តើមធ្វើអ្វីដែលយើងធ្វើដូចសព្វថ្ងៃនេះទេ គេមិនដែលចាប់រឹបធ្វើដូចយើងភ្លាមឡើយ ។ សព្វថ្ងៃនេះ សូវៀតកំពុងតែពិនិត្យបញ្ហាផ្សេងៗសាឡើងវិញ ពីព្រោះគេមិនអាចរក្សានូវការតស៊ូវណ្ណៈក្តៅគគុកដែលមានការពាក់ព័ន្ធនឹងបដិវត្តន៍បានឡើយ ។ ធ្វើបដិវត្តគឺពិបាកណាស់...ពេលយើងធ្វើបដិវត្ត ប្រជាជាតិប្រជាធិបតេយ្យប្រឆាំងនឹងខ្លាំងគេនិយាយថាពិបាក ។ នៅពេលសង្គ្រាមចប់ យើងចូលទៅក្នុងបដិវត្តន៍សង្គមនិយមហើយគេនិយាយថា យើងនឹងបានសប្បាយ ។ តែតាមការពិត វានៅតែពិបាកដដែល តាំងពីការស្លៀកពាក់ ហូបចុក សេរីភាពដើរហើរ ។ គ្មានចំណុចណាមួយដូចនៅប្រទេសគេទេ» ។[71]

ជ័យជម្នះបាននាំមកនូវគ្រោះថ្នាក់សម្រាប់កងទ័ពកម្ពុជាតិចណាស់ ។ ភាគច្រើន ជ័យជម្នះតែងតែមានភាពលើសលប់លើអ្វីដែលអ្នកទទួលនោះបានរងការលំបាក ឬធ្វើឲ្យប្រែប្រួលឋានៈរបស់ខ្លួន ។ យុវជនយុវនារីបានបោះបង់កិច្ចការស្រែចម្ការរបស់ឪពុកម្តាយដើម្បីមក«រំដោះ»ប្រទេសកម្ពុជានិងខ្លួនឯងផ្ទាល់ ។ នៅពេលបានទទួលជ័យជម្នះ យុវជនយុវនារីទាំងនោះមិនចង់ត្រឡប់ទៅធ្វើស្រែវិញទេ ។ វោហារសាស្ត្រ

គាំទ្រប្រជាកសិកររបស់របបកម្ពុជាប្រជាធិបតេយ្យបានត្រូវផ្ចាញ់ដោយយុទ្ធជនកម្ពុជា ដែលអ្នកទាំងនោះមានអារម្មណ៍ថាក្នុងនាមជាយុទ្ធជនបដិវត្ត ខ្លួនគេត្រូវតែមានសិទ្ធិដកខ្លួនចេញពីភក់ ពីការឈឺឆ្អឹងឈឺឆ្អែង និងពីឋានៈទន់ទាបជាកសិករធ្វើស្រែ ហើយប្រគល់ឋានៈនេះទៅឲ្យអ្នកផ្សេង ។ ជាការគួរឲ្យអស់សំណើចអ្នកដែលចាត់តាំងទោសកំហុសកម្របានធ្វើស្រែដោយផ្ទាល់ដៃណាស់ ។

កែ សាន (ហៅ សុខ) ដែលជាសមាជិកមានឋានៈខ្ពស់របស់បក្សមានកំហឹងចំពោះការវិវត្តន៍ទាំងនេះនិងក្លែមសម្ដីដើម្បីបញ្ជាក់គំនិតដែលគាត់ចង់និយាយថា÷

> [នៅខែឧសភា ឆ្នាំ១៩៧៥] មានម្នាក់ឈ្មោះ ចាស់ បាននិយាយថា «មិត្តឃើញទេ យើងបានរំដោះមួយខែកន្លងទៅហើយ ដោយគ្មានសម្រាកបន្តិចសោះ ។ រាល់អ្វីៗដែលយើងធ្វើគឺគិតតែពីវាយសម្រុក ។ យើងធ្វើស្រែទាំងយប់ទាំងថ្ងៃ អ្នកឯងសាកគិតមើល តើមានបញ្ហានិងភាពច្របូកច្របល់យ៉ាងដូចម្ដេចខ្លះ» ។[៨២]

ពីរបីខែក្រោយមក ឃឿង វុន ដែលជាកងទ័ពដូចគ្នាបានរាយការណ៍អំពីភាពទុក្ខព្រួយរបស់មិត្តខ្លួននៅពេលឃើញប្រជាជនជាច្រើនមានសម្លៀកបំពាក់រហែករយ៉ៃ÷

> សំ និយាយថា «ធ្វើបដិវត្តពិបាកនិងស្មុគស្មាញណាស់...រស់នៅក៏ពិបាក ស្លៀកពាក់ក៏ពិបាក ។ ឥឡូវមើលខោអាវយើងទៅមើល ។ យើងមិនដែលមានសម្លៀកបំពាក់ថ្មីទាល់តែសោះ ។ កម្មាភិបាល និងយុទ្ធជនធម្មតាគឺដូចតែគ្នា ។ ពេលអ្នកឯងទៅសមរភូមិ អ្វីដែលអ្នកឃើញគឺខោអាវរហែករយ៉ៃគោកយ៉ាកគ្មានអ្វីស្អាតបន្តិចសោះ ហើយនៅមានចំណុចជាច្រើនទៀត ។ មិនថាថ្ងៃណា ខែណា ឆ្នាំណាទេអ្នកនឹងឃើញ «យុទ្ធជន» ដេកផ្ទាល់នឹងដីហើយខ្លួនប្រាណរបស់គេមិនដែលប៉ះទឹកម្ដងណាឡើយ គេងូតទឹកងូតភក់តែម្ដងប៉ុណ្ណោះក្នុងមួយខែ» ។[៨៣]

យុទ្ធជនចាស់ៗបានត្អូញត្អែរថា ខ្លួនត្រូវបែកពីប្រពន្ធកូន ។ ការរស់បែកពីគ្រួសារមិនសមហេតុផលទាល់តែសោះ ។ ដូចដែល កេង បាក់ លើកឡើងអំពីបញ្ហានេះតាមរយៈសំឡេងរបស់អ្នកដទៃថា÷

> គាត់និយាយថា ខ្លួនគាត់ផ្ទាល់នឹកប្រពន្ធរបស់គាត់ ហើយខ្ញុំបានឆ្លើយតបទៅវិញថា «មិត្ត ប្រសិនបើមិត្តពិនិត្យមើលជនបដិវត្ត ជាពិសេសមិត្តរបស់មិត្តឯងផ្ទាល់ មិត្តនឹងដឹងថា នៅពេលដែលអង្គការនិយាយថា យើងត្រូវបានរំដោះឲ្យមានសេរីភាព ពាក្យសេរីភាពនោះគឺគ្មានផ្លូវបានឃើញទេ ។ បើមានសេរីភាពមែននោះ ម៉្លេះមិត្តត្រូវបានគេឲ្យទៅជួបជុំប្រពន្ធបាត់ទៅហើយ ។ តើមូលហេតុអ្វី បានជាមិនបានទៅជួបប្រពន្ធយ៉ាងដូច្នេះ?» ហាន ក៏ឆ្លើយថា «វាស្រេចតែលើអង្គការទេ ។ បើអង្គការមិន

> យកចិត្តទុកដាក់[ចំពោះយើង] ថ្ងៃណាមួយយើងនឹងរត់ចោលជួរមិនខានឡើយ ចាំតែមើលទៅថ្ងៃណាមួយ ខ្ញុំនឹងរកកន្លែងថ្មីដោយខ្លួនឯង» ។[៧៤]

ទោះបីជាការត្អូញត្អែរអំពីកម្ពុជាប្រជាធិបតេយ្យខ្វះ តែច្បាស់ មានប្រសិទ្ធភាព និងមានឥទ្ធិពល ប៉ុន្តែមានឧទាហរណ៍មួយចំនួននៅក្នុងបណ្ណសារមួយដែល ជេម ស្កុត ហៅថា «ចារឹកមិនចេញមុខ» ដែលមានតាំងពីការតស៊ូរហូតដល់ការគាបសង្កត់ ។ គំរូបង្ហាញអំពីការប្រឈមមុខគ្នា អំពើឃោរឃៅ និងសេចក្តីព្រហើនដែលមិននឹកស្មានដល់រវាងអ្នកជិះជាន់គេ និងអ្នកដែលត្រូវគេជិះជាន់ដែលលេចឡើងជាញឹកញាប់ នៅក្នុងកំណត់ប្រវត្តិនៃសារមន្ទីរហាយនភាពប្រជុំប្រមូលផ្តុំរបស់រុស្ស៊ីនិងចិន ពិតជាកម្រមានណាស់ ។[៧៥]

ដោយសារតែកម្រមាននៅក្នុងបណ្ណសារយ៉ាងនេះហើយបានជាឱកាសដែលអ្នកទោសវាយប្រហារបដិវត្តន៍ដោយផ្ទាល់មានភាពស្រួចស្រាវនិងគួរឲ្យរន្ធត់ណាស់ ។ ប្រាក់ ឈាន ជាយុទ្ធជនសាមញ្ញនៅកងពលលេខ៣១០ បាននិយាយដោយត្រង់ៗថា «អង្គការអាក្រក់មែនទែន» ។[៧៦] ហូ តុងហូ អតីតគ្រូបង្រៀនដែលធ្លាប់ទៅលេងសហរដ្ឋអាមេរិកកាលពីទសវត្សរ៍ឆ្នាំ១៩៥០ បានប្រើចម្លើយសារភាពរបស់ខ្លួនវាយប្រហារលើមនោគមវិជ្ជា និងការអនុវត្តជាក់ស្តែងរបស់បក្សកុម្មុយនិស្តកម្ពុជាដោយកត់សម្គាល់ថា «ខ្ញុំមិនអាចមើលឃើញផ្លូវដែលកុម្មុយនិស្តនឹងបានជ័យជម្នះទេទៅថ្ងៃអនាគត ប្រសិនបើអ្នកធ្វើការខាងបច្ចេកទេសត្រូវបណ្តេញចោលពីការងារ ផលិតកម្ម ឧស្សាហកម្មត្រូវគាំង ហើយរោងចក្រនានាត្រូវបិទទ្វារយ៉ាងនេះ» ។[៧៧] អ្នក អង្ការ ជាការីវិទ្យុផ្សាយសំឡេងបានសារភាពថា ការងាររបស់គាត់ត្រូវបាត់បង់ដោយសារតែគាត់មាន«កំហឹងក្តៅពេកចំពោះបដិវត្តន៍» ។[៧៨] តាន ឌឿន បានកត់សម្គាល់យ៉ាងច្បាស់ថា ចំពោះខ្លួនគាត់វិញ «កុម្មុយនិស្ត គឺហូបបាយមួយកំប៉ុងក្នុងមួយថ្ងៃ និងដើរតាមគំនិតមនុស្សចាស់គំរិល» ។[៧៩]

«ចារឹកមិនចេញមុខ» ជាច្រើនផ្សេងទៀតអាចត្រូវបានបញ្ចេញដោយផ្ទាល់មាត់ ហើយមិនទាន់ត្រូវបានចងក្រងឲ្យបានត្រឹមត្រូវដាក់ក្នុងបណ្ណសារទេ ។ ញ៉ែម អេន ដែលរស់នៅជាមួយអ្នកធ្វើការជាមួយខ្លួននៅក្នុងផ្ទះមានចម្ងាយប្រមាណមួយរយម៉ែត្រពីគុក បានរំឭកពីការចងចាំរបស់ខ្លួនដែលបានឮអ្នកទោសម្នាក់ស្រែកជិតាលខ្លាំងៗទាំងកណ្តាលអធ្រាត្រនៅក្នុងទីក្រុងដែលស្ងាត់ជ្រងំថា«បើចង់សម្លាប់ខ្ញុំ សម្លាប់មក! អាមនុស្សក្បត់!» ។[៨០]

អ្នកទោសភាគតិចណាស់មានចម្ងល់អំពីវិន័យឃោរឃៅចាប់ពីលើមកដល់ក្រោមរបស់កម្ពុជាប្រជាធិបតេយ្យ ជាចរិតដែលកម្ពុជាប្រជាធិបតេយ្យបានរួមចំណែកជាមួយរបបកម្ពុជាមុនសម័យបដិវត្តន៍ ។ ហៅឈ្មោះអ្នកធំថាអាមីងមិនបានជាដាច់ខាត ។ ខ្ញុំបានមើលចម្លើយសារភាពរបស់អ្នកទោសម្នាក់ឈ្មោះ អ៊ិន វ៉ាន់ ដែលធ្វើការនៅកងពិសេស «ការពារអង្គការ» រហូតដល់ថ្ងៃចាប់ខ្លួននាខែមីនា ឆ្នាំ១៩៧៧ ។ នៅក្នុងចម្លើយសារភាពនេះ វ៉ាន់ បានជេរប្រទេច ខៀវ សំផន ដែលប្រហែលជាបងលេខប្រាំមួយឬប្រាំពីរ ។

ខៀវ សំផន កំពុងតែធ្វើបដិវត្តន៍សង្គមនិយមគាបសង្កត់ ដោយវាយប្រហារសតិអារម្មណ៍សេរីរបស់

ប្រជាជន និងជិះជាន់កេងប្រវ័ញ្ចប្រជាជនគ្មានមេត្តា ។ ដូច្នេះយើងត្រូវតែវាយប្រយុទ្ធដើម្បីរំដោះបងប្អូនដែលស្ថិតនៅក្រោមការជិះជាន់សង្កត់សង្កិនរបស់ពួកនេះដែលមិនមានបដិវត្តន៍ស្អាតស្អំ ។[៨១]

កាន់តែក្តៅជាងនេះទៅទៀតឈ្មោះ ភួង កម្មាភិបាលជាន់ខ្ពស់មកពីភូមិភាគបូព៌ាដែលជាមុខសញ្ញារបស់សន្តិបាលតាំងពីឆ្នាំ១៩៧៦ ហើយដែលត្រូវចាប់ខ្លួននៅឆ្នាំ១៩៧៨ បានវាយប្រហាររបបនេះចំៗថា÷

ប្រជាជនកំពុងតែបាត់បង់នូវសិទ្ធិប្រជាធិបតេយ្យ និង សេរីភាព គ្រប់កម្មាភិបាលទាំងអស់និងអំណាចទាំងមូលគឺស្ថិតនៅក្រោមការកាន់កាប់របស់បក្សកុម្មុយនិស្តកម្ពុជាគ្រប់ពេល...មួយថ្ងៃៗ ប្រជាជននិងកម្មាភិបាលត្រូវបានចាប់ដាក់គុកដាក់ច្រវាក់យកទៅសម្លាប់ទាំងរយៗ ហើយអង្គការគ្មានច្បាប់ប៉ុនក្រចកមកការពារសិទ្ធិរបស់ប្រជាជនឡើយ ។ ប្រជាជននៅស្ងាត់ស្ងៀម ហាក់ដូចជាឈើចាប់ជាពន់ពេក ចង់និយាយ ក៏មិនហ៊ាននិយាយ ព្រោះចេះតែខ្លាច ។[៨២]

លេខាភូមិភាគបស្ចិមឈ្មោះ ជូ ជេត ដែលត្រូវបានចាប់ខ្លួននៅខែមីនា ឆ្នាំ១៩៧៨ បាននិយាយតទល់ជាមួយអ្នកដែលចាប់ខ្លួននូវចំណុចមួយចំនួនដែលជាការវាយប្រហារចំៗដោយឥតលាក់លៀមទៅលើបក្សកុម្មុយនិស្តកម្ពុជា និងនយោបាយរបស់បក្សនេះ ប៉ុន្តែមិននិយាយចំឈ្មោះអ្នកណាម្នាក់នៅក្នុងបក្សឡើយ÷

[ខ្ញុំនិយាយថា] របបសព្វថ្ងៃនេះគឺជារបបផ្តាច់ការ គឺងរឹង និងដាច់ខាត ហួសវិស័យ និងសតិអារម្មណ៍ប្រជាជនៗ ហេតុនេះហើយបានជាប្រជាជនជាច្រើនរអ៊ូរទាំ...ថា ខ្លួនធ្វើការច្រើនដែរតែទទួលបានផលតិចណាស់ តើរស់ជាមួយគ្រួសារជុំគ្នាម្តេចបាន មានពេលឯណានឹងបានសម្រាក នឹងបាននិយាយលេងសើចសប្បាយ... ។[៨៣]

យើងដឹងតាមរយៈដំណើររឿងរបស់ វ៉ាន់ ណាត ថា អ្នកទោសបាននិយាយខ្សឹបខ្សៀវដាក់គ្នាទៅវិញទៅមកជាមួយអ្នកទោសដូចគ្នា ហើយជួនកាល អ្នកធ្វើការនៅក្នុងគុកនិយាយជាមួយអ្នកទោសទៀតផងទោះជាដឹងថា វាខុសទៅនឹងវិន័យក៏ដោយ ។ ផាន ថនចាន់ បាននិយាយថា ខ្លួនបានគោះជញ្ជាំងថ្មបន្ទប់គាត់ឲ្យអ្នកទោសនៅសងខាងដឹង ។ ថនចាន់ មិនដែលបានឃើញ ឬដឹងថា អ្នកទោសទាំងនោះជាអ្នកណាខ្លះទេ ។ អ្វីដែលនិយាយចេញ ឬគោះនៅក្នុងកាលៈទេសៈបែបនេះដែលជា «ប្រតិចារឹកមិនចេញមុខ» ប្រសិនជាមាន គឺនៅតែមានលក្ខណៈអាថ៌កំបាំងនៅឡើយ ។ ដូចគ្នានេះដែរ ឯកសារនិយាយអំពីការសន្ទនាគ្នារវាងអ្នកសួរចម្លើយស្តីអំពីការងាររបស់ខ្លួនទៅលើអ្នកទោសកម្រមានណាស់ ហើយមិនអាចធ្វើឡើងវិញបានទេ ។ ជនរងគ្រោះនិងជនដៃដល់ភាគច្រើនអាចពុតាមរយៈក្រដាសស្នាមដែលនៅសល់តែប៉ុណ្ណោះ ។[៨៤]

«សកម្មភាពក្បត់» របស់អ្នកទោសដែលផ្ទុយពីការតវ៉ារិះគន់ទៅលើរបបនេះមិនអាចមានអ្វីបញ្ជាក់ថា

ពិតបានទេ ។ ប៉ុន្តែភាគច្រើន សកម្មភាពទាំងនេះធ្វើឲ្យយើងនឹកឃើញនូវបញ្ហាពិតៗដែលកម្មាភិបាលស្ថិតក្រោមការគាបសង្កត់ខ្លាំងបានជួបប្រទះនៅតាមជនបទ នៅពេលខ្លួនតស៊ូស៊ិតស្មាញក្នុងការដាក់ឲ្យអនុវត្តនយោបាយរបស់មជ្ឈិមបក្ស ។ អនុស្សរណៈចុះខែវិច្ឆិកា ឆ្នាំ១៩៧៦ ផ្ញើមកពីឈ្មោះ រឿន ដែលជាលេខាកងពលលេខ៨០១ ឈរជើងនៅខេត្តក្រចេះ ក្រុងជូនចំពោះ សុន សេន បានរៀបរាប់អំពី“សកម្មភាពរបស់អ្នកដែលបម្រើឲ្យខ្មាំង” នៅក្នុងអង្គភាពកងទ័ពថា÷

១) ពួកវាបានឃោសនាឲ្យកម្មាភិបាល និង ជួរផ្សេងៗទៀតកុំឲ្យជឿលើបដិវត្តន៍របស់យើងដោយលើកឡើងថា ហូបមិនគ្រប់គ្រាន់ ។

២) ពួកវាបញ្ចុះបញ្ចូលឲ្យយុទ្ធជនរត់ចោលជួរទ័ព ឬ រត់ចេញពីសហករណ៍ ដោយនិយាយថា នៅសហករណ៍ពិបាកណាស់ ។

៣) នៅការដ្ឋាន ពួកវាបានបំផុសឲ្យប្រជាជនលួចអ្វីក៏ដោយឲ្យតែអាចលួចបាន បើស៊ីមិនកើតគ្រវាត់ចោល ។

៤) ពួកវាបានបំផុសឲ្យប្រជាជន «សេរី» ដើរស្រេចតែចិត្ត និយាយតាមដែលខ្លួនយល់ឃើញថា នៅប្រទេសវៀតណាម និងនៅឡាវគេមានសេរីភាពជាង ។

៥) ពួកវាបំផុសប្រជាជនអំពីបញ្ហាបុណ្យស័ក្តិ សិទ្ធិ និង ប្រាក់ខែនៅប្រទេសវៀតណាមនិងឡាវ ដែលនៅទីនោះ[ប្រជាជន]មានការសប្បាយរីករាយចំពោះប្រាក់ខែ ចំណែកឯបដិវត្តន៍កម្ពុជាវិញមិនសប្បាយចិត្តទេ ហើយនឹងមិនសប្បាយចិត្តយូរតទៅទៀត ។

៦) ពួកវាបំផុសឲ្យប្រជាជនខ្ជិលធ្វើការ ដោយនិយាយថា «បើហូបមិនឆ្អែតគ្មានកម្លាំងឯណាទៅធ្វើការទេ» ។[៨៥]

«សកម្មភាពរបស់អ្នកបម្រើខ្មាំងទាំងនេះ» បង្ហាញអំពីអ្វីដែលកម្មាភិបាលបក្ស និងយុទ្ធជនធម្មតាបានឆ្លើយសារភាពដដែលៗ ។ ពាក្យដែលអ្នកទោសយកមកប្រើសម្រាប់រៀបរាប់ «សកម្មភាពក្បត់» របស់ខ្លួន ភាគច្រើនគឺជាពាក្យឡេនីននិយមដែលបានមកពីវគ្គសិក្សានានារបស់បក្សកុម្មុយនិស្តកម្ពុជា ។ ឧទាហរណ៍ជាក់ស្តែងមួយ អ្នកទោសបាននិយាយថា ខ្លួនបាន «អប់រំ» និង «ចាត់តាំង» កម្លាំងក្បត់ ។ ពាក្យទាំងពីរនេះគឺជាពាក្យម៉ាក្ស-ឡេនីន ដែលជាមូលដ្ឋានគំនិតសំខាន់របស់បក្សកុម្មុយនិស្តកម្ពុជា ។ ឧទាហរណ៍មួយទៀតដែលបង្ហាញពីភាសានិយាយរបស់បក្ស ដូចជាការអះអាងរបស់អ្នកទោសដែលថា ខ្លួនបាន «បិញ្ចឹមការសម្ងាត់» «កសាងកម្លាំង» «ពង្រីកកម្លាំង» «វាយសម្រុក» និង «ឃោសនា» ។

អ្នកទោសតែងតែឆ្លើយថា ធ្វើតាមកលល្បិចវិទ្ធង្សនាដែលបក្សកុម្មុយនិស្តកម្ពុជាប្រើដើម្បីកាន់កាប់អំណាច ។ គ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេថា បក្សភាគច្រើនដែលអ្នកទោសបង្កើត ឬ ចូលរួមគឺសុទ្ធតែត្រូវបានរៀបចំដូចគ្នាបេះបិទនឹងសណ្ឋានរបស់បក្សកុម្មុយនិស្តកម្ពុជា ។ មិនតែប៉ុណ្ណោះ «ខ្មាំង» មួយចំនួនបាន

សារភាពថា ខ្លួនធ្លាប់ «បង្កប់ស៊ីរូងផ្ទៃក្នុង» សង្គមកម្ពុជា ។ ប៉ុន្តែមិនដូចបក្សកុម្មុយនិស្តកម្ពុជាទេ បក្សក្បត់មានអ្នកដឹកនាំច្បាស់លាស់ (ជាទូទៅគឺកម្មាភិបាលដែលត្រូវបានចាប់ខ្លួនរួចហើយ ឬស្លាប់បាត់ទៅហើយ) ។ សមាជិករបស់បក្សក្បត់មានភក្តីភាពចំពោះមេរបស់ខ្លួន ដែលត្រូវបានបក្សកុម្មុយនិស្តកម្ពុជាចាប់ខ្លួន ឬសម្លាប់ ចំណែកឯមជ្ឈិមបក្សវិញ មើលងាយមើលថោកចំពោះអ្នកទាំងនេះទៅវិញ ។

ឆ្លើយតបទៅនឹងសំណួរថា តើមានលាក់អ្វីខ្លះមិនឲ្យអ្នកសួរចម្លើយដឹង អ្នកទោសជាច្រើនបានឆ្លើយប្រាប់ដោយនិយាយរឿងដែលមិនគួរឲ្យជឿដូចជាថា លាក់អាវុធ គ្រាប់រំសេវ ថ្នាំពេទ្យ កញ្ចប់ថ្នាំពុល និងវៀតណាម ដែលមានរហូតទៅដល់ម្ភៃករណីឯណោះ ។

ប៉ុកដា បានឆ្លើយថា បាន«ប្រមូលកម្លាំង» ដែលខ្លួនបាន «លាក់ទុកយ៉ាងជ្រៅ» មិនឲ្យគេដឹង ។ ចម្លើយសារភាពហុកសិបមួយច្បាប់ដែលទាក់ទងនឹងរបស់ ឬមនុស្សដែលលាក់ សុទ្ធតែមានអមដោយផែនទីគូរដោយដៃយ៉ាងស្អាត មានរបៀបរៀបចំដោយបុគ្គលិកធ្វើការនៅមន្ទីរស-២១ ដែលបញ្ជាក់ច្បាស់លាស់តាំងពីកន្លែងលាក់ រហូតដល់មន្ទីររបស់អ្នកគូររូបនេះ ។ ចម្លើយសារភាពដែលនិយាយអំពីជនជាតិវៀតណាមដែលត្រូវបានលាក់ខ្លួន គឺសុទ្ធតែសរសេរឡើងនៅក្នុងឆ្នាំ១៩៧៨ ក្រោយពីមានការផ្ទុះឡើងនូវភាពប្រទូសរ៉ាយជាមួយវៀតណាម ។ ភាពប្រទូសរ៉ាយទាំងនេះបានធ្វើឲ្យនឹកឃើញដល់ការរំដើបរំជួលយ៉ាងខ្លាំងនៅទូទាំងមជ្ឈិមបក្សនៅពេលនេះ ។ ជនជាតិវៀតណាមត្រូវបានគិតថា មានគ្រប់ទីកន្លែង «ដែលបង្កប់ស៊ីរូងផ្ទៃក្នុង» ត្រៀមខ្លួនវាយសម្រុកក្នុងពេលដែលកម្លាំងវៀតណាមនៅតាមជនបទវាយតទល់ដោយចំហជាមួយនឹងកងទ័ពកម្ពុជាប្រជាធិបតេយ្យ ។ ខ្មាំងបង្កប់តែងតែគ្រោះថ្នាក់បំផុត ។ នៅក្នុងខែកក្កដា ឆ្នាំ១៩៧៨ ក្រោយពីវគ្គសិក្សាដែលដាក់ឈ្មោះថា «អំពីបញ្ហាវៀតណាមបង្កប់» អ្នកសួរចម្លើយជាន់ខ្ពស់ ឈ្មោះ ប៉ុន សរសេរថា÷

> ជាការពិតណាស់ វៀតណាមគឺនៅមានបង្កប់នៅក្នុងទីក្រុងភ្នំពេញ ពីព្រោះភ្នំពេញមិនទាន់បានបោសសម្អាតពួកក្បត់អស់នៅឡើយទេ ។ ឯកសារនៅសន្តិបាលបង្ហាញថា ជនក្បត់បានបង្កប់ពួកវៀតណាមនៅភ្នំពេញ នៅពាយ័ព្យ និងនៅភូមិភាគដទៃៗទៀត ។[៨៦]

ចម្លើយសារភាពមួយចំនួនបង្ហាញថា វៀតណាមបានលាក់ខ្លួននៅតាមផ្ទះឬនៅតាមដីឡូ ដែលទុកចោលនៅម្តុំក្រសួង មន្ទីរសំខាន់ៗមួយចំនួននៅទីក្រុងភ្នំពេញ ។ ក្នុងចំណោមចម្លើយសារភាពទាំងនេះ គ្មានចម្លើយសារភាពណាមួយត្រូវបាន ឌុច និងកូនចៅខ្លួនទាត់ចោលថាជារឿងស្រមើស្រមៃនោះទេ ហើយក៏គ្មានឈ្លើយសង្គ្រាម និងគិញវៀតណាមណាម្នាក់ដែលត្រូវបានសួរចម្លើយនៅក្នុងគុកនេះឆ្លើយថា ខ្លួនត្រូវលាក់ទុកដោយជនជាតិខ្មែរដែរ ។ ករណីទាំងនេះប្រហែលជាឧទាហរណ៍ដ៏ច្បាស់ក្រឡែតនៅក្នុងបណ្ណសារនៃគំនិតរវើរវាយដែលអ្នកទោស អ្នកសួរចម្លើយ និងមជ្ឈិមបក្សដឹងថាមិនមានមូលដ្ឋានពិតប្រាកដ ។ ទន្ទឹមពេលជាមួយគ្នានេះដែរ ការក្បត់របបគឺមានន័យថា លាក់បំពួនវៀតណាមនៅក្នុងខ្លួន ដូចជាអំពើក្បត់ដែលស្មើនឹងនិន្នាការ «គហបតី» យ៉ាងដូច្នោះដែរ ។[៨៧]

ដូចជាផែនទីបង្ហាញពីទីតាំងលាក់អាវុធ ថ្នាំពេទ្យ ថ្នាំពុល និង វៀតណាម ដូច្នេះដែរ ដែលជាការនិយាយរៀបរាប់ការពិតតាមរយៈចម្លើយសារភាព ចម្លើយសារភាពភាគច្រើនគឺសុទ្ធតែនិយាយពីរឿងថ្មីៗ ដោយសារថា អ្នកទោសត្រូវបានបង្ខំឲ្យសារភាពថាបានធ្វើការឲ្យខ្មាំងដែលមជ្ឈិមបក្សកំពុងតែរកមុខ ។ គ្មានអ្នកណាម្នាក់ «លាក់វៀតណាម» ទេនៅក្នុងឆ្នាំ១៩៧៦ ។ ម្យ៉ាងវិញទៀត នៅឆ្នាំ១៩៧៨ ក៏គ្មានអ្នកណាម្នាក់ឆ្លើយថា ធ្វើការឲ្យរបប លន់ ណុល ដែរ ។ តាមធម្មតា «កំហុស» របស់អ្នកទោសក៏មានការទាក់ទងជាមួយនឹងការងាររបស់ខ្លួនដែរ ។ ដូច្នេះ អ្នកទោសដែលធ្វើការខាងកសិកម្មបានឆ្លើយថា ខ្លួនបានធ្វើឲ្យម៉ាស៊ីនខូច ធ្វើឲ្យទឹកលិចស្រូវ ដុត លួច និង ដកស្រូវ ដំណាំ បំផ្លាញ សម្ភារៈ និងធ្វើឲ្យបសុសត្វបាត់ ដោយមិនមើលឲ្យដិតដល់ និងកាប់ផ្តួលដើមឈើហូបផ្លែស្រេចតែទំនើងចិត្ត ។ កម្មកររោងចក្រឆ្លើយថា ធ្វើឲ្យម៉ាស៊ីនខូច លួចសម្ភារផ្សេងៗ រៀបចំទំនិញខុស និងមានផែនការជាមួយកម្មករដូចគ្នាក្នុងការបំផ្លិចបំផ្លាញខ្សែសង្វាក់ផលិតកម្ម ។ អ្នកដាំស្លនិយាយថា បានប៉ុនប៉ងជាច្រើនលើកក្នុងការបំពុលថ្នាក់ដឹកនាំខ្ពស់ៗ បំផ្លាញឆ្នាំងដីសម្រាប់ដាំស្ល បម្រើបាយភ្ញៀវចិនដោយប្រើចានប្រឡាក់ប្រឡូកដោយធូលីដីដើម្បី «កម្ទេចទំនាក់ទំនងជាមួយចិន» ឬថា ដាក់គ្រួស ឬលាមកនៅក្នុងឆ្នាំងសម្ល ។ ស្ត្រីម្នាក់ដែលរៀបចំបាយសម្រាប់ «ភ្ញៀវ» ចិនប្រចាំនៅក្រសួងការបរទេសនិយាយថា ខ្លួនបាន «រិះរកមធ្យោបាយចង់បំផ្លាញនយោបាយភ្ញៀវ» ដោយដាក់សម្ងំផាស់ឆ្អិនជ្រុល និងដាក់ស្លាបព្រាបាក់ឲ្យហូប ។[៧៨] អ្នកធ្វើការខាងអគ្គិសនីសារភាពថា បានលួចផ្តាច់ភ្លើង ចំណែកឯអ្នកធ្វើការនៅក្រសួងការបរទេសវិញនិយាយថា បានទាក់ទងជាមួយអ្នកការទូតបរទេសប្រចាំនៅទីក្រុងភ្នំពេញ ឬជាមួយ «ភ្នាក់ងារខ្មាំង» នៅក្នុងបេសកកម្មនៅបរទេស ។ បុគ្គលិកពេទ្យកម្ពុជាប្រជាធិបតេយ្យឆ្លើយថា បានចាក់ថ្នាំពុលឲ្យអ្នកជំងឺ លួចឬប្រើថ្នាំខុស និងរួមភេទជាមួយអ្នកដេកពេទ្យនិងជាមួយពេទ្យដូចគ្នា ។ អតីតអ្នកជំងឺម្នាក់បានឆ្លើយថា បានធ្វើពុតជាឈឺនិងញ៉ែគ្រូពេទ្យស្រីៗ ។ អ្នកបើកបររថយន្តសារភាពថា បានធ្វើឲ្យមានគ្រោះថ្នាក់ដោយ «ចេតនា» ធ្វើឲ្យបែកបាក់និងបង់ខាតដល់កម្មករដែលជិះរថយន្តខ្លួន ដឹកកម្មកររថភ្លើងធ្វើឲ្យខូចវ៉ាហ្គុង(ទូ) រថភ្លើង ។ យុទ្ធជនឆ្លើយថា បានរត់ចោលជួរ លាក់អាវុធនិងគ្រាប់រំសេវ និងថា បាននិយាយជាមួយបនក្បៀនរបស់ខ្លួនដែលនិយាយមើលងាយរបបនេះ ។ ចំណែកឯអ្នកធ្វើការនៅមន្ទីរស-២១ សារភាពថា ខ្លួនធ្វើការយឺត រៀបចំឯកសារឲ្យ«ច្របូកច្របល់មិនដឹងក្បាលកន្ទុយ» ឲ្យអ្នកទោសរត់គៀសខ្លួនពីគុក មិនឲ្យអ្នកទោសបត់ជើងធំ និងវាយអ្នកទោសទាល់តែស្លាប់ ។ អ្នកដែលធ្លាប់រស់នៅបរទេសនិយាយថា ខ្លួនលង់តាមឥទ្ធិពលបរទេសដូចជា «សេរីនិយម» ។ អ្នកការទូតសារភាពថាបានសន្ទនាជាមួយមន្ត្រីនៅបរទេស ។

នៅពេលដែល «អ្នកមានកំហុស» ត្រូវបាននាំយកមកមន្ទីរស-២១ គ្មានសកម្មភាពណាមួយត្រូវបានចាត់ទុកថាជារឿងចៃដន្យទេ ទោះជាសកម្មភាពពិតឬប្រឌិត សំខាន់ឬមិនសំខាន់ក៏ដោយ ។ តើទៅជាយ៉ាងម៉េចទៅវិញ បើមេដឹកនាំបក្សអនុវត្តតាមច្បាប់ប្រវត្តិសាស្ត្រនោះ? អារម្មណ៍ប្រឆាំងនឹងបដិវត្តន៍របស់អ្នកទោសដែលស្តែងឲ្យឃើញតាមរយៈការចាប់ខ្លួនផ្ទាល់និងតាមគំនិតរបស់អ្នកសួរចម្លើយ គឺជះឥទ្ធិពលដល់អ្វីៗគ្រប់យ៉ាងដែលខ្លួនបានប្រព្រឹត្ត រួមទាំងអ្វីដែលអាចកើតឡើងចំពោះអ្នកដទៃទៀតដែលជាការបម្រើ

ដោយស្មោះស្ម័គ្រចំពោះបក្ស ។ «បទល្មើស» ដែលត្រូវផ្តន្ទាទោសតាមច្បាប់ត្រូវបានកម្រិតទៅតាមទំហំនៃ «អំពើក្បត់» ដោយបង្ហាញនូវមូលហេតុក្បត់ចំពោះអ្វីៗដែលអ្នកទោសបានធ្វើ ។

ស្ថិតនៅក្រោមការបំភិតបំភ័យឲ្យរកគំនិតច្នៃប្រឌិត ប៉ុន្តែដោយការបង្ខំឲ្យនឹកស្រមៃនោះ អ្នកទោសបានខំ «រកនឹក» រាល់កំហុសទាំងឡាយដែលអ្នកសួរចម្លើយគ្មានបន្ទូរដៃនិងដីគួរឲ្យរន្ធត់ចង់ឲ្យខ្លួនឆ្លើយ ។ ជាលទ្ធផល អ្នកទោសខ្លះបានបង្ហាញនូវចម្លើយដ៏ចម្លែកដើម្បីដាក់ចេញជាចម្ងល់អំពីការរៀបចំបណ្តុំសារទាំងអស់នៅមន្ទីរស-២១ ។ ឧទាហរណ៍ ឡឿន មឿន កងទ័ពនៅវរសេនាធំលេខ១៧១ បានឆ្លើយថា៖

នៅខែ១ ឆ្នាំ១៩៧៧ ខ្ញុំបានបាញ់ស្ពានទូកវៀតណាមអស់បីគ្រាប់ ។ បន្ទាប់ពីបាញ់រួច ខ្ញុំបានរាយការណ៍ទៅ [ប្រធានរបស់ខ្ញុំ] សុវណ្ណា ។ នៅខែ២ ឆ្នាំ១៩៧៧ សុវណ្ណា បានបញ្ជាខ្ញុំឲ្យទៅបាញ់ស្ពានទូកចិនបីគ្រាប់ ហើយពីរគ្រាប់ទៀតបាញ់ដាក់សណ្ឋាគារសម្រាប់កម្មករក្មេងៗជនជាតិចិនស្នាក់នៅ ដើម្បីផ្តាច់នយោបាយរបស់កម្ពុជាចំពោះចិន ។ ក្រោយមក ខ្ញុំបានរាយការណ៍ទៅ សុវណ្ណា អំពីបញ្ហាដែលខ្ញុំជួបប្រទះក្នុងការប្រមូលកម្លាំង... ។ ក្រោយមកទៀតនៅខែ៣ ឆ្នាំ១៩៧៧ ខ្ញុំបានប្រាប់ សុវណ្ណា ថា ជុត និងខ្ញុំបានទៅបាញ់ដាក់ស្ពានទូកអាល់បានីបីគ្រាប់ ដាក់ស្ពានទូកកូរ៉េបីគ្រាប់ និងដាក់វិមានឯករាជ្យមួយគ្រាប់ ។ បាញ់ហើយខ្ញុំបានទៅប្រាប់ សុវណ្ណា អំពីការលំបាកនៅក្នុងការបាញ់នេះ ។ នៅពេលខ្ញុំប្រាប់គាត់ សុវណ្ណា និយាយថា «សមមិត្ត មិត្តគួរតែលាក់បាំងឲ្យជិត មិនត្រូវឲ្យគេដឹងថា មិត្តពាក់ព័ន្ធក្នុងសកម្មភាពបាញ់នេះទេ ។ យើងគួរតែរៀបចំផែនការខ្លាំងៗមួយចំនួនទៅថ្ងៃអនាគត ហើយប្រើប្រាស់កម្លាំងដែលមិត្តប្រមូលបានកន្លងមក ។ យើងចាំបាច់ត្រូវតែបាញ់ដាក់ស្ពានទូក កន្លែងអគ្គិការ រោងចក្រនិងក្រសួងមន្ទីរនានានៅភ្នំពេញ» ។ ក្រោយពីទទួលសេចក្តីណែនាំនេះរួចមក ខ្ញុំបានត្រឡប់មកផ្ទះវិញ ហើយនៅថ្ងៃទី២៧ ខែ៣ ឆ្នាំ[១៩]៧៧ ខ្ញុំត្រូវបានចាប់ខ្លួនតែម្តង ។[៨៩]

ក្នុងចំណោម «ទោសកំហុស» ចំពោះសកម្មភាពមិនល្អដែលរៀបរាប់មកនេះនិងនៅក្នុងចម្លើយសារភាពនានា គ្មានទោសកំហុសណាមួយអាចត្រូវដាក់ទណ្ឌកម្មដល់ជីវិតបានទេកាលពីសម័យមុនបដិវត្តន៍ ។ អំពើខ្លះមិនទាំងធ្វើឲ្យគ្រួសារ ឬអ្នកជិតខាងអ្នកប្រព្រឹត្តបទល្មើសចាប់អារម្មណ៍ទៀតផង ។ ប៉ុន្តែជាការសំខាន់ណាស់សម្រាប់បុគ្គលិកធ្វើការនៅមន្ទីរស-២១ ក្នុងការស្រង់យកចម្លើយសារភាពដែលឆ្លើយថា បានធ្វើអ្វីមួយ ។ ឧទាហរណ៍ អឿ អៀប បានឆ្លើយថា មាន«អាកប្បកិរិយាចង្អៀតចង្អល់» ដោយមិនស្រោចទឹកដំណាំ និងមិនគោរពការរស់នៅជាសមូហភាព ។ ម៉ុល មឿន បានឆ្លើយថា បាន «ហូបច្រើនដូចជាកម្មាភិបាលដែរ» ចំណែកឯ ពៅ ឈឹម ថា គាត់«ខ្ជិលហើយមិនត្រឹមត្រូវនិងនិយាយពីរឿងស្រីញី» ។[៩០]

ចម្លើយសារភាពក្រោយឆ្នាំ១៩៧៦ ភាគច្រើនមានបញ្ចូលផ្នែកមួយដាក់ថា «ផែនការ» ដែលរៀបរាប់អំពីសកម្មភាពប្រឆាំងនឹងបដិវត្តន៍ដែលអ្នកទោសសន្មឹមទុកថានឹងអនុវត្ត ប៉ុន្តែត្រូវខកខានដោយសារខ្លួនត្រូវចាប់ឃុំឃាំង ។ ចំពោះអ្នកទោសជាច្រើននាក់ «ផែនការ» របស់ខ្លួនបានបង្ហាញនូវភាពមិនគួរឲ្យចាំបាន ឬ

នឹកស្មានដល់ ។ ជាក់ស្តែងអ្នកសួរចម្លើយជាញឹកញយ បានតវ៉ានៅក្នុងចំណាររបស់ខ្លួនដាក់លើចម្លើយសារភាពថា «ផែនការ»របស់អ្នកទោសមានលក្ខណៈ«ច្របូកច្របល់» «ខ្វះខាត» ឬ «មិនច្បាស់លាស់» ។ ផែនការមួយចំនួនត្រូវបាន«លាតត្រដាង»ក្រោយពីការធ្វើទារុណកម្មដ៏ធ្ងន់ធ្ងរ ។ ទម្រង់ចម្លើយសារភាពដែលចាំបាច់ត្រូវមានគឺថា អ្នកទោសម្នាក់ៗដែលត្រូវបានសួរចម្លើយយូរ នឹងត្រូវធ្វើឯកសារដោយភ្ជាប់មកជាមួយ«ផែនការ»ផង ។ វាជាការសំខាន់សម្រាប់ប្រវត្តិសាស្ត្ររបស់បក្សនិងសុខុមាលភាពរបស់អ្នកដែលនៅក្នុងជួរបក្ស ដោយសារតែ«ផែនការ»មានច្រើនហើយគ្មានប្រសិទ្ធភាព ។

«ផែនការ»ជាច្រើនដូចដែលត្រូវបានរៀបរាប់នៅក្នុងចម្លើយសារភាពនានា មិនសមហេតុសមផល ហើយនៅក្នុងករណីជាច្រើន ផែនការទាំងនេះប្រហែលជាបញ្ជាក់អំពីអ្វីដែលអ្នកសួរចម្លើយជឿថា ជាការសមរម្យ ។ ដូច្នេះ យុទ្ធជនមកពីជនបទបានឆ្លើយសារភាពថាបានរៀបចំផែនការធ្វើឃាត«អង្គការ» ឬ «បងលេខមួយ» ដែលខ្លួនមិនដែលបានឃើញមុខទាល់តែសោះ ឬថា «ផ្តួលរំលំបដិវត្តន៍» នៅក្នុងពេលដែលខ្លួនមានគ្នាតែមួយក្តាប់តូចនិងគ្មានអាវុធនោះ ។ អតីតឆ្មាំគុកមន្ទីរស-២១ ឈ្មោះ ទុំ ធុន និយាយថា បានរៀបចំផែនការជាមួយអ្នកធ្វើការជាមួយក្នុងការបន្ទរខ្នោះអ្នកទោស បើកទ្វារចំហ ធ្វើជាដេកលក់នៅច្រកចេញចូលដើម្បីបើកដៃឲ្យអ្នកទោសលួចរត់ចេញពីគុក ហើយថា ខ្លួនបានវ៉ៃអ្នកទោសរហូតដល់ស្លាប់ ។[៩១] គួរឲ្យចាប់អារម្មណ៍ដែរ ទុំ ធុន មិនបានឆ្លើយថាបានប្រព្រឹត្តកំហុស ។ បើឆ្លើយត្រង់នឹងនាំឲ្យមានបញ្ជីស្មើឈ្មោះខ្លួនមិនខានឡើយ ។ ឆ្មាំនៅមន្ទីរស-២១ ម្នាក់ទៀតឈ្មោះ អាន ហុត បានឆ្លើយថា ខ្លួន «បានរៀបចំផែនការធ្វើជាដេកលក់នៅពេលយាម» ។ អ្នកកាន់ខាងការស្នើសម្រាប់ថតភាពយន្តឈ្មោះ គីម យូ បានរៀបចំផែនការ «បន្តុំទំនាស់ក្នុងជួរភ្ញៀវបរទេស» ដោយរៀបចំបញ្ចាំងខ្សែភាពយន្តជូនភ្ញៀវទស្សនាមិនបានល្អ ។ ឈ្មោះ ជួន នៅកងពលលេខ៤៥០ បានសារភាពថា ខ្លួនបានរៀបចំផែនការ «ផ្លាស់ប្តូរសតិអារម្មណ៍» អ្នកធ្វើការជាមួយបានសាមសិបនាក់ដោយគ្មាននិយាយច្បាស់ថា ផែនការនេះនឹងត្រូវសម្រេចតាមរបៀបណាទេ ។ ចំណែកឯអ្នកទោសម្នាក់ទៀតបានរៀបចំផែនការបំផុសឲ្យមិត្តភក្តិរបស់ខ្លួនរត់ទៅប្រទេសថៃ ឬប្រទេសវៀតណាម ។ និយាយរួមផ្នែកនិយាយអំពី «ផែនការ» នៅក្នុងចម្លើយសារភាពនៅក្នុងករណីជាច្រើន មើលទៅហាក់ដូចជាត្រូវបានផ្គុំគ្នាដោយអ្នកធ្វើការនៅមន្ទីរស-២១ ។ ផែនការនេះបង្ហាញរឿងរ៉ាវតិចតួចបំផុត ហើយប្រហែលជាការប្រឌិតឲ្យដូចៗគ្នាផងនៅក្នុងឯកសារទាំងនេះ ។[៩២]

លិខិតប្រវត្តិរូបខ្លីៗច្រើនបញ្ចប់ដោយមានដាក់ឈ្មោះ និងអាសយដ្ឋានរបស់សមាជិកគ្រួសារដែលអាចនឹងត្រូវបានហៅឲ្យមកធានាអះអាងថា រាល់សំណេរអំពីប្រវត្តិជីវិតនេះពិតជាត្រឹមត្រូវមែន ។ នៅក្នុងចម្លើយសារភាពឈ្មោះអ្នកទាំងនេះតែងតែត្រូវបានជំនួសនៅចុងអត្ថបទដោយពាក្យថា «ខ្សែក្បត់» និង «ខ្សែសម្ងាត់» ។ បញ្ជីទាំងនេះហាក់ដូចជាមានភាពងាយស្រួលសម្រាប់អ្នកសួរចម្លើយក្នុងការស្រង់យកពត៌មានហើយទិន្នន័យនៅក្នុងបញ្ជីនេះក៏ងាយនឹងអាចបញ្ជាក់ពីប្រភពផ្សេងៗទៀត ។ ក្នុងករណីជាច្រើនអ្នកទោសបានផ្តល់ឈ្មោះមនុស្សដែលត្រូវបានចាប់ខ្លួនហើយ ឬដែលបោសសម្អាតដោយអង្គការរួចហើយ ។ ឈ្មោះទាំងនេះត្រូវបានចារថា «ចាប់» ចំណែកឈ្មោះមួយចំនួនទៀតត្រូវបានដាក់ជាសញ្ញា ខ ប្រហែលជាចង់

និយាយថា ឈ្មោះនេះត្រូវបានសម្លាប់រួចហើយ ។ បញ្ជីដាក់ថា"ខ្មែរ"ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការចាប់ខ្លួនបន្តទៅទៀត ។ ឈ្មោះទាំងនេះក៏ត្រូវបានយកមកសង្ខេបនិងវាយជាអក្សរលីលេខដោយដាក់ឈ្មោះអ្នកដែលពាក់ព័ន្ធនៅតាមអង្គភាពយោធា តំបន់ មន្ទីរ រោងចក្រ ឬ ការដ្ឋាននានា ។[៩៣]

ហេតុអ្វីទៅបានជាវរល់តែចងក្រងនិងប្រឌិតជាឯកសារគរដូចភ្នំយ៉ាងដូច្នេះទៅវិញ? មូលហេតុមួយទំនងគួរឲ្យជឿដូចដែលខ្ញុំលើកឡើងនៅក្នុងវគ្គទី៣ គឺថាថ្នាក់ដឹកនាំបក្សចង់បានចម្លើយសារភាពដាក់ក្នុងប្រអប់ទុកជាឯកសារដើមសម្រាប់បញ្ជាក់ពីការអបអរជ័យជម្នះជាប្រវត្តិសាស្ត្ររបស់បក្សបន្តទៅមុខឥតឈប់ឈរ ។ មូលហេតុមួយទៀតគឺថា ចម្លើយសារភាពនិងរូបថតពាក់កណ្ដាលខ្លួនបានបង្ហាញពីគោលគំនិតមិនទុកចិត្តនិងសង្ស័យរបស់ថ្នាក់ដឹកនាំបក្ស ហើយឯកសារទាំងនេះត្រូវបានប្រើប្រាស់សម្រាប់ធ្វើឲ្យថ្នាក់ដឹកនាំទាំងនេះជឿថា ខ្មាំងរាប់មិនអស់កំពុងតែត្រូវបានវែកមុខ សួរចម្លើយ និងសម្លាប់ ។ ក៏ប៉ុន្តែការពន្យល់ផ្សេងៗទៀត មានឫសគល់ចេញមកពីសំណេរប្រវត្តិសាស្ត្រ និងប្រពៃណីនៅក្នុងប្រទេសកម្ពុជា ។

នៅក្នុងប្រទេសកម្ពុជាមុនសម័យបដិវត្តន៍ អំណាចកណ្ដាលនិងការកាន់កាប់ឯកសារប្រវត្តិសាស្ត្រពិតជានៅជាប់គ្នាស្អិតរមួត ។ កាលប្បវត្តិជាប្រវត្តិសាស្ត្រត្រូវបានរៀបចំនៅព្រះបរមរាជវាំង និងព្រះរាជបរិពារជាន់ខ្ពស់ដើម្បីប្រារព្ធជាព្រះរាជពិធីនិងធ្វើឲ្យពង្សាវលីឲ្យមានលក្ខណៈស្របច្បាប់សម្រាប់អ្នកកាន់អំណាចនិងអ្នកស្នងរាជ្យបន្តបន្ទាប់ទៀត ។[៩៤] ឯកសារអំពីវីរបុរសដែលតម្កល់ទុកនៅព្រះបរមរាជវាំងក្លាយជាផ្នែកមួយនៃសញ្ញាណសន្តតិវង្សរបស់ព្រះរាជា ។ នៅទូទាំងប្រទេសកម្ពុជា ការសរសេរប្រវត្តិសាស្ត្រត្រូវបានឲ្យតម្លៃខ្ពស់ណាស់ មួយផ្នែកគឺដោយសារការចេះអាន ចេះសរសេរគឺជាជំនាញមួយដែលបព្វជិត និងសិស្សឃ្លាំមើលយ៉ាងយកចិត្តទុកដាក់ ហើយមួយផ្នែកទៀតគឺដោយសារអត្ថបទសំណេរជាច្រើនផ្ទុកនូវមាតិកាដែលមានសារប្រយោជន៍ (និងសម្ងាត់) ឬមានឥទ្ធិពល ។ នៅក្នុងន័យព្រះពុទ្ធសាសនា ប្រវត្តិសាស្ត្រត្រូវបានចាត់ទុកថាជាទម្រង់ការនៅក្នុងដំណើរធ្លាក់ចុះដែលមិនអាចទប់បានក្នុងអំឡុងពេលរាប់ពាន់ឆ្នាំក្រោយពីព្រះពុទ្ធចូលទីវង្គតនិងត្រាស់ដឹងនៅឆ្នាំ៥៤៣មុនគ្រិស្តសករាជ ។ នៅក្នុងអំឡុងពេលដ៏វែងនេះប្រវត្តិសាស្ត្រមានចារិកតាមសន្តតិវង្សជានិទានខ្លីៗគួរឲ្យចាប់អារម្មណ៍តែមិនមែនជាការពិត និងកើតមានឡើងក្នុងរយៈពេលដ៏ទៀងទាត់ដោយផ្ដោតសំខាន់លើសកម្មភាពរបស់អ្នកកាន់អំណាច និងបញ្ចូលនិទានខ្លីៗ (យកមកពីកាលប្បវត្តិផ្សេងៗទៀតដោយដូរឈ្មោះ) ដែលនិយាយអំពីរឿងគួរឲ្យសប្បាយនៅក្នុងសមរភូមិ ពិធី បុណ្យផ្សេងៗ និងដំណើររឿងស្នេហាមួយចំនួនទៀត ។

ក្រោមរបប ប៉ុល ពត ឯកសារប្រវត្តិសាស្ត្រក៏ត្រូវបានតាក់តែងឡើង គ្រប់គ្រង និងកាន់កាប់ដោយ "ក្បាលម៉ាស៊ីន"ដឹកនាំ ហើយការនិយាយរឿងរ៉ាវប្រវត្តិសាស្ត្រនៅតែពិពណ៌នាអំពីភាពបរាជ័យរបស់ខ្មាំងសត្រូវ ។ នៅពេលទន្ទឹមគ្នានេះដែរ ការសរសេរអំពីប្រវត្តិសាស្ត្រត្រូវបានចាប់ផ្ដើមប្រឌិតតាមវិធីមួយផ្សេង ។ របៀបសរសេរទាំងពីរនេះទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលគាំទ្រដល់អ្នកកាន់អំណាចណាម្នាក់ ។ ចំណែកឯប្រវត្តិសាស្ត្របែបម៉ាក្ស-ឡេនីន គឺទាក់ទងនឹងការពន្យល់ពីបាតុភូត ការអង្កេតពីរឿងពិតដោយមានការពិភាក្សានិងការជជែកវែកញែកច្បាស់លាស់រវាងមនុស្សគ្រប់ឋានៈ ដែលជារបៀបសរសេរបែប

ទំនើបមួយប្រហែលជាដើរតាមគន្លងច្បាប់វិទ្យាសាស្ត្រ ។ ដោយធ្វើម្ចាស់បានលើច្បាប់ទាំងនេះតាមការគិត គឺបក្សម៉ាក្ស-ឡេនីនដូចជាបក្សកុម្មុយនិស្តកម្ពុជាដែរ គឺអាចឆក់យកអំណាចមកគ្រប់គ្រងនិងរក្សាខ្លួនឯងផ្ទាល់រហូតមក ។ ដូច្នេះ នៅពេលដែលអ្នកនាំពាក្យរបស់បក្សប្រកាសនៅឆ្នាំ១៩៧៦ថា «ប្រវត្តិសាស្ត្រពីរពាន់ឆ្នាំ» បានបញ្ចប់ បុគ្គលនោះប្រហែលជាមិនត្រឹមតែចង់និយាយថា រាល់ការអនុវត្តន៍កាលពីអតីតកាលបានរលាយបាត់អស់ហើយនោះទេ តែថែមទាំងចង់និយាយថា ប្រវត្តិសាស្ត្រផ្តោតតែទៅលើបក្សពេលនេះអាចជំនួសកាលប្បវត្តិនិងអ្វីៗដែលមានចរិតដូចគ្នានេះ ។ ការសរសេរប្រវត្តិសាស្ត្រកម្ពុជាក៏ដូចជាទំនាក់ទំនងសង្គមត្រូវបានក្រឡាប់ចាក់អស់រលីង ។

នៅក្នុងឯកសារដែលគ្មានចុះកាលបរិច្ឆេទមានចំណងជើងថា «លក្ខណៈសម្បត្តិរបស់បក្សកុម្មុយនិស្តកម្ពុជា» អ្នកនាំពាក្យរបស់បក្សបានលើកឡើងចំណុចទាំងនេះក្រោយពេលផ្តល់នូវចំណុចសំខាន់ៗនៃប្រវត្តិបក្ស÷

> ពួកជិះជាន់កេងប្រវ័ញ្ចបានសរសេរប្រវត្តិដើម្បីជិះជាន់កេងប្រវ័ញ្ចប្រជាជនកាន់តែខ្លាំងថែមទៀត ។ ចំណែកយើងវិញ សរសេរប្រវត្តិរបស់ប្រទេសយើង គឺយើងសរសេរអំពីការតស៊ូរបស់បក្សនិងប្រជាជនយើងដើម្បីឯករាជ្យហើយមិនមែនធ្វើជាខ្ញុំគេទៀតទេ ។ ឧទាហរណ៍ ពេលយើងសរសេរប្រវត្តិអង្គរ យើងសរសេរថា ប្រជាជនជាអ្នកធ្វើ នេះជាការពិត ប្រជាជនជាអ្នកធ្វើ មិនមែនស្តេចធ្វើទេ ។[៩៥]

ប្រវត្តិបក្សជាច្រើនចាប់ពីទសវត្សរ៍ទី៧០ បង្ហាញពីការផ្តោតសំខាន់និងវិធីសាស្ត្រដែលមានលក្ខណៈខុសគ្នា ។[៩៦] ជាមួយអ្វីដែល ទីម័រធី ខានី បានហៅថា «ជ័យជម្នះមិនសង្ឃឹមថានឹងបាន» របស់បក្សនេះនៅខែមេសា ឆ្នាំ១៩៧៥ ។ បក្សកុម្មុយនិស្តកម្ពុជាបានបញ្ចប់នូវអ្វីដែលខុះខាតនៅក្នុងឯកសារទាំងឡាយកាលពីដើមដំបូង ហើយក្តាប់បាន «កង់ប្រវត្តិសាស្ត្រ» ។ ដោយទទួលបានជ័យជម្នះប្រវត្តិសាស្ត្រកម្ពុជា «កាលពីពីរពាន់ឆ្នាំមុន» ប្រសព្វគ្នាជាមួយនឹងការឡើងកាន់អំណាចរបស់បក្ស ។ និយាយម្យ៉ាងវិញទៀត ជ័យជម្នះរបស់ជនកុម្មុយនិស្តនៅឆ្នាំ១៩៧៥ បង្ហាញច្បាស់អំពីអតីតកាលរបស់បក្ស ។ បំណកស្រាយផ្សេងៗអំពីសម័យកាលពីអតីត និងសត្រូវស៊ីសាច់ហុតឈាមរបស់បក្ស គឺបក្សមិនឲ្យអ្នកណាគិតដល់ ហើយបក្សត្រូវតែ«បោសសម្អាត»ចោលទាំងអស់ ។

ការទាក់ទិនរបស់មន្ទីរស-២១ នៅក្នុងការសរសេរប្រវត្តិសាស្ត្ររបស់បក្ស ចាប់ផ្តើមមានសារសំខាន់ក្រោយពីខែមេសា ឆ្នាំ១៩៧៦ នៅពេលដែល (ដូចដែលយើងឃើញស្រាប់) ភាពចលាចលផ្នែកយោធានៅទីក្រុងភ្នំពេញត្រូវបានថ្នាក់ដឹកនាំបក្សកុម្មុយនិស្តកម្ពុជាហៅថា ជាការបះបោរដែលគំរាមកំហែងដល់ការដឹកនាំរបស់បក្សនិងបំផ្លាញដល់ប្រវត្តិជោគជ័យដែលមានមកដល់បច្ចុប្បន្ន ។ ដោយសារមាន «ភ័ស្តុតាង» យ៉ាងច្រើនសន្ធឹកសន្ធាប់ស្តីអំពីការរួមគំនិតដែលចេញពីមន្ទីរស-២១ ដល់មជ្ឈមបក្ស ប្រវត្តិបក្សចាប់ពីពេល

នោះមកត្រូវបានយល់ជាទូទៅថា ជាការតស៊ូឥតចេះចប់ចេះហើយប្រឆាំងនឹងខ្មាំងផ្ទៃក្នុង ។ មន្ទីរស-២១ ក្លាយជាមុខកាំបិតដ៏មុតស្រួចរបស់របបកម្ពុជាប្រជាធិបតេយ្យ ។

ដូចដែលខ្ញុំបានលើកឡើងខាងដើមមកហើយថា ចម្លើយសារភាពដែលស្រង់មកពីមន្ទីរស-២១ បានបម្រើឲ្យគោលបំណងផ្នែកចិត្តសាស្ត្រដោយបង្ហាញចេញនូវគំនិតសង្ស័យនិងមិនទុកចិត្តរបស់ថ្នាក់ដឹកនាំនៃរបបនេះ ។ ចំពោះបញ្ហានេះ ភាពដូចគ្នារវាងវិធីសាស្ត្រ និងគោលបំណងរបស់អ្នកសួរចម្លើយ និងការយល់ឃើញរបស់លោក ហ្វ្រឺដ ដែលមានចរិតព្យាបាលរោគតាម «បុរាណវិទ្យា» គឺគួរឲ្យចាប់អារម្មណ៍មែនទែន ។ អ្នកសួរចម្លើយនៅមន្ទីរស-២១ ក៏ដូចជាមនោវិភាគវិទូដែរ គឺដឹកគាស់ការចងចាំរបស់«បុគ្គលមានកំហុស» ដែលត្រូវបានសន្មតថាលាក់បាំងប្រវត្តិសកម្មភាព ផែនការ និងខ្សែរយៈប្រឆាំងនឹងបដិវត្តន៍ ។[៩៧] អ្នកសួរចម្លើយមិនខុសពីមនោវិភាគវិទូជាច្រើនរូបទេ គឺបានធ្វើជាដឹងនូវអ្វីដែលខ្លួនកំពុងតែរុករក ហើយមានគំនិតមួយចំនួនទៅលើ «ការចងចាំ» ដែលខ្លួនចង់ឲ្យអ្នកទោស «រំពុកឡើងវិញ» ។ មិនតែប៉ុណ្ណោះអ្នកសួរចម្លើយដឹងអំពីទម្រង់ចម្លើយសារភាពពេញលេញ ប៉ុន្តែអ្នកទោសក៏ដូចជាអ្នកជំងឺចិត្តសាស្ត្រជាច្រើននាក់ទៀតមិនបានដឹងឡើយ ។

ទាក់ទងនឹងរឿងផ្សេងៗទៀត ការប្រៀបធៀបរវាងអ្វីដែលបានកើតឡើងនៅមន្ទីរស-២១ និងអ្វីដែលកើតឡើងមួយជងមួយកាលនៅក្នុងមនោវិភាគគឺយកជាការមិនបានទេ ។ នៅក្នុងការចាប់ផ្ដើមដំបូងអ្នកវិភាគកម្រនឹងងាកទៅប្រើអំពើហិង្សាណាស់ ចំណែកឯមន្ទីរស-២១ ឈរនិងដើរចេញដោយបោះបង់ចោលនូវដំណើរការកំពុងតែប្រព្រឹត្តទៅ ឬស្វែងរកដៃគូសន្ទនាដែលមានចរិតទន់ភ្លន់ មានក្ដីអាណិតអាសូរជាងអ្នកមុន ។ ចំណែកឯអ្នកទោសនៅមន្ទីរស-២១ គឺត្រូវបានសម្លាប់ចោលទាំងអស់ បន្សល់ទុកនូវចម្លើយសារភាពដែលជាអក្សរាចុងក្រោយពីផ្ទះមរណៈ ។ ទិដ្ឋភាពមួយទៀតនៃការសួរចម្លើយនៅមន្ទីរស-២១ ដែលផ្ទុយគ្នាទៅនឹងមនោវិភាគនោះគឺថា គំនិតរវើរវាយដែលកំពុងតែត្រូវបានដឹកគាស់សើរើបង្ហាញចេញនិងនិយាយចេញអំពីគុកសម្ងាត់របស់ ប៉ុល ពត មិនមែនជាអំពើដែលប្រព្រឹត្តដោយអ្នកទោសទេ ប៉ុន្តែជាអំពើដែលអ្នកទោសទទួលរងពីអ្នកសួរចម្លើយជួសមុខឲ្យចៅហ្វាយរបស់ខ្លួនក្នុងជួរមជ្ឈិមបក្ស ។ ភាពខុសប្លែកពីគ្នារវាងការវិភាគនិងការសួរចម្លើយគឺប្រហែលជាថាការវិភាគតាមទ្រឹស្ដីមានគោលបំណងធ្វើឲ្យអ្នកជំងឺមានភាពប្រសើរឡើង ចំណែកឯការសួរចម្លើយមានគោលបំណងស្រង់យកភ័ស្តុតាងពីអ្នកទោសដើម្បីយកមកប្រើក្នុងដំណើរនីតិវិធី ។ នៅពេលដែលការសួរចម្លើយនៅមន្ទីរស-២១ មានបំណងជួយជំរុញឲ្យមានចម្លើយដែលស្របគ្នាទៅនឹងទ្រឹស្ដីអប់រំតាមលទ្ធិម៉ៅនិយម បែបបទក្នុងការសួរទាំងពីរយ៉ាងនេះហាក់ដូចជាចូលគ្នាខ្លះ ។ ប៉ុន្តែទោះជាយ៉ាងនេះក្ដី ក៏នៅមានភាពដូចគ្នាមិនគួរឲ្យជឿរវាងការសន្ទនាទាំងពីរបែបនិងរវាងទំនាក់ទំនងអំណាចដែលផ្ទៀងម្ទាងៗដែរ ។ លោក ហ្វ្រឺដ ខ្លួនឯងធ្លាប់បានផ្ដល់ជាយោបល់ថា÷

> យើងមិនត្រូវជឿអ្វីដែលអ្នកជំងឺសរសៃប្រសាទនិយាយទេ យើងត្រូវទាញការសន្និដ្ឋានគ្រប់ពេល ហើយប្រាប់អ្នកជំងឺផងថា គេនៅលាក់រឿងអ្វីម្យ៉ាង...យើងត្រូវតែទទូចហើយទទូចទៀត យើងត្រូវ

> សម្ដែងការគោរពសន្ដាប់ម្ដងហើយម្ដងទៀត ហើយបង្ហាញថា យើងមិនចេះខុសទេ ធ្វើយ៉ាងនេះរហូតដល់យើងបានទទួលអ្វីម្យ៉ាង ។[៩៨]

វិធីរបស់អ្នកសួរចម្លើយនៅមន្ទីរស-២១ ដែលមានធម៌ត្រជាក់ជាងលោក ហ្រ៊ីដ នោះលើកឡើងនូវចំណុចដូចគ្នានេះដែរ នៅពេលយើងរំពុកឡើងនូវវាសនារបស់អ្នកទោស÷

> អ្នកទោសត្រូវសរសេរចម្លើយសារភាពតាមសំឡេងខ្លួនឯងផ្ទាល់ ច្បាស់ដោយប្រើប្រយោគ ពាក្យពេចន៍ និង គំនិតផ្ទាល់ខ្លួន ។ យើងគួរតែចៀសវាងកុំប្រាប់អ្នកទោសនូវអ្វីដែលគេចង់សរសេរ ។ នៅពេលរៀបរាប់ដំណើររឿងរបស់ខ្លួនឬសរសេរចប់សព្វគ្រប់ហើយ ទើបយើងលើកឡើងនូវចំណុចខ្សោយសង្កត់ឲ្យគេពន្យល់ថា តើហេតុអ្វីបានជាធ្វើយ៉ាងដូច្នេះ ហេតុអ្វីក៏កុហកយ៉ាងនេះ ហេតុអ្វីលាក់កំបាំងរឿងនេះ ហេតុអ្វីបានជានិយាយកាត់ៗបែបនេះទៅវិញ ។[៩៩]

ហេតុផលទីបីអំពីមូលហេតុនៃការថែរក្សាបណ្ណសារមន្ទីរស-២១ ត្រូវបានផ្ដល់ជាយោបល់ដោយលោក ភីតធ័រ ហូលឃ្វីស នៅក្នុងបរិបទផ្សេងដែលសរសេរអំពី“ការបញ្ចូលគ្រប់ព័ត៌មាន” ស្ដីពី “បរិយាកាសនយោបាយ”នៅសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត និងទំនាក់ទំនងរវាងការប្រមែប្រមូលព័ត៌មាន និងការថែរក្សាដោយប្រុងប្រយ័ត្នរបស់កងទ័ពរដ្ឋនេះទីមួយ ហើយទីពីរទៀតសរសេរអំពីអ្វីដែល ហូលឃ្វីស ហៅថាជាការយល់ឃើញរបស់លោក បូលសឺវិច ថាជា “ការឆ្លាក់” ឲ្យចេញជារូបរាងសង្គម ។

ដោយត្រូវបានមើលឃើញតាមផ្លូវនេះ ព័ត៌មានដែលប្រមូលបាននៅមន្ទីរស-២១ អាចយកមកប្រើប្រាស់ដោយមជ្ឈិមបក្ស ដើម្បីវាស់ស្ទង់ “បរិយាកាសនយោបាយ” របស់ប្រជាជនក្នុងគោលបំណងបង្ការកុំឲ្យមានការប្រឆាំងនឹងខ្លួន និងដើម្បីកសាងអ្នកដែលមិនទាន់ចាប់ដាក់គុកតាមមាគ៌ាបដិវត្តន៍ត្រឹមត្រូវ ។ ការប្រមូលប្រវត្តិរូបម្នាក់ៗដើម្បី “ដឹង” អំពីប្រជាជនគ្រប់ៗរូបនៅក្នុងប្រទេស គឺចូលនៅក្នុងគ្រោងការនេះហើយ ។ ម្យ៉ាងវិញទៀត កម្ពុជាប្រជាធិបតេយ្យហាក់ដូចជាជាប់ក្នុងគំនិតមួយថា ការប្រមូលព័ត៌មានពីខាងក្នុងខ្លួនបានបង្កើនសមត្ថភាពរបស់ខ្លួនក្នុងការជះឥទ្ធិពលទៅលើព្រឹត្តិការណ៍នានា ។ ជាអកុសលសម្រាប់របបនេះ ប៉ុន្តែជាការល្អទៅវិញសម្រាប់អ្នកដែលមានឱកាសបានរស់រានមានជីវិតជាច្រើន ព្រោះថាព័ត៌មានដែលប្រមូលបានតាមអំណាច ប្រើប្រាស់តាមចិត្តរបស់របបកម្ពុជាប្រជាធិបតេយ្យភាគច្រើនមានលក្ខណៈមិនពេញលេញ ឬពិតប្រាកដទេ ហើយ “ខ្មាំង” រាប់សែននាក់មិនដែលត្រូវបានរកឃើញឡើយ ។[១០០]

ប្រសិនបើយើងសន្មតថា ចម្លើយសារភាពនៅមន្ទីរស-២១“ពិត”នោះ គ្រាន់តែអានតែបន្តិចប៉ុណ្ណោះក៏អាចយល់បានថា ថ្នាក់ដឹកនាំបក្សដែលមានគំនិតខ្មៅងងឹតមានការសមគំនិតធ្វើអំពើទុច្ចរិតនិងក្បត់បានសម្ដែងចេញនូវភាពល្ងង់ខ្លៅដូចកូនក្មេង ទុកចិត្តលើមនុស្សខុសនិងនាំឲ្យយល់ខុសអំពីអាទិភាពនិងបំណងរបស់ប្រជាជន ។ ម្យ៉ាងវិញទៀត នេះគឺជាមាគ៌ាដែល ប៉ុល ពត ប្រកាន់យកដោយមានការកែប្រែបន្តិច

បន្ទូចក្រោយឆ្នាំ១៩៧៩ នៅក្នុងពេលនិយាយអំពីសម័យកាន់អំណាចរបស់ខ្លួន ។ ប៉ុល ពត បានប្រាប់កូនចៅរបស់ខ្លួនមួយចំនួនកាលពីឆ្នាំ១៩៨១ថា អ្វីដែលខុសនោះគឺថា ប៉ុល ពត ខ្លួនឯងបាន "ទុកចិត្តមនុស្សខ្លាំងជ្រុលពេក" ។ នៅក្នុងឆ្នាំ១៩៩៥ ប៉ុល ពត និយាយថា ការស្លាប់ដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺដោយសារ"យើងជាកូនក្មេងដែលទើបតែចេះដើរតេះតះ" ។ ការចៀសពីការទទួលខុសត្រូវរបស់ ប៉ុល ពត គឺងាយយល់ណាស់ ហើយការសោកស្ដាយរបស់ ប៉ុល ពត ក៏មិនពិបាកយល់ដែរ ។ ប៉ុន្តែកាលនោះកម្ពុជាប្រជាធិបតេយ្យមិនមែនជាក្មេងដូច ប៉ុល ពត ប្រៀបធៀបនោះទេ ពីព្រោះបើក្មេងមែននោះ តើធ្វើដូចម្ដេចទើបអាចដើរត្រាច់ចរមើលទិដ្ឋភាពប្រទេសកម្ពុជាទាំងមូលដោយបន្តឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរបាន ។[១០១]

ចម្លើយសារភាពនៅពេលដែលត្រូវបានស្រង់ចេញមកមិនមែនចង់បង្ហាញនូវភាពស្មោះត្រង់របស់មជ្ឈិមបក្សទេ ប៉ុន្តែជាភស្តុតាងនៃការដឹងពុរបស់បក្សកុម្មុយនិស្តកម្ពុជាទៅលើអ្វីៗ គ្រប់យ៉ាងដែលចេះតែបន្តកើតមានឡើងតែប្រមូលបានដោយយឺតៗ និងលទ្ធភាពឥតខ្ចោះរបស់ថ្នាក់ដឹកនាំក្នុងការក្ដាប់កង់ប្រវត្តិ-សាស្ត្រ ដើម្បីបង្កើតនិងគ្រប់គ្រងការរៀបរាប់ជាដំណើររឿងអំពីជ័យជម្នះរបស់បក្ស ។ ដូចគ្នាទៅនឹងរឿងរ៉ាវ"ជាតិ"និងបុគ្គលជាច្រើនដែលបានធ្វើដំណើរជាមួយគ្នាចូលក្នុងការរៀបរាប់ដែលមានការគ្រប់គ្រងនៃជ័យជម្នះរបស់បក្សកុម្មុយនិស្តកម្ពុជាទៅលើអ្វីដែលហៅថា "អាមេរិក" នៅខែមេសា ឆ្នាំ១៩៧៥នោះ "សកម្មភាពក្បត់" "ផែនការ" និង "ខ្សែក្បត់" ដែលកំពុងតែលាតត្រដាងក៏ត្រូវបានទាញចូលទៅក្នុងប្រវត្តិនោះដែរ ហើយ"ខ្មាំង"ត្រូវបានធ្វើឲ្យអស់លទ្ធភាពមុនពេលសកម្មភាពក្បត់ ឬ"ផែនការ"របស់ខ្លួនចាប់ដំណើរការ ។ ក្រោមការយល់ឃើញតាមរបៀបនេះ ចម្លើយសារភាពគឺជាមន្តអាគមដែលមិនត្រឹមតែការពារមជ្ឈិមបក្សមិនឲ្យមានខ្មាំងរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការពារមិនឲ្យមានអ្នកណាយល់ពីអ្វីដែលកំពុងតែកើតឡើងទៀតផង ។ ឌុច ប៉ុន ចាន់ និងអ្នកធ្វើការជាមួយខ្លួនគឺជាបព្វជិត ជាគ្រូពេទ្យ ជាកម្មករអណ្ដូងរ៉ែ អ្នកវះកាត់សត្វ និងអ្នកប្រវត្តិសាស្ត្រ ។ នៅក្នុងការប្រឌិតប្រវត្តិសាស្ត្រតាមគំនិតរវើរវាយរបស់ថ្នាក់ដឹកនាំខ្លួនដែលប្រហែលជាតាមគំនិតរបស់ខ្លួនដែរនោះ អ្នកទាំងនោះបានបម្រើចៅហ្វាយរបស់ខ្លួនបានយ៉ាងពេញចិត្ត ។

**ខគ្គធីប្រាំ:**

# បង្ខំឱ្យឆ្លើយ

ជំរំប្រមូលផ្ដុំណាហ្ស៊ីស្ថិតក្រោមការត្រួតពិនិត្យមើលការខុសត្រូវរបស់ វូល ហ្វែកសហ្សុី ។ ជំរំនេះមិនខុសគ្នាទៅនឹងមន្ទីរស-២១ ទេ ពោលគឺថា «អំពើហិង្សាហួសវិស័យគឺជាបាតុភូតប្រចាំថ្ងៃទៅហើយ» ។[១] ឯកសារមួយចំនួនបានមកពីគុកនេះ និងជាពិសេសបានមកពីអ្នកដែលធ្វើការខាងធ្វើទារុណកម្មបង្ហាញនូវអំពើដ៏គួរឲ្យភ័យរន្ធត់និងនិយាយដោយស្ងៀមស្ងាត់អំពីការឈឺចាប់ដែលពិបាកនឹងរៀបរាប់ ទោះជាអ្នកទាំងនោះនាំយើងទៅជួបជនរងគ្រោះក៏ដោយ ។ ឧទាហរណ៍ នៅខែកក្កដា ឆ្នាំ១៩៧៧ អ្នកសួរចម្លើយម្នាក់បានភ្ជាប់ចំណារមួយច្បាប់ដែលមិនមានចុះហត្ថលេខាជាមួយចម្លើយសារភាពរបស់ កែ គឹមហួត អតីតលេខាតំបន់៧ ភូមិភាគពាយ័ព្យ ។ កំណត់ហេតុនេះសរសេររៀបរាប់ថា÷

១) នៅព្រឹកថ្ងៃទី១៨ ខែកក្កដា ឆ្នាំ[១៩]៧៧ ខ្ញុំសម្រេចថាត្រូវតែធ្វើទារុណកម្ម ។ ខ្ញុំបានប្រាប់អ្នកទោសថា ខ្ញុំធ្វើដូច្នេះពីព្រោះខ្ញុំក្ដាប់ចំណុចខ្សោយដែលវានិយាយមិនទាន់បាន ហើយការសង្កត់សួររបស់ខ្ញុំមិនបានលទ្ធផលអ្វីសោះ ។ នេះជាជំហររបស់ខ្ញុំ ។ ខ្ញុំឃើញវាធ្លាក់ទឹកមុខតែមិនមានប្រតិកម្មអ្វីឡើយ ។ នៅពេលចាប់ផ្ដើមសួរ វានៅតែដដែល ។ ចំពោះសុខភាពរបស់វាវិញ វាបានស៊ីបបរ ប៉ុន្តែវាដេកមិនបានទេ ។ ពេទ្យនៅមើលវាហើយ ។

២) នៅព្រឹកថ្ងៃទី២០ ខែកក្កដា ឆ្នាំ៧៧ ខ្ញុំចាប់ផ្ដើមវាយវាម្ដងទៀត ។ ពេលនេះប្រតិកម្មវាគឺថាវាមិនមែនជាជនក្បត់ទេ ប៉ុន្តែអ្នកដែលចោទប្រកាន់វាទេដែលជាជនក្បត់ ។ សុខភាពវានៅមិនទាន់រឹងប៉ឹងទេ ប៉ុន្តែមិនមែនជារឿងធ្ងន់ធ្ងរអ្វីទេ ។

៣) ល្ងាចនិងយប់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ៧៧ ខ្ញុំសង្កត់សួរវាម្ដងទៀតដោយប្រើខ្សែភ្លើង និងលាមក ។ វាស្រែកថា«ពួកឯងវាយអញឲ្យងាប់តែម្ដងទៅ» ។ គេឲ្យវាស៊ីអាចម៍២-៣ស្លាបព្រា ហើយក្រោយមកទើបវាឆ្លើយពីឈ្មោះ ហ៊ីង, ចូវ, វ៉ា ។ល ។

៤) យប់នោះខ្ញុំវាយវាដោយខ្សែភ្លើងម្ដងទៀត ។ ឥឡូវនេះវាខ្សោយបន្តិចហើយ ។ ពេទ្យបានទៅមើលវាហើយ ។ វាបានសុំឲ្យសម្រាកសិន ។[២]

សម្ដីរបស់អ្នកសួរចម្លើយម្នាក់ទៀតបង្ហាញយ៉ាងច្បាស់នូវទំនាក់ទំនងលម្អៀងរវាងអ្នកធ្វើទារុណកម្មនិងជនរងគ្រោះ ។ លោក ម៉ៃឃើល ហុខល បានធ្វើការប្រៀបធៀបអ្នកទាំងពីរទៅនឹង «ការប្រយុទ្ធមួយទល់មួយ» ហើយនិងល្បែងអុក ។[៣]

មុនដំបូងខ្ញុំសួរខ្មាំងអំពីជីវិតនិងបក្សពួកវា ។ នៅពេលដែលខ្ញុំធ្វើយ៉ាងនេះ ខ្ញុំនិយាយពីរឿងវិន័យរបស់

មន្ទីរ[ស-២១] ហើយខ្ញុំប្រាប់វាថា ខ្លួនឯងថោកជាងសំរាមទៅទៀត ។

ខ្ញុំឲ្យវាគោរពខ្ញុំ ។ ខ្ញុំប្រាប់វាថា បើអញឲ្យឯងនិយាយអ្វី ឯងត្រូវតែនិយាយដាច់ខាត ។ ខ្ញុំឲ្យវាថ្វាយបង្គំរូបសត្វឆ្កែមួយក្បាល ដែលជាវិធីធ្វើទារុណកម្មទូទៅមួយមានរូបឆ្កែដែលមានដាក់ក្បាល ហូជីមិញ ។ ខ្ញុំបានវាយវានិងសួរវារហូតដល់វានិយាយថា វាធ្លាប់ធ្វើជាសេ.អ៊ី.អា ។ ក្រោយពីខ្ញុំវាយវាថែមទៀត វានិយាយថា វាចូលធ្វើសេ.អ៊ី.អានៅឆ្នាំ១៩៦៩ ។

នៅពេលវាឆ្លើយសារភាព ខ្ញុំមិនចាំបាច់វ៉ៃវាឈ្លេចយកប្រវត្តិរបស់វាដែលមិនទាន់និយាយទេ ប៉ុន្តែ នៅពេលវារួញរាមិនចង់ឆ្លើយ ឬនិយាយដល់ចំណុចខ្សោយនៅក្នុងប្រវត្តិវា ខ្ញុំវាយវា ហើយវ៉ៃវាឲ្យបញ្ជាក់ឲ្យបានច្បាស់ពីចំណុចទាំងឡាយនៅក្នុងប្រវត្តិវា ដែលពត៌មានសំខាន់ៗមានលក្ខណៈប្រហូកប្រហល់ ។[៤]

យើងគ្មានពាក្យអ្វីនឹងថ្លែងទេ នៅពេលជួបឯកសារនិងរូបថតគួរឲ្យរន្ធត់បែបនេះនៅមន្ទីរស-២១ ។ ពិតណាស់ ហ្សង់ អាមេរី, អ៊ីវ៉ាលិនទីន ដានីញ្ញែល និង អេឡេន ស្ការី បានបញ្ជាក់ដោយប្រើពាក្យយ៉ាងប៉ិនប្រសប់ថា បទពិសោធន៍ធ្វើទារុណកម្មមិនអាចរកពាក្យអ្វីមកនិយាយបានទេ ។ ស្ការី ថែមទាំងលើកឡើងថា ការឈឺចាប់បានលុបបំបាត់ភាសា ។ ប្រហែលជាយ៉ាងនេះហើយបានជាគ្មាននិយមន័យច្បាប់ច្បាស់លាស់សម្រាប់ពាក្យទារុណកម្ម ។ បើដូច្នេះមែន ហេតុអ្វីបានជាអ្នកនិពន្ធជាច្រើននៅតែបន្តព្យាយាមសរសេរអំពីពាក្យទារុណកម្មនេះទៀត? ហេតុអ្វីបានជាយើងគួរសរសេររឿងនេះ? ។ ការឈឺចាប់មិនអាចយកមក «សរសេរឲ្យបានល្អទេ» ។ អាមេរី បានកត់សម្គាល់ថា «ទារុណកម្មពិតជាព្រឹត្តិការណ៍ដ៏គួរឲ្យរន្ធត់បំផុតដែលមនុស្សលោកអាចរក្សានៅក្នុងខ្លួនគេផ្ទាល់» ។ លោកបន្ថែមទៀតថា «សម្រែកឈឺចាប់ ពិបាកនឹងយកភាសាមកប្រើណាស់» ។ ទោះបីជា ឬប្រហែលមកពីយ៉ាងនេះហើយបានជាអ្នកនិពន្ធក៏ដូចជាអ្នកអានហ៊ានរហូតដល់ប្រើប្រធានបទដែលអាក្រក់គួរឲ្យខ្លាច គួរឲ្យចាប់អារម្មណ៍ និងមិនអាចនិយាយចេញ ។[៥]

យើងអាចមានអារម្មណ៍ធ្លាក់ថ្លើមក្តុកនៅពេលគិតដល់ការធ្វើទារុណកម្មនៅមន្ទីរស-២១ តាមរយៈការមើលរូបថតនិងបើកឯកសារមើលម្តងមួយសន្លឹកៗនោះ ។ តាមគំនិតដែលទទួលបាននេះនាំឲ្យមានការមមៃថា អំពើទុយ៌សទាំងអស់ដែលរាលដាលនៅសម័យកម្ពុជាប្រជាធិបតេយ្យគឺមិនខុសពីទិដ្ឋភាពនៅក្នុងគុកនេះទេ ។ ពេលមើលរូបថតគ្រប់សន្លឹកនិងចម្លើយសារភាពទាំងអស់ ធ្វើឲ្យយើងដឹងពីវាសនារបស់អ្នកទោស ។ យើងប្រទះការពិពណ៌នាពីអំពើឃោរឃៅនិងអន្តុហេតុនៃការស្លាប់ជាបន្តបន្ទាប់ ។ នៅពេលជាមួយគ្នានេះដែរ យើងមិនបានឃើញអ្វីដែលកើតឡើងពិតប្រាកដចំពោះចិត្តគំនិតនិងរាងកាយរបស់ជនរងគ្រោះនិងបុគ្គលិកលក្ខណៈរបស់ជនដៃដល់ឡើយ ។ អ្វីដែលបានកើតឡើង គឺវាជារឿងអាក្រក់គួរឲ្យខ្លាចណាស់ ប៉ុន្តែការណ៍នេះកើតឡើងចំពោះមនុស្សផ្សេងទៀតយូរណាស់ហើយ ។ យើងគិតថា «អំពើអាក្រក់គ្មានសីលធម៌» មានកើតឡើងនៅកន្លែងផ្សេងៗទៀត ។

## បញ្ហានៃការសិក្សាអំពីធារុណកម្ម

ការសិក្សារបស់យើងអំពីទារុណកម្មនៅមន្ទីរស-២១ មានកម្រិត ដោយសារតែយើងមិនបាននៅជិតអ្វីដែលបានកើតឡើងកន្លងមកនិងប្រភពឯកសារពត៌មានមិនសូវសំបូរទាក់ទងនឹងប្រធានបទនេះ ។ ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៨០ មានតែអ្នកនៅរស់រានមានជីវិតពីមន្ទីរស-២១ បីនាក់ប៉ុណ្ណោះដែលបាននិយាយយ៉ាងពិស្តារអំពីអ្វីដែលខ្លួនបានជួបប្រទះ ។ សក្ខីកម្មរបស់ជនរងគ្រោះដែលមានវាសនារួចពីសេចក្តីស្លាប់ទាំងនេះពិតជាមានតម្លៃនិងនិយាយចេញពីដួងចិត្តពិតៗ ។ ប៉ុន្តែរឿងរ៉ាវដែលនិយាយចេញមកនេះមានកម្រិតដែលបានមកពីការឃោសនានៅទសវត្សរ៍ឆ្នាំ១៩៨០ បានមកពីកិច្ចសម្ភាសន៍ដែលសោះកក្រោះ និងបានមកពីការចងចាំស្រពិចស្រពិលរបស់ខ្លួនដែលជួបប្រទះព្រឹត្តិការណ៍យូរមកហើយ ។ មិនតែប៉ុណ្ណោះសោត អ្នកទាំងនេះមិនអាចរ៉ាយរ៉ាប់អំពីលក្ខខណ្ឌនៅក្នុងគុកនៅឆ្នាំ១៩៧៦ ពោលគឺមុនពេលដែលត្រូវបានគេចាប់ខ្លួនឡើយ ។

ស្រដៀងគ្នានេះដែរ មានតែអតីតអ្នកធ្វើការនៅមន្ទីរស-២១ ចំនួនប្រាំមួយនាក់ប៉ុណ្ណោះ មានដូចជាឌុច ឆ្មាំគុកបីនាក់ អ្នកថតរូបម្នាក់ និងម្នាក់ទៀតខាងធ្វើឯកសារដែលត្រូវបានសម្ភាសយ៉ាងលម្អិតនាពេលថ្មីៗនេះ ។ ក្នុងចំណោមអ្នកធ្វើការនៅមន្ទីរស-២១ ទាំងប្រាំមួយនាក់ មានតែម្នាក់គត់គឺឈ្មោះ ហ៊ឹម ហ៊ុយ ដែលនិយាយសារភាពថា ខ្លួនពិតជាបានសម្លាប់មនុស្សមែន ។ ហ៊ឹម ហ៊ុយ និយាយថា គាត់មិនមែនជាអ្នកធ្វើទារុណកម្មទេ ។ គ្មានអ្នកណាម្នាក់ក្នុងចំណោមអ្នកដែលសារភាពថាបានធ្វើទារុណកម្មអ្នកទោសហ៊ានចេញមុខឡើយ ។ អតីតអ្នកធ្វើការនៅក្នុងគុកមួយចំនួនដូចជា ហ៊ុយ ជាដើម ត្រូវបានចាប់យកទៅអប់រំនៅទសវត្សរ៍ឆ្នាំ១៩៨០ ដោយសារបានធ្វើសកម្មភាពនៅមន្ទីរស-២១ ក៏ប៉ុន្តែគ្មានអ្នកណាម្នាក់ធ្លាប់និយាយឲ្យពិស្តារអំពីសកម្មភាព ហើយក៏គ្មានអ្នកណាម្នាក់ត្រូវបានយកមកកាត់ទោសតាមច្បាប់ដែរ ។[៦]

នៅមន្ទីរស-២១ កម្រមានជនរួចពីសេចក្តីស្លាប់ណាស់ ហើយសក្ខីកម្មផ្ទាល់មាត់ឬការចងចាំអំពីគុកតាមរយៈសំណេរក៏កម្រមានដែរ ។ ការណ៍នេះវាផ្ទុយស្រឡះពីស្ថាប័នផ្សេងៗទៀតដូចជា នៅក្នុងមន្ទីរព្រហ្មទណ្ឌនៅប្រទេសសូវៀត ប្រទេសចិន និងជំរំណាហ្ស៊ីជាដើមដែលនៅទីនោះមាននៅសល់ស្នាដៃនិពន្ធ និងអ្នកនៅរស់ផុតពីសេចក្តីស្លាប់ជាច្រើន ។ ឯកសារទាក់ទងការធ្វើទារុណកម្ម និងអំពើឃោរឃៅគ្មានត្រាប្រណីក៏មានច្រើនដែរនៅប្រទេសផ្សេងៗទៀត ។ ឧទាហរណ៍ ស្នាដៃដែលទាក់ទងនឹងរឿងជនដៃដល់ជនជាតិអាល្លឺម៉ង់ធ្វើការសម្លាប់រង្គាលទៅលើជនជាតិជ្វីហ្វរបស់ គ្រីស្តូហ្វ័រ ប្រោនីង,ដានីញែល ហ្គោលហាហ្គិន,រ៉ូល ហ៊ីលប៊ឺក និង ហ្គីតា សឺរីនី មិនអាចដូចគ្នានឹងមន្ទីរស-២១ទេ ហើយក៏មិនដូចគ្នានឹងកំណត់ប្រវត្តិរបស់ ហ្សង់ អាមេរី, ប្រ៉ីម៉ូ ឡេវី, អាឡិចសាន់ឌ័រ សូលហ្សិននីតស៊ីន និង ចាកូបូ ទីម័រមែន ឬការសិក្សាស្រាវជ្រាវរបស់ អ៊ីវ៉ាលីនទីន ដានីញែល ទៅលើប្រទេសស្រីលង្កាការដែរ ដែលស្នាដៃនេះ ផ្អែកខ្លះផ្អែកទៅលើកិច្ចសម្ភាសន៍ជាមួយអតីតអ្នកសួរចម្លើយ និងជនរងគ្រោះ ។ ក្នុងការសិក្សាស្រាវជ្រាវអំពីទារុណកម្មនៅមន្ទីរស-២១ យើងផ្តោតយ៉ាងសំខាន់ទៅលើឯកសារដកស្រង់បានមកពីជនរងគ្រោះដែលត្រូវបានសួរចម្លើយ ដែលឥឡូវនេះបានស្លាប់អស់ហើយ ឬចម្លើយសារភាពដែលបង្ហាញពីទស្សនៈអំនួត ទស្សនៈឆ្លើយយករួចខ្លួន ឬឆ្លើយមិនឲ្យមាន

កំហុសរបស់អ្នកធ្វើទារុណកម្មផ្ទាល់តែម្តង ។ បើគ្មានការបញ្ជាក់អះអាងពីភាពត្រឹមត្រូវតាមរយៈប្រភពឯកសារផ្សេងទៀតទេ យើងមិនអាចនិយាយថា តើឯកសារទាំងអស់នេះនិយាយបំផ្លើស ឬនិយាយមិនអស់នូវខ្លឹមសារនៃអ្វីដែលកើតឡើងនៅមន្ទីរស-២១ឡើយ ។ ក្រោយពីចូលប្រឡូកក្នុងគំនរឯកសារអស់ជាច្រើនឆ្នាំមក ខ្ញុំទស្សន៍ទាយថា មានអំពើសាហាវយង់ឃ្នងរាប់មិនអស់និងទារុណកម្មរាប់រយជំពូកដែលមិនមានអ្នកណាកត់ត្រាទុក ។ អ្វីដែលយើងអាចអានបានមានតែដានមិនសូវច្បាស់លាស់នៃអ្វីដែលកំពុងតែដំណើរការកាលពីពេលនោះប៉ុណ្ណោះ ហើយតាមរយៈដាននេះ យើងដឹងពីការបំផ្លិចបំផ្លាញដែលកើតឡើងនៅមន្ទីរស-២១ រាល់ថ្ងៃតែរៀងៗប៉ុណ្ណោះ ។[៨]

ទោះបីជាមានឧបសគ្គទាំងអស់នេះយ៉ាងណាក៏ដោយ ក៏ការធ្វើទារុណកម្មនិងអំពើឃោរឃៅមានសារសំខាន់ណាស់ចំពោះមន្ទីរស-២១ និងចំពោះសមត្ថភាពរបស់យើងក្នុងការស្វែងយល់អំពីគុកនេះ ។ យើងចាំបាច់ត្រូវបន្តើតដំណើរដើមទងនៃការស្រង់បានជាចម្លើយសារភាពនេះ ។ យើងត្រូវស្វែងយល់ពីការគិតរបស់អ្នកគ្រប់គ្រងគុក និងយល់ពីហេតុផលដែលនាំឲ្យអ្នកទាំងនោះប្រើទារុណកម្ម ។ សំខាន់បំផុតដូចដែល អាឡិចហ្សាន់ឌ័រ ហ៊ិនតុន បានស្នើដែរថា យើងត្រូវ«ធ្វើឲ្យមានមនុស្សធម៌ឡើងវិញ»ចំពោះជនរងគ្រោះខ្មែរក្រហម ដោយបញ្ជាក់ច្បាស់អំពីការឈឺចាប់ដែលបានកើតឡើងចំពោះបុគ្គលទាំងនោះ ។[៨]

ក៏ប៉ុន្តែអ្វីដែលធ្វើឲ្យមានការចាប់អារម្មណ៍ចំពោះការដាក់ទារុណកម្មនៅក្នុងគុក គឺមិនមែនជាសភាពឃោរឃៅទេ ទោះបីជាទារុណកម្មដែលត្រូវបានធ្វើឡើងមានភាពឃោរឃៅយ៉ាងណាក៏ដោយ ។ ប៉ុន្តែអ្វីដែលចាប់អារម្មណ៍នោះគឺដំណើរការដែលគេយល់ថាសមហេតុសមផល ។ អំនួតក្នុងការជ្រើសរើសទារុណកម្មមកប្រើនិងសរសេរឡើងគឺស្តាប់ទៅមិនគួរឲ្យបាក់ទឹកចិត្តទេ ។ យើងអាចយល់នូវការផ្ទុះចេញនូវសភាពឃោរឃៅបានដោយងាយនៅក្នុងខ្លួនយើងឬអ្នកដទៃ ប៉ុន្តែយើងពិតជាពិបាកយល់ណាស់ចំពោះសភាពឃោរឃៅដែលគេរៀបចំទុកជាមុន ។ ការពន្យល់មួយទៅលើភាពមានអំនួតនេះដូចគ្នាទៅនឹងការសង្កេតរបស់ ដារី រីចាលី នៅក្នុងការសិក្សាស្រាវជ្រាវរបស់គាត់អំពីទារុណកម្មនៅប្រទេសអ៊ីរ៉ង់ដែរ គឺថាទារុណកម្មមិនមែនជាវិធីសាស្ត្រល្អណាស់ណាទេក្នុងការជម្រិតយកភ័ស្តុតាងនិងចម្លើយសារភាពជាក់លាក់ ហើយក៏មិនមែនជាទម្រង់នៃការសប្បាយដោយបានធ្វើបាបគេដែរ ដែលជាឧបករណ៍បង្ហាញ និងធ្វើឲ្យមានហេតុផលក្នុងការផ្តល់អំណាចដល់អ្នកដែលធ្វើទារុណកម្ម ជាពិសេសនៅពេលដែលអ្នកធ្វើទារុណកម្មទាំងនោះជាតំណាងរបស់រដ្ឋ ។ អ្នកនិពន្ធផ្សេងៗទៀតដែលសរសេរអំពីទារុណកម្មបានបញ្ចេញទស្សនៈប្រហាក់ប្រហែលគ្នានេះដែរ ។[៩]

ដោយចាំជាប់នូវរូបមន្តរបស់ រីចាលី នៅក្នុងគំនិតយើងអាចយល់បានថា ទារុណកម្មនៅមន្ទីរស-២១ គឺមិនមែនត្រឹមតែជារឿងរបស់យុវជនយុវនារីដែលបន្ទុំឆន្ទៈខ្លួនដាក់ទៅលើអ្នកទោសដែលគ្មានការការពារខ្លួនទាល់តែសោះនោះទេ ទោះជាគេបានធ្វើជារឿយៗក៏ដោយចុះ ហើយក៏មិនមែនជាការពង្រីកឲ្យកាន់តែវែងនូវដំណើរការនីតិវិធីរបស់នគរបាលដែរ ទោះជារបស់ទាំងអស់នេះ (មានជាអាទិ៍ដូចជា រូបថតពាក់កណ្តាលខ្លួន ស្នាមផ្តិតមេដៃ និងការវាយអ្នកទោសដំបូងដៃ) ជារឿងដែលកើតឡើងរៀងរាល់ថ្ងៃនៅមន្ទីរស-២១យ៉ាងណាក៏ដោយ ។ តែផ្ទុយទៅវិញ ទារុណកម្មនៅមន្ទីរស-២១ ត្រូវបានធ្វើឡើងដោយ

វេទនានិងបង្ខំ ។ ការវាយដំនិងធ្វើទារុណកម្មគឺពិតជាគ្មានមេត្តា ប៉ុន្តែទារុណកម្មជាទូទៅត្រូវមានការអនុញ្ញាតពីសំណាក់មេៗជាមុនសិនទើបអាចធ្វើទៅបាន ។ តែមេៗនៅពីលើជួនកាលក៏មិនអនុញ្ញាតឲ្យធ្វើទារុណកម្មដែរ ។ អ្នកសួរចម្លើយដែលប្រើទារុណកម្ម «ហួសហេតុ» (ទារុណកម្មដែលធ្វើឲ្យអ្នកទោសស្លាប់មុនពេលបញ្ចប់ចម្លើយសារភាពរបស់ខ្លួនចប់ចុងចប់ដើម) បានទិតៀនខ្លួនឯងនៅក្នុងការប្រជុំស្វ័យទិតៀន ហើយមានពេលខ្លះ អ្នកដែលធ្វើខុសត្រូវបានផ្តន្ទាទោសទៀតផង ។ នៅក្នុងចម្លើយសារភាពចំនួនប្រាំបីច្បាប់ដែលធ្វើឡើងនៅចុងឆ្នាំ១៩៧៨ អ្នកសួរចម្លើយកត់សម្គាល់ថា ចម្លើយសារភាពនេះស្រង់ចេញដោយមិនមានការវាយធ្វើបាប ឬធ្វើទារុណកម្មឡើយ ។[១០] កាលនោះ គុកនៃមន្ទីរស-២១ ដំណើរការយ៉ាងរលូននិង«សមហេតុផល» ជាងកាលពីឆ្នាំ១៩៧៦ ដែលកាលនោះបុគ្គលិកភាគច្រើនគឺជាអ្នកដែលទើបតែជ្រើសរើសថ្មីៗ ហើយមជ្ឈិមបក្សបានសំណូមពរ «ឲ្យកាត់បន្ថយការវាយដំ» ។[១១] នៅឆ្នាំ១៩៧៧ និង ១៩៧៨ នៅក្នុងការសួរចម្លើយមួយចំនួន អ្នកសួរចម្លើយបានចាប់ធ្វើទារុណកម្មជាមុន លើកលែងតែគ្រប់គ្រងខ្លួនឯងមិនបានប៉ុណ្ណោះ ហើយវាយម្តងទៀតនៅពេលអ្នកទោសមានការប្រឆាំងមានះ និងក្នុងករណីដែល «ស្មុគស្មាញ» ។ ទារុណកម្ម ជាឧបករណ៍ម្យ៉ាង ជាវិធីចុងក្រោយ ជាផ្នែកទាំងស្រុងនៃអ្វីដែលហៅថា «ការស្វែងរកការពិតតាមរបៀបផ្តាច់ការ» ។ អ្នកសួរចម្លើយដែលធ្វើទារុណកម្មគេយល់ថា វាជាការងាយណាស់គ្រាន់តែធ្វើតាមគេបញ្ជា ជាពិសេសនៅពេលដែលជីវិតរបស់ខ្លួនស្ថិតនៅក្នុងគ្រោះថ្នាក់ជានិច្ចនោះ ។ តាមដែលយើងអាចនិយាយបានគឺថា អ្នកទាំងនោះមិនសូវជាមានការសោកស្តាយចំពោះអំពើរបស់ខ្លួនប៉ុន្មានទេ ។

ការដាក់កម្រិតឲ្យធ្វើទារុណកម្មត្រូវបានកំណត់ឡើងមិនមែនដោយការមិនគោរពចំពោះជនរងគ្រោះទេ ហើយក៏មិនមែនដោយសារអ្នកគ្រប់គ្រងយល់ថា ការធ្វើបែបនេះមិនល្អដែរ ប៉ុន្តែគឺដោយសារវាមានទំនាក់ទំនងជាមួយនឹងការសួរចម្លើយមួយផ្នែកផ្សេងទៀតពោលគឺ «ការធ្វើនយោបាយ» ដែលមានន័យស្មើនឹងការពន្យល់អំពីនយោបាយរបស់បក្សដល់អ្នកទោសនិងការដកស្រង់ចម្លើយសារភាព ។ គេគិតថា ការលាយបញ្ចូលគ្នារវាងទារុណកម្ម ការជំរុញនិងឃោសនាអាចបង្ហាញទំនាក់ទំនងអំណាច ព្រមទាំងអាចផ្តល់នូវការចងចាំ ការចោទប្រកាន់ និងឯកសារដែលបក្សត្រូវការជាចាំបាច់ ។ ការធ្វើទារុណកម្មហួសកម្រិតនឹងអាចរាំងស្ទះ ឬពន្យារពេលដល់ការផលិតនូវអត្ថបទចាំបាច់ទាំងនេះ ។

## «ការដាក់ទណ្ឌកម្ម» និង «ការធ្វើនយោបាយ»

ភាពតានតឹងដែលកើនឡើងរវាងការធ្វើទារុណកម្មនិងការធ្វើនយោបាយ មានចងក្រងឡើងនៅក្នុងសៀវភៅកំណត់ហេតុសិក្សារបស់អ្នកសួរចម្លើយដែលសរសេរនៅឆ្នាំ១៩៧៦ និងសៀវភៅកំណត់ហេតុពីរដែលសរសេរដោយអ្នកសួរចម្លើយធំៗនៅឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៨ ។ ភាពតានតឹងកើតឡើងដោយសារនៅពេលអ្នកសួរចម្លើយទាំងអស់ត្រូវបានជំរុញឲ្យប្រើអំពើហិង្សា ក្នុងចំណោមអ្នកសួរចម្លើយទាំងអស់មានតែមួយចំនួនតូចប៉ុណ្ណោះដែលបានរៀនសូត្រអំពីនយោបាយ ឬការសួរចម្លើយ ។ សៀវភៅកំណត់ហេតុ

សរសេរថា ទារុណកម្មជា«រឿងទីពីរបន្ទាប់បន្សំនិងបំពេញបន្ថែម»នយោបាយ ប៉ុន្តែសៀវភៅនេះសរសេរបន្ថែមថា «ការធ្វើនយោបាយ»តែមួយមុខក៏មិនទាន់គ្រប់គ្រាន់ដែរ ។ គឺត្រូវប្រើអំពើហិង្សាជានិច្ច «យកនយោបាយជាមូលដ្ឋាន» ។ «ឈ្លេចសួរឲ្យបាន រួចហើយសឹមធ្វើទារុណកម្ម» ។ ពីរឆ្នាំក្រោយមក សៀវភៅកំណត់ហេតុដ៏សំខាន់របស់អ្នកសួរចម្លើយនេះ បញ្ជាក់ពី«ការធ្វើឲ្យអាម៉ាស់មុខ»គឺជាផ្នែកមួយនៃការធ្វើនយោបាយហើយសរសេរទៀតថា វៃតែមួយមុខ«មិនគ្រប់គ្រាន់ទេ» ប៉ុន្តែ«វៃ + នយោបាយ = សំខាន់» ។[១២]

អ្នកទោសនៅមន្ទីរស-២១ ត្រូវបានធ្វើឲ្យបាត់បង់តម្លៃជាមនុស្សតាំងពីពេលចូលខ្លួនមកដល់កន្លែងនេះដំបូងម្ល៉េះ ។ អ្នកទោសដែលត្រូវបិទមុខជិត និងដាក់ខ្នោះត្រូវបានទាញទម្លាក់ពីឡាន ជាទូទៅនៅពេលយប់ ។ អ្នកទោសត្រូវបានទាត់ ប្រានឲ្យដើរទៅមុខ និងវាយដំប្រំធាក់នៅពេលបណ្តើរចូលទៅក្នុងដើម្បីធ្វើឯកសារនិងថតរូប ។ ដូច វ៉ាន់ ណាត រំឭកឡើងវិញថា អ្នកទោសទៅដល់«កន្លែងមួយដែលអាក្រក់ជាងឋាននរកទៅទៀត» ។

វៃ និងធ្វើទារុណកម្មខុសគ្នានៅត្រង់ការប្រើអាវុធ គ្រឿងម៉ាស៊ីន ឬការធ្វើឲ្យអាម៉ាស់មុខ (ដូចជាទារុណកម្មឲ្យថ្វាយបង្គំរូប ហូ ជីមិញ ដែលមានខ្លួនជាឆ្កែ) ប៉ុន្តែការវាយនៅពេលសួរចម្លើយអាចចាត់ទុកជាទារុណកម្ម ហើយឯកសារជាច្រើនប្រើពាក្យវៃនិងធ្វើទារុណកម្មជំនួសគ្នាទៅវិញទៅមក ។ នៅពេលមានការចាប់ផ្តើមសួរចម្លើយ ការត្រួតពិនិត្យខាងក្រៅកម្រមានណាស់ ។ ដូចលោក សហ្គ្គី លើកឡើងទាក់ទងនឹងជំរំប្រមូលផ្តុំរបស់អាឡឺម៉ង់ដែរថា «ពីទារុណកម្មដើម្បីជម្រិតយកចម្លើយទៅទារុណកម្មដែលគ្មានគោលដៅច្បាស់លាស់គឺមានការប្រែប្រួលជានិច្ច» ។ សុខមាលភាពរបស់អ្នកទោសមិនមានអ្នកណាគិតគូរថែទាំអ្វីឡើយ ធ្វើយ៉ាងម៉េចឲ្យតែបានរស់ដើម្បីស្រង់ចម្លើយសារភាពតែប៉ុណ្ណោះក្រោយពីសួរហើយ ស្លាប់ក៏ស្លាប់ទៅគ្មានអ្នកណាខ្វល់ឡើយ ។[១៣]

## អំពើហិង្សានិងការសប្បាយដោយបានធ្វើបាបគេ

ការសួរចម្លើយត្រូវបញ្ឈប់ រឹតបន្តឹង ឬផ្អាកយ៉ាងណាៗនោះ គឺវាស្រេចតែប្រធានក្រុមសួរចម្លើយតែប៉ុណ្ណោះ ។ ចំណែកឯអ្នកធ្វើទារុណកម្មវិញអាចប្រើដៃ ប្រើអាវុធថ្មី ឬយកអ្នកទោសទៅបន្ទប់របស់ខ្លួនតែម្តង ។ ប្រសិនបើវាយឬសួរចម្លើយហើយចេញជាចម្លើយសារភាពវាមិនថ្មីទេ ប៉ុន្តែបើធ្វើទារុណកម្មខ្លាំងហើយនៅតែមិនចេញទៀតនោះជាបញ្ហាធំមែនទែន ។ អ្នកទោសខ្លះត្រូវបានសួរចម្លើយរៀងរាល់ថ្ងៃ ។ ទិន ចាន់ ជាអ្នកដែលមានវាសនាចាកផុតពីសេចក្តីស្លាប់បានរំឭកឡើងវិញថា ខ្លួនទទួលរងការវាយដំប្រំធាក់ហើយជួនកាលរងទារុណកម្មរហូតដល់ម្តេប្រាំមួយថ្ងៃនៅក្នុងជួរ ។[១៤]

ជនរងគ្រោះដោយសារទារុណកម្មច្រើនតែស្លាប់ ។ អ្នកគ្រប់គ្រងគុកមិនមានការបារម្ភអ្វីឡើយ អ្នកទោសណាស្លាប់ក៏ស្លាប់ទៅឲ្យតែបានជម្រិតយកចម្លើយសារភាពរួចហើយ ។ ប៉ុន្តែប្រសិនបើអ្នកទោសស្លាប់មុនពេលស្រង់ចម្លើយសារភាព អ្នកសួរចម្លើយច្រើនតែត្រូវបានសង្ស័យថាជាអ្នកធ្វើ«វិទ្ធង្សនា» ។ អ្នកសួរចម្លើយជាច្រើនដែលជាប់ឃុំនៅមន្ទីរស-២១ បានសារភាពថា ខ្លួនធ្លាប់ធ្វើឲ្យអ្នកទោសស្លាប់នៅពេលសួរ

ចម្លើយ ហើយឆ្នាំពីរនាក់ទៀតក៏និយាយដូចគ្នានេះដែរ ប៉ុន្តែភាគច្រើននៅតែមិនច្បាស់នៅឡើយថា តើនេះជាកំហុសមួយក្នុងចំណោមកំហុសនានាដែលនាំឲ្យអ្នកសួរចម្លើយនិងឆ្មាំត្រូវចាប់ខ្លួន ឬថាកំហុសនេះចេញពីការវាយតម្លៃលើសកម្មភាពរបស់អ្នកទាំងនេះកាលពីអតីតកាលដែលទើបតែកន្លងទៅឬក៏យ៉ាងណា ។ អារម្មណ៍សប្បាយដែលបានធ្វើបាបគេតែងតែកើតឡើងជារឿយៗដូចដែលអតីតឆ្មាំគុកម្នាក់ឈ្មោះ សុន មឿន បានសរសេរនៅក្នុងចម្លើយសារភាពរបស់ខ្លួនថា÷

> ក្រោយពីគេចាត់តាំងឲ្យខ្ញុំយាមអ្នកទោស (នៅក្នុងគុកពិសេស ខាងត្បូងទួលស្លែង) ខ្ញុំឃើញ (អ្នកសួរចម្លើយ) កំពុងតែវាយអ្នកទោស ហើយនៅពេលអ្នកសួរចម្លើយចេញបាត់ទៅ ខ្ញុំក៏លួចចូលទៅវាយអ្នកទោសបន្ថែមទៀត ដោយរុញ ទាត់ធាក់ និង វាយតាមចិត្ត វាយទាល់តែអ្នកទោសសួរថា «តើឯងកំពុងតែធ្វើអីហ្នឹង ។ ឯងចង់សម្លាប់ខ្ញុំតាមផ្លូវនេះមែនទេ!» ។

បន្ទាប់ពីការធ្វើទារុណកម្មមិនយូរប៉ុន្មាន អ្នកទោសឈ្មោះ ប៊ុន ថន ក៏ត្រូវស្លាប់ដោយរងរបួស ដែលបង្កឡើងដោយអ្នកសួរចម្លើយនិងឆ្មាំគុក ។ ចម្លើយសារភាពរបស់ ប៊ុន ថន មិនមានលក្ខណៈពេញលេញទេ ។[១៥]

ដោយចាក់សោទុកនៅក្នុងស្ថាប័នស្វយ័តដែលមានភាពប្រទាញប្រទង់គ្នារវាងការបណ្តោយឲ្យធ្វើតាមចិត្ត និង«វិន័យ» រវាងការផ្តល់អំណាចនិងការមិនទុកចិត្ត និងរវាងអំពើឃោរឃៅនិងការឃោសនានោះ អ្នកសួរចម្លើយតែងតែឈរខ្សែកណ្តាល មិនធ្វើខ្លាំងពេកមិនខ្សោយពេក ។ អ្នកសួរចម្លើយតែងតែមានកំហុសដោយការ (ធ្វើទារុណកម្ម) ហួសកំណត់ ។ កំហុសដោយធ្វើទារុណកម្មជ្រុលកម្រនឹងទទួលរងទណ្ឌកម្មណាស់ ចំណែកឯការប្រុងប្រយ័ត្នក៏គ្មានទទួលបាននូវការលើកទឹកចិត្តដែរ ។

មិនខុសពីអ្នកធ្វើការងារដូចគ្នានេះនៅជំរឹមរណៈណាហ្ស៊ីទេ អ្នកសួរចម្លើយគ្មានអារម្មណ៍ជាមនុស្សទេ ។ តាមតែការវាយតម្លៃលើឯកសារដែលនៅសេសសល់ឃើញថា ភាពឃោរឃៅនៅក្នុងគុក គឺជា«ភាពឃោរឃៅដែលគ្មានមនោសញ្ចេតនា» ដូចដែល វ៉ែនដល កូលីន បានហៅដែរ ដែលក្នុងនោះ «ប្រភពនៃភាពឃោរឃៅគឺគ្រាន់តែជាឧបករណ៍ឬឧបសគ្គមួយប៉ុណ្ណោះ ចំណែកឯការឈឺចាប់ដែល កូលីន បានទទួលរងគ្រាន់តែជាហេតុការណ៍កើតឡើងដោយចៃដន្យសម្រាប់បំណងផ្សេងៗទៀត ដែលជាទូទៅគ្មានអ្នកណាដឹងឮឡើយ» ។[១៦] ឧទាហរណ៍ជាក់ស្តែងបង្ហាញពីភាពឃោរឃៅ គឺចំណាររបស់ ប៊ុន ផ្ញើទៅកាន់ ឌុច ក្រោយពីធ្វើការសួរចម្លើយដ៏ធ្ងន់ធ្ងររួច ។ អ្នកទោសមានឈ្មោះថា កែវ មាស ជាអតីតសមាជិកគណៈកម្មាធិការមជ្ឈិម ។ ប៊ុន បានសរសេរថា÷

> នៅយប់ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៧៦ ក្រោយពីសម្លុត (អ្នកទោស) ពីរបីម៉ាត់ហើយ ខ្ញុំក៏ដោះអាវវាចេញនិងដាក់ខ្នោះវាដោយដាក់ដៃទៅក្រោយ ។ ខ្នោះនេះដោះចេញតែនៅពេលបាយប៉ុណ្ណោះ ។ មិនឲ្យវាដេកលក់ ហើយឲ្យមូសខាំវា ។[១៧]

## ទារុណកម្មព្រហ្មទណ្ឌ និងទារុណកម្មតាមផ្លូវតុលាការ

បាតុភូតនៃអំពើទារុណកម្មនិងអំពើឃោរឃៅនៅមន្ទីរស-២១ ចាំបាច់ត្រូវដាក់នៅក្នុងអត្ថបទប្រវត្តិសាស្ត្រ ។ តើអំពើទាំងនេះមានឫសគល់នៅក្នុងប្រទេសកម្ពុជាសម័យមុនបដិវត្តន៍ដែរឬទេ? ឬ តើវាជាបាតុភូតកើតឡើងដោយការចាំបាច់របស់ពួកខ្មែរក្រហមនិងយកគំរូតាមបរទេស?

ដើមកំណើតនៃពាក្យឆ្លុះបញ្ចាំងពីបញ្ហាទារុណកម្មខ្លួនឯងមួយកម្រិតដែរ ។ ពាក្យទារុណកម្មដែលប្រើដូចគ្នានឹងពាក្យថៃ គឺមានដើមកំណើតចេញមកពីពាក្យ ទារុណ ដែលមានន័យថា «កាច» ឬ «អាក្រក់» ចំណែកឯពាក្យបាលី កម្ម មានន័យថា «អំពើ» ។ តាមវចនានុក្រមខ្មែរបោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យនៅភ្នំពេញក្នុងទសវត្សរ៍ទី៦០ ន័យមួយទៀតនៃពាក្យនេះគឺ «អំពើកាច» «អំពើអាក្រក់» និង «អំពើសាហាវយង់ឃ្នង» ។ ប្រយោគជាឧទាហរណ៍មួយនៅក្នុងវចនានុក្រមនេះដាក់ថា «ពុំគួរធ្វើទារុណកម្មដល់មនុស្សនិងសត្វឡើយ» ។[១៨]

ដូច្នេះពាក្យទារុណកម្មនៅក្នុងភាសាខ្មែរគ្រាន់តែបញ្ជាក់អំពីភាពឃោរឃៅ បង្កប់ភាពអាប់យស ប៉ុន្តែមិនទាក់ទងនឹងរដ្ឋបាលតុលាការទេ ។ ឃ្លាថា «ដាក់ទារុណកម្ម» បញ្ជាក់ពីពិសោធន៍ឃោរឃៅឬអ្វីដែល ហ៊ូខល និង រីចាលី ហៅថា «ទារុណកម្មព្រហ្មទណ្ឌ» ដែលតំណាងឲ្យអ្វីដែល ហ៊ូខល ហៅថា «ការសងសឹករបស់អ្នកកាន់អំណាច» មិនមែនជាអ្វីដែល អេដវឹដ ភីតធ័រ ហៅថា ទារុណកម្មផ្នែកតុលាការដែលជាទូទៅទាក់ទងដល់ការប្រមែប្រមូលភ័ស្តុតាងនិងការទាញយកចម្លើយសារភាពនោះទេ ។

ការសិក្សាស្រាវជ្រាវរបស់ ភីតធ័រ មានដើមកំណើតចេញពីការធ្វើទារុណកម្មតាមផ្លូវតុលាការពីប្រទេសក្រិចនៅសតវត្សរ៍ទី៥មុនគ្រិស្តសករាជ ។ នៅប្រទេសក្រិចកាលនោះ ការធ្វើទារុណកម្មត្រូវបានធ្វើឡើងតែទៅលើទាសករតាមរយៈការវិវឌ្ឍន៍ក្រោមច្បាប់រ៉ូម៉ាំង និងការនិយមប្រើច្បាប់នេះឡើងវិញរបស់ពួកអឺរ៉ុបនៅសតវត្សរ៍ទី១២និងសតវត្សរ៍ទី១៣នៃគ្រិស្តសករាជ ។ ភីតធ័រ បន្តរៀបរាប់នូវអ្វីដែលលោកហៅថា «ធ្វើឲ្យស៊ីគ្នា» ទៅនឹងទារុណកម្មតាមផ្លូវតុលាការដែលកើតឡើងរវាងសតវត្សរ៍ទី១៣និង១៨ ដែលកាលនោះការអនុវត្តបែបនេះត្រូវទទួលការរិះគន់យ៉ាងខ្លាំង ។ ភីតធ័រ បិទសៀវភៅរបស់គាត់ ហើយពិភាក្សាអំពីការនិយមប្រើទារុណកម្មតាមផ្លូវតុលាការនៅលើពិភពលោកនៅពេលថ្មីៗនេះ ។[១៩]

ចំណុចខ្វះខាតនៅក្នុងការសិក្សារបស់ ភីតធ័រ គឺការមិនបានទាញយកគំរូទារុណកម្មផ្លូវតុលាការរបស់អាស៊ីឲ្យបានលម្អិត ។ ទាំងទារុណកម្មតាមផ្លូវតុលាការ និងទារុណកម្មព្រហ្មទណ្ឌត្រូវបានអនុវត្តជាទូទៅនៅប្រទេសចិន ជប៉ុន និងវៀតណាម ជាពិសេសប្រើសម្រាប់សួរចម្លើយឈ្លើយសឹកឬនៅពេលតម្រូវឲ្យមានចម្លើយសារភាព ឬឈ្មោះរបស់អ្នកធ្វើការជាមួយអ្នកទោស ។ វចនស័ព្ទចិនថា kao wen អាចយកមកបំបែកចេញជាពីរពាក្យមួយមានន័យថា «សួរចម្លើយ» និងមួយទៀតមានន័យថា «វាយ» ។ ចំណែកឯពាក្យវៀតណាម tra tan ប្រើជាកិរិយាស័ព្ទ«ពិនិត្យ» និង«សួរសំណួរ» ដោយមិននិយាយដល់អំពើឃោរឃៅឡើយ ។ សញ្ញាណនៃការផ្សំគ្នារវាងទារុណកម្មជាមួយនឹងការសួរចម្លើយដើម្បីជម្រិតយកចម្លើយសារភាពហាក់ដូចជាផ្ទត់គំនិតចិន-វៀតណាម និងផ្ទត់គំនិតអឺរ៉ុប ប៉ុន្តែគំនិតនេះមិនមាននៅក្នុងផ្នែកខ្លះនៃព្រះពុទ្ធសាសនា

និកាយថេរវាទនៅអាស៊ីអាគ្នេយ៍ទេ ។ គ្មានភ័ស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ផ្នត់គំនិតនេះបានមកដល់កម្ពុជាមុនសម័យកម្ពុជាប្រជាធិបតេយ្យឡើយ ។

ទោះបីជាមានការខ្វះចន្លោះរឿងរ៉ាវនៅអាស៊ីយ៉ាងណាក៏ដោយ ក៏អ៊ីដែល ភីតធ័រ សរសេរអំពីទារុណកម្មផ្លូវតុលាការនៅអឺរ៉ុបមុនឆ្នាំ១៨០០ គឺមានពាក់ព័ន្ធនឹងមន្ទីរស-២១ ។ ភីតធ័រ ប្រាប់យើងថា ដោយមានការកើនឡើងនូវគ្រិស្តសាសនា ទារុណកម្មតាមផ្លូវតុលាការក្លាយជាទារុណកម្មទាំងស្រុងចំពោះរឿងបរមតិ (មតិដែលផ្ទុយពីអ្វីដែលមានជាទូទៅ) ។ ករណីនេះត្រូវបានធ្វើយុត្តិកម្មពីព្រោះមួយផ្នែកមកពី “បរមតិគឺជាបទល្មើសរួម ហើយក្រៅពីការសង្គ្រោះព្រលឹងអញ្ញទិដ្ឋិជនអ្នកអង្កេតត្រូវការឈ្មោះរបស់អ្នកគាំទ្រអញ្ញទិដ្ឋិ” ។ ដោយមានការធ្វើទារុណកម្មមកលើខ្លួន អញ្ញទិដ្ឋិជនដែលត្រូវគេសង្ស័យបានឲ្យឈ្មោះអ្នកដែលនឹងចូលខ្លួនមកទទួលទារុណកម្ម ហើយអ្នកទាំងនេះចេះតែឲ្យឈ្មោះអ្នកផ្សេងៗទៀតបន្តកន្ទុយគ្នាដឹកក្នុងទ្រង់ទ្រាយធំមិនខុសពីអ្នកដែលជាប់ឃុំនៅទួលស្លែងប៉ុន្មានសតវត្សរ៍ក្រោយមកទេ ។ នៅក្នុងសំណេរមួយដែលងាយយល់ស្ដីអំពីទារុណកម្មនៅមជ្ឈិមសម័យ តាឡាល់ អាសាធ បានលើកឡើងថា “ដោយសារទោសនៃការប្រកាន់នូវទស្សនៈបរមតិគេមិនអាចបញ្ជាក់ដាច់ដោយឡែកតែឯងទៅលើចម្លើយសារភាពរបស់ជនជាប់ចោទ ទារុណកម្មត្រូវតែយកមកកាត់សេចក្ដីមុនពេលកំហុសត្រូវបានគេបង្កើតឲ្យចេញជារូបរាងឡើង” ។ ដោយសារទោសនេះត្រូវបានលាក់កំបាំង ការស្វែងរកការពិតត្រូវតែប្រើល្បិចសម្ងាត់ដល់កំពូលទើបបាន ។[២០] ករណីបែបនេះភាគច្រើនមិនខុសពីនៅមន្ទីរស-២១ ទេ គឺចុងចោទដែលត្រូវបានសន្មតថាប់តាំងពីក្បាលដំបូងថានឹងមានកំហុស នោះត្រូវទទួលការអនុញ្ញាតតិចតួចបំផុតបុមិនផ្លូវការក្នុងការការពារខ្លួន ហើយត្រូវបានថ្កោលទោសទៅតាមពាក្យចចាមអារ៉ាម ។

## ទារុណកម្មនៅកម្ពុជាកាលពីអតីតកាល

នៅប្រទេសកម្ពុជាមុនសម័យបដិវត្តន៍គ្មានការធ្វើឯកសារទារុណកម្មសម្រាប់ប្រើជាភ័ស្តុតាងទេ ទោះជាជនសង្ស័យជួនកាលត្រូវបានដាក់ឲ្យទទួលរងនូវពិសោធន៍ដ៏ខ្លោចផ្សាដើម្បីឲ្យ“បង្ហាញ”ថា ខ្លួនកំពុងតែកុហក ឬប្រាប់ការពិតក៏ដោយ ។ ប៉ុន្តែភ័ស្តុតាងនៅរាយប៉ាយបង្ហាញថា ទារុណកម្មមានលក្ខណៈដូចជាការដាក់ទណ្ឌកម្មដែរ ហើយទោសដែលត្រូវទទួលទណ្ឌកម្មធ្ងន់ធ្ងរជាងគេនោះគឺទោសក្បត់ព្រះរាជា ។ ឧទាហរណ៍ជាក់ស្ដែងគេឃើញមានលើសិលាចារឹកនៅអង្គរវត្តមួយចំនួន ហើយត្រូវបានលើកឡើងថា ជាទោសនៃការបំពានទៅលើសម្បថរបស់មន្ត្រីខ្មែរកាលពីមជ្ឈិមសម័យ ។ ចម្លាក់លឹបនៅវិចិត្រសាលខាងត្បូងអង្គរវត្តពិពណ៌នាអំពីទណ្ឌកម្មដែលអាចដាក់មកលើអ្នករំលោភបំពាន ។ នៅក្នុងចម្លាក់នោះមានឃើញរូប “យមៈ” ដែលជា “អធិបតីនរក” នៃសាសនាហិណ្ឌូ ជិះច្រកការលើខ្នងក្របីនាំយកមនុស្សប្រុសស្រីទាំងជួរៗទៅឋានសួគ៌ឬទៅឋាននរកដែលគេជឿថាមានរហូតដល់សាមសិបពីរជាន់ ដែលនៅឋាននរកអ្នកទាំងនោះត្រូវបានដាក់ទោសទៅតាមបាបកម្មរបស់ខ្លួនមិនខុសពីអ្វីដែលជាការអះអាងរបស់ ដាណេ នៅក្នុងសំណេររបស់គាត់ដែលមានចំណងជើងថា “អាំងហ្វែរណូ” ឡើយ ។ អ្នកនាំភ្ញៀវដើរមើលអង្គរវត្តម្នាក់បានចង្អុលប្រាប់

អ្នកទេសចរ កាលពីឆ្នាំ១៩៨១ ថា យមៈ នេះគឺប្រៀបដូចជា ប៉ុល ពត អីចឹង ។[៧១]

នៅប្រទេសកម្ពុជា ក្រោយសម័យអង្គរនៅតាមជញ្ជាំងវត្តអារាមគេឃើញមានគំនូររូបភាពឋាននរកដែលមានជនរងគ្រោះជាច្រើនទទួលទារុណកម្ម ។ វ៉ាន់ ណាត បានប្រៀបធៀបរូបភាពនៅតាមជញ្ជាំងវត្តនេះទៅនឹងបទពិសោធន៍ដែលគាត់ផ្ទាល់បានជួបប្រទះ ។ វ៉ាន់ ណាត កត់សម្គាល់ថា អ្នកធ្វើការនៅក្នុងគុកជាទូទៅចាត់ទុកអ្នកទោសដូចជាប្រេតអីចឹង ។ សព្វថ្ងៃនេះគំនូររបស់ វ៉ាន់ ណាត ដែលរៀបរាប់ពីទារុណកម្មធ្វើឡើងនៅមន្ទីរស-២១ បានដាក់តាំងនៅតាមជញ្ជាំងសារមន្ទីរទុក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។

នៅក្នុងន័យនេះ ការបំបាត់ភាពជាមនុស្សពីអ្នកទោសដែលធ្វើឡើងជាប្រព័ន្ធដូចដែល វ៉ាន់ ណាត បានលើកយកមកពិភាក្សានៅក្នុងបទសម្ភាសន៍ជាច្រើននោះ ប្រហែលជាអាចបញ្ជាក់បានថា អ្នកទោសទាំងនោះត្រូវបានចាប់ចងដោយយល់ថាជាទមិឡដែលមិនអាចកែប្រែបានទៀតទេ ។ ទមិឡ ជាគំនិតបែបព្រះពុទ្ធសាសនាដែលត្រូវបានចាត់ទុកថាជាមនុស្សក្រៅសង្គម ។ ការបំបាត់ភាពជាមនុស្សពីអ្នកទោសបានធ្វើឲ្យអ្នកធ្វើការក្នុងគុកមន្ទីរស-២១មានភាពងាយស្រួល ។ ការណ៍នេះមិនខុសគ្នាទៅនឹងអ្វីដែលកើតឡើងចំពោះជនជាតិជ្វីហ្វ ហ្គីបស៊ី អ្នករួមភេទដូចគ្នានិងអ្នកទោសដទៃទៀតនៅជំរំមរណៈរបស់ណាហ្ស៊ីទេ ។ អ្នកដែលកំពុងតែត្រូវធ្វើទារុណកម្ម និងសម្លាប់ដូចជារូបគំនូរនៅតាមជញ្ជាំងវត្តគឺជាអ្នកដទៃ ។ ប៉ុល ពត ខ្លួនឯងផ្ទាល់ បានបញ្ជាក់ច្បាស់នៅក្នុងសុន្ទរកថារបស់គាត់កាលពីឆ្នាំ១៩៧៧ ដែលនិយាយពីអត្ថិភាពរបស់បក្សកុម្មុយនិស្តកម្ពុជាថា «សមាសភាពប្រឆាំងនឹងបដិវត្តន៍ដែលក្បត់ និងព្យាយាមបំផ្លាញបដិវត្តន៍មិនត្រូវចាត់ទុកជាប្រជាជនយើងទេ» ។[៧២]

ការប្រហារជីវិតជាសាធារណៈនៅក្នុងប្រទេសកម្ពុជាមុនសម័យអាណានិគមដែលដាក់អ្នកទោសឲ្យជិះដាន់នោះ បានបង្ហាញអំពីអំណាចរបស់ព្រះមហាក្សត្រកម្ទេចពិរុទ្ធជន និងធ្វើឲ្យអ្នកមើលដែលគេកោះមកមានការស្ញើចសរសើរ ។ ការវិនិច្ឆ័យទៅលើមេៗ និងវាសនារបស់ពិរុទ្ធជនខ្លួនឯងផ្ទាល់ដូចដែលបានរៀបរាប់តាមរយៈគំនូរនៅតាមជញ្ជាំងអង្គរវត្តនិងក្រោយមកនៅតាមវត្តអារាមគឺមើលទៅហាក់ដូចជាត្រូវបានធ្វើឡើងដោយសាធារណជនទូទៅ ។[៧៣]

ការដាក់ទណ្ឌកម្មលើរាងកាយប្រភេទផ្សេងៗទៀតនៅសម័យមុនអាណានិគមក៏មានលក្ខណៈធ្ងន់ធ្ងរដែរ ។ ឧទាហរណ៍ជាក់ស្តែង ក្រមសីលធម៌កម្ពុជានៅសតវត្សរ៍ទី១៧មានទារុណកម្មចំនួនម្តមួយយ៉ាងដែលជាការដាក់ទណ្ឌកម្មយ៉ាងឃោរឃៅចំពោះអ្នកដែល «ចង់មានអំណាចខ្លាំងនិងចង់ក្បត់ព្រះរាជាជាស្តេចផែនដី» ។[៧៤] និទានកថារបស់ខ្មែររឿងទុំទាវដែលនិពន្ធនៅសតវត្សរ៍ទី១៧ និងបោះពុម្ពផ្សាយជាលើកដំបូងនៅដើមទសវត្សរ៍ឆ្នាំ១៩០០ ហើយសិស្សានុសិស្សគ្រប់ជំនាន់បានដឹងព្រោះបញ្ជាក់ថា នៅពេលសមាជិកគ្រួសារម្នាក់ត្រូវបានចោទប្រកាន់ថា ក្បត់នឹងព្រះរាជា នោះគ្រួសារទាំងមូលនឹងត្រូវសម្លាប់ចោលទាំងអស់មិនឲ្យសល់ម្នាក់ឡើយ ។ គ្រួសារនោះត្រូវបានកប់ក្នុងដីត្រឹមក ហើយឲ្យនាស់ក្របីអូសកាត់លើក្បាល ដែលលយចេញមកទាល់តែដាច់ខ្ទេចខ្ទី ។[៧៥]

ករណីដែលកើតឡើងក្នុងសម័យមុនអាណានិគម និងការប្រកាន់នូវរបៀបរបបបែបនេះមានលក្ខណៈ

ដូចគ្នានឹងករណីដែលកើតឡើងនៅស្រុកបារាំងមុនសម័យបដិវត្តន៍ដែរ ។ ការប្រហារជីវិតជាសាធារណៈនៅប្រទេសបារាំងនេះបានរៀបរាប់យ៉ាងពិស្តារដោយលោក ម៉ៃឃើល ហ្វូខល នៅដើមទំព័រដំបូងមានចំណងជើងថា «វិន័យនិងការដាក់ទណ្ឌកម្ម» ។ ប៉ុន្តែករណីទាំងនេះមានលក្ខណៈខុសប្លែកច្រើនពីអ្វីដែលកើតឡើងនៅមន្ទីរ ស-២១ ដែលនៅមន្ទីរនេះ ទារុណកម្មត្រូវបានធ្វើឡើងដោយរើសមុខសញ្ញាដាច់ដោយឡែក ហើយមិនមានការពាក់ព័ន្ធជាមួយការសម្លាប់ទេ ។ ការសម្លាប់ចោលជារឿងផ្សេងដែលត្រូវធ្វើឡើងនៅខាងក្រៅដោយសម្ងាត់និងទាំងហ្វូងៗ ហើយជាទូទៅនៅពេលយប់ទៀត ។ បើប្រមូលផ្តុំការធ្វើទារុណកម្មលើរាងកាយ និងភាពសម្ងាត់ដាច់ខាត ការធ្វើឯកសារនិងការស៊ើបការណ៍ឃើញថា ការអនុវត្តទាំងអស់នេះមានលាយឡំនូវអ្វីដែលលោក ហ្វូខល បានទាញហេតុផលរួចមកហើយថា មានការប្រែប្រួលទៅតាមដំណាក់កាល ហើយលោកហៅដំណាក់កាលទាំងនេះថាជា «ការសងសឹករបស់ព្រះរាជាឬអ្នកកាន់អំណាច» និង «ការការពារសង្គម» ។[២៦]

ក្នុងសម័យធ្វើអាណានិគមនៅកម្ពុជា (១៨៦៣-១៩៥៤) បារាំងបានបង្កើតនគរបាលអាជីពឲ្យធ្វើការក្រោមការគ្រប់គ្រងរបស់ខ្លួន ។ នៅត្រឹមឆ្នាំ១៩០០ ឬឆ្នាំប្រហាក់ប្រហែលនេះ មន្ត្រីកម្ពុជាលែងប្រើទារុណកម្មព្រហ្មទណ្ឌទៀតហើយ ។ ដោយសារបារាំងមានការក្រែងរអែង ទារុណកម្មព្រហ្មទណ្ឌមិនដែលត្រូវបានធ្វើឡើងជាចំហទេ ។ តែផ្ទុយទៅវិញ បារាំងបានបង្កើតនីតិវិធីតុលាការនិងស្ថាប័នរដ្ឋបាលយុត្តិធម៌តាមរបៀបលោកខាងលិច ។ ប៉ុន្តែនៅក្នុងគម្រោងដែលគេគិតថាមានលក្ខណៈសមហេតុផលនេះ ការសួរចម្លើយលើអ្នកទោសច្រើនតែស្ថិតក្នុងសភាពសាហាវណាស់ ។ ក្រោយពីប្រទេសកម្ពុជាបានទទួលឯករាជ្យ មន្ត្រីនគរបាលដែលមានចំហាយពីបារាំងនៅតែវាយធ្វើបាបអ្នកទោសដដែល ហើយអ្នកដែលត្រូវបានចោទថាក្បត់តែងតែត្រូវរងទារុណកម្មមុនពេលសម្លាប់ចោល ។ នៅក្នុងរបប លន់ ណុល ឈ្លើយសឹកត្រូវបានធ្វើទារុណកម្មជម្រិតយកពត៌មានជាធម្មតាទៅហើយ ។ ក៏ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏គ្មានភស្តុតាងឯណាបញ្ជាក់ថា នគរបាលបានអនុវត្តទារុណកម្មផ្លូវតុលាការយ៉ាងទូលំទូលាយ ឬយកទារុណកម្មបែបនេះធ្វើជាឧបករណ៍សម្រាប់សន្តិសុខជាតិដែរមុនពេលដែលខ្មែរក្រហមឡើងមកកាន់អំណាចនោះ ។

ហេតុអ្វីបានជាមានករណីបែបនេះ? ជាបឋមសូមលើកករណីមួយចំនួនមកបរិយាយ ។ អ្នកដែលត្រូវចោទប្រកាន់ថា ក្បត់ជាតិ ក្រោមការគ្រប់គ្រងរបស់សម្តេច សីហនុ និង លន់ ណុល កម្របានមកកាន់តុលាការណាស់ ។ ដូច្នេះគ្មានការសុំឲ្យមានការឆ្លើយសារភាពលម្អិតដូចការអនុវត្តទារុណកម្មតាមផ្លូវតុលាការឡើយ ។ កត្តាដាច់ណាត់មួយទៀតគឺថា មកដល់ឆ្នាំ១៩៧៥ទៅហើយ នៅតែមាននីតិវិធីនគរបាល និងតុលាការបែបលោកខាងលិចដដែល ។ ភស្តុតាងដែលបានមកដោយសារការធ្វើទារុណកម្ម ប្រសិនបើយកមកប្រើប្រហែលជាអាចយកមកតវ៉ាដេញដោលនៅក្នុងតុលាការ ហើយភាពបើកចំហដែលមិនអាចទទួលយកបានប្រហែលជាធ្វើឲ្យអាប់ដល់កិត្តិយសរបស់កម្ពុជាផង បើសិនជាការណ៍នេះលេចឮដល់អ្នកសង្កេតការណ៍បរទេស ។ ការគាបសង្កត់បែបនេះក៏មានអនុវត្តនៅប្រទេសដទៃទៀតដែរ ។ ប្រសិនបើទារុណកម្មផ្លូវតុលាការកើតឡើងនៅប្រទេសកម្ពុជាក្រោយសម័យអាណានិគម ការគ្មានសេចក្តីបញ្ជាក់ពីឯកសារបង្ហាញថា ទារុណកម្មបែបនេះត្រូវបានធ្វើឡើងដោយសម្ងាត់ដូចជាទម្លាប់ទៅហើយនៅកន្លែងផ្សេងទៀតនៅសម័យបច្ចុប្បន្ននេះ ។[២៧]

## ធារុណកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

បន្ទាប់ពីជ័យជម្នះរបស់ខ្មែរក្រហមថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជា បានបាត់ស្រមោលឈឹងតែម្ដង ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគ្មានតុលាការ គ្មានចៅក្រម គ្មានច្បាប់ និងគ្មានការជំនុំជម្រះក្ដីអ្វីឡើយ ។ «តុលាការប្រជាជន» ដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យត្រង់មាត្រាទី៩មិនដែលមានជារូបរាងទេ ។[២៨] ការគ្មានច្បាប់ ឬការការពារ ការផ្ដាច់ខ្លួនចេញពីពិភពលោក សារសំខាន់ដែលកំណត់ដោយមជ្ឈិមបក្សចំពោះចម្លើយសារភាពរបស់ «ខ្មាំង» និងការលាយឡំរវាងកិត្យានុភាពនិងភាពសម្ងាត់របស់មន្ទីរស-២១ ទាំងអស់នេះបានជំរុញឲ្យ ឌុច និងបក្ខពួកធ្វើទារុណកម្ម និងប្រើមធ្យោបាយផ្សេងទៀតដែលខ្លួនមានដើម្បីជម្រិតយកចម្លើយសារភាព ។ ក៏ប៉ុន្តែ អ្នកធ្វើការនៅមន្ទីរស-២១ បានលាក់បាំងរឿងនេះក៏ដូចជារឿងផ្សេងៗទៀតមិនឲ្យមហាជនកម្ពុជាដឹងឡើយ ។

កម្មាភិបាលធ្វើការនៅមន្ទីរស-២១ ជឿជាក់ថា ពេលដែលខ្លួនធ្វើទារុណកម្មអ្នកទោស គឺគេពិតជាបានឆ្លើយតបទៅនឹងអ្វីដែលប្រទេសជាតិត្រូវការជាចាំបាច់និងឆ្លើយតបទៅនឹងការភ័យខ្លាចរបស់អ្នកដឹកនាំប្រទេសនេះផង ។ ដូចយើងឃើញស្រាប់ហើយថា មនោគមវិជ្ជារបស់កម្ពុជាប្រជាធិបតេយ្យគឺការបន្តធ្វើសង្គ្រាមវណ្ណៈនិងធ្វើបដិវត្តន៍ ។ «ខ្មាំង» មាននៅគ្រប់កន្លែង ហើយត្រូវតែកម្ទេចចោល ។ ខ្មាំងខ្លះនៅរាយតាមព្រំដែនកម្ពុជា ចំណែកខ្មាំងផ្សេងទៀតនៅឆ្ងាយពីនេះទៀត ហើយមានមួយចំនួនទៀត «បង្កប់ស៊ីរូងផ្ទៃក្នុងបក្ស» ។ ខ្មាំងភាគច្រើនបន្លំខ្លួនធ្វើជាមិត្ត ។ ដើម្បីតាមដដឹករកពួកនេះ ចាំបាច់ត្រូវតែចាត់វិធានការឲ្យបានតឹងរ៉ឹង ។

ទារុណកម្មតាមផ្លូវតុលាការភាគច្រើននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលកើតឡើងនៅក្នុងមន្ទីរស-២១ គឺប្រហែលដោយសារមន្ទីរនេះមានតែមួយនៅក្នុងប្រទេសដែលមាននាទីគតិយុត្តិស្ទើរតែពេញលេញ ដូចដែលបានបង្ហាញតាមរយៈការផ្ញើឯកសារផលិតដោយមន្ទីរនេះស្រាប់ ។ មន្ទីរស-២១ ក៏មានអំណាចផ្ដល់ដោយមជ្ឈិមបក្សក្នុងការចាត់ការរឿងទោសក្បត់បក្សដែរ ។ បុរសនិងស្ត្រីរាប់ពាន់នាក់ដែលមានទោសស្រាល ឬ ចាប់ដាក់គុកថាជាខ្មាំងវណ្ណៈ ត្រូវស្លាប់ដោយកង្វះចំណីអាហារហូបមិនគ្រប់គ្រាន់ ជំងឺ និងការប្រព្រឹត្តិអំពើសាហាវឃោរឃៅក្នុងគុកនានានៅតាមបណ្ដាខេត្តផ្សេងៗ ។ ប៉ុន្តែជាទូទៅ ប្រជាជនទាំងនេះមិនទទួលរងទារុណកម្មដើម្បីបន្ទំឲ្យបង្ហាញភ័ស្ដុតាងថាខ្លួនធ្វើខុសឡើយ ។[២៩] ថ្វីបើដូច្នេះមែន អ្នកទោសដែលគេដាក់ផ្លាកសម្រាប់បញ្ជូនមកទួលស្លែង ជារឿយៗ ត្រូវបានធ្វើទារុណកម្មនៅក្នុងគុកតាមបណ្ដាខេត្តជាមុនដើម្បីលត់អ្នកទោសប្រមូលយកពត៌មានដំបូងសម្រាប់យកមកផ្ដល់ឲ្យអ្នកសួរចម្លើយនៅទីក្រុងភ្នំពេញធ្វើជាឯកសារ ។ ជាអាទិ៍ វ៉ាន់ ណាត ត្រូវបានធ្វើទារុណកម្ម «អស់ជាច្រើនម៉ោង» នៅខេត្តបាត់ដំបង មុនពេលគាត់មកដល់មន្ទីរស-២១ ។ ចំណែកឯឈ្មោះ ប៊េន ឆែ (ហៅ ឆោម សាវ៉ាត) បានរៀបរាប់នៅក្នុងចម្លើយសារភាពរបស់ខ្លួនថា គាត់បានទទួលទារុណកម្មនៅខេត្តកំពង់ចាមមុនគេបញ្ជូនមកភ្នំពេញ ។[៣០]

ដូច្នេះទារុណកម្មតាមផ្លូវតុលាការនៅមន្ទីរស-២១ ត្រូវបានភ្ជាប់ទៅនឹងឧក្រិដ្ឋកម្មដូចបរមតិនៅអឺរ៉ុបកាលពីមជ្ឈិមសម័យដែរ ។ ឧក្រិដ្ឋកម្មនេះរួមមានការក្បត់នឹងសតិអារម្មណ៍ក្នុងការដឹកនាំនិងការសង្ស័យទៅ

លើខ្សែបណ្ដាញបន្តប់ផ្ទៃក្នុង ។ កាលនៅក្នុងមជ្ឈិមសម័យ ចម្លើយសារភាពរបស់អ្នកទោសបានបង្កើតទោសកំហុសឡើងមុនគេ ។ គ្មានការបង្ហាញជាភស្តុតាងត្រឹមត្រូវទេ ។ ដូចយើងឃើញស្រាប់ក្រោយពី "ការបះបោរ" របស់ ចាន់ ចក្រី នៅខែមេសា ឆ្នាំ១៩៧៦ ថ្នាក់ដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យមានអារម្មណ៍ភ័យខ្លាចមិនឈប់ឈរ ។ ថ្នាក់ដឹកនាំទាំងនេះត្រូវការឲ្យមានមនុស្សទទួលថ្មបាក់ដែលបានធ្វើអ្វីដែលរដ្ឋធម្មនុញ្ញ (កម្ពុជាប្រជាធិបតេយ្យមាត្រា១០) ហៅថា "សកម្មភាពប្រឆាំងនិងបំផ្លិចបំផ្លាញហើយគ្រោះថ្នាក់ដល់រដ្ឋរបស់ប្រជាជន" ។ មិនយូរប៉ុន្មាន បរាជ័យនៃផែនការសេដ្ឋកិច្ចត្រូវការឲ្យមានមនុស្សទទួលថ្មបាក់ថែមទៀត ។ នៅពាក់កណ្ដាលឆ្នាំ១៩៧៦ អ្នកទោសភាគច្រើនដែលនាំមកមន្ទីរស-២១ ត្រូវបានចោទប្រកាន់ថាក្បត់ ឬមានការពាក់ព័ន្ធអ្នកដទៃទៀតដែលត្រូវបានចោទប្រកាន់រួចហើយ ។ មន្ទីរស-២១ បានក្លាយជាកន្លែងដ៏មានសារសំខាន់សម្រាប់ជីវិតរបស់របបកម្ពុជាប្រជាធិបតេយ្យ ។

ជំហានទីមួយក្នុងការដាក់គុកនិងការតែសោះកគ្រោះទៀតនៅក្នុងការធ្វើទារុណកម្មផ្លូវតុលាការគឺការបំបាត់ភាពជាមនុស្សពីអ្នកទោស ។ នៅមន្ទីរស-២១ ការអនុវត្តបែបនេះមានឥទ្ធិពលពីរយ៉ាង ទីមួយធ្វើឲ្យអ្នកធ្វើទារុណកម្មប្រព្រឹត្តផឹតផលមកលើអ្នកទោស និងទីពីរកាត់ផ្ដាច់អ្នកទោសមិនឲ្យមានគំនិតសហគមន៍ឬគោរពខ្លួនឯង ។ ដោយសារខ្លួនត្រូវបានដាក់ឈ្មោះថា "ខ្មាំង" (ដូចទមិឡកាលពីសម័យមុនបដិវត្តន៍) អ្នកទោសបានបាត់បង់សិទ្ធិជាប្រជាជនកម្ពុជាឬជាមនុស្សជាតិទៅហើយ ។ នៅពេលមកដល់មន្ទីរស-២១ អ្នកទោសត្រូវបានរុញច្រមុជចូលក្នុងឋាននរកដូចជាជនរងគ្រោះនៅលើចម្ងាក់តាមជញ្ជាំងអង្គរវត្តយ៉ាងដូច្នេះដែរ ។ ពេលគេចាប់ខ្លួនហើយ វាសនាអ្នកទោសបានផ្លាស់ប្ដូរយ៉ាងឆាប់រហ័ស ។ វ៉ាន់ ណាត បានរំឭករឿងរ៉ាវកាលពីនៅជាប់គុកក្នុងបន្ទប់ជាមួយកម្មាភិបាលខ្មែរក្រហមថា "កាលពីនៅសហករណ៍ គេគោរពវាដូចស្ដេច គ្មានអ្នកណាហ៊ានមើលមុខវាទេ ។ ប៉ុន្តែឥឡូវនេះ ពេលជាប់ខ្នោះជើងអ៊ីចឹង មើលទៅមុខដូចស្វាក្រិស" ។[៣១]

ការបំបាត់ភាពជាមនុស្សពី វ៉ាន់ ណាត ធ្វើឲ្យនឹកឃើញដល់រឿងរ៉ាវរបស់អ្នកទោសនៅប្រទេសផ្សេងៗទៀត ។ នៅទសវត្សរ៍ទី៣០ ជាយុវតីកុម្មុយនិស្តវ័យក្មេងជនជាតិរុស្ស៊ីដែល ស្តាលីន ចាប់ដាក់គុកមុនគេ និងក្រោយមកបានបញ្ជូនមកជួបជាមួយចៅក្រមសូវៀតម្នាក់ ។ ចៅក្រមនោះប្រាប់នាងថា "ខ្មាំងមិនមែនជាមនុស្សទេ ។ គេឲ្យយើងធ្វើចំពោះខ្មាំងតាមចិត្ត ចង់ធ្វើយ៉ាងម៉េចក៏គ្មានបញ្ហាដែរ" ។ ពាក្យរបស់ចៅក្រមម្នាក់នេះប្រហែលជាពាក្យដែលក្រសោបនូវសកម្មភាពនៅមន្ទីរស-២១ ក៏ថាបាន ។[៣២]

នៅគ្រប់ទីកន្លែងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ "ប្រជាជនមូលដ្ឋាន" ភាគច្រើនតែងទទួលបាននូវឋានៈយ៉ាងប្រសើរ ។ ប្រជាជនទាំងនេះត្រូវបានចាត់ទុកដូចជាសមាជិកបក្សកុម្មុយនិស្តដែលបានឆ្លងកាត់ "សម្ព័ន្ធយុវជនកុម្មុយនិស្ត"ទាំងត្រៀមទាំងពេញសិទ្ធិ ។ ចំណែកឯ "ប្រជាជនថ្មី" វិញ ដូចជាប្រជាជនមកពីទីក្រុង ឬ ប្រជាជនមានជំហរមិនបដិវត្តត្រូវបានហៅថា "ប្រជាជនបញ្ញើ" ជាការបញ្ជាក់ថា ប្រជាជនទាំងនេះជាអ្នកដែលត្រូវបានជម្លៀសទៅជនបទ ។ អ្នកទោសនៅមន្ទីរស-២១ មានឋានៈទាបជាងប្រជាជនបញ្ញើទៅទៀត ។[៣៣] មុនពេលសួរចម្លើយ អ្នកទោសត្រូវបានឆ្មាំឲ្យដោះសម្លៀកបំពាក់ខ្មៅបដិវត្តចេញ ហើយឆ្មាំ

ក៏បោះខោអាវហែករយ៉ៃពាក់មិនសមនឹងខ្លួនឲ្យស៊កជំនួសវិញ ។ ឆ្មាំគុកប្រើពាក្យ "អាមីង-អ្អែង-ហ្អង" ដូចភាសាប្រើចំពោះក្មេងនិងសត្វធាតុអីចឹង ។ មុនពេលចាប់ផ្ដើមសរសេរចម្លើយសារភាព អ្នកទោសតែងតែរៀបរាប់ពីប្រវត្តិរូបផ្ទាល់ខ្លួនជាមុនសិន ។ ប៉ុន្តែប្រវត្តិរូបផ្ទាល់ខ្លួននៅពេលនេះមិនមានដាក់វណ្ណៈភាពដូចជា នៅក្នុងឯកសារដែលបក្សតម្រូវនោះទេ ។ អ្នកទោសត្រូវបានដោះសម្លៀកបំពាក់ចេញ បំបាត់ភាពជាមនុស្ស និង វណ្ណៈភាព រំលោភបំពាន វាយដំប្រំធាក់ និងធ្វើឲ្យអាម៉ាស់មុខ ។ ឆ្មាំធ្វើយ៉ាងនេះទាល់តែអ្នកទោសឆ្លើយតាមអ្វីដែលបក្សចង់បានដែលជាការបង្ហាញថា អ្នកទោសត្រូវបានធ្វើបាបស្មើរស្លាប់ស្មើររស់ ។

## ការជំនុំជម្រះឆោសរបស់សូវៀតដែលធ្វើសម្រាប់តែបន្ត្រប់កិច្ច

ដូចយើងបានឃើញស្រាប់ហើយ កម្មាភិបាលធ្វើការនៅមន្ទីរស-២១ ធ្វើការដោយផ្អែកតែលើការសន្មតប៉ុណ្ណោះដែលថា អ្នកទោសមានកំហុសដោយសារតែគេចោទប្រកាន់ ហើយការដែលចាត់ទុកអ្នកទោសក្រោមឋានៈមនុស្សទូទៅ គឺដោយសារតែអ្នកទោសទាំងនោះត្រូវបានចាប់ខ្លួន ។ គំនិតនេះបានចាក់ឫសយ៉ាងជ្រៅនៅក្នុងវប្បធម៌ខ្មែរ ។ ប៉ុន្តែគួររំពុកថា ការជំរុញឲ្យមានការសួរចម្លើយរយៈពេលយូរនៅមន្ទីរស-២១ ដែលអមដោយការធ្វើទារុណកម្មតាមផ្លូវតុលាការនិងដើម្បីផលិតចេញជាឯកសារចម្លើយសារភាពដ៏ច្រើនហូរហៀរនោះ គឺមានប្រភពចេញមកពីបរទេសទៅវិញទេ ពោលគឺប្រភពមកពី "ការជម្រះក្ដីស៊ីគេនោះ" ដែលធ្វើឡើងនៅទីក្រុងមូស្គូ (ជួនកាលគេហៅថាមហាភយន្តរាយ) នៅឆ្នាំ១៩៣៦-១៩៣៨ ។ កាលនោះកម្មាភិបាលកុម្មុយនិស្តនិងឥស្សរជនសូវៀតរាប់រយនាក់បានឆ្លើយសារភាពជាសាធារណៈថា ខ្លួនបានធ្វើវិទ្ធង្សនា ចារកម្ម និងប្រព្រឹត្តអំពើក្បត់ ។ ប៉ុន្តែការឆ្លើយសារភាពភាគច្រើនមិនមានលក្ខណៈត្រឹមត្រូវឡើយ ចេះតែឆ្លើយឲ្យតែបានៗប៉ុណ្ណោះ ។ មានមនុស្សរាប់ពាន់នាក់ផ្សេងទៀតត្រូវបានសម្លាប់ចោលដោយគ្មានការជម្រះក្ដីឡើយ ។ ចម្លើយសារភាពយ៉ាងល្អិតល្អន់ដែលដកស្រង់នៅទីក្រុងមូស្គូគឺត្រូវបានធ្វើឡើងសម្រាប់តម្រូវចិត្ត ស្តាលីន តែប៉ុណ្ណោះ ។ ធ្វើនេះគឺដើម្បីឲ្យ ស្តាលីន លែងមានការភ័យខ្លាចនិងមមៃពីរឿង "ខ្មាំង" ព្រមទាំងដើម្បីពង្រឹកអំណាចរបស់ខ្លួនផ្ទាល់ ។ ទាក់ទងរឿងនេះ វិសុទ្ធកម្មនិងចម្លើយសារភាពធ្វើឡើងនៅសូវៀតដូចគ្នាទៅនឹងចម្លើយសារភាពដែលចម្រាញ់នៅមន្ទីរស-២១ ដែរ ។ ស្តាលីន បានចំណាយពេលយ៉ាងច្រើនទៅលើការជម្រះក្ដី ដើម្បីបិទបាំងមិនឲ្យមតិសាធារណៈដឹងពុសុសសាយ ។ ប៉ុល ពត ក៏ដូចស្តាលីន ដែរ បានរៀបចំឈុតឆាកមួយចំនួនតូចប្រកបដោយការប្រុងប្រយ័ត្ននៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។ ជាងនេះទៀត ជនចុងចោទសូវៀតដែលទទួលការចង្អុលបង្ហាញ(ឬបំពាក់ដំហរដោកដាំ) ហើយនោះភាគច្រើនមិនដែលបដិសេធពីកំហុសរបស់ខ្លួនទេនៅពេលឡើងដល់តុលាការ ហើយកម្រនិយាយការពារខ្លួនណាស់ ។ ករណីនេះមិនខុសពីចុងចោទនៅក្នុងប្រទេសកម្ពុជានៅសម័យក្រោយៗនេះទេ ។ អ្នកទោសនៅប្រទេសទាំងពីរនេះត្រូវចាត់ទុកថា "ថោកជាងសំរាមទៅទៀត" ។ ក្រោយពីអានចម្លើយសារភាពរបស់ខ្លួនឡើងវិញចំពោះមុខតុលាការរួចហើយ អ្នកទោសសូវៀតភាគច្រើនដូចអ្នកទោសនៅទួលស្លែងដែរ គឺត្រូវបានសម្លាប់ចោលយ៉ាងសម្ងាត់បំផុត ។

នៅក្នុងករណីទាំងពីរនេះ ការកាត់ទោសប្រហារជីវិតត្រូវបានធ្វើឡើងមុនគេដូចជាសម្ដីរបស់ វ៉េត ឃ៊ីន ដែលថា «កាត់ទោសមុនសឹមសម្រេចជាក្រោយ» ។ ប៉ុន្តែនៅទីក្រុងមូស្គូ ពិសោធន៍នេះត្រូវធ្វើឡើងជាចំហនៅក្នុងតុលាការដែលមានលក្ខណៈយុត្តិធម៌នៅក្នុងសតវត្សរ៍ទី២០ ។ ចំណែកនៅមន្ទីរស-២១ វិញ អ្វីៗគ្រប់យ៉ាងត្រូវតែសម្ងាត់ គ្មានឱកាសបាននិយាយគ្នា ហើយទាំងអ្នកទោសទាំងចៅក្រមមិនដែលចេញមុខទេ ។ មូលហេតុដែលនាំឲ្យមានភាពខុសគ្នាគឺថា ការជម្រះទោសនៅទីក្រុងមូស្គូធ្វើឡើងដោយចេតនា ដើម្បីបង្ហាញថា សហភាពសូវៀតជាអ្នកដឹកនាំចលនាកុម្មុយនិស្តពិភពលោក ចំណែកថ្នាក់ដឹកនាំខ្មែរក្រហមមិនខ្វល់នឹងទស្សនៈពិភពលោកទេ ហើយជឿថា ការរក្សាភាពសម្ងាត់គឺជាធាតុផ្សំយ៉ាងសំខាន់សម្រាប់នាំខ្លួនទៅដល់ជោគជ័យ ។

ភាពខុសគ្នាមួយទៀតរវាងដំណើរនីតិវិធីទាំងពីរនេះគឺថា ការធ្វើទារុណកម្មលើរាងកាយមុនពេលមានការជម្រះក្ដីនៅសូវៀតហាក់ដូចជាមិនសូវជាញឹកញាប់ប៉ុន្មានទេ ហើយមានកម្រិតទៀតផង គឺគ្រាន់តែមិនឲ្យដេកនិងដាក់អ្នកទោសចំពន្លឺភ្លើងខ្លាំង បន្ទាយពេលវេលាសួរចម្លើយ អាហារមិនគ្រប់គ្រាន់ និងការដាក់ឲ្យនៅតែឯង ។ សូលហ្សិន នីតស៊ីន បានសរសេរដោយយោងតាមបទពិសោធន៍របស់គាត់ដែលត្រូវបានគេសួរចម្លើយនៅក្នុងទសវត្សរ៍ឆ្នាំ៤០ថា «អ្នកសួរចម្លើយខ្ញុំបានប្រើវិធីផ្សេងៗមកលើខ្ញុំជាជាងមិនឲ្យដេកលក់ ភូតភរ និង គំរាមកំហែង ។ អ្វីៗគ្រប់យ៉ាងគឺតាមច្បាប់ទាំងអស់» ។ នៅមន្ទីរស-២១ ការគាបសង្កត់ទាំងនេះត្រូវបានប្រើប្រាស់ជាមួយនឹងការប្រើអំពើហិង្សា ។ វិធីសាស្ត្ររបស់សូវៀតវាគ្រប់គ្រាន់ទៅហើយសម្រាប់វាយបំបាក់អ្នកទោស ។ ទារុណកម្មលើរាងកាយត្រូវបានធ្វើឡើងតែនៅពេលណាដែលមើលទៅអ្នកទោសហាក់ដូចជាមានសុខភាពមាំមួននៅមុខតុលាការ ហើយស្ដាប់ទៅអ្នកទោសអាចឆ្លើយតាមចិត្តរបស់ខ្លួន តែទោះជាយ៉ាងណាក៏ដោយ ការធ្វើទារុណកម្មលើរាងកាយត្រូវបានអនុញ្ញាតឲ្យប្រើដោយ ស្តាលីន ទៅលើ«ខ្មាំងរបស់ប្រជាជនដែលល្បីល្បាញ និងពិបាកកម្ទាត់» តែប៉ុណ្ណោះ ដោយសារថា អំពើនេះត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយដោយ «ភ្នាក់ងារស៊ើបការណ៍គហបតី» ។ ចំណែកឯជនរងគ្រោះនៅមន្ទីរស-២១ ដែលគេមិនបញ្ចេញឲ្យឃើញវិញ អាចត្រូវបានវាយដំនិងធ្វើទារុណកម្មញឹកញយ ឬសាហាវយ៉ាងណា ស្រេចតែលើអ្វីដែលអ្នកចាប់ចងយល់ថាសមស្រប ។[៣៨]

ទោះបីជាមានការកត់ទុកក្នុងចិត្តអំពីការខុសប្លែកគ្នាយ៉ាងនេះក៏ដោយ ប៉ុន្តែក៏នៅមានភាពដូចគ្នាច្រើនរាប់មិនអស់ ដែលមិនមែនជាការចៃដន្យឡើយរវាងការចោទប្រកាន់និងការឆ្លើយសារភាពនៅសូវៀតនិងនៅមន្ទីរស-២១ ។ តើគំរូទាំងនេះមកដល់កម្ពុជាដោយរបៀបណាទៅ? ចម្លើយគឺ «បងៗថ្នាក់លើ» ភាគច្រើនដឹងច្បាស់អំពីការជម្រះក្ដីនៅមូស្គូ ។ ប៉ុល ពត, សុន សេន, អៀង សារី និង ខៀវ សំផន អាចដឹងអំពីការជម្រះក្ដីទាំងនេះនៅដើមទសវត្សរ៍ទី៥០ នៅពេលខ្លួនកំពុងរៀននៅស្រុកបារាំង និងធ្វើសមាជិកបក្សកុម្មុយនិស្តបារាំង ។ និស្សិតក្រហមទាំងនេះអាចបានអានឯកសារទិនានុប្បវត្តិនិងពត៌មានសង្ខេបរបស់បក្ស ដែលនិយាយពីរឿងវិសុទ្ធកម្ម ។ គេក៏ប្រហែលជាបានដឹងនិងយល់ស្របតាមការជម្រះក្ដីដែលរៀបចំឡើងដោយសូវៀតនៅប្រទេសឆេកូស្លូវ៉ាគី ហុងគ្រី និងប្រទេសផ្សេងៗទៀតដែលជាប្លុករបស់សូវៀតដែរ ។[៣៩]

ទោះជាមិនបានបញ្ចេញយោបល់ជាសាធារណៈចំពោះការជម្រះក្តីក៏ដោយ ប៉ុន្តែជនជាតិកម្ពុជាវ័យក្មេងទាំងនេះច្បាស់ជាមានចំណាប់អារម្មណ៍យ៉ាងខ្លាំងទៅលើការធ្វើទោសដោយខ្លួនឯងរបស់ជនជាប់ចោទក័ស្តុតាងលម្អិតគ្រប់បែបយ៉ាងប្រឆាំងនឹងជនជាប់ចោទ និងការរកយុត្តិធម៌បដិវត្តជាមួយនឹងថ្នាក់ដឹកនាំដែលលាក់មុខនិងមានអំណាចបំផុត ។ ការហ៊ឹកហ៊ឺនរបស់ខ្លួននៅក្នុងបក្សកុម្មុយនិស្តបារាំងដែលគាំទ្រ ស្តាលីន ដាច់ខាតពិបាកនឹងគាំទ្រជនរងគ្រោះរបស់ ស្តាលីន ឬកោតសរសើរសុជីវធម៌របស់គហបតីដែលជាការប្រឆាំងនឹងយុត្តិធម៌បដិវត្តណាស់ ។ នៅពេលវេលាមកដល់ ចម្លើយសារភាពដែលដកស្រង់នៅមន្ទីរស-២១ ដូចគ្នាទៅនឹងគំនិតសង្ស័យនិងមិនទុកចិត្តគ្នា ការគិតថា អ្វីៗទាំងមូលវាសំខាន់ជាង ដោយផ្អែកទម្រង់នៃការចោទប្រកាន់និងដំណើរការសួរចម្លើយនៅក្នុងការជម្រះក្តីនៅសូវៀតដែលធ្វើឲ្យតែល្អមើលនោះ ។ តាមរយៈករណីទាំងពីរនេះ បក្សកុម្មុយនិស្តមួយដែលមមៃដល់ប្រវត្តិសាស្ត្របានធ្វើវិសុទ្ធកម្មលើខ្លួនឯងដើម្បីការពារមេដឹកនាំរបស់ខ្លួនដែលមានការសង្ស័យ ។ ការធ្វើបែបនេះមិនមែនជាការភ្ញាក់ផ្អើលអ្វីទេ ។

## គំរូរបស់ប្រទេសចិននិងវៀតណាម

គំរូមួយទៀតដែលនាំឲ្យមាននីតិវិធីឃោរឃៅព្រៃផ្សៃនៅមន្ទីរស-២១ គឺបានមកពីវិសុទ្ធកម្មរបស់បក្សកុម្មុយនិស្តនិងយុទ្ធនាការអប់រំកសាងខ្លួននៅក្នុងប្រទេសចិនដែលជ្រាបរហូតមកដល់ប្រទេសវៀតណាម ។ ជនកុម្មុយនិស្តកម្ពុជាដែលកំពុងតែកៀកស្មាប្រយុទ្ធជាមួយវៀតណាមនៅក្នុងសង្គ្រាមឥណ្ឌូចិន (១៩៤៦-១៩៥៤) ប្រហែលជាបានដឹងពីបច្ចេកទេសសួរចម្លើយរបស់សូវៀត "ការអប់រំកសាងខ្លួន" តាមបែបចិននិងទម្រង់ធម្មតានៃចម្លើយសារភាព "ដែលប្រឆាំងនឹងបដិវត្តន៍" តាមរយៈវៀតណាមដែលជាអ្នកឧបត្ថម្ភខ្លួន ។

ការហ៊ឹកហាត់របស់វៀតណាមចំពោះកម្មាភិបាលខ្មែរក្នុងផ្នែកសន្តិសុខប្រសិនជាមាន គឺប្រហែលជាយកតាមគំរូរបស់ចិន ។ នៅដំណាក់កាលដំបូងនេះ មានការកែយុទ្ធនាការតម្រង់ *(zhen-fan)* ដែលធ្វើឡើងនៅ *Yan's* នៅឆ្នាំ១៩៤៣ និងយុទ្ធនាការកែទម្រង់ដីធ្លីនៅចិនខាងជើងក្រោយឆ្នាំ១៩៤៩ ។ រលកវិសុទ្ធកម្មកើតឡើងនៅទូទាំងប្រទេសចិននិងវៀតណាមនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៥០ ។ មនុស្សរាប់ពាន់នាក់ត្រូវបានសម្លាប់ អាជីពការងាររាប់ពាន់ត្រូវបានបំផ្លាញ ហើយមនុស្សរាប់សែននាក់ត្រូវបានចាប់មកសួរចម្លើយរួចហើយក៏លែងទៅវិញ ។ ចិននិងវៀតណាមបានលាយបញ្ចូលគ្នានូវសញ្ញាណដែលមិនអាចជំនួសបាននៃយុត្តិធម៌បដិវត្តរបស់សូវៀតជាមួយគំនិត "កែទម្រង់ស្មារតី" ឬ "អប់រំកសាងខ្លួន" ដែលមាននៅប្រទេសចិននិងវៀតណាមតាំងពីសម័យមុនបដិវត្តមកម្ល៉េះ ប៉ុន្តែនៅមានចំហាយរហូតមកនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ។[៣៦]

ដោយផ្អែកលើប្រពៃណីនេះ ចិននិងវៀតណាមបានអនុវត្តនូវអ្វីដែល ភីតធ័របឺ និង ថូម៉ាស់ ឡាក់មែន ហៅថាយុទ្ធសាស្ត្រនៃ "ការព្យាបាលរោគ" ដើម្បីទប់ទល់ជាមួយមនុស្សខុសពីអ្នកដទៃ ។ ការណ៍នេះខុសទៅនឹង "ការបំបាត់ចោល" ដែលធ្វើឡើងនៅសហភាពសូវៀត និងក្រោយមកនៅមន្ទីរស-២១ ។ នៅក្នុងប្រទេសទាំងបួននេះអ្នកទោសត្រូវតែឆ្លើយយ៉ាងពេញលេញនិងជាចំហទៅនឹងការចោទប្រកាន់នានា និង

និយាយស្មានៗអំពីអតីតកាលរបស់ខ្លួនឲ្យស៊ីគ្នាទៅនឹងតម្រូវការរបស់បក្ស ។ ជាងនេះទៀត អ្នកទោសត្រូវតែសម្តែងនូវការសោកស្តាយយ៉ាងខ្លាំងទៀតផង ។ ប៉ុន្តែការទិញសេរីភាពពិបាកធ្វើណាស់ ហើយកម្របានពេញលេញទៅទៀត ។ អត្តចរិតរបស់អ្នកដែលត្រូវបានចោទប្រកាន់ថា ធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ ត្រូវបានបន្ទុចជាអចិន្ត្រៃយ៍ ប៉ុន្តែក្រោយពី «ការកែតម្រង់» រួចមក ចំនួនជនរងគ្រោះនៅប្រទេសចិននិងវៀតណាមស្លាប់តិចជាងនៅសូវៀតឆ្ងាយណាស់ ។ ផ្ទុយមកវិញ «ខ្មាំង» រាប់ពាន់នាក់បានចំណាយពេលយ៉ាងយូររស់នៅក្នុងគុក ។[៣៧]

នៅប៉ុន្មានខែចុងឆ្នាំ១៩៧៨ អ្នកធ្វើការនៅមន្ទីរស-២១ បានលេងសើចជាមួយនឹងគំនិតយកគំរូតាមយុទ្ធសាស្ត្រស្រដៀងគ្នានេះ ដែលប្រហែលជាស្របគ្នាទៅនឹងការលើកលែងទោសរបស់ ប៉ុល ពត ចំពោះអតីត «ខ្មាំង» នៅដើមឆ្នាំនោះដែរ ។ ឯកសារមួយមកពីមន្ទីរ៨៧០ ដែលគេហៅថា គណៈកម្មាធិការមជ្ឈិមនោះបានសន្យាអត់ឱនឲ្យអ្នកដែលបាន «ចូល សេ.អ៊ី.អា ធ្វើការឲ្យវៀតណាម ឬអ្នកដែលចូល កា.ហ្សេ.បេ» មុនឆ្នាំ១៩៧៥ ។ អ្នកដែលធ្វើខុសក្រោយមកទៀតនឹងត្រូវចាត់ការតាមករណីជាក់ស្តែង ។[៣៨]

នៅឆ្នាំ១៩៧៨ ដែលប្រហែលជាឆ្នាំឆ្លុះបញ្ចាំងឲ្យឃើញការប្រែប្រួលវិធីសាស្ត្រនោះ មន្ទីរស-២១ ត្រូវបានដាក់នៅក្នុងចម្លើយសារភាពមួយចំនួនថា «សាលាកែប្រែ» ជាឈ្មោះគុកនៅតាមខេត្តរបស់កម្ពុជាប្រជាធិបតេយ្យ ។ តាមសៀវភៅកំណត់ហេតុរបស់ ប៊ុន បានបង្ហាញថា នយោបាយមួយត្រូវបានចាប់ផ្តើមដាក់ចេញនៅខែតុលា ឆ្នាំ១៩៧៨ មិនមែនឲ្យវាយអ្នកទោសជនជាតិខ្មែរទេ តែជាការខឹងសម្បារបស់សន្តិបាលចំពោះ «ជនបរទេសដូចជាភ្នាក់ងារវៀតណាម និង សេ.អ៊ី.អារបស់ចក្រពត្តិ» ។ តាមសម្តីរបស់ វ៉ាន់ ណាត យើងដឹងថា ចំនួនអ្នកជាប់គុកនៅមន្ទីរស-២១ បានធ្លាក់ចុះយ៉ាងច្រើននៅពេលនោះ ក្រោយពីការប្រារព្ធពិធីខួបបក្សកុម្មុយនិស្តកម្ពុជាលើកទីដប់ប្រាំបី ។ ការចងចាំរបស់ វ៉ាន់ ណាត ត្រូវគ្នាទៅនឹងស្ថិតិអ្នកទោសបញ្ជូនចូលមន្ទីរស-២១ សម្រាប់ខែតុលា និងខែវិច្ឆិកា ។ បន្ទប់តូចសម្រាប់កម្មាភិបាលជាន់ខ្ពស់ត្រូវបានបោសសម្អាត និងលាបថ្នាំថ្មី ហើយក្បួនច្បាប់សម្រាប់អ្នកទោសធូរស្រាលជាងមុន ។ ប៊ុន បានបញ្ជាក់នៅក្នុងសៀវភៅកំណត់ហេតុរបស់ខ្លួនថា ឥឡូវនេះ មិនមានការវាយដំដើម្បីស្រង់យកចម្លើយសារភាពទៀតទេ ដែលករណីនេះមានរហូតដល់ទៅ៨០ភាគរយនៃចំនួនអ្នកទោសទាំងអស់ឯណោះ ប៉ុន្តែគាត់បានបន្ថែមថា ប្រសិនបើធ្វើតាមទ្រឹស្តីនយោបាយហើយមិនបានសម្រេច នោះអ្នកសួរចម្លើយនៅតែប្រើវិធី «វាយដំ» តែដដែលហ្នឹង ។ ប៊ុន សរសេរនៅខែធ្នូថា «មិនមែនថាមិនវ៉ៃសោះទេ តែត្រូវវ៉ៃឲ្យតិចបំផុត» ។ នយោបាយថ្មីនេះបង្កើតឡើងមិនមែនមានន័យថា នយោបាយមុនៗខុសទេ ហើយអ្នកដែលមើលការខុសត្រូវលើអំពើហិង្សាធ្ងន់ធ្ងរនៅឆ្នាំ១៩៧៧ នៅមន្ទីរស-២១នោះក៏ស្ថិតនៅក្នុងមុខតំណែងដដែលដែរ ។

នៅក្នុងកំណត់ហេតុមួយភ្ជាប់ជាមួយចម្លើយសារភាពចុះខែធ្នូ ឆ្នាំ១៩៧៨ អ្នកសួរចម្លើយម្នាក់បាននិយាយដល់ការកែទម្រង់នេះថា÷

ចំពោះអ្នកទោស នៅពេលខ្ញុំប្រើនយោបាយទៅ វាចង់និយាយ ប៉ុន្តែវាថា វាបានចូលសេ.អ៊ី.អាត្រឹម

ឆ្នាំ១៩៧៧ប៉ុណ្ណោះ ។ វានៅតែនិយាយរឿងរ៉ាវដដែលៗ ។ វានិយាយហើយសរសេរចេញជាអក្សរអស់ ហើយរហូតមកដល់ឆ្នាំ១៩៧៨ ក៏វានៅតែដាក់ថា វាមិនបានក្បត់បក្សដែរ ។ នៅត្រង់ចំណុចនេះ ខ្ញុំបានយកវាមកជិតខ្ញុំហើយពន្យល់ពីមាគ៌ាបក្សថ្មីថា ចង់ជួយ(អ្នកទោស) ហើយសម្លុតវា រួចនិយាយថា បើឯងមិននិយាយទេអញនឹងវ៉ៃមិនខាន ។ និយាយដល់ចំណុចនេះ វាក៏ព្រមបន្តនិយាយរឿងវាប្រាប់គេទៅទៀត ។[៣៩]

គ្មានឯកសារណាពន្យល់ពីមូលហេតុដែលនាំដល់ការកែទម្រង់បែបនេះទេ ហើយដោយសារតែគុកនេះត្រូវបិទទ្វារបន្តិចក្រោយមកនោះ វាពិបាកនិយាយណាស់ថា តើការកែទម្រង់នេះកើតមានឡើងដោយទ្រង់ទ្រាយធំដែរឬក៏អត់ ដូចជា «ការកសាង» និងការដោះលែងអ្នកទោសមួយចំនួនជាដើម ។ ប៉ុន្តែនៅពេលចុងក្រោយបន្ទាប់ពីគុកមកដល់ថ្ងៃបញ្ចប់ ការប្រហារជីវិតមនុស្សនៅតែមានដដែល ហើយមុនពេលការចូលមកដល់របស់កងទ័ពវៀតណាម អ្នកទោសនៅមន្ទីរស-២១ ត្រូវបានបាញ់សម្លាប់ចោលនៅនឹងកន្លែងតែម្តង ។ នៅចុងបញ្ចប់សៀវភៅកំណត់ហេតុរបស់ខ្លួន ប៉ុន បានស្នើថា «តើចាំបាច់គួរបំបែកមនុស្សផ្សេងៗពីគ្នា តើគួរធ្វើទារុណកម្មពិសេស ប្រើអ្នកសួរចម្លើយពិសេស ឬប្រើវិធីផ្សេងទេ?» ។ ប្រាំខែមុននេះ អ្នកនៅពីលើ ប៉ុន បានចោទសួរសំណួរដូចគ្នានេះនៅក្នុងសៀវភៅរបស់ខ្លួន ដោយឲ្យយោបល់ថា អ្នកសួរចម្លើយត្រូវតែ «មានបទពិសោធន៍» វាយដំត្រូវធ្វើឡើងទន្ទឹមនឹង «កិច្ចការ» ផ្សេងទៀត ហើយថាសុខភាពរបស់អ្នកទោសគួរតែគិតដែរ ។ ចាន់ បានបញ្ចប់កំណត់ហេតុរបស់ខ្លួនដោយស្នើថា «តើអ្នកសួរចម្លើយត្រូវវាយ (អ្នកទោស) នឹងដៃផ្ទាល់ឬ? ចម្លើយរបស់ ចាន់ គឺ «បើធ្វើអ៊ីចឹងមែន ធ្វើតែតិចតួចទៅបានហើយ» ។[៤០]

ទោះបីជាការកែទម្រង់គំនិតនិងគំនិតរបៀបចិន-វៀតណាមទៅលើបញ្ហាយុត្តិធម៌មានលក្ខណៈដូចគ្នាជាមួយនឹងវប្បធម៌កម្ពុជាមុនសម័យបដិវត្តន៍ ឬមុនរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ប៉ុន្តែវាហាក់ដូចជាថា ការប្រព្រឹត្តិគ្មានមេត្តាដែលធ្វើឡើងនៅមន្ទីរស-២១ គឺបានចូលមកក្នុងប្រទេសតាមរយៈមន្ត្រីចិនម្នាក់ដែលធ្លាប់បានសង្កេតការណ៍ក្នុងតុលាការនៅទីក្រុងមូស្គូដែលធ្វើគ្រាន់តែល្អមើលនាទសវត្សរ៍ឆ្នាំ១៩៣០ ពោលគឺមិនមែនមកតាមរយៈវៀតណាមឬមកពីសូវៀតដោយផ្ទាល់នោះទេ ។

មន្ត្រីម្នាក់នេះមានឈ្មោះថា កាង សេង (១៨៩៨-១៩៧៥) ដែលជាអ្នករៀបចំនិងដឹកនាំដោយផ្ទាល់នូវយុទ្ធនាការអប់រំកសាងខ្លួននៅតំបន់ យ៉ាន អាន ក្នុងឆ្នាំ១៩៤២ និងឆ្នាំ១៩៤៣ និងការបោសសម្អាតទូទាំងប្រទេសនៅទសវត្សរ៍ឆ្នាំ១៩៥០ ។ កាង សេង គឺជាមេប៉ូលិសសម្ងាត់របស់ ម៉ៅ សេទុង ។ ក្រោយពីក្លាយជាមេសន្តិសុខ និងកិច្ចការស៊ើបអង្កេតរបស់បក្សកុម្មុយនិស្តចិននៅក្នុងតំបន់គ្រប់គ្រងដោយបក្ស កុកម៉ីងតាំង នៅឆ្នាំ១៩៣១ កាង សេង បានទៅរស់នៅប្រទេសសូវៀតរាប់ឆ្នាំ ។ នៅប្រទេសសូវៀត កាង សេង បានសិក្សាពីបញ្ហាសន្តិសុខ និង ដំណើរការសួរចម្លើយរបស់សូវៀត ហើយព្រមទាំងបានឃើញការចាប់ផ្តើមវិសុទ្ធកម្មនៅទីនោះទៀតផង ។ ដោយប្រើនូវការទាក់ទងជាមួយសូវៀត កាង ខ្លួនឯងបានបញ្ជាក់ថា សមាជិកបក្សកុម្មុយនិស្តចិនដែលគេបង្ខំឲ្យចាកចោលស្រុកមួយចំនួនត្រូវបានបោសសម្អាត ។ នៅ

ពេល កាង សេង វិលត្រឡប់មកស្រុកវិញនៅឆ្នាំ១៩៣៧ បទពិសោធន៍របស់ខ្លួនធ្វើឲ្យប្រធាន ម៉ៅ ពេញចិត្តពេញថ្លើមយ៉ាងខ្លាំង ហើយប្រហែលក្លាយជាអ្នកនាំចូលក្នុងប្រទេសចិននូវបច្ចេកទេសបោសសម្អាតតាមរបៀបសូវៀតទៀតផង ។ នៅក្នុងអំឡុងសង្គ្រាមលោកលើកទីII កាង សេង ជាអ្នកកាន់កាប់ខាងសន្តិបាល ។ កាង សេង ពេលនោះត្រូវគេហៅថា «កាំភ្លើងខ្លីរបស់ ម៉ៅ» ហើយនៅក្នុងវិសុទ្ធកម្ម «ការកែតម្រង់» និង «ការជួយសង្គ្រោះ» នៅឆ្នាំ១៩៤២-១៩៤៣ ដែល កាង សេង មើលការខុសត្រូវដោយផ្ទាល់ គឺមានលក្ខណៈឃោរឃៅនិងហ្មត់ចត់ណាស់ ។ ក្រោយពីយុទ្ធនាការទាំងនេះត្រូវបានបញ្ចប់សព្វគ្រប់ហើយ កាង សេង និយាយថា មនុស្សតិចជាង១០ភាគរយដែល «បានឆ្លើយសារភាព» គឺពិតជាគិញនិងខ្លាំង ។ ស្ថិតក្នុងពាក់កណ្តាលវ័យចូលនិវត្តន៍ក្នុងទសវត្សរ៍ឆ្នាំ១៩៦០ «កាង សេង ដែលគួរឲ្យគោរព» បានក្លាយជាមេមនោគមវិជ្ជានៃបដិវត្តវប្បធម៌ដែលមានសម្ព័ន្ធភាពជិតស្និទ្ធជាមួយនឹងក្រុម ដែលគេហៅថា «បនបួននាក់» ហើយបានចូលប្រឡូកក្នុងយុទ្ធនាការវិសុទ្ធកម្មទូទាំងបក្សនៅឆ្នាំ១៩៦៧ និង១៩៦៨ ។ នៅពេល កាង សេង ទទួលមរណភាពនាឆ្នាំ១៩៧៥ មានការធ្វើបុណ្យយ៉ាងអធិកអធមជាផ្លូវរដ្ឋជូនដល់វិញ្ញាណក្ខន្ធរបស់គាត់ ។ ប្រាំឆ្នាំក្រោយមក នៅពេលបនបួននាក់ដួលរលំទៅ កាង សេង ត្រូវបានបណ្តេញចេញពីបក្សកុម្មុយនិស្តទាំងព្រលឹងជាខ្មោច ។[៤១]

អតីតមន្ត្រីចិនម្នាក់ដែលមានការពាក់ព័ន្ធក្នុងកិច្ចការកម្ពុជាចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៦០ បាននិយាយថា កាង សេង បានជួយយកអាសា ប៉ុល ពត នៅពេល ប៉ុល ពត ធ្វើទស្សនកិច្ចនៅទីក្រុងប៉េកាំងក្នុងឆ្នាំ១៩៦៦ ។ កាលនោះ កាង សេង ទទួលបន្ទុកខាងទំនាក់ទំនងជាមួយបក្សកុម្មុយនិស្តបរទេស ហើយឥឡូវនេះ ត្រូវគេស្គាល់ថាជាអ្នកគាំទ្រអ្នកដែលយល់ស្របចំពោះការវាយប្រហាររបស់ចិនទៅលើ «លទ្ធិសេរីនិយម»របស់សូវៀត ។ នៅក្នុងអំឡុងពេលទស្សនកិច្ចរបស់ សាឡុត ស, កាង សេង គឺជាសមាជិកដ៏សំខាន់របស់គណៈកម្មាធិការត្រួតពិនិត្យករណីយុត្តិសាស្ត្រ (ដែលក្រោយមកដូរឈ្មោះមកជា «ក្រុមមជ្ឈិមត្រួតពិនិត្យករណីយុត្តិសាស្ត្រ») ដែលជាអង្គភាពសម្ងាត់មួយបង្កើតឡើងនៅខែឧសភា ឆ្នាំ១៩៦៦ ដើម្បី «គ្រប់គ្រងវិសុទ្ធកម្មទៅលើអ្នកសេរីប្រឆាំងនឹងបដិវត្តន៍» ។ ដូច្នេះទោះជាយើងមិនដឹងថា តើកាលនោះ ឬក្រោយមក សាឡុត ស បានដឹងអំពីប្រព័ន្ធអង្គភាពនេះដែរឬយ៉ាងណាក៏ដោយ ប៉ុន្តែ ការណ៍នេះបានផ្តល់ជាគំរូដល់ស្ថាប័នមួយនៅមន្ទីរស-២១ ។

កាង សេង និង សាឡុត ស ប្រហែលពន្យល់គ្នាឲ្យដឹងទៅវិញទៅមកនៅក្នុងដំណើរទស្សនកិច្ចជាបន្តបន្ទាប់របស់កម្ពុជាទៅកាន់ប្រទេសចិនក្នុងឆ្នាំ១៩៧០ និង១៩៧១ ។ នៅពេល កាង សេង ទទួលមរណភាពនៅឆ្នាំ១៩៧៥ មន្ត្រីចិនរូបនោះបាននិយាយថា ប៉ុល ពត បានមកធ្វើទស្សនកិច្ចនៅស្ថានទូតចិនប្រចាំនៅទីក្រុងភ្នំពេញដើម្បីសម្តែងនូវការរំលែកទុក្ខផ្ទាល់ខ្លួន ។ ប្រសិនបើទំនាក់ទំនងរវាង ប៉ុល ពត និង កាង សេង ពិតជាមានមែននោះអាចជាហេតុផលគួរឲ្យជឿបានថា មន្ទីរស-២១ មានដើមកំណើតមកពីដំណើរការសន្តិសុខ និង មនោគមវិជ្ជានៅក្នុងទសវត្សរ៍ឆ្នាំ១៩៣០ និងវិសុទ្ធកម្មតាមរបៀបសូវៀត-ចិន ដែលធ្វើឡើងក្រោយមកទៀត ។[៤២]

## ធារុណកម្មនៅមន្ទីរស-២១

ដោយចាំទុកក្នុងចិត្តនូវអ្វីៗដែលកើតឡើងពីមុន និងឃុតឆាកពិស្តារទាំងប៉ុន្មានខាងដើមនេះ យើងអាចវិលត្រឡប់មកពិនិត្យមើលការអនុវត្តធារុណកម្មជាក់ស្តែងនៅមន្ទីរស-២១ និងហេតុផលរបស់អ្នកធ្វើការនៅទីនោះក្នុងការធ្វើធារុណកម្ម ។ សព្វថ្ងៃនេះគ្មាននៅសល់ឯកសារណាមួយដែលនិយាយលម្អិតអំពីការធ្វើធារុណកម្មនៅក្នុងគុកនេះឡើយ ។ ដើម្បីសិក្សាអំពីបាតុភូតនេះ យើងត្រូវផ្អែកទៅលើកំណត់ហេតុវិពុកដែលនៅសល់រតាត់រតាយរបស់អ្នកសួរចម្លើយ និងថ្នាក់លើរបស់ខ្លួនបានសរសេរឆ្លងឆ្លើយគ្នា ។ កំណត់ហេតុនេះត្រូវបានបន្ថែមដោយចម្លើយសារភាពរបស់អ្នកសួរចម្លើយផ្ទាល់ ចំណារនៅតាមជាយទំព័រចម្លើយសារភាព អត្ថបទសិក្សាចំនួនបីច្បាប់ដែលសរសេរឡើងដោយកម្មាភិបាលធ្វើការនៅមន្ទីរស-២១ និងសៀវភៅកំណត់ហេតុរបស់អ្នកសួរចម្លើយដែលចងក្រងឡើងនៅឆ្នាំ១៩៧៦ ។

ឯកសារទាំងនេះមិនបានបង្ហាញពីធារុណកម្មគ្រប់បែបគ្រប់យ៉ាងដែលធ្វើឡើងនៅមន្ទីរស-២១ទេ ។ ឯកសារនេះក៏មិនបានបញ្ជាក់ឲ្យបានច្បាស់ថា ធារុណកម្មត្រូវធ្វើឡើងញឹកញាប់ដល់កម្រិតណា ការបង្កើតនយោបាយប៉ះពាល់ដល់ការធ្វើធារុណកម្មយ៉ាងដូចម្តេច ហើយរយៈពេលនិងធារុណកម្មដែលត្រូវធ្វើឡើងនោះក៏មិនបញ្ជាក់ច្បាស់ដែរ ។ ប៉ុន្តែវាហាក់ដូចជាថា ការគ្រប់គ្រងការធ្វើធារុណកម្មមិនខុសពីរឿងផ្សេងទៀតនៅក្នុងគុកទេ គឺបានក្លាយទៅជារឿងធម្មតាទៅហើយនៅពេលដែល «ប្រព័ន្ធ» នេះចេះតែវិវឌ្ឍន៍ទៅមុខ នៅពេលអ្នកសួរចម្លើយលែងមានការស្ទាក់ស្ទើរ និងនៅពេលដែលវិធីធ្វើធារុណកម្មក្លាយទៅជាចំណង់ចំណូលចិត្តរបស់អ្នកធ្វើការនៅទីនោះ ។

នៅពាក់កណ្តាលឆ្នាំ១៩៧៧ ដូចយើងបានឃើញស្រាប់ហើយ មន្ទីរស-២១ មានដំណើរការទៅយ៉ាងរលូនៗ ដោយមានបទពិសោធន៍សាកល្បងមួយឆ្នាំមកហើយ អ្នកសួរចម្លើយកាន់តែស៊ាំទាំងការ «ធ្វើនយោបាយ» និងធ្វើធារុណកម្ម ។ អ្នកទាំងអស់នេះមានគំនិតកាន់តែច្បាស់ថែមទៀតថា ការធ្វើឯកសារប្រភេទណាដែលធ្វើឲ្យថ្នាក់លើរបស់ខ្លួនពេញចិត្ត តើធារុណកម្មបែបណា «ដំណើរការល្អ» ហើយថា តើអ្នកទោសនិងចម្លើយសារភាពរបស់ខ្លួនត្រូវ «ដាក់ឲ្យដំណើរការ» យ៉ាងដូចម្តេចឲ្យបានលឿនៗ ។ ពេលដែលពេលវេលាចេះតែរំកិលទៅមុខ ការសួរចម្លើយកាន់តែធ្វើលឿន ហើយចម្លើយសារភាពក៏កាន់តែខ្លីៗ ចម្លើយសារភាពច្រើនតែត្រូវបានថតជាខ្សែអាត់ ហើយយកមកវាយអង្គុលីលេខៗ សង្ខេបលម្អិតរួចហើយយកមកភ្ជាប់ជាមួយចម្លើយសារភាពអង្គភាពយោធា តំបន់ភូមិសាស្ត្រ និង «ខ្សែក្បត់» ។ ប៉ុន្តែមិនអាចនិយាយថា តើការិយាធិបតេយ្យនៃដំណើរការទាំងមូលនៅមន្ទីរស-២១ ប៉ះពាល់ដល់កម្រិតនិងចំនួនធារុណកម្មយ៉ាងដូចម្តេចទេ ទោះបីជាយើងដឹងថា ធារុណកម្មនិងការវាយដំចេះតែបន្តទៅយ៉ាងលឿននៅឆ្នាំ១៩៧៧ក៏ដោយ ។ អ្នកថតរូបម្នាក់ឈ្មោះ ញ៉ែម អេន នៅចាំបានថា ធ្លាប់ឮ «សម្រែកដង្ហោយហៅជាច្រើនលើក ជាពិសេសនៅពេលយប់ជាពេលដែលទីក្រុងភ្នំពេញស្ងាត់ជ្រងំគ្មានឮសំឡេងអ្វីសោះ ។ សម្រែកនេះឮខ្លាំងណាស់ សូម្បីតែដីប្រហែលមួយគីឡូម៉ែត្រក៏ឮដល់ដែរ» ។ ស្រដៀងគ្នានេះដែរ អតីតឆ្មាំគុកឈ្មោះ ខៀវ ល បាននិយាយទៅកាន់ អាឡិចហ្សាន់ឌ័រ ហ៊ិនតុន ថា «ខ្ញុំឮតែសម្រែកមិនឮនិយាយអ្វីទេ ជួនកាលទៅស្ងាត់ឈឹងតែម្តង» ។

គក ស្រស់ ក្នុងកិច្ចសម្ភាសន៍ជាមួយលោក ឌូក្លាស់ នីវិន បាននិយាយថា «រាល់ពេលចេញទៅធ្វើការ» ខ្លួនបានព្រួមនុស្សស្រែកដោយការសួរចម្លើយ និង «ពេលដែលអ្នកទោសមិនធ្វើតាមឆ្នាំ» ។[៤៣]

សម្រែកមនុស្សដែលកំពុងទទួលរងទារុណកម្មគឺបន្ទឺឡើងនៅពេលមានបញ្ហាខាងរដ្ឋបាលដែលជាការសម្ងាត់ក្នុងការប្រតិបត្តិការក្នុងគុក ។ «បញ្ហារអប់រំនយោបាយ» ទុយ បានសរសេរនៅក្នុងសៀវភៅកំណត់ហេតុរបស់ខ្លួនថា «ជួនកាលសំឡេងអ្នកទោសដែលកំពុងតែត្រូវវាយដំអាចលេចព្រួដល់ខាងក្រៅ(គុក) ទៀតផង» ។[៤៤]

ភាពតឹងតែងរបស់អ្នកសួរចម្លើយភាគច្រើនមិនសម្រេចបានអ្វីឡើយ ។ ក្នុងករណីជាច្រើន ទាំងអ្នកទោសនិងអ្នកសួរចម្លើយគឺមិនបានដឹងថា តើមានការប្រព្រឹត្តិអ្វីខុស ឬការឆ្លើយសារភាពមិនច្បាស់និងពិបាកយល់មានន័យយ៉ាងដូចម្តេចទេ ។ លក្ខណៈពិសេសនៃការសួរចម្លើយ ភាគច្រើនគឺសួរកំបុតកំបុយពីមូលហេតុដែលគេចាប់ខ្លួនមក និងវាយដំអ្នកដែលឆ្លើយថាមិនដឹងមូលហេតុ ។ ដោយខ្វះពត៌មានខ្លួនឯងផ្ទាល់ អ្នកសួរចម្លើយបាននាំគមករកការធ្វើទារុណកម្ម ហើយដូចដែលលោក អារីស្តូតថល បានកត់សម្គាល់ដែរថា កាលពីជាងពីរពាន់ឆ្នាំមុន ចម្លើយសារភាពដែលចេញមកពីការធ្វើទារុណកម្មមានការពិតតិចណាស់ ។[៤៥]

អ្នកសួរចម្លើយតែងតែបាត់បង់នូវការគ្រប់គ្រងខ្លួនឯង ។ ចំណង់ច្បាស់ជាមានលើសលប់ នៅពេលក្មេងៗបីនាក់ប្រដាប់ដោយដំបងធំៗ ខ្សែតី ខ្សែភ្លើងសម្រាប់ឆក់ និងប្រភេទសម្ភារផ្សេងៗទៀតត្រូវបានចាក់សោដាក់ក្នុងបន្ទប់មួយដែលមានអ្នកទោសក្បត់ជាប់ខ្នោះដៃ និងគ្មានអ្នកណាជួយ ។ ដូចលោក វ៉ូលហ្វែង សហ្វស្គី បានលើកឡើងដូច្នេះដែរថា «ប្រសិនបើអំពើឃោរឃៅត្រូវបានចាត់ទុកថាជារឿងធម្មតានៅក្នុងសហករណ៍ នោះវានឹងក្លាយទៅជាកាតព្វកិច្ចទៅហើយ» ។[៤៦] ម៉ា ម៉េងឃាង (ហៅរិន) អតីតអ្នកសួរចម្លើយបានសារភាពថា អំពើឃោរឃៅគឺជារឿងចុងក្រោយបំផុតនិងមានការលើកទឹកចិត្តផង ។ រិន និយាយនៅក្នុងកិច្ចសន្ទនាធម្មតាជាមួយអ្នកធ្វើការជាមួយខ្លួនថា÷

> ពីរសប្តាហ៍ក្រោយមក...ម្នាក់ឈ្មោះ នឿន ម្នាក់ឈ្មោះ ស្រេង និងម្នាក់ទៀតខ្ញុំផ្ទាល់កំពុងតែឈប់សម្រាកនិយាយគ្នាលេងនៅកន្លែងដាំបាយជាន់លើគេបង្អស់ (នៅមន្ទីរស-២១) ។ នៅពេលនោះ នឿន និយាយថា «នៅក្នុងក្រុម (សួរចម្លើយ) ទី១ ព្រួតែពីរៃទៅកន្លែងណាក៏ព្រួដែរ ហើយសួរថា (អ្នកទោស) តើឯងជា (សេ.អ៊ី.អា) មែនទេ...សួរសំណួរបែបនេះ តើមានអ្នកណាឆ្លើយរួច បើគេមិនស្គាល់សូម្បីតែ«សេ»ហ្នឹងតំណាងអ្វីផងនោះ ។ មិនដែលព្រួក្រុម១នេះ «ធ្វើនយោបាយ» ម្តងណាសោះ អ្វីដែលគេគិតនោះ គឺគិតតែពីរៃ ហើយនៅពេលរៃខ្លាំង វាចេះតែឆ្លើយបាតណាប៉ាតណីចោទអ្នកនេះ ចោទអ្នកនោះ ។ នេះជាចំណុចខ្សោយរបស់ក្រុម១ ។ អាម្នាក់ឈ្មោះ សែង និយាយថា នៅជិតវាក៏ព្រួអ៊ីចឹងដែរព្រួតែ «ឌីបៗ ដាំងៗ ខ្ទប់ៗ ហើយអូយ!! សេឬមិនមែនសេ?» នៅពេលវាមិនស្គាល់មួយណាជា«សេ» មាន់ និងមួយណាជា«សេ» ទាផងនោះ ។[៤៧]

ដូចយើងឃើញស្រាប់ហើយ តាមរយៈអ្វីដែលលើកមកនិយាយនេះ គុណភាពរវាងទារុណកម្មនិង

នយោបាយភាគច្រើនមិនអាចសម្រេចទៅបានទេ ជាពិសេសពេលដែលអ្នកសួរចម្លើយមានការហ៊ឹកហាត់បានតិចពេកទាំងផ្នែកនយោបាយនិងការសួរចម្លើយ ធ្វើតាមរដ្ឋបាលពេក មានកំហឹងកញ្ច្រោលពេក និងមានបទពិសោធន៍ប្រយុទ្ធច្រើនពេក ។ រំឭកម្តងទៀតដល់សម្តីរបស់លោក កូសវីត ដែលថា «ធ្វើនយោបាយ» នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានន័យថា ធ្វើសង្គ្រាមតាមគ្រប់មធ្យោបាយ ។ ដូចគ្នានឹងឆ្នាំក្រហមនៅប្រទេសចិនគ្រប់គ្រងដោយប្រធាន ម៉ៅ អ៊ីចឹងដែរ អ្នកសួរចម្លើយនៅមន្ទីរស-២១ ត្រូវបានបង្ហាត់បង្រៀនថា «ខ្លាំង» របស់បក្សត្រូវតែ «វាយសម្រុក» «កម្ទេចចោល» ។ មិនតែប៉ុណ្ណោះនៅបានបង្រៀនថាពួកគេជា «ដង្ហើម» របស់របបនេះទៀតផង ។ ក្រោយពីមានការហ៊ឹកហាត់ដ៏ឆ្អិនឆ្អៅស្ដីពីពិភពសម្ងាត់ និងប្រហែលជាអំពីហេតុផលនៃមន្ទីរស-២១រួចមក អ្នកធ្វើការនៅមន្ទីរស-២១ ក៏ចាប់ផ្ដើម «បោសសម្អាតខ្លាំង» ដោយដៃទទេនិងអាវុធផ្សេងៗគ្មានញញើតដៃ ។[៤៨]

អ្នកទោសកម្រមាននិយាយអំពីទារុណកម្មណាស់ ហើយសម្ដីរបស់អ្នកទោសមិនសូវជាមានការស្មុគស្មាញប៉ុន្មានដែរ ។ ឧទាហរណ៍ជាក់ស្ដែងមួយ នៅពេល ណៃ សារ៉ាន់ សរសេរនៅក្នុងចម្លើយសារភាពរបស់ខ្លួនថា «ចម្លើយរបស់ខ្ញុំនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧៦ ត្រូវបានផ្ដល់ក្រោយពីគេធ្វើទារុណកម្មមកលើខ្ញុំយ៉ាងខ្លាំង» ឃ្លានេះត្រូវបាន ឌុច គូសខ្វែងចោល ។ ឌុច ក៏បានផ្ញើឯកសារមួយមកវិញដែលមានចំណារថា «ឯងគ្មានសិទ្ធិវាយការណ៍រឿងនេះមកអង្គការទេ» ។[៤៩]

នៅក្នុងចម្លើយសារភាពរបស់ខ្លួន ស៊ុន ទី បានសរសេរកំណត់សម្គាល់ដោយឡែកដល់អង្គការដែលនៅតែសង្កត់ថាគាត់មានកំហុស ហើយបាននិយាយថា ខ្លួនត្រូវបានធ្វើទារុណកម្ម៖

> មុនដំបូងខ្ញុំមិនព្រមឆ្លើយទេ ប៉ុន្តែក្រោយពីគេវាយខ្ញុំនឹងដំបងធំមួយមក ខ្ញុំក៏ប្រឌិតចម្លើយតែម្ដងទៅ ។ ខ្ញុំសូមឲ្យបក្សកុំចាប់មនុស្សដែលខ្ញុំរៀបរាប់ឈ្មោះនេះ ។ សមមិត្តយើងសុទ្ធតែមនុស្សល្អទេ ។ ខ្ញុំមិនមែនជា សេ.អ៊ី.អា ឬ ខ្មែរសេរីទេ ។

តាមរយៈសម្ដីដកស្រង់ពីឯកសាររបស់ ស៊ុន ទី ផ្ទាល់បញ្ជាក់ថា ពាក្យសម្ដីទាំងនេះមិនដែលលេចចេញទៅខាងក្រៅទេ ។[៥០]

គំរូទារុណកម្មមួយចំនួនដែលរៀបរាប់នៅក្នុងបណ្ណសារនេះ និងរៀបរាប់ដោយអ្នកដែលមានវាសនារួចផុតពីសេចក្ដីស្លាប់នៅទីនោះមានដូចខាងក្រោមនេះ៖

◆ វាយៈ

- ដោយដៃ
- ដោយដំបង
- ដោយមែកឈើ

- ដោយខ្សែភ្លើង
- អុចភ្លើងបារី
- ឆក់ខ្សែភ្លើង
- ឲ្យស៊ីលាមក
- ឲ្យផឹកទឹកនោម
- ឲ្យស៊ីទាំងបង្ខំ
- ព្យួរជើងឡើងលើដាក់ក្បាលចុះក្រោម
- ព្យួរដៃឡើងលើពេញមួយថ្ងៃ
- យកម្ជុលចាក់ចូលសាច់
- ឲ្យសំពះរូបឆ្កែ (ចាប់ពីឆ្នាំ១៩៧៨មក)
- ឲ្យសំពះជញ្ជាំង
- ឲ្យសំពះតុ
- ឲ្យសំពះកៅអី
- ចាប់ដកក្រចក
- ឆូតសាច់
- រុញផ្កាប់មុខ
- យកថង់ខ្ទប់ច្រមុះ
- ទារុណកម្មដោយទឹក
  - ជ្រមុជទឹក
  - ដាក់ទឹកឲ្យស្រក់លើក្បាលរយៈពេលយូរ ៗ

ប្រភេទទារុណកម្មទាំងនេះមិនបញ្ចូលទារុណកម្មដែលរៀបរាប់តាមរយៈផ្ទាំងគំនូររបស់ វ៉ាន់ ណាត ផងទេ ។ និយាយទៅកាន់អ្នកថតកុនមកពីអាល្លឺម៉ង់ខាងកើត វ៉ាន់ ណាត រំឭកឡើងវិញថាៈ

> នេះជាបន្ទប់ដែលខ្ញុំធ្វើការ ។ ជួនកាលខ្ញុំមើលតាមប្រហោងបង្អួចប្រេះឃើញហេតុការណ៍ដែលកំពុងកើតឡើងនៅខាងក្រៅ ។ ខ្ញុំឃើញគេចាប់អ្នកទោសជ្រមុជទឹក ។ អ្នកផ្សេងទៀតត្រូវបានចាប់យកទៅសួរចម្លើយដោយគ្មានសម្លៀកបំពាក់ជាប់ខ្លួនឡើយ ។ អ្វីៗដែលខ្ញុំលួចមើល ខ្ញុំព្យាយាមកត់ទុកហើយគូរចេញជារូបភាពទាំងនេះ ។[៥១]

ក្នុងចំណោមអ្នកសួរចម្លើយទាំងម្ភៃមួយនាក់ដែលត្រូវបានកត់ទុកនៅក្នុងសៀវភៅទូរស័ព្ទនៅមន្ទីរ

ស-២១ មានដប់ប្រាំបីនាក់មានពាក់ព័ន្ធក្នុងការធ្វើទារុណកម្មអ្នកទោស ។ ពាក្យទាំងនេះមាននៅក្នុងចម្លើយសារភាពរបស់អ្នកទោសផ្ទាល់ ឬនៅក្នុងការប្រជុំស្វ័យទិតៀននានាដែលធ្វើឡើងសម្រាប់បុគ្គលិកគុក ។ ក្នុងចំណោមអ្នកសួរចម្លើយនៅមន្ទីរស-២១ ចំនួនម្ភៃបួននាក់ ដែលក្រោយមកត្រូវបានចាប់ខ្លួននោះ មានដប់ប្រាំបីនាក់បានសារភាពថាបានធ្វើទារុណកម្មលើអ្នកទោស ។ មានដប់មួយនាក់ថា បានវាយអ្នកទោសទាល់តែស្លាប់ហើយឆ្មាំគុកម្នាក់ក៏បាននិយាយដូច្នេះដែរ ។ មានចម្លើយមួយចំនួនក្នុងចម្លើយសារភាពទាំងអស់នេះបានឆ្លើយដាក់អ្នកផ្សេងទៀតដែលជាបុគ្គលិកនៅមន្ទីរស-២១ ប៉ុន្តែឯកសារទាំងអស់នេះមិនមាននៅសល់ទេ ។ បណ្ណសារនេះបញ្ជាក់ថា អ្នកសួរចម្លើយមួយចំនួនបានរៀបចំខ្លួនជាស្រេចក្នុងការធ្វើទារុណកម្ម ។ មានម្នាក់ឈ្មោះ បុត ហេង ដែលក្រោយមកត្រូវបានចាប់ខ្លួនដែរនោះ បានសារភាពថា បានរំលោភផ្លូវភេទជនរងគ្រោះ ហើយថាបានវាយអ្នកទោសទាល់តែស្លាប់ រួមទាំងម្នាក់ដែលទទួលរងរបួសធ្ងន់ធ្ងរក្រោយពីប៉ុនប៉ងធ្វើអត្តឃាតមិនបានសម្រេច ។[៥២]

ការរំលោភផ្លូវភេទទៅលើអ្នកទោសជាស្ត្រីប្រហែលជាកើតឡើងញឹកញាប់ណាស់ ប៉ុន្តែរឿងនេះកម្រមាននិយាយនៅក្នុងចម្លើយសារភាពរបស់បុគ្គលិកគុកណាស់ ។ អ្នកមើលការខុសត្រូវនៅក្នុងគុកច្បាស់ជាមិនយល់ព្រមឲ្យមានអំពើនេះកើតឡើងទេ ដូចជាសៀវភៅកំណត់ហេតុរបស់ ចាន់ បញ្ជាក់ស្រាប់ថា÷

នៅពេលសួរស្រីៗត្រូវតែមានមនុស្សពីរនាក់ ។ កុំផ្តេកគេ ហើយកុំចាប់សក់ឬបិចថ្ពាល់ឲ្យសោះ ។[៥៣]

អ្នកដែលមានវាសនានៅរស់ទាំងអស់បានរំឭកឡើងវិញនូវការវាយដំមកលើខ្លួន ។ អ្នកទោសនៅមន្ទីរស-២១ ម្នាក់ឈ្មោះ អ៊ីង ប៊ិច ដែលបានចាកផុតពីសេចក្តីស្លាប់បាននិយាយប្រាប់លោក ដេវីដ ហក ថា «ចំពោះរឿងវៃវិញ គឺប៉ះអី វាវៃហ្នឹងដូចជាមែកឈើ ដើមឫស្សី រំពាត់ខ្សែភ្លើងជាដើម» ។[៥៤]

ការឆក់ខ្សែភ្លើងត្រូវបានធ្វើឡើងជាទូទៅទៅហើយ រហូតដល់មានសេចក្តីណែនាំដែលមានចំណុចមួយដាក់ថា «កុំស្រែកនៅពេលឆក់ខ្សែភ្លើង» ។ សេចក្តីណែនាំនោះដាក់ថា ពិន័យសម្រាប់ការមិនធ្វើតាមអ្នកសួរចម្លើយគឺវៃដប់រំពាត់ ឬ «ឆក់ខ្សែភ្លើងប្រាំឆាច់» ។[៥៥] ការចងចាំរបស់ វ៉ាន់ ណាត ប្រហែលជាពិសេសណាស់មើលទៅ÷

អ្នកសួរ (ចម្លើយ) យកខ្សែភ្លើងមករុំខ្នោះដៃខ្ញុំ ហើយយកម្ជុលខ្ទាស់មកភ្ជាប់កន្ទុយខ្សែទៅនឹងខោ ។ វាក៏អង្គុយចុះវិញទៅ ។

តើឯងនៅចាំទេ? អ្នកណាជាអ្នកចូលរួមក្បត់(អង្គការ) ? ។ ខ្ញុំរកនឹកអ្វីមកនិយាយមិនចេញសោះ ។ វាក៏ភ្ជាប់ខ្សែភ្លើងជាមួយចរន្តភ្លើងមកឆក់ខ្ញុំ ។ ពេលនោះខ្ញុំសន្លប់បាត់ស្មារតី មិនដឹងជាគេឆក់ប៉ុន្មានដងទេ ។ ប៉ុន្តែនៅពេលដឹងខ្លួនឡើងវិញខ្ញុំឮសំឡេងពីចម្ងាយសួរល្បើយៗទៀតថា តើអ្នកណាជាខ្សែរបស់ឯង ។ ខ្ញុំមិនអាចនិយាយកើតឡើយសូម្បីតែពាក្យមួយម៉ាត់ក៏និយាយមិនចេញផង ។ វា

បានឆក់ខ្ញុំខ្លាំងណាស់ ទាល់តែខ្ញុំដួលទៅលើឥដ្ឋ ហើយអាវខ្ញុំទទឹកញើសជោក...មកដល់ថ្ងៃនេះ ខ្ញុំមិនដឹងទេថា ហេតុអ្វីបានជាគេចាប់ខ្ញុំទេ ។[៥៦]

ចំណាររបស់អ្នកសួរចម្លើយទៅលើចម្លើយសារភាពមួយចំនួនបង្ហាញថា អ្នកទោសជាញឹកញយតែងតែទ្រុឌទ្រោមរាងកាយ និងឆ្លើយ «យ៉ាងពេញលេញ» នៅពេលខ្លួនត្រូវបានគំរាមកំហែងឆក់ខ្សែភ្លើង ។ អ្នកខ្លះទៀតក្រោយពីឆក់ខ្សែភ្លើងរួចទើបឆ្លើយ ។ អ្នកសួរចម្លើយបានសរសេរថា អ្នកទោសម្នាក់និយាយថា «វាមិនអាចស៊ូទ្រាំជាមួយនឹងការឆក់ខ្សែភ្លើងបានទៀតទេ ហើយថាថ្នើមប្រមាត់វារលាយអស់ហើយ» ។ អ្នកទោសផ្សេងទៀតត្រូវធ្វើទារុណកម្មរឹតតែតឹងតែងជាងនេះទៅទៀត ។ អ្នកសួរចម្លើយបានកត់សម្គាល់ថា អាម្នាក់នោះ «វាមិនឆ្លើយទេ ទាល់តែធ្វើទារុណកម្មខ្លាំងទើបវាឆ្លើយ» ហើយម្នាក់ទៀតនៅពេល «ធ្វើទារុណកម្មខ្លាំងទៅជាមិនព្រមឆ្លើយទៅវិញ» ។ អ្នកសួរចម្លើយរបស់ លី ផេន ដែលជាជនបដិវត្តជើងចាស់កត់សម្គាល់ថា«ក្រាញមិនព្រមនិយាយពីសកម្មភាពរបស់វា ដូច្នេះខ្ញុំក៏ប្រើទារុណកម្ម» ។ «នៅពេលវាដឹងខ្លួនឡើង គឺគិតតែពីកួត» ។ អ្នកសួរចម្លើយហៅស្ត្រីម្នាក់ថា«ខិលខូចណាស់» ។ «ដោយមិនអាចស៊ូទ្រាំនឹងការធ្វើទារុណកម្ម វាក៏ស្រាតសារុងចេញធ្វើពុតជាឈឺ» ។ ឌុច ពុំមានត្រាប្រណីទេចំពោះអ្នកណាដែលចចេសមិនព្រមសម្របខ្លួន ។ មានពេលមួយ ឌុច បានប្រាប់ទៅអ្នកសួរចម្លើយម្នាក់ថា «វៃ (អ្នកទោស) រហូតទាល់តែវាឆ្លើយអស់ វៃវាឲ្យនិយាយតាន់តែស៊ីជម្រៅ» ។[៥៧]

ទារុណកម្មម្យ៉ាងទៀតដែលត្រូវបានធ្វើជាញឹកញាប់នៅមន្ទីរស-២១ គឺការ «ថ្វាយបង្គំ» ។

វ៉ាន់ ណាត រំឭកឡើងវិញអំពីការគូររូបផ្ទាំងដែលមានក្បាលជា ហូ ជីមិញ បិទជាប់ទៅនឹងជញ្ជាំងសួរចម្លើយនិងការនិយាយស្តីរបស់អ្នកសួរចម្លើយនៅទីនោះ ។[៥៨] ដូចដែល ចន ម៉ាសស្តុន លើកឡើងដូច្នេះដែរថា ការថ្វាយបង្គំរបៀបនេះគឺជា «ការបញ្ជាក់អំពីឋានៈ» ខ្លាំងជាងការប្រតិបត្តិក្នុងការសំពះរបស់ប្រជាជនកម្ពុជាទូទៅទៅទៀត ។ ពាក្យទាំងពីរនេះត្រូវបានប្រើសម្រាប់បញ្ជាក់ការធ្វើទារុណកម្មពិសេសនេះ ។ នៅក្នុងសង្គមកម្ពុជាមុនសម័យបដិវត្តន៍ របៀបរបបថ្វាយបង្គំដែលលើកដៃពីរប្រណម្យឡើងទៅលើក្បាល និងជួនកាលក្រាបផ្ទាល់នឹងដីគឺប្រើសម្រាប់ក្រាបថ្វាយបង្គំសម្តែងការគោរពចំពោះព្រះមហាក្សត្រ ឬព្រះសង្ឃ ឬសម្រាប់គោរពព្រះពុទ្ធបដិមាតែប៉ុណ្ណោះ ។[៥៩] នៅមន្ទីរស-២១ កាយវិការនេះប្រហែលជាបង្កឲ្យមានការឈឺចាប់លូនក្រាបលើដីផ្ទាល់ ហើយប្រហែលជាទាក់ទងនឹង «យន្តហោះ» ដែលគេបង្ខំអ្នកទោសឲ្យធ្វើតាមនៅក្នុងបដិវត្តវប្បធម៌ចិន ។ ចំណាររបស់អ្នកសួរចម្លើយម្នាក់និយាយថា បានឲ្យអ្នកទោសសំពះអស់ពេលកន្លះម៉ោង ហើយមានមួយទៀតនិយាយថា ឲ្យអ្នកទោសថ្វាយបង្គំ «ប្រាំដង» ។ នៅក្នុងករណីខ្លះ «ការថ្វាយបង្គំ» ជាការគួរឲ្យឈឺចាប់គ្រប់គ្រាន់ទៅហើយដែលធ្វើឡើងសម្រាប់ចម្រាញ់យកចម្លើយសារភាពឲ្យបានពេញលេញ ។[៦០]

នៅឆ្នាំ១៩៧៨ រូបភាពតំណាងអាមេរិកាំងត្រូវបានច្នៃចូលក្នុងលក្ខណៈដូចគ្នាទៅនឹងរូបរបស់ ហូ ជីមិញ ដែរ ។ ចំណាររបស់អ្នកសួរចម្លើយម្នាក់នៅលើចម្លើយសារភាពរបស់ ស្វាង គុំ បញ្ជាក់ថា រូបទីពីរជារូបរបស់ លីនដុន ចនសុន÷

ដំបូងនៅពេលដែលយើងចូលទៅដល់កន្លែងសួរចម្លើយ ក្រោយពីខ្ញុំសួរស្រីនោះអំពីប្រវត្តិនិងសួរថា ហេតុអ្វីបានជាអង្គការចាប់ខ្លួន វាក៏ស្រែកយំហ៊ូដោយនិយាយថា ប្ដីរបស់វាជាជនក្បត់ ហើយថា វាមិនបានក្បត់ទេ ។ ខ្ញុំក៏ដាក់ពិន័យដោយឲ្យវាថ្វាយបង្គំរូបផ្ដែដែលមានក្បាល ហូ ជីមិញ និងក្បាលរបស់ចនសុន ប៉ុន្តែវាមិនព្រមសំពះឡើយ ។ ខ្ញុំក៏វ៉ៃវាដែលមិនព្រមនិយាយរឿងនិងមិនគោរពវិន័យរបស់សន្តិបាល ។ វាអស់សង្ឃឹម ហើយក៏ចាប់ផ្ដើមនិយាយអំពីខ្សែសម្ងាត់ ។[៦១]

ខាងក្រោមនេះជាអត្ថបទទាំងស្រុងដែលជាចំណារពីរនិយាយអំពី «ការថ្វាយបង្គំ» រូបគំនូរ ។ អត្ថបទទាំងពីរនេះ មួយជារបស់ ចាន់ និងមួយទៀតជារបស់ ទុយ-ប៉ុន ដែលសរសេរនៅក្នុងការប្រជុំជីវភាពនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៨ ។ កំណត់ហេតុទាំងពីរនេះមានភាពខុសគ្នាបន្តិចបន្តួចហើយមានលក្ខណៈគួរឲ្យកត់សម្គាល់ទៀតផង ។

**អត្ថបទរបស់ ទុយ-ប៉ុន**

យើងសាកល្បងឲ្យវាថ្វាយបង្គំផ្ដែទាំងពីរ ។ ផ្ដែនេះគឺមានន័យនយោបាយ ។ ផ្ដែទីមួយគឺជាអាមេរិក ។ ផ្ដែទីពីរគឺវៀតណាម ។ នៅពេលវាគោរព វាទទួលស្គាល់ថា វាគាំទ្រអាពីរនេះ ។ តាមទស្សនៈសតិអារម្មណ៍ យើងទុក (អ្នកទោស) មួយដុំ ហើយមិនឲ្យវានៅឡូកឡំជាមួយយើងទេ ។ តាមទស្សនៈអង្គការ យើងបង្ខំឲ្យវាគោរពសន្តិបាល ។ កន្លងមក យើងបានសម្រេចលទ្ធផលល្អណាស់ ។

នៅចុងបញ្ចប់ ទុយ-ប៉ុន បានដកស្រង់សម្ដីរបស់អ្នកឡើងមានយោបល់នៅវគ្គសិក្សានោះ ដែលនិយាយថា «អ្នកមិនត្រូវវាយអ្នកទោសនៅពេលគេខឹងទេ ។ នៅពេលខឹង វាយមិនឈឺទេ» ។ អ្នកសួរចម្លើយក៏ត្រូវបានជំរុញឲ្យទប់កំហឹងដូចដែលសៀវភៅរបស់អ្នកសួរចម្លើយម្នាក់បានកត់សម្គាល់ថា «នៅពេលខ្លះយើងធ្វើទាំងកំរោល ហើយការណ៍នេះធ្វើឲ្យយើងបាត់បង់ម្ចាស់ការ ។ វាធ្វើឲ្យ (អ្នកទោស) មានសតិអារម្មណ៍មិនពេញលេញ និយាយវិលចុះវិលឡើងតែពីរឿងរស់និងស្លាប់» ។ អ្វីដែលត្រឹមត្រូវនិងអ្វីដែលមិនត្រឹមត្រូវក្នុងការចាត់ការរឿងអាយុជីវិតនេះមិនត្រូវបានលើកមកនិយាយច្បាស់ទេ ។[៦២]

**អត្ថបទរបស់ ចាន់**

យើងបង្ខំវាឲ្យគោរពរូបផ្ដែទាំងពីរក្បាល ។ នេះគឺជាវិធីសួរចម្លើយមួយ ។ រូបផ្ដែនេះមានសារសំខាន់ផ្នែកនយោបាយ ។ ផ្ដែទីមួយ ជាចក្រពត្តិអាមេរិក ។ ផ្ដែទីពីរ ជាខ្មាំងលេបទឹកដី ។ យើងឲ្យគោរពដើម្បីក្ដាប់វាឲ្យបានណែន ពីព្រោះនៅពេលចាប់ខ្លួនវាមកមាន៩០ភាគរយនៅតែគិតថា ខ្លួនឯងជាជនបដិវត្តនៅឡើយ ។ នៅក្រោយពេលវាគោរពរូបផ្ដែនោះហើយគេនឹងដឹងខ្លួនថា គេជាជនក្បត់មិនខាន ។ តាមជំហរសតិអារម្មណ៍យើងបដិសេធសតិអារម្មណ៍វា ។ តាមគោលជំហរអង្គការៈ តើគេ

គោរពសន្តិបាលដែរឬទេ? វិធីៈ ត្រូវនិយាយអ្វីដែលអាចធ្វើឲ្យវាផ្លាស់ប្តូរគំនិតនិងគោរពតាម«បង» ។ បើវាតវ៉ាកុំអាលវាយវា ចាំមួយនាទីសិនទើបឲ្យវានិយាយថា វាបានធ្វើការឲ្យវៀតណាមតាំងពីរនេះចាប់ពីឆ្នាំណា? នៅអង្គការណា? ប្រយ័ត្នៈ វាអាចនិយាយថា សេ.អ៊ី.អា គ្មានកម្លាំងពិសពុល ។

«ការថ្វាយបន្តុំ»តាមវិធីនេះបាននាំឲ្យអ្នកទោសស្គាល់ពីទំនាក់ទំនងអំណាចរបស់មន្ទីរស-២១ ។ វាបានបង្ហាញអំពីភាពផុយស្រួយនៅក្នុងការគិតរបស់ខ្មែរក្រហមរវាង «អង្គហេតុ» ដែលត្រូវបានលាក់កំបាំងមានលក្ខណៈទាបបំផុត លក្ខណៈបរទេស និងដែលមានលក្ខណៈក្បត់ជាមួយនឹង «ការពិត» លើសលប់របស់អង្គការដែលត្រូវបានលាក់កំបាំង ប៉ុន្តែអស្ចារ្យ ហើយម្យ៉ាងទៀតរវាងអំណាចទាំងស្រុងរបស់អ្នកសួរចម្លើយនិង «ជនមានកំហុស» ដែលគ្មានអំណាចទាល់តែសោះ ។ ការធ្វើទារុណកម្មប្រភេទនេះក៏បង្ហាញនូវវិន័យក្នុងការសួរចម្លើយដែលធ្វើតាមក្រោយនិងបន្តុំឲ្យអ្នកទោសហៅខ្លួនឯងថា ជនក្បត់ ។

វាហាក់ដូចជាថា អ្នកទោសប្រមាណជាកៅសិបភាគរយចាប់ផ្តើមទទួលនូវការសួរចម្លើយដោយហៅខ្លួនឯងយ៉ាងក្លាហានថាជា«ជនបដិវត្ត» ។ អ្នកសួរចម្លើយឆ្លើយថា បើជាជនបដិវត្តមែនហេតុអ្វីបានជាគេចាប់ខ្លួនមក? តើគេគាបដាក់លេខរៀង និងចាក់សោជនបដិវត្តចោលទៅរួចដែរឬ? «ការថ្វាយបន្តុំ» គឺជាអំពើមួយក្នុងចំណោមអំពើបន្ទាបតម្លៃមនុស្សផ្សេងៗទៀត ដែលធ្វើឡើងដើម្បីបន្តុំឲ្យអ្នកទោសទទួលស្គាល់ខ្លួនឯងថាជាសត្វធាតុ ។ ពាក្យចៅហ្វាយនាយបរទេសថា «អញ» ត្រូវបានចាត់ទុកថាជាសត្វ ហើយមានតែសត្វទេដែលអាចគោរពសត្វគ្នាឯង ។ នៅពេលភក្តីភាពរបស់ចៅហ្វាយនាយជាថ្មី និងភក្តីភាពរបស់អ្នកទោសចំពោះចៅហ្វាយខ្លួនត្រូវបានបង្ហាញចេញមកច្បាស់ហើយនោះ អ្នកទោសត្រូវបានដកហូតអស់នូវភាពជាជនបដិវត្តនិងភាពជាមនុស្ស ហើយការសួរចម្លើយក៏ចាប់ផ្តើមដើម្បីជជីកសួររក«សកម្មភាពក្បត់» «ផែនការ» និង «ខ្សែក្បត់» ។ ពេលដល់ចំណុចនេះ អ្នកទោសបានក្លាយជាអស់ន័យ អស់តម្លៃ សុខភាពចុះទ្រុឌទ្រោម ក្លាយជាសត្វសម្រាប់គេផលិតឯកសារដែលដើរវារដើងបួនទៅរកសេចក្តីស្លាប់ ។

ដើម្បីដាក់ប្រធានបទទារុណកម្មទៅក្នុងរឿងរ៉ាវប្រវត្តិសាស្ត្រ វាហាក់ដូចជាច្បាស់ណាស់ថា «ការថ្វាយបន្តុំ» ការឆក់ខ្សែភ្លើង ការជ្រមុជទឹក ការធ្វើឲ្យថប់ដង្ហើម ការវាយដំ និងទារុណកម្មតាមរូបភាពផ្សេងៗទៀតនៅមន្ទីរស-២១ វាបានលាយបញ្ចូលគ្នារវាង «គំនុំសង្សឹកចំពោះបរទេស» ដែលមានលក្ខណៈជាប្រពៃណីជាមួយនឹង «ហេតុផល» និងការស្វែងរកឯកសារកំណត់ប្រវត្តិ និងភ័ស្តុតាងប្រកបដោយភាពព្រឺខ្លាចពិតៗ ដែលទាំងអស់នេះនឹងប្រែក្លាយឲ្យទៅជាប្រធានបទប្រវត្តិសាស្ត្រ ។

ស្ថិតក្នុងបរិយាកាសស្ងប់ស្ងាត់និងឃោរឃៅបែបនេះ សកម្មភាពប្រឆាំងនឹងបដិវត្តន៍ទោះជា «ពិត» ឬ «មិនពិត» ក៏ដោយ គឺចាំបាច់ត្រូវតែលាតត្រដាង ហើយកំណត់ប្រវត្តិត្រូវតែសរសេរឲ្យត្រូវគ្នានឹងការសង្ស័យទុក ។ ដូច្នេះជាការពិតណាស់ «ការធ្វើនយោបាយ» ភាគច្រើនមិនបានជំរុញអ្នកសួរចម្លើយ ឬមិនបានបង្ហាញឲ្យឃើញអំពីកំណត់ប្រវត្តិដែលតម្រូវឲ្យមាននោះទេ ។ តើការធ្វើទារុណកម្មមានភាពគួរឲ្យជឿទុកចិត្តបានទៀតទេ? ចំណុចនេះមិនអាចនិយាយបានទេ ។ ការពិភាក្សាលើបញ្ហានេះមិនមាននៅសល់ឡើយ ។ ការ

អនុវត្តន៍អំពើនេះមាននៅគ្រប់កន្លែង ។ ខ្ញុំសូមទាញហេតុផលថា ក្រោយពីបំបាត់ភាពជាមនុស្សពី «ខ្មាំង» ដែលជាទម្លាប់តែងតែមានអំពើហិង្សានិងការបណ្ដោយតាមកំហឹងរបស់អ្នកសួរចម្លើយនោះ អំពើទារុណកម្មត្រូវបានសាយភាយក្នុងទ្រង់ទ្រាយធំនៅមន្ទីរស-២១ ដោយមិនគិតដល់ការឈឺចាប់ ឬបើនិយាយពី «ការពិត» វិញ តម្លៃរបស់វាគឺស្មើនឹង «ការធ្វើនយោបាយដែរ» ។

## សៀវភៅកំណត់ហេតុរបស់អ្នកសួរចម្លើយ

ទំនាក់ទំនងរវាងការធ្វើទារុណកម្មនិង «ការធ្វើនយោបាយ» ដែលមន្ត្រីធ្វើការនៅមន្ទីរស-២១ ចង់បានត្រូវបានស្ដែងចេញច្បាស់តាមរយៈសៀវភៅកំណត់ហេតុសរសេរដៃ មិនមានចុះហត្ថលេខាដែលរៀបចំនៅក្នុងគុកផ្ទាល់តែម្ដងក្នុងចន្លោះខែកក្កដា និងខែកញ្ញា ឆ្នាំ១៩៧៦ ដែលមានអក្សរខ្សៀកសរសេរនៅឆ្នាំ១៩៧៨ នៅទំព័រក្រោយគេបង្អស់ ។ សៀវភៅកំណត់ហេតុនេះអាចសរសេរឡើងដោយកម្មាភិបាលធ្វើការនៅមន្ទីរស-២១ ដែលប្រហែលជាអ្នកដែលត្រូវបានកម្ចាត់ចោលនៅឆ្នាំ១៩៧៦ ឬអាច១៩៧៧ ហើយបានបាត់ ឬត្រូវគេទុកចោលអស់ពីរបីឆ្នាំក្រោយទៀត ។[៦៣] នៅក្នុងទំព័រដែលមាននិយាយអំពីទារុណកម្មនិងការធ្វើនយោបាយ កំណត់ហេតុនេះសរសេរថា÷

> យើងត្រូវគិតថា បញ្ហាទុកឲ្យអ្នកទោសរស់ ឬឲ្យវាសរសេរចម្លើយចេញមក ឬសម្លាប់វាចោលទាំងអស់នេះគឺត្រូវតែសម្រេចដោយបក្ស ។ ពោលគឺយើងធ្វើអ្វីដែលយើងអាចធ្វើបាន ដូចជាចាំទទួលចម្លើយជាដើម ។
>
> ការប្រើទារុណកម្មគឺជាមធ្យោបាយបន្ទាប់បន្សំទេ ។ តាមបទពិសោធន៍របស់យើងកន្លងមកជាមួយកម្មាភិបាលសួរចម្លើយគឺថា គេហាក់ដូចជាប្រកាន់យកតែការធ្វើទារុណកម្ម ។ គេផ្ដោតលើការធ្វើទារុណកម្មច្រើនជាងធ្វើការឃោសនា ។ ធ្វើដូច្នេះមិនត្រឹមត្រូវទេ ។ យើងត្រូវប្រាប់ផ្លូវត្រូវដល់អ្នកទាំងនោះ ។

កំណត់ហេតុនេះបន្តទៀតថា នៅពេលចាំបាច់ខានមិនបានហើយសឹមធ្វើ ហើយការធ្វើទារុណកម្មនេះទៀតសោតគួរតែពន្យារពេល ក្នុងករណីខ្លះ ទាល់តែស្រង់យកចម្លើយសារភាពបានចប់សព្វគ្រប់ច្បាស់លាស់សិនចាំធ្វើ÷

> ខ្មាំងមិនអាចចៀសផុតពីការធ្វើទារុណកម្មទេ គ្រាន់តែថា វាតិចឬច្រើនប៉ុណ្ណោះ ។ យើងត្រូវចាត់ទុកថា ទារុណកម្មគឺជាវិធានការមួយចាំបាច់ ។ ចំណែកឯការធ្វើនយោបាយក៏ត្រូវធ្វើដែរ ប៉ុន្តែនៅពេលដែលយើងបង្ខំឲ្យវាឆ្លើយតាមការធ្វើនយោបាយហើយវាមិនព្រមឆ្លើយទើបប្រើទារុណកម្ម ។ ទាល់តែយើងសង្កត់ខាងនយោបាយហើយទើបការធ្វើទារុណកម្មមានប្រសិទ្ធភាព... ។ ជាងនេះទៀត ការធ្វើ

នយោបាយធ្វើឲ្យអ្នកទោសឆ្លើយបានច្បាស់លាស់ទោះជាត្រូវ ឬមិនត្រូវធ្វើទារុណកម្មតាមក្រោយក៏ដោយចុះ ។

ខាងលើនេះបញ្ជាក់ថា ទារុណកម្មគួរតែប្រើ ហើយក្លាយជាវិធានការដ៏មាន «ប្រសិទ្ធភាព» ទៀតផង ក្រោយពីស្រង់យកចម្លើយសារភាពចប់សព្វគ្រប់ហើយ ដែលប្រហែលជាការទទួលស្គាល់ថា អ្នកធ្វើការនៅមន្ទីរស-២១ ចាំតែធ្វើទារុណកម្មលើអ្នកទោសក្នុងកម្រិតណាមួយ ហើយថាប្រហែលជាទារុណកម្មខ្លះដែលធ្វើឡើងក្នុងលក្ខណៈជាការពិសោធន៍ឱសថសាស្ត្រអាចមានលក្ខណៈសមស្របជាងគេទាំងអស់នៅពេលការធ្វើឯកសារត្រូវបានបញ្ចប់សព្វគ្រប់អស់ហើយ ។ មិនតែប៉ុណ្ណោះសោត នេះក៏បញ្ជាក់ដែរថា អ្នកទោសដែលត្រូវទទួលរងនូវអំពើទារុណកម្មអាចជារង្វាន់បន្ថែមសម្រាប់អ្នកធ្វើការនៅមន្ទីរស-២១ ក្រោយពីខ្លួនបានចម្លើយរួចរាល់អស់ហើយ ។ ថាតើ «ប្រសិទ្ធភាព» មានន័យយ៉ាងណានោះនៅតែមិនច្បាស់នៅឡើយទេ ។ ម្យ៉ាងវិញទៀត អ្នកសួរចម្លើយមិនត្រូវបានដាក់ទណ្ឌកម្មអ្វីឡើយ ទោះបីជាធ្វើឲ្យអ្នកទោសឈឺចាប់យ៉ាងណាក៏ដោយ វៀរលែងតែអ្នកទាំងនោះធ្វើឲ្យអ្នកទោសបាត់បង់ជីវិត ។ សៀវភៅកំណត់ហេតុមានព្រលយពាក្យទាក់ទងនឹងវិធីសាស្ត្រដែលអ្នកសួរចម្លើយអាចយកមកឃោសនា លួងលោម និងសម្រួលចិត្តអ្នកទោសដោយមិនធ្វើទារុណកម្ម ។ សៀវភៅនេះសរសេរទៀតថា÷

> គោលបំណងមួយក្នុងការធ្វើទារុណកម្មគឺត្រូវរកចម្លើយពីវា ហើយត្រូវធ្វើចិត្តឲ្យរីករាយ...គឺមិនត្រូវធ្វើទាំងកំរោលនិងក្ដៅក្រហាយទេ ។ ការវាយគឺសម្រាប់ធ្វើឲ្យវាភ័យតែប៉ុណ្ណោះ ប៉ុន្តែតាមពិតមិនសម្លាប់ទេ ។ នៅពេលណាក៏ដោយឲ្យតែវ៉ៃវា ត្រូវកុំភ្លេចពិនិត្យមើលសុខភាពវាឲ្យស្រួលបួលជាមុនសិន ហើយពិនិត្យរំពាត់ទៀតផង តើត្រូវយកធំឬតូច ។ កុំស្ទុះទៅរកតែសម្លាប់ភ្លាមឲ្យសោះ ។

សារនេះបញ្ជាក់ថា អ្នកទោសដែលត្រូវបានធ្វើទារុណកម្ម ធ្វើឲ្យអ្នកសួរចម្លើយមួយចំនួន «រីករាយ» ចំណែកអ្នកផ្សេងទៀតធ្វើឡើងទាំង «ក្ដៅក្រហាយ» ឬរកតែសម្លាប់ «ខ្មាំង» របស់បក្ស ។ មិនតែប៉ុណ្ណោះសោត ប្រសិនបើរំពាត់នោះមានលក្ខណៈអាចទទួលយកបានហើយ ការវាយទៅលើអ្នកទោសដែលមានសុខភាពមាំទាំរហូតក្បែរស្លាប់គឺត្រូវបានចាត់ទុកថា ជាការត្រឹមត្រូវ ។ អំពើឃោរឃៅរបៀបនេះស្ដាប់ទៅមិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលទេ ដោយសារតែការបំបាត់ភាពជាមនុស្សរបៀបនេះកើតមានឡើងជាទូទៅនិងជាវប្បធម៌របស់គុកទៅហើយ ។ ប៉ុន្តែ នៅពេលរឿងទាំងអស់នេះត្រូវបានយកមកសរសេរយ៉ាងលម្អិតហើយមិនលម្អៀងទៀតនោះ មើលទៅគួរឲ្យញាក់សាច់មែនទែន ។ នៅពេលដឹងខ្លួនថា ខ្លួនឯងធ្វើជ្រុលដៃហើយនោះ ក៏បានសរសេរថយបន្តិចមកវិញថា÷

> ត្រូវតែដឹងថា ធ្វើនយោបាយគឺវាសំខាន់ចាំបាច់ណាស់ ។ ចំណែកឯការធ្វើទារុណកម្មវិញគ្រាន់តែជា

> រឿងបន្ទាប់បន្សំប៉ុណ្ណោះ ។ នយោបាយតែងតែនាំមុខគេជានិច្ច ។ សូម្បីតែនៅពេលធ្វើទារុណកម្មក៏យ៉ាងអ៊ីចឹងដែរ ត្រូវតែឃោសនាឲ្យជាប់ជានិច្ច ។

ទោះបីជា «ការធ្វើនយោបាយ» មានមុខងារយ៉ាងសំខាន់យ៉ាងនេះក៏ដោយ ក៏ទារុណកម្មនៅតែមានហើយ «ការធ្វើនយោបាយ» ជួនកាលអាចត្រូវបានមើលរំលង ។ វាពិបាកណាស់ក្នុងការសម្រេចថា តើការបញ្ជាយ៉ាងនេះចេញមកដោយសុទ្ធចិត្តនិងដាក់ឲ្យអនុវត្តជាប្រព័ន្ធឬក៏គេចង់លាក់បាំងអំពើរបស់ ឌុច និងកូនចៅតាមរយៈការិយាធិបតេយ្យ ប្រសិនបើ«បង១ថ្នាក់លើ»[៦៤] រកឃើញថាមានការលើសលស់ក្នុងការអនុវត្តអំពើទារុណកម្ម ឬធ្វើឲ្យអ្នកទោសសំខាន់ណាម្នាក់ស្លាប់ដោយសារកំហឹងឬការធ្វើជ្រុលជ្រួសនោះ ។ សៀវភៅកំណត់ហេតុនេះបន្តទៀតថា÷

> បង្ក្រាបវាដោយការឃោសនាឬដោយការធ្វើទារុណកម្ម ប៉ុន្តែកុំឲ្យវាងាប់ ។ កុំឲ្យវាខ្សោយរហូតដល់យើងមិនអាចសួរវាបាននោះ...ការពារខ្លាំង ។ កុំឲ្យ (អ្នកទោស) ងាប់ ។ កុំឲ្យពុពីមួយទៅមួយ ។

ពីរឆ្នាំក្រោយមក ចាន់ បានសរសេរបៀបដូចគ្នានេះដែរថា÷

> សរសេររបាយការណ៍វា មើលទឹកមុខវា ។ កៀបវាខាងនយោបាយនិងវាយឲ្យទាល់តែចេញ ។ គិតតែពីធ្វើទារុណកម្មដូចជាដើរជើងម្ខាងអ៊ីចឹងដែរ ។ ត្រូវមានការសង្កត់ផ្នែកនយោបាយ (ដើម្បីយើងអាច) ដើរជើងពីរបាន ។[៦៥]

បានសេចក្តីថា ការសួរចម្លើយដែលត្រូវបានប្រដូចទៅនឹង «ការដើរជើងម្ខាង» គឺនៅតែប្រើនៅឡើយទេ ។ នៅប្រហាក់ប្រហែលពេលជាមួយគ្នានេះដែរ ប៉ុន បានកត់សម្គាល់ថា «បញ្ហា» នៅមន្ទីរស-២១ មាន «ការវាយដំដែលធ្វើឲ្យកម្លាំងរបស់ខ្មាំងចុះខ្សោយ» និង «បញ្ហាធ្វើទារុណកម្មៈ នៅតែធ្ងន់ធ្ងរពេក ដដែល» ។ ប៉ុន បន្ទោះគន់អ្នកសួរចម្លើយម្នាក់ចំៗថា «វានិយាយថា វាវ៉ៃ (អ្នកទោស) តិចៗ តែតាមការពិតវ៉ៃខ្លាំងណាស់» ។[៦៦]

ទំនាស់នៅក្នុងការគិតរបស់ខ្មែរក្រហមដែលប៉ះពាល់ដល់ការអនុវត្តជាក់ស្តែងនៅមន្ទីរស-២១ កើតឡើងរវាងគំនិត «ឯករាជ្យម្ចាស់ការ» ដែលលើកឡើងដោយមោទកភាពដោយរបបកម្ពុជាប្រជាធិបតេយ្យជាមួយនឹងតម្រូវការដែលអ្នកដើរតាមអង្គការដោយមិនបានគិតពិចារណាទៅលើតម្រូវការនេះ ។ «ឯករាជ្យម្ចាស់ការ» ប្រហែលជាមានន័យថា ផ្តាច់ចំណងដ៏គួរឲ្យគោរពពីអ្នកគាំទ្របដិវត្តន៍ ។ ដំណើរការនេះនាំដល់ការផ្តល់អំណាចទៅតាមឯករាជ្យភាពរបស់បុគ្គលដោយសារថានេះជាតម្រូវរបស់វិន័យបដិវត្តន៍ ។ ប្រជាជនត្រូវបានរំដោះចេញពីការពឹងពាក់ទៅជាការសាមគ្គីរបស់បក្ស ។ បុរស ស្ត្រីដែលត្រូវបានផ្តល់អំណាចរួច

ហើយបានក្លាយជាឧបករណ៍តំណាងឲ្យឆន្ទៈរបស់ប្រជាជន ពោលគឺចង់និយាយដល់អ្នកបម្រើបក្ស ។ ចំណុចលម្អិតនេះត្រូវបានធ្វើឲ្យបាត់បង់ដោយសារអ្នកចំណូលថ្មីដែលយល់ថា ការធ្វើទារុណកម្មទៅលើ «សត្រូវ» របស់អង្គការ ឬ «អ្នកដែលមានទោសកំហុស» គឺមិនមែនជាការចាត់តាំងទេ ប៉ុន្តែចាត់ទុកថាជាសិទ្ធិទៅវិញ ។ នៅក្នុងករណីទាំងនេះ អំពើឃោរឃៅក្នុងការផ្តល់អំណាចបានបង្អាក់ដល់ការគោរពបញ្ជាដាច់ខាតរបស់បក្ស ។ ប៉ុន្តែស្ថិតក្រោមចំហាយរបស់បដិវត្តន៍ ការបែក «ឆ្វេង» ដែលមានពាក់ព័ន្ធជាមួយ «ខ្លាំង» ជារឿយៗ ត្រូវគេធ្វើមិនដឹងមិនឮ ។

## ទោសនៃការគោរពឱវាទ

ឃ្លាសង្ខេបគោលការណ៍នៅមន្ទីរស-២១ ខុសពីពាក្យទំនឹមទំនៀមដ៏ល្បីល្បាញរបស់ តាឡឺរ៉ាន់ ។ ឃ្លានេះប្រហែលជាមានន័យថា «ជាពិសេស (បង្ហាញអំពី) យតិភាពខ្លាំងហួសពេក» ។ ដូចដែលសៀវភៅកំណត់ហេតុឆ្នាំ១៩៧៦ បានសរសេរយ៉ាងដូច្នេះថា÷

> ត្រូវចៀសវាងបញ្ហារួញរា ឬ ស្ទាក់ស្ទើរក្នុងការធ្វើទារុណកម្ម ។ ធ្វើរបៀបនេះពិតជាមិនអាចយកចម្លើយពីខ្មាំងបានទេ...ត្រូវប្រកាន់ជំហរកុំរួញរាឬស្ទាក់ស្ទើរ ។ យើងត្រូវតែដាច់ខាត ។

តើអ្នកណានឹងធ្វើការសម្រេច ហើយតើមានបញ្ហាអ្វីចំពោះអ្នកសួរចម្លើយនៅពេលដែល «ភាពដាច់ខាត» ប្រែក្លាយជា «ជ្រុលលើសលស់»?

អំពើឃោរឃៅយង់ឃ្នងធ្វើឡើងនៅមន្ទីរស-២១ និងនៅវាលពិឃាតជើងឯកដូចគ្នាទៅនឹងអ្វីដែលឃេលមែន និង ហាមីលតុន ហៅថា «ទោសនៃការគោរពបញ្ជា» ។ ឃេលមែន និង ហាមីលតុន បានទាញសេចក្តីសន្និដ្ឋាននេះតាមស្នាដៃនិពន្ធរបស់ ស្តេនលី មីលហ្គ្រាម និងអ្នកដទៃទៀត ។ អ្នកសួរចម្លើយនៅមន្ទីរស-២១ ដែលធ្វើទារុណកម្មលើអ្នកទោស និងអ្នកដែលត្រូវបានចោទថា បានធ្វើឲ្យអ្នកទោសស្លាប់ឆ្លើយថា មកពីបញ្ជាអ្នកដែលខ្លួនទទួលអំណាចហើយមិនបានសួរនាំ មួយផ្នែកមកពីការដែលថា បើហ៊ានសួរដេញអំណាចនោះខ្លួននឹងស្លាប់ជាមិនខាន ។ ហ្សីម៉ាន់ បូមែន ដែលសរសេរអំពីការសម្លាប់រង្គាលរបស់ណាហ្ស៊ីទៅលើជនជាតិជ្វីហ្វ បញ្ជាក់ថា «ការទប់ចិត្តមិនធ្វើអំពើឃោរឃៅចេះតែរេចរឹលទៅៗ» នៅពេលអំពើឃោរឃៅទទួលបាននូវការអនុញ្ញាតត្រឹមត្រូវនិងត្រូវគេធ្វើឲ្យទៅជាទម្លាប់ទៅហើយ និងនៅពេលដែលជនរងគ្រោះត្រូវបានបំបាត់ភាពជាមនុស្សអស់គ្មានសល់ ។ វេតាន តូដូរ៉ូ ក៏មានទស្សនៈប្រហាក់ប្រហែលគ្នានេះដែរ ។[៦៧] ជាងនេះទៅទៀត នៅពេលបន្តការឈឺចាប់និងសម្លាប់អ្នកទោស អ្នកសួរចម្លើយជាច្រើននៅមន្ទីរស-២១ និងពេជ្ឈឃាតនៅជើងឯកគិតថា ខ្លួនគេបានឆ្លើយតបទៅនឹងថ្នាក់លើថា ខ្លួនមានសីលធម៌និងវិន័យខ្លាំងជាងអ្វីដែលខ្លួនបានជួបប្រទះកន្លងមកទៅទៀត ។ ដោយស្ថិតនៅឯកោ ស្ថិតនៅជុំគ្នា និងប្រកបដោយការភ័យខ្លាចតែមិនទាន់ត្រូវបានគេផ្តល់អំណាចឲ្យនោះ យុវជនវ័យក្មេងទាំងនេះមិនយូរប៉ុន្មានក៏បានក្លាយទៅជាឧបករណ៍

ដ៏គួរឲ្យព្រឺខ្លាច ។ ការសប្បាយដែលយុវជនវ័យក្មេងទាំងនេះបានមកពីការប្រព្រឹត្តអំពើឃោរឃៅ ក្នុងករណីខ្លះបានជួយផ្តល់កម្លាំងចិត្តក្នុងការរស់នៅក្នុងគុក និងទទួលបាននិងកាន់កាប់ការអនុញ្ញាតរបស់ចៅហ្វាយនាយទៀតផង ។

ភាគច្រើននៃយុវជនវ័យក្មេងទាំងនោះមានចិត្តរីករាយក្នុងការបម្រើបដិវត្តន៍តាមការបញ្ចុះបញ្ចូលរបស់មេកើយខ្លួននិង «បង១ថ្នាក់លើ» ដែលមិនដែលឃើញមុខផង ។[៦៨] នៅពេលក្លាយជា «អ្នកឯកទេស» ហើយយុវជនវ័យក្មេងទាំងនេះ បើតាមពាក្យប្រធាន ម៉ៅ នៃប្រទេសចិនថា គឺនៅ«ក្រហមឆ្អៅ»ជានិច្ច ។ យុវជនទាំងនេះប្រហែលជាយល់ស្របជាមួយឆ្នាំក្រហមចិនដែលសរសេរថា «វិមនុស្សស្លាប់គឺជារឿងតូចតាចប៉ុណ្ណោះ ប៉ុន្តែធ្វើបដិវត្តន៍ បង្ក្រាបការងើបបះបោរ និង រក្សាភាពក្រហមឆ្អិនឆ្អៅឲ្យនៅគង់វង្ស ទើបជារឿងសំខាន់» ។[៦៩]

ចំពោះរឿងកម្ពុជាវិញ ចុងក្រោយបដិវត្តន៍ក៏ត្រូវដួលរលំ «ការបះបោរ» ងើបឡើងនៅគ្រប់ទិសទី ហើយ«ភាពក្រហមឆ្អិនឆ្អៅ»ក៏ត្រូវបានគេបរិហារ ។ ប៉ុន្មានឆ្នាំក្រោយ យើងក៏ដូចជាអ្នកនៅរស់រានមានជីវិតត្រូវបានបន្សល់ទុកឲ្យនូវសំឡេងនិងស្រមោលនៃ«អំពើឃោរឃៅដ៏ច្រើនលើសលប់» ។ យើងបានឃើញហេតុការណ៍ទាំងអស់នេះនៅពេលយើងបើកមើលឯកសារចម្លើយសារភាពមួយសន្លឹកម្តង១ ឬនៅពេលយើងថតចម្លងរូបថតពាក់កណ្តាលខ្លួនរបស់អ្នកដែលសុំក្តីមេត្តាឬខឹងនឹងអ្នកដែលកំពុងតែថតយករូបខ្លួន ហើយក្រោយពីខ្លួនត្រូវបានសម្លាប់អស់ពេលយ៉ាងយូរមក អ្នកទាំងនេះក៏បែរមកសម្លឹងនិងខឹងនឹងយើងម្តង ។ ឯកសារដែលនៅសេសសល់ទាំងនេះដែលមានដូចជារូបថត កំណត់ហេតុរំពុក បញ្ជីឈ្មោះ ស្ថិតិ និងចម្លើយសារភាពបានបង្ហាញនូវការរីករាយ ការឈឺចាប់ និងភាពច្របូកច្របល់ដ៏អសោចដែលក្លាយទៅជាវប្បធម៌និងភាពគួរឲ្យព្រឺខ្លាចរៀងរាល់ថ្ងៃនៅមន្ទីរស-២១ ។

## រូបភាពមន្ទីរស-២១

យើងអាចទិតចូលកាន់តែជិតថែមទៀតមករកអ្វីដែល«កើតឡើងជាក់ស្តែង» នៅពេលយើងចូលទៅធ្វើទស្សនកិច្ចសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ចាត់ឌី លិចជីវ្វូដ ដែលធ្វើការនៅទួលស្លែងអស់ជាច្រើនខែនៅក្នុងគម្រោងថតចម្លងមីក្រូហ្វិល ខរណែល បានសរសេរថា÷

> ពេលវេលាចេះតែរំកិលទៅមុខ អ្នកនឹងឃើញរូបភាពកាន់តែលម្អិត ។ ជាក់ស្តែងនៅកន្លែងឈប់សំចត នៅតាមជណ្តើរនានាមានប្រហោង ដែលគេចោះជញ្ជាំងដើម្បីចាក់ទឹកសម្អាតតាមជណ្តើរនិងបន្ទប់ ។ នៅពីក្រោមកន្លែងចំហនៅផ្នែកខាងក្រៅ យើងនៅឃើញឈាមហូរធ្លាក់ចុះមកនៅឡើយ ដូចជាអគារហ្នឹងបង្ហូរឈាមខ្លួនឯងអ៊ីចឹង ។[៧០]

នៅពេលដើរចូលទៅកាន់តែជិតតាមច្រករបៀងយ៉ាងដូច្នេះ យើងកាន់តែជិតបាន«អាន»នូវអ្វីដែល

កើតឡើងប្រចាំថ្ងៃនៅទីនេះ ។ ពេលយើងអានឯកសារមួយចំនួន វាបានទាញយើងឲ្យខិតទៅរកឯកសារផ្សេងទៀត ។ ឃ្លាប្រយោគត្រង់នេះមួយកន្លែង ត្រង់នោះមួយកន្លែង សំណេរក្រវេមក្រវាមរបស់អ្នកសួរចម្លើយ ឬ ទឹកមុខរបស់អ្នកទោសក្នុងរូបថតពាក់កណ្ដាលខ្លួនអាចឆ្លុះបញ្ចាំងយ៉ាងច្បាស់នូវបទពិសោធន៍ទាំងស្រុងរបស់គុក ទោះបីជា«ការឆ្លុះបញ្ចាំង»បែបនេះមានភាពខុសៗគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតយ៉ាងណាក៏ដោយ ។ ចំពោះខ្ញុំវិញ សម្ដីរបស់ ញ៉ែម អេន បានបញ្ជាក់ពីភាពព្រឺខ្លាចជាប្រចាំដែលកើតឡើងនៅក្នុងគុក ។ នៅពេល ដូហ្គាស នីវិន សួរថា «តើអ្វីដែលគួរឲ្យរន្ធត់កើតឡើងនៅមន្ទីរស-២១ ដែល អេន នៅចងចាំបានដល់សព្វថ្ងៃ?» ។ អេន ឆ្លើយថា÷

> អ្វីដែលធ្វើឲ្យខ្ញុំព្រឺមែនទែននោះគឺនៅពេលខ្ញុំឃើញគេដឹកមនុស្សទាំងឡានៗចូល ហើយរុញទម្លាក់ចេញពីឡានដួលផ្ងាល់នឹងដី ។ កាលនោះខ្ញុំនៅក្មេងនៅឡើយ ដូច្នេះពេលឃើញហេតុការណ៍បែបនេះ ខ្ញុំខ្លាចខ្លាំងណាស់ ។ អ្នកទាំងនោះត្រូវគេរុំមុខជិតហើយចងស្លាបសេក ។[៧១]

ផ្ទុយមកវិញ នៅពេលអ្នកទោសត្រូវដឹកចេញពីមន្ទីរស-២១ យកទៅសម្លាប់ចោល គេបានលើកអ្នកទោសម្ដងមួយៗដាក់លើឡានដូចសត្វឆ្មា ឬកូនក្មេងអីចឹង ។ ដូចដែល ហ៊ឹម ហ៊ុយ បាននិយាយទៅកាន់ ភីតធ័រ ម៉ាឃ្វៀ ថា «អ្នកទោសឡើងឡានមិនរួចទេ ពីព្រោះឡានខ្ពស់ពេក» ។

ការសម្លាប់ស្ទើរតែទាំងអស់ត្រូវបានធ្វើឡើងដោយសម្ងាត់និងនៅពេលយប់ ។ គក ស្រស់ បានរំឭកឡើងវិញថានៅឆ្នាំ១៩៧៦ អ្នកទោសដែលគេចងមុខជិត ត្រូវបានគេយកទៅសម្លាប់ចោលនៅបរិវេណខាងលិចដោយសំពងនឹងព្រនង់ដែក ។ ស្លាប់កន្លែងណាគេកប់កន្លែងហ្នឹង ។ ចំណែកឯរណ្ដៅនោះរាក់ទេ មានជម្រៅប្រមាណតែមួយម៉ែត្រកន្លះប៉ុណ្ណោះ ។ ទោះបីជាការសម្លាប់មិនដែលត្រូវបានពិភាក្សាជាចំហក៏ដោយ ក៏ក្លិនសាកសពស្អុយរហ៊ុម លាយឡំជាមួយនឹងក្លិនលាមកនិងទឹកនោមមិនអាចលាក់ជិតបានឡើយ ។[៧២]

## «ការកម្ទេចខ្មាំង» នៅជើងឯក

នៅក្នុងអំឡុងឆ្នាំ១៩៧៧ នៅពេលដែលវិសុទ្ធកម្មចេះតែខ្លាំងឡើងៗ គុកនៅមន្ទីរស-២១ ឡើងពេញប្រៀប ហើយកន្លែងកប់ខ្មោចនៅជិតនោះក៏ពេញទាំងអស់ ។ នៅពេលមួយក្នុងឆ្នាំ១៩៧៧ ម៉ុងខ្មោចចិននៅជិតភូមិជើងឯងដែលស្ថិតនៅភាគនិរតីទីក្រុងភ្នំពេញចម្ងាយដប់ប្រាំគីឡូម៉ែត្រត្រូវបានយកមកធ្វើជាវាលពិឃាត ។ ចំណែកឯអ្នកទោសសំខាន់ៗនៅតែបន្តសម្លាប់ចោលនៅបរិវេណគុកដដែល ។ ទីតាំងនេះស្ថិតនៅជិតកន្លែងជំនាញការសេដ្ឋកិច្ចរបស់ចិនស្នាក់នៅ ។ គុកនិងមន្ទីរស-២១ មានបំពាក់ភ្លើងអគ្គិសនីដើម្បីធ្វើការសម្លាប់មនុស្ស និងឲ្យឆ្មាំគុកអាន និងចុះហត្ថលេខាលើបញ្ជីឈ្មោះអ្នកទោសដែលត្រូវយកទៅសម្លាប់ចោល ។ កន្លែងនេះហើយជាកន្លែងដែល ញ៉ែម អេន ឃើញគេយកអ្នកទោសទៅ «កម្ទេច» ឬ «បោះចោល» ។ ក្រោយរកឃើញនៅឆ្នាំ១៩៨០ ទីតាំងនេះក៏ត្រូវបានប្រែក្លាយទៅជាកន្លែងទេសចរណ៍

ក្រោមការដឹកនាំរបស់វៀតណាម ។ កាលនោះនៅមានកម្ទេចឆ្អឹង និងសម្លៀកបំពាក់នៅជិតរណ្តៅដែលគេទើបគាស់ខ្មោចថ្មីៗនៅឡើយ ។[៧៣]

គក ស្រស់ និង ហ៊ឹម ហ៊ុយ មានមតិផ្ទុយគ្នាទៅលើការចងចាំរបស់ខ្លួនអំពីការសម្លាប់នេះ ។ គក ស្រស់ និយាយថា គាត់មិនដែលទៅជើងឯកទេ ។ ចំណែកឯ ហ៊ឹម ហ៊ុយ វិញនិយាយថាបានបើកឡានដឹកអ្នកទោសពេញៗទៅកាន់កន្លែងនោះជាញឹកញយ ហើយបានសម្លាប់មនុស្សដោយផ្ទាល់ដៃ «ពីរបីដង» ទៀតផង ។ តាម គក ស្រស់ និង ញែម អេន ដែលត្រូវបានសម្ភាសប៉ុន្មានខែក្រោយមកទៀតបានឲ្យដឹងថា នៅឆ្នាំ១៩៧៨ ហ៊ឹម ហ៊ុយ គឺជាអ្នកសម្លាប់ខ្លាំងជាងគេ ជាមនុស្សសំខាន់នៅក្នុងគុក និងជាអ្នកសកម្មនៅក្នុងដំណើរការសម្លាប់មនុស្ស ។ វ៉ាន់ ណាត ដែលបានបង្ហាញរូបថតគាត់នៅឆ្នាំ១៩៩៦ បានយល់ស្របចំពោះការអះអាងនេះ ។ គក ស្រស់ និយាយថា នៅឆ្នាំ១៩៧៨ ហ៊ឹម ហ៊ុយ បានជ្រើសរើសក្រុមសម្លាប់ជាញឹកញាប់ដែលក្រុមទាំងនោះមាន «បុរសដែលអាចធ្វើអ្វីៗគ្រប់យ៉ាង» ។ អ្នកដែលមិនធ្លាប់មានបទពិសោធន៍សម្លាប់មនុស្សពីមុនមកគាត់មិនយកទេ ហើយពេជ្ឈឃាតមិនដែលនិយាយអំពីការសម្លាប់មនុស្សទេ ។ ជាញឹកញាប់ គក ស្រស់ បាននាំយកអ្នកទោសពីបន្ទប់តូចមកចំណុចប្រមូលផ្តុំនៅក្រៅរបងតែម្តង ។ គក ស្រស់ បញ្ជាក់ថា «នៅពេលអ្នកទោសឮថាគេមកយកខ្លួនទៅ អ្នកទោសបានព្យាយាមបំបាក់សោហើយតដៃជាមួយឆ្មាំគុក» ។ បន្តិចក្រោយមក គេក៏ចាប់ដាក់ឡានហើយយកទៅលិចដែលតាមទេវកថាវិទ្យាខ្មែរគេហៅថាទិសមរណៈ ។

ការរៀបរាប់ម្តងអីចេះម្តងអីចុះរបស់ ហ៊ឹម ហ៊ុយ អំពីការសម្លាប់នៅជើងឯកគឺគ្រាន់តែជាពត៌មានដំបូងដៃតែប៉ុណ្ណោះដែលយើងមានមកដល់ពេលនេះ ។ ពត៌មានបន្ទាប់មកទៀត គឺដកស្រង់ចេញពីកិច្ចសម្ភាសន៍ទាំងនេះដែលធ្វើឡើងនៅអំឡុងឆ្នាំ១៩៨៧ និង១៩៩៧ ។

អ្នកទោសដែលត្រូវបានសម្លាប់នៅជើងឯករាល់ថ្ងៃមានចំនួនខុសគ្នា ជួនកាលមានរាប់សិបនាក់ ជួនកាលឡើងដល់បីរយនាក់ ។ ចំនួនបីរយនាក់នេះត្រូវបានកត់នៅក្នុងបញ្ជីនៅខែឧសភា ឆ្នាំ១៩៧៨ នៅពេលដែលការបោសសម្អាតភូមិភាគបូព៌ាឡើងដល់កម្រិត ។ ជាធម្មតាក្នុងមួយខែ ឬបីសប្តាហ៍ម្តងមានឡានដឹកមនុស្សពីរទៅបីឡានពីមន្ទីរស-២១ ទៅជើងឯក ។ ឡានមួយៗមានឆ្មាំជិះបីទៅបួននាក់និងមានអ្នកទោសពីម្ភៃទៅសាមសិបនាក់ដែលញ័រខ្លួនចំប្រប់ និងស្ងាត់មាត់ដូចគេចុក ។ នៅពេលឡានមកដល់ទីតាំង ហ៊ុយ និយាយថា អ្នកទោសត្រូវបានប្រមូលផ្តុំមួយកន្លែងនៅផ្ទះតូចមួយដែលមានបញ្ជីរាយឈ្មោះអ្នកត្រូវសម្លាប់ហើយជាស្រេច ។ ឈ្មោះទាំងអស់នេះ សួស ធី ជាអ្នករៀបចំ ។ សួស ធី ជាប្រធានខាងធ្វើឯកសារ ។ បញ្ជីឈ្មោះសម្លាប់មួយចំនួនតូចនៅសល់រហូតដល់សព្វថ្ងៃ ។ ក្រោយមកគេបំបែកអ្នកទោសជាក្រុមតូចៗ បណ្តើរទៅកាន់ប្រឡាយនិងរណ្តៅដែលអ្នកប្រចាំការនៅទីជើងឯកបានជីកទុករួចជាស្រេច ។ ហ៊ឹម ហ៊ុយ បន្តរៀបរាប់យ៉ាងលម្អិតនិងស្ទើរតែមិនលម្អៀងថា៖

> គេឲ្យអ្នកទោសលុតជង្គង់ចុះនៅមាត់រណ្តៅ ។ ដៃចងស្ពាយសេក ។ អ្នកទោសត្រូវបានវាយដោយដែកក្បៀរទេះគ្រង់កញ្ចឹងក ជួនកាលវាយមួយដង ជួនកាលពីរដង... ។ ហ៊ី ជាអ្នកត្រួតពិនិត្យការសម្លាប់

ទាំងនេះ និងជាអ្នកចុះឈ្មោះ ។ យើងយកឈ្មោះទៅឲ្យ សួស ធី វិញ ។ មិនមានបាត់ឈ្មោះអ្នកណាម្នាក់ឡើយ ។

ហ៊ឹម ហ៊ុយ នឹកឃើញសំឡេងអ្នកទោសស្រែកយំ «សូមកុំសម្លាប់ខ្ញុំអី!» ហើយ «អ៊ូយ» ។ ហ៊ឹម ហ៊ុយ បាននិយាយថា គាត់ធ្លាប់បានប្រាប់អ្នកទោសម្នាក់ថា បើខ្ញុំមិនសម្លាប់ឯងតាមគេបញ្ជាទេ គេច្បាស់ជាសម្លាប់ខ្ញុំមិនខាន ។ នៅពេលសួរថា តើមាន «ភាពក្រៀមក្រំ ឬភ័យខ្លាចដែរឬទេ?» ពេលនៅដើងឯក ហ៊ឹម ហ៊ុយ បានឆ្លើយតបវិញថា «ទេ ប៉ុន្តែជួនកាលខ្ញុំគិតថា តើគួរតែរត់ចេញពីទីនេះ តែបើរត់ តើរត់ទៅណា តើទៅណាកើតបើគ្មានអាវុធផង? ប្រសិនបើខ្ញុំមានអាវុធ និងមានអីជិះវិញម៉្លេះ... ។ ខ្ញុំគិតដល់រឿងនេះច្រើនណាស់កាលនោះ» ។

ការសម្លាប់អ្នកដែលធ្លាប់ធ្វើការជាមួយពិតជាពិបាកណាស់សម្រាប់ ហ៊ឹម ហ៊ុយ ហើយមុនពេលអ្នកទាំងនោះស្លាប់ ហ៊ឹម ហ៊ុយ និយាយថា ជនរងគ្រោះទាំងនេះ «ឃើញខ្ញុំមុខស្រពោនដល់កម្រិតណាជាមិនខាន» ។ ហ៊ឹម ហ៊ុយ នៅចាំបានថា មានពេលមួយនៅពេលអ្នកទោសស្លាប់ ហើយសាកសពមួយចំនួនត្រូវគេដោះខោអាវដែលមានតម្លៃយកអស់ ។ ចំណែកឯសាកសពស្ត្រីវិញមិនមានអ្នកណាដោះយកទេ ។

នៅពេលដែលយើងសិក្សាពីមន្ទីរស-២១ វាដូចជាចង់តែធ្វើការវិនិច្ឆ័យភ្លាមៗ ប៉ុន្តែវាក៏ជាការធ្ងន់ធ្ងរពេកដើម្បីវិនិច្ឆ័យពួកអ្នកសួរចម្លើយ ឆ្មាំគុក ឬអ្នកសម្លាប់ ។ បើគ្មានបទពិសោធន៍ ការទប់ចិត្តនិងការគាបសង្កត់ប្រហាក់ប្រហែលនេះទេ យើងមិនអាចនិយាយថា តើយើងគួរតែធ្វើយ៉ាងដូចម្តេច ប្រសិនបើយើងជាអ្នកសួរចម្លើយដែលត្រូវបានចាក់សោនៅក្នុងបន្ទប់តូចជួបនឹងក្តីអស់សង្ឃឹមនិង«ខ្លាំង» ដែលត្រូវគេដកហូតតម្លៃអស់រលីង ព្រមជាមួយនឹងអ្នកធ្វើការជាមួយគ្នាពីរនាក់ដែលអ្នកទាំងពីរនេះនឹងរាយការណ៍ទៅអាជ្ញាធរថាមិនបានធ្វើទារុណកម្មឬមានការរួញរា «ប្រឆាំងនឹងបដិវត្តន៍»នោះ ។ ស្រដៀងគ្នានេះដែរ យើងមិនអាចនិយាយនូវអ្វីដែលយើងអាចនឹងធ្វើនៅដើងឯកទេ ប្រសិនបើមេកើយយើងហុចដែកគោលទេះឲ្យមកវាយបំបែកលលាដ៏ក្បាលជនរងគ្រោះដែលកំពុងតែលុតជង្គង់ចាំមាត់រណ្តៅនោះ ។ ប្រឈមមុខនឹងការគំរាមកំហែងនិងភាពមិនប្រាកដប្រជាជាច្រើន តើអ្នកធ្វើទារុណកម្ម និងអ្នកសម្លាប់មានការរួញរា ចេះតែរំលោភទៅ ឬធ្វើការជ្រើសរើសទៅតាមករណីមួយៗផ្សេងៗពីគ្នា? ការបដិសេធមិនព្រមធ្វើទារុណកម្ម ឬសម្លាប់អ្នកទោសមិនមាននិយាយនៅក្នុងបណ្ណសារឡើយ ។ នៅពេលបុគ្គលិកគុកចាប់ផ្តើមធ្វើទារុណកម្ម វាហាក់ដូចជាថា អ្នកសួរចម្លើយមានភាពឥតមេត្តាជ្រុលពេក ហើយត្រូវបានប្រមូលផ្តុំគ្នាផ្តល់អំណាចឲ្យ ឬភ័យខ្លាំងរហូតមិនអាចបញ្ឈប់ ឬឆ្ងល់នូវអ្វីដែលខ្លួនកំពុងតែធ្វើ ។ កំហិតមួយចំនួនកើតចេញមកពីអ្នកនៅពីលើខ្លួន មកពីជនរងគ្រោះ ឬពីអ្នកដទៃទៀតដែលនៅក្នុងក្រុមរបស់ខ្លួន ។ ភាពគួរឲ្យព្រឺខ្លាចពិតៗដែលកើតឡើងនៅមន្ទីរស-២១ អាចស្ថិតនៅក្រោមអំពើហិង្សា ដោយសារភាពធ្វើមិនអើពើរបស់អ្នកគ្រប់គ្រងគុកផ្ទាល់និងភាពព្រងើយកន្តើយរបស់មជ្ឈិមបក្សចំពោះអ្វីដែលគេកំពុងតែធ្វើចំពោះមនុស្សផ្សេងទៀត ។ ក្នុងន័យម្យ៉ាង យើងអាចនិយាយបានថា អ្នកដែលត្រូវទទួលរងទារុណកម្មនៅទួលស្លែងអាចមាន

សំណាងដែលមិននៅរស់នេះ បើសិនជាយើងគិតពីផលប៉ះពាល់ក្រោយពីហេតុការណ៍និងភាពតក់ស្លុតដែលបណ្តាលមកពីទារុណកម្មដែលកើតឡើងចំពោះជនរងគ្រោះជាច្រើននិងដែលធ្វើឲ្យអ្នករស់រានមានជីវិត ជាច្រើនពីជំរំណាហ្ស៊ីបន្ទុំចិត្តសម្លាប់ខ្លួន ក្រោយពេលគេដោះលែងឲ្យមានសេរីភាពវិញនោះ ។[៧៨] ភាពក្រៀមក្រំចុងក្រោយហេតុការណ៍ប្រហាក់ប្រហែលគ្នានេះដែរ កើតឡើងចំពោះអ្នកដែលត្រូវបានធ្វើឲ្យអាម៉ាស់មុខនិងវាយប្រហារនៅក្នុងបដិវត្តវប្បធម៌ចិន ។ ជនដែលដល់នៅទីនោះរឹតតែឥតធម៌មេត្តាជាងនេះទៅទៀត ។

សូមលើកឧទាហរណ៍ជាក់ស្តែងចំនួនពីរដែលបានមកពីជនរងគ្រោះ ។ ហ្សង់ អាមេរី ជាបញ្ញវន្តជនជាតិជ្វីហ្វដ៏សំខាន់នៅអឺរ៉ុបក្រោយពេលសង្គ្រាម និងអ្នករស់រានមានជីវិតម្នាក់ពីជំរំមរណៈអូសវិច ។ អ្នកទាំងពីរបានធ្វើអត្តឃាតនៅឆ្នាំ១៩៧៨ ។ មួយទសវត្សរ៍ក្រោយមក មិត្តរបស់ខ្លួននៅជំរំមរណៈអូសវិច ឈ្មោះព្រីម៉ូ បានលោតទម្លាក់ខ្លួនពីលើបន្ទប់នៅតំបន់ទូរីន ។ នៅក្នុងសៀវភៅខ្លីមួយមានចំណងជើងថា «ដែនកំណត់នៃចិត្ត» អាមេរី អាចទាយទុកមុនអំពីមរណភាពរបស់លោកផ្ទាល់និងរៀបរាប់អំពីអំពើទារុណកម្មដូចតទៅនេះ÷

> អ្នកដែលត្រូវបានធ្វើទារុណកម្មហើយ នៅតែទទួលរងទារុណកម្មទៀត...អ្នកដែលទទួលរងនូវអំពើទារុណកម្មហើយមិនអាចរស់នៅស្រួលក្នុងពិភពលោកយើងនេះបានទេ ។ អំពើកម្មេចមនុស្សដ៏គួរឲ្យស្អប់ខ្ពើមនេះមិនមានអ្នកណាធ្វើឲ្យរលត់បានឡើយ ។ សេចក្តីទុកចិត្តទៅលើមនុស្សជាតិមានភាពប្រេះស្រាំរួចទៅហើយ ដោយការទះចំមុខមួយដៃនិងដែលលុបបំបាត់ដោយទារុណកម្មនោះគឺមិនអាចយកមកវិញបានឡើយ ។[៧៩]

## វគ្គទីប្រាំមួយៈ

# បរិយាយអំពីមន្ទីរស-២១

ក្រោយពីបានដឹងនូវអ្វីទាក់ទងនឹង«ស្ថាប័នស្វយ័ត»មួយ ពោលគឺមន្ទីរស-២១ ដែលចងក្រងឯកសារទាក់ទិនអំពើគួរឲ្យព្រឺខ្លាចនិងប្រវត្តិសាស្ត្រសម្រាប់បម្រើរបបមួយដែលសាហាវនិងគួរឲ្យស្អប់ខ្ពើម តើយើងត្រូវយកមកពន្យល់ឬបរិយាយយ៉ាងណាដើម្បីឲ្យមានផលប្រយោជន៍ចំពោះអ្នកដែលនៅរស់រានមានជីវិត អ្នកប្រវត្តិសាស្ត្រ និងអ្នកអានទូទៅ?

ចម្លើយគឺមាននៅក្នុងវគ្គទីប្រាំតែម្តង ។ ដោយប្រកាន់យកនូវគំនិតមិនលម្អៀងទៅលើអ្វីដែលកើតឡើងនៅមន្ទីរស-២១ ខ្ញុំមិនចង់បង្រួញអំពើឃោរឃៅដែលធ្វើឡើងនៅក្នុងគុកឬឧក្រិដ្ឋកម្មរបស់មជ្ឈិមបក្សឡើយ ។ ជំពូកមុនៗបានចងក្រង ឬ បកស្រាយនូវឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលត្រូវបានប្រព្រឹត្តឡើងនៅមន្ទីរស-២១ ។ ប៉ុន្តែរឿងដែលត្រូវយល់ដឹងអំពីមន្ទីរស-២១ មានច្រើនជាងការបដិសេធថា វាជារឿងអាក្រក់ ។ ការព្យាយាមស្វែងយល់អំពីអ្វីដែលកើតឡើងនៅទីនោះ «តើកើតឡើងយ៉ាងដូចម្តេច និងហេតុអ្វី» វាមានសារប្រយោជន៍ជាងការកាត់សេចក្តីថាល្អអាក្រក់ភ្លាមៗ ។

អ្នកនិពន្ធភាគច្រើនបានធ្វើការប្រៀបធៀបមន្ទីរស-២១ ទៅនឹងជំរំមរណៈណាហ្ស៊ីនៅក្នុងសង្គ្រាមលោកលើកទីII ។ អ្នកនិពន្ធដែលបានពិនិត្យជំរំណាហ្ស៊ីបានបញ្ជាក់នូវវប្បធម៌នៃការគោរពបញ្ជាដែលបានជះឥទ្ធិពលដល់ស្ថាប័នស្វយ័តនានា និងបង្ហាញពីការបំបាត់ភាពជាមនុស្សដែលកើតឡើង ទាំងចំពោះជនដៃដល់ និងជនរងគ្រោះ ។ ការសិក្សាអំពីការសម្លាប់រង្គាលទៅលើជនជាតិជ្វីហ្វក៏នាំយើងឲ្យយល់អំពីភាពមិនអើពើដែលពួកណាហ្ស៊ីក៏ដូចជាជនជាតិកម្ពុជាបង្ហាញដល់ជនរងគ្រោះរបស់ផងខ្លួន ហើយមានករណីខ្លះ អ្នកទាំងនោះសម្តែងចេញនូវសេចក្តីរីករាយដែលបានមកពីការបង្កការឈឺចាប់ទៅលើអ្នកដទៃ ។[១] ភាពឥតមេត្តាធ្វើឡើងចំពោះ «អ្នកមានកំហុស» និងការសប្បាយដែលបានមកពីការធ្វើឲ្យគេឈឺចាប់គឺបង្ហាញចេញតាមរយៈចៅក្រមនៅទីក្រុងមូស្គូដែលចូលរួមនៅក្នុងតុលាការជម្រះក្តីបង្គ្រប់កិច្ចនៅទសវត្សរ៍ឆ្នាំ១៩៣០ ការសម្លាប់រង្គាលនៅប្រទេសឥណ្ឌូណេស៊ីនៅឆ្នាំ១៩៦៥ និង១៩៦៦ អ្នកធ្វើទារុណកម្មយោធានៅប្រទេសអាហ្សង់ទីន និងអ្នកដែលរៀបចំការសម្លាប់នៅបូស្នៀ និងរ៉ាន់ដានៅទសវត្សរ៍ឆ្នាំ១៩៩០ ។ ដូច្នេះមន្ទីរស-២១ មិនមែនជាអ្វីដែលថ្មីមានតែមួយនោះទេ ។[២]

ទោះបីជាយ៉ាងនេះក្តី នៅពេលយើងកកាយឯកសាររបស់គុកនេះ យើងបានប្រទះភាពគួរឲ្យព្រឺខ្លាចយ៉ាងច្រើនលើសលប់ ។ យើងរកនិយាយអ្វីក៏មិនចេញ ។ ប្រវត្តិវិទូជនជាតិបារាំងម្នាក់ឈ្មោះ អាឡាំង ហ្វ័ររ៉េស ដែលបានចូលមកទស្សនាសារមន្ទីរនេះនៅឆ្នាំ១៩៨២ បានសរសេរថា «ខ្ញុំទំទប់អារម្មណ៍មិនបានទាល់តែសោះ ហើយគ្មានឱកាសថានឹងគិតដល់ឬសរសេរអំពីរឿងនេះឡើយ ។ខ្ញុំហួសចិត្តរកពាក្យអ្វីមកនិយាយមិនបាន» ។[៣] ក្នុងទសវត្សរ៍ឆ្នាំ១៩៣០ លោក បូរីស ប៉ាស្ទ័រណាក់ បានទៅទស្សនាកសិដ្ឋានសហករណ៍នៅអតីតសហភាពសូវៀត ដែលកាលនោះមានមនុស្សរាប់ពាន់នាក់ត្រូវស្លាប់បាត់បង់ជីវិតដោយសារការអត់

ឃ្លាន ។ ប៉ាស៊័រណាក បាននិយាយថា «អ្វីដែលខ្ញុំបានឃើញមិនអាចរកពាក្យអ្វីមកនិយាយបានទេ ។ ដោយរឿងនេះមានភាពអមនុស្សធម៌និងទុក្ខសោកមិនអាចនឹកស្មានដល់យ៉ាងដូច្នេះ ធ្វើឲ្យមានអារម្មណ៍ថា គ្រោះគួរឲ្យរន្ធត់នេះហាក់ក្លាយជារឿងអរូបិយគ្មានសតិសម្បជញ្ញៈ ។ នៅពេលនោះខ្ញុំចង់ឈឺតែម្តង» ។[៤]

នៅពេលយើងជួបប្រវត្តិជាច្រើនដែលផុតរលត់អស់ហើយនេះ យើងចាំបាច់ត្រូវនិយាយអ្វីដែលត្រឹមត្រូវជាក់ស្តែងជាមួយនឹងមន្ទីរស-២១ និងជាភ័ស្តុតាងសម្រាប់ជនរងគ្រោះ ។ ប៉ុន្តែ ចូនណាថាន ស្ពិន បានរំពុកយើងដោយមើលពីជ្រុងម្ខាងទៀតថា «នេះជាសោកនាដកម្មមួយក្នុងការសរសេរអំពីសោកនាដកម្មដែលទម្ងន់និងការរៀបចំស្រេះពាក្យមានបញ្ហាយ៉ាងខ្លាំង ដោយសារការឈឺចាប់ត្រូវការថ្លឹងថ្លែងតាមពាក្យពេចន៍ឲ្យបានសមរម្យចំពោះអ្នកដទៃ» ។[៥] ក្នុងន័យម្យ៉ាង កិច្ចខិតខំប្រឹងប្រែងរបស់ ម៉ៃ ឡាំ ក្នុងការប្រែក្លាយមន្ទីរស-២១ឲ្យក្លាយជាសារមន្ទីរ គឺជាការប៉ុនប៉ងធ្វើឲ្យមន្ទីរនេះក្លាយជាកន្លែងផ្ទុកទៅដោយភាពគួរឲ្យព្រឺខ្លាចពិតៗសម្រាប់អ្នកដទៃទស្សនា ។ ផែនទីក្បាលខ្មោចនៅដាក់តាំងនៅមន្ទីរស-២១ ដែល ម៉ៃ ឡាំ ជាអ្នករៀបចំផ្ទាល់មានលក្ខណៈអាក្រក់អាក្រីណាស់ រហូតដល់ធ្វើឲ្យយើងឃ្លាតកាន់តែឆ្ងាយពីគុកនេះ ។ ដូចគ្នានេះដែរ ចេតិយដែល ម៉ៃ ឡាំ សង់ជិនួសនៅជើងឯកធ្វើឲ្យផ្ទុយនឹងការបកស្រាយតាមធម៌ព្រះពុទ្ធចំពោះលលាដ៏ក្បាលដែលដាក់តាំងនៅក្នុងចេតិយនោះ ។ គ្រប់រឿងដែលយើងនិយាយឬសរសេរអំពីមន្ទីរស-២១ ឬអំពីសារមន្ទីរហាយនភាពគឺមានខ្លឹមសារងាយយល់និងត្រឹមត្រូវទៅនឹងអ្វីដែលបានកើតឡើងកន្លងមក ។ វាជារឿងច្រំដែលៗ និងនិយាយតែអំពីភាពឃោរឃៅនៅមន្ទីរស-២១ និងសារមន្ទីររបស់ ម៉ៃ ឡាំ ដែលមិនខុសគ្នាទៅនឹងការនិយាយអំពីកន្លែងនិងពេលវេលាផ្សេងទៀតដែលគេយកមកប្រៀបប្រដូចជាមួយនឹងមន្ទីរស-២១ នោះឡើយ ។ យើងក៏មិនដឹងនិយាយយ៉ាងម៉េចដែរពីព្រោះ ជូឌីត ស្យក្លា បានសរសេរថា «យើងនិយាយវាទាវង់តែពីរឿងឃោរឃៅ ពីព្រោះយើងមិនដឹងនិយាយយ៉ាងម៉េច» ។[៦]

ដូច្នេះ តើហេតុអ្វីបានជាយើងនៅតែពុះពារតស៊ូពីរឿងនេះ? តើវាមានសារប្រយោជន៍នាំយើងឲ្យខិតកាន់តែជិត និងកាន់តែស្គាល់ច្បាស់នូវភាពគួរឲ្យព្រឺខ្លាចនៅមន្ទីរស-២១ឬ? ប្រសិនបើយ៉ាងដូច្នេះមែន តើក្រៅពីអ្នកអានរបស់ខ្ញុំនិងរូបខ្ញុំផ្ទាល់ អ្នកណាជាអ្នកទទួលផលប្រយោជន៍? ប្រវត្តិវិទូជានិច្ចកាលតែងតែលូកដៃលូកជើងចូលមក ។ ខ្ញុំសរសេរជំពូកនេះក្នុងខណៈពេលដែលខ្ញុំជាអ្នកទស្សនាមន្ទីរស-២១ ដោយគ្មានការអញ្ជើញ ។ ខ្ញុំបាននាំមកនូវភ័ស្តុតាងដែលបានមកពីជនរងគ្រោះ និងអ្នកធ្វើបាបជនរងគ្រោះនៅក្នុងគុកផ្ទាល់ ។ នៅក្នុងឯកសារនេះ ខ្ញុំរៀបរាប់ «ជុំវិញភាពឃោរឃៅ» ហើយនេះគឺជាការអនុវត្តន៍ជាក់ស្តែងប្រកបដោយគ្រោះថ្នាក់ដូចលោក ស្យក្លា បានសង្កត់ធ្ងន់ថា «ទោះជាទ្រព្យសម្បត្តិបទពិសោធន៍ខាងប្រវត្តិសាស្ត្ររបស់យើងមានច្រើនប៉ុនណាក៏យើងមិនអាចដឹងថា តើត្រូវគិតយ៉ាងម៉េចដែរអំពីភាពជាអ្នករងគ្រោះនេះ ។ ស្ទើរតែគ្រប់ចំណុចទាំងអស់ គេអាចនិយាយបានថា វាជារឿងមិនយុត្តិធម៌បម្រើឲ្យផលប្រយោជន៍ផ្ទាល់ខ្លួន មិនថ្លៃថ្នូរ មិនពិត ក្បត់ខ្លួនឯង មានភាពផ្ទុយគ្នា ឬមានគ្រោះថ្នាក់ ។ ដូច្នេះការឆ្លើយតបតាមបែបអ្នកសិក្សាជាន់ខ្ពស់ គឺត្រូវសរសេរប្រវត្តិសាស្ត្ររបស់ជនរងគ្រោះនិងអ្នកធ្វើបាបជនរងគ្រោះឲ្យបានត្រឹមត្រូវតាមខ្លឹមសារពិតតាមតែអាចធ្វើទៅបាន...» ។[៧]

នៅក្នុងស្នាដៃនិពន្ធរបស់ខ្ញុំនេះ ខ្ញុំបានព្យាយាមអស់ពីសមត្ថភាពក្នុងការដើរតាមការណែនាំដ៏ល្អរបស់ សូរក្សា ធ្វើយ៉ាងណាដើម្បីបញ្ជាក់ជាកសិណដល់ជនរងគ្រោះ ក្រោបនូវអ្វីដែលនាំឲ្យមន្ទីរស-២១ កើតឡើង និងគិតពិចារណាអំពីអ្វីដែលនាំឲ្យស្ថាប័នប្រហាក់ប្រហែលគ្នានេះកើតឡើងក្នុងអតីតកាល និងដែលអាចកើតឡើងសាជាថ្មី ។ ដើម្បីធ្វើកិច្ចការនេះបាន ខ្ញុំត្រូវតែពុះពារជម្នះរាល់ការរួញរាស្ទាក់ស្ទើរមិនហ៊ានចូលទៅជិត ការរួញរាមិនហ៊ានចូលរួមទទួលខុសត្រូវនូវអ្វីដែលបានកើតឡើងនិងការចង់រក្សានូវគុណភាពឲ្យដល់កម្រិត ។ ខ្ញុំចាំបាច់ត្រូវព្យាយាមរកពាក្យអ្វីឲ្យសម ប៉ុន្តែអ្វីដែលបានកើតឡើងនៅក្នុងគុកនោះ វាពិតជាមានទម្ងន់ខ្លាំងជាងពាក្យដែលយកមកប្រើទៅទៀត ។ ក្នុងនាមជាប្រវត្តិវិទូ និងជានិស្សិតផ្នែកអក្សរសាស្ត្រ ខ្ញុំបានព្យាយាមអស់ជាច្រើនឆ្នាំក្នុងការគ្រប់គ្រងទិន្នន័យដែលខ្ញុំយកមកសរសេរ ហើយស្វែងយល់នូវរាល់សំណេរដែលខ្ញុំបានអាន ។ នៅពេលខ្ញុំជ្រមុជខ្លួនចូលទៅក្នុងបណ្ណសារមន្ទីរស-២១ ភាពព្រឺខ្លាចដែលសម្ងំលាក់ខ្លួននៅខាងក្នុងបានធ្វើឲ្យខ្ញុំទៅនេះបន្តិចទៅនោះបន្តិច ធ្វើឲ្យជំនាញផ្ទាល់ខ្លួនរបស់ខ្ញុំរេចរឹល និងធ្វើឲ្យខ្សោះដល់ការទុកចិត្តរបស់ខ្ញុំផ្ទាល់ ។ បទពិសោធន៍កាលនោះគឺត្រូវលិចលង់អស់ហើយ ។

ម៉ាសេឡូ ស៊ូរ៉េ អូរ៉ូស្កូ ដែលបានសរសេរប្រធានបទនៃអំពើឃោរឃៅនៅប្រទេសអាហ្សង់ទីននៅទសវត្សរ៍ឆ្នាំ១៩៧០ បានលើកឡើងអំពីបុគ្គលដែលមានការស្ទាក់ស្ទើរក្នុងការប្រឈមមុខនិងវិភាគលើបាតុភូតនេះ ។ លោកបានសរសេរថា អ្នកកំសាកទាំងនេះបានអះអាងថា «ឯកសារទាំងនេះគួរឲ្យខ្លាចណាស់ មិនអាចធ្វើការវិភាគដោយគ្មានភាពលម្អៀងបានទេ ។ រាល់ការប៉ុនប៉ងក្នុងការវិភាគឯកសារនេះនឹងរំលោភដល់ប្រធានបទដ៏ធំនិងស្មុគស្មាញនេះមិនខាន ។ នៅចុងបញ្ចប់ ការវិភាគបង្កើតសាជាថ្មីនូវអំពើឃោរឃៅតាមរបៀបរបស់ផ្សេងទៀត» ។ ស៊ូរ៉េ អូរ៉ូស្កូ ទាញសេចក្តីសំអាងទៀតថា ការវិភាគទៅលើភាពគួរឲ្យព្រឺខ្លាចត្រូវតែបន្តទៅមុខ ទោះបីជាឯកសារទាក់ទងនិងប្រធានបទនេះ «ខ្វះនូវទំនុកចិត្តថា វានឹងឃ្លាតចាកពីភាពព្រឺខ្លាចពិតប្រាកដ» យ៉ាងណាក៏ដោយចុះ ។ នេះមិនមែនដោយសារការយល់នូវអ្វីដែលបានកើតឡើងនេះធ្វើឲ្យយើងអត់ឱនទោសឲ្យជនដៃដល់ទេ តែគឺដោយសារ «ភាពព្រឺខ្លាចគឺជាផ្នែកមួយនៃជីវិតរស់នៅប្រចាំថ្ងៃ» ។[៨] លោកមានប្រសាសន៍ថា នៅពេលប្រឈមមុខនឹងភាពព្រឺខ្លាចនេះ យើងកំពុងតែប្រឈមមុខនឹងអ្វីដែលមិនត្រឹមតែមាន «នៅទីនោះ» ទេ តែក៏មាននៅក្នុងខ្លួនរបស់យើងដែរ ។ មន្ទីរស-២១ នៅជិតយើងជាងយើងគិត ។ ហេតុនេះ នៅទន្ទឹមពេលនៃការព្យាយាមសរសេរប្រវត្តិសាស្ត្រកន្លែងនេះឲ្យ «ត្រូវតាមសភាពពិតតាមតែអាចធ្វើទៅបាន» ខ្ញុំបានព្យាយាមស្វែងរកពត៌មានទាក់ទងនឹង «ភាពធម្មតា» ដែលលោក ស៊ូរ៉េ អូរ៉ូស្កូ បានលើកឡើងនេះ ។ ប្រសិនបើ«មន្ទីរស-២១» មាននៅគ្រប់ទីកន្លែង ហើយយើងនៅក្នុងនោះដែរនោះ ពិតជារីវរជាមិនខាន ប៉ុន្តែវាងាយស្រួលក្នុងការពន្យល់ឲ្យបានក្បោះក្បាយ ។

នៅឆ្នាំ១៩៧១ អ្នកសារពត៌មានជនជាតិអង់គ្លេសម្នាក់ឈ្មោះ ហ៊ីតា សិរីនី បានចំណាយពេលជាច្រើនសប្តាហ៍ធ្វើកិច្ចសម្ភាសន៍ជាមួយឧត្តមសេនីយ៍ឯកម្នាក់ ដែលគ្រប់គ្រងបញ្ជាជំរំមរណៈនៅទ្រឹប្លីងកា ។ នៅទីនោះមានមនុស្សជាងមួយលាននាក់ដែលភាគច្រើនជាជនជាតិជ្វីហ្វត្រូវបានសម្លាប់ចាប់ពីឆ្នាំ១៩៤១ ដល់ឆ្នាំ១៩៤៣ ។ ស្តាងហ្គល ត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៦៧ នៅប្រទេសប្រេស៊ីល ដែលនៅក្នុងប្រទេស

នោះ គាត់រស់នៅក្រោមឈ្មោះពិតរបស់គាត់ផ្ទាល់ ពោលគឺគាត់មិនបានផ្លាស់ឈ្មោះថ្មីទេ ។ នៅពេល ស៊ីវ៉ៃនី និយាយទៅកាន់ ស្តាងហ្គុល ស្តាងហ្គុល ត្រូវបានគេកាត់ទោសរួចហើយនៅឌូសេលដូហ្វ ពីបទបានធ្វើសកម្មភាពនៅក្នុងសង្គ្រាមលោកលើកទីII និងត្រូវបានកាត់ទោសឲ្យជាប់គុកអស់មួយជីវិត ។ គាត់បានស្លាប់បាត់បង់ជីវិតនៅក្នុងគុកក្នុងឆ្នាំ១៩៧២ ដោយសារជំងឺគាំងបេះដូងក្រោយពេល ស៊ីវ៉ៃនី សម្ភាសគាត់រួចនិងមុនពេលនាងចេញផ្សាយសៀវភៅនេះ ។

នៅក្នុងកិច្ចសម្ភាសន៍ ស្តាងហ្គុល បានខ្នះខ្នែងជួយនិងខំរៀបរាប់ប្រៀបធៀបពីការចិញ្ចឹមបីបាច់របស់កាតូលិក និងកិត្តិយសរបស់ខ្លួនឯងដែលធ្លាប់ធ្វើជាប៉ូលិស ជាមួយនឹងអ្វីដែលគាត់បានឃើញនិងបានធ្វើនៅក្នុងសង្គ្រាមលោកលើកទីII ។ ស៊ីវ៉ៃនី គួរសមជាមួយគាត់ណាស់ ប៉ុន្តែព្យាយាមស្រង់យកពត៌មានពីគាត់អស់ពីសមត្ថភាពដែលអាចធ្វើទៅបាន ។ នៅពេលសួរត្រង់ចំណុចថា ហេតុអ្វីបានជាណាហ្ស៊ីសម្លាប់ជនជាតិជ្វីហ្វ ស្តាងហ្គុល ឆ្លើយថា ពីព្រោះពួកណាហ្ស៊ី «ចង់បានលុយពីជនជាតិជ្វីហ្វ» ។ បន្ទាប់មក ស៊ីវ៉ៃនី ក៏សួរទៀតថា «ប្រសិនបើគេចង់សម្លាប់ជនជាតិជ្វីហ្វចោលទាំងអស់ តើចាំបាច់ធ្វើអំពើគួរឲ្យអាម៉ាស់និងអំពើឃោរឃៅយ៉ាងនេះធ្វើអ្វី?» ។ ស្តាងហ្គុល តបវិញថា «គឺដើម្បីលត់ដំអ្នកដែលត្រូវអនុវត្តនយោបាយ ។ ដើម្បីឲ្យគេអាចធ្វើអ្វីដែលគេបានធ្វើកន្លងមកនេះ» ។

ស្តាងហ្គុល បញ្ជាក់ថាពេលវេលាចេះតែកន្លងទៅ អ្នកធ្វើការនៅ ទ្រីប្លីងកា ក៏លត់ដំសម្របខ្លួនបានក្នុងការអនុវត្តការកិច្ចដ៏គួរឲ្យព្រឺខ្លាចទាំងអស់នេះតាមរយៈការយល់ព្រមនិងការជំរុញលើកទឹកចិត្ត ហើយពេលនោះជនរងគ្រោះគ្មានន័យសម្រាប់អ្នកទាំងនេះឡើយ ហើយជាទូទៅជនរងគ្រោះថែមទាំងត្រូវបានចាត់ទុកថា មិនមែនជាពូជសាសន៍មួយក្នុងចំណោមមនុស្សជាតិទាំងមូលទៀតផង ។ ក្នុងលក្ខណៈប្រហាក់ប្រហែលគ្នានេះដែរ «កូនប៉ូលិសធម្មតា» នៅវរសេនាតូចប៉ូលិសបម្រុង ស-ស ដែល គ្រីសស្តូហ្វ័រ ប្រោនីង បានលើកមករៀបរាប់ មុនដំបូងមានការប្រឆាំងជំទាស់មិនព្រមអនុវត្តអំពើបែបនេះទេ តែក្រោយមកបានសម្លាប់រង្គាលជនជាតិជ្វីហ្វរាប់ពាន់នាក់នៅប្រទេសប៉ូឡូញក្នុងឆ្នាំ១៩៤១ ។[៩] ចំណែកឯអ្នកធ្វើការនៅមន្ទីរស-២១វិញ ដំណើរការតឹងតែងប្រហាក់ប្រហែលគ្នានេះត្រូវបានរឹតបន្តឹងមិនមែនត្រឹមតែដោយសារការគិតថា មាន «ខ្មាំង» គ្រប់ទីកន្លែងនៅពាសពេញប្រទេសកម្ពុជាប៉ុណ្ណោះទេ តែដោយវិន័យគ្មានមេត្តានៅមន្ទីរនេះផ្ទាល់តែម្តង ។ ប្រសិនបើអ្នកធ្វើការក្នុងគុកមិនព្រមធ្វើការឬធ្វើការយឺត ឆ្មាំនិងអ្នកសួរចម្លើយនៅមន្ទីរស-២១ប្រហែលជាក្លាយជាជនរងគ្រោះមួយរំពេច មិនដូចជាអ្នកធ្វើការនៅជំរំណាហ្ស៊ីទេ ។ មិនយូរប៉ុន្មានជនរងគ្រោះទាំងនេះទទួលរងនូវការងារជាទម្ងន់ ។ ដូចដែល គក ស្រស់ បានរំឭករឿងចាស់ថា «ខ្ញុំព្យាយាមធ្វើការយ៉ាងសកម្ម ។ បើខ្ញុំស្លាប់ក៏ស្លាប់ទៅចុះ ។ ធ្វើប៉ុណ្ណឹងដែរនៅតែស្លាប់ទៀតក៏ស្លាប់ចុះ វាប្រសើរជាងស្លាប់ដោយសារមិនបានធ្វើការគ្រប់គ្រាន់» ។[១០]

ចំពោះ គក ស្រស់, ស្តាងហ្គុល និង «កូនប៉ូលិសធម្មតា» ដែល ប្រោនីង បានលើកឡើង សារសំខាន់នៃការធ្វើការងារបានល្អវាលប់លើអ្វីដែលអ្នកទាំងនេះបានធ្វើបាត់ទៅហើយ ។ ក្នុងនាមជានាយក ទ្រីប្លីងកា ស្តាងហ្គុល ជឿជាក់ថា គាត់បានទប់ស្កាត់មិនឲ្យមានអំពើឃោរឃៅដ៏ព្រៃផ្សៃនេះកើតឡើងបាន តាមរយៈ

ការធ្វើការងារយ៉ាងខ្លាំង និងសម្របខ្លួនតាមរបៀបបញ្ជាការមិនលម្អៀងនិងមានមនសិការ ។ ស្តាងហ្កុល បានប្រាប់ទៅ ស៊ឺរ៉េនី ថា "ពិតណាស់ការគិត (ដល់អ្វីដែលកើតឡើងនៅទ្រឹប្លីងកា) ក៏មានដែរ ។ ប៉ុន្តែខ្ញុំបានបង្វែការគិតនេះឲ្យចេញពីក្បាលអស់ ។ ខ្ញុំគិតតែពីរឿងការងារ ធ្វើហើយធ្វើទៀត ធ្វើមិនឈប់ឈរ" ។[១១] ប៉ុន្តែ ស្តាងហ្កុល និយាយថា ទោះជាយ៉ាងដូច្នេះក៏ដោយ គាត់ត្រូវការផឹកស្រាជាច្រើនកែវនៅពេលយប់ ដើម្បីបំបាត់ការស្មុគស្មាញមុនពេលចូលដេក ។

ក្រោយពីយល់ស្របនឹងអ្វីដែល ស្តាងហ្កុល បាននិយាយនេះមក ស៊ឺរ៉េនី បានសរសេរថា "ដើម្បីសម្រេចនូវការសម្លាប់មនុស្សរាប់លានទាំងស្រី ទាំងប្រុស ទាំងចាស់ ទាំងក្មេង ណាហ្ស៊ីបានសម្លាប់ទាំងរាងកាយនិងស្មារតីទៅលើអ្នកដែលខ្លួនសម្លាប់ អ្នកដែលធ្វើការកាប់សម្លាប់មនុស្ស អ្នកដែលដឹងថា ការសម្លាប់កំពុងតែកើតឡើង ហើយក្នុងកម្រិតណាមួយនោះ...សម្លាប់ទាំងរាងកាយនិងស្មារតីមកលើយើងរាល់គ្នាតែម្តងដែលមានជីវិតនិងជាសត្វលោកមានសតិសម្បជញ្ញៈនៅកាលនោះ" ។[១២] យោបល់របស់ ស៊ឺរ៉េនី បញ្ជាក់ថា ដើម្បីសម្រេចគោលដៅមនុស្សឃាតនៅទ្រឹប្លីងកា ណាហ្ស៊ីអាចពឹងផ្អែកទៅលើការស្លាប់ខាងស្មារតីរបស់ពិភពលោកទាំងមូលតែម្តង ។ នៅក្នុងន័យប្រហាក់ប្រហែលគ្នានេះ ខ្ញុំសូមនិយាយថា យើងបង្កើតឲ្យមានសំណេរអំពីមន្ទីរស-២១ឡើង ពីព្រោះភាគច្រើននៃយើងទាំងអស់គ្នាព្រងើយកន្តើយទៅនឹងបាតុភូតមានចរិតបែបនេះដែលកើតឡើងនៅឆ្ងាយពីអ្នកដទៃ ។ យើងគិតថា អំពើអាក្រក់កើតឡើងនៅគ្រប់កន្លែង ។[១៣]

ប៉ុន្តែទោះជាយ៉ាងនេះក្តី ព្រេានីង ស៊ឺរ៉េនី និងអ្នកនិពន្ធផ្សេងទៀតអះអាងថា ដោយស្ថិតនៅក្រោមសភាពធ្ងន់ធ្ងរដូចជាអ្វីដែលត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងសង្គ្រាមលោកលើកទីII កម្រិតព្រំដែននៃការប្រព្រឹត្តិបែបនេះមិនអាចទាញចេញជារូបភាពពិតបានឡើយ ។ ប្រ៊ីម៉ូ លីវី បានសរសេរថា "តំបន់ស្រអាប់" បានបង្កើតឲ្យមានឆ្មាំ និងអ្នកទោសជាច្រើននាក់នៅអូសឈ្វិច ។ ព្រេានីង ហៅ "តំបន់" នេះ តាមទស្សនៈរបស់ជនដៃដល់ថា ជា"ពិភពមិនច្បាស់លាស់មួយប្រកបដោយហេតុផលជំរុញ សតិអារម្មណ៍ ទំនាស់ និងអាទិភាពចម្រុះ ជម្រើសស្មុគស្មាញ និងឱកាសនិយមសម្រាប់បម្រើផលប្រយោជន៍ផ្ទាល់ខ្លួន ព្រមទាំងការសម្របខ្លួនទៅនឹងទម្លាប់មួយដែលភូតកុហកនិងបដិសេធខ្លួនឯង" ។ ក្នុងន័យម្យ៉ាង នៅមន្ទីរស-២១ គ្មានតំបន់បែបនេះទេ ពីព្រោះគ្មានការសមគំនិតគ្នារវាងជនរងគ្រោះ ជនដៃដល់ និង អ្នកមកពីពិភពខាងក្រៅក្នុងការកសាងតំបន់នេះ ។ ប៉ុន្តែ អ្នកទោសនៅមន្ទីរស-២១ មិនអាចក្លាយជាអ្នកសួរចម្លើយឬឆ្មាំគុកក៏ពិតមែន ប៉ុន្តែបុគ្គលិកគុកនៅមន្ទីរស-២១ អាចក្លាយជាអ្នកទោសមួយរំពេច ។ ក្នុងន័យនេះ ម្នាក់ៗនៅមន្ទីរស-២១ សុទ្ធតែរស់នៅក្នុងតំបន់ស្រអាប់គ្រប់ពេលវេលា ។[១៤]

ដើម្បីឲ្យកាន់តែស៊ីជម្រៅថែមទៀត យើងចាំបាច់ត្រូវចាំថា មនុស្សធ្វើការនៅជំរំណាហ្ស៊ីនិងមន្ទីរស-២១ មិនសាហាវនិងផ្តាច់ការដូចគ្នាទេ ។ ភាគច្រើននៃអ្នកទាំងនោះមានលក្ខណៈដូចគ្នាត្រង់ថា មិនចេះអក្សរឬមិនសូវបានរៀនសូត្រ ។ បុរស ស្ត្រីទាំងនេះត្រូវបានបង្ហឹកឲ្យដើរតួយ៉ាងសាហាវយង់ឃ្នង ។ ពិបាកកំណត់ណាស់ថា តើការជ្រើសរើសដោយសេរី ការគាបសង្កត់ប្រហាក់ប្រហែលគ្នា ការគោរពបញ្ជា និង

មហិច្ឆតាមានកម្រិតត្រឹមណាទេនៅក្នុងអ្វីដែលគេបានធ្វើកន្លងមក ។ អ្វីដែលយើងដឹងអំពីអ្នកធ្វើការនៅមន្ទីរស-២១ ក្នុងករណីភាគច្រើនដូចដែលការសិក្សាស្រាវជ្រាវរបស់លោក ប្រោននីង បញ្ជាក់ស្រាប់ គឺភាពសាមញ្ញនិងភាពគ្មានខ្លឹមសាររបស់អ្នកធ្វើការនៅក្នុងមន្ទីរ ។ ដោយស្ថិតនៅជាមួយមនុស្សដូចខ្លួនឯងដែរ និងគោរពអ្នកទទួលខុសត្រូវក្បាលដល់ដី អ្នកធ្វើការនៅមន្ទីរស-២១ ក៏ដូចជាអ្នកទោសដែរ ត្រូវជាប់អន្ទាក់នៅក្នុងកន្លែងមួយដែលគ្មានក្តីមេត្តានិងអាណិតអាសូរ ។

ការស្ថិតនៅក្នុងអន្ទាក់និងការប្រព្រឹត្តិអំពើយ៉ាងដូច្នេះ មិនចាំបាច់តែនិយាយដល់រឿងនៅទ្រីប្លីងកាអូសឈ្វិច ឬនៅមន្ទីរស-២១ឡើយ ។ ដំណើរការនេះត្រូវបានស្តែងចេញគួរឲ្យភ្ញាក់ផ្អើលក្រោមលក្ខខណ្ឌនៃការចេះដឹង សមរម្យ និងថ្លៃថ្នូរនៅ ប៉ាឡូ អាល់តូ រដ្ឋកាលីហ្វ័រញ៉ា ពីរបីឆ្នាំមុនពេលមន្ទីរស-២១ចាប់ផ្តើមប្រវត្តិប្រតិបត្តិការរបស់ខ្លួន ។ នៅក្នុងការពិសោធន៍ដែលគេហៅថា ហ្ស៊ីមបាដូ នៅក្នុងឆ្នាំ១៩៧១ ក្រុមនិស្សិតបញ្ចប់ឧត្តមសិក្សាមួយក្រុមនៃសាកលវិទ្យាល័យស្តែនហ្វ័រដ៍ដែលសុទ្ធតែជាអ្នកស្ម័គ្រចិត្ត ត្រូវបានរៀបចំឲ្យដើរតួគ្រាប់តាមវប្បធម៌ ការអនុវត្តជាក់ស្តែង និងទំនាក់ទំនងអំណាចនៃគុកមួយរបស់អាមេរិកាំង ។ នៅខណៈពេលដែល"ឆ្មាំ"សប្បាយចិត្តនឹងការផ្តល់អំណាចមកឲ្យខ្លួន ហើយ"អ្នកទោស"មានការភ័យខ្លាចនិងត្រូវបំបាត់ភាពជាមនុស្សចេញពីខ្លួននោះ ការពិសោធន៍នេះចេះតែធ្វើទៅមុខដោយគ្មានអ្នកណាគ្រប់គ្រងបាន ។ ការសាកល្បងនេះត្រូវបានបញ្ឈប់ឲ្យខ្លីកុំឲ្យតួអង្គម្នាក់ៗមានការឈឺចាប់ទាន់ ។[១៥]

ការសម្តែងមួយទៀតត្រូវបានរៀបចំឡើងនៅសហរដ្ឋអាមេរិកនៅដើមទសវត្សរ៍ឆ្នាំ១៩៦០ ដោយស្តេនលី មីលក្រាម ផ្តល់នូវទិដ្ឋភាពកាន់តែជ្រៅថែមទៀត ។ អ្នកស្ម័គ្រចិត្តនៅទីក្រុងញូហេវិន រដ្ឋខណេធិខិតត្រូវបាន"ចិត្តវិទូខាងអប់រំ" ឲ្យអង្គុយក្នុងបន្ទប់មួយ ហើយឲ្យដើរតួជា"គ្រូបង្រៀន" ។ (សិស្សមហាវិទ្យាល័យត្រូវបានហាមប្រាមមិនឲ្យចូលរួមជាមួយទេ) ។ អ្នកស្ម័គ្រចិត្តទាំងនោះ បន្ទាប់មកត្រូវបានឲ្យចុចកុងតាក់ឆក់ខ្សែភ្លើងចំពោះការឆ្លើយណា "មិនត្រឹមត្រូវ" ទៅនឹងសំណួររបស់ "ចិត្តវិទូខាងអប់រំ" ។ សំណួរទាំងអស់គឺទុកឲ្យខាងនិស្សិតជាអ្នកឆ្លើយដែលស្ថិតនៅក្នុងបន្ទប់ផ្សេងមិនអាចមើលគ្នាឃើញ តែស្តាប់ឮ ។

តាមការពិតគ្មានចរន្តឆ្លងកាត់នៅក្នុងកុងតាក់ដែលខាងលោកគ្រូចុចទេ ហើយនិស្សិតជាអ្នកដើរតួ ។ ចំណែកនិសិត្សទាំងអស់លោក មីលក្រាម ជាអ្នកជួលមក ។ នៅពេល "កំហុស" របស់និស្សិតចេះតែកើនឡើងច្រើនទៅៗ អាំងតង់ស៊ីតេនៃការឆក់ចេះតែកើនឡើងរហូតដល់គ្រូមួយចំនួនចុចដល់កម្រិតខ្លាំងបំផុតដែលស្តាប់ទៅពិតជាគួរឲ្យឈឺចាប់និងគ្រោះថ្នាក់ ពោលគឺជាការស្តែងចេញតាមរយៈការសង្កត់កុងតាក់ដោយមេដៃស្រែកខ្លាំងៗនិងភាពស្ងាត់ជ្រងំពីបន្ទប់នៅជាប់គ្នា ។ ប៉ុន្មានថ្ងៃក្រោយមកមានតែគ្រូមួយនាក់ក្នុងគ្រូបីនាក់នៃគ្រូទាំងអស់បានបដិសេធនូវអ្វីដែលបានកើតឡើងឬឈប់ធ្វើពិសោធន៍តែម្តង ។ពីរឆ្នាំក្រោយមកទៀតក៏មានការពិសោធន៍តាមរបៀបផ្សេងៗដែរ ។ ដូចជាយកអ្នកទាំងនេះទៅទីក្រុងមមាញឹកមួយ គឺទីក្រុងប្រ៊ីចផត ឲ្យគ្រូនិងសិស្សទាក់ទងគ្នាដោយផ្ទាល់ ឲ្យមានចំនួនស្ត្រីច្រើននៅខាងក្រុមគ្រូៗនិងប្តូរចិត្តវិទូចេញទៅកន្លែងផ្សេង ។ លទ្ធផលភាគច្រើននៅតែដូចគ្នាដដែល ។ ការពិសោធន៍ទាំងអស់ដែលបានធ្វើមក ដែលមានករណីលើកលែងតិចបំផុតបង្ហាញថា "ពីរភាគបីនៃជនជាតិអាមេរិកាំងទូទៅ (ក្នុងចំនួនមនុស្សដែលយកមក

ធ្វើពិសោធន៍) ចង់ឆក់ជនរងគ្រោះដែលស្លូតត្រង់រហូតដល់គាត់ស្រែកសុំជីវិតរស់ ហើយចង់បន្តឆក់ជនរងគ្រោះនេះរហូតដល់ដួលស្រ៊ុបបាត់មាត់ឈឹងតែម្តង ។[១៦] នេះជាអ្វីដែល អាឡាំង អែម្ស បានសរសេរ ។

នៅក្នុងការសិក្សាពិសោធន៍មួយទៀត ចន ដាលី ឲ្យយោបល់ថា ការគោរពគ្រូត្រូវបានធ្វើឲ្យស្របទៅតាមវត្តមាននៃអ្នកធ្វើពិសោធន៍ដែលត្រូវបានឲ្យបញ្ជាក់ពីអំពើឃោរឃៅទ្រង់ទ្រាយធំ ។ ចន ដាលី និយាយថា ដោយត្រូវគេបណ្តោយឲ្យធ្វើអ្វីៗស្រេចតែចិត្ត គ្រូៗនឹងមិនមើលការខុសត្រូវចំពោះការឆក់ខ្សែភ្លើងឡើយ ។ ដូច្នេះតាមដែលលោកទាញហេតុផលគឺវាធ្វើឲ្យមានចន្លោះរវាងគ្រូៗដែល មើលក្រាម រៀបចំនិងអ្នកដែលប្រព្រឹត្តអំពើឃោរឃៅ ។ ចន ដាលី បន្ថែមទៀតថា ធ្វើឲ្យមនុស្សហ៊ានប្រព្រឹត្តអំពើឃោរឃៅគឺទាក់ទងនឹងពេលវេលា ។

អាឡិចហ្សាន់ឌ័រ ហ៊ីនតុន បានទាញហេតុផលថា ការគោរពដល់ថ្នាក់នេះកើតឡើងស្ទើរតែគ្រប់ពេលនៅក្នុងការពិសោធន៍ទាំងនេះ ហើយវាកាន់តែជ្រាលជ្រៅជាងនេះទៅទៀតនៅក្នុងវប្បធម៌ខ្មែរ ។ ខ្ញុំសូមនិយាយថាការកម្ទេច“ខ្មាំង”នៅមន្ទីរស-២១ ត្រូវបានធ្វើឡើងដោយងាយ គឺដោយសារការយល់ព្រមនិងគោរពដែលមានជាប្រពៃណីទៅហើយ នៅក្នុងសង្គមខ្មែរពីសំណាក់អ្នកតូចទាបចំពោះអ្នកមានអំណាច ។ វប្បធម៌កេងប្រវ័ញ្ច ការពារ គោរព និងពឹងពាក់ទាំងអស់នេះបានចាក់ឫសគល់យ៉ាងជ្រៅនៅក្នុងការអនុវត្តជាក់ស្តែងនៅក្នុងសង្គមកម្ពុជានិងពង្រឹងការក្តាប់អំណាចរបស់អ្នកកាន់អំណាចនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បើទោះបីជាឫដោយសារអ្នកកាន់អំណាចបញ្ជាក់ហើយបញ្ជាក់ទៀតថា ទំនាក់ទំនងអំណាចមុនបដិវត្តន៍ត្រូវបានកម្ទេចចោលអស់ហើយក៏ដោយ ។[១៧] ឋានានុក្រម ការគួរសមនិង“ការគោរពសំពះ”ដែលបង្ហាញយ៉ាងច្បាស់ពី“ការជិះជាន់”មិនត្រូវបានលុបបំបាត់ដោយសារបដិវត្តន៍ទេ ។ ប៉ុន្តែនៅមានភាពលម្អៀងនៅក្នុងរូបភាពថ្មីជាចៅហ្វាយ និងអ្នកបម្រើ (ដូចជាការ “ទទួលអំណាច” និងចាត់តាំងឲ្យធ្វើជាកម្មាភិបាល) និងជនរងគ្រោះបែបថ្មី ។ នៅក្រោមវិន័យរបស់ខ្លួនអ្នកនៅមន្ទីរស-២១ ត្រូវបានបែងចែកជា÷ ម្ខាងជាអ្នកបញ្ជាឬប្រើអ្នកដទៃ និងអ្នកស្តាប់ដែលគេដាក់ឲ្យប្រើអ្នកបម្រើ រីឯម្ខាងទៀតជាជនរងគ្រោះទូទៅ ។ ក្នុងផ្លូវខ្លះសង្គម“ថ្មី”មានចម្រុះដោយបញ្ហានេះដូចពីមុននិងក្រោយការប្រើអំណាចនិងគោរពអំណាចបដិវត្តន៍ដែរ ។[១៨]

ទោះជាអ្នកសួរចម្លើយនៅមន្ទីរស-២១ ធ្លាប់មានសេចក្តីស្មោះត្រង់ចំពោះអ្នក“នៅពីលើ”ខ្លួន ហើយទោះជាទំនាក់ទំនងរវាងអ្នកសួរចម្លើយនិងអ្នកទោសនៅរាល់ស្ថាប័នតែងតែមានភាពស្មុគស្មាញក៏ដោយ ប៉ុន្តែ “ភាពមានប្រៀប” របស់អ្នកសួរចម្លើយនៅមន្ទីរស-២១ បើតាមរយៈសៀវភៅរបស បុ៊ន គឺថា អ្នកទោស “ស្ថិតនៅក្នុងដៃ (របស់អ្នកសួរចម្លើយ)” ។ គ្មានការអនុវត្តកំហិតជាលក្ខណៈច្បាប់ គ្មានសម្ពាធពីខាងក្រៅរដ្ឋាភិបាល និងគ្មានពេលកំណត់ជាក់លាក់ឡើយ ។ ដរាបណាអ្នកសួរចម្លើយសួរអ្នកទោសដោយសន្ទាប់ និងធ្វើទារុណកម្មគ្រប់គ្រាន់ដើម្បីទទួលចម្លើយសារភាព ហើយអ្នកសួរចម្លើយអាចធ្វើអ្វីបាន ស្រេចតែចិត្តតាមខ្លួនយល់ថាសមរម្យ ។[១៩]

គិតដល់អំណាចរបស់អ្នកសួរចម្លើយនិងភាពគ្មានអំណាចទាល់តែសោះរបស់អ្នកទោស ព្រមទាំងដំណើរការសួរចម្លើយនៅមន្ទីរស-២១ ធ្វើឲ្យនឹកឃើញដល់រឿងល្បើកដែលជាស្នាដៃនិពន្ធរបស់ ឡា ហុងតែន

ដែលនិយាយពីចចកនិងកូនចៀម ។ នៅក្នុងរឿងព្រេងនេះ ចចកបានជួបនឹងកូនចៀមមួយនិងសុំសម្លាប់ចៀមនោះ ពីព្រោះកូនចៀមនេះបើតាមចចកនិយាយថា បានធ្វើឲ្យខ្លួនអាម៉ាស់មុខ "មួយឆ្នាំមកហើយ" ។ នៅពេលកូនចៀមឆ្លើយថា កាលពីឆ្នាំមុនវាមិនទាន់កើតផង រំពេចនោះចចកក៏តបវិញថា "ប្រសិនបើមិនមែនឯងក៏បងរបស់ឯងដែរ" ។ ចៀមឆ្លើយប្រាសវិញថា "ខ្ញុំគ្មានបងទេ" ។ "អ៊ីចឹងមានតែបងប្អូនឯង គង្វាលរបស់ឯង ឬ ឆ្កែរបស់ឯង" ចចកសឹកសម្ដីរួចហើយក៏ស៊ីកូនចៀមតែម្ដងទៅ ។[២០]

នៅក្នុងជំពូកទី៥ យើងបានពិនិត្យករណីមួយចំនួនដែលកើតមានឡើងពីមុននៅក្នុងអតីតកាលរបស់ប្រទេសកម្ពុជាលើអំពើឃោរឃៅនៅមន្ទីរស-២១ និងផ្លូវនានាដែលទារុណកម្មក្នុងគុកក្លាយជាពាក្យពន្យល់របស់ ហ៊ុខល ដែលថា "ការសងសឹករបស់អ្នកកាន់អំណាច" ។ យើងក៏ដឹងថា ភាពដាច់ខាតនិងហ្មត់ចត់នៅមន្ទីរស-២១ ស្រដៀងគ្នាទៅនឹងគំរូពិសេសៗមួយចំនួននៅសតវត្សរ៍ទី២០ ដែលមួយផ្នែកភ្ជាប់ទៅនឹងការអនុវត្តតាមបែបកុម្មុយនិស្ត និងមួយផ្នែកទៀតទាក់ទងនឹងប្រព័ន្ធស៊ើបការណ៍សម្ងាត់ទំនើប ។ គំរូសម្រាប់មន្ទីរស-២១ រួមមានការកាត់ក្ដីនៅមូស្គូដែលគ្រាន់តែឲ្យល្អមើលនិងវិសុទ្ធកម្មនៅក្នុងទសវត្សរ៍ឆ្នាំ១៩៣០ និង "យុទ្ធនាការអប់រំកសាង" នៅប្រទេសចិនក្រោមអំណាចរបស់ ម៉ៅ សេទុង និងវៀតណាមកុម្មុយនិស្ត ។ មន្ទីរស-២១ នាំដល់គំនិត"យុត្តិធម៌បដិវត្តន៍"របស់បារាំង ។ នៅទសវត្សរ៍ឆ្នាំ១៧៩០ យុត្តិធម៌បដិវត្តន៍បានឡើងដល់កំពូល បើនិយាយតាមន័យភាសាវិទ្យាថា ពាក្យថ្មីប្រឆាំងនឹងបដិវត្តន៍និងអ្នកប្រឆាំងនឹងបដិវត្តន៍ដែលអនុញ្ញាតឲ្យអ្នកគាំទ្រមានសេរីភាពយ៉ាងពេញទំហឹង ។ សារសំខាន់នៃពាក្យទាំងពីរម៉ាត់នេះអាចប្រែប្រួលពីមួយថ្ងៃទៅមួយថ្ងៃ ។[២១] នៅមន្ទីរស-២១ ពាក្យថា "ខ្មាំង" មានន័យប្រែប្រួលពីមួយថ្ងៃទៅមួយថ្ងៃដូចជាពាក្យខាងលើនេះដែរ ។

មជ្ឈិមបក្សបានអនុម័តនូវមនោគមវិជ្ជាពីរបបកុម្មុយនិស្តដទៃទៀតដែលថា ថ្នាក់ដឹកនាំបក្សកុម្មុយនិស្តដែលមិនប៉ះពាល់ក្រមច្បាប់គហបតីឬប្រព័ន្ធតុលាការមិនល្អនោះមានសិទ្ធិពេញលេញក្នុងការដាក់ទណ្ឌកម្មទៅលើខ្មាំងរបស់រដ្ឋ ។ ថ្នាក់ដឹកនាំត្រូវបានផ្ដល់អំណាចឲ្យធ្វើយ៉ាងដូច្នេះ ដោយសារថ្នាក់ដឹកនាំទាំងនោះមានទំនាក់ទំនងពិសេសទៅនឹងច្បាប់ប្រវត្តិសាស្ត្រ ។ តាមគន្លងរបស់ចិននិងវៀតណាមកុម្មុយនិស្តមានគំនិតបដិបក្ខថា យ៉ាងហោចណាស់មានសត្រូវខ្លះអាចយកទៅអប់រំ កសាង និងកែប្រែបាន ពោលគឺជាគំនិតដែលចាក់ឫសគល់យ៉ាងជ្រៅនៅក្នុងប្រទេសទាំងពីរនេះ និងមានការអនុវត្តតិចតួចនៅក្នុងប្រទេសកម្ពុជា ។ ឧបករណ៍សម្រាប់ការកែប្រែនេះរួមមានការទិតៀននិងស្វ័យទិតៀនដែលនិយាយអំពីរឿងផ្ទាល់ខ្លួនជាសាធារណៈ ។ នៅមន្ទីរស-២១ អ្នកទោសបានកែប្រែខ្លួន និងត្រូវបានអប់រំកសាងតាមរយៈចម្លើយសារភាពរបស់ផងខ្លួន ពោលគឺដោយអត្ថបទដែលថ្កោលទោសអ្នកទោសទាំងអស់ដល់ជីវិត ។

អ្វីដែលកើតឡើងនៅមន្ទីរស-២១ គឺ"កម្ពុជា" "កុម្មុយនិស្ត" និង "បរទេស" ដែលមានកម្រិតផ្សេងៗគ្នា ។ ចំនួនមនុស្សស្លាប់យ៉ាងច្រើនសន្ធឹកសន្ធាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យជំរុញឲ្យយើងស្វែងរកការពន្យល់ឲ្យកាន់តែស៊ីជម្រៅថែមទៀតអំពីរបបនេះ ជាពិសេសគឺអំពីមន្ទីរស-២១ តែម្ដង ។ លោក ប៉ែន ឃៀរនិន បញ្ចេញទស្សនៈផ្ទាល់ខ្លួនថា ផ្ទៃរឿងដ៏សំខាន់មួយក្នុងចំណោមផ្ទៃរឿងសំខាន់ពីរគឺ "បញ្ហា

ពូជសាសន៍» ។ ចំណែកឯលោក ម៉ៃឃើល វីករី មានប្រសាសន៍ថា បដិវត្តន៍កម្ពុជាមានលក្ខណៈខុសឆ្ងាយពីបដិវត្តន៍ម៉ាក្ស-ឡេនីន ដែលនិយាយឲ្យចំគឺការផ្ទុះឡើងនូវកំហឹងប្រជាកសិករដែលអួសបន្ទាយនិងមិនអាចគ្រប់គ្រងបាន ។

គំនិតរបស់ ឃៀរនិន គឺមានប្រយោជន៍ ពីព្រោះភាពសាហាវយង់ឃ្នងនិងភាពមិនអើពើរបស់មន្ទីរស-២១ បង្ហាញពីជំនឿមួយថា អ្នកដែលត្រូវសម្លាប់ត្រូវបានចាត់ទុកថា ជាអ្នកដែលមានឋានៈក្រោមមនុស្សទូទៅ ហើយថាមិនមាន «ពូជសាសន៍» ដូចជាឃាតករដែលសម្លាប់ជនរងគ្រោះទាំងអស់នោះទេ ។ ជាការច្បាស់ណាស់ ការប្រឆាំងនឹងពូជសាសន៍វៀតណាមដែលជាគំនិតប្រឆាំងពូជសាសន៍ដ៏ជ្រាលជ្រៅរបស់ខ្មែរក៏គ្របដណ្តប់លើគំនិតពាក្យសម្តីនិងកាយវិការរបស់កម្ពុជាប្រជាធិបតេយ្យដែរ នៅក្រោយឆ្នាំ១៩៧៧ ។ នៅឆ្នាំ១៩៧៨ អ្នកទោសជាច្រើននៅមន្ទីរស-២១ ដែលជាខ្មាំងរបស់រដ្ឋតាមពិតទៅបានក្លាយទៅជាវៀតណាម ។[២២] តាមរបៀបឲ្យអ្នកទោសថ្វាយបង្គំរូប ហូ ជីមិញ និង លីនដុន ចនសុន បង្ហាញថាអ្នកទោសកំពុងត្រូវបានកម្ចាត់ចោលពីទឹកដីកម្ពុជាដែលកាន់កាប់ដោយ ប៉ុល ពត មិនខុសពីអ្វីដែលខ្មាំងពូជសាសន៍របស់ណាហ្ស៊ីធ្វើទេ ។ សូម្បីតែមុនពេលយកទៅសម្លាប់ ក៏ខ្មាំងទាំងនោះត្រូវបានកម្ចាត់ចេញពីទឹកដីអឺរ៉ុបដែលកាន់កាប់ដោយ ហ៊ីត្លែរ ដែរ ។ តាមពិតជនរងគ្រោះភាគច្រើន មានដើមកំណើតជាពូជសាសន៍ដូចជាឃាតកររបស់ខ្លួនដែរ ។ ប៉ុន្តែអ្នកប្រកាន់ពូជសាសន៍បានដើរតួជាអ្នកចាប់ចង ធ្វើទារុណកម្ម និងសម្លាប់ជនរងគ្រោះទាំងនេះ ។ ដោយប្រែក្លាយជនរងគ្រោះឲ្យទៅជា «អ្នកផ្សេង» តាមបែបពូជសាសន៍និងដោយប្រើពាក្យ អា មីង ដូចសត្វធាតុមកលើជនរងគ្រោះ ធ្វើឲ្យឃាតករទាំងនោះមានភាពងាយស្រួលក្នុងការធ្វើបាបនិងសម្លាប់ ។ ដំណើរការប្រហាក់ប្រហែលគ្នានេះដែរ ត្រូវបានអ្នកនិពន្ធនានាលើកឡើងទាក់ទងនឹងការសម្លាប់រង្គាលរបស់ណាហ្ស៊ីទៅលើជនជាតិជ្វីហ្វ និងការសម្លាប់រង្គាលនៅក្នុងឆ្នាំ១៩៦៥ និង១៩៦៦ ។

តាមទស្សនៈរបស់លោក ស្ទីវ ហេដឌ័រ ការប្រកាន់ពូជសាសន៍របស់របបកម្ពុជាប្រជាធិបតេយ្យទៅលើខ្មាំងរបស់ខ្លួនសំខាន់គឺសំដៅទៅលើបុគ្គលដែលមិនចង់និងមិនអាចអនុវត្តបដិវត្តន៍បែបម៉ាក្ស-ឡេនីនច្រើនជាងទៅលើពូជសាសន៍ ។ អ្នកដែលជាមុខសញ្ញាថា គ្មានសមត្ថភាពឬអ្នកប្រឆាំងនឹងបដិវត្តន៍ជាញឹកញាយត្រូវបានហៅថា «វៀតណាម» ។ ហេដឌ័រ សរសេរថា «ការប្រកាន់ពូជសាសន៍របស់របបកម្ពុជាប្រជាធិប-តេយ្យគឺជាលទ្ធផលកើតចេញពីកិច្ចខិតខំប្រឹងប្រែងនានា ដើម្បីឈានទៅរកលោកទស្សនៈបែបប្រវត្តិសាស្ត្រមួយផ្អែកលើការសន្និដ្ឋានដោយគ្មានការពិនិត្យពិច័យនិងរកការពិតឲ្យបានច្បាស់លាស់ទៅលើសក្តានុពលភាពរបស់សញ្ជាតិនិង«ពូជសាសន៍»កម្ពុជា ដើម្បីរួមចំណែកដល់ពិភពលោកទំនើបតាមរយៈការកសាងសង្គមនិយមមហាលោតផ្លោះ មហាអស្ចារ្យ» ។[២៣]

ប៉ុន្តែមានភាពស្របគ្នាទៅនឹងលោក វីក ឃ័ររី ដែលថា ភាពឃោរឃៅរបស់បដិវត្តន៍កម្ពុជាគឺបណ្តាលមកពីកំហឹងកសិករច្រើនជាង ដោយសារការប្រកាន់ពូជសាសន៍ឬលទ្ធិម៉ាក្សឡេនីន ។ វីក ឃ័ររី ទាញហេតុផលថា មជ្ឈិមបក្សត្រូវបានសម្រិតសម្រាំងដោយកំហឹងវណ្ណៈពី «ថ្នាក់ក្រោម» ដែលក្នុងកម្រិតណាមួយប្រហែលជាផ្ទុយនឹងឆន្ទៈរបស់ខ្លួន ។ ការទាញហេតុផលរបស់ វីក ឃ័ររី ដែលប្រហែលគ្នាទៅនឹងចលនា

ម៉ាក្សឡេនីន ដូចជាអនាធិបតេយ្យនិយមរបស់ប្រទេសអេស្ប៉ាញដែរនោះ អាចនិយាយជាសំអាងទៅលើវិសុទ្ធកម្មក្នុងប្រទេសកម្ពុជានៅពាក់កណ្ដាលឆ្នាំ១៩៧៥ និងលើការធ្វើបាប «ប្រជាជនថ្មី» ពីសំណាក់កម្មាភិបាលរបស់កម្ពុជាប្រជាធិបតេយ្យដែលមានក្រោយមកនិងជាពិសេសនៅភូមិភាគពាយ័ព្យ ។ ការនិយមវណ្ណៈកសិករ គឺជាធាតុផ្សំមួយនៃបដិវត្តន៍កម្ពុជា ដូចជាបដិវត្តន៍នៅប្រទេសចិន និងជាការប្រមូលគំហឹងចលនាបដិវត្តន៍ទាំងអស់ ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ការពន្យល់របស់លោក វីក យ័ររី មិនសូវជាមានប្រយោជន៍ទេ នៅពេលយើងបានជួបភ្នំឯកសាររបស់កម្ពុជាប្រជាធិបតេយ្យដែលរួមមានទាំងទិនានុប្បវត្តិផ្នែកទ្រឹស្តីសុន្ទរកថារបស់ថ្នាក់ដឹកនាំ និងឯកសារសៀវភៅកំណត់ហេតុក្នុងកិច្ចប្រជុំស្វ័យទិតៀន ។ ការទាញហេតុផលរបស់លោក វីក យ័ររី បានបំបែកកាន់តែលម្អិតថែមទៀតដោយផ្អែកលើដំណើរការសួរចម្លើយប្រកបដោយវិធីសាស្ត្រ និងជំរុញដោយលទ្ធិកុម្មុយនិស្តនិង «ការឆ្លើយសារភាព» ដែលធ្វើឡើងយ៉ាងខ្ជាប់ខ្ជួននៅមន្ទីរស-២១ ។ ចំពោះរឿងការងារវិញ ឌុច, ចាន់ និង ប៉ុន ដែលជាអ្នកចេះដឹងទាំងអស់ គួរតែបានបង្ហាញនូវសន្តានចិត្តដែលកូនចៅមានចំពោះខ្លួនជាជាងគិតតែពីសន្តានចិត្តរបស់ខ្លួនឯងផ្ទាល់ ។[៧៨]

នៅមន្ទីរស-២១ ដូចយើងឃើញស្រាប់ហើយ ការដាក់ទណ្ឌកម្មតាមលក្ខណៈប្រពៃណីនិងទណ្ឌកម្មតាមគំរូកុម្មុយនិស្តផ្សេងៗទៀតមានផ្សំជាមួយនឹងបច្ចេកទេសស៊ើបអង្កេត ធ្វើឯកសារនិងការគ្រប់គ្រងនៅសតវត្សរ៍ទី២០ ។ របៀបទាំងអស់នេះមាននិយាយលម្អិតនៅក្នុងស្នាដៃនិពន្ធរបស់លោក ហ្វូខល ដែលមានចំណងជើងថា «វិន័យនិងការដាក់ទណ្ឌកម្ម» និងនៅក្នុងគំនិតផ្សេងមួយទៀតរបស់លោក អូវែល បោះពុម្ពនៅឆ្នាំ១៩៨៤ ។ ធាតុផ្សំផ្ទុយមកវិញដែលធ្វើឲ្យ «មន្ទីរស-២១» មានរូបរាងឡើងនេះ ត្រូវបានបង្កើតឡើងតាមគំនិតឧត្តមភាពកើតចេញពីក្នុងខ្លួនដែលសាយភាយនៅក្នុងគំនិតរបស់មជ្ឈិមបក្ស ផ្តល់នូវភាសាសម្រាប់ប្រើនៅពេលប្រកាសជ័យជម្នះនិងបិទបាំងសមាជិករបស់ខ្លួនមិនឲ្យដឹងពីការពិត ។ សញ្ញាណឧត្តមភាពទាំងអស់នេះ មួយផ្នែកចេញមកពីការបកស្រាយរបស់កម្ពុជាប្រជាធិបតេយ្យស្តីអំពីប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា និងមួយផ្នែកមកពីការផ្តល់អំណាចដោយចៃដន្យទៅឲ្យប្រជាកសិករនៅតាមជនបទមួយភាគតូចដែលប្រហែលជាត្រូវបានចាត់ទុកថាជាជនបដិវត្តមិនចេះនឿយហត់ គឺជាកម្លាំងដែលគេរៀបចំឡើងដើម្បីកម្មវិធីសេដ្ឋកិច្ច ។ អ្នកទាំងនេះជាញឹកញាប់បានបង្កើតនូវឃ្លាសម្ងែងចំពោះអំណាចដែលទើបតែទទួលបានដោយអះអាងអភ័យឯកសិទ្ធិនិងធ្វើឲ្យអាម៉ាស់មុខ និងកម្ចាត់«ខ្មាំងវណ្ណៈ»នៅពេលប្រជាកសិករទាំងនេះត្រូវបានគេឲ្យធ្វើយ៉ាងដូច្នេះ ។

ដូច្នេះមន្ទីរស-២១ ក៏ដូចជារបបកម្ពុជាប្រជាធិបតេយ្យផ្ទាល់ គឺជាវត្ថុចំឡែកខុសគេរបស់ប្រទេសកម្ពុជាដែលមានបែបផែនជាកុម្មុយនិស្តនិងនាំចូលពីបរទេស ។ ដោយសារតែមានធាតុផ្សំច្រើនដូច្នេះហើយបានជាមន្ទីរស-២១ មានលក្ខណៈខុសគេ ។ ដោយហេតុនេះ ការប្រៀបធៀបជាមួយគុកនៅពេល និងទីកន្លែងខុសគ្នានេះគឺមិនមានអ្វីពិសេសឡើយ ។ ទោះជាមានចរិតជា«ខ្មែរ»ក៏ដោយ ក៏ឆ្នាំគុកម្នាក់នៅប្រទេសកម្ពុជាមុនសម័យបដិវត្តន៍ត្រូវទាល់គំនិតដោយសារមន្ទីរស-២១ នេះដែរ ។ នៅពេលឆ្មាំគុកនេះមានភាពស៊ាំទៅនឹងការរំលោភលើរាងកាយ ប្រវ៉ាក់ ខ្នោះឃ្នាង ការស៊ើអត់ស៊ីឃ្លាន និងភាពគ្មានមេត្តា ហើយភាពដាច់ខាត

ភាពឥតប្រែប្រួល ភាពឯកោពីពិភពលោក និងឯកសារដ៏ច្រើនសន្ធឹកសន្ធាប់ដែលធ្វើឡើងនៅទីនោះពិតជាមិនដែលមានពីមុនមកទេ ។ ដូចគ្នានេះដែរ ព្រែសអាចយកមកប្រៀបធៀបជាមួយកន្លែង«អប់រំ» នៅប្រទេសចិននិងវៀតណាម ។ ចំណែកភាពគ្មានមេត្តារបស់មន្ទីរស-២១ មិនស៊ីគ្នាទៅនឹងប្រទេសទាំងពីរនេះទេ ។ រីឯការសួរចម្លើយនៅមន្ទីរស-២១ ដែលជាភារកិច្ចយ៉ាងសំខាន់របស់មន្ទីរនេះមិនដូចគ្នាទៅនឹងជំរំមរណៈណាហ្ស៊ីដែលអ្នកនិពន្ធតែងតែលើកយកមកប្រៀបធៀបគ្នាឡើយ ។

តាមប្រភពដែលខ្ញុំបានពិនិត្យមើលមិនអាចកំណត់ថា តើអ្នកធ្វើការនៅមន្ទីរស-២១ ឬអ្នកនៅពីលើធ្លាប់ដែលមានទុក្ខព្រួយ ឬវង្វេងស្មារតីដែរឬអត់ទេ ចំពោះអ្វីដែលខ្លួនកំពុងតែធ្វើការនៅអំឡុងពេលនោះ ។ អារម្មណ៍មិនទុកចិត្តគឺជាគ្រឿងដ៏ប្រណីតដែលអ្នកធ្វើការនៅក្នុងគុក និងថ្នាក់ដឹកនាំប្រទេសមិនអាចអត់បាន ។ ប៉ុន្តែ គក ស្រស់ បានប្រាប់ ឌូហ្វាស នីវិន ថា អ្នកសួរចម្លើយដែលរួញរាស្ទាក់ស្ទើរមិនហ៊ានប្រើទារុណកម្មត្រូវបានចាប់ខ្លួន ។ គក ស្រស់ និយាយថា ជួនកាលក៏មានការស្ទាក់ស្ទើរកើតឡើងដែរ ហើយនៅក្នុង «កិច្ចប្រជុំជីវភាព» ក្នុងចំណោមបុគ្គលិកមន្ទីរស-២១ ដែលរៀបចំឡើងដោយ ចាន់ នៅខែកុម្ភៈ ឆ្នាំ១៩៧៦ ឌុច ខ្លួនឯងផ្ទាល់ត្រូវបានកត់ត្រាសម្ដីដែលបាននិយាយទៅកាន់បុគ្គលិករបស់ខ្លួនថា៖ «ត្រូវកម្ចាត់នូវទស្សនៈថា វាយអ្នកទោសគឺឃោរឃៅ ។ (ករណីនេះ) មិនត្រូវធ្វើចិត្តល្អទេ ។ ត្រូវវាយ (វា) ដោយមូលហេតុជាតិ មូលហេតុវណ្ណៈ និងមូលហេតុអន្តរជាតិ» ។[២៥]

គួរឲ្យចាប់អារម្មណ៍មែនទែនដែលពាក្យសម្ដីរបស់ ឌុច មានចាប់ពីពេលសន្តិបាលចាប់ផ្ដើមដំណើរការដំបូង គឺជាពេលមួយដែល គ្រីសស្តូហ្វ័រ ប្រោននីង និងនិស្សិតដទៃទៀតដែលសិក្សាពីការសម្លាប់រង្គាលរបស់ណាហ្ស៊ីទៅលើជនជាតិជ្វីហ្វបានកត់ត្រាទុកនូវការស្ទាក់ស្ទើរដំណើរត្រឡប់ទៅជាស្ងប់ខ្ទើម និងការភ្ញាក់ផ្អើលក្នុងចំណោមអ្នកដែលត្រូវបានចោទថា បានសម្លាប់មនុស្សទាំងហ្វូងៗ ។ នៅពេលមន្ទីរស-២១ ចាប់ផ្ដើមប្រតិបត្តិការដំបូង ការស្ទាក់ស្ទើរពីធម្មជាតិក្នុងការធ្វើទារុណកម្មនិងសម្លាប់អ្នកទោសត្រូវបានព្យាយាមជម្នះដូចជាម្នាក់ដែល ឌុច បានព្រមានខាងលើ ។ នៅពេលវេលាចេះតែរំកិលទៅមុខបុគ្គលិកធ្វើការនៅមន្ទីរស-២១ ដូចជានៅណាហ្ស៊ីដែរ បានខំបិទបាំងអំពើរបស់ខ្លួន ក្លិនអសោចរបស់សាកសព រូបរាងគោកយ៉ាករបស់អ្នកទោស និងសម្រែករបស់អ្នកទោស ។

ការលាក់កំបាំងរបៀបនេះគឺអាចយល់បាន ប៉ុន្តែការធ្វើមិនអើពើចំពោះការឈឺចាប់របស់អ្នកដទៃនៅតែបន្តលទ្ធភាពធ្វើឲ្យមនុស្សមានការរន្ធត់តទៅទៀត ។ អ្វីដែលយើងរង់ចាំហើយមិនបានទទួលផលនោះគឺការព្រលយពាក្យថា អ្វីដែលអ្នកធ្វើការនៅមន្ទីរស-២១ធ្វើ បានធ្វើឲ្យខូចខាតដល់ទំនាក់ទំនងក្នុងចំណោមអ្នកទាំងនោះ ធ្វើឲ្យញ័រដៃនៅពេលសរសេរ និងធ្វើមិនឲ្យដេកលក់ស្រួល ។ ចំពោះ ឌុច និងកូនចៅខ្លួនចាត់ទុកថាអ្នកទោស «ថោកជាងសំរាមទៅទៀត» ។ ការស្រង់យកចម្លើយសារភាពពីអ្នកទោសមើលទៅហាក់ដូចជាសំខាន់ក្នុងការការពារបដិវត្តន៍និងមិនសូវស្មុគស្មាញ ឬទុក្ខព្រួយជាងការលាងចិញ្ចើមថ្ពាល់ឬភ្ជួររែស្រែឡើយ ។ អំពើឃោរឃៅដែលជនដៃដល់បានធ្វើឡើង ស្របគ្នាទៅនឹងការមិនអើពើរបស់មេកោយ ឬត្រូវបានការយល់ព្រម ហើយវាគ្មានផ្លូវអាចប្រាប់ថា តើពេលណាអំពើឃោរឃៅត្រូវបានចងក្រងជាឯកសារច្រើនជាង

គេនៅក្នុងបណ្ណសារ ឬតើជនដៃដល់មានការរីករាយចំពោះទង្វើរបស់ខ្លួនដល់កម្រិតណានោះទេ ។ គ្មានជនដៃដល់ណាម្នាក់និយាយនៅក្នុងកិច្ចសម្ភាសន៍ថា ខ្លួនជួបសុបិនអាក្រក់នៅក្រោយឆ្នាំ១៩៧៩ឡើយ វាផ្ទុយទៅនឹងជនរងគ្រោះដែលនៅរស់រានមានជីវិត ។

ដោយសារការមិនចេញមុខរបស់អ្នកសួរចម្លើយយើងអាចត្រឹមតែស្មានបានថា អ្នកសួរចម្លើយមានអារម្មណ៍បែបណានៅពេលខ្លួនកំពុងធ្វើការនៅមន្ទីរស-២១ ប៉ុណ្ណោះ ។ ប្រសិនមានជនដៃដល់ណាម្នាក់ត្រូវបាននាំយកមកកាត់ទោសនៅចំពោះមុខតុលាការនោះ ម្ល៉ោះគេនឹងឆ្លើយថា គេធ្វើតាមបញ្ជានៅក្រោមលក្ខខណ្ឌពេលមានសង្គ្រាម ហើយថាការវាយដំនិងធ្វើទារុណកម្ម (ទោះជាអាចប្រកែកមិនព្រមធ្វើក៏ដោយ) បានជំរុញឲ្យមានការស៊ើបរកការពិតឲ្យបានកាន់តែលឿនដើម្បីការពារមជ្ឈិមបក្ស និងសង្គ្រោះជាតិកុំឲ្យ «អាខ្មាំងយួនលេបទឹកដី» ។ មិនខុសអ្វីពី អាដុល អេចម៉ាន់ ហ្វ្រានស៍ ស្តាងហ្គល និងក្រុមផ្តាច់ខ្លួនថ្មីៗនេះមានដូចជា អៀង សារី នួន ជា និង ខៀវ សំផន ទេ អ្នកធ្វើការនៅមន្ទីរស-២១ ទាំងនោះក៏អាចនិយាយការពារខ្លួនដែរថា កាលនោះវាផ្សេង ឥឡូវវាផ្សេង ។ ដូចឃ្លាមួយដែល ខៀវ សំផន និយាយនៅឯសន្និសីទសារពត៌មាននៅខែធ្នូ ឆ្នាំ១៩៩៨ ជាភាសាអង់គ្លេសទាំងរដាក់រដុបថា «រឿងដែលកន្លងហួសទៅហើយឲ្យវាហួសទៅចុះ» ។ អ្នកទាំងនោះអាចបន្ថែមទៀតថា អំពើឃោរឃៅនិងការរំលោភបំពានធ្វើឡើងនៅមន្ទីរស-២១ គឺដោយសារខ្មាំងបរទេសឈ្លានពានទឹកដីកម្ពុជាប្រជាធិបតេយ្យ និងដើម្បីតស៊ូសង្គ្រោះ «ពូជសាសន៍ខ្មែរ» ស្ទួតត្រង់ដែលត្រូវរងគ្រោះ ។ បើតាមលោកទស្សនៈបែបកម្មផលវិញ «រាល់កំហុស» ឬ ការធ្វើជ្រុលដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងគុក គឺសុទ្ធតែជាស្នាដៃរបស់«គិញវៀតណាម» ។ នេះជាមាគ៌ាដែល ខៀវ សំផន ប្រកាន់យកនៅទសវត្សរ៍ឆ្នាំ១៩៨០ ហើយជាមាគ៌ាដែល ប៉ុល ពត ផ្ទាល់និយាយហើយនិយាយទៀតនៅក្នុងកិច្ចសម្ភាសន៍ជាមួយលោក ណេត ថាយ័រ ។ ឧបករណ៍ភាសាប្រើសម្រាប់បុគ្គលិកធ្វើការនៅក្នុងគុក និង «បង១ថ្នាក់លើ» នៅរក្សាលក្ខណៈដូចដើម ។

ការសុំទោសដូចអ្វីដែល អៀង សារី នួន ជា និង ខៀវ សំផន បាននិយាយប្រហែលជាងាយស្រួលយល់ណាស់ ប៉ុន្តែការកំណត់ពីអំពើមនុស្សឃាតយ៉ាងធំធេងនិងអំពើគួរឲ្យព្រឺខ្លាចពិតជាមានកម្រិត ។ គ្មាន «បរិបទ» ណាមានទំហំគ្រប់គ្រាន់សម្រាប់ទង្វើរបស់ សុន សេន, ឌុច និង «បង១ថ្នាក់លើ» ទេ ។ បរិយាយយ៉ាងម៉េចក៏នៅតែឃើញថា ឃាតករសម្លាប់មនុស្សមួយម៉ឺនបួនពាន់នាក់មានបញ្ហាដែរ ។ បុគ្គលម្នាក់ឬបុគ្គលមួយចំនួនដែលដើរតួជំនួសមុខឲ្យមជ្ឈិមបក្សបានសម្រេចចិត្តធ្វើឃាតអ្នកទោស ដែលសន្តិបាលបានឃុំឃាំងដោយមិនខ្វល់ថា អ្នកទោសបានធ្វើអ្វីឡើយ ។ ធ្វើដូច្នេះដើម្បីកម្ចាអ្នកជំទាស់សំខាន់ៗ ការពារការណ៍សម្ងាត់និងបង្ហាញថា បក្សធ្វើអ្វីមិនចេះខុសទេ ។ ដោយដឹងពីរបៀបចាត់តាំងរបស់កម្ពុជាប្រជាធិបតេយ្យឃើញថា សេចក្តីសម្រេចចិត្តឲ្យធ្វើការងារក្នុងលក្ខណៈនេះគឺប្រហែលជាចេញមកពី ប៉ុល ពត ឬយ៉ាងហោចណាស់ធ្វើឡើងត្រូវទៅនឹងការយល់ព្រមរបស់ ប៉ុល ពត ទោះជាមកដល់សព្វថ្ងៃមិនទាន់ឃើញមានភស្តុតាងបញ្ជាក់ពីការយល់ព្រមរបស់ ប៉ុល ពត ក៏ដោយ ។ «បង១ថ្នាក់លើ» ដែលដើរតាមក្រោយប្រតិបត្តិការនៅមន្ទីរស-២១ និងសុន សេន ព្រមទាំងឌុច ដែលជាអ្នកទទួលខុសត្រូវដំណើរការទាំងអស់នេះដោយផ្ទាល់ដៃ ដឹងថា

អ្វីដែលគេកំពុងធ្វើនិងអ្វីដែលត្រូវធ្វើតទៅទៀត ។ តាមការពិតបុគ្គលទាំងនេះប្រហែលជាអាចបន្ធូរបន្ថយការឈឺចាប់របស់អ្នកទោស ដោះលែងកូនក្មេងតូចៗដែលជាប់គុកជាមួយម្ដាយ ឬបន្ធូរបន្ថយការកាប់សម្លាប់ ប្រសិនបើគេពិតជាចង់ធ្វើមែន ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពិតជាមានជម្រើសធ្វើបែបនេះបាន ហើយយុត្តិធម៌បដិវត្តន៍ក៏អាចធ្វើដោយក្ដីមេត្តាបានដែរ ។ មិនតែប៉ុណ្ណោះ អ្នកដែលនៅរស់រានមានជីវិតចាកផុតពីរបបកម្ពុជាប្រជាធិបតេយ្យបានលើកឡើងនូវឈ្មោះកម្មាភិបាលខ្មែរក្រហមមួយចំនួនដែលមានចិត្តល្អ ឬកម្មាភិបាលមិនសូវតឹងតែង ។ ក៏ប៉ុន្តែនៅមន្ទីរស-២១វិញ មិនអាចមានផ្លូវផ្សេងបែបនេះឡើយ ។ ទាំង សុន សេន ឌុច និងកូនចៅដែលធ្វើការនៅក្រោមបង្គាប់ខ្លួនបានបង្កការឈឺចាប់ហួសប្រមាណមកលើអ្នកទោសដោយចិត្តត្រជាក់ជាប្រព័ន្ធ និងគ្មានវិប្បដិសារីចំពោះទង្វើរបស់ខ្លួនឡើយ ។ ហ្សឺមុន បូមែន ដែលសរសេរអំពីការសម្លាប់រង្គាលរបស់ណាហ្ស៊ីទៅលើជនជាតិជ្វីហ្វ និងគំនិតសម័យថ្មីនៅក្នុងស្នាដៃរបស់ មីលក្រាម បានរំឭកយើងថា «ពត៌មានគួរឲ្យរន្ធត់បំផុតដែលបានមកពីអំពើមហាឃាតកម្មទៅលើជនជាតិជ្វីហ្វ និងអ្វីដែលយើងដឹងពីជនដៃដល់នៃអំពើនេះ មិនមែនបញ្ជាក់ពីលទ្ធភាពថា «អំពើនេះ» អាចធ្លាក់មកលើយើងទេ ប៉ុន្តែគំនិតថាយើងអាចធ្វើអំពើនេះបាន ។ ប្រសិនបើអត្ថន័យនៃមន្ទីរស-២១ (ឬការសម្លាប់រង្គាលជនជាតិជ្វីហ្វ) អាចត្រូវបានបង្រួញមកត្រឹមមួយប្រយោគ ខ្ញុំសូមជ្រើសរើសយកប្រយោគរបស់ បូមែន ។ ចិត្តវិទូមួយរូបឈ្មោះ រ៉ូបើត ជេ លីហ្វុន ដែលសរសេរអំពីបុគ្គលិកពេទ្យនៅតាមជំរំណាហ្ស៊ីមានគំនិតប្រហាក់ប្រហែលគ្នានេះដែរ ។ លោកបានកត់សម្គាល់ថា «មនុស្សធម្មតាអាចប្រព្រឹត្តអំពើឃោរឃៅបែបនេះបាន» ។[២៦]

ការពន្យល់អំពីមន្ទីរស-២១ ដែលបន្ទោស «មនុស្សអាក្រក់» ថា បានធ្វើអំពើអាក្រក់ ពោលគឺបន្ទោសអ្នកដទៃថាជាអ្នកធ្វើអំពើអាក្រក់ មិនបានគិតថា អ្វីដែលយើងទាំងអស់គ្នាចូលរួមជាមួយជនដៃដល់ប្រព្រឹត្តអំពើអាក្រក់តាមពិតគឺមិនមែនជាវប្បធម៌ ជាលទ្ធិ ឬទំនោរចង់សម្លាប់មនុស្សដែលមានពីកំណើតនោះទេ ប៉ុន្តែវាជាសារជាតិរបស់មនុស្សជាតិ ហើយជាពិសេសជាទំនោររបស់យើងទៅរកការធ្វើតម្រាប់តាមនិងគោរពបញ្ជា ។ ភាគច្រើននៃយើងទាំងអស់គ្នា ខ្ញុំសង្ស័យថា អាចចាប់ផ្ដើមស៊ាំនឹងការធ្វើអ្វីមួយ (ដូចជាការធ្វើទារុណកម្ម ឬការកាប់សម្លាប់) ក្នុងខណៈអ្នកដែលយើងគោរពប្រាប់ឲ្យយើងធ្វើបែបនេះ និងខណៈដែលគ្មានកំហិតថាត្រូវធ្វើយ៉ាងម៉េចៗខ្លះនោះ ។ ចំពោះយើងរាល់គ្នាស្ទើរតែទាំងអស់ កិច្ចការបែបនេះនឹងគ្មានអ្វីពិបាកទេ បើជនរងគ្រោះត្រូវបានចាត់ទុកថាជាអ្នកក្រៅទៅហើយនោះ ។ មីលក្រាម បានធ្វើការកត់សម្គាល់ក្នុងសំណេរទាក់ទងនឹងបទពិសោធន៍របស់ខ្លួនថា «បុគ្គលម្នាក់គឺជាភ្នាក់ងារម្នាក់ នៅពេលបុគ្គលនោះចាត់ទុកខ្លួនឯងថាស្ថិតនៅក្នុងស្ថានភាពសង្គមជាក់ស្ដែងដែលតម្រូវឲ្យខ្លួនធ្វើតាមបទបញ្ជាពីបុគ្គលម្នាក់ទៀតដែលមានឋានៈខ្ពស់ជាងខ្លួន» ។[២៧] ចង់និយាយថា អ្វីដែលត្រូវបានអនុញ្ញាត ឬបញ្ជាឲ្យធ្វើ ទោះជាអាក្រក់បែបណាក៏ដោយគឺត្រូវតែកើតឡើង ។ ក្នុងលក្ខខណ្ឌបែបនេះកម្រមានការប្រកែកណាស់ មានតែការប្រព្រឹត្តតែម្ដង ។ ចំណែកឯអំពើផ្ទុយនឹងសីលធម៌វិញដូចដែល បូមែន លើកហេតុផលសមរម្យដែរថា គឺត្រូវតែទៅតាមសង្គមដែរ ។ ផ្ទុយមកវិញ អំពើជម្នះ រឹងរូស ឬភាពមេត្តាគឺវាអាស្រ័យទៅលើជម្រើសផ្ទាល់ខ្លួនរបស់បុគ្គល ។ ជម្រើសដែលផ្ទុយទៅនឹងឆន្ទៈរបស់ខ្លួនកម្រមានណាស់ ។ ដូចដែលអ្នកនិពន្ធ ស្តូប រំឭកយើង

នៅក្នុងន័យផ្សេងមួយទៀតថា «សេចក្តីក្លាហានដែលតម្រូវឲ្យមានក្នុងការកម្រិតអំពើហិង្សានោះ ជាទូទៅមិនមែនជាសេចក្តីក្លាហានចេញមកពីកម្លាំងកាយដែលជាឆន្ទៈចង់ដាក់ជីវិតនោះទេ ប៉ុន្តែ វាជាសេចក្តីក្លាហានក្នុងការជំទាស់ក្រុមរបស់ខ្លួន និងសេចក្តីក្លាហានក្នុងការធ្វើឲ្យគ្រោះថ្នាក់ដល់ឋានៈនៅក្នុងក្រុម ឬ អាជីពរបស់ខ្លួន ។[២៨]

ប៉ុន្តែដោយរំពុកពាក្យស្រដេះស្រដោចរបស់ បូមែន វាហាក់ដូចជាថា ការបរិយាយពីអំពើឃោរឃៅរបស់មន្ទីរស-២១ វាលពិឃាតជើងឯកនៃកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងអំពើឃោរឃៅដូចជាការសម្លាប់រង្គាលរបស់ពួកណាហ្ស៊ីទៅលើជនជាតិជ្វីហ្វ ការសម្លាប់រង្គាលនៅរ៉ាន់ដា បូសនៀ និងនៅតំណ្ឌនេស៊ីចាំបាច់ត្រូវស្វែងរកមិនត្រឹមតែក្នុងចំណោមអ្នកដែលបង្កការឈឺចាប់និងអ្នកដែលចេញបញ្ជាប៉ុណ្ណោះទេប៉ុន្តែត្រូវស្វែងរកកម្រិតរួមទូទៅតែម្តង ដូចដែល ស៊ីរីនី និង បូមែន បានស្នើឡើង ។ នៅក្នុងស្នាដៃនិពន្ធមានចំណងជើងថា «ប្រឈមមុខនឹងអ្វីដែលនឹកស្មានមិនដល់» គ្រូនតាន់ តូដូរ៉ូវ បានបដិសេធការចោទប្រកាន់ដែលថា ស៊ីរីនី គាំទ្រ ស្តាងហ្គល ជ្រុលពេក ។ តូដូរ៉ូវ សរសេរថា «តើនេះជាអ្វីដែលយើងចង់បានឬ? ។ ប្រតិកម្មរបៀបនេះបង្ហាញនូវអារម្មណ៍ភ័យខ្លាចដែលបុគ្គលម្នាក់អាចមានក្នុងការរកឃើញថា អ្នកធ្វើអំពើអាក្រក់មិនខុសគ្នាច្រើនទៅនឹងខ្លួនឯងទេ» ។[២៩]

ការបរិយាយអំពីបាតុភូតដូចជានៅមន្ទីរស-២១ នេះគឺបង្កប់នៅក្នុងសមត្ថភាពរបស់យើងផ្ទាល់តែម្តង ដែលមានដូចជាការបញ្ជានិងគោរពគ្នាទៅវិញទៅមករួមគ្នាជាមួយអ្នកផ្សេងទៀតប្រឆាំងនឹងជនចម្លែកលង់ប្រាណនៅក្នុងក្រុមចង់បានភាពឥតខ្ចោះ និងការយល់ព្រម និងសមត្ថភាពក្នុងការបញ្ចេញកំហឹង និងការយល់ច្រឡំរបស់យើង ជាពិសេសនៅពេលយើងត្រូវបានជំរុញពីអ្នកដែលយើងគោរពឲ្យធ្វើដូច្នេះទៅលើអ្នកដទៃដែលភាគច្រើនគ្មានអ្នកណាជួយ ។ ចង់ស្វែងរកប្រភពនៃអំពើអាក្រក់ដែលត្រូវបានប្រព្រឹត្តឡើងរៀងរាល់ថ្ងៃនៅមន្ទីរស-២១ យើងមិនចាំបាច់មើលទៅណាឆ្ងាយពីខ្លួនយើងទេ ។

## ឧបសម្ព័ន្ធ
## ការបដិសេធន៍របស់ សៀត ឆៃ ចំពោះការចោទប្រកាន់ថាស្រឡាញ់កូនខ្លួនឯង

សៀត ឆៃ ហៅ ទុំ ត្រូវបាននាំចូលក្នុងចលនាកុម្មុយនិស្តដោយលោកគ្រូរបស់ខ្លួនឈ្មោះ ប៉ុល ពត និងប្រពន្ធ ប៉ុល ពត ឈ្មោះ ខៀវ ប៉ុណ្ណារី កាលគាត់នៅជាសិស្សសាលា ។ សៀត ឆៃ ធ្វើជាជំនួយការផ្ទាល់របស់បងលេខ១អស់រយៈពេលជាច្រើនឆ្នាំ ដោយដើរតាម និង ព្យាបាលជំងឺរបស់ ប៉ុល ពត ជានិច្ចទោះជាទៅទីណាក៏ដោយ ។ ដោយសារ សៀត ឆៃ មានគំនិតស្មោះត្រង់ គាត់ក៏មានឋានៈខ្ពង់ខ្ពស់នៅក្នុងជួរបក្សកុម្មុយនិស្តកម្ពុជា ។ ប៉ុន្តែ នៅពាក់កណ្តាលឆ្នាំ១៩៧៧ ដោយសារតែគាត់មានខ្សែរយៈជាមួយភូមិភាគបូព៌ា និងបញ្ញវន្តដែលកំពុងតែត្រូវបោសសម្អាតនាពេលនោះ សៀត ឆៃ ក៏ត្រូវបានចាប់បញ្ជូនខ្លួនមកកាន់មន្ទីរស-២១ ។ មកដល់មន្ទីរស-២១ ជាច្រើនថ្ងៃ សៀត ឆៃ ក៏មិនជឿខ្លួនឯងថា ប៉ុល ពត បានបោះបង់គាត់ចោលដែរ ។ អ្នកសួរចម្លើយឈ្មោះ ទុយ បានសួរចម្លើយគាត់នៅខែមិថុនា ឆ្នាំ១៩៧៧ ។ សៀត ឆៃ ត្រូវបានដាក់គុកអស់ជាច្រើនសប្តាហ៍ ហើយទទួលរងនូវការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរ ។ នៅខែឧសភា សៀត ឆៃ បានសុំការអនុញ្ញាតពី ឌុច ធ្វើអត្តឃាត ។ ប៉ុន្តែ សៀត ឆៃ មិនទាន់ «ខូចចិត្ត» នៅឡើយទេ ។ ទុយ បានសរសេរទៅកាន់ សៀត ឆៃ ដោយគោរព តែមិននិយាយអំពីអំពើឃោរឃៅរបស់ខ្លួនមកលើ សៀត ឆៃ ទេ ។

«លោក ទុំ ជាទីគោរព ។ ចូរលោកសរសេររៀបរាប់អំពីសកម្មភាពខុសសីលធម៌ជាមួយកូនខ្លួនឯងឲ្យបានលម្អិត ពីព្រោះតាមទស្សនៈរបស់មហាជន គេឃើញ(កំហុស) នេះច្បាស់ណាស់ ។ លោកមិនបាច់បដិសេធទេ ។ កុំឲ្យឈឺខ្លួនជាងនេះទៀតដោយសារតែរឿងកំប៉ិកកំប៉ុកបែបនេះ» ។

ការឆ្លើយតបរបស់ សៀត ឆៃ ប្រកបដោយមនោសញ្ចេតនា មានដូចខាងក្រោមដែលប្រែសម្រួលដោយ រីឆាត អារិន ។ វាបង្ហាញអំពីការប៉ុនប៉ងដឹកម្ររបស់អ្នកទោសមន្ទីរស-២១ ក្នុងការឆ្លើយតបទៅនឹងកំហុស ពោលគឺការប្រឈមមុខដ៏ធំទៅនឹងការចោទប្រកាន់ផ្ទាល់ខ្លួន ។ អត្ថបទនេះក៏បង្ហាញនូវគំនិតភក្តីភាពមួយចំនួនដែលជាចំណងចងភ្ជាប់ជនបដិវត្តកម្ពុជាជាច្រើនជាមួយនឹងសមាជិកគ្រួសារខ្លួន ។

នេះគឺជាកំណត់ហេតុចុងក្រោយដែល សៀត ឆៃ បានជម្រាបជូនអង្គការ ។ អស់រយៈពេល៥ខែ សៀត ឆៃ បានឆ្លើយសារភាពដោយមានការធ្វើទារុណកម្មអំពីសកម្មភាពប្រឆាំងបដិវត្តន៍ដ៏ច្រើនលើសលប់មុនពេលគេយកទៅសម្លាប់ចោល ។ ការចោទប្រកាន់ថា ស្រឡាញ់កូនខ្លួនឯងមិនត្រូវបានរំពុកឡើងវិញទេ ហើយការបដិសេធន៍របស់គាត់ក៏មិនត្រូវគេជំទាស់ហើយក៏មិនយល់ស្របដែរ ។ ការដែលកំណត់ហេតុដើមរបស់ សៀត ឆៃ មាននៅក្នុងបណ្ណសារនេះបង្ហាញថា កំណត់ហេតុនេះមិនដែលចេញទៅក្រៅគុក ដូចដែល សៀត ឆៃ សង្ឃឹមនោះទេ ។

## សូមគោរពអង្គការជាទីគោរព

ខ្ញុំសូមធ្វើសេចក្តីរាយការណ៍ជូនអង្គការអំពីបញ្ហាកូនស្រីខ្ញុំ ដែលមានការចោទប្រកាន់(ចំពោះខ្ញុំ) ។

ឆ្នាំ១៩៥៧ កូនរបស់ខ្ញុំកើត ឲ្យឈ្មោះ ស៊ាត សូផា (ប.វ. សាធ) ។ វាជាកូនច្បង ។ វាជាកូនស្រីតែមួយក្នុងចំណោមកូនខ្ញុំទាំង៤ ។

ខ្ញុំជំពាក់ចិត្តនឹងវាជាងគេ តាំងពីតូច ។ វាអាយុបានប្រាំបីឆ្នាំ (គឺឆ្នាំ១៩៦៤) ខ្ញុំត្រូវចូលព្រៃ ព្រាត់ពីកូននេះ និងគ្រួសារទាំងមូលប្រមាណប្រាំពីរឆ្នាំ ។

ពេលម្តាយមីងវាជួប សមមិត្ត ដាំ ផេង នាំគ្រួសារនិងកូននេះទៅជាមួយ ។ រស់នៅជាមួយសមមិត្ត ដាំ ផេង កូននេះស្រឡាញ់ និងស្និទ្ធស្នាលពូថ្ងៃដូចជាឪពុករបស់ខ្លួន ។ សមមិត្ត ដាំ ផេង បានបង្ហាត់ឲ្យកូននេះចេះច្រៀងចម្រៀងបដិវត្តពេលនោះជាច្រើន ។ ព្រមនេះ ក៏មានបង្ហាត់ក្បាច់វាយខ្លះ (បន្តិចបន្តួច) ឲ្យកូននេះ ។ អាយុ១២ឆ្នាំហើយ នៅតែឱប-កពូថ្ងៃយ៉ាងស្និទ្ធស្នាល ។ ខ្ញុំជួបកូននេះដំបូងនៅចុងឆ្នាំ១៩៧០ ឃើញកូននេះចរិតរបៀបប្រុស ។ ជាមួយប្អូនៗប្រុសទាំងបីនាក់របស់វា ដែលធំបន្តបន្ទាប់គ្នា (រមៀលក្រូច) ក៏ឃើញស្និទ្ធស្នាលជារបៀបប្រុសនឹងប្រុស ។ ដូចជាមិនធ្លាប់ចាប់ភ្លឹកថា ខ្លួនជាស្រី ។

ឆ្នាំ១៩៦៨ ខ្មាំងបានទៅគោះទ្វារដាស់ចាប់កូននេះ ដែលដេកចាំផ្ទះម្នាក់ឯង ។

ចុងឆ្នាំ១៩៧០ កូននេះបានទៅដល់តំបន់រំដោះនៃតំបន់២២ជាមួយម្តាយ ។ ពេលជួបខ្ញុំដំបូង កូននេះស្ទុះមកឱបឪពុកនៅមុខគេខ្សឹកខ្សួល ។ យប់នេះ ខ្ញុំនៅសម្រាកជាមួយគ្រួសារ នៅផ្ទះសមមិត្តយើងក្រាលកន្ទេលនៅផ្ទះមួយល្វែងកណ្តាលវាល ។ ម្ចាស់ផ្ទះនៅល្វែងមួយទៀតនៅក្បែរនោះ អមទ្វារ ។ គ្រួសារខ្ញុំកូនខ្ញុំទាំងអស់ព្រមទាំងខ្ញុំ បានរួមកន្ទេលតែមួយជាមួយគ្នា ។ ម្តាយនៅម្ខាង, កូនស្រីនេះម្ខាងដេកអមខ្ញុំ ហើយបីនាក់ទៀតដេកជាប់ៗគ្នា ដោយក្តីនឹករឮកយ៉ាងជ្រាលជ្រៅនឹងកក់ក្តៅបំផុត ។

បន្ទាប់មក ខ្ញុំប្រគល់កូនស្រីនេះ (អាយុប្រមាណ ១៣ ១៤ឆ្នាំ) ជូនមន្ទីរពេទ្យតំបន់២២ ។

ប្រហែលជាចុងឆ្នាំ១៩៧៤ ខ្ញុំដកមកបម្រើការងារមន្ទីរ ព្រោះនៅផ្ទះពេទ្យចេះតែមានសំបុត្រដុងឲ្យកូននេះមិនសូវល្អ ហើយដែលខ្ញុំសង្ស័យជាសកម្មភាពរបស់ពួកក្បត់ (តាមខ្លឹមសារឃ្លោឃ្លោងសំបុត្រ) តែរកមុខមនុស្សមិនឃើញ ។

ចុងខែ៤ ឆ្នាំ១៩៧៦ ដកពីតំបន់២២មកកោះខកញ្ញ៉ាតីជាមួយម្តាយមីង ។

ពេលមកនៅកោះខកញ្ញ៉ាតី កូននេះដែលមកទួលគោកប្រមាណបីបួនដង ក្នុងដំណើរជូនម្តាយមីងដែលឈឺទៅព.១៧ ឬមកជាមួយប្អូនទៅពេទ្យព.១៧ខ្លួនឯង ដែលមានជំងឺទឹកក្នុងសួត និងជំងឺវិលជាប្រចាំ និងមានម្តងមកពីរនាក់បងប្អូន ធ្វើដំណើរទៅរកម្តាយនៅ២៥ ហើយជូនម្តាយទៅកោះធំ មើលជីដូនឈឺ ។

ផ្ទះនៅទួលគោក (ខាងលើ) ជាធម្មតា គឺបិទទ្វារ បង្អួច ព្រោះគ្មានមនុស្សនៅ ។ មានបើកម្តងៗ តែបន្ទប់ខ្ញុំមួយពេលខ្ញុំទៅ ។

ឯបន្ទប់ផ្សេងទៀត កាលណាមានភ្ញៀវ គឺបើកបង្អួច ពេលគ្មានភ្ញៀវនៅបន្ទប់បិទចោល ។ ផ្នែកខាងក្រោមសម្រាប់ប្រជុំការងារខ្លះ ។ បើគ្មានប្រជុំទេ ទាំងទ្វារ ទាំងបង្អួចផ្នែកក្រោម បិទជិតទាំងអស់ ។

ខ្ញុំស្រឡាញ់កូនស្រីនេះលើសអាប្អូនៗប្រុសទាំងបីបន្តិច ព្រោះវាជាកូនស្រីតែមួយនៅក្នុងគ្រួសារ ហើយដឹងខុសត្រូវជាងអាប្អូនៗប្រុសរបស់វា ។

ពេលខ្ញុំចូលព្រៃ កូននេះដឹងក្តីបន្តិច ហើយចេះរួមព្រួយជាមួយម្តាយ ពេលគិញផ្ញើទុកបុកម្ទេញក្នុងពេលបាត់ខ្ញុំ ។

វាត្រូវខ្មាំងចាប់ដាក់គុក តាំងពីអាយុ១២ឆ្នាំ ក្នុងព្រឹត្តិការណ៍ឆ្នាំ១៩៦៨ ជាមួយពូថ្លៃ (សមមិត្ត ដាំផេង) និងម្តាយមីងវា ។ល ។

ទាំងអស់នេះធ្វើឲ្យខ្ញុំអាណិតនឹងស្រឡាញ់កូននេះជាងគេ ។ ទោមកម្តងៗ បើជួបច្រើនតែទះក្បាលទះស្មា ដោយសេចក្តីអាណិតស្រឡាញ់ស្មោះបំផុតរបស់ឪពុកចំពោះកូន ។

ក្នុងបញ្ហាសីលធម៌ខ្ញុំជឿប្រាកដថា វាជាក្មេងស្ថិតក្នុងចំណោមក្មេងត្រឹមត្រូវ ដែលអាចទុកចិត្តបាន ។ តាំងពីនោះមកដល់ថ្ងៃនេះ ខ្ញុំប្រាកដថា វាជាក្មេងព្រហ្មចារីយ៍បរិសុទ្ធ គ្មានសៅហ្មងជាមួយប្រុសណាទៀតឡើយ ។ មតិដែលចោទថា ខ្ញុំត្របាក់កូនឯង...នោះ គឺជាមតិហួសហេតុ ។

ខ្ញុំស្រឡាញ់កូន ចង់ឲ្យកូននេះបរិសុទ្ធ ហើយអនាគតបានជួបយុទ្ធជនបដិវត្តម្នាក់ ដែលល្អបរិសុទ្ធទាំងខាងនយោបាយ ទាំងខាងសីលធម៌រស់នៅដែរ ។

ហេតុដូចរាយការណ៍មកនេះ មានទាស់ខុសយ៉ាងណា សូមអង្គការប្រោសប្រណីដោយអនុគ្រោះ ។

ថ្ងៃទី ៩/៦/៧៧

ខ្ញុំ

## កំណត់សម្គាល់ និងឯកសារពិគ្រោះ

ខាងក្រោមនេះគឺជាពាក្យសរសេរកាត់ដែលប្រើនៅក្នុងឯកសារពិគ្រោះនេះ÷

*CMR* ពាក្យពេញមានន័យថាៈ ដុំមីក្រូហ្វីលនៃសាកលវិទ្យាល័យខណែល ។

*DC-Cam* ពាក្យពេញមានន័យថាៈ មជ្ឈមណ្ឌលឯកសារកម្ពុជា ។

*FBIS* ពាក្យពេញៈ សេវាកម្មផ្សព្វផ្សាយពត៌មានបរទេសនៃសហរដ្ឋអាមេរិក ។

កិច្ចសម្ភាសន៍របស់លោក ស៊ីវ ហេងឌ័រ ឃ្លាពេញៈ ស៊ីវ ហេងឌ័រ «កិច្ចសម្ភាសន៍ជាមួយជនភៀសខ្លួនខ្មែរនៅតាមបណ្តោយព្រំដែនថៃ-កម្ពុជា», ខែកុម្ភៈ-មីនា ឆ្នាំ១៩៨០-ឯកសារមិនទាន់បោះពុម្ពផ្សាយ ។

## វគ្គទីមួយៈ ការរកឃើញមន្ទីរស-២១

១) សូមមើលស្នាដៃនិពន្ធរបស់ បួយ ទិន មានចំណងជើងថា «ដើរតាម ហូ ជីមិញ» ទំព័រទី១១៧-ការរៀបរាប់របស់សាក្សី ។ ចំពោះប្រវត្តិនៃជម្លោះសូមមើលស្នាដៃនិពន្ធរបស់លោក អ៊ីវ៉ុត មានចំណងជើងថា «ជម្លោះឥណ្ឌូចិនលើកទីបី» ។ បើចង់ជ្រាបពីទិដ្ឋភាពទូទៅនៃយុទ្ធនាការនេះ សូមមើលស្នាដៃនិពន្ធរបស់លោក ចាន់ដា មានចំណងជើងថា «កម្ពុជាៈ ដប់ប្រាំថ្ងៃ» ។

២) ពត៌មានទូទៅដែលល្អបំផុតទាក់ទងនឹងសម័យខ្មែរក្រហមប្រហែលជាមាននៅក្នុងស្នាដៃនិពន្ធដំបូងគេបង្អស់ចំនួនបី (មើលមួយណាក៏បានដែរ) របស់ ប៊េកឃ័រ ដែលមានចំណងជើងថា «ពេលសង្គ្រាមផុតរលត់ទៅ» ស្នាដៃនិពន្ធរបស់លោក គ្រេក អេចឆេសិន «ការកកើតនិងការរលំរលាយនៃរបបកម្ពុជាប្រជាធិបតេយ្យ» និងស្នាដៃមួយទៀតរបស់ ប៉ុងស៊ូ មានចំណងជើងថា «កម្ពុជាឆ្នាំសូន្យ» ។ ការសិក្សាបន្តបន្ទាប់មកទៀតមានដូចជាស្នាដៃនិពន្ធរបស់ ប៊ីឃ្ល័រ មានចំណងជើងថា «ភ្នែកម្ចាស់» និងស្នាដៃនិពន្ធរបស់លោក ប៉ែន ឃៀរនិន មានចំណងជើងថា «របប ប៉ុល ពត» ។ ឯកសារនិពន្ធពីរផ្សេងទៀតទាក់ទងនឹងសម័យនេះគឺជាស្នាដៃលោក ឆេនដល័រ និង ឃៀរនិន ដែលមានចំណងជើងថា «បដិវត្តន៍និងលទ្ធផលចុងក្រោយ» និងស្នាដៃនិពន្ធរបស់លោក ជែកសុន មានចំណងជើងថា «កម្ពុជាឆ្នាំ១៩៧៥-១៩៧៨» ។

៣) កិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយលោក ញ៉ែម អេន និង គក ស្រស់ ។ បុគ្គលិកធ្វើការនៅមន្ទីរស-២១ ទាំងពីរនាក់នេះបានលាក់ខ្លួនពេញមួយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ មុនពេលដើរចេញពីទីក្រុងនៅថ្ងៃបន្ទាប់ ។

៤) ចង់ដឹងពីទិដ្ឋភាពទូទៅនៃទីក្រុងភ្នំពេញនៅសម័យកម្ពុជាប្រជាធិបតេយ្យសូមអានស្នាដៃនិពន្ធរបស់ ប៊េកឃ័រ មានចំណងជើងថា «ពេលសង្គ្រាមផុតរលត់ទៅ» ទំព័រទី៤២០ ។ ប៊េកឃ័រ បានមកទស្សនកិច្ចទីក្រុងភ្នំពេញ នៅក្នុងខែធ្នូ ឆ្នាំ១៩៧៨ ។ សូមមើលស្នាដៃនិពន្ធរបស់ គីលជ័រ មានចំណងជើងថា «វីរជន» ទំព័រទី៣៨០ ។ គីលជ័រ មកកាន់ទីក្រុងភ្នំពេញនៅរដូវក្តៅឆ្នាំ១៩៧៩ ហើយមួយឆ្នាំក្រោយមកបានចូលមកទស្សនាមន្ទីរស-២១ ។ នៅពេលខ្ញុំនៅទីក្រុងភ្នំពេញក្នុងខែសីហា ឆ្នាំ១៩៨១ ខ្ញុំឃើញមនុស្សម្នារើសលុយសម័យមុនបដិវត្តន៍នៅតាមដងផ្លូវនៅឡើយ ។ គំនិត «ឆ្នាំសូន្យ» ដែលបានចម្លងតាមបដិវត្តន៍បារាំង ខ្មែរ

ក្រហមមិនដែលដើរតាមពិតប្រាកដឡើយ ។ ប៉ុន្តែខ្មែរក្រហមយកតាមប្រក្រតីទិនគ្រិស្តសករាជពេញអំឡុងពេលនៃការកាន់អំណាចរបស់ខ្លួន ។

៥) កិច្ចសម្ភាសន៍ជាមួយ ជ័យ សាផុន ខែតុលា ឆ្នាំ១៩៩៧ ។

៦) ស្នាដៃនិពន្ធរបស់លោក ចាន់ដា មានចំណងជើងថា «ហាយនភាពកម្ពុជា» រួមទាំងរូបថតអគារសិក្សាដ៏គួរឲ្យខ្លាចមួយសន្លឹក និងរូបថតសាកសពដែលរកឃើញដោយ «កងទ័ពវៀតណាមវាយលុកចូលប្រទេសកម្ពុជានៅថ្ងៃទី៨ ខែមករា ឆ្នាំ១៩៧៩» ។ បើចង់ដឹងខ្លឹមសារសូមមើលស្នាដៃនិពន្ធរបស់ វីវ៉ី មានចំណងជើងថា «ឋាននរក» ទំព័រទី២៤ ។ ចំពោះប្រវត្តិលម្អិតរបស់ទីតាំងនេះសូមមើលស្នាដៃនិពន្ធរបស់ ឡេច ជ័រវួដ មានចំណងជើងថា «សារមន្ទីរទួលស្លែងនៃប្រទេសកម្ពុជា» ។

៧) ប័ណ្ណប្រកាសមានបង្ហាញជូននៅឆ្នាំ១៩៨១ នៅក្នុងខ្សែភាពយន្តរបស់អាឡឺម៉ង់មានចំណងជើងថា «អគ្គការស៊ីគេនោះ» ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោក ភីតធ័រ ម៉ាឃៀ ដែលបានផ្តល់សៀវភៅមួយក្បាលនិយាយពីឯកសារសាច់រឿងខ្សែភាពយន្តនេះ ព្រមទាំងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចសម្ភាសន៍របស់គាត់ធ្វើឡើងជាមួយអ្នកផលិតខ្សែភាពយន្តផ្ទាល់នៅឆ្នាំ១៩៩៥ គឺលោក ហ្គ័រហាដ ឃ្យូម៉ាន់ ។ ម៉ាឃៀ បានរៀបចំបញ្ចាំងខ្សែភាពយន្តនៅមហាវិទ្យាល័យ បាដ នៅខែតុលា ឆ្នាំ១៩៩៨ ហើយខ្ញុំក៏បានចូលរួមមើលភាពយន្តនោះដែរ ។ រូបថតគ្មានចលនានៅក្នុងខ្សែភាពយន្តដែលគេរកឃើញនៅសារមន្ទីរទួលស្លែង នៅឆ្នាំ១៩៧៩ និងឆ្នាំ១៩៨០ បានបាត់បង់អស់ហើយ ។

៨) ឯកសារលម្អិតទាំងនេះបានមកពីសាធារណរដ្ឋប្រជាមានិតកម្ពុជា, តុលាការប្រជាជនបដិវត្ត, មណ្ឌលប្រល័យពូជសាសន៍ទួលស្លែង ។ ឯកសារដើមជាភាសាបារាំងរៀបចំដោយលោក អ៊ីង ប៊ុច ដែលជាអ្នកមានវាសនារស់រានមានជីវិតពីមន្ទីរស-២១ និងជានាយកសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងមុនគេបង្អស់ ។

៩) កិច្ចសម្ភាសន៍របស់លោក ឌូក្លាស នីវិន ជាមួយ ហូ វ៉ាន់ ថាយ ។ គក ស្រស់ អតីតឆ្មាំនៅមន្ទីរស-២១ បានរំឭករឿងចាស់ថា អ្នកទោស«ប្រមាណជាម្ភៃនាក់»ត្រូវបានសម្លាប់នៅមន្ទីរស-២១ មុនពេលវៀតណាមចូលមកបន្តិច (កិច្ចសម្ភាសន៍របស់អ្នកនិពន្ធ) ។ យោងតាមប្រភពនានាបានឲ្យដឹងថា នៅឆ្នាំ១៩៧៨ អគារខាងត្បូងបំផុតក្លាយជា «គុកពិសេស» សម្រាប់ឃុំឃាំងអ្នកទោសដែលមានឋានៈខ្ពស់ៗ ។ ចម្លើយសារភាពមួយចំនួនត្រូវបានកត់ត្រាជាលាយលក្ខណ៍អក្សរនៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ទាំងមុនឬក្រោយពេលដែលអ្នកទោសត្រូវបានសម្លាប់ចោលជាលើកចុងក្រោយ ។

១០) ស្នាដៃនិពន្ធរបស់លោក ស-គ្រោះ មានចំណងជើងថា «គុណសម្បត្តិនៃការប្រោសប្រណី» ។ លោក ស-គ្រោះ បានមកទស្សនាគុកនេះមុនដំបូងនៅឆ្នាំ១៩៨០ ។

១១) អ្នកនិពន្ធមួយចំនួនទាញសេចក្តីសន្និដ្ឋានថា «ស» ប្រើជំនួសឲ្យពាក្យពេញថា «សន្តិបាល» ប៉ុន្តែបុព្វបទនេះមានឃើញប្រើសម្រាប់អង្គភាពរបស់កម្ពុជាប្រជាធិបតេយ្យមួយចំនួនមានជាអាទិ៍ដូចជា÷ ស-៧១ (សាលាបក្ស) និងស-៨ (មន្ទីរភ័ស្តុភារ) ។

១២) ចង់ស្វែងយល់ឲ្យកាន់តែច្បាស់ពី ពញាយ៉ាត សូមអានស្នាដៃនិពន្ធរបស់លោក ម៉ៃឃើល វីកឃ័រី មានចំណងជើងថា «កម្ពុជាក្រោយសម័យអន្តរ» ។ លោក សឺច ឌីយ៉ុង ដែលសរសេរស្នាដៃជាច្រើនទាក់ទងនឹងបញ្ហាកម្ពុជា ធ្លាប់បង្រៀននៅវិទ្យាល័យពញាយ៉ាតក្នុងឆ្នាំ១៩៦៦-១៩៦៧ ។

១៣) លោក ឆាំង យុ «ទួលពិសពុល» ។

១៤) សាធារណរដ្ឋប្រជាមានិតកម្ពុជា «មណ្ឌលប្រល័យពូជសាសន៍ទួលស្លែង» បានរៀបរាប់ទីតាំងសាខាសន្តិបាលដូចជា«មន្ទីរសន្តិបាលតាខ្មៅអតីតមន្ទីរពេទ្យឆ្កួត អតីតទីបញ្ជាការដ្ឋាននគរបាលជាតិខាងត្បូងផ្សារធំថ្មី, អតីតវិទ្យាល័យដេកាត វត្តភ្នំ នៅក្នុងអគារអតីតការិយាល័យទ័ពជើងទឹក អតីតវិទ្យាល័យសង្គមរាស្ត្រនិយមនិងនៅព្រៃសភាគខាងលិចនៃទីក្រុងភ្នំពេញក្នុងខេត្តកណ្ដាល» ។ ការអះអាងមួយចំនួនបញ្ជាក់ថា ពិតជាមានទីតាំងដូចបានរៀបរាប់ខាងលើនេះដូចជានៅក្នុងឯកសារចម្លើយសារភាពផ្ញើឡើងនៅមន្ទីរស-២១ និងនៅក្នុងកិច្ចសម្ភាសន៍របស់លោក ឌូក្លាស់ នីវិន ជាមួយ ញ៉ែម អេន អ្នកថតរូបនៅសន្តិបាល ។

១៥) សូមមើលឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាលេខN០ ១២២៣ «សេចក្ដីសង្ខេបចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៧៦» ដែលជាកំណត់ហេតុរំឭករបស់ឈ្មោះ ភាព នៅកងវរសេនាធំលេខ៥៨៨ផ្ញើជូន «បង៨៩» (សុន សេន អតីតរដ្ឋមន្ត្រីការពារប្រទេសនៃរបបកម្ពុជាប្រជាធិបតេយ្យទទួលបន្ទុកខាងយោធានិងសន្តិសុខជាតិ) ។ កំណត់ហេតុនេះរាយការណ៍ថា «នៅសាលាទួលស្វាយព្រៃ មានមនុស្សមួយក្រុមមានគ្នា២០នាក់បានមកបោសសម្អាតជាន់ទី១និងជាន់ទី២ រើតុចេញអស់២៥០តុ ហើយកាត់ស្មៅអស់២០ម៉ែត្រការ៉េ» ។ គ្មានពត៌មានណាមួយបញ្ជាក់ថា តើមន្ទីរស-២១ ទទួលអ្នកទោសជាលើកដំបូងនៅពេលណាទេ ។ ចង់ជ្រាបអំពីថ្ងៃចុងក្រោយនៃមន្ទីរស-២១ សូមមើលកិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយ គកស្រស់ ញ៉ែម អេន និង ហ៊ីម ហ៊ុយ ។ នៅចុងឆ្នាំ១៩៧៨ ការងារមួយចំនួននៃមន្ទីរស-២១ ប្រហែលជាត្រូវផ្ទេរទៅកងពលលេខ៥០២ ដែលជាការបង្ហាញពីការសង្ស័យនៅក្នុងជួរមជ្ឈិមបក្សមកលើ សុន សេន (ការទាក់ទងផ្ទាល់ខ្លួនរបស់លោក ស៊ីវ ហេដឌ័រ) ។

១៦) ស្នាដៃនិពន្ធរបស់ វីវ៉ូ មានចំណងជើងថា «ឋាននរក» ទំព័រទី២៥ ។ ចង់ជ្រាបអំពីរបាយការណ៍អ្នកសារពត៌មាននៅឆ្នាំ១៩៧៩ សូមមើលស្នាដៃនិពន្ធរបស់ ម៉េត មានចំណងជើងថា «អំពើប្រល័យពូជសាសន៍នៅកម្ពុជា» ។ ការសង្កេតចុងក្រោយរបស់ វីវ៉ូ អាចឆ្លុះបញ្ចាំងពីការគិតប្រកបដោយបំណងល្អ ពីព្រោះ «សៀវភៅតូចពណ៌ក្រហម» នេះមិនទាន់មានបោះពុម្ពជាភាសាខ្មែរទេ ។ យោងតាមលោក ប៊ែន ឃៀរនិន ដែលនិពន្ធសៀវភៅ «របប ប៉ុល ពត» បានឲ្យដឹងថា មន្ទីរស-២១ ត្រូវលោក វ៉ាយហ្វ្រិដ បឺឈិត ផ្សព្វផ្សាយជូនជនមិនមែនកុម្មុយនិស្តនៅទីក្រុងឡុងដ៏ ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៩ ។

១៧) ស្នាដៃនិពន្ធរបស់លោក ហក មានចំណងជើងថា «កម្ពុជាៈ របាយការណ៍ពីទីក្រុងភ្នំពេញ» ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ១៩៨១ ។ មកដល់សព្វថ្ងៃ ម៉ៃ ឡាំ មានអាយុខ្ទង់ចិតសិបឆ្នាំហើយ ។ គាត់បានផ្ដល់កិច្ចសម្ភាសន៍ចំនួនពីរលើកជាមួយអ្នកស្រី សារ៉ាខូម និងម្ដងជាមួយលោក ភីតធ័រ ម៉ាឃៀ និង គ្រីស រីលី ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកទាំងអស់នេះដែលបានផ្តល់ជាកំណត់ហេតុកិច្ចសម្ភាសន៍មកឲ្យខ្ញុំប្រើប្រាស់ជាឯកសារ ។

១៨) ម៉ាឃៀ និង រីលី សម្ភាសជាមួយ ម៉ៃ ឡាំ ។ និយាយទៅកាន់អ្នកស្រី សារ៉ាខូម ម៉ៃ ឡាំ ឲ្យយោបល់ថា កត្តាវប្បធម៌កម្ពុជាមួយចំនួនធ្វើឲ្យប្រជាជនកម្ពុជាមិនយល់ពីអ្វីដែលបានកើតឡើងចំពោះខ្លួននៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ ម៉ៃ ឡាំ និយាយថា «លក្ខណៈទូទៅរបស់ប្រជាជនកម្ពុជាចង់រស់នៅក្នុងបរិយាកាស ស្ងប់ស្ងាត់ សុខសាន្ត មានវត្តអារាម មានដីចម្ការ ភូមិករ ។ ប្រជាជនខ្មែរមានចិត្តអាឡោះអាល័យណាស់ចំពោះពេលវេលាសុខសាន្តដែលគាត់ធ្លាប់មានពីមុន» ។ គំនិតរបស់ ម៉ៃ ឡាំ ចំពោះប្រជាជនខ្មែរមានលក្ខណៈស៊ីគ្នាទៅនឹងអ្វីដែល គ្រិស្តូហ្វ័រ ហ្គោឆា ហៅថា និន្នាការ«ផ្សព្វផ្សាយលទ្ធិព្រះយេស៊ូ» នៅក្នុងទំនាក់ទំនងវៀតណាមជាមួយកម្ពុជា និងឡាវ (ការទាក់ទងផ្ទាល់ខ្លួន) ។

១៩) ស្នាដៃនិពន្ធរបស់លោក ស៊ឺច ឌីយ៉ុង មានចំណងជើងថា «ការប្រល័យពូជសាសន៍ជាឧបករណ៍នយោបាយ» និងស្នាដៃនិពន្ធរបស់លោក ឃៀរនិន មានចំណងជើងថា «អំពើប្រល័យពូជសាសន៍និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា» ទំព័រទី១៨៤ ។

២០) បទសម្ភាសន៍របស់ ម៉ៃ ឡាំ ជាមួយ សារ៉ាខូម, ម៉ាឃៀ និង រីលី និង បទសម្ភាសន៍របស់ អ៊ីង ប៉ិច ជាមួយលោក ដេវីដ ហក ។ សូមមើលពត៌មានបន្ថែមទៀតនៅក្នុងកិច្ចសម្ភាសន៍របស់លោក ស៊ីវ ហេងឌី ទំព័រទី១០-១១ និង ១៤ ជាមួយ អ៊ុង ជុងហៀង អ្នកចេះដឹងមួយរូបដែលធ្លាប់ធ្វើការនៅមន្ទីរស-២១ ផ្នែកឯកសារក្នុងចន្លោះខែមិថុនា និងខែវិច្ឆិកា ឆ្នាំ១៩៧៩ ។ «ថ្ងៃ៣០ ខែវិច្ឆិកា ជាថ្ងៃគេដេញខ្ញុំចេញពីទីក្រុងភ្នំពេញ» នៅក្នុងព្រឹត្តិបត្របោះពុម្ពផ្សាយមានចំណងជើងថា «កិច្ចការរបស់កម្ពុជា» ទំព័រទី១២១-២៨ ។

២១) សូមមើលជាពិសេសសៀវភៅមានចំណងជើងថា «អ្នកទោសជាជាងគំនូរ» ដែល វ៉ាន់ ណាត បានរៀបរាប់ជីវិតរបស់គាត់នៅក្នុងគុក ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកស្រី សារ៉ាខូម ដែលបានណែនាំខ្ញុំឲ្យស្គាល់ វ៉ាន់ ណាត នៅក្នុងឆ្នាំ១៩៩៥ ។ អ្នកដែលមានវាសនារស់រានមានជីវិតម្នាក់ទៀតឈ្មោះ អៀម ចាន់ ក៏ត្រូវបានជួបសម្ភាសជារឿយៗដូច អ៊ីង ប៉ិច ដែរ ។ ក្រៅពីនេះសូមមើលកិច្ចសម្ភាសន៍របស់លីអូណេល វ៉ៃរ៉ុង ជាមួយ ផាន ថនចាន់ ដែលក្លាយជាអ្នកវាយអត្ថលីលេខនៅមន្ទីរស-២១ និងមើលឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាលេខD០០០១៧ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៨៥ កិច្ចសម្ភាសន៍ជាមួយលោក រុយ នាគង់ ដែលធ្វើជាជាងឈើធ្វើការនៅមន្ទីរស-២១ ចាប់ពីឆ្នាំ១៩៧៦ រហូតដល់វៀតណាមចូលមក ។

២២) ជាការពិបាកនឹងសម្រេចណាស់ថា តើឯកសារចម្លើយសារភាពប៉ុន្មានភាគរយនៅសេសសល់ ។ ប្រសិនបើអ្នកទោសម្នាក់សរសេរចម្លើយសារភាពមួយច្បាប់មានន័យថា ឯកសារចម្លើយសារភាពចំនួនមួយម៉ឺនច្បាប់ត្រូវបាត់ ។ ករណីនេះប្រហែលមិនអាចទៅរួចទេ ។ ប្រសិនបើពាក់កណ្តាលនៃចំនួនចម្លើយសារភាពនេះបាត់ស្រមោល ប្រហែលជាអ្នកទោសរាប់ពាន់នាក់នៅមន្ទីរស-២១ មិនដែលបានរៀបចំធ្វើចម្លើយរបស់ខ្លួនទេមើលទៅ ។ ចម្លើយសារភាពចំនួនពីរសំខាន់ៗដែលបាត់ គឺចម្លើយសារភាពរបស់ ចៅ

សេង បញ្ញាវុទ្ធនៃនិយមដែលធ្វើជារដ្ឋមន្ត្រីក្រសួងពត៌មានរបបទ្រង់ សីហនុ និង ជា សាន ឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំនៅសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត និងប្រទេសរូម៉ានី ។ រូបថតរបស់ ជា សាន ដែលថតតាំងពីខែកុម្ភៈ ឆ្នាំ១៩៧៨ មានឃើញនៅក្នុងខ្សែភាពយន្តរឿង «អង្គការស្អីគេនោះ» ។

២៣) អត្ថបទដែលផ្តោតសំខាន់ពីការសម្លាប់រង្គាលមកលើជនជាតិជ្វីហ្វដែលធ្វើឲ្យខ្ញុំចាប់អារម្មណ៍បំផុតនោះគឺជាស្នាដៃរបស់ អាមេរី មានចំណងជើងថា «ដែនកំណត់នៃចិត្ត» ស្នាដៃរបស់ បូមែន មានចំណងជើងថា «ហាយនភាពនិងគំនិតសម័យថ្មី» ស្នាដៃរបស់ ប្រោននីង មានចំណងជើងថា «ពលយុទ្ធជនសាមញ្ញ» ស្នាដៃរបស់ ឡេវី មានចំណងជើងថា «អ្នកលិចលង់និងអ្នកដែលគេជួយសង្គ្រោះ» ស្នាដៃនិពន្ធរបស់ ស៊ីរីនី មានចំណងជើងថា «នៅក្នុងភពងងឹតអន្ធការ» ស្នាដៃនិពន្ធរបស់ សហ្វស្គី មានចំណងជើងថា «ប្រព័ន្ធភេរវកម្ម» និងស្នាដៃនិពន្ធរបស់ តូដូរ៉ូវ មានចំណងជើងថា «ប្រឈមមុខនឹងរឿងរ៉ាវហួសពីការនឹកស្មាន» ។ ចង់ជ្រាបអំពីប្រទេសអាហ្សង់ទីន សូមមើលស្នាដៃនិពន្ធរបស់ ហ្វេត ឡូវីត «សន្ធានុក្រមនៃភាពព្រឺខ្លាច» និងស្នាដៃនិពន្ធរបស់លោក ហ្គ្រាស៊ីអាណូ មានចំណងជើងថា «ហិង្សាពីអាទិទេព» ។ សៀវភៅដែលនិពន្ធដោយ ស៊ីរីនី និង ហ្វេតឡូវីត ផ្តុកទៅដោយគំនិតទូលំទូលាយទាក់ទងនឹងជនដៃដល់ ។ ការសិក្សាអំពីការសម្លាប់រង្គាលនៅប្រទេសឥណ្ឌូនេស៊ីក្នុងឆ្នាំ១៩៦៥-៦៦ និងអំពើឃោរឃៅដែលរៀបចំដោយរដ្ឋនៅក្នុងបដិវត្តន៍វប្បធម៌ប្រទេសចិនក៏មានសារប្រយោជន៍ដែរ ហើយការពិភាក្សារបស់ខ្ញុំស្តីអំពីមន្ទីរស-២១ បានទទួលគំនិតល្អៗពីនិស្សិតនៅសាកលវិទ្យាល័យ វីខុនស៊ីន នៅឆ្នាំ១៩៩៨ ។ និស្សិតទាំងនោះបានចូលរួមសិក្ខាសាលាដែលខ្ញុំជាអ្នករៀបចំឡើងផ្តោតសំខាន់ទៅលើការសម្លាប់ដោយហេតុផលនយោបាយនៅសតវត្សរ៍ទី២០ ។

២៤) កិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយ តាំង គីមម៉ែន ។ ពត៌មានបន្ថែមសូមមើលចម្លើយសារភាពរបស់ សៀត ឆែ ហៅ ទុំ *CMR138.11* ។ សៀត ឆែ បានសរសេរទៅកាន់ប្រធានគុកឈ្មោះ ឌុច ថា «ខ្ញុំយល់ហើយថា ចំពោះការចូលមកមន្ទីរស-២១ គឺមានតែម្តងទេ បើចូលហើយមិនអាចចេញបានទេ ។ *CMR179.16* ទត រី ក៏បញ្ចេញទស្សនៈប្រហាក់ប្រហែលគ្នានេះដែរ ។

២៥) ស្នាដៃនិពន្ធរបស់លោក ថាយ័រ មានចំណងជើងថា «ថ្ងៃជម្រះបញ្ជី» ។ ប៉ុល ពត អាចស្គាល់ទួលស្លែងតាមរយៈលេខកូដ(ស-២១) ។ ពត៌មានបន្ថែមសូមមើលកិច្ចសម្ភាសន៍របស់ គ្រីស៊ីន ឆាំម៉ូ ជាមួយ អៀង សារី «ការស្តារឡើងវិញត្រូវបានបញ្ចប់» នៅក្នុងនោះ អៀង សារី និយាយថា «ខ្ញុំមិនដែលស្គាល់ទួលស្លែងទេ... ។ យើងតែងតែនិយាយទាក់ទងគ្នាជាលេខកូដ ហើយសន្តិសុខគឺ ស-២១» ។ នៅពេលសួរថា តើអ្នកណាជាអ្នកចេញបញ្ជាមកមន្ទីរស-២១ អៀង សារី ឆ្លើយថា «សម្រាប់បញ្ហានយោបាយបែបនេះគឺ ខៀវ សំផន (ជាអ្នកបញ្ជា)» ។ ការអះអាងបែបនេះគ្មានសេចក្តីបញ្ជាក់ពីបណ្ណសារនៅមន្ទីរ ស-២១ ឡើយ ។

២៦) ស្នាដៃនិពន្ធរបស់លោក ឡិច ដ័រវ៉ូដ មានចំណងជើងថា «សារមន្ទីរទួលស្លែងនៃប្រទេសកម្ពុជា ទំព័រទី៩០ ។ ប្រជាជនកម្ពុជាកំពុងតែមើល ។ ពត៌មានបន្ថែមសូមមើលស្នាដៃនិពន្ធរបស់ សេធ មីដាន មាន

ចំណងជើងថា «ម្ភៃឆ្នាំក្រោយមក» ។

២៧) ស្នាដៃនិពន្ធរបស់លោក ឡិច ជ័រវ៉ូដ មានចំណងជើងថា «សារមន្ទីរទួលស្លែងនៃប្រទេសកម្ពុជា» ទំព័រទី៨៨ ដកស្រង់ចេញពីរបាយការណ៍ក្រសួងវប្បធម៌ ។ ឡិច ជ័រវ៉ូដ បន្ថែមថា «សារមន្ទីរនេះបានបើកទ្វារឲ្យសាធារណជនចូលទស្សនានៅរាល់ថ្ងៃអាទិត្យ...(ចំណែកឯ) ដំណើរទស្សនកិច្ចរបស់ជនបរទេស ឬ ក្រុមក្នុងស្រុកវិញគឺរៀបចំឡើងរៀងរាល់ចុងសប្តាហ៍» ។

២៨) កិច្ចសម្ភាសន៍របស់អ្នកស្រីសារ៉ាខូម ជាមួយ ម៉ៃ ឡាំ ។ នៅពេលសួរថា ហេតុអ្វីបានជាប្រជាជនកម្ពុជាចូលចិត្តតែបន្ទោសបរទេសថា ជាអ្នកប្រព្រឹត្តអំពើឃោរឃៅនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទៅវិញ ម៉ៃ ឡាំ បានបន្ថែមថា «ប្រជាជនកម្ពុជាមិនចង់បើកគំនិតឲ្យទូលំទូលាយទេ... ។ គេអស់កម្លាំង គេមិនចង់គិតអ្វីទាំងអស់» ។ ក្នុងនាមជាប្រវត្តិវិទូ ម៉ៃ ឡាំ គ្មានទីករអែងទឹងអ្វីដែលគាត់កំពុងធ្វើទេ ។ ជាងនេះទៅទៀត បើគ្មានការពុះពារប្រឹងប្រែងរបស់គាត់ ម្ល៉េះសារមន្ទីរនេះមិនអាចមានរូបរាងទេ ហើយសៀវភៅនេះក៏មិនបានបោះពុម្ពផ្សាយដូចពេលនេះដែរមើលទៅ ។

២៩) ស្នាដៃនិពន្ធរបស់ ហ៊ីដេល ឡង់ដ្រាក មានចំណងជើងថា «ខ្មែរក្រហម» ទំព័រទី៦៥ ។ ចង់ជ្រាបព័ត៌មានបន្ថែមទៀតសូមមើលស្នាដៃនិពន្ធរបស់ ហ៊ីដេល ឡង់ដ្រាក ដដែលមានចំណងជើងថា «បដិវត្តន៍ខ្មែរក្រហម»និងស្នាដៃរបស់ ឡេវី មានចំណងជើងថា «អ្នកលិចលង់ និងអ្នកដែលគេសង្គ្រោះ» ។

៣០) អ៊ុង ថុងហៀង (កិច្ចសម្ភាសន៍របស់ ហេដឌ័រ ទំព័រទី១៨) អះអាងថា នៅចុងឆ្នាំ១៩៧៩ គេឲ្យគាត់ធ្វើជាគណៈកម្មាធិការធ្វើសេចក្តីព្រាងរដ្ឋធម្មនុញ្ញរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជានិងឲ្យសរសេរ «សៀវភៅប្រវត្តិសាស្ត្រជាផ្លូវការរបស់រដ្ឋាភិបាលនេះ»÷ «វៀតណាមឲ្យខ្ញុំប្រើប្រាស់រដ្ឋធម្មនុញ្ញរបស់វៀតណាមជាគំរូក្នុងការសរសេររដ្ឋធម្មនុញ្ញកម្ពុជាហើយឲ្យខ្ញុំកុំរវីរវល់នឹងប្រភពឯកសាររបស់បារាំង... ហើយឲ្យសរសេរអ្វីដែលបង្ហាញជាមូលដ្ឋានសាមគ្គីភាពរវាងប្រទេសវៀតណាមនិងកម្ពុជា» ។ ចំពោះបញ្ហានេះសូមអានស្នាដៃនិពន្ធរបស់ ហ្វ្រឹង មានចំណងជើងថា «សម្ព័ន្ធភាពនិងសមភាព» ។

៣១) កិច្ចសម្ភាសន៍របស់ លីអូណេល វែរ៉ុង ជាមួយ ដាន ថនចាន់ ដែលបានអះអាងថា តើមានការសម្លាប់ជនបរទេសមែនឬយ៉ាងណា តម្រូវឲ្យមានភ័ស្តុតាងមកបញ្ជាក់ច្បាស់លាស់សិន ។ ចង់ជ្រាបព័ត៌មានបន្ថែមទៀតសូមមើលស្នាដៃនិពន្ធរបស់ បួយ ទិន មានចំណងជើងថា «ដើរតាម ហូ ជីមិញ»÷ «តាមការណ៍ជាក់ស្តែង [នយោបាយប្រល័យពូជសាសន៍របស់ខ្មែរក្រហម] មានភាពឃោរឃៅ និងគ្រោះថ្នាក់ដល់ជីវិតខ្លាំងជាងអំពើរបស់ពួកណាហ្ស៊ីនៅក្នុងសង្គ្រាមលោកលើកទី២ទៅទៀត ។ ប៉ុន្តែ «នយោបាយនេះ» ត្រូវបានលាក់បាំងយ៉ាងជិតក្រោមផ្លាកកុម្មុយនិស្ត ពោលគឺកុម្មុយនិស្តស្អាតស្អំបរិសុទ្ធ កុម្មុយនិស្តដ៏សែនបរិសុទ្ធ» ទំព័រទី១៣១ ។

៣២) ស្នាដៃនិពន្ធរបស់លោក ឡិច ជ័រវ៉ូដ មានចំណងជើងថា «សារមន្ទីរទួលស្លែងនៃប្រទេសកម្ពុជា» ទំព័រទី៩១ ។ ថ្ងៃចងកំហឹងប្រារព្ធឡើងនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៨៣ ដែលកាលនោះបក្សកុម្មុយនិស្តកម្ពុជាបានសម្តោធការប្រមូលផ្តុំជាសហករណ៍មកពីផ្នែកផ្សេងៗនៃប្រទេសកម្ពុជាដាក់ឲ្យស្ថិតនៅក្រោម

ការគ្រប់គ្រងរបស់ខ្លួន៖ សូមមើលកិច្ចសម្ភាសន៍របស់លោក ហេដឌ័រ ទំព័រទី៣៥ ។

៣៣) មើលស្នាដៃនិពន្ធរបស់ ហែន ណាំ និង លោក ដេវីដ ហក ដែលមានចំណងជើងថា «សំណុំរឿងប្រឆាំងនឹងគណៈកម្មាធិការអចិន្ត្រៃយ៍» និង «អំពើប្រល័យពូជសាសន៍នៅកម្ពុជា» ។ ចង់ជ្រាបពីតម្លៃនៃការឃោសនាអំពីមន្ទីរស-២១ សូមអានស្នាដៃនិពន្ធរបស់លោក ចាន់ដា មានចំណងជើងថា «សត្រូវបងប្អូនឯង» ទំព័រទី៣៨២ ។

៣៤) សូមមើលពត៌មានក្នុងកាសែតញូវយ៉កថៃមស៍ ច្បាប់ចេញផ្សាយថ្ងៃទី២៧ ខែមេសា ឆ្នាំ ១៩៩៨ ។ កិច្ចខិតខំប្រឹងប្រែងក្នុងការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោសជិតបានទទួលលទ្ធផលទៅហើយ ស្រាប់តែ ប៉ុល ពត ធ្វើអត្តឃាតនៅខែមេសា ឆ្នាំ១៩៩៨ ហើយចលនានេះក៏មានសន្ទុះម្តងទៀតក្រោយពី នួន ជា និង ខៀវ សំផន ចុះចូលជាមួយរដ្ឋាភិបាលទីក្រុងភ្នំពេញនៅខែធ្នូ ឆ្នាំ១៩៩៨ ។ សូមមើលស្នាដៃនិពន្ធរបស់លោក រីចបឺក មានចំណងជើងថា «កិច្ចគាំទ្រឲ្យមានតុលាការកាត់ទោសខ្មែរក្រហមចេះតែកើនឡើង» និងស្នាដៃនិពន្ធរបស់លោក អាដាម មានចំណងជើងថា «បែរជាត្រូវបរាជ័យនៅពេលហៀបតែនឹងបានជ័យជម្នះទៅហើយ» ។ ប្រសិនបើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមកើតឡើងមែនឯកសារនៅបណ្ណសារមន្ទីរស-២១ ដែលសព្វថ្ងៃនេះយកមកតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាប្រាកដជាអាចយកទៅប្រើប្រាស់ជាភស្តុតាងបានមិនខាន ។ អ្នកដែលមានវាសនារស់រានមានជីវិតចាកផុតពីរបបកម្ពុជាប្រជាធិបតេយ្យ ប្រហែលជាកំពុងតែច្របូកច្របល់ក្នុងគំនិតចង់បានយុត្តិធម៌ការអត់ឱន ការត្រាប្រណីនិងការសងសឹក ។ ប៉ុន្តែគួរឲ្យសោកស្តាយនៅពេលខ្ញុំដឹងថា មានស្នាដៃនិពន្ធរបស់ម៉ាថា មីណូ ដែលផ្តោតការសិក្សាលើបញ្ហាប្រហាក់ប្រហែលនឹងស្នាដៃរបស់ខ្ញុំនេះសៀវភៅសំឡេងពីមន្ទីរស-២១ របស់ខ្ញុំបានទៅដល់រោងពុម្ពមុនបាត់ទៅហើយ ។ សៀវភៅរបស់ ម៉ាថា មានចំណងជើងថា «រវាងការសងសឹកនិងការអត់ឱន» ។

៣៥) យុវជនវ័យក្មេងទាំងនេះបានរៀបចំចម្លើយសារភាពដែលសរសេរជាភាសាអង់គ្លេស ដោយចោទប្រកាន់ថា អ្នកទាំងនោះជាភ្នាក់ងារសេ.អ៊ី.អា ហើយគេឲ្យលុយច្រើនណាស់ឲ្យមកស៊ើបយកការណ៍ពីកម្ពុជាប្រជាធិបតេយ្យ ។ អ្នកទោសទាំងនេះគឺជាមនុស្សចុងក្រោយគេបង្អស់ដែលត្រូវបានសម្លាប់ចោលនៅក្នុងគុកនេះ ។ ចង់ជ្រាបពត៌មានអំពីអ្នកទោសជនជាតិអាមេរិកាំង សូមមើលស្នាដៃនិពន្ធរបស់ ប្រ៊ីសុន មានចំណងជើងថា «កម្ពុជាសម្អាតគំនរដេះដង់របស់ខ្លួន» ។ ស្នាដៃសិក្សាស្រាវជ្រាវរបស់លោក ភីតធ័រ ម៉ាឃៀ បង្ហាញថាជនជាតិអាមេរិកាំងបួននាក់ដែលធ្លាប់ស្គាល់គ្នាកាលនៅរៀននៅវិទ្យាល័យជាមួយគ្នានៅរដ្ឋកាលីហ្វ័រញ៉ាត្រូវបានចាប់នៅជិតឆ្នេរសមុទ្រកម្ពុជា ក្នុងខណៈដែលអ្នកទាំងបួនកំពុងធ្វើដំណើរពីប្រទេសសិង្ហបូរីសំដៅមកកាន់ទីក្រុងបាងកក ដើម្បីដឹកកញ្ឆាដែលខ្លួនបម្រុងយកទៅចែកចាយនៅរដ្ឋហាវ៉ៃ ។ ដោយសារអ្នកទាំងបួននាក់មានមិត្តរួមថ្នាក់ធ្វើការនៅក្រុមស៊ើបការណ៍សម្ងាត់អាមេរិកប្រចាំនៅប្រទេសថៃ នោះយើងអាចគិតថា អ្នកទាំងនោះប្រហែលជាបានថតរូបឆ្នេរសមុទ្រនៅពេលចាប់ខ្លួនដើម្បីជាថ្នូរបន្តិចបន្តួច ។

៣៦) ឯកសារមិនមែនចម្លើយសារភាពមាននៅក្នុងដុំហ្វីលលេខCMR93-103/ 112-15/ 187-88 និង

198 ។ សៀវភៅកំណត់ហេតុរបស់អ្នកសួរចម្លើយដែលលើកយកមកពិភាក្សាជាលម្អិតនៅវគ្គទី៥ គឺដុំហ្វីល លេខCMR99.7 ។ ចំពោះឯកសារបកប្រែសូមមើល "សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង" របស់លោក ដេវីដ ហក ទំព័រទី២៧ ។ "ផែនការចុងក្រោយ" (CMR99.13) បកប្រែនៅក្នុងស្នាដៃនិពន្ធរបស់លោក ជេក សុន មានចំណងជើងថា "កម្ពុជាឆ្នាំ១៩៧៥-១៩៧៨" ទំព័រទី២៩៩-៣១៤ ។

៣៧) ស្នាដៃនិពន្ធរបស់ ជីឡាស់ មានចំណងជើងថា "អំពីគុកនិងគំនិត" ទំព័រទី១៣៩ ។

៣៨) ដូចលោក រូបឺត ម៉ូលរ៉ែ បានមានប្រសាសន៍ថា រូបថតពាក់កណ្តាលខ្លួនក៏នាំមកនូវពត៌មានដទៃទៀត (ជាទម្រង់ទឹកមុខ សម្លៀកបំពាក់ និងការចងចាំ) មកពីខាងក្រៅគុក ។ រូបថតទាំងនេះបញ្ជាក់ពីមុខមាត់របស់អ្នកដែលគេនាំយកមកស្ថាប័នស្វយ័តនេះ (ស-២១) ។ ស្នាដៃនិពន្ធរបស់ នីរិន និង រីលី ដែលមានចំណងជើងថា "វាលពិឃាត" មានរូបថតពាក់កណ្តាលខ្លួនប្រកបដោយភាពព្រឺខ្លាចច្រើនណាស់ ។ ក្រុមបណ្ណសាររូបថតរបស់ នីរិន និង រីលី បានសម្អាតហ្វីល ផ្តិតហ្វីល និង ចងក្រងទុកដាក់ហ្វីលចំនួនប្រាំមួយពាន់ដែលរកឃើញនៅក្នុងសារមន្ទីរកាលពីឆ្នាំ១៩៩៤-១៩៩៥ ។ រូបថតភាគច្រើនអាចរកបាននៅតាមស៊ីឌីរ៉ូមដែលរៀបចំដោយកម្មវិធីសិក្សាពីអំពើប្រល័យពូជសាសន៍នៃសាកលវិទ្យាល័យយ៉េល ។ ឈ្មោះ លីនសេ ហ្រ្វេញ ដែលសរសេរពី"ការបង្ហាញពីភាពព្រឺខ្លាច" បាននិយាយពីការតាំងពិព័រណ៍រូបថតនៅសារមន្ទីរម៉ូដឺនអាតនៅទីក្រុងញូវយ៉កក្នុងឆ្នាំ១៩៩៧ ។ វ៉ាន់ ណាត និយាយថា គាត់បានគូររូបធ្វើទារុណកម្មនេះនៅខែកញ្ញា ឆ្នាំ១៩៧៩ ដែលកាលនោះរដ្ឋាភិបាលបានចាប់ផ្តើមបើកទ្វារមន្ទីរស-២១ ជាលក្ខណៈសារមន្ទីរសម្រាប់ភ្ញៀវទស្សនា ។ សៀវភៅនិពន្ធដោយ ចមម៉ូ មានចំណងជើងថា "៥៥ ចេញសាលក្រម" ។

## ខគ្គទីពីរ: ស-២១: ស្ថាប័នស្វយ័ត

១) ស្នាដៃនិពន្ធរបស់ ហ្កហ្វមែន មានចំណងជើងថា "ពេទ្យវិកលចរិត"ទំព័រទី១១ ។ សូមមើលស្នាដៃនិពន្ធរបស់ បូសេ មានចំណងជើងថា"គុក", ស្នាដៃនិពន្ធរបស់ ហ្សូរ៉ូ វីត មានចំណងជើងថា "មន្ទីរព្រហ្មទណ្ឌនៅប្រជុំកោះ" វ៉ុល១ វគ្គទី១៤ "ភាពផ្តាច់ការជាអាណានិគមព្រហ្មទណ្ឌ" ។

២) ស្នាដៃនិពន្ធរបស់ ហ្កហ្វមែន មានចំណងជើងថា "ពេទ្យវិកលចរិត"ទំព័រទី២២ ។

៣) ស្នាដៃនិពន្ធរបស់ ហ្វូខូល មានចំណងជើងថា "វិន័យនិងទណ្ឌកម្ម" ទំព័រទី៣០២-៣÷ "អំណាចនៃការដាក់ទណ្ឌកម្មមិនខុសគ្នាទៅនឹងអំណាចនៃការព្យាបាលឬអប់រំទេ" ។ សកម្មភាពទាំងបីនេះកើតឡើងនៅមន្ទីរស-២១ ។ សូមមើលស្នាដៃនិពន្ធរបស់ គីន ហ្សី មានចំណងជើងថា "សហនិមិត្តហេតុនៃជីវប្រមូលផ្តុំ" ។ ស្នាដៃនិពន្ធរបស់ បូមែន មានចំណងជើងថា "គំនិតសម័យថ្មី និងហាយនភាព" ធ្វើការប្រៀបធៀបសង្គមមួយដែលកំពុងដំណើរការក្រោមលក្ខខណ្ឌបែបនេះទៅនឹង "សួនច្បារដែលនឹងត្រូវធ្វើជាគម្រោងនិងរក្សាជារូបរាងមួយដោយប្រើកម្លាំង" ដែលក្នុងសួននោះ "រុក្ខជាតិ" ត្រូវបានថែរក្សា ចំណែកឯស្មៅវិញត្រូវគេធ្វើយ៉ាងស្អាត ទំព័រទី១៨ ។

៤) មន្ទីរស-២១ ត្រូវបានគេឲ្យហេតុផលថា ជាស្ថាប័នមួយដ៏សំខាន់នៅក្នុងរបបកម្ពុជាប្រជា-

ធិបតេយ្យ ។ យោងតាមសម្ដីរបស់ ញ៉ែម អេន (កិច្ចសម្ភាសន៍របស់អ្នកនិពន្ធ) បានឲ្យដឹងថា សុន សេន ដែលទទួលបន្ទុកផ្នែកសន្តិសុខជាតិរបស់កម្ពុជាប្រជាធិបតេយ្យបានហៅមន្ទីរស-២១ ថាជា«ដង្ហើមជាតិ» ។ សូមមើលដុំមីក្រូហ្វីលលេខCMR99.7 ដែលជាសៀវភៅកំណត់ហេតុរបស់អ្នកសួរចម្លើយតាំងពីឆ្នាំ១៩៧៦÷ «កិច្ចការរបស់សាខាពិសេសគឺកិច្ចការតស៊ូវណ្ណៈ វាយសម្រុកកម្ទេចវណ្ណៈជិះជាន់ សម្លាប់ពួកវាឲ្យអស់ដើម្បីការពារបក្ស វណ្ណៈអធន កម្ពុជាប្រជាធិបតេយ្យ និងការពារមាគ៌ាឯករាជ្យស្ម័យម្ចាស់ការ...។ ភ្នាក់ងារខ្មាំងមិនអាចធ្វើដូចយើងធ្វើចំពោះវាបានទេ ។

៥) អៀង សារី និយាយទៅកាន់លោក ស្ទីវ ហេដឌ័រ កាលពីឆ្នាំ១៩៩៦ថា «គណៈកម្មាធិការយោធាសន្តិសុខ» ដែលមានសមាសភាពដូចជា ប៉ុល ពត, នួន ជា, សុន សេន, និង សោ ភឹម ជាមួយប្រពន្ធ សុន សេន ឈ្មោះ យុន យ៉ាត ដែលចូលរួមជាលក្ខណៈក្រៅផ្លូវការជាអ្នក«មើលការខុសត្រូវការចាប់ខ្លួន ការឃុំខ្លួន និងការសម្លាប់នៅមន្ទីរស-២១» (ការទាក់ទងផ្ទាល់ខ្លួនរបស់លោក ស្ទីវ ហេដឌ័រ) ។ មានការបញ្ជាក់តែមួយគត់ចំពោះការអះអាងរបស់ អៀង សារី ។ ឯកសារនោះគឺមានលេខ CMR71.10 មាស ម៉ុន (ហៅ កែវ ស៊ីធុន) ដែលសរសេរនៅខែមិថុនា ឆ្នាំ១៩៧៨ ក្រោយពី សោ ភឹម ធ្វើអត្តឃាត ។ ឯកសារនេះបានដកស្រង់សម្ដីរបស់ សោ ភឹម ដែលនិយាយថា គាត់នៅតែជាសមាជិក «គណៈកម្មាធិការយោធាសន្តិសុខ» ដដែលទេ ។ និយាយទៅកាន់អ្នកយកពត៌មានម្នាក់កាលពីឆ្នាំ១៩៩៧ អៀង សារី និយាយថា មានតែ«មនុស្សពីរនាក់ប៉ុណ្ណោះដែលដឹងពីរឿង[ស-២១] នេះច្បាស់...គឺមាន នួន ជា ដែលទទួលបន្ទុកខាងសន្តិសុខបក្ស និង សុន សេន ដែលទទួលខុសត្រូវសន្តិសុខរដ្ឋ» (សៀវភៅនិពន្ធដោយ ខាម មានចំណងជើងថា «កម្ពុជា» ទំព័រទី១៨) ។ វាហាក់ដូចជាថា កម្មាភិបាលយោធាជាន់ខ្ពស់នៅទីក្រុងភ្នំពេញក៏បានដឹងថា មានគុកនេះដែរ ពីព្រោះប្រតិភូមកពីមន្ទីរស-២១ ដូចដែលបានកត់ត្រានៅក្នុងកំណត់ហេតុបានចូលរួមប្រជុំមួយចំនួនដែលរៀបចំឡើងដោយ សុន សេន ផ្ទាល់ ។

៦) ស្នាដៃនិពន្ធរបស់លោក សាំម័រ មានចំណងជើងថា «បក្សកុម្មុយនិស្តកម្ពុជាៈ ទ័ពស្រួចសម្ងាត់» ។

៧) ទស្សនាវដ្ដីទង់បដិវត្តច្បាប់ចេញផ្សាយខែធ្នូ ឆ្នាំ១៩៧៧-ខែមករា ឆ្នាំ១៩៧៨ ទំព័រទី១៦ ។

៨) ស្នាដៃនិពន្ធរបស់លោក សាំម័រ មានចំណងជើងថា «បក្សកុម្មុយនិស្តកម្ពុជាៈ ទ័ពស្រួចសម្ងាត់» ទំព័រទី១១ ។ សូមមើលសុន្ទរកថារបស់ ប៉ុល ពត «ជយោ! បុណ្យខួបអនុស្សាវរីយ៍បក្សកុម្មុយនិស្តលើកទី១៧» ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៧៧ FBIS ២ តុលា ១៩៧៧ ។ សុន្ទរកថាកត់សម្គាល់ថា «ខ្សែបណ្ដាញសម្ងាត់គឺជាបញ្ហាសំខាន់ណាស់ ។ វាធ្វើឲ្យយើងការពារបដិវត្តន៍ និងបំផុសបំផុលប្រជាជនបាន» ។

៩) CMR99.7 ។ ឯកសារបន្តនិយាយថា «រក្សាការណ៍សម្ងាត់ជាដួងព្រលឹងនៃការងារសន្តិបាល» ។

១០) «ផែនការបក្ស ៤/៨/៧៨» ឯកសារមិនទាន់ចុះលេខមួយទំព័រពីបណ្ណសារមន្ទីរស-២១ ។

១១) សៀវភៅទូរស័ព្ទលេខCMR187.9 ។ បន្ទប់សួរចម្លើយនិងបន្ទប់អន្តភាពនីមួយៗសុទ្ធតែមានលេខទូរស័ព្ទរៀងៗខ្លួន ។ ឌុច មានពីរ ។ ការទាក់ទងទៅខាងក្រៅគុកធ្វើឡើងតាមវិទ្យុទាក់ទង ។

១២) កិច្ចសម្ភាសន៍របស់លោក ឌូក្លាស់ នីវិន ជាមួយ គក ស្រស់ ។

១៣) ពត៌មានអំពីរថយន្តរបស់ចិន សូមមើលកិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយ អ្នក ឯក ប៊ុនណា ។ ចំណែកការិយាល័យ១០០ សូមមើលស្នាដៃនិពន្ធរបស់លោក ឆេនដល័រ មានចំណងជើងថា «បងលេខមួយ» ទំព័រទី៧១ ។ CMR42.21 អ៊ុង ឆេងអ៊ីម ។ CMR53.27 យាង ស៊ីមហ៊ិន និង CMR138.11 សៀត ផៃ (ហៅទុំ) ។

១៤) ស្នាដៃនិពន្ធរបស់លោក ជែកសុន មានចំណងជើងថា «កម្ពុជាៈ ១៩៧៥-១៩៧៨» ទំព័រទី ៨៨ ។ ចង់ជ្រាបពត៌មានបន្ថែមស្តីពី «គហបតី» សូមមើលដុំមីក្រូហ្វីលលេខCMR134.28 ជ័យ សួន ជាការពិពណ៌នាត្រួសៗអំពីថ្នាក់ដឹកនាំបក្សកុម្មុយនិស្តកម្ពុជាដែលបង្កើតបានជាផ្នែកមួយនៃចម្លើយសារភាព ។ ជ័យ សួន និយាយបន្តថា គាត់យល់ថា សុន សេន អាច«កសាងបុគ្គលិកលក្ខណៈរបស់គាត់ដើម្បី...ឲ្យចូលចំណោមវណ្ណៈកម្មករ កសិករ ទាំងការនិយាយស្តី ទាំងការរស់នៅរាល់ថ្ងៃ» ។ ក្រោយពីនិយាយចេញនូវសម្តីនេះមក «ខ្ញុំក៏សុំឲ្យគាត់អភ័យទោសឲ្យខ្ញុំផង ចុះក្រែងលោមានពាក្យសម្តីមិនសមគួរ» (ឯកសារបកប្រែរបស់លោក ស្ទីវ ហេដឌ័រ) ។

១៥) កិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ញ៉ែម អេន ដែលអះអាងថា សុន សេន បានមកកាន់មន្ទីរស-២១ ទៀងរាល់ចុងសប្តាហ៍ ។ កំណត់ហេតុរំពុករបស់ «សុន សេន ជូនចំពោះ ឌុច»ចុះខែតុលា ឆ្នាំ១៩៧៧ ។ CMR67.25 លឿង លី មានចំណារមួយពី សុន សេន ជូនចំពោះ ឌុច ។ បុគ្គលិកបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញឯកសារចំនួនប៉ែតសិបបួន ពីមន្ទីរស-២១ ។ ឯកសារទាំងអស់ដែលធ្វើឡើងនៅឆ្នាំ១៩៧៧មានតែបួនប៉ុណ្ណោះដែលមានចំណាររបស់ សុន សេន ។

១៦) ចម្លើយសារភាពនៅបណ្ណសារមន្ទីរស-២១ ដែលនិយាយពាក់ព័ន្ធ សុន សេន រួមមានឯកសារនៅដុំមីក្រូហ្វីលលេខCMR20.34 ជា សាម៉េត, CMR21.25 ឆាយ គីមហួរ និង CMR21.26 ចាន់ គីម ។

១៧) នៅពេល ប៉ុល ពត ត្រូវបាន «កាត់ទោស» នៅមូលដ្ឋានខ្មែរក្រហមអន្លង់វែងកាលពីខែកក្កដា ឆ្នាំ១៩៩៧ ប៉ុល ពត ត្រូវបានចោទប្រកាន់ពីបទបញ្ជាឲ្យសម្លាប់ សុន សេន ហើយត្រូវកាត់ឲ្យជាប់ទោសអស់មួយជីវិត ។ នៅក្នុងកិច្ចសម្ភាសន៍ជាមួយលោក ណេត ថាយ័រ បីខែក្រោយមក ប៉ុល ពត បានអះអាងទទួលខុសត្រូវថា ខ្លួនពិតជាបានបញ្ជាឲ្យគេសម្លាប់ សុន សេន ពិតមែន ប៉ុន្តែមានការសោកស្តាយណាស់ចំពោះកូន សុន សេន ដែលត្រូវសម្លាប់ជាមួយគ្នាទាំងអស់ ។ សូមមើលស្នាដៃនិពន្ធរបស់លោក ណេត ថាយ័រ មានចំណងជើងថា «ថ្ងៃជម្រះបញ្ជី» ។

១៨) កិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយ អ្នក ឯក ប៊ុនណា ។ សូមមើលស្នាដៃនិពន្ធរបស់លោក ព្រីងហ្គល មានចំណងជើងថា «មនុស្សស៊ីឈ្នួលរបស់ ប៉ុល ពត» ។ ស្នាដៃនិពន្ធរបស់លោក ប៉ែន យៀវនិន មានចំណងជើងថា «របប ប៉ុល ពត» ទំព័រទី៣១ និងស្នាដៃនិពន្ធរបស់ ប៉េកយ័រ មានចំណងជើងថា «ពេលសង្គ្រាមផុតរលត់ទៅ» ទំព័រ២៧២ ព្រមទាំងស្នាដៃរួមគ្នារបស់ ដាន់ ឡុប និង ថាយ័រ មានចំណងជើងថា «ឌុច ឆ្លើយសារភាព» ។

១៩) «នៅលើគ្គាររៀន» ជាកិច្ចសម្ភាសន៍របស់ ហ្សរីមី ស្តូន ជាមួយ លី សូសានណេ ក្នុងរបាយការណ៍ «សមាគមអ្នកវិទ្យាសាស្ត្រអាតូមិក ៤២៤» (ខែមេសា ឆ្នាំ១៩៨៩) ។ ចង់ជ្រាបពត៌មានអំពីឈ្មោះ ចាន់

សូមមើលកិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ឡាច វលក្ខណ៍កល្យាន ។

២០) កិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយ អ្នក ឯក ប៊ុនណា និងអតីតនិស្សិតជនជាតិចិនដែលសុំមិនបញ្ចេញឈ្មោះនិងបានអះអាងថា សហការីរបស់គាត់ទាំងអស់លើកលែងតែម្នាក់ដែលធ្លាប់សិក្សានៅទីក្រុងភ្នំពេញនៅទសវត្សរ៍ឆ្នាំ៦០គឺនៅតែធ្វើជា "អ្នកជំនាញការកម្ពុជា" ដដែល ។

២១) កិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ហ្វ្រង់ស្វ័រ ប៊ីហ្សូត ។ សូមមើលស្នាដៃនិពន្ធរបស់ ស៊េន មានចំណងជើងថា "ចរន្តនៃពេលវេលា" ទំព័រ២៥៨-៦១ និងស្នាដៃនិពន្ធរបស់លោក វីកឃ័រី មានចំណងជើងថា "កម្ពុជាឆ្នាំ១៩៧៥-១៩៨២"ទំព័រ១៥២ ។ ស្នាដៃនិពន្ធរបស់ ឡឺហ្គារ៉េ មានចំណងជើងថា "អ្នកធ្វើធម្មយាត្រាសម្ងាត់" ទំព័រទី២៥៥ និយាយពីប្រលោមលោកប្រឌិតទាក់ទងនឹងការជាប់ឃុំឃាំងរបស់ ប៊ីហ្សូត ។ ពីរឆ្នាំក្រោយមក ឌុច មានមុខនៅក្នុងកិច្ចប្រជុំ "អ្នកចេះដឹង" នៅក្នុងភូមិភាគពិសេស ។ អ្នកចូលរួមជាភ្ញៀវម្នាក់បានធ្វើការកត់សម្គាល់ថា នៅក្នុងខណៈពេលនោះ ឌុច មើលទៅ "ស្គមហើយមានជំងឺទៀតផង" អត្ថបទបោះផ្សាយរបស់ ខានី មានចំណងជើងថា "អំណាចរបស់បក្សកុម្មុយនិស្តក្នុងប្រទេសកម្ពុជា" ទំព័រទី១២ ។ ប្រពន្ធរបស់ ឌុច ឈ្មោះ រ៉ុម ។ រៀបការជាមួយគ្នានៅ អមលាំង ។ កាលនោះ រ៉ុម ទទួលខុសត្រូវខាង "ឃ្លាំងកាត់សម្លៀកបំពាក់" ។

២២) ស្នាដៃនិពន្ធរបស់ ឃៀវនិន មានចំណងជើងថា "យុទ្ធសាស្ត្រឡើងកាន់អំណាចរបស់ ប៉ុល ពត" ទំព័រ៣៣១-៣៥ ។ សូមមើលស្នាដៃនិពន្ធរបស់លោក ឆេនដល័រ មានចំណងជើងថា "សោកនាដកម្ម" ទំព័រទី៣៥៩ និងកិច្ចសម្ភាសន៍របស់លោក ស៊ីវ ហេងឌ័រ ទំព័រទី២៥-២៧ ។

២៣) ចង់ជ្រាបពីចំណាររបស់ ឌុច សូមមើល CMR53.13 កុយ សួន, CMR90.23 អ៊ុំ សឿន, CMR117.112 ព្រាំ ឃឿន និងCMR139.9 ស្ថាន ស្លេស ។ ឯកសារមិនទាន់ចុះបញ្ជីមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជាចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៧៦ និយាយដល់ "ម-២១" ។ តាមការសន្មត "ម" សំដៅមន្ទីរ ហើយឯកសារនេះដាក់ថា ឌុច ជាប្រធាន ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះ ហេងឌ័រ ដែលបានផ្តល់ឯកសារយោងនេះដល់ខ្ញុំ ។

២៤) ចង់ជ្រាបពត៌មានអំពីទីតាំងមន្ទីរនៅតាខ្មៅសូមមើលCMR24.11 ដួង ឃឿន ។

២៥) ទិន្នន័យបានមកពីកិច្ចសម្ភាសន៍របស់អ្នកនិពន្ធផ្ទាល់ លោក ប៉ែន ឃៀវនិន និង ភីតធ័រ ម៉ាឃៀ ជាមួយគាត់និងកិច្ចសម្ភាសន៍របស់ អាឡិចហ្សាន់ឌ័រ ជាមួយ ខៀវ ល ។ ស្ន័យទិគៀនរបស់ ឌុច មាននៅក្នុងកំណត់ហេតុប្រជុំជីវភាពនៅក្នុងសៀវភៅកំណត់ហេតុរបស់ ម៉ម ណៃ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៦ (ឯកសារមិនទាន់ចុះបញ្ជី) ដែលក្នុងឯកសារនេះ ឌុច បាននិយាយថាខ្លួន "មិនសូវមានរបៀបរៀបរយទេ" ដោយផ្អែកតែទៅលើកិច្ចការរបស់ខ្លួនឯង ភ្លេច"សមូហភាព" និង ជួនកាល"បាត់ម្ចាស់ការ និងអស់សង្ឃឹមទៀតផង" ។ គក ស្រស់ ដែលផ្តល់បទសម្ភាសន៍អំពីមន្ទីរស-២១ ជាលើកដំបូងក្នុងឆ្នាំ១៩៩៧ បានរៀបរាប់ការចងចាំរបស់គាត់ទាក់ទងរឿងរបស់ ឌុច ។ ការរៀបរាប់របស់ គក ស្រស់ ហាក់ដូចជាបង្ហាញថាអំពើអាក្រក់របស់ ឌុច មិនធ្វើឲ្យមានផលប៉ះពាល់ដល់គាត់ឡើយ ។

២៦) CMR99.13 ។

*២៧) ចង់ជ្រាបពីការចាកចេញរបស់ ឌុច សូមមើលកិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ហ៊ីម ហ៊ុយ ញ៉ែម អេន និង វ៉ាន់ ណាត ព្រមទាំងកិច្ចសម្ភាសន៍របស់ ប៉ែន យៀវនិន ជាមួយ ហ៊ីម ហ៊ុយ ។ នៅឆ្នាំ១៩៩៨ ញ៉ែម អេន និយាយយ៉ាងដាច់ណាត់ថា ឌុច ស្លាប់បាត់ហើយ ។ ចង់ជ្រាបពីការលេចមុខសាជាថ្មីដ៏គួរឲ្យភ្ញាក់ផ្អើលរបស់ ឌុច នៅឆ្នាំ១៩៩៩ សូមមើលស្នាដៃនិពន្ធរួមរបស់ ដាន់ ឡុប និង ណេត ថាយ័រ មានចំណងជើងថា «ឌុច ឆ្លើយសារភាព» និង ស្នាដៃនិពន្ធរបស់ សេដ មីដាន់ មានចំណងជើងថា «អ្នកធ្វើទារុណកម្មទសវត្សរ៍ទី៧០ក្នុងប្រទេសកម្ពុជាឥឡូវកំពុងតែសុំសីល» ។*

*២៨) កិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយ គក ស្រស់ ។ អតីតអ្នកធ្វើការខាងឯកសារឈ្មោះ សួស ធី បានប្រាប់ សេដ មីដាន់ ក្នុងឆ្នាំ១៩៩៦ថា «ខ្ញុំខ្លាច "ហ៊ី" ណាស់ សូម្បីតែមើលមុខគាត់ ក៏ខ្ញុំមិនហ៊ានមើលផង ។ ខ្ញុំសុបិនឃើញគាត់ហាក់ដូចជាសត្វខ្លាអ៊ីចឹង (មីដាន់ៈ ឯកសារសម្ងាត់របស់ឃាតករខ្មែរ) ។ ហ៊ីម ហ៊ុយ ប្រាប់ ឌូក្លាស នីវីន និង ភីតធ័រ ម៉ាឃ្វៀ ថា «មានពេលមួយនោះក្រោយពី ហ៊ី ជេរប្រទេចខ្ញុំ ខ្ញុំអង្គុយយំម្នាក់ឯង ។ ខ្ញុំចង់បាញ់សម្លាប់ខ្លួនឯងចោល» ។*

*២៩) អុង ផេង ឯកសារលេខD០០០១៥ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា កិច្ចសម្ភាសន៍ជាមួយ ហ៊ីម ហ៊ុយ ឆ្នាំ១៩៨៧ ។ ឯកសារមិនទាន់ចុះបញ្ជីនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៧៨ មានរាយឈ្មោះអ្នកទោសដប់ប្រាំបីនាក់ មានអ្នកទោសខ្លះមានអាយុទើបតែប្រាំបួនឆ្នាំ ។ បញ្ជីរាយឈ្មោះនេះមានចំណាររបស់ ឌុច ដាក់ថា «ពូ ប៉េង! វាយចោលឲ្យហួត» ។*

*៣០) ការសួរចម្លើយជនជាតិវៀតណាម ដែលមានសរសេរនៅក្នុងសៀវភៅរបស់ ចាន់ ដុំមីក្រូហ្វីល CMR18 ។ ញ៉ែម អេន និយាយថា ចាន់ បានសួរចម្លើយ «អ្នកទោសវៀតណាមទាំងអស់» (កិច្ចសម្ភាសន៍របស់អ្នកនិពន្ធនៅខែកុម្ភៈ ឆ្នាំ១៩៩៧) និងសៀវភៅកំណត់ហេតុគ្មានចំណងជើងដែលមានប្រវត្តិរូបរបស់អ្នកទោសវៀតណាមមួយចំនួនមានស្នាមផ្តិតមេដៃរបស់ ចាន់ ។ ឯកសារទាំងនេះមាននៅក្នុងប្រអប់លេខ ១៣ តម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ នៅឆ្នាំ១៩៩០ ណេត ថាយ័រ មើល ញ៉ែម អេន ធ្វើគ្រាប់តាម ចាន់ នៅពេលសួរចម្លើយអ្នកទោសវៀតណាមនៅព្រំដែនថៃ-កម្ពុជា (ការទាក់ទងផ្ទាល់ខ្លួន) ។ គ្រីស្តូហ្វេ ប៉េសឈួស (ការទាក់ទងផ្ទាល់ខ្លួន) ។*

*៣១) សូមមើល«ជីវទស្សន៍បដិវត្តរបស់សមមិត្ត ប៉ុន» ។ ឯកសារមិនទាន់ចុះបញ្ជីចំនួន២១សន្លឹក តម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាទំព័រ១៧-២១ ខែធ្នូ ឆ្នាំ១៩៧៦ ។ នៅក្នុងឯកសារនេះ ប៉ុន ចាត់ទុកការធ្វើទារុណកម្មជាច្រើនលើកថា ជាចំណុចខ្វះខាត ប៉ុន្តែពាក្យស្តីបន្ទោស ប៉ុន មាននៅក្នុងបណ្ណសារ ។ នៅក្នុងសៀវភៅកំណត់ហេតុរបស់ ចាន់ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៧៧ ប្រហែលជាក្រោយពីវគ្គប្រជុំស្វ័យទិតៀន ប៉ុន ត្រូវបានគេលើកសរសើរថា «គោរពតាមអង្គការថ្នាក់លើបានយ៉ាងហ្មត់ចត់» ។*

*៣២) សៀវភៅកំណត់ហេតុរបស់ ទុយ-ប៉ុន មិនទាន់ចុះបញ្ជីតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៨ ។*

*៣៣) សូមមើលប្រវត្តិស្វ័យទិតៀនរបស់ សួស ធី ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ១៩៧៧ តម្កល់ទុកនៅ*

មជ្ឈមណ្ឌលឯកសារកម្ពុជា ។

៣៤) កិច្ចសម្ភាសន៍របស់លោក ភីតធ័រ ម៉ាឃៀ ជាមួយ សួស ធី ។

៣៥) កិច្ចសម្ភាសន៍របស់អ្នកស្រី សារ៉ាខូម ជាមួយ វ៉ាន់ ណាត, កិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ញ៉ែម អេន និងឯកសារលេខD០០០១៥, បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា ១៩៨៧ ។ ពត៌មានបន្ថែមសូមមើលសៀវភៅប្រវត្តិ វ៉ាន់ ណាត ទំព័រ១១០, ប្រវត្តិស៊ុយទិតៀន ឯកសារមិនទាន់ចុះបញ្ជីតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជានិងអត្ថបទរបស់ ម៉ូលី អូខេន មានចំណងជើងថា "ការបំបាត់ឆ្នាំសូន្យ" នៅក្នុងសារពត៌មាន ហ្កាឌាន វីកឃិន ចេញផ្សាយថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៧ ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះ វីកតូរីយ៉ា ស្មីត ដែលបានធ្វើឲ្យខ្ញុំចាប់អារម្មណ៍លើអត្ថបទនេះ ។

៣៦) ចម្លើយសារភាពរបស់ "ហ៊ុយ ស្រែ" នៅដុំមីក្រូហ្វីលលេខCMR83.2 ។ ចង់ជ្រាបអំពីវគ្គសិក្សាសូមមើលដុំមីក្រូហ្វីលលេខCMR97.2 សៀវភៅកំណត់ហេតុវគ្គសិក្សានយោបាយរបស់ លន់ គីមអាយតាំងពីឆ្នាំ១៩៧៦ ។ ប្រវត្តិស៊ុយទិតៀនរបស់ប្រពន្ធ ហ៊ុយ មាននៅក្នុងឯកសារលេខ96ST មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ប៉ុន្តែចម្លើយសារភាពរបស់គាត់មិនមាននៅសេសសល់ទេ ។ គក ស្រស់ បាននិយាយថាមានតែកម្មាភិបាលជាន់ខ្ពស់ដូចជា ឌុច, ហ៊ី និង ចាន់ ទើបគេអនុញ្ញាតឲ្យយកគ្រួសារមកនៅក្បែរៗមន្ទីរ [ស-២១] (កិច្ចសម្ភាសន៍របស់អ្នកនិពន្ធ) ។

៣៧) ក្រុមកាចៈ ដុំមីក្រូហ្វីលលេខCMR87.2, ណុប នួន ។ ក្រុមស្លូត cf.1067 មជ្ឈមណ្ឌលឯកសារកម្ពុជា-ខែមិថុនា ឆ្នាំ១៩៧៧ ។ ចំពោះការហាមប្រាមរបស់ក្រុមស្លូតសួរចម្លើយក្នុងការធ្វើទារុណកម្មគឺមាននៅក្នុងដុំមីក្រូហ្វីលលេខCMR92.11 អ៊ូច អ៊ីន ។ ចង់ជ្រាបអំពីពត៌មានទាក់ទងនឹងក្រុមត្រជាក់សូមមើលដុំមីក្រូហ្វីលលេខCMR159.2 សុខ ញឹម, ចម្លើយសារភាពរបស់ ឈឹម ឈុន លេខ៤១៨បបក២ (មិនទាន់ថតចម្លងនៅឡើយ) កំពុងតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា និងឯកសារតារាងអ្នកទោសមិនទាន់ចុះបញ្ជីពីមជ្ឈមណ្ឌលឯកសារកម្ពុជាចុះថ្ងៃទី៣០ ខែមីនា និង២៧ ខែឧសភា ឆ្នាំ១៩៧៨ ។ ក្រុមអង្កៀម និងក្រុមត្រជាក់មាននៅក្នុងបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជាចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៧៨ ។ អ្នកទោសដែលសួរចម្លើយដោយក្រុម"អង្កៀម" ច្រើនជាកម្មាភិបាលថ្នាក់កណ្តាលមកពីបណ្តាភូមិភាគនានា ។ នៅខែកុម្ភៈឆ្នាំ១៩៧៨ អ្នកទោសចំនួនហាសិបមួយនាក់ត្រូវបានក្រុមនេះយកមកសួរចម្លើយ ។ មួយខែក្រោយមកក្រុមអង្កៀមនេះបានចាត់ការជាមួយអ្នកទោសចំនួនសែសិបនាក់ ។ ចំពោះក្រុមក្តៅ សូមមើលឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមិនទាន់ចុះបញ្ជីចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៧៨ និងឯកសារចុះខែកុម្ភៈនិង៣០ មីនា ១៩៧៨ ។ ស្នាដៃនិពន្ធរបស់លោក សីបុល មានចំណងជើងថា "ភាពព្រឺខ្លាច និងសភាពដូចគ្នា" មានរៀបរាប់ពីក្រុមសួរចម្លើយ "ស្លូត" និង "ក្តៅ" នៅយ៉ាអាន ឆ្នាំ១៩៨៣ ។

៣៨) ឯកសារលេខ96TS មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ដុំមីក្រូហ្វីលលេខCMR45.2 ចម្លើយសារភាពរបស់ គុន ប្រពន្ធរបស់កម្មាភិបាលជាន់ខ្ពស់ត្រូវបានចុះហត្ថលេខាដោយយុវនារីសួរចម្លើយពីរនាក់ ឈ្មោះ នី និង លី ។

៣៩) ដុំមីក្រូហ្វីលលេខCMR69.30 ។

៤០) សូមមើលCMR86.25 នៅ ភុច ។

៤១) ចម្លើយសារភាពរបស់អ្នកធ្វើការខាងឯកសាររួមមានដុំមីក្រូហ្វីលលេខCMR3.24 ប៊ុត ហេង, CMR46.15 កែវ លីថុង និងCMR106.11 ផេង ឡេងហួយ ។

៤២) ហ្វីលត្រូវបានលាងសម្អាត ផ្ចិត និងចុះលេខបញ្ជីដោយក្រុមបណ្ណសារផ្នែករូបថតជាអង្គការក្រៅរដ្ឋាភិបាលដែលត្រូវបង្កើតឡើងនៅឆ្នាំ១៩៩៤ ដោយអ្នកថតរូបសម្រាប់សារព័ត៌មានរបស់អាមេរិកាំងលោក ឌូក្លាស នីវិន និង គ្រីស រីលី ដែលនិពន្ធសៀវភៅ«វាលពិឃាត» ។ បើយោងតាមសម្តីរបស់ ញ៉ែម អេន ថា ក្រុមរូបថតនេះក៏បានយករូបថត (ថតដោយឥតព្រានទុក) របស់អ្នកធ្វើការនៅក្នុងគុក ។ រូបថតទាំងនេះមួយចំនួនដែលមាននៅក្នុងខ្សែភាពយន្តរបស់អាឡឺម៉ង់ខាងកើតមានចំណងជើងថា «អង្គការស្ទីគេនោះ» តាំងពីពេលនោះមកមិនឃើញលេចស្រមោលឡើយ មិនខុសពីរូបថតអ្នកទោសស្លាប់ដែលមានបញ្ចាំងនៅក្នុងភាពយន្តនេះទេ ។

៤៣) កិច្ចសម្ភាសន៍របស់អ្នកនិពន្ធ និងលោក ដូក្លាស នីវិន ជាមួយ ញ៉ែម អេន ។ ព័ត៌មានបន្ថែមទៀតសូមមើលស្នាដៃនិពន្ធរបស់ ម៉េក ដូវើល មានចំណងជើងថា «ជាងថតរូបនឹកដល់ថ្ងៃនៅក្រោយកញ្ចក់កាមេរ៉ានៅទួលស្លែង» ។ ចំពោះឯកសារយោង «រូបថត ថតមិនល្អ ឬមិនច្បាស់» សូមមើលសៀវភៅកំណត់ហេតុរបស់ ចាន់ តម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៧៧ ។

៤៤) សូមមើលដុំមីក្រូហ្វីលលេខCMR99.8 «អំពីវិន័យការពារខ្មាំង» ។ សូមមើលឯកសារមិនទាន់ចុះបញ្ជីពីបណ្ណសារមន្ទីរស-២១ ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៧៦ (ជាវិន័យមួយផ្សេងទៀត) ។

៤៥) កិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយ គក ស្រស់ ។

៤៦) ដុំមីក្រូហ្វីលលេខCMR98.8 មានសរសេរអំពីវិន័យចំនួនសាមសិប «ខ» សម្រាប់ឆ្នាំ ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាលេខ១០៦៤ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៧៦ មានរាយបទបញ្ជាមួយចំនួនមានលក្ខណៈខុសគ្នាតែបន្តិចបន្តួចប៉ុណ្ណោះ ។ វិន័យរបស់ឆ្នាំដែលមិនបានសង្កេតមើលការសួរចម្លើយមាននៅក្នុងឯកសារមិនទាន់ចុះបញ្ជីតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ ១៩៧៦ ។

៤៧) សូមមើលដុំមីក្រូហ្វីលលេខCMR29.3 អ៊ាម រ៉ុន ។ វ៉ាន់ ណាត និយាយថា អ្នកទោសជួនកាលត្រូវបានគេវាយព្រាវៗនៅក្នុងចន្លោះអគារគុក ។

៤៨) ឯកសារលេខD-1063 មជ្ឈមណ្ឌលឯកសារកម្ពុជាចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៧៦ ។ ចុងបញ្ចប់ឯកសារសរសេរថា នៅពេលនោះមានអ្នកទោសតែ២៥៨នាក់ប៉ុណ្ណោះ ដែលត្រូវឃុំឃាំងនៅមន្ទីរស-២១ ។ គ្មានចម្លើយសារភាពរបស់អ្នកទោសណាម្នាក់ដែលមានឈ្មោះនៅក្នុងអត្ថបទនេះនៅសេសសល់ឡើយ ។ លោក ស្ទីវ ហេដឌ័រ មានយោបល់ថា ដំណើរការនេះប្រហែលជាត្រូវបានរឹតបន្តឹងក្រោយពី កែវ មាស ត្រូវបានចាប់ឃុំខ្លួននៅខែកញ្ញា ឆ្នាំ១៩៧៦ (ទំនាក់ទំនងផ្ទាល់ខ្លួន) ។ ភាពពិសេសនៃឯកសារ

ជាពិសេសប្រភេទឯកសារដែលរៀបចំធ្វើឡើងនៅពេលយប់បង្ហាញថា ឯកសារជាច្រើនដែលរៀបចំនៅមន្ទីរស-២១ត្រូវបាត់បង់អស់ ។

៤៩) ដុំមីក្រូហ្វីលលេខCMR17.24 ជ័យ ផាង និង CMR29.3 ង៉ាម វ៉ុន ដែលបានសារភាពថា បានបង្អត់បាយនិងវាយអ្នកទោសមួយចំនួនដែលខ្លួនប្រើឲ្យកើបលាមក ។ ចង់ជ្រាបពីឧទាហរណ៍ដែលនិយាយអំពីអ្នកទោសដែលត្រូវផ្ទេរពីព្រៃសមកមន្ទីរស-២១ សូមមើលដុំហ្វីលលេខCMR20.4 ឈឿន ចេក ។

៥០) ចំពោះក្រុមសេដ្ឋកិច្ច សូមមើលឯកសារតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមិនទាន់ចុះបញ្ជីចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧៧ ។ របាយការណ៍របស់ ឌុច មាននៅក្នុងដុំមីក្រូហ្វីលលេខCMR99.10 ។ ទា និង មាន់ មានប្រយោជន៍សេដ្ឋកិច្ចមិនដូចជាមនុស្សទេ ។

៥១) ឯកសារមិនទាន់ចុះបញ្ជីប្រមូលពីព្រៃសមកតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ។ សូមមើលដុំមីក្រូហ្វីលលេខCMR80.28 ម៉ម បុល ដែលត្រូវបានចាប់មកវិញក្រោយពីរត់ពីព្រៃសរយៈពេលបីថ្ងៃ ។ ម៉ម បុល ត្រូវគេចាប់ដាក់ព្រៃសដោយសាររត់ចោលអង្គភាព ។

៥២) សូមមើលឯកសារតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាលេខ1116 TSL ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ១៩៧៦ ដែលចុះហត្ថលេខាដោយ ចាន់ ក្នុងនោះមានរាយឈ្មោះអ្នកទោស “ជាច្រើន” ដែលមានជំងឺ ។ ពត៌មានក្រៅពីនេះសូមមើលសៀវភៅរៀនវគ្គសិក្សានយោបាយមានចំណងជើងថា “លិទ្ធិម៉ាក្ស-ឡេនីន” ដែលជាឯកសារមិនទាន់ចុះបញ្ជីតម្កល់ទុកនៅបណ្ណសារមន្ទីរស-២១ លេខ៣៨ ។ សូមមើលសៀវភៅកំណត់ហេតុរបស់ ចាន់ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៧៧ “ការចោទប្រកាន់ឈ្មោះ ផេង ទ្រី ដុំមីក្រូហ្វីលលេខCMR183 ។ វ៉ា ស្រេង ពេទ្យយោធានៅមន្ទីរស-២១ បានឆ្លើយសារភាពថា បានរៀនវគ្គមីក្រូស្កុបចំនួនពីរសប្តាហ៍មុនពេលមកកាន់មន្ទីរស-២១ ។

៥៣) ដុំមីក្រូហ្វីលលេខCMR106.3 ដួង ជីវ ។ សូមមើលឯកសារមិនទាន់ចុះបញ្ជីនៅមន្ទីរស-២១ ចុះថ្ងៃទី២ ខែមីនា ឆ្នាំ១៩៧៧: “មនុស្ស៤នាក់ត្រូវបានសម្លាប់ដោយអារកយកឈាម” ។ ស្នាដៃរបស់ លោក ប៊ែន ឃៀរនិន មានចំណងជើងថា “របប ប៉ុល ពត” ទំព័រទី៤៣៩ និយាយដល់ “កូនសៀវភៅតូចមួយមានរាងចតុកោណកែង...មានដាក់ចំណងជើងថា “ពិសោធន៍មនុស្ស” ដែលត្រូវបានគេរកឃើញនៅជិតមន្ទីរស-២១ កាលពីឆ្នាំ១៩៧៩ ។ នៅក្នុងទំព័រកូនសៀវភៅផ្អត់ដែលត្រូវបានផលិតសាជាថ្មីនៅក្នុងខ្សែភាពយន្តមួយមានចំណងជើងថា “អង្គការស្ទីគេនោះ” ជាមួយនឹងសក្ខីកម្មរបស់អតីតអ្នកធ្វើការនៅមន្ទីរស-២១ ដែលបង្ហាញថា ជួនកាលអ្នកទោសត្រូវបានចាក់បង្ហូរឈាមទាល់តែខ្សោះខ្លួនស្លាប់ ។ ចង់ជ្រាបពត៌មានបន្ថែមទាក់ទងនឹងការពិសោធន៍មួយផ្សេងទៀត សូមមើលស្នាដៃនិពន្ធរបស់ រីឆាត អារ៉ង់ (ការទាក់ទងផ្ទាល់ខ្លួន) ដែលលើកឡើងនៅក្នុងកិច្ចសម្ភាសន៍ដែលគាត់ធ្វើជាមួយអតីតកម្មាភិបាលខ្មែរក្រហមនៅឆ្នាំ១៩៩៦ ។

៥៤) ប្រភេទវណ្ណៈដែលបែងចែកដោយប្រជាជនមូលដ្ឋានជនបទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (“កសិករមាន” “កសិករកណ្តាល” ពីរវណ្ណៈ និង “កសិករក្រ” បីវណ្ណៈ) ជាគំរូដែលខ្ចីពីប្រទេសចិន តាមរយៈប្រទេសវៀតណាមដោយគ្មានគិតគូរពីស្ថានភាពប្រជាជនកម្ពុជាឡើយ ។ សូមមើលស្នាដៃរបស់ ខានី មាន

ចំណងជើងថា «អង្គការដ៏មានអំណាច» ទំព័រទី៩៩-១០០ ។

៥៥) សម្តីរបស់ ម៉ៅ ធ្វើឡើងជាលើកដំបូងនៅឆ្នាំ១៩៥៦ ។ សូមមើលស្នាដៃរបស់ ស្តារ និង ដាយ័រ មានចំណងជើងថា «កិច្ចការរបស់ ម៉ៅ សេទុង ក្រោយរំដោះ» ទំព័រទី៧៣ និងស្នាដៃនិពន្ធរបស់ មូឌី «ការជិតាស់និងខ្វែងយោបល់» ទំព័រទី៦២ ។ សូមមើលស្នាដៃនិពន្ធរបស់លោក បូមែន មានចំណងជើងថា «គំនិតសម័យថ្មី និង ហាយនភាព» ដែលសរសេរនៅក្នុងន័យផ្សេងមួយទៀតថាៈ«ភាពងាយបត់បែនបាន និងភាពឯកោគ្មានទីរំពឹងបង្កើតបានជាការចាប់អារម្មណ៍មួយដែលអ្នកមានគំនិតហួសវិស័យ [អាច] ជិតាស់រឹងទទឹង ហើយក៏អាចបង្កើតជាសភាពមួយដែលអ្នកទាំងនោះមិនអាចត្រូវបានគេជិតាស់ដែរ» ទំព័រទី១១៤ ។

៥៦) ដុំមីក្រូហ្វីលលេខCMR47.14 កាង លាង ។ ឃ្លានេះក៏ដកស្រង់កិច្ចសម្ភាសន៍របស់ សួង សូរិយា, សៀ ឆេង និង មុត សុភា ដែលជាក្មេងជំទង់នៅសម័យកម្ពុជាប្រជាធិបតេយ្យ ។

៥៧) និយាយទៅកាន់លោក អាឡិចហ្សាន់ឌ័រ ហ៊ិនតុន អតីតឆ្មាំសន្តិសុខខ្មែរក្រហមឈ្មោះ ខៀវ ល បានកត់សម្គាល់ថា «យុវជនវ័យក្មេងជាច្រើនត្រូវតែយកមកធ្វើជាកម្មាភិបាលចេញពីសង្គ្រាមស៊ីវិល ដែលកាលនោះអ្នកទាំងនេះនៅតូចៗនៅឡើយ ។ យុវជនវ័យក្មេងទាំងនេះក្រោយមកក៏ឡើងចាង ហើយចាប់ផ្តើមយកកុមារក្មេងៗជាងខ្លួនឲ្យមកជួយធ្វើកិច្ចការខ្លួននៅក្នុងគុកជាបន្តបន្ទាប់» ។

៥៨) សូមមើលស្នាដៃនិពន្ធរបស់ ហ្គូរីវិច មានចំណងជើងថា «លិខិតមកពីរ៉ាន់ដា» ទំព័រ៧៨-៩៥ និងស្នាដៃរស់រវើកនិងមើលទៅគួរឲ្យចុកចាប់ក្នុងចិត្តមានចំណងជើងថា «ខ្ញុំសូមជម្រាបប្រាប់អស់លោកអ្នកថា ថ្ងៃស្អែកគេនឹងសម្លាប់គ្រួសារយើងទាំងពូជហើយ» ។ ម៉ូលីកា បានធ្វើការងារយ៉ាងច្រើនជាមួយជនភៀសខ្លួនខ្មែរនៅសហរដ្ឋអាមេរិក ។ សូមមើលស្នាដៃនិពន្ធរបស់ ប៉ុន ចត មានចំណងជើងថា «ការផ្លាស់ប្តូរសង្គមនៅក្នុងគំនូចបដិវត្តន៍» ដែលអះអាងថា «ជនបដិវត្តខ្មែរកែប្រែនូវអ្វីដែលជាសារជាតិរបស់សង្គមខ្មែរ» ទំព័រ១៦៩ ។ ចំពោះការសិក្សាស្វែងយល់អំពីកងទ័ពជើងទឹកអាមេរិកដែលមានអាយុដំណាលៗគ្នា សូមមើលស្នាដៃនិពន្ធរបស់ សូលី មានចំណងជើងថា «សឺន ថាង» ។

៥៩) កំណត់ហេតុប្រជុំក្រសួងលើកទីពីរថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៧៦ ឯកសារលេខ៧០៥ តម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាទំព័រទី២៩ ។ ប៉ុល ពត បន្តទៀតថា កម្មាភិបាលវ័យក្មេងនៅតាមមន្ទីរពេទ្យជួនកាលគ្រប់គ្រងផ្នែកឱសថខុសដោយសារខ្លួនមិនចេះអានអក្សរ ។ ប៉ុល ពត បានបិទកិច្ចប្រជុំដោយកត់សម្គាល់ទាំងក្តីរីករាយថា «បីទៅប្រាំឆ្នាំទៅមុខទៀត នៅពេលខ្មាំងធ្វើអ្វីយើងមិនកើត យើងនឹងកាន់តែមានអំណាច ។ យើងនឹងក្លាយទៅជាគំរូរបស់ពិភពលោកទាំងមូល» ។ ចង់ជ្រាបពត៌មានបន្ថែម សូមមើលឯកសារលេខ១១២៧តម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែលជាកិច្ចប្រជុំយុទ្ធជននៅមន្ទីរស-២១ ។ ឯកសារនេះធ្វើការកត់សម្គាល់ថា យុទ្ធជនវ័យក្មេងនៅមន្ទីរស-២១ ច្រើនតែខ្ជិលធ្វើការ «ហើយងៀតពេលកំពុងប្រជុំ និងរៀនសូត្រទៅ «លេងសើចសប្បាយ»» ។

៦០) ដកស្រង់ចេញពីស្នាដៃនិពន្ធរបស់ ស ក្រោះ មានចំណងជើងថា «គុណសម្បត្តិនៃការប្រោសប្រណី» ទំព័រទី៣៣៤ ។

៦១) សូមមើលស្នាដៃនិពន្ធរបស់លោក ឆេនដល័រ មានចំណងជើងថា «សោកនាដកម្ម» ទំព័រទី២១៨ - ១៩ និងស្នាដៃនិពន្ធរបស់លោក ហ៊ីប សុន មានចំណងជើងថា «បង្រៀនមនុស្សឲ្យចេះធ្វើបាបគេ» ទំព័រទី ៧២-៨៧ ។ ប្រភេទវិន័យ និង ការផ្គួបចូលគ្នានៃការស៊ើបអង្កេតរបស់ ហ៊ីប សុន ដែលលាតត្រដាងនៅក្នុងចំណោមបុគ្គលិកយោធានៅប្រទេសក្រិចកាលពីទសវត្សរ៍ឆ្នាំ៧០ មានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងវិន័យដែលអ្នកសួរចម្លើយនៅមន្ទីរស-២១ធ្លាប់បានឆ្លងកាត់ ។

៦២) កិច្ចសម្ភាសន៍របស់លោក ប៊ែន ឃៀរនិន ជាមួយ ហ៊ឹម ហ៊ុយ ។ ទាក់ទងនឹង ខៀវ សំផន សូមមើលស្នាដៃនិពន្ធរបស់ ហេដឌ័រ ដែលមានចំណងជើងថា «ប៉ុល ពត និង ខៀវ សំផន» និង ស្នាដៃនិពន្ធរបស់ ថាយ័រ មានចំណងជើងថា «ថ្ងៃជម្រះបញ្ជី» ។

៦៣) កិច្ចសម្ភាសន៍របស់លោក ដូក្លាស នីវិន ជាមួយ ញ៉ែម អេន ។

៦៤) កិច្ចសម្ភាសន៍របស់លោក ដូក្លាស នីវិន ជាមួយ ញ៉ែម អេន ដែលនិយាយថា ការកំណត់ដាក់លេខរៀងអ្នកទោសនៅក្នុងឆ្នាំ១៩៧៦-១៩៧៧ គឺផ្អែកទៅលើការចូលរបស់អ្នកទោសប្រចាំថ្ងៃ ដោយចាប់ផ្ដើមរាប់ពីលេខមួយនៅពាក់កណ្ដាលយប់រៀងរាល់ថ្ងៃ ។ រូបថតមួយចំនួនមានដាក់ឈ្មោះនៅជាប់អាវមានចំនួនតួលេខលើសពី៣០០ ។ ចាប់តាំងពីខែធ្នូ ឆ្នាំ១៩៧៨ អ្នកទោសត្រូវបានថតរូបជាមួយនឹងផ្លាកដែលមានរាយឈ្មោះនិងថ្ងៃខែថតរូប ហើយលេខរៀងដល់ខែថ្មីដូរទើបដូរម្ដង ។

៦៥) ចំណារពី ហ៊ុយ ផ្ញើទៅឲ្យ ឌុច ខែធ្នូ ឆ្នាំ១៩៧៨ ដែលជាឯកសារនៅបណ្ណសារមន្ទីរស-២១ ដែលមិនទាន់ចុះបញ្ជី ។ សូមមើលឯកសារលេខ១១៨០ តម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានរាយឈ្មោះអ្នកទោសម្ភៃបួននាក់ដែលជាប់ឃុំនៅក្នុង«គុកពិសេស» ក្នុងខែវិច្ឆិកា និងខែធ្នូ ឆ្នាំ១៩៧៨ ។ និយាយទៅកាន់លោក ភីតធ័រ ម៉ាឃៀ, ហ៊ឹម ហ៊ុយ រំឭកឡើងវិញថាមន្ទីរស-២១ ត្រូវបាន «បោសសម្អាត» ទាំងស្រុងនៅចុងឆ្នាំ១៩៧៨ ។ តាមឯកសាររបស់ រុយ នាគង់ វានៅតែមិនច្បាស់ដដែល មិនដឹងថា «សិប្បករ» ទាំងអស់ដែល នាគង់ ខ្លួនឯងបានលើកឡើង និងដែលមានរៀបរាប់នៅក្នុងកំណត់ប្រវត្តិរបស់ វ៉ាន់ ណាត ជាអ្នកទោសដូច នាគង់ ឬមនុស្សដែលនាំពីកន្លែងផ្សេងទៀតក្រៅពីគុកដែរ ឬយ៉ាងណានោះទេ ។

៦៦) សូមមើលស្នាដៃនិពន្ធរបស់លោក ឡូកា មានចំណងជើងថា «ប្រព័ន្ធព្រហ្មទណ្ឌខ្មែរក្រហម» ។ អ្នកទោសកងទ័ពជាច្រើននាក់ដែលត្រូវជាប់ចោទ (ឬសារភាព) ថាបានប្រព្រឹត្តបទល្មើសធម្មតានិយាយថា អ្នកទោសកងទ័ពកម្ពុជាប្រជាធិបតេយ្យត្រូវបានយកមកឃុំឃាំងនៅមន្ទីរស-២១ ជាជាងឃុំឃាំងក្នុងគុកនៅតាមខេត្ត ។

៦៧) ចម្លើយសារភាពរបស់ស្ត្រីដែលមានឋានៈខ្ពង់ខ្ពស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមាននៅក្នុងដុំមីក្រូហ្វីលលេខCMR26.3 ឌឹម សារឿន, CMR27.3 អៀ ហុង, CMR41.8 អ៊ឹម លី, CMR61.25 ឡេង សុន ហាក់, CMR67.21 ឡាច វ៉ារី, CMR116.20 ព្រុន អូហាល់, CMR165.11 យ៉ាយ ខុន និងCMR167.4 ទេព សាម ។

៦៨) ពីរនាក់ក្នុងចំណោមអ្នកទាំងអស់នេះពោលមាន វ៉ន វ៉េត និង សោ ភឹម ធ្លាប់ធ្វើជាឧបនាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅពេលជាមួយគ្នានោះដែរ សោ ភឹម ធ្វើជាលេខាបក្សភូមិភាគ

បូព៌ា ។ ចង់ជ្រាបពត៌មានអំពីការបោសសម្អាតតាមដំណាក់កាល ៗ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យសូមមើលវគ្គទី៣ ។

៦៩) កិច្ចសម្ភាសន៍របស់លោក ដូក្លាស នីវីន ជាមួយ គក ស្រស់ ។ ឯកសារយោងទាំងអស់អំពីរឿង "គុកពិសេស" មាននៅក្នុងបណ្ណសារដែលតាំងពីឆ្នាំ១៩៧៨ ។ កុយ ធួន កម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមម្នាក់ដែលត្រូវបានដាក់គុកនៅឆ្នាំ១៩៧៧ ។ ក្នុងរូបថតនេះ កុយ ធួន ត្រូវជាប់ច្រវាក់ភ្ជាប់ទៅនឹងគ្រែដែក (មើលរូប) ។

៧០) ស្នាដៃរបស់ សហុស្តី មានចំណងជើងថា "ប្រព័ន្ធភេរវកម្ម" ទំព័រទី១៥៣ ។

៧១) ស្នាដៃនិពន្ធរបស់ ហក មានចំណងជើងថា "មណ្ឌលប្រល័យពូជសាសន៍ទួលស្លែង" ទំព័រទី២៦ ។

៧២) តារាងសម្លាប់សម្រាប់ថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៧៧ ឯកសារនៅបណ្ណសារមន្ទីរស-២១ ដែលមិនទាន់ចុះបញ្ជី ។ ចង់ជ្រាបពីការរំលោភផ្លូវភេទរបស់បុគ្គលិកគុកមកលើអ្នកទោស សូមមើលដុំមីក្រូហ្វីល CMR183.27 វង់ សម្បត្តិ ។ ទោះបីជាឯកសារទាក់ទងនឹងការរំលោភផ្លូវភេទកម្រមានមែន ប៉ុន្តែការបំបាត់ភាពជាមនុស្សរបស់អ្នកទោសនិងការបង្ខំឲ្យអ្នកធ្វើការក្នុងគុករស់នៅស្អាតស្អំបង្ហាញច្បាស់ថា ការរំលោភបំពានបែបនេះពិតជាកើតមានជាញឹកញាប់ ។

៧៣) ស្នាដៃនិពន្ធរបស់ ហ្វុខល មានចំណងជើងថា "វិន័យនិងទណ្ឌកម្ម" ទំព័រទី២៣៧ ។

៧៤) កិច្ចសម្ភាសន៍របស់អ្នកស្រី សារ៉ាខូម ជាមួយ វ៉ាន់ ណាត ។ ពត៌មានបន្ថែមសូមមើលស្នាដៃរបស់ ចម ម៉ី មានចំណងជើងថា "៥៥ ចេញសាលក្រម" ដែលក្នុងនោះបានដកស្រង់សម្តីរបស់ វ៉ាន់ ណាត ដែលនិយាយថា "យប់ទីមួយ ខ្ញុំមានសង្ឃឹមខ្លះ ប៉ុន្តែ លុះព្រឹកឡើង ក្តីសង្ឃឹមទាំងអស់របស់ខ្ញុំក៏រលាយបាត់អស់" ។

៧៥) សូមមើលឯកសារសាធារណរដ្ឋប្រជាមានិតកម្ពុជាមានចំណងជើងថា "សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង" ។

៧៦) កិច្ចសម្ភាសន៍របស់អ្នកស្រី សារ៉ាខូម ជាមួយ វ៉ាន់ ណាត ។

៧៧) CMR22.8 ស៊ិន ហេង, CMR156.11 ស្លួស ប៊ុន, CMR169.17 ថៃ ផេង និងCMR174.6 គុន ទិត ។ សូមមើលបន្ថែម CMR48.13 ខៀវ សុន ដែលក្នុងនោះក្រោយពីសួរចម្លើយហើយ ចាន់ និយាយប្រាប់ថា មានការឃុំឃាំងបន្តទៅទៀត ប៉ុន្តែថាមិនសម្លាប់ទេ ។ គក ស្រស់ និយាយទៅកាន់លោក ដូក្លាស នីវីន ថា "គុកនៅតាខ្មៅ ជួនកាលអ្នកទោសត្រូវបានដោះលែងឲ្យរួចខ្លួននៅពេលណាគេឆ្លើយការពិត ។ នៅក្នុងខ្សែភាពយន្តដែលមានចំណងជើងថា "អគ្គការស្អីគេនោះ" បង្ហាញពីឯកសារមួយដែលសរសេរពីឈ្មោះ ឌុក ឈាម ដាក់ថា "ដោះលែង" នៅឆ្នាំ១៩៧៦ ។ ខ្ញុំរកឯកសារមួយនេះនៅក្នុងបណ្ណសារមិនឃើញសោះ ។

៧៨) កិច្ចសម្ភាសន៍របស់លោក អាស្ទូលី ជាមួយ វ៉ាន់ ណាត ។ ឯកសារចម្លងមិនមាននៅសល់ទេ ។ គំនិតដែលថា ប៉ុល ពត គួរតែត្រូវបានគូររូបកាន់ "សៀវភៅកិច្ចការបដិវត្ត" គឺជាការផ្ទុយស្រឡះពីព្រោះសម្តីរបស់ ប៉ុល ពត សឹងតែគ្មានន័យបើផ្ទៀងផ្ទាត់ទៅនឹងប្រភពឯកសារដែលសរសេរជាលាយលក្ខណ៍អក្សរនានានិងមិនដែលត្រូវបានប្រមូលចងក្រងជាសៀវភៅឡើយ ។ គោលបំណងនៃការធ្វើរូប

*ចម្ងាក់នេះហាក់ដូចជាចង់បង្ហាញពីភាពដូចគ្នារវាង ប៉ុល ពត និងជនបដិវត្តជើងចាស់ ម៉ៅ សេទុង និង គីម អ៊ីលស៊ុង ។*

## ខគ្គទីបីៈ ការជ្រើសរើសសត្រូវ

*១) ចង់ជ្រាបពីគំនិតរបស់ ម៉ៅ ស្តីអំពីអត្តិភាពបដិវត្តន៍ សូមមើលស្នាដៃនិពន្ធរបស់ ម៉េស ន័រ មានចំណងជើងថា «ប្រទេសចិនជំនាន់ ម៉ៅ និងសម័យក្រោយមកទៀត» ទំព័រទី២០៦-១៦ ។ ពត៌មានបន្ថែមសូមមើលស្នាដៃនិពន្ធរបស់ វើលង័រ មានចំណងជើងថា «គំនិតជ្រុលនិយមនៃបដិវត្តវប្បធម៌» ។ វើលង័រ មានប្រសាសន៍ថា តម្លៃនៃបដិវត្តវប្បធម៌ត្រូវបាន «ស្តែងចេញឲ្យឃើញជាទម្រង់ទ្រឹស្តីនៃការរួមគំនិតទុច្ចរិត» ទំព័រទី៤៣ ។ សូមមើលស្នាដៃនិពន្ធរួមរបស់ ស្តារ និង ដាយ័រ «កិច្ចការរបស់ ម៉ៅ សេទុង ក្រោយរំដោះ» ។ ពាក្យថា «ខ្មាំង» នៅក្នុងទំព័រទី១២០-២២ តាមឯកសារយោងគឺនិយាយសំដៅ «អ្នកសមគំនិត, ក្អាក់ងារ, សមាសភាពវណ្ណៈបរទេស, សមាសភាពមិនល្អ, ចោរព្រៃ, អ្នកគ្មានសីលធម៌, បរិវារ, អ្នកប្រឆាំង, ជនក្បត់លទ្ធិម៉ាក្ស-ឡេនីន» ។ «មិត្ត» ប្រើសម្រាប់តែនិយាយដល់ការកើតមានទំនាស់តែប៉ុណ្ណោះ ។*

*២) ស្នាដៃរបស់លោក ឡូកា មានចំណងជើងថា «សៀវភៅតូចពណ៌ក្រហម» ទំព័រទី១៣៣ ។ វ៉ាន់ណាត ប្រាប់លោក អាឡិចហ្សាន់ឌ័រ ហ៊ីនតុន ថា «ពាក្យថាខ្មាំងមួយម៉ាត់នេះមានឥទ្ធិពលខ្លាំងណាស់... ។ ក្រោយពីឮពាក្យថា «ខ្មាំង» ម្នាក់ៗជ្រួលច្រាល់ក្នុងចិត្ត» ។ ស្នាដៃនិពន្ធរបស់លោក ហ៊ីនតុន មានចំណងជើងថា «ហេតុអ្វីបានជាសម្លាប់មនុស្ស» ទំព័រ១១៣ ។ ពាក្យថា «បោសសម្អាត» ជាកិរិយាស័ព្ទនៃភាសាខ្មែរដែលប្រែជាភាសាអង់គ្លេសមានន័យថា «Clean» មិនមានន័យលាក់កំបាំងទេ ។ ពាក្យនេះគេនិយាយជាទូទៅសំដៅដល់ការបោសសម្អាតផ្ទះសម្បែងជាដើម ។*

*៣) ចំពោះអត្ថបទសុន្ទរកថានេះដែលថ្លែងនៅឆ្នាំ១៩៥៧ សូមមើលស្នាដៃនិពន្ធរបស់ ម៉េកហ្វា គូហារួមជាមួយអ្នកដទៃទៀតមានចំណងជើងថា «សុន្ទរកថាសម្ងាត់» ទំព័រទី១៣១-៩៨ ។ ប៉ុល ពត ប្រហែលជាលើកយកផ្នែកណាដែលនិយាយសមរម្យសម្រាប់ការចេញផ្សាយជាសាធារណៈនៅពេលនិយាយសរសើរម៉ៅ (FBIS ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៧៦) ។ នៅក្នុងកំណត់ហេតុនៃសុន្ទរកថា (ទំព័រទី១៤២-៤៣) ម៉ៅនិយាយដោយឥតលាក់លៀមនៅក្នុងយុទ្ធនាការស៊ូហ្វានក្នុងឆ្នាំ១៩៥០-១៩៥២ថា÷ «យើងសម្លាប់មនុស្សអស់ ៧០០ ០០០នាក់...ប្រសិនបើយើងមិនសម្លាប់ពួកវាទេ ម្ល៉េះប្រជាជនមិនអាចងើបក្បាលរួចឡើយ...ប្រជាជនចង់បានការសម្លាប់នេះដើម្បីរំដោះកម្លាំងផលិតកម្ម» ។ ប្រយោគចុងក្រោយនេះ ប្រហែលជាបម្រើឲ្យមជ្ឈិមបក្សនៅកម្ពុជាក្នុងការយកហេតុផលទៅសម្លាប់វគ្គាល «ខ្មាំងវណ្ណៈ» នៅឆ្នាំ១៩៧៥ ប៉ុន្តែមិនមែនសម្រាប់បង្កើតមន្ទីរស-២១ទេ ។*

*៤) ប៉ុល ពត «ជយោ! បុណ្យខួបកំណើតបក្សកុម្មុយនិស្តកម្ពុជាលើកទី១៧» FBIS ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៧៧ ។ សូមមើលទស្សនាវដ្តីទង់បដិវត្តលេខពិសេសចេញផ្សាយខែធ្នូ ឆ្នាំ១៩៧៥-មករា ១៩៧៦*

ទំព័រទី៤១ ។ ទស្សនាវដ្ដីនេះនិយាយដល់ «អ្នកឆ្វេងឱកាសនិយម, ជនប្រតិវត្តន៍វែជន្យ, និងអ្នកដែល...មានប្រវត្តិរូបមិនច្បាស់» ។ ទស្សនាវដ្ដីទង់បដិវត្តចេញផ្សាយខែមីនា ឆ្នាំ១៩៧៨ បកប្រែនៅក្នុងស្នាដៃនិពន្ធរបស់លោក ជែកសុន ដែលមានចំណងជើងថា «កម្ពុជា១៩៧៥-១៩៧៨» និយាយអំពី «ជនប្រតិវត្តន៍សាហាវឃោរឃៅ ដែលមិនអាចអប់រំបាន» ទំព័រទី២៩៧ ។ ពត៌មានបន្ថែមសូមមើលសៀវភៅ «លិទ្ធិម៉ាក្ស-ឡេនីន» ដែលជាសៀវភៅកំណត់ហេតុមិនមានចុះថ្ងៃខែតម្កល់ទុកនៅបណ្ណសារមន្ទីរស-២១ ។ «វណ្ណៈជិះជាន់ដែលត្រូវបានកម្ទេចខ្ទាត់ខ្ទាយកាលពីឆ្នាំ១៩៧៥ ត្រូវតែកម្ចាត់ឲ្យខ្ទាត់ខ្ទាយម្ដងទៀត» ទំព័រទី៥៩ ។ចង់ជ្រាបពីពត៌មានស្ដីពីការពិភាក្សាលើអំពើឃោរឃៅខាងនយោបាយនិងការបង្កើតខ្មាំង សូមមើលស្នាដៃនិពន្ធរបស់ ម៉ើក ខល មានចំណងជើងថា «អំពើឃោរឃៅខាងនយោបាយនិងអំពើគួរឲ្យព្រឺខ្លាច» ទំព័រទី២៨-២៩ និងស្នាដៃនិពន្ធរបស់ អាប់ ធ័រ មានចំណងជើងថា «ការធ្វើឲ្យអំពើឃោរឃៅមានលក្ខណៈស្របច្បាប់» ទំព័រទី១-២០ ។

៥) សូមមើលស្នាដៃរបស់ ថាក់ ឃ័រ មានចំណងជើងថា «គំនិតនយោបាយរបស់សូវៀត» ទំព័រទី៥៥ ដែលបានដកស្រង់សម្ដីរបស់ ស្ដាលីន ក្នុងឆ្នាំ១៩២៨ ដែលនិយាយថា «យើងមានខ្មាំងផ្ទៃក្នុង ។ យើងមានខ្មាំងខាងក្រៅ ។ សមមិត្តទាំងឡាយ ការណ៍នេះមិនត្រូវភ្លេចមួយវិនាទីណាឡើយ» ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោក ស៊ីវ ដែលបានផ្ដល់ជាឯកសារយោងដល់ខ្ញុំ ។

៦) «ផែនការសេ.អ៊ី.អា» ឯកសារចុះថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៧៦ មិនទាន់ចុះបញ្ជីនៅក្នុងសំណេររបស់ ម៉ម ណៃ ដែលតម្កល់នៅបណ្ណសារមន្ទីរស-២១ ។ ឯកសារនេះនិយាយថា «កម្លាំងទ័ព សឺន ង៉ុកថាន់ ដែលគាំទ្រអាមេរិកនិងវៀតកុងបាននិងចងសម្ព័ន្ធជាមួយគ្នាអស់ពេលជាច្រើនឆ្នាំមកហើយ» ។

៧) ឯកសារលេខ១០៩០ តម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា «អត្ថន័យការសួរចម្លើយយុទ្ធជនមកពីអាមេរិក» ។

៨) ស្នាដៃនិពន្ធរបស់លោក សាំម័រ មានចំណងជើងថា «បក្សកុម្មុយនិស្តកម្ពុជាៈ ទ័ពស្រួចសម្ងាត់» ទំព័រទី៣០ ។ ប៉ុល ពត បានចូលរួមមតិដ៏អស្ចារ្យស្ដីអំពីលោកទស្សនៈ ។ និយាយទៅកាន់អ្នកកាសែតលោកខាងលិចនៅខែធ្នូ ឆ្នាំ១៩៧៨ ប៉ុល ពត ប្រាប់ថា មានតែអង្គការ«ណាតូ»ទេ ទើបអាចទប់ស្កាត់ផែនការឈ្លានពានទឹកដីកម្ពុជាពីសំណាក់កងទ័ពដែលមានការពាក់ព័ន្ធនៅក្នុងកតិកាសញ្ញាវ៉ារស្សាវ ។ ស្នាដៃនិពន្ធរបស់ បេកឃ័រ មានចំណងជើងថា «ពេលសង្គ្រាមផុតរលត់ទៅ» ទំព័រទី៤៣៣-៣៦ ។ ស្រដៀងគ្នានេះដែរ យោងតាមវគ្គមួយ «ផែនការចុងក្រោយ» នៅក្នុងស្នាដៃនិពន្ធរបស់ ជែកសុន ដែលមានចំណងជើងថា «កម្ពុជា១៩៧៥-១៩៧៨» បានឲ្យដឹងថា «អាមេរិកប្រើវៀតណាម [ក្រោយឆ្នាំ១៩៧៥] ដោយមានកិច្ចសហការគ្នាជាមួយសូវៀត ពីព្រោះអាមេរិកគ្មានកងទ័ពច្បាំងនៅកម្ពុជា» ទំព័រទី៣១២ ។

៩) ស្នាដៃរបស់លោក ឡូកា មានចំណងជើងថា «សៀវភៅតូចពណ៌ក្រហម» ទំព័រទី១៦៦ ។ ពត៌មានបន្ថែមទៀតសូមមើលស្នាដៃនិពន្ធរបស់ ឌិតម័រ មានចំណងជើង «ការកែទម្រង់គំនិតនិងបដិវត្តវប្បធម៌» ដែលមានដកស្រង់សម្ដីរបស់ចិនថា «ខ្មាំងគ្មានអាវុធ លាក់ខ្លួនជិត វៃឆ្លាត សាហាវនិងទទួលបានជោគជ័យ

ជាផ្ទាំងមានអាវុធ» ទំព័រទី៧៥ ។

១០) កិច្ចសម្ភាសន៍ជាមួយ សេង កាន «ប្រជាជនថ្មី» ដែលត្រូវជាប់គុកអស់ពីរឆ្នាំនៅខេត្តស្វាយរៀង ។ សូមមើលស្នាដៃនិពន្ធរបស់លោក ឡូកា មានចំណងជើងថា «ប្រព័ន្ធព្រហ្មទណ្ឌខ្មែរក្រហម» និងស្នាដៃនិពន្ធរបស់ ក្រេក អេចឆេសិន មានចំណងជើងថា «អំពើគួរឲ្យព្រឺខ្លាចនៅក្នុងសម័យខ្មែរក្រហម» ។

១១) ស្នាដៃនិពន្ធរបស់លោក ប៉ែន ឃៀរនិន មានចំណងជើងថា «របប ប៉ុល ពត» ទំព័រទី៥៥-៥៩ មានការពិភាក្សាយ៉ាងលម្អិតអំពីការប្រជុំនេះផ្អែកលើកិច្ចសម្ភាសន៍ជាមួយអ្នកដែលបានចូលរួមប្រជុំ ។

១២) ទស្សនាវដ្ដីទង់បដិវត្តចេញផ្សាយខែធ្នូ ឆ្នាំ១៩៧៥-ខែមករា ឆ្នាំ១៩៧៦ ទំព័រទី៤១ (ប្រែសម្រួលដោយលោក ស៊ីវ ហេងឌ័រ) ។ «សម្រួចស្មារតីវណ្ណៈអធន» ទស្សនាវដ្ដីទង់បដិវត្តចេញផ្សាយខែកញ្ញា-តុលា ឆ្នាំ១៩៧៦ ប្រែសម្រួលនៅក្នុងសៀវភៅដែលជាស្នាដៃនិពន្ធរបស់ ដែកសុន «កម្ពុជា ១៩៧៥-១៩៧៨»÷ «វណ្ណៈសក្តិភូមិនាយទុនត្រូវបានកម្ចាត់អស់ក៏ពិតមែន ប៉ុន្តែប្រភេទទំនាស់...នៅតែមាននៅក្នុងនយោបាយ សតិអារម្មណ៍ គោលជំហរ និងកំហឹងវណ្ណៈ»(២៧០) ។

១៣) «ប្រុងប្រយ័ត្នក្នុងការបោសសម្អាតខ្មាំងបង្កប់» ទស្សនាវដ្ដីទង់បដិវត្ត ចេញផ្សាយខែកក្កដា ឆ្នាំ១៩៧៨ ទំព័រទី៩-១០ ។ ឃ្លានេះចង់និយាយឲ្យបក្សកុម្មុយនិស្តកម្ពុជាដែលមានលក្ខណៈចំហ ក្លីស្វាង ប្រុងប្រយ័ត្ន និង ត្រចះត្រចង់ ប្រឆាំងនឹងកម្លាំងបង្កប់ស៊ីរូងផ្ទៃក្នុងដែលលាក់មុខនិងខ្មៅងងឹត ។ អ្នកចូលរួមស្តាប់មួយចំនួនប្រហែលជានឹកឃើញដល់ការតស៊ូរបស់ព្រះពុទ្ធប្រឆាំងនឹងមារសត្រូវដែលមកផ្ចាញ់ផ្ចាលព្រះអង្គ ។

១៤) ស្នាដៃនិពន្ធរបស់លោក សាំម័រ មានចំណងជើងថា «បក្សកុម្មុយនិស្តកម្ពុជាៈ ទ័ពស្រួចសម្ងាត់» ទំព័រទី២៧ ។

១៥) «សម្រួចស្មារតី» ទំព័រ២៧៣ ។ សូមមើល «មេរៀនសង្ខេបស្តីអំពីប្រវត្តិចលនាបដិវត្តន៍កម្ពុជា» នៅក្នុងស្នាដៃនិពន្ធរបស់លោក ឆេនដល័រ, ឃៀរនិន និង ប៊ូ មានចំណងជើងថា «ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត»÷ «ទំនាស់រវាងវណ្ណៈផ្សេងៗនឹងកើតមាន....ជាគោលជំហរសីលធម៌និងផលប្រយោជន៍សួនតួ» (២២២) និងដុំមីក្រូហ្វីលលេខCMR55.5 កែវ សានៈ «តើយើងឃើញចំណុចខ្សោយបដិវត្តន៍អ្វីខ្លះ? ។ ខ្សោយនៅត្រង់ថា ខាងសតិអារម្មណ៍បុគ្គលនិយមមិនទាន់ធ្វើបាន ។ នៅមានបដិបក្ខនៅឡើយ ។ នៅមានសតិអារម្មណ៍ អត្តភាពនិយម អត្តការនិយម ។ មានសតិអារម្មណ៍ប្រកាន់តែផ្នែក, ភូមិភាគរៀងៗខ្លួន ជាពិសេសគិតតែពីខ្លួនឯងតែម្តង» ។ គំនិតនេះមានលើកឡើងនៅក្នុងអត្ថបទនិពន្ធរបស់ ចាង ឈុនឆាវ មានចំណងជើងថា «អំពើផ្តាច់ការទូទៅចំពោះពួកគហបតី» ដែលជាអត្ថបទសំខាន់មួយបោះផ្សាយនៅប្រទេសចិនក្នុងខែមេសា ឆ្នាំ១៩៧៥ ។ សូមមើលស្នាដៃនិពន្ធរបស់ លីង សែវ មានចំណងជើងថា «ទិតៀនគហបតីជានិច្ច» ។ ជាការគួរឲ្យហួសចិត្តដែល ស្តាលីន, ម៉ៅ និង ប៉ុល ពត ដែលសុទ្ធតែជាអ្នកមិនជឿថាមានអាទិទេពនោះមើលទៅហាក់ដូចជាជឿស្ទុងទៅលើលទ្ធិមួយដែលមានលក្ខណៈដូចគ្នាទៅនឹងលទ្ធិសាសនារ៉ូម៉ាំងកាតូលិកទៅវិញ ។ តាមលោកទស្សនៈ ប្រសិនបើការតស៊ូជាមួយខ្មាំងប្រព្រឹត្តទៅ

មិនចេះចប់មិនចេះហើយ នោះតម្រូវការចង់ក្លាយជាមេដឹកនាំបក្សក៏មានមិនចេះចប់មិនចេះហើយដែរ ។ នៅពេលប្រជាជននៅតែត្រូវហ៊ុមជុំជិតដោយខ្មាំងសត្រូវ តើធ្វើឲ្យរដ្ឋបាត់បង់កម្លាំងប៉ុន្មានទៅ ។

១៦) ស្នាដៃរបស់លោក ឡូកា មានចំណងជើងថា «កូនសៀវភៅពណ៌ក្រហម» ទំព័រទី១៧៥ ។ ពាក្យស្លោកនេះប្រហែលជាមានប្រភពចេញពីវៀតណាម ។ សូមមើលស្នាដៃនិពន្ធរបស់លោក វ៉ូ យ៉ាន់ទ្រី មានចំណងជើងថា «នយោបាយសេដ្ឋកិច្ចវៀតណាម» ទំព័រទី២-៧ ដែលសរសេរយោងពីស្នាដៃនិពន្ធ វ៉ូ ង្វៀន ង្វៀប តាំងពីឆ្នាំ១៩៥៦ ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោក ស៊ីវ ហេដឌ័រ ដែលបានផ្តល់ឯកសារយោងនេះដល់ខ្ញុំ ។ អ្នកណាមានកំហុសដោយរបៀបណាឬដោយអ្នកណានោះគឺសុភាសិតខ្មែរក្រហមនេះជាអ្នកសន្មត ។ ចំនួនមនុស្ស «ស្លូតត្រង់» ដែលត្រូវគេធ្វើឲ្យទៅជាមនុស្ស «មានកំហុស» ច្បាស់ជាមានមិនខានឡើយ ។ នៅក្នុងកម្រងកំណាព្យ តែងសេចក្តី និងរឿងផ្សេងៗរបស់លោក ឡូកា ពាក្យស្លោកនេះលេចឡើងស្របគ្នាជាមួយពាក្យស្លោកមួយដែលជាញឹកញយគេសំដៅដល់ «ប្រជាជនថ្មី» និងត្រូវបានអ្នកនៅរស់រានមានជីវិតចាកផុតពីរបបកម្ពុជាប្រជាធិបតេយ្យហៅតាមតៗគ្នាពោលគឺ៖ «ទុកក៏មិនចំណេញ ដកចេញក៏មិនខាត» ។

១៧) ចង់ជ្រាបអំពីយុទ្ធសាស្ត្រ សូមមើល «ផែនការចុងក្រោយ» នៅក្នុងស្នាដៃនិពន្ធរបស់ ដែកសុន មានចំណងជើងថា «កម្ពុជា១៩៧៥-១៩៧៨»៖ «ប៉ុល ពត ចង់ឲ្យម្នាក់ៗស្អាតបរិសុទ្ធ ។ អ្នកណាមិនស្អាតបរិសុទ្ធត្រូវសម្លាប់ចោល» (៣០៥) ។ ចង់ជ្រាបពត៌មានបន្ថែមសូមមើលកិច្ចសម្ភាសន៍របស់ ផាន ថនចាន់ជាមួយ លីអូណោល វែរ៉ុង ។ ចង់ជ្រាបពត៌មានអំពីខ្មាំងសត្រូវដែលជាអ្នកក្រៅសុទ្ធសាធ សូមមើលស្នាដៃនិពន្ធរបស់ ហ៊ីដឹន មានចំណងជើងថា «រដ្ឋនិងអំពើឃោរឃៅ» ទំព័រទី១១៧ ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះ ហ្សាវ៉ា គីរី គីនូនិន ដែលបានផ្តល់ឯកសារយោងនេះដល់ខ្ញុំ ។ បន្ថែមពីលើនេះទៀត សូមមើលស្នាដៃនិពន្ធរបស់ កាប់ ហ៊ីរី «រឿងព្រេងប្រជាប្រិយ» ដែលនិយាយថា ទមិឡនៅប្រទេសស្រីលង្កា ដូចជាទមិឡនៅប្រទេសកម្ពុជាដែរ គឺបង្ហាញឲ្យឃើញភាពរីងរូសនិងសារជាតិអាក្រក់ចំពោះព្រះពុទ្ធសាសនានិកាយថេរវាទដែលកំពុងតែពេញនិយមពីសំណាក់ពុទ្ធបរិស័ទ ។

១៨) ចំពោះសុន្ទរកថាដែលប្រែសម្រួលជាភាសាអង់គ្លេសរួចហើយ សូមមើលនៅក្នុងស្នាដៃនិពន្ធរបស់លោក ឆេនដល័រ និង ប៊ូ មានចំណងជើងថា «ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត» ទំព័រទី១៨៣ ។ បន្ថែមពីលើនេះទៀតសូមមើលស្នាដៃនិពន្ធរបស់ ស៊ូអារ៉េ អូរ៉ូស្កូ មានចំណងជើងថា «វេយ្យាករណ៍ភេរវកម្ម» ទំព័រទី២៣៩ដែលយោងតាមលោកឧត្តមនាវីឯកម្នាក់នៅប្រទេសអាហ្សង់ទីនកាលពីទសវត្សរ៍ឆ្នាំ៧០ ដែលហៅក្រុមមរណៈថា ជា«អង្គបដិបក្ខ» ដែលប្រយុទ្ធតទល់ជាមួយ «មេរោគ» នៃការខ្វែងគំនិតគ្នាដ៏ធំ ។ ទស្សនាវដ្តីទង់បដិវត្ត ច្បាប់ចេញផ្សាយខែកក្កដា ឆ្នាំ១៩៧៦ ឃ្លាមួយដាក់ថា «ប្តេជ្ញាវាយសម្រុករៀនសូត្រលក្ខន្តិកៈបក្ស» ។ ឃ្លានេះអះអាងថា «សេ.អ៊ី.អា វាយបដិវត្តន៍ដោយចាក់ថ្នាំតាមសរសៃឈាម» ទំព័រទី៥១ ។

១៩) ដុំមីក្រូហ្វីលលេខCMR12.25 (ឯកសារប្រែសម្រួលដោយលោក ស៊ីវ ហេដឌ័រ) ។ ពត៌មានបន្ថែមសូមមើលស្នាដៃនិពន្ធរបស់ ប៉ុងសូ មានចំណងជើងថា «កម្ពុជាឆ្នាំសូន្យ» ទំព័រទី៤០ ។ នៅក្នុងឆ្នាំ១៩៨៨

ប៉ុល ពត បានប្រាប់ទៅកាន់កម្មាភិបាលថា អតីតអ្នកធ្វើការឲ្យរបប លន់ ណុល ត្រូវបាន «បោសសម្អាត... ពីព្រោះអ្នកទាំងនេះជាខ្សែចក្រពត្តិ» (រ៉ូហ័រ ន័រមែន-ការទាក់ទងផ្ទាល់ខ្លួន) ។ សូមមើលកិច្ចសម្ភាសន៍របស់លោក ស៊ីវ ហេងឌ័រ÷ «[អតីតមន្ត្រីរបប លន់ ណុល] ត្រូវបានស្នើឲ្យទៅជួបអង្គការ...ហើយថា មិនយកទោសពៃរ៍អ្វីទេ ប៉ុន្តែតាមការពិតត្រូវយកទៅសម្លាប់ចោលទាំងអស់»ទំព័រទី៤៦ ។ ទោះបីជាមានភ័ស្តុតាងគ្រប់គ្រាន់ជាច្រើនទាក់ទងនឹងការសម្លាប់នេះមិនត្រូវបានមានចេញផ្សាយក៏ដោយ មើលស្នាដៃរបស់ ឃឺន មានចំណងជើងថា «គំរូនិងទំហំនៃអំពើឃោរឃៅ» ប៉ុន្តែមានឯកសារមួយចំនួនតូចដែលកត់ត្រាពីការសម្លាប់មាននៅសេសសល់រហូតដល់សព្វថ្ងៃ ។ ចង់ជ្រាបពត៌មានស្តីអំពីយុទ្ធនាការឃោសនាជំរុញឲ្យមានការសម្លាប់មនុស្ស សូមមើលស្នាដៃនិពន្ធរបស់ ប៉ុងសូ មានចំណងជើងថា «កម្ពុជាឆ្នាំសូន្យ» ទំព័រទី៥០-៥១ ។ ចំពោះពត៌មានស្តីអំពីការបន្ថយការកាប់សម្លាប់មនុស្សនៅពេលខ្លួនលែងទប់ទល់បានហើយ សូមមើលស្នាដៃនិពន្ធរបស់លោក ឃៀរនិន មានចំណងជើងថា «របប ប៉ុល ពត» ទំព័រទី៩២ ។ មុត សុភា រំឭកឡើងវិញនូវបញ្ហាដែលធ្លាក់មកដល់ដៃកម្មាភិបាលខ្មែរក្រហមនៅខែមិថុនា ឆ្នាំ១៩៧៥ នៅខេត្តបាត់ដំបង (កិច្ចសម្ភាសន៍របស់អ្នកនិពន្ធខែកុម្ភៈ ឆ្នាំ១៩៩៨) ។ សូមមើលស្នាដៃនិពន្ធរបស់លោក វីកឃ័រី មានចំណងជើងថា «កម្ពុជាប្រជាធិបតេយ្យ» ទំព័រទី១០៩-១០ ។ នៅក្នុង «ប្រវត្តិចលនាគស្ទ៊ូ» (១៩៩៧) នួន ជា ប្រកែកមិនទទួលយកការទទួលខុសត្រូវថ្នាក់មជ្ឈិមថា ជាអ្នកបញ្ជាទេ ។ នួន ជា សរសេរថា «ចំពោះការកាប់សម្លាប់ យើងអត់ដឹងទាំងអស់ទេ ។ ពួកខាងក្រោមទេដែលជាអ្នកធ្វើផ្តេសផ្តាស» ។ មិនមានឯកសាររបស់ពិរុទ្ធជនណាម្នាក់ក្នុងចំណោមពិរុទ្ធជនទាំងនេះដែលកំពុងតែត្រូវបានផ្តន្ទាទោសឡើយ ។

២០) ស្នាដៃនិពន្ធរួមរបស់ ឆំស្គី និង ហ័រមែន មានចំណងជើងថា «ក្រោយមហាវិនាសកម្ម» ទំព័រទី៣៨-៣៩ និង១៩៤០ ។ សូមមើលស្នាដៃនិពន្ធរបស់ អារ៉ុន មានចំណងជើងថា «L'histoire de l'épuration (ទីក្រុងប៉ារីស ១៩៦៧-១៩៧៥)» និងស្នាដៃនិពន្ធរបស់ ម៉ាហ្គូរី ឌូរ៉ាស មានចំណងជើងថា «អាល់ប៊ែរប្របាំរដ្ឋធានី» ។ «ភេរវកម្មស» នៅក្នុងប្រទេសបារាំងក្នុងឆ្នាំ១៧៩៥-១៧៩៦ និងការសម្លាប់រង្គាលជនកុម្មុយនិស្តដែលត្រូវសង្ស័យនៅប្រទេសឥណ្ឌូនេស៊ីឆ្នាំ១៩៦៥-១៩៦៦ ។ សូមមើលស្នាដៃនិពន្ធរបស់ គ្រីប មានចណងជើងថា«ការសម្លាប់ជនជាតិឥណ្ឌូនេស៊ី» ទំព័រទី១-៤៣ ។

២១) ចង់ជ្រាបពីខ្មែរហាណូយ សូមមើលស្នាដៃនិពន្ធរបស់ ឃៀរនិន មានចំណងជើងថា «យុទ្ធសាស្ត្រឡើងមកកាន់អំណាចរបស់ ប៉ុល ពត» ទំព័រទី៣១៩-២១ និង ៣៥៨ និងកិច្ចសម្ភាសន៍របស់ ហេងឌ័រ ។ ក្នុងកិច្ចសម្ភាសន៍អតីតកម្មាភិបាលខ្មែរក្រហមរំឭកឡើងវិញថា នៅឆ្នាំ១៩៧៤ «គេនិយាយថា អ្នកដែលមកពីខត្តរឲ្យ...វៀតណាមត្រឡប់មកគ្រប់គ្រងប្រទេសកម្ពុជាវិញ» ទំព័រទី៤៤ ។ «ផែនការចុងក្រោយ» ហៅអ្នកទាំងនោះថា ជាវៀតណាមសុទ្ធមួយរយភាគរយដែលគ្មានទៅសល់អ្វីជាខ្មែរសោះឡើយ (ស្នាដៃនិពន្ធរបស់ ដែកសុន មានចំណងជើងថា «កម្ពុជាឆ្នាំ១៩៧៥-១៩៧៨» ទំព័រទី៣០) ។ អ្នកទោសផ្សេងទៀតនៅមន្ទីរស-២១ កាលពីពេលនោះរួមមានអ្នកធ្វើពុតឈឺ ចោរ អ្នករត់ចោលជួរ និងជនបរទេសដែលលួចចូលទឹកដីកម្ពុជា ។ មនុស្សក្នុងជំពូកនេះត្រូវបាននាំចូលមន្ទីរស-២១ ជាបន្តបន្ទាប់រហូតដល់ថ្ងៃដែលរបប

កម្ពុជាប្រជាធិបតេយ្យត្រូវដួលរលំ ។

២២) ស្នាដៃនិពន្ធរបស់ ប៊េកឃ័រ មានចំណងជើងថា «ពេលសង្គ្រាមផុតរលត់ទៅ» ទំព័រទី២៧៤ និង ស្នាដៃនិពន្ធរបស់ អារ៉េន មានចំណងជើងថា «ផ្ដាច់ការនិយម» ទំព័រទី១២០ ។

២៣) ចំពោះព្រឹត្តិការណ៍ផ្ទុះគ្រាប់នៅខេត្តសៀមរាប សូមមើលស្នាដៃនិពន្ធរបស់ ឃៀរនិន មានចំណងជើងថា «របប ប៉ុល ពត» ទំព័រទី៣១៦-១៩ និងស្នាដៃនិពន្ធរបស់លោក វីកឃ័រី មានចំណងជើងថា «កម្ពុជាឆ្នាំ១៩៧៥-១៩៨២» ទំព័រទី១២៨ ។ ជាការគួរឲ្យកត់សម្គាល់ឯកសារនៅមន្ទីរស-២១ មានចំណងជើង «ផែនការសេ.អ៊ី.អា» (ដែលរៀបចំមួយសប្ដាហ៍ក្រោយមក) ក៏មិនមាននិយាយដល់រឿងនេះឡើយ ហើយទូរលេខផ្ញើមកពីលេខាភូមិភាគឧត្ដរ កែ ពក មកឲ្យ សុន សេន ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៧៦ (ឯកសារមិនទាន់ចុះបញ្ជីតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា) មិនបានរាយការណ៍អំពីភាពរំជើបរំជួលនៅក្នុងភូមិភាគនេះដែរ ។ ដុំមីក្រូហ្វីលលេខCMR12.25 ជៅ ចាន់ (ហៅ ស្រេង) ដែលនិយាយតាមមាត់បក្សបានអះអាងកាលពីខែមីនា ឆ្នាំ១៩៧៧ថា ការផ្ទុះនេះបានបង្ហាញពី «កំហឹងរបស់ចក្រពត្តិអាមេរិកដែលមិនដែលឆ្លាប់ចាញ់ប្រទេសណាមួយនៅក្នុងពិភពលោក» ។ លោក ស៊ីវ ហេដឌ័រ ការ (ទាក់ទងផ្ទាល់ខ្លួន) បានឲ្យយោបល់ថា យន្តហោះប្រយុទ្ធរបស់ថៃអាចពាក់ព័ន្ធច្រើនក្នុងរឿងនេះ ។

២៤) ការសរសេរប្រវត្តិសាស្ត្របែបនេះគឺជាគោលដៅរបស់ខ្ញុំតាំងពីដំបូងឡើយ នៅពេលខ្ញុំចាប់ផ្ដើមមើលឯកសារនៅមន្ទីរស-២១ កាលពីឆ្នាំ១៩៩៤ ។ ដោយសារឯកសារនៅបណ្ណសារមន្ទីរស-២១ មើលពិបាកយល់ មិនយូរប៉ុន្មានកិច្ចការនេះក៏ត្រូវបញ្ចប់ ។ សូមមើលវគ្គទី១ សំយោគឯកសារប្រវត្តិសាស្ត្រសម័យខ្មែរក្រហម ។ មានតែស្នាដៃនិពន្ធរបស់ ប៊េកឃ័រ «ពេលសង្គ្រាមផុតរលត់ទៅ» ទេដែលបានប្រើឯកសារនៅមន្ទីរស-២១ បានច្រើន ។

២៥) ស្ដីអំពីការប្រើឯកសារចម្លើយសារភាពជាភ័ស្ដុតាង សូមមើលស្នាដៃនិពន្ធរបស់លោក ស៊ីវ ហេដឌ័រ មានចំណងជើងថា «ការប្រឆាំងជំទាស់របស់ខ្មែរក្រហមជាមួយ ប៉ុល ពត «ជាគោលការណ៍លោកអ្នកត្រូវសន្មតថា ពាក្យនីមួយៗអាចជាការកុហកដែលធ្វើឡើងដោយអ្នកសរសេរដែលស្ថិតនៅក្រោមការបំភិតបំភ័យ...ឬការមិនពិតដែលប្រឌិតឡើង ដោយអ្នកសរសេរក្នុងគោលបំណងរកតែរួចខ្លួនកុំឲ្យគេសម្លាប់ចោលដោយព្យាយាមបដិសេធអ្វីដែលជាការពិត...ប៉ុន្តែគ្រាន់តែអានទំព័រដំបូង (មិនទាន់អានរាប់ពាន់សន្លឹកផងនោះ) អ្នកអានពិតជាយល់ច្បាស់ដោយគ្មានមន្ទិលសង្ស័យថា រឿងរ៉ាវទាំងនេះជាការពិត»» ទំព័រទី ១១ ។ ហេដឌ័រ (ឯកសារទាក់ទងផ្ទាល់ខ្លួន) មានប្រសាសន៍ថា ចម្លើយសារភាពដែល «មានលក្ខណៈពិតជាងគេ» គឺចម្លើយសារភាពទាក់ទងនឹងព្រឹត្តិការណ៍មុនឆ្នាំ១៩៧០ ។

២៦) សូមមើលការវាយតម្លៃរបស់ខ្ញុំដែលប្រកបដោយគុណវិបត្តិនៅក្នុងស្នាដៃនិពន្ធរបស់ ឆេនដល័រ, ឃៀរនិន និង ប៊ូ «ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត» xviii ។

២៧) ឯកសាររបបកម្ពុជាប្រជាធិបតេយ្យដែលប្រែសម្រួលជាភាសាខ្មែររួមមាននៅក្នុងស្នាដៃនិពន្ធរបស់ ប៊េកឃ័រ «ពេលសង្គ្រាមផុតរលត់ទៅ-(សេចក្ដីបន្ថែមនៅទំព័រចុងក្រោយ)», ស្នាដៃនិពន្ធរបស់ ខាទី

មានចំណងជើងថា «អំណាចរបស់បក្សកុម្មុយនិស្តក្នុងប្រទេសកម្ពុជា» ទំព័រទី២៥១-៣១៤ និងស្នាដៃនិពន្ធរបស់ ឆេនដល័រ, ឃៀរនិន និង ប៊ូ មានចំណងជើងថា «ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត» ។ ហេដឌ័របានប្រែសម្រួលអត្ថបទសំខាន់ៗមួយចំនួនពីទស្សនាវដ្ដីទង់បដិវត្តនិងយុវជនយុវនារីបដិវត្ត ព្រមទាំងចម្លើយសារភាពរាប់ពាន់សន្លឹកពីមន្ទីរស-២១ ។ ឯកសារដែលប្រែសម្រួលជាភាសាអង់គ្លេសដ៏សំខាន់ទាំងនេះលើកលែងតែឯកសារចម្លើយសារភាពនៅក្នុងសេចក្ដីបន្ថែមក្នុងសៀវភៅរបស់ ហ៊េកយ័រ មិនទាន់បានបោះផ្សាយទាំងស្រុងនៅឡើយទេ ។ ដោយមានការអនុញ្ញាតពីលោក ហេដឌ័រ ខ្ញុំបានប្រើឯកសារប្រែសម្រួលមួយចំនួននៅក្នុងសៀវភៅនេះ ។

២៨) នៅក្នុងឆ្នាំ១៩៩៥-១៩៩៧ ឯកសារបន្ថែមដែលទាក់ទងនឹងរបបកម្ពុជាត្រូវបានប្រគល់ជូនកម្មវិធីសិក្សាស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍នៅកម្ពុជានិងមជ្ឈមណ្ឌលឯកសារកម្ពុជាដោយក្រសួងមហាផ្ទៃ និងប្រភពផ្សេងៗទៀត ។ ចង់ជ្រាបពត៌មានអំពីបណ្ណសារកម្ពុជាប្រជាធិបតេយ្យនៅប្រទេសវៀតណាម សូមមើលស្នាដៃនិពន្ធរបស់ អ៊ីងដេល ប៊ីត និង ហ្គូស ឆា មានចំណងជើងថា «ផ្ដាច់ការទាក់ទង» xv-xvii ។ សហករណ៍បានទុកឯកសារជាច្រើននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តែឯកសារមួយភាគធំបានបាត់បង់អស់ហើយ (ការទាក់ទងផ្ទាល់របស់លោក ហេដឌ័រ) ។ ឯកសារក្នុងសម័យកម្ពុជាប្រជាធិប-តេយ្យត្រូវបានប្រមែប្រមូលដោយគណៈកម្មាធិការស្រាវជ្រាវប្រវត្តិសាស្ត្រនៃបក្សប្រជាជនបដិវត្តកម្ពុជា ។ ឯកសារទាំងនេះគេដឹងថា មិនទាន់បាត់បង់ទេ ប៉ុន្តែអ្នកក្រៅមិនមានឱកាសមើលឯកសារទាំងនេះទេ ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះ រីឆាត អារិន ដែលបានផ្ដល់ពត៌មាននេះដល់ខ្ញុំ ។

២៩) លោក ហេដឌ័រ សន្ទនាជាមួយអ្នកនិពន្ធក្នុងឆ្នាំ១៩៩៥-៩៦ ។

៣០) សូមមើលឯកសាររបស់គណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនិស្តសូវៀត «ប្រវត្តិបក្សកុម្មុយ-និស្ត» ។ ឆ្លងតាមកិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ពៀរ ប្រូឆុក សមាជិកបក្សកុម្មុយនិស្តបារាំងនៅដើមទសវត្សរ៍ទី៥០ ដែលអាចថាជាអ្នកបញ្ចូល ប៉ុល ពត, សុន សេន និង អៀង សារី ទៅក្នុងបក្សនោះបានសិក្សាឯកសារនេះយ៉ាងយកចិត្តទុកដាក់ ។ ចង់ជ្រាបពីប្រជាប្រិយភាពរបស់ឯកសារនេះនៅឯ យ៉ាន់អាននៅអំឡុងទសវត្សរ៍ឆ្នាំ៤០ សូមមើលស្នាដៃរបស់ អាប់ធ័រ និង សៃ មានចំណងជើងថា «ការនិយាយស្តីបដិវត្ត» ទំព័រទី២៧៥ ។ ចង់ជ្រាបពីគំនិតរបស់បក្សកុម្មុយនិស្តកម្ពុជាចំពោះបញ្ហាប្រវត្តិសាស្ត្រ សូមមើលស្នាដៃនិពន្ធរបស់ ឆេនដល័រ មានចំណងជើងថា «ចងកំហឹង» និងប្រវត្តិរបស់បក្សដែលប្រែសម្រួលជាភាសាអង់គ្លេសនៅក្នុងស្នាដៃនិពន្ធរបស់ ជែកសុន «កម្ពុជាឆ្នាំ១៩៧៥-១៩៧៨» ទំព័រទី២៥១-៦៨ និងនៅក្នុងស្នាដៃនិពន្ធរបស់លោក ឆេនដល័រ និង ប៊ូ មានចំណងជើងថា «ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត» ទំព័រទី២១៣-២៦ ។

៣១) អ៊ីង ដេល ផ្ញើការកត់សម្គាល់ទៅកាន់ ម៉ាក្ស នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៨៧០ ។ សូមមើលស្នាដៃនិពន្ធរបស់ ជាន់ កូវ៉ាឌី ប៉ាទ្រីស្យ៉ា វើស ហ្មេជិន និង មែនញ៉ូល អាតូនីអូ «ការភ័យខ្លាចៈ គំនិតវប្បធម៌និងនយោបាយដ៏ស្មុគស្មាញដែលប្រឌិតឡើង» ទំព័រទី១-១០ ។

៣២) ស្នាដៃនិពន្ធរបស់ ស្តេន មានចំណងជើងថា «ការពិតជាលក្ខណៈនិទានកថានិងការពិតជាលក្ខណៈប្រវត្តិសាស្ត្រ» និងស្នាដៃនិពន្ធរបស់ ម៉ាល ខូម មានចំណងជើងថា «Purloined Clinic» ទំព័រទី៣១-៤៧ ដែលជាការពិនិត្យយ៉ាងហ្មត់ចត់ឡើងវិញទៅលើសៀវភៅរបស់ ស្តេន ។ សូមមើលស្នាដៃនិពន្ធរបស់ អ៊ីកណាធីហ្វ មានចំណងជើងថា «កិត្តិយសអ្នកចម្បាំង» ទំព័រទី៩៨-៩៩ ដែលនិយាយពី «និទានកថាជាការពន្យល់» ជាមួយនឹង «និទានកថាអំពីសីលធម៌» ដែលជួយបង្កើតគំនិតនិងចរិយាធម៌របស់យើង ។ នៅក្នុងសៀវភៅដែលទើបតែបោះពុម្ពថ្មីៗនេះលោក ដេវីដ អាប់ធ័រ ធ្វើការប្រៀបធៀបអ្វីដែលលោកឲ្យយោបល់ថា ជា«ប្រវត្តិសាស្ត្រសរសេរដោយប្រវត្តិវិទូ» ជាមួយនឹង «ប្រវត្តិសាស្ត្រដែលមានលក្ខណៈច្នៃប្រឌិត» ដែលជារឿងរ៉ាវនិងរឿងព្រេងប្រជាជននិយាយតៗគ្នាដើម្បីធ្វើឲ្យហេតុការណ៍ជីវិតរបស់ខ្លួនមានលក្ខណៈ«រលូនតាមលំដាប់លំដោយ» និងត្រូវតាមកាលៈទេសៈ (ការធ្វើឲ្យអំពើឃោរឃៅមានលក្ខណៈស្របច្បាប់) ទំព័រទី២០ ។

៣៣)«សេចក្តីសម្រេចចិត្តរបស់គណៈកម្មាធិការមជ្ឈិមស្តីអំពីបញ្ហាជាច្រើន» នៅក្នុងស្នាដៃនិពន្ធរបស់លោក ឆេនដល័រ, ឃៀរនិន និង ប៊ូ មានចំណងជើងថា «ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត» ទំព័រទី១-៩ ។

៣៤) សូមមើលឯកសារមិនទាន់ចុះលេខតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៦ ។ មានកំណត់ហេតុរបស់ ឌុច ភ្ជាប់ជាមួយចម្លើយសារភាពខ្លីមួយដែលមិនទាន់ថតចម្លងចូលម៉ាស៊ីនមីក្រូហ្វីលរបស់ យឹម សម្បត្តិ ។ យឹម សម្បត្តិ គឺជាកងទ័ពកងពលលេខ១៧០ ដែលបានសារភាពថា ខ្លួនជាអ្នកបោលគ្រាប់បែក ។ មេបញ្ជាការកងអនុសេនាធំរបស់ សម្បត្តិ ឈ្មោះ សុខ ចាន់ (CMR145.13) បានសារភាពថា ខ្លួនជាអ្នកបញ្ជាឲ្យ «វាយប្រហារ» ។ ចំណារបញ្ជាក់របស់ ឌុច នៅលើចម្លើយសារភាពរបស់ សម្បត្តិ និយាយថា មានការស្វែងរកសំឡេងទាំងសងខាង ។ ម្នាងថតសំណួរ ហើយម្ខាងទៀតថតចម្លើយរបស់ សម្បត្តិ ហើយធ្វើការកត់សម្គាល់ថា សម្បត្តិ «សន្ទប់» ជាច្រើនលើកនៅពេលសួរចម្លើយ ។

៣៥) ចង់ជ្រាបពីចំនួនអ្នកទោសកងពលលេខ១៧០ សូមមើលដុំមីក្រូហ្វីលលេខCMR103.2 «កងពលលេខ១៧០» ។ ព្រឹត្តិការណ៍ដែលកើតឡើងនៅថ្ងៃទី២ ខែមេសា នៅតែមិនទាន់មានអ្នកណាដឹងច្បាស់នៅឡើយទេ ។ ភ័ស្តុតាងនៅកន្លែងនេះមួយដុំ កន្លែងនោះមួយដុំបញ្ជាក់ថា អារម្មណ៍ប្រឆាំងរដ្ឋាភិបាលកើតមាននៅជួរកងទ័ពនៅក្នុងទីក្រុងនិងកំពុងតែពង្រីកខ្លួនចូលក្នុងភូមិភាគបូព៌ា ។ សូមមើលកិច្ចសម្ភាសន៍របស់លោក ហេដឌ័រ ។ ក្នុងកិច្ចសម្ភាសន៍នោះ អតីតកម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ និយាយថា «ប្រហែលជាក្នុងខែមេសា ឆ្នាំ១៩៧៦ មានបោះទីតាំងកាំភ្លើងធំនៅជុំវិញច្បារអំពៅដើម្បីបាញ់ផ្តោងដាក់ការិយាល័យប៉ុល ពត... ។ ខាងមជ្ឈិមរកឃើញផែនការនេះហើយក៏បង្ក្រាបភ្លាមមិនឲ្យវាធ្វើប្រតិបត្តិការបានឡើយ» ទំព័រទី៤៥ ។ វានៅតែមិនច្បាស់ដដែល មិនដឹងថា កម្មាភិបាលរូបនេះនិយាយដោយផ្អែកលើការចងចាំរបស់ខ្លួន ឬផ្អែកលើអ្វីដែលគេប្រាប់ខ្លួននៅក្នុងកិច្ចប្រជុំបក្សក្រោយពីព្រឹត្តិការណ៍នេះកើតឡើងរួចហើយ ឬក៏យ៉ាងណាទេ ។

៣៦) ចម្លើយសារភាព៨៤៩សន្លឹករបស់ ចាន់ ចក្រី មាននៅក្នុងដុំមីក្រូហ្វីលលេខCMR11.7 ។ ចង់ជ្រាបពីអាជីពរបស់ ចាន់ចក្រី សូមមើលកិច្ចសម្ភាសន៍របស់លោក ហេដឌ័រ ទំព័រទី៤៤ ។ ស្នាដៃនិពន្ធរបស់ បឺឃ្ល័រ មានចំណងជើងថា "ភ្នែកម្នាស់" ទំព័រទី១០៨-៩ និងស្នាដៃនិពន្ធរបស់ ឃៀរនិន មានចំណងជើងថា "យុទ្ធសាស្ត្រឡើងមកកាន់អំណាចរបស់ ប៉ុល ពត"ទំព័រទី២៥៧ ។ យោងតាមកិច្ចសម្ភាសន៍របស់លោក ហេដឌ័រ (ការទាក់ទងផ្ទាល់ខ្លួន) ចាន់ ចក្រី ត្រូវបានប៉ូលិសទ្រង់ សីហនុ ជួលឲ្យលួចជ្រៀតចូលបន្ទំខ្លួននៅក្នុងជួរបក្សកុម្មុយនិស្តកម្ពុជា ប៉ុន្តែបែរជានាំមេកោយរបស់ខ្លួនមួយចំនួនចូលបក្សកុម្មុយនិស្តកម្ពុជាទៅវិញ ។ ស្នាដៃនិពន្ធរបស់ ឃឺន មានចំណងជើងថា "គំរូនិងទំហំនៃអំពើឃោរឃៅ" ទំព័រទី១៩៥ បានដកស្រង់សម្តីរបស់ជនភៀសខ្លួនខ្មែរទាក់ទងនឹងរឿងរបស់ ចក្រី ។ ជនភៀសខ្លួនទាំងនោះប្រហែលជាកម្មាភិបាលប្រាប់អំពីកំហុសដែលគេចោទប្រកាន់ ចក្រី តាមរយៈការប្រើពត៌មានពីចម្លើយសារភាពរបស់ ចក្រី ។ សូមមើលស្នាដៃនិពន្ធរបស់លោក ឆេនដល័រ, ឃៀរនិន និង ប៊ូ "ប៉ុល ពត ឡើងមកកាន់អំណាចដោយរបៀបណា" ដែលនៅក្នុងស្នាដៃនិពន្ធនេះ ហ៊ូ នឹម ឆ្លើយសារភាពថា ចាន់ ចក្រី បានប្រាប់ខ្លួនថា "ខ្ញុំដឹងថាត្រូវបន្ទំខ្លួនយ៉ាងម៉េចហើយ ។ នៅពេលណាខ្ញុំទៅដល់កន្លែងផ្សេង ខ្ញុំដូរឈ្មោះថ្មី ។ គ្មានអ្នកណាដឹងពីប្រវត្តិរបស់ខ្ញុំឡើយ" (២៩៩) ។ សៀវភៅមានចំណងជើងថា "កម្ពុជាប្រជាធិបតេយ្យ, សៀវភៅខ្មៅ" សរសេរថា ចក្រី "ចង់ធ្វើឃាតថ្នាក់ដឹកនាំបក្សកុម្មុយនិស្តកម្ពុជា" ។

៣៧) ខ្ញុំសូមថ្លែងអំណរគុណចំពោះ រីឆាត អារិន ដែលបានចង្អុលប្រាប់ឯកសារដកស្រង់នេះដល់ខ្ញុំ និងផ្តល់ឯកសារប្រែសម្រួលដ៏ស្ទាត់ជំនាញនេះឲ្យខ្ញុំ ។ ចង់ជ្រាបអំពីការចាប់ខ្លួនរបស់ ឈូក សូមមើលដុំមីក្រូហ្វីលលេខCMR123.2 ក្នុង ចុះខែវិច្ឆិកា ឆ្នាំ១៩៧៨÷ "ក្រោយពី ភឹម ត្រឡប់មកពីបរទេសវិញ ភឹម ក៏មកចាប់ ឈូក បញ្ជូនទៅអង្គការយោងតាមឯកសារពីអង្គការ" ។

៣៨) ចំពោះកម្មាភិបាលដែលបានសម្របខ្លួនទៅតាមផែនការនេះសូមមើល "យុទ្ធសាស្ត្រឡើងមកកាន់អំណាចរបស់ ប៉ុល ពត" ទំព័រទី៩-៣៥ ដែលជាសុន្ទរកថា ធ្វើឡើងនៅខែមិថុនា ឆ្នាំ១៩៧៦ ដោយ "អ្នកនាំពាក្យបក្ស" នៅភូមិភាគបស្ចិម ។ សូមមើលដុំមីក្រូហ្វីលលេខCMR50.14 កែវ មាស, CMR80.36 ណៃ សារ៉ាន់, CMR13.28 ជ័យ សួន ។ ជើងចាស់ទីបួន ឈ្មោះ កែវ មុនី (លេខXVI CMR49.15) គឺជា"ខ្មែរហាណូយ" ដែលត្រូវបានចាប់ខ្លួននៅចុងខែតុលា ឆ្នាំ១៩៧៦ ។ អនុរបស់ ឈូក នៅតំបន់២៤ ឈ្មោះ ប៉ុត អ៊ុន (CMR106.28) មកដល់ពាក់កណ្តាលឆ្នាំ១៩៧៧ ទើបគេចាប់ខ្លួន ។ ឥស្សរជនពីររូបទៀតដែលស្ថិតក្នុងចលនាប្រឆាំងនឹងបារាំងគឺមាន សោ ភឹម និង រស់ ញឹម ។ សោ ភឹម ជាលេខាភូមិភាគបូព៌ា ចំណែកឯ រស់ ញឹម ជាលេខាភូមិភាគពាយ័ព្យ ។ ក្នុងខែមេសា ឆ្នាំ១៩៧៦ អ្នកទាំងពីរនេះក្លាយទៅជាអនុប្រធានរដ្ឋទីមួយ និងទីពីរបន្ទាប់ពី ខៀវ សំផន ។ ឈ្មោះរបស់អ្នកទាំងពីរចាប់ផ្តើមលេចឡើងនៅក្នុងចម្លើយសារភាពនានាដែលធ្វើឡើងនៅពាក់កណ្តាលឆ្នាំ១៩៧៦ ។ ប៉ុន្តែ រស់ ញឹម មកដល់ឆ្នាំ១៩៧៨ ទើបត្រូវគេចាប់ខ្លួន ចំណែកឯ សោ ភឹម វិញបានធ្វើអត្តឃាតក្នុងខែឧសភា ឆ្នាំ១៩៧៨ ។ មាស ម៉ុន ដែលត្រូវបានចាប់ខ្លួនក្រោយ សោ ភឹម ធ្វើអត្តឃាត និយាយនៅក្នុងចម្លើយសារភាពរបស់ខ្លួនថា ការសមគំនិតដ៏ពេញទំហឹងកំពុងតែធ្វើឡើងនៅ

ភូមិភាគបូព៌ាក្នុងឆ្នាំ១៩៧៦ ។ ភាពយឺតយ៉ាវរបស់មជ្ឈិមបក្ស ក្នុងការចាត់ការរឿងផ្សំគំនិតនេះសបញ្ជាក់ឲ្យឃើញថា អំពើនេះមិនកើតមានពិតប្រាកដឡើយ ឬថា មជ្ឈិមបក្សមិនសូវទុកចិត្តក្នុងការវាយប្រហារកម្មាភិបាលជាន់ខ្ពស់នៅភូមិភាគ ឬក៏ថា កែវ សំណាង កំពុងតែសន្មតថា នៅឆ្នាំ១៩៧៨ មជ្ឈិមបក្សនឹងមានការមន្ទិលសង្ស័យទៅលើភូមិភាគបូព៌ាដូចក្នុងឆ្នាំ១៩៧៦ ដែរ ដែលការធ្វើយ៉ាងនេះគឺចង់បានស្នាដៃថាខ្លួនមានប្រាជ្ញាញាណ ។ រាល់លទ្ធភាពទាំងបីនេះប្រហែលជាកំពុងតែប្រព្រឹត្តទៅនៅពេលនោះ ។

៣៩) ទាក់ទងនឹងមូលដ្ឋានគ្រឹះរបស់បក្សពលករកម្ពុជា សូមមើលស្នាដៃនិពន្ធរបស់ ឃៀវនិន មានចំណងជើងថា «យុទ្ធសាស្ត្រឡើងមកកាន់អំណាចរបស់ ប៉ុល ពត» ទំព័រទី១៩០-៩៣ និងស្នាដៃនិពន្ធរបស់លោក ឆេនដល័រ មានចំណងជើងថា «បងលេខមួយ» ទំព័រទី៧៩ ។ គំនិតដែលថា បក្សពលករកម្ពុជាជា «បក្សប្រកួតប្រជែង» គឺជាករណីច្បាស់ណាស់របស់មជ្ឈិមបក្សនិងមន្ទីរស-២១ ដែលប្រឹងប្រែងធ្វើឲ្យ «ភស្តុតាង»ស៊ីគ្នាទៅនឹងប្រវត្តិរបស់បក្សដែលត្រូវបានផ្លាស់ប្តូររួចហើយ និងទម្លាប់របស់មជ្ឈិមបក្សក្នុងការចាត់អ្នកប្រឆាំងជាជំពូកផ្សេងៗគ្នាយ៉ាងច្រើន ។ ការវាយប្រហារមកលើបក្ស «ប្រកួតប្រជែង» មានពេញមួយជីវិតរបស់កម្ពុជាប្រជាធិបតេយ្យ ។ ដូចជានៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៧៨ សៀវភៅកំណត់ហេតុទុយ-ប៉ុន មានកំណត់សម្គាល់មួយថា «កិច្ចការរបស់យើងគឺស្វែងរកក្បាលម៉ាស៊ីនរបស់បក្សពលករកម្ពុជា (ដែលជាទាសករវៀតណាម)» ។ ដល់ពេលនោះ សោ ភឹម ដែលត្រូវបានសង្ស័យថាជាអ្នកកាន់តំណែងនេះបានសម្លាប់ខ្លួនបាត់ទៅហើយ ។

៤០) *CMR124.17* ឯកសារប្រែសម្រួលជាភាសាអង់គ្លេស ។ ស៊ីវ ហេងឌ័រ ។ *CMR71.10* មាស ម៉ុន ឆ្លើយថា បក្សពលករកម្ពុជាត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៦ និងមានសមាជិកចំនួនប្រាំនាក់ ។ កម្មាភិបាលជាន់ខ្ពស់មួយចំនួនតែងតែសារភាពថាបានប្រព្រឹត្តបទឧក្រិដ្ឋនិងជាសមាជិករបស់បក្សនេះ ដែលការអះអាងទាំងអស់នេះ កម្មាភិបាលជាន់ខ្ពស់អាចបានដឹងយ៉ាងច្បាស់នៅក្នុងវគ្គសិក្សាមុនពេលត្រូវគេចាប់ខ្លួន ។ សូមមើល «ផែនការចុងក្រោយ» ទំព័រទី៣១៣÷ «ខ្ញាំងឆ្លើយថា មានឈ្មោះច្រើនណាស់ មានដូចជាបក្សកុម្មុយនិស្តថ្មី បក្សកុម្មុយនិស្តបដិវត្តន៍កម្ពុជា បក្សពលករកម្ពុជា បក្សប្រជាជន បក្សសង្គមនិយម» ។ នៅពេលអ្នកទោសក្លាយជាជនក្បត់តាមរយៈការចាប់ខ្លួន ឈ្មោះរបស់ «បក្សទាំងឡាយ» ដែលខ្លួនបម្រើគ្រាន់តែជាការបន្ទាប់បន្សំប៉ុណ្ណោះ ប៉ុន្តែការឆ្លើយថា ខ្លួនជាសមាជិករបស់បក្សនោះទើបសំខាន់ ។

៤១) សុន្ទរកថា និងផែនការមានប្រែសម្រួលជាភាសាអង់គ្លេសនៅក្នុងស្នាដៃនិពន្ធរបស់លោក ឆេនដល័រ, ឃៀវនិន, និង ប៊ូ «ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត» ទំព័រទី១១៩-៦៣ និង ៣៦-១១៨ ។ ស្នាដៃរបស់ វីលម៉ុត មានចំណងជើងថា «កំហុសនៃការវិភាគ» បានធ្វើការវិភាគទៅលើគោលគំនិតនៃផែនការបួនឆ្នាំនិងការផ្តួចផ្តើមគំនិតផ្សេងៗទៀតរបស់បក្សកុម្មុយនិស្តកម្ពុជា ។ ការប្រកាសអំពីអត្ថិភាពរបស់បក្សត្រូវបានពន្យារពេលរហូតដល់ខែកញ្ញា ឆ្នាំ១៩៧៧ ហើយផែនការបួនឆ្នាំមិនដែលបានដាក់ចេញជាផ្លូវការទេ ។

៤២) កិច្ចសម្ភាសន៍របស់លោក ហេងឌ័រ ទំព័រទី៦១ ។ នៅពិធីបុណ្យថ្ងៃទី១៨ ខែកញ្ញា ប៉ុល ពត

បានថ្លែងការសរសើរពីឃ្លាដល់ថ្នាក់ដឹកនាំចិន (*FBIS* ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៧៦) ។ ចំពោះការកត់សម្គាល់របស់ ស៊ិន ហាវ សូមមើល *FBIS* ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៧៨ ។ ការវាយប្រហាររបស់កម្ពុជាប្រជាធិបតេយ្យមកលើ តេង ស៊ាវពីង ដែលផ្សាយតាមរលកធាតុអាកាសវិទ្យុផ្សាយសំឡេងទីក្រុងភ្នំពេញថ្ងៃទី១ ខែតុលា មិនយូរប៉ុន្មានក៏ត្រូវស្ងប់ទៅវិញដោយសារការចាប់ខ្លួន «បនបួននាក់» ហើយនៅថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៧៦ បន្ទាប់ពី ប៉ុល ពត ចូលកាន់ការងារជាសាធារណៈសាជាថ្មីជានាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត ក៏ផ្ញើទូរលេខមួយច្បាប់ទៅទីក្រុងប៉េកាំងថ្កោលទោស «បនទាំងបួន» ។ យោងតាមអតីតអ្នកការទូតចិនបានឲ្យដឹងថា បុគ្គលិកសំខាន់ៗនៃស្ថានទូតចិនប្រចាំនៅទីក្រុងភ្នំពេញដែលសុទ្ធតែជាអ្នកជំនាញការខ្មែរនៅមានសមាសភាពដដែលមិនមានការផ្លាស់ប្តូរទេ (កិច្ចសម្ភាសន៍របស់អ្នកនិពន្ធ) ។

៤៤) ចង់ជ្រាបអំពីការលាលែង សូមមើល *FBIS*ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦ ។ ចំពោះប្រតិកម្មរបស់ តាម៉ុក និង នួន ជា សូមមើល (ការទាក់ទងផ្ទាល់ខ្លួនរបស់) ណេត ថាយ័រ ។ ការដែល អៀង សារី និយាយរឿងខុបទុវហេតុនេះយ៉ាងច្បាស់ក្នុងកិច្ចសម្ភាសន៍ជាមួយ ស្ទីវ ហេដឌ័រ បង្ហាញថា «ការលាលែង» នេះប្រហែលជាមានបញ្ហាខាងកិច្ចការបរទេស ។ អាចនិយាយបានថា ប្រហែលជាការនេះត្រូវបានធ្វើឡើងដើម្បីឲ្យ ប៉ុល ពត គេចមិនជួបភ្ញៀវដែលមិនគួរស្វាគមន៍ ។ ក៏ប៉ុន្តែនៅមិនទាន់មានប្រភពណាមួយបញ្ជាក់ច្បាស់ថា សម្មតិកម្មនេះមានលក្ខណៈពិតប្រាកដនៅឡើយទេ ។

៤៥) ចំពោះការបកប្រែកំណត់សម្គាល់នេះសូមមើលនៅក្នុងស្នាដៃនិពន្ធរបស់ ឆេនដល័រ,ឃៀរនិន និង ប៊ូ ដែលមានចំណងជើងថា «ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត» ពីទំព័រ១៦៤ដល់១៧៦ ។

៤៦) សូមមើលនៅក្នុងស្នាដៃនិពន្ធរបស់ ឆេនដល័រ, ឃៀរនិន និង ប៊ូ ដែលមានចំណងជើងថា «ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត» ទំព័រទី១៧១ ។

៤៧) *CMR80.36* ។ សំណេររបស់ ណៃ សារ៉ាន់ លើទំព័រមួយចំនួនមើលសឹងតែមិនដាច់ ហើយចម្លើយសារភាពទាំងដុលរបស់គាត់ប្រសិនជាមានប្រហែលជាបានឆ្លងកាត់«បង១ថ្នាក់លើ»ហើយ ។ ប៉ុន្តែឯកសាររបស់ «បង១ថ្នាក់លើ» បាត់បង់អស់ទៅហើយ ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ឯកសារសំខាន់ៗអាចនៅសល់ខ្លះ ពីព្រោះអតីតអន្តរក្សរបស់ ណៃ សារ៉ាន់ ដែលផ្តល់កិច្ចសម្ភាសន៍ដល់អ្នកស្រី សារ៉ាខូម នៅឆ្នាំ១៩៩៦ ដោយមិនបញ្ចេញឈ្មោះបាននិយាយថា ខៀវ សំផន បានអានចម្លើយសារភាពរបស់ សារ៉ាន់ អស់ «បីម៉ោង» នៅក្នុងកិច្ចប្រជុំមួយរបស់បក្ស (ការទាក់ទងផ្ទាល់ខ្លួនរបស់អ្នកស្រី សារ៉ាខូម) ។ ម្យ៉ាងវិញទៀត ចំណាររបស់ ឌុច និង ប៊ុន នៅលើចម្លើយសារភាពមួយផ្នែកដែលនៅសល់រហូតដល់សព្វថ្ងៃនេះបង្ហាញថា ណៃ សារ៉ាន់ គឺជាអ្នកទោសម្នាក់ដែលមានចិត្តមានះរឹងរូសដែលបក្សមិនចង់ទុកឲ្យនៅជាខបសត្តតទៅទៀត ។ ណៃ សារ៉ាន់ អាចត្រូវបានសម្លាប់ចោលដោយមិនទាំងបានឆ្លើយសារភាពឲ្យបានក្បោះក្បាយផង ។ សូមមើល «កម្ពុជាប្រជាធិបតេយ្យ-សៀវភៅខ្មៅ» ទំព័រទី៥៧ ដែលអះអាងថា ណៃ សារ៉ាន់ គឺជា «ភ្នាក់ងារមុខពីរ ធ្វើការឲ្យវៀតណាមផងនិងឲ្យសេ.អ៊ី.អាផង» ដើម្បីបំផ្លាញកម្ពុជាប្រជាធិបតេយ្យ ។

៤៨) CMR50.14 វគ្គទី៨ ចុះថ្ងៃទី២៥ ខែកញ្ញា ដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៦ ។

៤៩) CMR50.14 ឯកសារសរសេរដោយដៃរបស់ កែវ មាស ដែលមានកម្រាស់២៧ទំព័រ «និយាយច្បាស់អំពីទំនាស់នៅទីក្រុងហាណូយលើបញ្ហាថា តើត្រូវកំណត់យកថ្ងៃកំណើតរបស់បក្សឆ្នាំ១៩៥១ ឬ ១៩៦០» ។

៥០) ស្នាដៃនិពន្ធរបស់ ឆេនដល័រ, ឃៀរនិន និង ប៊ូ ដែលមានចំណងជើងថា "ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត" ទំព័រទី៤ ។ ការទាក់ទងផ្ទាល់របស់លោក ស៊ីវ ហេដឌ័រ បានបញ្ជាក់ថា កំណើតរបស់បក្សក៏ត្រូវបានលើកមកពិភាក្សាដែរ នៅក្នុងមហាសន្និបាតបក្សកុម្មុយនិស្តកម្ពុជានៅដើមឆ្នាំនោះ ។ កែវ មាស ដែលស្ថិតក្រោមការឃ្លាំមើលស៊ើបគ្រប់វិនាទីប្រហែលជាមិនបានចូលរួមក្នុងកិច្ចពិភាក្សានេះទេ ។

៥១) សូមមើលបន្ថែមនូវកិច្ចសម្ភាសន៍មិនទាន់បោះពុម្ពផ្សាយរបស់លោក ស៊ីវ ហេដឌ័រ ជាមួយ ទួន មុំ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៨០ៈ «[ក្នុងឆ្នាំ១៩៧៣] យើងយកឆ្នាំ១៩៥១ ជាថ្ងៃបង្កើតបក្ស ប៉ុន្តែ ចូរចាំថា គ្មានអ្នកណាលើកយកថ្ងៃខែចាប់ពីឆ្នាំ១៩៥១មកនិយាយឡើយ ។ ផ្ទុយទៅវិញយើងយកថ្ងៃខែ មហាសន្និបាតក្នុងឆ្នាំ១៩៦០» ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោក ស៊ីវ ហេដឌ័រ ដែលបានផ្តល់ឯកសារកិច្ចសម្ភាសន៍ចម្លងមួយច្បាប់ដល់ខ្ញុំ ។

៥២) FBIS (វៀតណាមសឺរីស) ថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៧៨ មុនពេលដែលវៀតណាមមើលឯកសារនៅមន្ទីរស-២១ ។ អ្នកចុះចូលម្នាក់នេះបន្តរាយការណ៍បន្ថែមអំពីការធ្វើវិសុទ្ធកម្មក្នុងទ្រង់ទ្រាយធំនៅខែមេសា ឆ្នាំ១៩៧៧ ។ គ្មានឯកសារសារាចរណាបញ្ជាក់ថា សមាជិកភាពរបស់បក្សកុម្មុយនិស្តមិនមានលក្ខណៈស្របច្បាប់ឡើយមុនពេលដែល "ឆ្នាំ១៩៦០" ត្រូវបានលាតត្រដាងច្បាស់លាស់នោះ ។

៥៣) ទង់បដិវត្តលេខពិសេស ខែកញ្ញា-តុលា ១៩៧៦ ទំព័រទី៤ និងទង់បដិវត្ត ខែកញ្ញា ឆ្នាំ១៩៧៦ ទំព័រទី៣ ។ ព័ត៌មានបន្ថែមទៀតសូមមើលស្នាដៃនិពន្ធរបស់លោក ឆេនដល័រ មានចំណងជើងថា «សេរីរឿងអតីតកាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ» ។

៥៤) CMR13.28 ។ ព័ត៌មានស្តីពីការចាប់ខ្លួនរបស់ ណុន សួន សូមមើលកិច្ចសម្ភាសន៍របស់លោក ស៊ីវ ហេដឌ័រ ទំព័រទី២៩ ។ អ្នកផ្តល់កិច្ចសម្ភាសន៍ដែលសុំមិនបញ្ចេញឈ្មោះដែលជាអតីតនិរសាពិសេសរបស់ ណុន សួន និយាយប្រាប់ លោក ស៊ីវ ថា ព័ត៌មានស្តីពីការចាប់ខ្លួនរបស់ សួន ក្នុងឆ្នាំ១៩៧៦ គាត់ក៏មិនដឹងដែរ ពីព្រោះ«ខ្ញុំមិនដែលឮ [សួន] សម្តែងការមិនពេញចិត្តចំពោះមាគ៌ារបស់បក្សទេ ទោះជាខាងផ្នែកកសាងជាតិ...ឬខាងការពារជាតិក៏ដោយ» ។ ចម្លើយសារភាពរបស់ ណុន សួន ដែលមាន៣៩៤ទំព័រ មានរៀបរាប់ពីប្រវត្តិរបស់ ប៉ុល ពត, នួន ជា, អៀង សារី, សោ ភឹម, តាម៉ុក និង សុន សេន ដែរ ។ ការរៀបរាប់របស់ ណុន សួន បានចោទ តាម៉ុក ដែលជាលេខាភូមិភាគនិរតីថា ជា«មនុស្សបុគ្គលនិយមនិងបក្សពួកសាច់ញាតិនិយម» ហើយចចេសនិងអួតអាង ។ បុគ្គលិកលក្ខណៈរបស់ តាម៉ុក បែបនេះមានរហូតមកដល់ទសវត្សរ៍ឆ្នាំ១៩៩០ ។ ណុន សួន ក៏បានកត់សម្គាល់ដែរអំពី «ប្រវត្តិចេញពីកសិករមាន» របស់ នួន ជា និង អៀង សារី និងប្រវត្តិចេញពី «ម្ចាស់ដី» របស់ សុន សេន ។ វានៅមិនច្បាស់នៅឡើយថា ហេតុអ្វីបានជាការរិះគន់ទាំងនេះ

លើកឡើងបន្តនិយាយចេញដោយគ្មានអ្នកណាបន្ទំយ៉ាងនេះ ។ ឯកសារទាំងនេះជាឯកសារដើមសរសេរដោយដៃ ហើយប្រហែលជាមិនដែលផ្ញើទៅមជ្ឈិមបក្សផងក៏មិនដឹង ។

៩៥) សុន្ទរកថាខែធ្នូ បានជំរុញឲ្យប្រជាជនកម្ពុជា«រៀបចំខ្លួនធ្វើសង្គ្រាមឈ្លបយូរអង្វែង» ។ ឆេនដល័រ, ឃៀរនិន និង ប៊ូ «ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត»ទំព័រទី១៩១ ។ សូមមើលស្នាដៃនិពន្ធរបស់លោក ឃៀរនិន មានចំណងជើងថា «របប ប៉ុល ពត» ទំព័រទី៣៥៧ ។ ភាពប្រទូសរ៉ាយរបស់កម្ពុជាប្រជាធិបតេយ្យចំពោះវៀតណាមប្រហែលជាត្រូវបានបញ្ឆេះឲ្យកាន់តែសន្ធោសន្ធៅដោយសេចក្ដីសម្រេចដែលធ្វើឡើងនៅក្នុងមហាសន្និបាតលើកទីបួននៃបក្សពលកវៀតណាម នៅខែធ្នូ ឆ្នាំ១៩៧៦ ក្នុងគោលបំណងធ្វើឲ្យមានដំណើរឆ្ពោះទៅមុខឈានទៅបង្កើត «ទំនាក់ទំនងពិសេស» ជាមួយប្រទេសឡាវនិងប្រទេសកម្ពុជា ។ បក្សកុម្មុយនិស្តកម្ពុជា ហាក់ដូចជាមិនត្រូវបានហៅទៅពិភាក្សាអំពីបញ្ហានេះ សូមមើលស្នាដៃនិពន្ធរបស់ ឈិន ដែលមានចំណងជើងថា «សង្គ្រាមចិនជាមួយវៀតណាម» ទំព័រ៣៣ ។ ស្នាដៃនិពន្ធ របស់ វ៉ៃរ៉ុន ដែលយកជាការបាន មានចំណងជើងថា «បក្សឥណ្ឌូចិន» បានផ្ដល់នូវការប្រមើលមើលទៅលើដំណាក់កាលដ៏សំខាន់នេះដោយផ្អែកលើកិច្ចសម្ភាសន៍ជាមួយសមាសភាពខ្មែរក្រហមនិងវៀតណាម ។

៩៦) *CMR139.15* សៀន អាន និង*CMR35.10* ហាក់ សៀង ឡាយនី ។ *CMR35.28* ហាក់ ប៉ាដេត ចម្លើយសារភាពរបស់ប្រពន្ធ ហាក់ សៀង ឡាយនី និង *CMR174.14* តូច ខាំឌឿន ដែលជាអ្នកការទូតរបស់កម្ពុជាប្រជាធិបតេយ្យដែលបានទៅសិក្សានៅប្រទេសបារាំង ។ តូច ខាំឌឿន បានសារភាពថា «និស្សិតនៅប្រទេសបារាំង រៀនសប្បាយហ៊ុហាដូចពួកអឺរ៉ុបអ៊ីចឹង ។ ដូច្នេះគេឲ្យទៅជិះជាន់ប្រជាជនម្ដេចនឹងកើត» ។ ខាំឌឿន ដែលជាបងប្រុសរបស់កម្មាភិបាលជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យឈ្មោះ តូច ភឿន «ស្លាប់នៅមន្ទីរស-២១ដោយសារជំងឺ» ។

៩៧) នៅពេលគេយកគាត់មកដល់ភ្នំពេញនៅដើមឆ្នាំ១៩៧៦ កុយ ធួន ត្រូវបានឈ្លេចសួរអំពីការប្រព្រឹត្តិខុសសីលធម៌ (រួមភេទ) របស់គាត់ ។ *CMR140.12* ស្បូវ ហិន អតីតលេខា (ភូមិភាគឧត្ដរ) កងពលលេខ៣១០ បានរាយឈ្មោះស្ត្រីម្នាក់ដែល «ខូចសីលធម៌» ជាមួយ កុយ ធួន ហើយនៅក្នុងចម្លើយសារភាពរបស់ប្រពន្ធកុយ ធួន (*CMR162.18* យុន) គាត់ហៅ កុយ ធួន ថា «អាធួន» ហើយនិយាយថា កុយ ធួន មិនស្មោះត្រង់នឹងគាត់ឡើយ ។

៩៨) «ផែនការចុងក្រោយ» នៅក្នុងស្នាដៃនិពន្ធរបស់លោក ជែកសុន មានចំណងជើងថា «ប្រទេសកម្ពុជាឆ្នាំ១៩៧៥-១៩៧៨» ទំព័រទី៣០៧ ។ ពាក្យធ្វើឲ្យអាម៉ាស់មុខបង្ហាញថា កុយ ធួន ប្រហែលជាបាននិយាយញ៉ាំកូនចៅរបស់ខ្លួនមែន ។

៩៩) នៅពេលថតចូលមាំស៊ីនថតចម្លងមីក្រូហ្វីល ចម្លើយសារភាពរបស់ កុយ ធួន (*CMR50.19*) មានតែ៣៨ទំព័រប៉ុណ្ណោះ ដែលបានមកពីការសួរចម្លើយបីលើកនៅដើមខែមីនា ឆ្នាំ១៩៧៧ ។ ប៉ុន្តែចំពោះសាច់ឯកសារសុទ្ធដែលតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាជាដុំៗ ៩១៦-២០ មានរហូតដល់ជាង ៦០០សន្លឹកដែលបានមកពីការសួរចម្លើយចំនួន៤៥លើកចាប់ពីខែកុម្ភៈ ដល់ខែមេសា ឆ្នាំ១៩៧៧ ។

ឯកសារនេះដែលតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានចំណាររបស់ ឌុច និង សុន សេន ច្រើនណាស់ ។ ឯកសារចម្លើយសារភាពនៅមន្ទីរស-២១ ដែលមិនល្អត្រូវបានបោះចោលដោយទុកតែឯកសារណាដែលល្អ ។ ទោះបីជាយ៉ាងដូច្នេះក៏ដោយ ឯកសារចម្លើយសារភាពដែលវែងជាងគេតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាក៏នៅតែមិនទាន់គ្រប់ទាំងស្រុងដែរ ពីព្រោះមានសន្លឹកឯកសារមួយចំនួនទៀតដែលវាយជាអត្ថលិខិតឡើងវិញបានមកពីប្រភពសម្ងាត់មួយនៅឆ្នាំ១៩៩៧ ដែលប្រហែលជាចេញពីចម្លើយសារភាពរបស់ កុយ ធួន មានតម្កល់ទុកនៅបណ្ណសារផ្សេងមួយទៀតមិនជាន់គ្នានឹងឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាទេ ។

៦០) ស្នាដៃនិពន្ធរបស់លោក ស៊ីវ ហេងឌ័រ មានចំណងជើងថា «សាសន៍និយម, ម៉ាក្សស៊ីសនិយម និងការចាត់ជាពួក» ទំព័រទី១២៦ ទាញហេតុផលករណីនេះយ៉ាងពិស្តារ ។ អ្វីដែលហៅថា «សកម្មជនប្រជាធិបតេយ្យ» នោះរួមមានដូចជា ម៉ៅ កែម, នួន (ហៅ ជុំ) លេខាស-៧១ សាលាបក្ស, ភោគ ឆាយ (ហៅទូច) ដែលធ្វើការនៅមន្ទីរ៨៧០ និង សៀត ឆែ (ហៅ ទុំ) ដែលធ្វើជាលេខាតំបន់២២ ភូមិភាគបូព៌ា ហើយក្រោយមកធ្វើការនៅក្រោមបញ្ជារបស់ សុន សេន នៅសេនាធិការភូមិភាគ ។

៦១) ចង់ជ្រាបពីការបះបោរនេះសូមមើលស្នាដៃនិពន្ធរបស់ ប៉ូល មានចំណងជើងថា «ផែនការសម្ងាត់ត្រូវបែកការណ៍», ស្នាដៃនិពន្ធរបស់ បឺឃ័រ មានចំណងជើងថា «ភ្នែកម្នាស់» ទំព័រទី១១៨-១៩ ។ ស្នាដៃនិពន្ធរបស់លោក ប៊ែន គៀរនិន មានចំណងជើងថា«របប ប៉ុល ពត»ទំព័រទី៣២៤ និង លោក ឃ៊ីន មានចំណងជើងថា «គំរូនិងទំហំនៃអំពើឃោរឃៅ» ទំព័រទី២០០ ។ វាអាចទៅរួចដែលថាជនភៀសខ្លួនដែលលោក ប៉ូល បានសម្ភាសនៅឆ្នាំ១៩៧៨ រំឭកអំពីការចោទប្រកាន់ដែលធ្វើឡើងនៅក្នុងវគ្គសិក្សាកម្មាភិបាល ។ សូមមើលបន្ថែមនូវឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាលេខL០១៨១៨ ដែលជាកំណត់ហេតុរំឭកផ្ដើមកពីមន្ទីរ៤១០និយាយសង្ខេបអំពីការបោសសម្អាតនៅភូមិភាគឧត្តរក្នុងឆ្នាំ១៩៧៧ ។

៦២) ក្រុមទីពីរនេះរួមមានសមាសភាពបញ្ញវន្តជាតិនិយម ហង់ ធុនហាក់ ដែលធ្លាប់រៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិជាមួយ កុយ ធួន ហើយបានក្លាយជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាល លន់ ណុល ក្នុងឆ្នាំ១៩៧២ ។ យោងតាមសមាជិកសភាម្នាក់ដែលធ្លាប់ធ្វើការជាមួយ ធុនហាក់ បានឲ្យដឹងថា ធុនហាក់ ជាសកម្មជនក្នុងមជ្ឈដ្ឋានគាំទ្រចិនរួមជាមួយនិង ហ៊ូ នឹម, ភោគ ឆាយ និង កុយ ធួន នៅទសវត្សរ៍ទី៦០ (កិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយ លឹម ហ្គិចគី) ។ ក្នុងនាមជានាយករដ្ឋមន្ត្រី ធុនហាក់ បានព្យាយាមបើកការចរចាជាមួយខ្មែរក្រហមដោយយកការទាក់ទងមុនឆ្នាំ១៩៧០មកប្រើប្រាស់ ។ នៅឯមន្ទីរស-២១ រាល់ការផ្ដើមគំនិតដែល ធុនហាក់ ខ្លួនឯងបដិសេធថា មិនពិត បានក្លាយជាអំពើក្បត់ដែលរៀបរាប់ដោយ កុយ ធួន រួចជាស្រេចហើយនោះ ។

៦៣) សៀវភៅកំណត់ហេតុ ទុយ-ប៉ុន ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៧៨ ។

៦៤) សូមមើលវគ្គ «ផែនការចុងក្រោយ» នៅក្នុងស្នាដៃនិពន្ធរបស់លោក ជែកសុន ដែលមានចំណងជើងថា «កម្ពុជាឆ្នាំ១៩៧៥-១៩៧៨» ទំព័រទី៣០៩: «កុយ ធួន ត្រូវបានវែកមុខដេញចេញពីការងារ

និងជំនួសដោយជនក្បត់ម្នាក់ទៀត» ។

៦៥) ស្នាដៃនិពន្ធរបស់លោក ស៊ីវ ហេដឌ័រ មានចំណងជើងថា "ប៉ុល ពត និង ខៀវ សំផន" បង្ហាញថា ខៀវ សំផន គឺជាកម្លាំងជំរុញឲ្យមានការបោសសម្អាត "សកម្មជនប្រជាធិបតេយ្យ" នៅឆ្នាំ១៩៧៧ ហើយប្រវត្តិជីវិតរបស់ "សកម្មជនប្រជាធិបតេយ្យ" ទាំងនេះមិនខុសពីប្រវត្តិជីវិតរបស់ ខៀវ សំផន ឡើយ ។ មិនតែប៉ុណ្ណោះសោត នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ ខៀវ សំផន បាននិយាយអំពីភាពចាំបាច់ក្នុងការ "បង្ក្រាបសត្រូវគ្រប់ប្រភេទ គ្រប់ពេលវេលា" (ស្នាដៃនិពន្ធរបស់ បាណេត, ឃៀរនិន និង ប៊ូ ដែលមានចំណងជើងថា "ច្បាប់ទម្លាប់មរណៈ" ទំព័រទី៦៦៩) ។ ខៀវ សំផន ចុះចូលមកខាងរដ្ឋាភិបាលទីក្រុងភ្នំពេញនៅខែធ្នូ ឆ្នាំ១៩៩៨ ។

៦៦) សូមមើលស្នាដៃនិពន្ធរបស់លោក ឆេនដល័រ, ឃៀរនិន និង ប៊ូ មានចំណងជើងថា "ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត" ទំព័រទី២២៧-៣១៨ ។ ឯកសារជាភាសាខ្មែរគឺមានក្នុងដុំមីក្រូហ្វីល CMR34.19 ។ បន្ទប់តូចដាក់ ហ៊ូ នឹម នៅមន្ទីរស-២១ គឺជាបន្ទប់តែមួយគត់ដែលត្រូវបានរកឃើញជាមួយនឹងអ្នកទោសពិសេសម្នាក់នៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។

៦៧) ស្នាដៃនិពន្ធរបស់លោក ឃៀរនិន មានចំណងជើងថា "របប ប៉ុល ពត" ទំព័រទី៣៥១ ។

៦៨) ស្នាដៃនិពន្ធរបស់ ប៊ីយ៉ូវ មានចំណងជើងថា "ភ្នែកម្នាស់" ទំព័រទី១២០ ។

៦៩) ស្នាដៃនិពន្ធរបស់លោក ឆេនដល័រ, ឃៀរនិន និង ប៊ូ មានចំណងជើងថា "ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត" ទំព័រទី២៩៣ ។ ប្រពន្ធរបស់ ហ៊ូ នឹម (CMR185.8) ដែលត្រូវបានចាប់ខ្លួនមកជាមួយគ្នា បានសុំឲ្យបក្សកុម្មុយនិស្តកម្ពុជាទុកជីវិតឲ្យកូនតូចរបស់គាត់ "ដែលមិនទាន់ចេះអានអក្សរនៅឡើយ" និងបានប្រគល់កូននោះជូនបក្ស ។

៧០) ខ្ញុំសូមថ្លែងអំណរគុណចំពោះ វីឆាត អារិន ដែលបានប្រាប់ពីឯកសារមួយផ្នែកដែលជាចម្លើយសារភាពរបស់ សៀត ឆែ ហើយបានផ្តល់អត្ថបទបកប្រែព្រាងដល់ខ្ញុំ ។ ប្រពន្ធរបស់ សៀត ឆែ ឈ្មោះ ពុន សុធា (CMR121.2) ត្រូវបានចាប់ខ្លួននៅដើមឆ្នាំ១៩៧៨ ។ ចំពោះចម្លើយសារភាពរបស់ សៀត ឆែ សូមមើលសេចក្តីបន្ថែមនៅទំព័រខាងក្រោយ ។

៧១) ស្នាដៃនិពន្ធរបស់ លោក ស៊ីវ ហេដឌ័រ មានចំណងជើងថា "ប៉ុល ពត និង ខៀវ សំផន" ទំព័រទី១៧ ។

៧២) សូមមើលដុំមីក្រូហ្វីលមួយចំនួនដូចជា CMR12.4 ឈឹម ឈុន ដែល "មិនប្រុងប្រយ័ត្នបណ្តោយឲ្យគោស៊ីស្រូវ"៖ CMR16.15 ចាន់ អឿន ដែលបានសារភាពថា "បានដុតនិងបើកទឹកឲ្យជន់លិចស្រែ ធ្វើឲ្យគោងាប់ប្រាំរយក្បាល បំផ្លាញស្រូវអស់ប្រាំមួយរយហិកតា និងឲ្យប្រជាជនរត់គេចខ្លួនទៅប្រទេសថៃ" និង CMR127.12 វឿន រុន ដែល "មិនឲ្យប្រជាជនធ្វើស្រែ" ។

៧៣) សូមមើលការពិភាក្សានៅក្នុងស្នាដៃនិពន្ធរបស់លោក ម៉ៃឃើល វីកឃ័រី ដែលមានចំណងជើងថា "កម្ពុជាប្រជាធិបតេយ្យ" ទំព័រទី១១៦-២២ និងស្នាដៃនិពន្ធរបស់លោក ឃៀរនិន មានចំណងជើងថា "របប ប៉ុល ពត" ទំព័រទី២១៦-៥០ ។ ស្តីពីព្រឹត្តិការណ៍នៅសំឡូត សូមមើលស្នាដៃនិពន្ធរបស់លោក

ឆេនដល័រ មានចំណងជើងថា «សោកនាដកម្ម» ទំព័រទី១៦៣-៦៧ និងពត៌មានលម្អិតនៅក្នុងសៀវភៅរបស់ ឃៀវសំផន និង ប៊ូ មានចំណងជើងថា «ប្រជាកសិករនិងនយោបាយ» ទំព័រទី១៦៦-២០៥ ។

៧៤) ពត៌មានទាក់ទង ខែក ប៉ែន សូមមើល *CMR48.20* និងស្នាដៃនិពន្ធរបស់ លោក ឃៀវសំផន មានចំណងជើងថា «របប ប៉ុល ពត» ទំព័រទី២៨៥ ។ ទស្សនាវដ្តីចេញផ្សាយខែតុលា-វិច្ឆិកា ឆ្នាំ១៩៧៧ ទំព័រទី៤ ។ នៅក្នុងវគ្គមួយដែលមានចំណងជើងថា «ផែនការចុងក្រោយ» ដែលជាស្នាដៃនិពន្ធរបស់លោក ដេកសុន មានចំណងជើងថា «កម្ពុជាឆ្នាំ១៩៧៥-១៩៧៨» ទំព័រ៣១២ ខែក ប៉ែន ត្រូវបានស្តីបន្ទោសយ៉ាងខ្លាំងថា បានប្រើ «ប្រជាជនថ្មី» ដែលជា «ភ្នាក់ងារសេ.អ៊ី.អា» ឲ្យ «ក្តាប់ផ្នែកបច្ចេកទេសគ្រប់គ្រងកងចល័ត ។ល ។ ធ្វើដូច្នេះគឺគេចង់បង្កើតរដ្ឋបាលក្បត់...បង្កើតរដ្ឋក្នុងរដ្ឋ» ។

៧៥) ចម្លើយសារភាពរបស់ រស់ ញឹម (*CMR78.21*) តម្កល់ទុកនៅបណ្ណសារមានតែ៣០ទំព័រប៉ុណ្ណោះ ហើយប្រហែលជាត្រូវបានប្រមូលបោះចោលខ្លះហើយក្រោយឆ្នាំ១៩៧៩ ។ រស់ ញឹម ធ្លាប់បានធ្វើការជាមួយមិត្តរបស់ខ្លួនមកពីខាងភូមិភាគពាយ័ព្យឈ្មោះ ស៊ីវ ហេង និង នួន ជា នៅភូមិភាគពាយ័ព្យនៅក្នុងពេលសង្គ្រាមឥណ្ឌូចិនលើកដំបូង ហើយបានចុះមកលេងកម្មាភិបាលកុម្មុយនិស្តនៅមន្ទីរ១០០ ក្នុងឆ្នាំ១៩៦៤ ។

៧៦) សូមមើលស្នាដៃនិពន្ធរបស់លោក ម៉ៃឃើល វីកឃ័រី ដែលមានចំណងជើងថា «កម្ពុជាឆ្នាំ១៩៧៥-១៩៨២» ទំព័រទី១២១ ។

៧៧) ស្នាដៃនិពន្ធរបស់លោក ឆេនដល័រ, ឃៀវសំផន និង ប៊ូ មានចំណងជើងថា «ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត» ទំព័រទី៥៦ ។ ដូចដែលលោក ឃៀវសំផន បានបញ្ជាក់ច្បាស់ហើយ (នៅក្នុងសៀវភៅៈ របប ប៉ុល ពត ទំព័រទី២៤៦) ថាភូមិភាគពាយ័ព្យត្រូវបានដាក់ផែនការបង្កបង្កើនផលស្រូវឲ្យបានច្រើនសម្រាប់ជាតិទាំងមូលនៅក្រោមផែនការបួនឆ្នាំ ។ ប៉ុន្តែមិនដូចជាភូមិភាគដទៃទៀតទេ ភូមិភាគពាយ័ព្យមិនមានកំណត់ឲ្យមានបរិមាណកំណត់នៃភោគផលសម្រាប់ប្រើប្រាស់នៅក្នុងមូលដ្ឋានរបស់ខ្លួនឡើយ ។

៧៨) ស្នាដៃនិពន្ធរបស់ អេលីហ្សាប៊ែត ប៊ែកឃ័រ មានចំណងជើងថា «ពេលសង្គ្រាមផុតរលត់ទៅ» ទំព័រទី២៤៦-៤៧ ។

៧៩) *CMR118.11* ឯកសារបកប្រែដោយលោក ស៊ីវ ហេងឌ័រ ។ សូមមើលបន្ថែមទស្សនាវដ្តីទង់បដិវត្តចេញផ្សាយខែកក្កដា ឆ្នាំ១៩៧៨ «ប្រុងប្រយ័ត្នបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង»ៈ «[ខ្មាំង] បានបង្អត់អាហារប្រជាជននិងធ្វើឲ្យប្រជាជនស្រេកឃ្លាន គ្មានសម្លៀកបំពាក់ និងគ្មានទីជម្រក ។ បង្ហូរទឹកមិនឲ្យធ្វើស្រែ បំផ្លាញស្រូវពូជ ដីដាក់ស្រែ កម្លាំងអូសទាញទន្ក្ល និងរនាស់ ចប ស្ទាបព្រា ចានក្បាន ឆ្នាំងបាយ បំផ្លាញសព្វបែបសព្វយ៉ាង...ធ្វើយ៉ាងណាឲ្យតែប្រជាជនអត់ឃ្លាន» (១៣) ។ សូមមើល *CMR124.17* វ៉ន វើត និយាយអំពីកម្មាភិបាលដែលខស្សហ៍ធ្វើការៈ «មានពេលខ្លះ [កម្មករ] ត្រូវគេឲ្យធ្វើការជ្រុលរហូតដល់ធ្លាក់ខ្លួនឈឺនិងធុញទ្រាន់នឹងរបបសមូហភាព» ។ នៅតំបន់៤ ភូមិភាគពាយ័ព្យប្រជាជនដែលត្អូញត្អែរថា គ្មានអាហារហូបគ្រប់គ្រាន់ត្រូវគេចោទប្រកាន់ថា «សេរី» (*CMR37.2* ហាង ប៊ុន) ។

៨០) ចង់ជ្រាបពត៌មានស្តីពីការបោសសម្អាតនៅភូមិភាគពាយ័ព្យនៅក្នុងឆ្នាំ១៩៧៧ និង១៩៧៨

សូមមើលស្នាដៃនិពន្ធរបស់ ដៃកសុន មានចំណងជើងថា «កម្ពុជាឆ្នាំ១៩៧៥-១៩៧៨» ទំព័រទី១០៥-៧ ។

៨១) សូមមើលឯកសារមួយចំនួនមានជាអាទិ៍ដូចជាស្នាដៃនិពន្ធរបស់ កាម មានចំណងជើងថា «ជនភៀសខ្លួនកម្ពុជា» ទំព័រទី១៣០ និងស្នាដៃនិពន្ធរបស់ ក្រាម័រ មានចំណងជើងថា «របបកុម្មុយនិស្តកម្ពុជា» ។

៨២) ស្នាដៃនិពន្ធរបស់ ប៊ីឆិត មានចំណងជើងថា «ត្រីកោណប្រទេសចិន កម្ពុជា និងវៀតណាម» ទំព័រទី១៦០ ។

៨៣) FBIS ថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៧៧ ។ ការដែលគួរឲ្យចាប់អារម្មណ៍នោះគឺមានតែសមាជិកពីររូបនៃមជ្ឈិមបក្សទេពោលគឺ នួន ជា និង ខៀវ សំផន ដែលត្រូវបានលើកឡើងចំឈ្មោះនៅក្នុងសុន្ទរកថានោះ ។ ស្នាដៃនិពន្ធរបស់លោក ស៊ីវ ហេដឌ័រ មានចំណងជើងថា «សាសន៍និយម ម៉ាក្សស៊ីសនិយម និងការចាត់ជាពួក» ទំព័រទី១៣៩ និង១៤២ ។ ការវាយប្រហារនៅខែកញ្ញាដែលស្នើឡើងដោយ សោ ភឹម និង តាម៉ុក ត្រូវបានមជ្ឈិមបក្សយល់ព្រមនិងឡូងមកវិញនៅពេលដែលវៀតណាមវាយបកត្រឡប់មកវិញ ក្នុងទ្រង់ទ្រាយធំជាងនិងមានប្រសិទ្ធភាពជាងនៅក្នុងខែវិច្ឆិកា ។ បន្ថែមពីលើនេះទៀត សូមមើលស្នាដៃនិពន្ធរបស់លោក ចាន់ដា ដែលមានចំណងជើងថា «សត្រូវបងប្អូនឯង» ទំព័រទី៨៤ ។

៨៤) CMR96.20 ឯកសារដែលមានដប់ប្រាំពីរសន្លឹកចុះថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៨ ដែលមានចំណងជើងថា «របៀបវាយវៀតណាមឲ្យបរាជ័យ» ។ មុខសញ្ញាជនជាតិវៀតណាមដែលត្រូវសម្លាប់ក៏ត្រូវបានផ្សព្វផ្សាយតាមវិទ្យុផ្សាយសំឡេងទីក្រុងភ្នំពេញៈ ស្នាដៃនិពន្ធរបស់លោក ឃៀរនិន មានចំណងជើងថា «របប ប៉ុល ពត» ទំព័រទី៣៩៣-៩៤ ។ បន្ថែមពីលើនេះទៀតសូមមើល CMR96.10 ដែលជាឯកសារស្តើងទីមួយមកពីមន្ទីរ៨៧០ ផ្តល់ការលើកលែងទោសពៃក្នុងគោលបំណងទាក់ទាញការគាំទ្រសម្រាប់ផ្ទើសគ្រោម ។ ឯកសារទីមួយ មានលើកមកពិភាក្សានៅក្នុងសៀវភៅនិពន្ធដោយលោក ឃៀរនិន មានចំណងជើងថា «របប ប៉ុល ពត» ទំព័រទី៣៨៧-៨៨ ។ សៀវភៅកំណត់ហេតុ ទុយ-ប៉ុន ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៧៨ ដែលពិភាក្សាអំពីយុទ្ធនាការឆ្នាំ១៩៧៧-៧៨ កត់សម្គាល់ថា ជនជាតិខ្មែរ «ពលីជីវិត» មួយនាក់ទល់នឹងវៀតណាមដប់ក្បាល ។

៨៥) សៀវភៅកំណត់ហេតុ ទុយ-ប៉ុន ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៧៨ ។

៨៦) ស្នាដៃនិពន្ធរបស់លោក ឃៀរនិន មានចំណងជើងថា «របប ប៉ុល ពត» ទំព័រ៣៨៦-៩០ ។ ស្នាដៃនិពន្ធរបស់លោក ស៊ីវ ហេដឌ័រ មានចំណងជើងថា «សាសន៍និយម ម៉ាក្សស៊ីសនិយម និងការចាត់ជាពួក» ទំព័រទី១៣៨ និង «ឯកសារកម្ពុជាទី១» ។ បន្ថែមពីនេះទៀត សូមមើលកិច្ចសម្ភាសន៍របស់ រីឆាត អារិន ជាមួយឈ្មោះ ឡាយ សាម៉ុន ជា «ខ្មែរហាណូយ» ដែលចាប់ផ្តើមហ៊ឹកហាត់នៅតាមបណ្តោយព្រំប្រទល់កម្ពុជាក្នុងខែកុម្ភៈ ឆ្នាំ១៩៧៨ ។ សៀវភៅខ្មៅ ទំព័រ៧៥ៈ «[វៀតណាម] អាចថ្លែងអំណរគុណយ៉ាងលឿនចំពោះភ្នាក់ងាររបស់ខ្លួនបង្កប់នៅក្នុងផ្ទៃក្នុងកម្ពុជា» ។

៨៧) ចំពោះការពិភាក្សាលើបញ្ហារូបភាពនេះ សូមមើលជំពូកទី៥ ។ បន្ថែមពីលើនេះសូមមើល «ចូរប្រុងប្រយ័ត្នបោសសម្អាតខ្មាំងបង្កប់ផ្ទៃក្នុងឲ្យអស់» ទង់បដិវត្តចេញផ្សាយខែកក្កដា ឆ្នាំ១៩៧៨ៈ «ខ្មាំង

បង្កប់ផ្ទៃក្នុងដែលជាភ្នាក់ងារខ្មែរបម្រើរបស់វៀតណាម...គឺមានពិសពុលបំផុត ហើយក៏គ្រោះថ្នាក់បំផុតដែរ» (៤) ។

៨៨) ស្នាដៃនិពន្ធរបស់លោក ស្ទីវ ហេដឌ័រ មានចំណងជើងថា ប៉ុល ពត និង ខៀវ សំផន ទំព័រទី២១ យោងក័ស្តុតាងពីចម្លើយសារភាពរបស់ សុក ធួក ហៅ វ៉ន វេត (CMR124.17) និង ជូ ជេត (CMR12.22) ។ បន្ថែមពីលើនេះសូមមើលសៀវភៅ «កម្ពុជាប្រជាធិបតេយ្យៈ សៀវភៅខ្មៅ» ទំព័រទី៧៦-៧៧ ។

៨៩) CMR124.17 សុក ធួក (ឯកសារបកប្រែដោយ ស្ទីវ ហេដឌ័រ) ។ បន្ថែមពីលើនេះទៀតសូមមើលស្នាដៃនិពន្ធរបស់ ឆេនដល័រ ដែលមានចំណងជើងថា «សោកនាដកម្ម» ទំព័រទី២៩៦ ដែលយោងតាមការចងចាំរបស់អ្នកនៅរស់រានមានជីវិតនិងចម្លើយសារភាពរបស់ វ៉ន វេត ដែលបានស្រង់សម្តីរបស់ សោ ភឹម និយាយថា «យើងត្រូវធ្វើការសម្ងាត់និងដោយប្រុងប្រយ័ត្នដើម្បីបង្កើតបក្សមួយដែលប្រឆាំងនឹងបក្ស-កុម្មុយនិស្តកម្ពុជា ។ យើងមានផែនការចំណាយលុយម្តងទៀត ។ នឹងមានប្រាក់ខែនិងប្រើសញ្ញាស័ក្តិនិងមានទីផ្សារ ។ ទាំងនេះគឺជាគោលដៅរបស់យើង» ។

៩០) ចំពោះការវាយតម្លៃរបស់អ្នកធ្វើការជាមួយ សោ ភឹម ស្តីពីចិត្តសាស្ត្ររបស់ សោ ភឹម នៅពេលនេះសូមមើលកិច្ចសម្ភាសន៍របស់ រីឆាត អារិន ជាមួយ យី យ៉ូន ។ ស្នាដៃនិពន្ធរបស់លោក ឃៀរនិន មានចំណងជើងថា «មាន់ព្រៃ» ទំព័រទី១៨៨-៨៩ និង «របប ប៉ុល ពត» ទំព័រទី៣៩២ ។

៩១) វាអាចទៅរួចដែរក្នុងការនិយាយថា ជូ ជេត បានចូលរួមផែនការបង្កការបះបោរយោធានៅភូមិភាគនេះ ។ សូមមើល «របប ប៉ុល ពត» ទំព័រទី៣៩១ ។ បំណែកឯកសារផ្សេងៗទៀតនៃចម្លើយសារភាពរបស់ប្រពន្ធគាត់ត្រូវបានចងក្រងដាក់នៅក្រោមឯកសាររបស់ អ៊ឹម លី (CMR39.23) និង អ៊ឹម ណន (CMR41.8) ។ ដោយមានមោទកភាពដែលបានបម្រើបក្សអស់ប៉ុន្មានឆ្នាំកន្លងមក ប្រពន្ធ ជូ ជេត បានលើកសរសើរ កែវ មាស ដែលជាមេរបស់ខ្លួនដោយក្តីក្លាហាន ។ «ខ្សែក្បត់» ដែលភ្ជាប់នៅក្នុងដុមីក្រូហ្វីលCMR41.8 មានឈ្មោះរហូតដល់ពីររយនាក់ ។ បន្ថែមពីលើនេះទៀតសូមមើល «ផែនការចុងក្រោយ» ដែលមានរាយឈ្មោះ ជូ ជេត ថាជាអ្នកសមគំនិតទុច្ចរិតជាមួយ សោ ភឹម និង រស់ ញឹម ។

៩២) កិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយ គក ស្រស់ និង ញ៉ែម អេន ។

៩៣) រឿងលម្អិតស្តីអំពីថ្ងៃចុងក្រោយរបស់ សោ ភឹម បានមកពីស្នាដៃរបស់លោក ឃៀរនិន មានចំណងជើងថា «មាន់ព្រៃ», កិច្ចសម្ភាសន៍របស់ រីឆាត អារិន ជាមួយ យី យ៉ូន (សាក្សីឃើញហេតុការណ៍ផ្ទាល់ភ្នែក) និងស្នាដៃនិពន្ធរបស់ លោក ឃៀរនិន មានចំណងជើងថា «របប ប៉ុល ពត»ទំព័រទី៤០០ ។

៩៤) ស្នាដៃនិពន្ធរបស់លោក ឃៀរនិន មានចំណងជើងថា «របប ប៉ុល ពត» ទំព័រទី៤០៥ និង «កម្ពុជាៈការសម្លាប់រង្គាលនៅភូមិភាគបូព៌ា» ។ ចង់ជ្រាបបន្ថែម សូមមើលការបកស្រាយរបស់លោក ស្ទីវ ហេដឌ័រ នៅក្នុងស្នាដៃនិពន្ធរបស់លោកមានចំណងជើងថា «សាសន៍និយម ម៉ាក្សស៊ីសនិយម និងការចាត់ជាពួក» ទំព័រទី១៤៩-១៥១ ។ លោក ស្ទីវ ហេដឌ័រ បានទាញហេតុផលថា ដោយសារកម្មាភិបាលភូមិភាគបូព៌ា «បេះតែសង្ស័យអំពីគំនិតនិងមនុស្សសាស្ត្រក្នុងការកសាងសង្គមនិយមឲ្យបានលឿនបំផុតនោះ នៅក្រោម

ក្រសែក្អែកមជ្ឈិមបក្ស កម្មាភិបាលទាំងនោះគឺជាវៀតណាម ហើយ (បើតាមការប្រើឃ្លារបស់លោក ស្ទីវ ហេដឌ័រ) ធូររលុង ដឹកនាំក្បត់ និងបំពាក់មនោគមវិជ្ជាតាមផ្លូវខុស» ។

៩៥) ចម្លើយសារភាពដែលឆ្លើយដាក់ សុន សេន (ចម្លើយសារភាពទាំងអស់នោះផ្ញើឡើងនៅចុងឆ្នាំ ១៩៧៨) រួមមានដុំមីក្រូហ្វីលCMR21.25 ។ ឆាយ គឹមហ័រ, CMR43.10 អ៊ុន ណាត, CMR159.11 ស៊ុន ទី, CMR159.16 សឿង គុន និង CMR165.17 យ៉ាង ខុន ។ ចង់ជ្រាបបន្ថែមសូមមើលស្នាដៃនិពន្ធរបស់លោក ស្ទីវ ហេដឌ័រ មានចំណងជើងថា «សាសន៍និយម ម៉ាក្សស៊ីសនិយម និងការចាត់ជាពួក» ។

៩៦) «រៀនសូត្រពីបទពិសោធន៍សំខាន់ៗក្នុងការបំពេញភារកិច្ចឆមាសទីមួយរបស់បក្ស ឆ្នាំ១៩៧៨» ទស្សនាវដ្ដីទង់បដិវត្ត លេខពិសេស ចេញផ្សាយខែឧសភា-មិថុនា ឆ្នាំ១៩៧៨ ទំព័រទី១៧-៣៣ និង «សេចក្ដីណែនាំរបស់គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជាចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៨» ដែលជាឯកសារមិនទាន់ចុះលេខនៅបណ្ណសារមន្ទីរស-២១ ។ បន្ថែមពីលើនេះទៀតសូមមើលស្នាដៃនិពន្ធរបស់លោក ម៉ៃឃើល វីកឃ័រី ដែលមានចំណងជើងថា «កម្ពុជាឆ្នាំ១៩៧៥-១៩៨២» ទំព័រទី១៤១ ។

៩៧) កិច្ចសម្ភាសន៍របស់លោក ស្ទីវ ហេដឌ័រ ជាមួយ ម៉ៃ ម៉ាន់ ។

៩៨) ឯកសារបកប្រែដោយលោក ដេវីដ អាស្លេលី ចេញពីខ្សែអាត់ដែលថតទុកការកាត់ទោស ប៉ុល ពត នៅអន្លង់វែង ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៧ ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោក អាស្លេលី ដែលបានផ្ដល់ឯកសារនេះដល់ខ្ញុំ ។ ចង់ជ្រាបបន្ថែមពីការពិពណ៌នាការកាត់ទោសនេះ សូមមើលស្នាដៃនិពន្ធរបស់លោក ណេត ថាយ័រ មានចំណងជើងថា «បងលេខសូន្យ» ។

៩៩) CMR161.3 យ៉ាន់ ។ ប្រហាក់ប្រហែលគ្នានេះដែរ នៅក្នុងឯកសារCMR56.3 គី ឈិន អតីតអ្នកសួរចម្លើយម្នាក់ទៀតបានកត់សម្គាល់ថា «ការសួរចម្លើយមិនចាំបាច់ច្បាស់ទេ ពីព្រោះបើគេជាអង្គការ ម្ល៉េះចាប់គ្មានសល់ម្នាក់ឡើយ» ។ នៅក្នុងឆ្នាំ១៩៨០ អ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហមម្នាក់និយាយប្រាប់លោក ស្ទីវ ហេដឌ័រ ថា បើធ្វើតាមប្រព័ន្ធឥតខ្ចោះនេះវិញ ម្ល៉េះអ្នកណាក៏ត្រូវស្លាប់ដែរ លើកលែងតែ ប៉ុល ពត ម្នាក់ប៉ុណ្ណោះ ។

## ជំពូកទីបួន: ការបង្កើតសំណួរ

១) កិច្ចសម្ភាសន៍របស់អ្នកស្រី សារ៉ាខូម ជាមួយ វ៉ាន់ ណាត ។ សូមមើល CMR27.1 អែម យ៉ាន ដែលក្នុងនោះអ្នកសួរចម្លើយបានកត់សម្គាល់ថា «វានិយាយថា មិនដឹងហេតុអ្វីបានជាគេចាប់វាមក» និង CMR33.14 ហាង ឡូន ដែលក្នុងនោះអ្នកសួរចម្លើយ «សួរថា ហេតុអ្វីបានជាអង្គការចាប់ខ្លួនមក» ។ ចំពោះពត៌មានប្រហាក់ប្រហែលនេះសូមមើល CMR42.11 អ៊ឹម សំអុល, CMR59.7 កែវ គុន, CMR62.12 លី ហុកបាយ, CMR150.13 ស៊ឹម យ៉េត និង CMR151.35 សុខ សារ៉េត ។ CMR59.16 គ្រិន លាន មានចំណាររបស់ ម៉ម ណៃ នៅក្រោម «មូលហេតុនៃការចាប់ខ្លួន»: មូលហេតុពីរនេះមាននាំមុខដោយពាក្យ «ប្រហែល» ។

២) ចង់ជ្រាបពីគំរូកុម្មុយនិស្តផ្សេងៗទៀត សូមមើលស្នាដៃនិពន្ធរបស់ សូលហ្សិន នីតស៊ីន មានចំណង

ជើងថា «មន្ទីរព្រហ្មទណ្ឌនៅប្រជុំកោះ» ទំព័រទី១៣៧ និងស្នាដៃនិពន្ធរបស់ ហែរ្សនតាលីនស្គី មានចំណងជើងថា «សំឡេងចាប់ខ្លួន» ទំព័រទី២៤ ដែលនិយាយពីឈ្មោះ អ៊ីសាក់ បាបេល ដែលត្រូវគេសួរកាលពីឆ្នាំ១៩៣៩ថា «នៅពេលចាប់ខ្លួន តើនិយាយយ៉ាងម៉េចឲ្យគេជឿថា ខ្លួនអត់បានធ្វើអ្វីខុស?» ។ បន្ថែមពីលើនេះទៀតសូមមើលស្នាដៃនិពន្ធរបស់ ហ្គីលប៊ឺរ មានចំណងជើងថា «ឆ្លើយភ្លាម! ឆ្លើយភ្លាម» ទំព័រទី១២៨ដែលរៀបរាប់អំពីអ្នកសួរចម្លើយ ហ្គីលប៊ឺរ ផ្ទាល់ ដែលនិយាយនៅឆ្នាំ១៩៤១ថា «ឈប់និយាយពីរឿងឆ្កួតៗទៀត! NKVD មិនដែលធ្វើខុសរបៀបនេះទេ ។ បើអ្នកឯងមកដល់ទីនេះហើយ មានន័យថា គេដឹងអ្វីៗសព្វគ្រប់អស់ហើយ...យើងដឹង ប៉ុន្តែទោះជាយ៉ាងណាក៏ឯងត្រូវនិយាយចេញមកដែរ ។ និយាយភ្លាមមក» ។ ពត៌មានបន្ថែមទៀត សូមមើលស្នាដៃនិពន្ធរបស់លោក រីធិនបឹក និង បឹក ណោត ដែលមានចំណងជើងថា «អ្នកដែលនៅពីក្រោយខ្នង» ទំព័រទី៣៩២ៈ «[នៅឆ្នាំ១៩៦៨ នៅទីក្រុងប៉េកាំង] មានអ្នកស៊ើបអង្កេតមួយក្រុមជួបខ្ញុំហើយចុងបញ្ចប់គ្មានរកឃើញតម្រុយណាមួយដើម្បីចោទប្រកាន់ខ្ញុំទេ ។ ក្រុមស៊ើបអង្កេតបានព្រមានខ្ញុំឲ្យរកនឹកមើលកំហុសរបស់ខ្លួនឯង» ។ ប្រហាក់ប្រហែលគ្នានេះដែរ ស្នាដៃរបស់ ភីក មានចំណងជើងថា «នៅឯនាយជើងមេឃ» ទំព័រទី១២៣ និយាយដល់ អៀង សារី រដ្ឋមន្ត្រីការបរទេសនៃកម្ពុជាប្រជាធិបតេយ្យដែលបាននិយាយនៅពេលប្រជុំកម្មាភិបាលថា «ចំពោះអ្នកក្បត់ចុងក្រោយ ជាភារកិច្ចសម្រាប់មិត្តទាំងអស់គ្នាហើយ ត្រូវរកឲ្យឃើញ» ។ មុត សុភា (ការទាក់ទងផ្ទាល់ខ្លួន) បានរំឭកដល់ «ការប្រជុំជីវភាព» នៅខេត្តបាត់ដំបង រវាងឆ្នាំ១៩៧៦-១៩៧៨ ដែលក្នុងនោះកម្មាភិបាលអាចនិយាយដាក់អ្នកណាម្នាក់ ហើយថា «អង្គការដឹងអស់ហើយ ថាឯងធ្វើអ្វីខុស ។ ចាំបាច់ឯងត្រូវតែប្រាប់អង្គការ» ។ ចង់ជ្រាបបន្ថែមសូមមើលស្នាដៃនិពន្ធរបស់ អហ្សេ មានចំណងជើងថា «ចម្លើយសារភាពធ្វើឡើងដោយបង្ខំ» ទំព័រទី១-១៥ ។

៣) ស្នាដៃនិពន្ធរបស់ ហេ្គ មានចំណងជើងថា «ហ្រ្វីដ» ទំព័រទី១៧២ ។ បន្ថែមពីលើនេះ សូមមើលស្នាដៃនិពន្ធរបស់ ស្ទូស្តេ មានចំណងជើងថា «ហ្រ្វីដ» ។ អាយរីណា ប៉ាប៊ីណូ បានផ្ដល់ឯកសារយោងនេះមកឲ្យខ្ញុំ ។

៤) ចំពោះការពិភាក្សាលើបញ្ហាទាំងនេះ សូមមើលស្នាដៃនិពន្ធរបស់ ស្តេន មានចំណងជើងថា «ការពិត រៀបរាប់តាមដំណើររឿង» ទំព័រទី៨១ ។ ស្នាដៃនិពន្ធរបស់ គ្រូស៍ មានចំណងជើងថា «សង្គ្រាមសតិ» និងស្នាដៃនិពន្ធរួមរបស់ អហ្សេ និង វិតធ័រ មានចំណងជើងថា «បង្កើតមនុស្សអាក្រក់» ។

៥) ស្នាដៃនិពន្ធរបស់ អហ្សេ និង វិតធ័រ ទំព័រទី៤០, កូតគីន «ភ្នំមេដែក» ទំព័រទី៣៣៦ ។

៦) *CMR157.9* ។

៧) ឯកសារបកប្រែដោយ ស៊ីវ ហេងឌ័រ ។ ប្រពន្ធរបស់ ស្បូវ ហិន ឈ្មោះ ព្រំ ញ៉ី (*CMR119.20*) ដែលធ្លាប់ធ្វើការជាមួយគ្នានៅកងពលលេខ៣១០ ត្រូវបានចាប់ខ្លួនមួយខែក្រោយមក ។ បន្ថែមលើនេះទៀតសូមមើល*CMR17.24* ជ័យ ដេង ដែលមុនពេលចាប់ខ្លួនធ្វើការនៅក្រុមសេដ្ឋកិច្ចមន្ទីរស-២១ ។ អ្នកសួរចម្លើយប្រាប់គាត់ថា បើគាត់និយាយការពិត គាត់នឹងត្រូវដោះលែង ។ គាត់ដឹងហើយថា អ្នកសួរចម្លើយនិយាយកុហក ហើយបានសរសេរថា «ខ្ញុំអស់សង្ឃឹមហើយ...ដៃជាប់ខ្នោះ រស់ក៏ដូចជាមិនរស់ដែរ» ។

៨) *CMR140.12* ។ ខ្លឹមសារទាំងស្រុងមានដូចតទៅៈ «ចំពោះការចោទប្រកាន់ថាក្បត់បក្ស និងបដិវត្ត

ខ្ញុំមិនយល់ស្របទេ ។ ខ្ញុំសូមស្លាប់តាមរបៀបអ្នកស្មោះត្រង់នឹងបក្សនិងបដិវត្ត មុននឹងស្លាប់សូមបក្សជួយរកយុត្តិធម៌ឲ្យខ្ញុំផង ។ មានតែបក្សទេដែលដឹងពីប្រវត្តិរបស់ខ្ញុំ» ។

៩) ស្នាដៃនិពន្ធរបស់ គុនឌីវ៉ា មានចំណងជើងថា «សិល្បៈប្រលោមលោក» ទំព័រទី៨៤ ។

១០) ស្នាដៃនិពន្ធរបស់ ហ៊ូរីត មានចំណងជើងថា «ឆក់យកជីវិត» ទំព័រទី១៨៥ យោងទៅអ្នកនិពន្ធ សូលហ្សិន នីតស៊ីន ។ សៀវភៅកំណត់ហេតុរបស់ តាន់ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៧៨ ។ បន្ថែមពីលើនេះ សូមមើលសៀវភៅកំណត់ហេតុរបស់ ទុយ-ប៊ុន ចុះថ្ងៃទី១៨ខែកញ្ញា ឆ្នាំ១៩៧៨ៈ «យើងត្រូវលេងល្បិចជាមួយ [ខ្មាំង] លាក់កុំឲ្យគេដឹងថាយើងចង់ធ្វើអ្វី ។ ប៉ុន្តែយើងត្រូវដឹងរបៀបសួរដូចជាឆ្ងល់ ហើយពេលសួរត្រូវជជីកសួរចាក់ឫសចាក់គល់ពីដើមដល់ចប់» ។

១១) CMR43.2 ។ នៅក្នុងឯកសារសរសេរមួយខែក្រោយមក ប៊ុត បន្ថែមទៀតថា «បើគេសួរអំពី សុន សេន ខ្ញុំនឹងឆ្លើយ ព្រោះការលាក់រឿងនេះពិតជាមានគ្រោះថ្នាក់ណាស់» ។ ពត៌មានបន្ថែមទៀត សូមមើល CMR24.27 ឌុក សំបូរ ដែលត្រូវជាប់ឃុំឃាំងអស់មួយប្រាំពីរថ្ងៃនៅបាត់ដំបង ដែលនៅទីនោះគាត់បានប្រាប់សន្តិសុខនូវឈ្មោះអ្នកចូលរួមអំពើក្បត់ជាមួយគាត់មុនពេលគេបញ្ជូនបន្តមកមន្ទីរស-២១ ។

១២) CMR182.13 ។ ប៉ុន្តែនៅត្រឹមឆ្នាំ១៩៧៧ ឈ្មោះសម្ងាត់នៃគុកនេះត្រូវបានលេចឮដល់អ្នកក្រៅមួយចំនួនតូច ។ អ៊ុន សុខហួ ដែលបានរំឭកឡើងវិញ នូវការចងចាំអំពីកំហុសរបស់ខ្លួនបានសារភាពថា បានប្រាប់មនុស្សម្នាក់ផ្សេងទៀតអំពីទីតាំងមន្ទីរស-២១ ។

១៣) ស្នាដៃនិពន្ធរបស់ ឆេនដល័រ, ឃៀរនិន និង ប៊ូ មានចំណងជើងថា «ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត» ទំព័រទី៣១២ ។ ហ៊ូ នឹម បានលើកឡើងអំពីអ្នកធ្វើការជាមួយឈ្មោះ ព្រំ សំអា ដែលបាននិយាយនៅពេលប្រជុំស្វ័យទិតៀនថា «ខ្ញុំគឺជាខ្មាំងដែលអង្គការត្រូវតែកម្ទេច» ។ ហ៊ូ នឹម បន្តទៀតថា «ក្រុមដែលចូលរួមនៅក្នុងកិច្ចប្រជុំនោះធ្វើសេចក្តីសន្និដ្ឋានថាៈ ព្រំ សំអា ពេលនោះ ត្រូវបានរាយការណ៍ដល់អង្គការ ហើយ បងហែម (ខៀវ សំផន) បានចេញបញ្ជាឲ្យតាមឈ្លបមើលថែមទៀត» ។ ពិរុទ្ធជនម្នាក់នេះបានធ្វើអត្តឃាតមុនពេលចាប់ខ្លួន ។

១៤) «របប ប៉ុល ពត» ទំព័រទី៣៤៦ ។ ចង់ជ្រាបពីការបញ្ជូនឯកសារបន្ទាប់បន្សំមួយចំនួនទៀត សូមមើលCMR81.7 ណាម ឌុល ដែលត្រូវបានសួរចម្លើយនៅតំបន់៥០៥ ហើយបញ្ជូនមកកាន់មន្ទីរស-២១ និងឯកសារលេខD០០១២៣ តម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៧ ដែលជាលិខិតផ្ញើពីមន្ទីរ៤០១ នៅតំបន់៣២ ផ្ញើជូនអង្គការក្នុងនោះមានរាយឈ្មោះអ្នកទោសធ្ងន់ចំនួនដប់បួននាក់ ព្រមទាំងអ្នកទោសស្រាលសាមសិបប្រាំនាក់ ដែលត្រូវយកមក «អប់រំកសាងឡើងវិញ» ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាលេខ១០៦៦-៦៨ ដែលនិយាយពីការបញ្ជូនអ្នកទោសពីកងពលលេខ៥០២ ។ ឯកសារលេខ១១២០ និយាយពីការបញ្ជូនជនសង្ស័យបីនាក់មកពីកំពង់ធំនិងឯកសារលេខ N០១៨៨០ និយាយពីការសួរចម្លើយដំបូងនៅតំបន់២១ ។ ឯកសារCMR87.37 នួន និង CMR166.13 យស់ ធឿន មាននិយាយអំពីទិន្នន័យដែលមន្ទីរសន្តិសុខកងពលលេខ៣១០ បញ្ជូនមកមន្ទីរស-២១ ។ អ្នកទាំងពីរ

ធ្វើការនៅកងពលលេខ៣១០ ។ CMR80.30 មាស អែម និងCMR4.25 ប៊ុយ បឿន រៀបរាប់ពីការងាររបស់សន្តិបាលនៅភូមិភាគពាយ័ព្យ ។ ពត៌មានបន្ថែមពីលើនេះទៀត សូមមើលឯកសារតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា លេខL០០០៨៥ ក្នុងនោះឈ្មោះ ម៉េត ដែលជាកម្មាភិបាលកងពលលេខ៨២០ បានរាយការណ៍ទៅ សុន សេន ថា ខ្លួនបានបញ្ជូន «ពួកមិនល្អជាងហាសិបនាក់មកកាន់មន្ទីរស-២១» ។ ឯកសារបានមកពីខាងក្រៅ ហើយនិយាយដល់មន្ទីរស-២១ បែបនេះកម្រមានណាស់ ។

១៥) ឯកសារលោក ស្ទីវ ហេដឌ័រ សរសេរចេញពីកាសែ្សតថតសំឡេងដែលជាកិច្ចសន្ទនាជាមួយ ដេវីដ ហក នៅឆ្នាំ១៩៨៥ ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះ ហក ដែលបានផ្តល់ឯកសារចម្លងមួយច្បាប់នេះមកឲ្យខ្ញុំ ។

១៦) CMR43.11 ។

១៧) CMR120.4 ។

១៨) CMR126.20 ។

១៩) ចង់ជ្រាបពីការធ្វើឲ្យហេវហត់អស់កម្លាំង និងការធ្វើឲ្យងាយទទួលឥទ្ធិពលក្នុងការសួរចម្លើយ សូមមើលស្នាដៃនិពន្ធរបស់ ហ្មេល មែន មានចំណងជើងថា «ការបង្កើតទម្រង់នៃអំពើឃោរឃៅ» ។ បន្ថែមលើនេះទៀត សូមមើលស្នាដៃនិពន្ធ របស់ ជីហ្គាត់ ចនសុន មានចំណងជើងថា «ការប្រើរបៀបសួរចម្លើយដែលធ្វើឲ្យងាយទទួលឥទ្ធិពលសម្រាប់ការដេញដោលសួររបស់ប៉ូលិស» ទំព័រទី២៨០-៨៨ ។

២០) CMR99.7 ។ សូមមើលបន្ថែមនូវឯកសារCMR87.11 ណុង ចាន់ ក្នុងនោះអ្នកសួរចម្លើយរៀបរាប់នូវ «អ្វីដែលសួររួចហើយ» មុនពេលចូលមកមន្ទីរស-២១ៈ «ប្រវត្តិរូប, ហេតុអ្វីបានជាអង្គការចាប់វាមក, វាខ្មាំងឬមិនខ្មាំង, តើវាមានបានរៀនសូត្រនយោបាយហើយឬនៅ? ក្រៅពីនេះសូមមើលកំណត់ហេតុមិនទាន់ចុះបញ្ជីដែលបានមកពីមន្ទីរស-២១ ឆ្នាំ១៩៧៦-១៩៧៧ ដែលនៅក្នុងឯកសារនោះ សំណួរដែលអ្នកសួរចម្លើយឲ្យឆ្លើយតាមលំដាប់លំដោយមានដូចជា «ឯងជាអ្នកក្បត់មែនឬ? ក្បត់តាំងពីពេលណាមក? ប្រវត្តិនិងអាយុ? សកម្មភាពកន្លងមក? ហេតុអ្វីបានក្បត់?» ។

២១) កិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយ គក ស្រស់ ។ កិច្ចសម្ភាសន៍របស់ លីអូណេល វ៉ៃរ៉ុន ជាមួយ ផាន ថនចាន់ ។ ពត៌មានបន្ថែមសូមមើលសៀវភៅកំណត់ហេតុ ទុយ-ប៉ុន ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៧៨ ។

២២) ស្នាដៃនិពន្ធរបស់ ម័យ មានចំណងជើងថា «ការកែទម្រង់ជីថ្មីនៅប្រទេសចិននិងវៀតណាម» ទំព័រទី២៤៦ ។ ទោះបីជាមើលទៅឃើញថា ជនជាតិខ្មែរជាច្រើនបានរៀនសូត្រពីវិធីសាស្ត្រទាំងនេះពីប្រទេសវៀតណាមនៅទសវត្សរ៍ទី៥០ និង៦០ក៏ដោយ ប៉ុន្តែមិនទាន់ឃើញមានការចងក្រងជាឯកសារចំពោះការហ្វឹកហាត់នេះឡើយ ។

២៣) CMR174.2 ថុង វ៉ាន់ សរសេរក្រោយមកទៀតថាៈ «ខ្ញុំដឹងថា អង្គការឆាប់ក្តាប់សភាពការណ៍បានហើយត្រឹមត្រូវ ។ អង្គការបក្សជាទីគោរព ខ្ញុំពិតជារស់នៅក្នុងភាពងងឹតអន្ធការ ហើយបាត់បង់ម្ចាស់ការអស់ហើយ» ។ ចង់ជ្រាបពីឧទាហរណ៍ជាក់ស្តែងមួយចំនួនទៀតស្តីពីវិធីសាស្ត្រក្នុងការសួរចម្លើយតាមបែប

កុម្មុយនិស្តដែលរួមទាំងសំណួរនិងចម្លើយ សូមមើលស្នាដៃនិពន្ធរបស់ ប្រែង កូវ ដែលមានចំណងជើងថា «ចាណូសកាដា» ដកស្រង់ចេញពីកាសែតសំឡេង ។

២៤) CMR138.11 ឯកសារបកប្រែដោយ រីឆាត អារិន ។ ខ្ញុំបានយកឯកសារខ្មែរមកប្រើសម្រាប់ផ្ទៀងផ្ទាត់ហើយធ្វើការផ្លាស់ប្តូរតែបន្តិចបន្តួចប៉ុណ្ណោះ ។

២៥) CMR118.20 ឯកសារបកប្រែដោយ រីឆាត អារិន ។ បន្ថែមពីលើនេះទៀត សូមមើលឯកសារលេខN០ ១៨៨០ តម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ឯកសារនេះបញ្ជាក់ថា អ្នកទោសរូបនេះត្រូវបានសួរចម្លើយពីរដងរួចមកហើយដោយ ឆោម សារ៉ាត នៅតំបន់២១ នាថ្ងៃទី៤-៥ ខែមិថុនា ឆ្នាំ១៩៧៦ ។ ឯកសារនេះពាក់ព័ន្ធអ្នកធ្វើការមួយចំនួនមកពីតំបន់ជាមួយគ្នានេះ រួមទាំង កែវ មាស, ណៃ សារ៉ាន់, ឈូក, កុយ ធួន និង ទីវ អុល ។ ឯកសារCMR67.13 (លឿង សុខ) បង្ហាញថា មនុស្ស៩៦នាក់ក្នុងចំណោម១៧០នាក់ដែលដាក់ថាជា «ខ្សែក្បត់» ត្រូវបានចាប់ខ្លួនរួចហើយ ។

២៦) សៀវភៅកំណត់ហេតុរបស់ ទុយ-ប៉ុន ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៧ ។ លទ្ធិដូចគ្នានេះឃើញមាននៅក្នុងសៀវភៅមួយដែលមិនមានចុះហត្ថលេខាឡើយ ដែលនៅសល់តាំងពីពេលនោះមក ដែលដាក់ថា «លទ្ធិម៉ាក្ស-លេនីន» ទំព័រ៧៣ ។

២៧) CMR99.7 ។ CMR99.14 «ផែនការថ្មី» ដែលប្រហែលជាសរសេរតាំងពីឆ្នាំ១៩៧៧ ។ ឯកសារនេះសរសេរថា «វាយសម្រុកបម្រើចលនាមហាជន និងមហាលោតផ្លោះ មហាអស្ចារ្យ» ។ ឯកសារនេះហាក់ដូចជាធ្វើឲ្យនឹកឃើញដល់ឯកសារលេខCMR96.4 ដែលសរសេរថាៈ «កសាងនិងពង្រីកបក្សតាមទ្រឹស្តីម៉ាក្ស-លេនីន» ដែលគ្មានចុះថ្ងៃខែច្បាស់លាស់ ប៉ុន្តែសរសេរនៅមុនឆ្នាំ១៩៧៥ ។ «ច្បាប់» ទាំងបួននៃបដិច្ចសមុប្បាទ ដែលពិភាក្សានៅក្នុងឯកសារលេខCMR96.4 គឺថាអ្វីៗសុទ្ធតែទាក់ទងគ្នា, អ្វីៗសុទ្ធតែផ្លាស់ប្តូរ, អ្វីៗសុទ្ធតែប្រែប្រួល, អ្វីៗសុទ្ធតែទំនាស់ ។ មុត សុភា បានកត់សម្គាល់ (ការទាក់ទងផ្ទាល់ខ្លួន) ថា «ច្បាប់» ពីរបួនដូចគ្នាទៅនឹងទ្រឹស្តីរបស់ព្រះពុទ្ធ ហើយប្រើពាក្យទស្សនវិជ្ជារបស់ព្រះពុទ្ធទៀតផង ។

២៨) CMR141.20 ។

២៩) កិច្ចសម្ភាសន៍របស់លោក ស៊ីវ ហេងឌ័រ ដែលមិនទាន់បោះផ្សាយដែលនិយាយយោងដល់អ្នកនិពន្ធ ប៊ីយ៉ូរ មានចំណងជើងថា «ភ្នែកម្នាស់» ទំព័រទី១៦០ ។

៣០) កំណត់ហេតុរំពុករបស់ សុន សេន ជាឯកសារមិនទាន់ចុះបញ្ជី តម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ សូមមើលសៀវភៅកំណត់ហេតុ ទុយ-ប៉ុន ដែលចុះថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៨ៈ «ប្រសិនបើចម្លើយរបស់អ្នកទោសណាម្នាក់ពាក់ព័ន្ធមនុស្សសំខាន់ ត្រូវរៀបចំសង្ខេបនិងដាក់ជូន [អ្នកគ្រប់គ្រង] សុំមតិ» ។ គ្មានអត្ថបទសង្ខេបប្រភេទនេះនៅសេសសល់ឡើយ ។ មើលសៀវភៅកំណត់ហេតុ ទុយ-ប៉ុន ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៧៧ៈ «ប្រសិនបើយើងឲ្យតម្លៃខ្មាំងខ្ពស់ពេកនាំឲ្យយើងទុទិដ្ឋិនិយម ។ យើងនឹងមើលឃើញថា បក្សខ្មោចងងឹត កងទ័ពខ្មោចងងឹត ប្រជាជនខ្មោចងងឹត ។ ប៉ុន្តែប្រសិនបើយើងឲ្យតម្លៃខ្មាំងទាបពេក យើងនឹងបាត់បង់ការប្រុងប្រយ័ត្នបដិវត្ត ពេលនោះខ្មាំងនឹងបំផ្លាញយើងមិនខាន» ។

៣១) គ្របមុខនៃសៀវភៅកំណត់ហេតុកម្មាភិបាលដែលមិនទាន់ចុះបញ្ជីតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ទំព័រខាងដើមមួយចំនួនរហែកអស់ហើយ ។ សូមអានបន្ថែមនូវឯកសារលេខ១១២៨ តម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាៈ កំណត់ហេតុប្រជុំយុវជនកុម្មុយនិស្តនៅក្នុងគុកៈ «អ្នកយាមគុកខ្ជិលខ្ជិលច្រអូស លំបាក ហើយខ្លាចសប្តងៗ» ។

៣២) កិច្ចសម្ភាសន៍របស់ ឌូក្លាស នីវិន ជាមួយ គក ស្រស់ ។

៣៣) កិច្ចសម្ភាសន៍របស់លោក ស្ទីវ ហេដឌ័រ ទំព័រទី៥៩ ។ បន្ថែមពីលើ សូមមើលស្នាដៃនិពន្ធរបស់ រីតធ័រ ស្ទុន មានចំណងជើងថា «រដ្ឋប្រឆាំងនឹងខ្លួនឯង» ដែលនិយាយដល់ «ភាពជាក់ស្តែងនៃប្រព័ន្ធរបស់ "សូវៀត" ដែលមិនអាចទាយទុកមុនបាន មិនអាចយល់បាន និងប្រកបដោយគ្រោះថ្នាក់» ទំព័រទី៩៥ ។

៣៤) សូមមើល CMR88.17 ងិន ឡឹយ, CMR104.17 អ៊ូ យ៉ាន, CMR154.31 សៅ សាយ, និង CMR159.5 សឿម ពៅ ។ ពាក្យថា «ចោល» ជាមួយពាក្យ «កម្ទេច» គឺជាពាក្យប្រើជំនួសឲ្យពាក្យសម្លាប់ចោល ដែលធ្វើឡើងនៅមន្ទីរស-២១ ។

៣៥) សូមមើលឯកសារមួយចំនួនដូចជា CMR62.1 លាង ចាន់ហេន (ទំព័រទី៣២៨), CMR64.7 លី រ៉ាយ (ទំព័រទី៣៦៦) និង CMR65.7 ឡាម សារិទ្ធ (ទំព័រទី៣០៤) ។

៣៦) សូមមើលCMR137.9 ស ង៉ុន និង CMR140.11 ស ផុន ឯកសារទាំងពីរនេះសរសេរតាំងពីខែ តុលា ឆ្នាំ១៩៧៥មកម្ល៉េះ ។

៣៧) សៀវភៅកំណត់ហេតុ ទុយ-ប៊ុន ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៧៨ ។ ចម្លើយសារភាពតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាប្រហែលស្មើនឹងពាក់កណ្តាលនៃចម្លើយសារភាពដែលផ្ញើទៅឲ្យ «បងៗថ្នាក់លើ» ហើយប្រហែលជាចាត់ចែងដោយ សុន សេន ផ្ទាល់ ។ នៅពេលដែលអាជ្ញាធរកម្ពុជាផ្ទេរឯកសារទាំងអស់នេះមកមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងឆ្នាំ១៩៩៧ ឯកសារទាំងនេះនៅលាយឡំជាមួយឯកសារសម័យកម្ពុជាប្រជាធិបតេយ្យទាក់ទងកិច្ចការការពារ ពោលគឺទាក់ទងនឹងឯកសារដែល សុន សេន ទទួលខុសត្រូវ ។

៣៨) បើចង់ធ្វើការប្រៀបធៀបជាមួយសូវៀត សូមមើលស្នាដៃនិពន្ធរបស់ ខន់ ខេស ដែលមានចំណងជើងថា «មហាភេរវកម្ម» និងស្នាដៃនិពន្ធរបស់ ខ្វូនី យុគ ដែលមានចំណងជើងថា «គោលបំណងនៃមហាភេរវកម្ម» ។

៣៩) ឯកសាររបស់ក្រុមសួរចម្លើយទី៥ មិនទាន់ចុះបញ្ជីតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៦ ។ សូមមើល CMR151.35 សុខ សារិត ដែលមានចំណារដាក់ថា «សំណួរដែលត្រូវសួរ» ។

៤០) វាហាក់ដូចជាថា ទម្រង់ទាំងនេះនៅដល់សព្វថ្ងៃដោយគ្មានបំណងទេ ហើយទម្រង់ប្រហាក់ប្រហែលគ្នានេះដែលត្រូវបានបំផ្លាញរៀងរាល់ថ្ងៃ បានបង្ហាញប្រាប់អ្នកទោសរាប់រយនាក់ផ្សេងទៀតឲ្យដឹងពីកិច្ចការរបស់អ្នកសួរចម្លើយ ។

៤១) ចង់ជ្រាបពីរបៀបសរសេរនេះសូមមើលស្នាដៃនិពន្ធរបស់ រ៉ូស៊ី ដែលមានចំណងជើងថា "បក្សកុម្មុយនិស្តសព្វថ្ងៃ" និងទង់បដិវត្ត លេខពិសេសចេញផ្សាយខែធ្នូ ឆ្នាំ១៩៧៥-ខែមករា ឆ្នាំ១៩៧៦ ទំព័រទី៤០-៤១ ។ បឹកឃ្វ័រ មានប្រសាសន៍ថា "ជីវប្រវត្តិទិតៀន-ស្វ័យទិតៀន...វាបំបាត់ចោលពេលវេលា ក្នុងខណៈពេលដែលអ្វីៗគ្រប់យ៉ាងនៅក្នុងអតីតកាលត្រូវបានយកមកបកស្រាយសាជាថ្មីតាមភាពចាំបាច់ដែលកើតមានចំពោះមុខ" (ភ្នែកម្នាស់) ទំព័រទី១១៤ ។

៤២) ស្នាដៃនិពន្ធរបស់ ដេវីដ អាប់ធ័រ និង ជូនី សៃ មានចំណងជើងថា "ការនិយាយស្តីបដិវត្ត" ទំព័រទី២៦៤ ។ កម្ពុជាប្រជាធិបតេយ្យមិនយកគំរូផ្សព្វផ្សាយប្រវត្តិរូបវីរជនបដិវត្តដូចជាចិននិងសូវៀតទេ កុំថាឡើយទៅដល់ផ្សព្វផ្សាយប្រវត្តិរូបរបស់យុវជន យុវនារី នៅក្នុងជួរមជ្ឈិមបក្សនោះ ។ នៅមន្ទីរស-២១ រឿងរ៉ាវជីវិតរបស់អ្នកទោសនិងខ្លួនប្រាណត្រូវបានតាមឃ្លាំមើលមិនដាច់ ព្រមទាំងចងក្រងជាឯកសារនិងពិនិត្យសាចុះសាឡើងទៀតផង ។

៤៣) ឯកសារលេខ១១២៩តម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា មានចងក្រងឯកសារវគ្គប្រជុំស្វ័យទិតៀននៃក្រុមយុវជនកុម្មុយនិស្តធ្វើការនៅមន្ទីរស-២១ ធ្វើឡើងនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៧ ។ នៅពេលប្រជុំ អ្នកសួរចម្លើយមួយចំនួនបានធ្វើការវាយតម្លៃទៅលើ "ចំណុចខ្លាំង" "ចំណុចខ្សោយ" រៀងៗខ្លួន ទៅលើសំណេរដែលខ្លួនបានសរសេរ ។ នៅពេលសំណេរវាយតម្លៃត្រូវបានហុចតៗគ្នាឲ្យក្រុមទាំងមូលមើល ប្រហែលជាម្នាក់ៗអាចអាននូវអ្វីដែលអ្នកមុនៗសរសេរ ។ ដោយដឹង "ចំណុចខ្សោយ" របស់អ្នកធ្វើការជាមួយ ហើយអ្នកដែលដឹងនោះនឹងទុកលើកយកទៅចោទប្រកាន់ពីកំហុសដែលខ្លួនមើលឃើញនៅក្នុងកិច្ចប្រជុំលើកក្រោយ ។ កំហុសមិនដូចជាចំណុចខ្លាំងទេ ពោលគឺត្រូវបានចាប់គិតនឹងកើនឡើងជាបន្តបន្ទាប់ ។ ដូច្នេះ ក្នុងការទិតៀនគេត្រូវអានយ៉ាងប្រុងប្រយ័ត្ន ក្រែងលោធ្វើឲ្យចំណុចខ្វះខាតមានលក្ខណៈស្រាលពេក និងធ្ងន់ធ្ងរពេក ។

៤៤) អាប់ធ័រ និង សៃ មានចំណងជើងថា "សេចក្តីថ្លែងការណ៍បដិវត្ត" ទំព័រទី២៩៣ ។ ទម្រង់ការប្រហាក់ប្រហែលគ្នានេះ ជាការពិតណាស់គឺត្រូវបានសង្កមសម្ងាត់ជាច្រើនយកមកប្រើប្រាស់ ។

៤៥) កិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយ គក ស្រស់ និង ញ៉ែម អេន ។

៤៦) ចង់ជ្រាបពីខេត្តរតនគិរី សូមមើលស្នាដៃនិពន្ធរបស់លោក ហង់រី ឡូកា ដែលមានចំណងជើងថា "ប្រព័ន្ធព្រហ្មទណ្ឌរបស់ខ្មែរក្រហម" ទំព័រ១៤៨ ។ ទង់បដិវត្តលេខពិសេសចេញផ្សាយខែធ្នូ ឆ្នាំ១៩៧៥-ខែមករា ១៩៧៦ ទំព័រទី៨, ទង់បដិវត្តចេញផ្សាយខែមីនា ឆ្នាំ១៩៧៨ ទំព័រ៣៧-៥៣ ដែលបកប្រែនៅក្នុងស្នាដៃនិពន្ធរបស់ ជែកសុន ដែលមានចំណងជើងថា "កម្ពុជា ឆ្នាំ១៩៧៥-១៩៧៨ ទំព័រទី២៩៦": "ពិនិត្យប្រវត្តិរូបឲ្យបានល្អិតល្អន់" ។ ចំពោះសេចក្តីថ្លែងការណ៍របស់ ប៉ុល ពត សូមមើលស្នាដៃនិពន្ធរបស់លោក ឆេនដល័រ, ឃៀរនិន និង ប៊ូ មានចំណងជើងថា "ប៉ុល ពត រៀបចំផែនការសម្រាប់អនាគត" ទំព័រទី២០៣ ។ ចង់ជ្រាបពីសារសំខាន់នៃប្រវត្តិរូបក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ សូមមើលស្នាដៃនិពន្ធរបស់ សូម៉េត ម៉ៃ មានចំណងជើងថា "សាក្សីកម្ពុជា" ទំព័រទី១៩៥-៩៧ ។

៤៧) CMR13.28 ឯកសារបកប្រែដោយលោក ស៊ីវ ហេងឌ័រ ។

៤៨) សូមមើល«ប្រវត្តិរូបរបស់ ជា កាក់» ដែលមានចំណាររបស់ ម៉ម ណៃ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៧៧ (ឯកសារមិនទាន់ចុះបញ្ជីតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា) ។ នៅក្នុងខ្សែរឿងនេះ ជា កាក់ និយាយពីផ្ទះសម្បែង និងដីធ្លីរបស់ម្ដាយខ្លួន រៀបរាប់តាំងពីចំនួនបសុសត្វដែលចិញ្ចឹមបាននិងដំបូលផ្ទះ (ក្បឿងប្ញស្សី) ។ ទោះបីជា ប៉ុល ពត បានប្រកាសក្នុងឆ្នាំ១៩៧៧ថា ប្រជាជនភាគច្រើនជាកសិករក្រីក្រ ក៏ប៉ុន្តែតាមពិតចំនួន «កសិករថ្នាក់កណ្ដាល» ប្រហែលមានច្រើនជាង បើយោងតាម ដេល វីត ដែលនិពន្ធសៀវភៅមួយមានចំណងជើងថា «កសិករកម្ពុជា» ទំព័រទី៤៩០ ។ បន្ថែមពីលើនេះទៀត សូមមើលស្នាដៃនិពន្ធរបស់ វីល ម៉ូត មានចំណងជើងថា «កំហុសនៃការវិភាគ» ។ វណ្ណៈក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានរាយឈ្មោះហើយស្រេចដោយមានការបរិយាយផងនៅក្នុងស្នាដៃនិពន្ធរបស់ ជែកសុន ដែលមានចំណងជើងថា «កម្ពុជាឆ្នាំ១៩៧៥-១៩៧៨» ទំព័រទី៩៩-១០០ ដែលដកស្រង់តារាងមួយផ្នែកពីសៀវភៅរបស់ សាំម័រ មានចំណងជើងថា «បក្សកុម្មុយនិស្តកម្ពុជាៈ ទំពស្រួចសម្ងាត់» ទំព័រទី១៥ ។

៤៩) CMR129.3 សារី ឈាង ។ ប៉ុន្តែ ឈាង សារភាពថា ខ្លួនមានឪពុកម្ដាយជាអ្នកមាន ហើយព្រមទាំងបានរៀបរាប់ចំនួនគោ ក្របី និងដីដែលឪពុកម្ដាយគាត់មានទាំងប៉ុន្មាន ។

៥០) ចំពោះការពិភាក្សាអំពីប្រភេទវណ្ណៈដែលអ្នកស្រុកអ្នកភូមិប្រើខ្លួនឯងផ្ទាល់ សូមមើលស្នាដៃនិពន្ធរបស់ ម៉េ អេប៊ីហារ៉ា មានចំណងជើងថា «បដិវត្តនិងការរៀបចំវប្បធម៌ស្រុកភូមិកម្ពុជាសាជាថ្មី» និងស្នាដៃនិពន្ធរួមគ្នារបស់ អាប៊ីន និង ហន្ទូដ ដែលមានចំណងជើងថា «ការឈឺចាប់របស់ជនជាតិខ្មែរ» ទំព័រទី២០ ។ អេប៊ីហារ៉ា (ការទាក់ទងផ្ទាល់ខ្លួន) មានប្រសាសន៍ថា នៅតាមភូមិឃុំ គ្មានការទាក់ទងគ្នារវាងទ្រព្យសម្បត្តិ និងអំណាចឡើយ ។ មិនតែប៉ុណ្ណោះ សូមមើលស្នាដៃនិពន្ធរបស់ ហ៊ីនតុន ដែលមានចំណងជើងថា «ហេតុអ្វីបានជាអ្នកឯងសម្លាប់» ទំព័រទី៩៩-១០០ ។

៥១) សូមមើល «សេចក្ដីណែនាំខ្លីស្ដីពីការប្រើលក្ខន្តិកៈបក្ស» នៅក្នុងសៀវភៅនិពន្ធដោយ ខានី ដែលមានចំណងជើងថា «អំណាចបក្សកុម្មុយនិស្ត» ទំព័រទី៥៦ ។ បន្ថែមលើនេះទៀត សូមមើលឯកសារលេខCMR21.25 ឆាយ គីមហ៊័រ ដែលបានសារភាពថា នៅពេល សុន សេន ជ្រើសរើសគាត់ឲ្យចូល ស.អ៊ី.អា នៅឆ្នាំ១៩៦២ ទាំងលក្ខន្តិកៈស.អ៊ី.អា និងលក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជាត្រូវបានលើកយកមកពិភាក្សានៅក្នុងវគ្គសិក្សារៀនសូត្រ ។ CMR26.3 ឌិម សារឿន រំឭកថា «គោរពទង់ជាតិស.អ៊ី.អា តែឥឡូវខ្ញុំភ្លេចអស់ហើយមិនដឹងជាធ្វើអ្វីខ្លះទេ», CMR87.8 នុត កាប និយាយប្រាប់ពីពិធីចូលស.អ៊ី.អា នៅស្ថានទូតអាមេរិកប្រចាំនៅទីក្រុងភ្នំពេញ ហើយឯកសារCMR136.14 សុន ហឿន និយាយថា បានគោរពទង់ជាតិ «ដែលមានរូបផ្កាយ» ។ នៅដើមឆ្នាំ១៩៧៦ បញ្ជីសំណួរបោះពុម្ពដោយម៉ាស៊ីនរ៉ូណេអូដែលរៀបចំឡើងនៅមន្ទីរស-២១ ប្រាប់គ្រួសៗអំពីប្រវត្តិការងាររបស់អ្នកទោសមួយចំនួន អំពីប្រាក់ខែនិងអ្នកធានាឲ្យចូលបម្រើស.អ៊ី.អា ។ សូមមើល CMR2.16 ជូ បាយ, CMR173.5 តាំង ដេង និង CMR184.11 វ៉ា ហេង ។

៥២) ឯកសារលេខ៦០-៨៤តម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា បានមកពីមន្ទីរសន្តិសុខ

ភូមិភាគឧត្តរចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៧៦ ។ ឈ្មោះរបស់អាមេរិកាំងប្រែពីភាសាខ្មែរមកវិញដែលសរសេរថា "ហ្សំប៉ូ ឌូវិន" ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោក ឆាំង យុ ដែលបានទាញអារម្មណ៍ខ្ញុំឲ្យផ្ដោតលើឯកសារនេះ ។

៥៣) ចំពោះឯកសារយោងទាក់ទងនឹង អៀង ធីរិទ្ធ សូមមើលCMR64.12 ឡុក ឆុត ។ CMR173.13 លាង គីនី ដែលបានសិក្សានៅប្រទេសអាឡឺម៉ង់ខាងលិចអះអាងថា ខ្លួនត្រូវបានជនជាតិអាមេរិកាំងម្នាក់ឈ្មោះ វីកឃ័រី រើសឲ្យធ្វើជាតិញសម្ងាត់នៅឆ្នាំ១៩៦៧ នៅកែប និងCMR78.12 ម៉ែន ទល់ ដែលជា "ខ្មែរហាណូយ" និយាយថា ខ្លួនត្រូវបាននាំចូលសេ.អ៊ី.អានៅទីក្រុងហាណូយក្នុងឆ្នាំ១៩៥៦ តាមរយៈ "ភ្ញៀវទេសចរ" ជនជាតិអាមេរិកាំងម្នាក់ ។ បន្ថែមលើនេះទៀតសូមមើល CMR131.3 សុខ ខ្នុល ដែលនិយាយថា ខ្លួនត្រូវបានឈ្មោះ ចន សុន រើសចូលសេ.អ៊ី.អា ។ សុខ ខ្នុល នៅបានដកស្រង់សម្ដីរបស់អ្នកធ្វើការជាមួយម្នាក់ដែលមិនដែលបានឃើញមុខប្រពន្ធមួយឆ្នាំទៅហើយថា "មូលហេតុនេះហើយ បានជាយើងរកផ្លូវទៅកាន់សុភមង្គល...ពោលគឺសេ.អ៊ី.អានេះឯង" ។ ចំណែកឯកសារ CMS178.20 ទ្រឿង ស៊ីន និយាយថា "សេ.អ៊ី.អា មានមុខមាត់ និងជីវិតហ៊ឺហា" ។ CMR166.28 អ៊ីស៊ូប គន្ធី អ្នកការទូតកម្ពុជាប្រជា-ធិបតេយ្យនិយាយថា មុនដំបូងបង្អស់អ្នកដែលរើសគាត់ឲ្យចូលសេ.អ៊ី.អា គឺឈ្មោះ អាន់ដឺសុន ហើយម្ដងទៀត ក្នុងខណៈធ្វើទូតនៅស្ដុកខូម នៅឆ្នាំ១៩៧១ដោយឈ្មោះ ចន សុន ។ គន្ធី លើកឡើងពី "ផែនការ" របស់សូវៀតក្នុងការដឹករថក្រោះមកកាន់ភ្នំពេញមកឈ្លានពានកម្ពុជា ។

៥៤) CMR161.4 យិន រ៉ុន និងCMR184.11 វ៉ា ហេង ។ ពត៌មានបន្ថែមសូមមើលCMR127.5 ប៉ែន សុភាព ដែលជាកូនស្រីរបស់ វ៉ន វេត ។

៥៥) កិច្ចសន្ទនារវាងលោក ស៊ីវ ហេដឌ័រ ជាមួយ ដេវីដ ហក ។ ឯកសារយោងទាក់ទងនឹងប្រទេសចិន សូមមើលស្នាដៃនិពន្ធរួមគ្នារបស់ ឌីត ម័រ និង រូហ្វ៊ី ដែលមានចំណងជើងថា "ក្រមសីលធម៌ និងវេហាសាស្ត្រ" ទំព័រទី៤៤ ។ CMR188.36 ឯកសាររដ្ឋបាលមន្ទីរស-២១ មានតារាងសមាសភាពតាមលំដាប់ថ្នាក់របស់ សេ.អ៊ី.អា ក្រោមការដឹកនាំរបស់ លន់ ណុល ។ ឌុច នឹកមមៃទៅលើ"សេ.អ៊ី.អា" ហើយការណ៍នេះធ្វើឲ្យ ឌុច ឲ្យគេបកប្រែបញ្ជីភ្នាក់ងារសេ.អ៊ី.អាទូទាំងពិភពលោកដែលបោះពុម្ពផ្សាយនៅទីក្រុងប៉ែរឡាំងខាងកើតនៅទសវត្សរ៍ឆ្នាំ១៩៦០ ។ ឯកសារទាំងពីរនេះជាឯកសារមិនទាន់ចុះបញ្ជីដែលតម្កល់ទុកនៅមន្ទីរស-២១ ។ ពត៌មានបន្ថែមសូមមើលសៀវភៅកំណត់ហេតុ ទុយ-ប៊ុន ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៧៨ ដែលសរសេរថា "សេ.អ៊ី.អា" នៅក្នុងប្រទេសកម្ពុជាត្រូវបានបែងចែកជាភ្នាក់ងារក្បត់ៗមួយចំនួនបញ្ជូនទៅហាណូយ នៅសល់ប៉ុន្មានទុកបង្កប់នៅក្នុងប្រទេស ។

៥៦) សៀវភៅនិពន្ធដោយ វ៉ៃ ដែលមានចំណងជើងថា "នយោបាយប្រឡូកប្រឡល់" ។ ឧទាហរណ៍ជាក់ស្ដែង និងការពិភាក្សាដ៏គួរឲ្យចាប់អារម្មណ៍ សូមមើលសៀវភៅនិពន្ធដោយ លូ ស៊ីយ៉ន ដែលមានចំណងជើងថា "ជំហានឆ្ពោះទៅស្វែងយល់អំពើឃោរឃៅរបស់ប្រជាជន" ទំព័រទី៥៣-៦២ ។

៥៧) "ពាក់ព័ន្ធជាមួយភ្នាក់ងារស៊ើបការសម្ងាត់" គឺជាពាក្យដ៏ស៊ីជម្រៅនៅក្នុងប្រទេសសូវៀតដែល

គ្រួសារនេះ ប្រើនៅក្នុង «សុន្ទរកថាសម្ងាត់របស់គាត់» នៅក្នុងឆ្នាំ១៩៥៦ ក្នុងពេលដែលគាត់ចោទប្រកាន់ ឡាវរ៉េនទ្រី ដែលជាចៅក្រមកាត់ទោសចង្កក ស្តាលីន នៅទសវត្សរ៍ឆ្នាំ១៩៣០ថា បានធ្វើការឲ្យភ្នាក់ងារសម្ងាត់បរទេស ។ សូមមើលស្នាដៃនិពន្ធរបស់ អាលី មានចំណងជើងថា «កេរដំណែលរបស់ ស្តាលីន» ទំព័រទី ២៥៨ ។ បន្ថែមលើនេះទៀតសូមមើលCMR174.15 គួច គៀន កម្មាភិបាលជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ដែលអះអាងថា ការសម្លាប់រង្គាលមនុស្សប្រឆាំងនឹងលទ្ធិកុម្មុយនិស្តនៅក្នុងប្រទេសឥណ្ឌូនេស៊ីឆ្នាំ១៩៦៥ និង១៩៦៦ ដែលគាត់ហៅថាជារដ្ឋប្រហារនោះ គឺជាស្នាដៃរបស់ភ្នាក់ងារសេ.អ៊ី.អា ដែល«បង្កប់ស៊ីរូងផ្ទៃក្នុង» បក្សកុម្មុយនិស្តឥណ្ឌូនេស៊ី ។

៥៨) CMR99.19 មានអត្ថបទសុន្ទរកថា ។

៥៩) ស្នាដៃនិពន្ធរបស់ ថាយ័រ មានចំណងជើងថា «ថ្ងៃជម្រះបញ្ជី» ។ នៅពេលដែលអ្នកធ្វើការជាមួយ ប៉ុល ពត ទាត់ ប៉ុល ពត ចោលក្នុងឆ្នាំ១៩៩៧នោះ អ្នកដែលមកជំនួស ប៉ុល ពត គឺ តាម៉ុក (ប្រហែលជាបងលេខបី) បានហៅអតីតមេរបស់ខ្លួនថាជា «ភ្នាក់ងារវៀតណាម» ។ គួរឲ្យចាប់អារម្មណ៍កាន់តែខ្លាំងដែរនោះគឺថា ការដែលអ្នកនៅរស់រានមានជីវិតចាកផុតពីរបប ប៉ុល ពត បាននិយាយតៗគ្នាថា ប៉ុល ពត ធ្វើការឲ្យយួន (ចាត់ឌី លេចជ័រវ៉ូដ-ការទាក់ទងផ្ទាល់ខ្លួន) ។

៦០) CMR141.3 សំ ហ៊ាន លើកឡើងពីកំហុសប្រាំមួយលើកដែលខ្លួនបានធ្វើ ។ កំហុសនេះនាំឲ្យគេចាប់ខ្លួនតែម្តង ។ ពត៌មានប្រហាក់ប្រហែលគ្នានេះដែរ សូមមើលCMR160.15 យ៉េន គុន ដែលនិយាយថា «ចំណុចខ្សោយ» របស់ខ្លួនគឺខ្វះសីលធម៌ (រួមភេទ) ។ សូមមើលសៀវភៅនិពន្ធដោយលោក ហង់រី ឡូកា ដែលមានចំណងជើងថា «សៀវភៅតូចពណ៌ក្រហម» «សមមិត្តដែលមានចំណុចខ្សោយច្រើន មានន័យថាខ្លាំង» ទំព័រទី១៨៥ ។

៦១) CMR166.13 យស់ ធឿន ។ CMR36.16 ហ៊ុយ សាវ៉ន និង CMR88.3 នៅ កន្ធា អ្នកសួរចម្លើយដែលអះអាងថា ខ្លួនធ្លាប់គេប្រើឲ្យអូសនង្គ័ល «ដូចជាអ្នកទោសដែរ» ដែលមានយោងនៅក្នុងសៀវភៅនិពន្ធដោយ វីកឃ័រី មានចំណងជើងថា «កម្ពុជាៈ១៩៧៥-១៩៨២» ។ ចង់ជ្រាបពី «មនុស្សជាប់គុកដែលមានសិទ្ធិចេញទៅក្រៅបាន» សូមមើលសៀវភៅនិពន្ធដោយ ឡេវី ដែលមានចំណងជើងថា «អ្នកលិចលង់និងអ្នកជួយសង្គ្រោះ» ទំព័រទី២២-៥១ និងសៀវភៅរបស់ សហ្វស្គី មានចំណងជើងថា «ប្រព័ន្ធភេរវកម្ម» ទំព័រទី១៣០ ។ ចង់ជ្រាបពីភាពមិនស្រួលក្នុងចិត្តដែលអ្នកធ្វើការបានអះអាងសូមមើល CMR20.19 ជន ឆាយ, CMR22.23 ចៅ គត់ និង CMR46.6 ឃ្លាំង ហ៊ួ ។

៦២) ចង់ជ្រាបពីសាសនា សូមមើលCMR47.17 គម រ៉ុំ, CMR160.25 យូ ប៊ុន និងCMR173.16 តាន់ ឡឿន ។ ចង់ជ្រាបពីសាសនាសូមមើល «ប្រវត្តិរូបរបស់ ជា កាក់ ដែលជាឯកសារមិនទាន់ចុះបញ្ជីតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ឆ្មាំគុកនៅមន្ទីរស-២១ រូបនេះបានធ្វើការកត់សម្គាល់ថា ខ្លួនបានចូលបដិវត្តន៍ ម្យ៉ាង «ដោយសារខ្ញុំចង់មានឈ្មោះ ហើយចង់ឲ្យគេសរសើរ» ។

៦៣) CMR87.2 និង CMR58.4 ។

៦៤) CMR107.16 និង CMR56.28 ឃុត បឿន ។ បន្ថែមលើនេះទៀត សូមមើល CMR144.1 សុខ ហាក់៖ «ខ្ញុំបំផុសឲ្យប្រជាជនពុករលួយ ផឹកស៊ីចាក់ប្រាស តាមញីស្រី ធ្វើអ្វីៗដែលសប្បាយ និង CMR169.13 តុង ឈុន៖ «រស់នៅជាមួយបដិវត្តន៍មិនបានទេ ។ បដិវត្តន៍មិនសប្បាយសោះ» ។ CMR105.28 អ៊ូ ស៊ូណេង កត់សម្គាល់ថា «យើងមិនដឹងថា បដិវត្តន៍មានអ្វីកើតឡើងខ្លះទេ ហើយមិនដឹងជាដើរផ្លូវណាទេ» ។ ហាស សារ៉ន (CMR33.5) សម្តែងការសោកស្តាយថា «ការទាក់ទងរបស់ខ្ញុំសុទ្ធតែផ្ទាល់ខ្លួនមិនមានរបៀបរៀបរយ ហើយខ្វះការអនុញ្ញាតពីបក្ស» ។ ដោយអនុវត្តគោលនយោបាយដែលសន្យាថានឹងឡើងឋានៈឆាប់រហ័ស មានរបស់របរប្រើប្រាស់ និងរស់នៅឲ្យកាន់តែស្អាតស្អំនោះ បក្សកុម្មុយនិស្តកម្ពុជាមិនសូវជាផ្តល់សុភមង្គលឡើយ ហើយការណ៍នេះធ្វើឲ្យបក្សបាត់បង់ប្រជាប្រិយភាព ។ ចំពោះគំនិតស្រឡាញ់ភាពស្អាតស្អំបែបកុម្មុយនិស្ត សូមមើលCMR119.23 ពូ ឡាប៊ីន បក្សជននារីដែលឆ្លើយប្រកបដោយមោទកភាពថា «ខ្ញុំធ្វើបដិវត្តន៍អស់រយៈពេលប្រាំឆ្នាំហើយ ។ ខ្ញុំបានកសាងខ្លួនដោយកាត់បន្ថយសេរីនិយម គ្រួសារនិយម បក្សពួកនិយម និងគុណសម្បត្តិនិយម» ។

៦៥) អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺថា ប្រជាជនដែលគ្មានដីធ្លីធ្វើស្រែចម្ការ មុនសម័យបដិវត្តន៍ ដូចជាអ្នកលេងល្បែង, ចោរលួចគោក្របី និងអ្នកប្រមឹក អ្នកទាំងអស់នោះជាញឹកញយត្រូវបានរើសចូលក្នុងចលនាតស៊ូវាយបារាំង (ថុង ផែល និង សុខ ភិរុណ-ការទាក់ទងផ្ទាល់ខ្លួន) ។ ទាក់ទងនឹងបញ្ហានេះ សូមមើលស្នាដៃនិពន្ធរបស់ វ៉ែស មានចំណងជើងថា «កម្ចាត់អង្គែ» ក្នុងនោះអតីតគ្រូបង្រៀនម្នាក់ដែលរស់នៅជាជនភៀសខ្លួននៅប្រទេសថៃ ត្រូវបានដកស្រង់សម្តីនិយាយថា «កម្ពុជាគ្រប់គ្រងដោយអ្នកប្រមឹក ចោរ មនុស្សឃោរឃៅ គ្មានវប្បធម៌ក្នុងខ្លួន និងអនក្ខរជនគ្មានវណ្ណៈត្រឹមត្រូវ» ។

៦៦) សូមមើលចម្លើយសារភាពរបស់ ឈិន ឈុំ បបក១៨១៨ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

៦៧) CMR19.10 ។

៦៨) CMR24.8 ។

៦៩) CMR183.18 ។

៧០) CMR88.2 ។ ក្រៅពីនេះសូមមើលCMR48.8 ខុម ខាន៖ «នៅវៀតណាម មានផ្សារ មានស្រី មានស្រា និងមានម៉ូតូជិះ ។ គ្មានអ្នកណាត្រូវគេប្រើវិលក្បួងទេ» ។ សម្តីនេះប្រហែលគេមិនកាត់ចោល ដោយសារវាផ្តល់នូវភ័ស្តុតាងបង្ហាញពីភាពលម្អៀងរបស់អ្នកដែលប្រឌិតវាឡើង ។

៧១) CMR23.13 ។

៧២) CMR55.5 ។ CMR26.32 អ៊ី ផៃ ដែលចូលបក្សតាមរយៈប្រពន្ធរបស់ សុន សេន ក៏បានបែកដាច់ពីគ្នាដែរចំពោះពាក្យថា «សម្រាក» និង «វាយសម្រុក» ។

៧៣) CMR56.24 ។

៧៤) CMR56.14 ។ ឯកសារបន្ថែមសូមមើលCMR55.5 កែវ សាន៖ «ឈិន និយាយថា មានអ្វីៗដូចសព្វថ្ងៃនេះគឺពិបាកណាស់ ។ ប្រពន្ធរបស់គាត់នៅភ្នំពេញ ហើយក្រោយមកនៅកំពង់ឆ្នាំង ។ តើមាន

សុកមន្តលអ៊ីទៅ បើមួយឆ្នាំទៅជួបប្រពន្ធគាត់ម្តងនោះ?» (ឯកសារបកប្រែដោយ ស៊ីវ ហេងឌ័រ) ។ CMR141.20 សារ៉ កាន ជនបដិវត្តជើងចាស់ដែលបានរាយការណ៍អំពីសមាជិកបក្សម្នាក់ទៀតនិយាយថា ការបំបែកប្តីប្រពន្ធមិនឲ្យរស់នៅជាមួយគ្នាគឺជារឿង «ធំណាស់» ហើយការតស៊ូប្រឆាំងនឹងនយោបាយនេះ អាចនាំដល់ «ការធ្វើបដិវត្តន៍ជាលើកទីពីរ» ។

៧៥) ស្នាដៃនិពន្ធរបស់ សុក មានចំណងជើងថា «ការគ្របសង្កត់និងការបង្ខិតប្រសប់ក្នុងការតស៊ូ» ។ ប៉ុន្តែសូមមើលពាក្យចាស់ដែលត្រូវបានដកស្រង់នៅក្នុងឯកសារCMR108.2 ប៉ិច នី នៅឆ្នាំ១៩៧៨ ដូចជា នៅមណ្ឌលគិរីថ្មីៗនេះៈ «រៀតណាមយកដីយើងអស់ហើយ ប៉ុន្តែអង្គការនិយាយថា យើងច្បាស់ជាឈ្នះ» ហើយ «ធ្វើការទាំងយប់ទាំងថ្ងៃ» «តើមានកម្លាំងឯណាមកធ្វើការ» ។

៧៦) CMR123.26 ។ ចម្លើយសារភាពនេះមានតែពីរសន្លឹកតែប៉ុណ្ណោះ ។

៧៧) CMR35.237 ។ នៅក្នុងចម្លើយសារភាពនេះឈ្មោះ ហូ ក៏បានវាយប្រហារសមូហភាវូបនីយកម្ម ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ។

៧៨) CMR84.27 ។

៧៩) CMR173.16 ។ សូមមើលCMR128.9 ក្នុងនោះមានការវាយតម្លៃដ៏មោះមុតរបស់ឈ្មោះ ស្រី ដួង ដែលនិយាយថា «បក្សដើរឆ្វេងលឿនពេក ។ ខ្ញុំលែងជឿទៀតហើយ ។ ខ្ញុំចង់ប្រយុទ្ធប្រឆាំងនឹង បក្សកុំឲ្យបក្សដើរលឿនពេក» ។

៨០) កិច្ចសម្ភាសន៍របស់ ដួក្លាស នីវិន ជាមួយ ញ៉ែម អេន ។

៨១) CMR39.25 ។ សំណេរប្រវត្តិរូបដែលរៀបចំដោយ ណុន សួន (CMR39.25) ដែលមិនិរិះគន់ ដល់បងលេខមួយ និងបងលេខពីរ គឺជាករណីលើកលែង ។

៨២) CMR123.2 ដែលត្រូវបានដកស្រង់នៅក្នុងស្នាដៃនិពន្ធរបស់លោក ស៊ីវ ហេងឌ័រ មានចំណងជើង ថា «ប៉ុល ពត និង ខៀវ សំផន» ទំព័រទី២២ ។ ភួង បន្តនិយាយអំពី «ការឈឺចាប់របស់ប្រជាជនដែលមិនអាច ទ្រាំបាន និងទុក្ខព្រួយអួលណែនក្នុងចិត្ត» ហើយហៅកម្ពុជាប្រជាធិបតេយ្យថា «គឺជារដ្ឋខ្មៅងងឹតនិងគួរឲ្យ ធុញទ្រាន់» ។

៨៣) CMR12.22 (ឯកសារបកប្រែដោយលោក ស៊ីវ ហេងឌ័រ) ។ បន្ថែមពីលើនេះទៀត សូមមើល CMR76.16 ម៉ៅ ខែមនួន កម្មាភិបាលជាន់ខ្ពស់ម្នាក់ដែលដកស្រង់សម្តីរបស់អ្នកធ្វើការជាមួយថា «អ្នកដែល ទោមនស្សទៅនឹងការរៀបចំថ្មីនេះមានរហូតដល់...ជាងពាក់កណ្តាលនៃប្រជាជនទាំងអស់ ។ នេះជាកម្លាំង មួយច្រើនគួរឲ្យខ្លាច» ។

៨៤) កិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយ វ៉ាន់ ណាត ។ កិច្ចសម្ភាសន៍របស់ ដាន ថនចាន់ ជាមួយ លីអូណែល វ៉ៃរ៉ុន ។

៨៥) កំណត់ហេតុរំពុកផ្ញើពីឈ្មោះ រឿន កងពលលេខ៨០១ មកដល់បងលេខ៨៩ (សុន សេន) ឯកសារចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៦ ។ ឯកសារមិនទាន់ចុះបញ្ជីតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារ

កម្ពុជា ។ បន្ថែមពីលើនេះទៀត សូមមើលCMR99.19 "សង្ខេបទស្សនៈរបស់អង្គការ" ដែលមិនមានចុះថ្ងៃខែ ប្រហែលជាសរសេរនៅចុងឆ្នាំ១៩៧៧ ។ នៅក្នុងឯកសារនេះ ប៉ុល ពត និយាយថា "ពួកក្បត់ [នៅតាមជនបទ] បានបំផ្លាញប្រេងឥន្ធនៈ ម៉ាស៊ីន អង្ករ ខោអាវ ដើមដូង និងដើមខ្នុរ ។ វាស្ទូងស្រូវយកគល់ឡើងលើស្លឹកចុះក្រោម" ។ នៅក្នុងវគ្គ "ផែនការចុងក្រោយ" ដែលជាស្នាដៃនិពន្ធដោយលោក ដែកសុន មានចំណងជើងថា "ប្រទេសកម្ពុជាឆ្នាំ១៩៧៥-១៩៧៨" ឌុច និយាយថា "ការលួចប្លន់ អំពើអបាយមុខ និងការនិយាយពាក្យឃោសនា ពាក្យចចាមអារ៉ាមគឺដើម្បីធ្វើឲ្យប្រជាជនមានអារម្មណ៍មិនស្រណុកក្នុងចិត្ត" ។

៨៦) CMR174.9 សៀវភៅកំណត់ហេតុ ឌុយ-ប៊ុន ដែលចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៧៨ បន្តទៀតថា "បើយើងអាចចាប់វៀតណាមដែលលាក់ខ្លួនបានទើបជាមហាជោគជ័យ ។ បើចាប់អ្នកក្បត់ដែលលាក់វៀតណាមនេះជាជ័យជម្នះតូចតាចទេ ។ ក៏ប៉ុន្តែបើយើងចាប់ជនក្បត់ឲ្យបានច្រើននាក់ដែលកំពុងតែលាក់វៀតណាមនោះគឺជាជ័យជម្នះដ៏ធំធេង" ។ សូមមើលពត៌មានបន្ថែមនៅCMR16.4 ជា ស៊ីន ដែលរាយឈ្មោះវៀតណាមលាក់ខ្លួននៅតំបន់២២ ។ តាមការប៉ាន់ស្មានប្រហែលជាមានមនុស្សប្រភេទនេះមែន ។ ការភ័យខ្លាចបែបនេះធ្វើឲ្យរបបកម្ពុជាប្រជាធិបតេយ្យនៅស្ថិតស្ថេរបានយូរ ។ នៅឆ្នាំ១៩៩២ មន្ត្រីខ្មែរមួយរូបបាននិយាយទៅកាន់លោក សីច ធីយ៉ុង ថា "វៀតណាមមានគ្រោះថ្នាក់ណាស់ នៅពេលគេមើលមិនឃើញ" ។

៨៧) ចង់ជ្រាបពីឧទាហរណ៍ផ្សេងៗទៀតរបស់អ្នកទោសដែលសារភាពថា ខ្លួនបានលាក់បិទបាំងវៀតណាម សូមមើលCMR57.28 គឹម សុខ CMR58.3 គង់ គឿ, CMR67.22 ឡេង ឆាង, CMR67.24, ឡុត សោភ័ណ, CMR166.11 យិន យំ និងCMR184.27, វ៉ែន វៀន ដែលជាមន្ត្រីពេទ្យតូចតាចម្នាក់ដែលមិនត្រឹមតែ "រៀបចំផែនការ" ធ្វើរដ្ឋប្រហារទេ តែថែមទាំងរៀបចំផែនការ "លាក់វៀតណាម លាក់ថៃ និងលាក់ថ្នាំពេទ្យ" ។ សៀវភៅកំណត់ហេតុ ឌុយ-ប៊ុន ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៧៨ ។

៨៨) CMR164.13 ។

៨៩) CMR84.8 ។ សូមមើលCMR144.3 សំ ហួយ ហៅ មាស តាល់ (ឯកសារបកប្រែដោយ ស៊ីវ ហេងឌី): "យើងត្រូវតែមានឧបាយកលសឹកកម្ទេចដូចជា បាញ់កម្មាភិបាលបដិវត្ត, លួចចោលគ្រាប់បែក, ដាក់មីន និងបាញ់កាំភ្លើងខ្លី ឬប្រើថ្នាំបំពុលគ្រប់រូបភាព ។ កម្មាភិបាលនៅគ្រប់ជាន់ថ្នាក់ទាំងអស់ដែលមិននៅខាងយើងទេ ត្រូវតែកម្ទេចចោល" ។

៩០) CMR104.23, CMR79.19, CMR107.14 ។ ពត៌មានបន្ថែមសូមមើល CMR24.5 ដុង គិន ដែលសារភាពថា បាន "ជួញក្រណាត់ និងបាញ់លេងមួយគ្រាប់" និងCMR34.18 ហ៊ុល គិមហួត ដែល "បំផុសសីលធម៌មិនល្អ និងដាំបាយហូបផ្ទាល់ខ្លួន" ។

៩១) ចម្លើយសារភាពនៅមជ្ឈមណ្ឌលឯកសារកម្ពុជាលេខ៨៤៦បបកខ មិនទាន់ផតចម្លង ។

៩២) CMR56.21 ឃឹម យូ, CMR7.14 អាន ហួត, CMR26.4 ឈួន ។

៩៣) ចម្លើយសារភាពសង្ខេបចំនួនសែសិបប្រាំពីរច្បាប់ ដែលចែកជាចម្លើយសារភាពមកពីអង្គភាព

យោធា ក្រសួងមន្ទីរ តំបន់ និងភូមិភាគមាននៅក្នុងCMR102, 103, 113 និង 114 ។ ឯកសារទាំងនេះ មួយចំនួនមានរាយឈ្មោះទាំងអស់ដែលមាននៅក្នុងចម្លើយសារភាពដែលផ្តើមកពីអគ្គភាពឬតំបន់ពាក់ព័ន្ធមុខសញ្ញា ។ សេចក្តីសង្ខេបភាគច្រើនមានរហូតដល់ជិតសែសិបសន្លឹក ។

៩៤) ចង់ជ្រាបពីការសរសេរប្រវត្តិសាស្ត្រនៅប្រទេសកម្ពុជា សូមមើលស្នាដៃនិពន្ធរបស់លោក ឆេនដល័រ មានចំណងជើងថា «ប្រឈមមុខនឹងអតីតកាលរបស់កម្ពុជា» ទំព័រទី១៨៩-២០៤ ។ ស្នាដៃនិពន្ធរបស់ ក្លូត ជែក មានចំណងជើងថា «សេចក្តីណែនាំថ្មីសម្រាប់ការសិក្សាអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា XIII (1-4) (1982) ទំព័រទី៣៩-៥៧ និងសៀវភៅនិពន្ធដោយ ម៉ៃឃើល វីកឃ័ររី មានចំណងជើងថា «ប្រទេសកម្ពុជាក្រោយសម័យអង្គរ» ។ ទាក់ទងនឹងគំរូគ្រប់គ្រងបែបសូវៀត សូមមើលសៀវភៅរបស់ ថាក់ឃ័រ មានចំណងជើងថា «ស្តាលីន បាក់ការីន និងប្រវត្តិរួមគំនិតប្រព្រឹត្តអំពើទុច្ចរិត» ។

៩៥) CMR99.14 គ្មានចុះកាលបរិច្ឆេទ ប៉ុន្តែប្រហែលពីឆ្នាំ១៩៧៧ ។

៩៦) ឧទាហរណ៍មួយចំនួនបញ្ជាក់ពីប្រវត្តិរបស់បក្ស សូមមើលសៀវភៅនិពន្ធដោយ ជែកសុន មានចំណងជើងថា «កម្ពុជាឆ្នាំ១៩៧៥-១៩៧៨» ទំព័រទី២១៥-៦៨ ។ សម្រាប់ការពិភាក្សា សូមមើលស្នាដៃនិពន្ធរបស់លោក ឆេនដល័រ មានចំណងជើងថា «ចងកំហឹង» និងសៀវភៅនិពន្ធដោយ លី ចាវជី មានចំណងជើងថា «ការបំផ្លាញគំនិតរបស់ មែនស៊ីវិក នៅក្នុងជួរបក្ស» ។ សូមមើលសៀវភៅរបស់ សៃ មានចំណងជើងថា «តើប្រវត្តិត្រឹមត្រូវរបស់បក្សបានមកពីណា?» ។ ចំណងជើងនេះធ្វើឲ្យនឹកឃើញដល់សំណេររបស់ ម៉ៅ ដែលថា «តើគំនិតត្រឹមត្រូវបានមកពីណា?» ដែលក្នុងនោះ ម៉ៅ បានធ្វើការប្រៀបធៀបគំនិត «ត្រឹមត្រូវ» ទៅនឹងគំនិតរបស់អ្នកដែលទទួលជោគជ័យក្នុងការងារ ។

៩៧) សៀវភៅរបស់ ស្តេន មានចំណងជើងថា «ការពិតដែលជានិទានកថា» ទំព័រទី២៦៣-៧៨ និយាយទាក់ទងនឹងគំនិត «វប្បធម៌បុរាណ» របស់ ហ្វ៊ើដ និងទំនាក់ទំនងទៅនឹងអ្វីដែល ស្តេន ដែលជាអ្នកចិត្តសាស្ត្រហៅថា «ការពិតដែលជានិទានកថា» ។ ចង់ជ្រាបពីការយល់ឃើញរបស់ ស្តេន សូមមើលវគ្គទីបី ។ ក្រៅពីនេះសូមមើលសៀវភៅដែលជាស្នាដៃនិពន្ធរួមរបស់ អហ្សេ និង វ៉ាគឃ័រ ដែលមានចំណងជើងថា «បង្កើតមនុស្សអាក្រក់» ជាពិសេសទំព័រទី១៥-៤៤ និង ២៨៩-៣០៤ រឿងដែលធ្វើឲ្យមួយម៉ោ «ការចងចាំឡើងវិញនូវការរំលោភផ្លូវភេទ» ។

៩៨) មានយោងនៅក្នុងសៀវភៅរបស់ គ្រូ មានចំណងជើងថា «សង្គ្រាមសតិ» ទំព័រទី២០៩ ដែលលើកយកស្នាដៃនិពន្ធចងក្រងរបស់ ហ្វ៊ើដ លេខ១២ ទំព័រទី២៧៩-៨០ ។ ឯកសារនេះអាចត្រូវបានសរសេរដោយអ្នកធ្វើការនៅមន្ទីរស-២១ ។ មានឯកសារផ្សេងទៀតដែល គ្រូ ស្រង់យកមកសរសេរថា «យើងមិនត្រូវឲ្យការបដិសេធជាលើកដំបូងដឹកមុខទេ...យើងត្រូវគ្រប់ភាពរឹងរូសដោយផ្តោតសំខាន់ទៅលើសារជាតិនៃការជឿស៊ប់របស់យើង» (ទំព័រទី116n.8) ។ បន្ថែមពីលើនេះទៀត សូមមើលសៀវភៅរបស់ ថសស៊ីក មានចំណងជើងថា «វប្បធម៌នៃអំពើគួរឲ្យព្រឺខ្លាច»: «វាក៏មានលក្ខណៈច្បាស់ដែរថា អ្នកធ្វើបាបជនរងគ្រោះត្រូវការជនរងគ្រោះដើម្បីបង្កើតការពិត ដោយយកការស្រមើស្រមៃរបស់ខ្លួនធ្វើជារបស់អ្នក

ដទៃ» សៀវភៅនិពន្ធរួមរបស់ ថាក់យ័រ និង ខូហិន មានចំណងជើងថា «ការជំនុំជម្រះរបៀបវិសុទ្ធកម្មដ៏ខ្លាំងក្លា» ចាត់ទុកការឆ្លើយសារភាពដោយបង្ខំកាលពីសម័យ ស្តាលីន កាន់កាប់អំណាចថា ជា«យានយន្តសម្រាប់សម្តែងចេញនូវប្រព័ន្ធនៃការភ័ន្តគំនិតមិនទុកចិត្តគ្នាដែលមានផ្ទៃរឿងសំខាន់មួយកំប្លែ (ការរួមគំនិតធ្វើអំពើទុច្ចរិតដ៏ធំ) និងសហគមន៍ដែលតាំងខ្លួនជាមនុស្សអាក្រក់» ។ ក្រៅពីនេះ សូមមើលសៀវភៅរបស់ហានសុន មានចំណងជើងថា «ទារុណកម្មនិងការពិតនៅប្រទេសអង់គ្លេសសតវត្សរ៍ទី១៨-១៦» ។ អ្នករិះគន់របស់ក្រុមកាតូលិកទៅលើការធ្វើទារុណកម្មដែលគ្រប់គ្រងដោយពួកប្រូតេស្តង់ ។ ហានសុន អះអាងថា អ្នកធ្វើទារុណកម្មមិនរុករកការពិតដែលលាក់កំបាំងនោះទេ តែបែរជាបង្ខំឲ្យអ្នកទោសប្រឌិតការពិតដែលខ្លួនចង់បានទៅវិញ» ។

៩៩) CMR99.7 ។ ចំណាររបស់អ្នកសួរចម្លើយនៅក្នុងចម្លើយសារភាពមួយច្បាប់ (CMR105.4 អ៊ឹឆាន) សរសេរថា «នៅពេលមានចំណុចណាដែលវាមិននិយាយ ខ្ញុំវ៉ៃវាទៅតាមចំណុចខ្សោយនៅក្នុងប្រវត្តិរបស់វា» ។ ចំណាររបស់អ្នកសួរចម្លើយមួយទៀត (CMR126.20 រី ស៊ុម) សរសេរថា «ខ្ញុំធ្វើទារុណកម្មវាថែមទៀតដោយផ្តោតទៅលើរឿងដែលវាលាក់» ។

១០០) ចង់ជ្រាបពីការពិនិត្យទៅលើការឃ្លាំមើលតាមដាននៅអឺរ៉ុបនាសតវត្សរ៍ទី១៩ សូមមើលសៀវភៅនិពន្ធដោយ ហូលឃ្វីស មានចំណងជើងថា «ពត៌មានគឺជារឿងស្លាប់រស់» ។

១០១) សូមមើលសៀវភៅនិពន្ធដោយលោក ឆេនដល័រ មានចំណងជើងថា «បងលេខមួយ» ទំព័រទី១៨៧ ។ ពាក្យសម្តីដកស្រង់ទីពីរលោក អាស្លូលី ជាអ្នកផ្តល់ឲ្យខ្ញុំ ។ គំនិតដែលថា «រៀនដើរតេះតះ» ប្រហែលជានាំឲ្យមានការសម្លាប់មនុស្សដែលគ្មានការអនុញ្ញាតទៅលើជនសង្ស័យគ្រង់ជាច្រើនរាប់មិនអស់ ។ នៅក្នុងកិច្ចសម្ភាសន៍របស់ខ្លួនជាមួយលោក ណេត ថាយ័រ ប៉ុល ពត បានសារភាពថា មាន «កំហុស» មួយចំនួន ប៉ុន្តែស្តីបន្ទោសថា មហន្តរាយទាំងនេះជាស្នាដៃរបស់ «ភ្នាក់ងារ» មកពីខាងក្រៅនិងវៀតណាម ។

## ខគ្គធីប្រាំ: បង្ខំឱ្យឆ្លើយ

១) សៀវភៅនិពន្ធដោយ សហ្សុី មានចំណងជើងថា «ប្រព័ន្ធភេរវកម្ម» ទំព័រទី២២៤ និងសៀវភៅនិពន្ធដោយ តូដូរ៉ូ មានចំណងជើងថា «ប្រឈមមុខនឹងរឿងរ៉ាវហួសពីការស្មាន» ទំព័រ១៧៩-៩៣ («ការរីករាយនឹងអំណាច») ។

២) CMR57.24 ។ ចង់ជ្រាបពីការធ្វើទារុណកម្មផ្សេងៗទៀតសូមមើល CMR122.9 ប៉ុល ពិសិដ្ឋ ។ នៅក្នុងចម្លើយសារភាពនេះ អ្នកសួរចម្លើយអះអាងថាបានវាយអ្នកទោសឆក់ខ្សែភ្លើង និងច្រកបបរ ។ ក្រោយមកអ្នកទោសឆ្លើយទាំងរដាក់រដុបនិងច្រំដែលៗ ។

៣) ស្នាដៃនិពន្ធរបស់ ហ្វូខូល មានចំណងជើងថា «វិន័យនិងការដាក់ទណ្ឌកម្ម» ទំព័រទី២៣ ។ ចង់ជ្រាបពីជំហររបស់ ហ្វូខូល ចំពោះទារុណកម្ម សូមមើលសៀវភៅនិពន្ធដោយ មីលល័រ ដែលមានចំណងជើងថា «អារម្មណ៍រំជើបរំជួលរបស់ ម៉ៃឃើល ហ្វូខូល» ទំព័រទី១៦៥-២០៧ និងស្នាដៃនិពន្ធរបស់ ហ្វូខូល ដដែល

*មានចំណងជើងថា «ហេតុអ្វីចាំបាច់សិក្សាអំពីអំណាច» ជាពិសេសទំព័រទី២២០-២១ ស្តីពីអំពើឃោរឃៅ ។ ព័ត៌មានបន្ថែមពីលើនេះសូមមើល «ជម្រើសយកការរួមភេទ, អំពើរួមភេទ» ដែលជាកិច្ចសម្ភាសន៍មួយ ក្នុងនោះ ហ្វូខូល ធ្វើការប្រៀបធៀបការសប្បាយផ្ទាល់ខ្លួនដោយឲ្យដៃគូមានការឈឺចាប់ដោយសារការរួមភេទទៅនឹងការ «លេងល្បែងអុក ដែលការលេងល្បែងនេះច្បាស់ជាមានអ្នកឈ្នះនិងអ្នកចាញ់ ។ ថៅហ្កាយអាចចាញ់...ប្រសិនបើខ្លួនយល់ឃើញថា មិនអាចឆ្លើយតបទៅនឹងការចាំបាច់របស់ជនរងគ្រោះរបស់ខ្លួនទេនោះ ។ ផ្ទុយមកវិញ អ្នកបម្រើអាចចាញ់ប្រសិនបើមិនបានធ្វើតាមឬមិនអាចប្រឈមមុខនឹងការលំបាកដែលថៅហ្កាយខ្លួនប្រគល់ឲ្យ» ។ សូមមើលសៀវភៅនិពន្ធដោយ ហ្សូលឡែកា និង ឌូក្លាស មានចំណងជើងថា «ភេរវកម្ម និងការហាមប្រាមមិនឲ្យប៉ះពាល់» ទំព័រទី១៩០ ។*

*៤) CMR105.4 អឺ ចាន់ និងសៀវភៅនិពន្ធដោយ ឡេវី មានចំណងជើងថា «អ្នកលិចលង់និងអ្នកដែលគេជួយសង្គ្រោះ» ទំព័រទី៧៧-៧៨ ។*

*៥) ដោយសារគន្លះនិយមន័យច្បាស់លាស់និងមានការទទួលស្គាល់ជាសាកល សូមមើលស្នាដៃនិពន្ធរួមរបស់ ម៉ូលីកា និង កាសភី យ៉ាវីន ដែលមានចំណងជើងថា «ការវាយតម្លៃទៅលើទារុណកម្ម» ទំព័រទី៥៨២ ។ចង់ជ្រាបពីការឲ្យនិយមន័យមួយជាក់ស្តែង សូមមើលឯកសាររបស់គណៈកម្មាធិការទំនាក់ទំនងការបរទេសនៃព្រឹទ្ធសភាអាមេរិក «អនុសញ្ញាប្រឆាំងនឹងទារុណកម្ម» ។ ចង់ជ្រាបពី «ការនិយាយមិនចេញ» សូមមើលស្នាដៃរបស់ អាមេរី មានចំណងជើងថា «ដែនកំណត់នៃចិត្ត» ទំព័រទី២៨និង៣៣ ។ សូមមើលសៀវភៅនិពន្ធដោយ ដានីញ៉ែល មានចំណងជើងថា «ត្រជាក់ស៊ីជ្រៅ» ទំព័រទី១៣៥-៥៣ ។ សៀវភៅនិពន្ធដោយ រ៉េចាលី មានចំណងជើងថា «ទារុណកម្មនិងគំនិតសម័យថ្មី» ទំព័រទី១៦០-៧៦ ។ ស្នាដៃនិពន្ធរបស់ ស្ការី មានចំណងជើងថា «រាងកាយឈឺចាប់» ទំព័រទី២៧-៥៩ និងសៀវភៅនិពន្ធដោយ ស៊ែគូ មានចំណងជើងថា «ទទួលទារុណកម្មរាងកាយជីវិតយកចម្លើយ» ។*

*៦) កិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយ ហ៊ឹម ហ៊ុយ ខែមករា ឆ្នាំ១៩៩៧ ។ ហ៊ុយ ធ្លាប់បានផ្តល់សម្ភាសន៍ដល់លោក ប៉ែន ឃៀវនិន, ភីតធ័រ ម៉ាឃ្យៀ, ឆាំង យុ និង ឌូក្លាស នីវិន ។ អ្នកសួរចម្លើយនៅមន្ទីរស-២១ ដែលត្រូវបានដកស្រង់សម្តីសង្ខេបៗ នៅក្នុងខ្សែភាពយន្តឯកសារដែលមានចំណងជើងថា «អន្តការស៊ីគេនោះ» ចាប់តាំងពីពេលនោះមកមិនទាន់មានអ្នកណាបានជួបម្តងទៀតនៅឡើយទេ ។ បន្ថែមពីលើនេះ សូមមើលស្នាដៃនិពន្ធរបស់ មីដាន មានចំណងជើងថា «រឿងរ៉ាវរបស់ស្ត្រីខ្មែរម្នាក់» ។ ទាក់ទងនឹងភាពកម្រនៃកសិណរបស់ជនដៃដល់ ហ្គោលហាជិន និយាយនៅក្នុង «ពេជ្ឈឃាតចេតនារបស់ហ៊ីត្លែរ» ថាៈ «វាជាការគួរឲ្យចាប់អារម្មណ៍ណាស់ថា ព័ត៌មានទាក់ទងនឹងជនដៃដល់ប្រព្រឹត្តអំពើប្រល័យពូជសាសន៍ផ្សេងៗទៀតមិនមានអ្នកណាដឹងច្រើនជាងជនដៃដល់នៃការកាប់សម្លាប់ជនជាតិជ្វីហ្វឡើយ ។ ការពិនិត្យតាមបែបអក្សរសាស្ត្របង្ហាញតិចតួចណាស់អំពីអត្តសញ្ញាណ, ការរស់នៅឬចេតនារបស់ជនដៃដល់ទាំងនោះ (596n.78) ។ នៅពេលយើងសាកគិតមើលថា តើជនដៃដល់ក្រៅពីនៅប្រទេសអាល្លឺម៉ង់ និងថ្មីៗនេះនៅប្រទេសរ៉្វាន់ដាមានតិចប៉ុណ្ណាដែលមិនទាន់ត្រូវបាននាំយកមកកាត់ទោស ថាចំនួនជនដៃដល់ដែលកំពុងតែ*

លាក់ខ្លួនច្រើនប៉ុនណា រស់នៅបែបណានិងប្រកបដោយគ្រោះថ្នាក់បែបណា ប្រសិនបើខ្លួនបង្ហាញមុខនោះ ការសង្កេតរបស់ ហ្គោលដាជិន មិនសមហេតុផលឡើយ ។ ជាងនេះទៀត «គណៈកម្មាការស្វែងរកការពិត» នៅប្រទេសមួយចំនួនដូចជា ប្រទេសអាហ្វ្រិកខាងត្បូងនិងអែលសាវ៉ាឌ័រនិងការលើកលែងទោសនៅប្រទេសអាហ្សង់ទីនជាដើម បានជំរុញឲ្យអតីតជនដៃដល់និយាយស្ដីដោយសេរី ហើយថែមទាំងធ្វើឲ្យអន្តរាយដល់ការអះអាងរបស់ ហ្គោលហាជិន ទៀតផង ដែលនិយាយថា យើងដឹងរឿងរ៉ាវរបស់ជនដៃដល់តិចតួចណាស់ ។ ចង់ជ្រាបពីកសិណដ៏មានតម្លៃរបស់ជនដៃដល់ សូមមើលសៀវភៅនិពន្ធដោយ ហ្វេតឡូវីត មានចំណងជើងថា «សន្ទានុក្រមនៃភាពព្រឺខ្លាច» ទំព័រទី១៩៣-២៥៦ និងស្នាដៃនិពន្ធរបស់ ហាក់ហ្គិន មានចំណងជើងថា «អំពើហិង្សានយោបាយរបស់ប្រេស៊ីល» ។

៧) ស្នាដៃរបស់ ប្រោននីង មានចំណងជើងថា «ពលយុទ្ធជនសាមញ្ញ», សៀវភៅនិពន្ធដោយ ហ្គោលហាជិន មានចំណងជើងថា «ពេជ្ឈឃាតចេតនារបស់ហ៊ីត្លែរ», រ៉ូលហ៊ីលប៊ឺក មានចំណងជើងថា «ជនដៃដល់ ជនរងគ្រោះ អ្នកនៅក្បែរកន្លែងកើតហេតុ», ទីម័រមែន «អ្នកទោសឥតផ្លាកឈ្មោះ», ឡេវី «អ្នកលិចលង់និងអ្នកដែលគេជួយសង្គ្រោះ, ស្នាដៃនិពន្ធរបស់ ស៊ីរីនី មានចំណងជើងថា «នៅក្នុងភាពងងឹតអន្ធការ» និង «មន្ទីរព្រហ្មទណ្ឌនៅប្រជុំកោះ» ។ ពត៌មានបន្ថែមពីលើនេះ សូមមើលសៀវភៅនិពន្ធដោយ ម៉ៃឃើល ជូសស៊ីង មានចំណងជើងថា «ភាពគួរឲ្យព្រឺខ្លាចគឺជារឿងធម្មតា» ។ អ្នកនិពន្ធដែលធ្វើការនៅអាមេរិកឡាទីន មានលទ្ធភាពច្រើនក្នុងការទាញយកភ័ស្តុតាងពីជនដៃដល់ ។ សៀវភៅនិពន្ធដោយ ហ៊ុជិន និងអ្នកដទៃទៀត ដែលមានចំណងជើងថា «ការភ័យខ្លាចនៅចុងបញ្ចប់» ទំព័រទី៣៩-១២០ ។ ហាក់ហ្គិន «អំពើហិង្សានយោបាយរបស់ប្រេស៊ីល» ។ ក្នុងស្នាដៃនេះមានកិច្ចសម្ភាសន៍ជាច្រើនជាមួយអតីតអ្នកធ្វើទារុណកម្ម ។ សូមមើលស្នាដៃនិពន្ធរបស់ ហ្វេត ឡូវីត «សន្ទានុក្រមនៃភាពព្រឺខ្លាច» ។ ចង់ជ្រាបពីពត៌មានស្តីពីអ្នកសួរចម្លើយនៃប្រទេសក្រិច សូមមើលសៀវភៅនិពន្ធដោយ ហ៊្គីបសុន និង ហារ៉ូតូសហ្វូទូរ៉ូស មានចំណងជើងថា «ការបង្រៀនពីការធ្វើទារុណកម្ម» ។

៨) ចង់ជ្រាបពីគំនិត «ការធ្វើឲ្យមានមនុស្សធម៌ឡើងវិញ» នៃជនរងគ្រោះកម្ពុជាប្រជាធិបតេយ្យ សូមមើលស្នាដៃនិពន្ធរបស់លោក ហ៊ិនតុន មានចំណងជើងថា «ភ្នាក់ងាររមរណៈ» និងសៀវភៅរបស់ ដានីញៀល មានចំណងជើងថា «ត្រជាក់ស៊ីជ្រៅ» ទំព័រទី១៩៤-២១២ ។

៩) ស្នាដៃនិពន្ធរបស់ រ៉េចាលី មានចំណងជើងថា «ទារុណកម្មនិងគំនិតសម័យថ្មី» ទំព័រទី១៧៦ ។ សៀវភៅនិពន្ធរួមគ្នាដោយ ហ្សូលឡែកា និង ឌូក្លាស មានចំណងជើងថា «ភេរវកម្មនិងការហាមប្រាមមិនឲ្យប៉ះពាល់» ទំព័រទី១៩៣ ។ បន្ថែមពីលើនេះ សូមមើលស្នាដៃនិពន្ធរបស់ បូមែន «គំនិតទំនើបនិងហាយនភាព» និងគ្រីហ្គូរី និង ទីម័រមែន មានចំណងជើងថា «ដំណើរការរបស់រដ្ឋសម័យថ្មី» ។ អ្នកនិពន្ធទាំងអស់នេះសុទ្ធតែបានទាញហេតុផលថា អ្នកធ្វើទារុណកម្មជា «អ្នកជំនាញការខាងដំណើរការ» ហើយថា ការធ្វើទារុណកម្មគឺដូចគ្នាទៅនឹងដំណើរការផ្លាស់ប្តូរគួរឲ្យរន្ធត់ចិត្តដែរ ។ បូមែន សរសេរថា «អំពើឃោរឃៅបានប្រែក្លាយទៅជាបច្ចេកទេសមួយទៅហើយ ។ ដូចគ្នាទៅនឹងបច្ចេកទេសទាំងអស់ដែរ អំពើឃោរឃៅគ្មានមនោសញ្ចេតនាទេ

ហើយសមហេតុផលទាំងអស់»(៩៨) ។ សែតូ ចាត់ទុកថា ទារុណកម្មគឺជា «ការប៉ះទង្គិចគ្នារវាងហេតុផលរបស់អ្នកបច្ចេកទេសនិងអំពើឃោរឃៅនៃអំណាច» «ធ្វើទារុណកម្មលើរាងកាយជម្រិតយកចម្លើយ»៦៤ ។

១០) ចង់ជ្រាបពីការអនុញ្ញាតសុំវាយ សូមមើលCMR22.33 ចៅ គត់ ។ CMR49.2 ឃុន ខុម និងCMR99.7 (សៀវភៅសរសេររបស់អ្នកសួរចម្លើយ)(៦៨) ។ ចំពោះអ្នកទោសដែលមិនត្រូវវាយដំ សូមមើល CMR36.10 ហ៊ិន ស៊ីណន, CMR54.13 កែង យឹម, CMR57.32 កែវ ផាត, CMR67.27 លីវ ឈាម, CMR68.30 ម៉េ ឡែន, CMR80.22 មុក ខុន, CMR157.29 សេង សុភា និងCMR171.3 ទេព ម៉េង ។

១១) សូមមើល CMR86.1 ងិល គង់ ។

១២) CMR99.7 សៀវភៅក្បួនរបស់អ្នកសួរចម្លើយមានបកប្រែផ្នែកខ្លះនៅក្នុងស្នាដៃនិពន្ធរបស់ ដេវីដ ហក «មណ្ឌលពិឃាតទួលស្លែង» ហើយឯកសារបកប្រែដូចគ្នានេះមាននៅក្នុងស្នាដៃនិពន្ធរបស់ ភីតធ័រ មានចំណងជើងថា «ទារុណកម្ម»ទំព័រទី២៧០-៧២ ។ នៅក្នុងសេចក្តីដកស្រង់បន្ទាប់មកទៀត ខ្ញុំយកពីឯកសារដើមជាភាសាខ្មែរ ។ សេចក្តីដកស្រង់ទីពីរ យកមកពីសៀវភៅកំណត់ហេតុ ទុយ-ប៉ុន ចុះកាលបរិច្ឆេទថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៨ ។

១៣) សហ្សុគ្គី «ប្រព័ន្ធភេរវកម្ម» ទំព័រទី២២៦ ។

១៤) កិច្ចសម្ភាសន៍របស់លោក ភីតធ័រ ម៉ាឃ្យៀ និង គ្រីស រីលី ជាមួយ ទិន ចាន់ ។ សូមមើលឯកសាររបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាដាក់ថា «ជំរំពិឃាតទួលស្លែង» ទំព័រទី៦ ដែលបានដកស្រង់សម្តីរបស់ ទិន ចាន់ ដែរ ។

១៥) ឯកសារតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា បបក១៦៧៥ មិនទាន់ថតចម្លងចូលម៉ាស៊ីនមីក្រូហ៊្វីលនៅឡើយ ។ នៅលើគម្របឯកសារមានចំណាររបស់ ឌុច ដាក់ថា«អានេះហើយ ដែលវាយ ប៊ុន ថន ទាល់តែស្លាប់» ។ ចម្លើយសារភាពមិនពេញលេញរបស់ ប៊ុន ថន មាននៅក្នុង CMR3.10 ។

១៦) ស្នាដៃនិពន្ធរបស់ ខូលីន មានចំណងជើងថា «អំពើអាក្រក់បីយ៉ាង» ។

១៧) កំណត់សម្គាល់ផ្ញើពី ប៉ុន មកឲ្យ ឌុច ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៦ ដែលជាឯកសារមិនទាន់ចុះបញ្ជី តម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

១៨) វចនានុក្រមខ្មែរ-ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ (ភ្នំពេញ១៩៦៧) ទំព័រទី៤២២ ។ អត្ថបទនេះគឺជាមូលដ្ឋាននៃវចនានុក្រមខ្មែរ-អង់គ្លេសពីរភាគរបស់លោក រ៉ូបឺត ហ៊ីតលី វ៉ាស៊ីនតោនឌីស៊ីៈ សាកលវិទ្យាល័យកាតូលិកនៃសហរដ្ឋអាមេរិក (បោះពុម្ពផ្សាយនៅឆ្នាំ១៩៧៧) ។ ហ៊ីតលី សរសេរពាក្យទារុណកម្មនៅទំព័រទី៣៨០ ។ ពត៌មានបន្ថែមពីនេះសូមមើលវចនានុក្រមថៃ-អង់គ្លេស វីតឆាន ប៊ូរ៉ានណាថាន់ (បោះពុម្ពផ្សាយនៅទីក្រុងបាងកក ឆ្នាំ១៩៩២) ទំព័រទី៥៨៣ និង៦១៥ ។ អៀន ម៉ាបែត ជម្រាបខ្ញុំថាភាសាសំស្ក្រឹតមានពាក្យច្រើនណាស់ទាក់ទងនឹងពាក្យ «ទារុណកម្ម» ហើយថានៅប្រទេសឥណ្ឌាកាលពីសម័យបុរាណ ការធ្វើទារុណកម្មតាមបែបតុលាការត្រូវបានប្រើច្រើនណាស់ ។

១៩) ចង់ជ្រាបពីការសួរចម្លើយនិងសារភាពនៅប្រទេសចិនមុនសម័យទំនើប សូមមើលសៀវភៅ

និពន្ធដោយ ស៊ូសាន ណាឃ័រ មានចំណងជើងថា «ចម្លើយសារភាពពិត», សៀវភៅនិពន្ធដោយ ម៉ាក ខូម៉ាក មានចំណងជើងថា «ច្បាប់ព្រហ្មទណ្ឌ ចិនបុរាណ» និងស្នាដៃនិពន្ធរបស់ ខូគុន មានចំណងជើងថា «ការល្បោត និងការដាក់ទណ្ឌកម្មនៅក្នុងប្រទេសចិន» លោក ភីតធ័រ ដែលនិពន្ធសៀវភៅមួយមានចំណងជើងថា «ទារុណកម្ម» ទំព័រទី៩៣ បានលើកមកពិភាក្សាត្រួសៗអំពីទារុណកម្មតាមបែបតុលាការនៅក្នុងប្រទេសជប៉ុនៗ ការធ្វើទារុណកម្មលើរាងកាយដើម្បីធ្វើជាភ័ស្តុតាងដែលកម្រកើតមានអនុវត្តនៅប្រទេសចិនដែលគ្រប់គ្រងដោយ ម៉ៅ ត្រូវបានសើរើឡើងវិញនៅក្នុងអំឡុងបដិវត្តវប្បធម៌ ម៉ៃឃើល ស្កូអ៊ិនហល (ការទាក់ទងផ្ទាល់ខ្លួន) ។

២០) សៀវភៅនិពន្ធដោយ ភីតធ័រ មានចំណងជើងថា «ទារុណកម្ម» ទំព័រទី៦៦ ។ ស្នាដៃនិពន្ធរបស់ អាសាធ មានចំណងជើងថា «កំណត់សម្គាល់ពីការឈឺចាប់លើរាងកាយ»ទំព័រទី៣០៥ ។ ពត៌មានបន្ថែមពីលើនេះសូមមើលសៀវភៅនិពន្ធដោយ មីឡេត មានចំណងជើងថា «នយោបាយឃោរឃៅ» ទំព័រទី២៩៦ និងស្នាដៃនិពន្ធរបស់ ហានសុន មានចំណងជើងថា «ទារុណកម្មនិងការពិត» ។

២១) ចង់ជ្រាបពីចម្លាក់លិបនៅអង្គរវត្ត សូមមើលសៀវភៅនិពន្ធដោយ អេលីនន័រ ម៉ានីកា មានចំណងជើងថា «អង្គរវត្តៈ ពេលវេលា, ទីកន្លែងទំនេរនិងភាពជាព្រះរាជា» (បោះពុម្ពនៅសាកលវិទ្យាល័យហាវ៉ៃ ឆ្នាំ១៩៩៦) ទំព័រទី១៥៥-៦០ ។ គំនិតថាមានឋានសួគ៌និងឋាននរកបានជ្រាបដល់ជនជាតិកម្ពុជាសម័យអង្គរតាមរយៈលោកធាតុវិទ្យាបែបព្រះពុទ្ធសាសនា ។ សូមមើលសៀវភៅនិពន្ធដោយ ខូដេស និង អាឆៃបូល មានចំណងជើងថា «លោកទាំងបី» ។ ចង់ជ្រាបពីសម្តីរបស់អ្នកនាំភ្ញៀវកាលពីឆ្នាំ១៩៨១ សូមមើលសៀវភៅនិពន្ធដោយ ហ្គូស មានចំណងជើងថា «បុរសគល់នៃរបប ប៉ុល ពត» ទំព័រទី១៥៥-៥៦ ។ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺចម្លាក់លិបនៅតាមដងផ្លូវចូលទៅវត្តព្រហ្មរត នៅក្រុងសៀមរាបដែលសង់ឡើងនៅឆ្នាំ១៩៩០ មានរៀបរាប់ពីព្រះពុទ្ធមួយអង្គដែលកំពុងតែផ្ចាញ់ផ្ចាលដោយពួកមារដែលស្លៀកពាក់ឯកសណ្ឋានជាកងទ័ពខ្មែរក្រហម ។

២២) កិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយ វ៉ាន់ ណាត ខែធ្នូ ឆ្នាំ១៩៩៥ ។ ចង់ជ្រាបពីគំនិតបែបព្រះពុទ្ធសាសនាហិនយានចំពោះពាក្យថា «ទមិឡ» សូមមើលសៀវភៅនិពន្ធដោយ កាបហ៊្វើរ មានចំណងជើងថា «រឿងព្រេងប្រជាប្រិយនិងពិភពខាងត្បូង-ព្រះពុទ្ធសាសនានិងនរក» ។ បន្ថែមលើនេះទៀត សូមមើលសៀវភៅនិពន្ធដោយ អ៊ុល ម៉ុនណែន មានចំណងជើងថា «ការឆ្លើយតបទៅនឹងការផ្លាស់ប្តូរបដិវត្តន៍» ទំព័រទី៣៦ ដែលក្នុងនោះអ្នកស្រុកអ្នកភូមិកាលពីទសវត្សរ៍ឆ្នាំ៩០ ហៅខ្មែរក្រហមថា «ទមិឡ» ។ ចង់ជ្រាបពីឧទាហរណ៍មួយចំនួនស្តីពីការដកភាពជាមនុស្ស នៅអឺរ៉ុបមជ្ឈិមសម័យ សូមមើលសៀវភៅនិពន្ធដោយ បូមែន ដែលមានចំណងជើងថា «គំនិតសម័យថ្មីនិងហាយនភាព»ទំព័រទី៤០ ។ ដំណើរការប្រហាក់ប្រហែលគ្នានេះដែរមាននៅក្នុងការសម្លាប់រង្គាលជនជាតិឥណ្ឌូនេស៊ីដែលត្រូវបានសង្ស័យថា ជាជនកុម្មុយនិស្តនៅអំឡុងឆ្នាំ១៩៦៥-៦៦ ដែលមានលើកយកមកពិភាក្សានៅក្នុងស្នាដៃនិពន្ធរបស់ ហេុន មានចំណងជើងថា «អំពើប្រល័យពូជសាសន៍បដិវត្ត និងប្រឆាំងបដិវត្ត» ។ បន្ថែមលើនេះ សូមមើលសៀវភៅនិពន្ធដោយ ស្តូប

មានចំណងជើងថា «ចិត្តសាស្ត្រនិងវប្បធម៌នៃទារុណកម្មនិងអ្នកធ្វើទារុណកម្ម» ។ សេចក្តីដកស្រង់សម្តី ប៉ុល ពត ចុងក្រោយបានមកពី *FBIS* ថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៧៧» *H*២៨ ។

២៣) ជាឧទាហរណ៍ សូមមើល អ៊ីវ៉ាន ធ័រជិននីវ មានចំណងជើងថា «ការសម្លាប់ ត្រូមែន» (១៨៧១) បោះពុម្ពសាជាថ្មីនៅក្នុងស្នាដៃរបស់ ឡូដេត មានចំណងជើងថា «សិល្បៈនៃការសាកល្បងផ្ទាល់ខ្លួន» ។ ពត៌មានបន្ថែម សូមមើលសៀវភៅនិពន្ធដោយ ស្បៀស វ៉េនបឺក មានចំណងជើងថា «ទិដ្ឋភាពឈឺចាប់» ទំព័រទី១៨៨ ។

២៤) ឯកសារបកប្រែដោយ ឡេកែ្ល «ច្បាប់កម្ពុជា»លេខ១ ទំព័រទី២៣៤-៣៦ ។ សូមមើល សៀវភៅនិពន្ធដោយ អ៊ីមប៊ែ ដែលមានចំណងជើងថា «ប្រវត្តិសាស្ត្រសង្គមខ្មែរ» ទំព័រទី១១២ ។

២៥) សូមមើលសៀវភៅទុំទាវ ទំព័រទី១៣០-៣១ ។ បន្ថែមពីលើនេះទៀត សូមមើលឯកសារ ចងក្រងដោយ អ៊ុក សាម៉េត ដែលមានចំណងជើងថា «សិក្សាកថាទុំទាវ» ។ នៅក្នុងទឹកដីខេត្តបាត់ដំបង ដែល សៀមកាន់កាប់កាលពីដើមសតវត្សរ៍ទី២០ មានការកាប់សម្លាប់សាហាវយង់ឃ្នងណាស់ហើយកើតឡើងជា ញឹកញាប់ទៀតផង ។ នៅសម័យកម្ពុជាប្រជាធិបតេយ្យ ប្រពន្ធកូនរបស់អ្នកទោសសំខាន់ៗមួយចំនួនត្រូវ បានសម្លាប់ចោលជាមួយគ្នាទាំងអស់ ។ ការសម្លាប់ សុន សេន និងកូនចៅសែសិបនាក់ ដើម្បីកុំឲ្យសងសឹក វិញ រួមទាំងកូនក្មេងតូចៗផងកាលពីខែមិថុនា ឆ្នាំ១៩៩៧ តាមបញ្ជារបស់ប៉ុល ពត និងការសម្លាប់ពួក ប្រឆាំងនឹងសម្តេច ហ៊ុន សែន ជាងហាសិបនាក់ មួយខែក្រោយមកជាការបញ្ជាក់ពីគំណជាប្រពៃណីមក ។ ចង់ជ្រាបពីគំរូរបស់ថៃ សូមមើលសៀវភៅនិពន្ធដោយ រ៉េ ណុល មានចំណងជើងថា «ការនាំបំបះ បំបោរនៅក្នុងប្រវត្តិសាស្ត្រថៃ» ។

២៦) ស្នាដៃនិពន្ធរបស់ ហ្វូខល មានចំណងជើងថា «វិន័យនិងការដាក់ទណ្ឌកម្ម» ទំព័រទី៨៧ ។ បន្ថែមពី លើនេះ សូមមើលសៀវភៅនិពន្ធដោយ មីលល័រ មានចំណងជើងថា «ការរំដើបរំជួល របស់ ម៉ៃឃើល ហ្វូខូល» ទំព័រទី២០៨ ។ ការធ្វើទារុណកម្ម ជាការដាក់ទោសនិងពន្ធនាគារសាស្ត្រ «ទំនើប» ដើរទៅទន្ទឹមគ្នានៅ ប្រទេសអាហ្សង់ទីន នៅទសវត្សរ៍ទី៧០ ទោះបីជាឯកសារដែលបញ្ជាក់ពីមន្ទីរស-២១ មានការខ្វះខាត យ៉ាងណាក៏ដោយ ។ សូមមើលស្នាដៃនិពន្ធរបស់ គ្រីហ្គូរី និង ទីម័រមែន មានចំណងជើងថា «ដំណើរការ របស់រដ្ឋសម័យថ្មី» ទំព័រទី៦៨ ។

២៧) ចង់ជ្រាបពីទំនាក់ទំនងភ្ជាប់គ្នារវាងទារុណកម្មនិងការសម្ងាត់ សូមមើលសៀវភៅនិពន្ធដោយ អាមេរី មានចំណងជើងថា «ដែនកំណត់នៃចិត្ត» ទំព័រទី២៣-២៤ ។ ចំពោះការពិភាក្សាអំពីទារុណកម្មតាម ផ្លូវតុលាការនៅសតវត្សរ៍ទី២០ សូមមើលសៀវភៅនិពន្ធដោយ ភីតធ័រ មានចំណងជើងថា «ទារុណកម្ម» ទំព័រទី១៦៦ ។

២៨) សូមមើលសៀវភៅរបស់ ឆេនដល័រ មានចំណងជើងថា «រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ» ។

២៩) សូមមើលសៀវភៅនិពន្ធដោយ ឡូកា មានចំណងជើងថា «ប្រព័ន្ធព្រហ្មទណ្ឌខ្មែរក្រហម» ។

៣០) កិច្ចសម្ភាសន៍របស់អ្នកស្រី សារ៉ាខូម ជាមួយ វ៉ាន់ណាត ។ *CMR118.20* បែន កែ និង *CMR66.18*

ឡុង មុយ ដែលនិយាយថា ខ្លួនត្រូវបានធ្វើទារុណកម្មនៅវត្តភ្នំមុនពេលនាំយកមកទួលស្លែង ។

៣១) កិច្ចសម្ភាសន៍របស់ អាឡិច ហ៊ិនតុន ជាមួយ វ៉ាន់ ណាត ។

៣២) ដកស្រង់ចេញពីស្នាដៃនិពន្ធរបស់ តួដូរ៉ូវ មានចំណងជើងថា «ប្រឈមមុខនឹងរឿងរ៉ាវហួសពីការនឹកស្មាន» ទំព័រទី១៥៩ ។ ក្រៅពីនេះសូមមើលឯកសារតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាលេខN ០១៨៨០ ចំណារពីមន្ទីរសន្តិសុខ តំបន់២១ ភូមិភាគបូព៌ា ដែលក្នុងនោះ«អ្នកក្បត់»ត្រូវបានរាប់ជា «ក្បាល» ។ ពាក្យថា «ក្បាល» ជាទូទៅគេប្រើជាមួយសត្វ ។

៣៣) ចង់ជ្រាបពីឋានៈសង្គម សូមមើលសៀវភៅនិពន្ធដោយ ដែកសុន មានចំណងជើងថា «កម្ពុជាឆ្នាំ១៩៧៥-១៩៧៨» ទំព័រទី៨៤ ។ ចង់ជ្រាបពីការដកភាពជាមនុស្ស សូមមើលសៀវភៅនិពន្ធរួមដោយ កែលម៉ាន និង ហាមីលតុន មានចំណងជើងថា «បទល្មើសនៃការគោរពឱវាទ» ទំព័រទី១៩ ។ (សៀវភៅនេះស៊ីជម្រៅលើការសម្លាប់រង្គាលនៅ មីឡាយ) ។

៣៤) ចង់ជ្រាបពីពត៌មានស្តីពីការជំនុំជម្រះគ្រាន់តែបង្គ្រប់កិច្ច សូមមើលស្នាដៃនិពន្ធរួមរបស់ ឡេតថេស និង ប៉ែណូត មានចំណងជើងថា «របៀបទូទាត់» ។ បន្ថែមពីលើនេះទៀត សូមមើលសៀវភៅនិពន្ធរួមដោយ ប៉ែក និង ហ្គេដាំង មានចំណងជើងថា «វិសុទ្ធកម្មជនជាតិរុស្ស៊ី» ។ សៀវភៅនិពន្ធដោយ គ្រេវនីយុក មានចំណងជើងថា «កម្មវត្ថុនៃមហាភេរវកម្ម» និងស្នាដៃនិពន្ធរបស់ នីគីតា គ្រូសឆេវ មានចំណងជើងថា «របាយការណ៍សម្ងាត់ជូនចំពោះមហាសន្និបាតបក្សលើកទី២០នៃបក្សកុម្មុយនិស្តសូវៀត» ។ ទាក់ទងដល់ការធ្វើទារុណកម្ម សូលហ្សិន នីតស៊ីន និយាយថា ការធ្វើទារុណកម្មលើរាងកាយត្រូវបានប្រើស្ទើរគ្រប់កន្លែងនៅប្រទេសរុស្ស៊ីនាទសវត្សរ៍ទី៣០ ប៉ុន្តែធ្វើឡើងដោយសម្ងាត់ (សៀវភៅ«មន្ទីរព្រហ្មទណ្ឌនៅប្រជុំកោះ» ទំព័រទី១០២) ។ របៀបសួរចម្លើយទាំងនេះដែលរួមមានទាំង «ការដុសខាត់ស្មារតី» កាលពីទសវត្សរ៍ឆ្នាំ៥០ផង ត្រូវបានយកមកអនុវត្ត និងអភិវឌ្ឍថែមទៀតពីសំណាក់កម្លាំងប៉ូលិសលោកខាងលិច ហើយត្រូវបានស្គាល់ជាទូទៅថាជា វិធីសាស្ត្រកា.ហ្សេ.បេ ។ សូមមើលសៀវភៅនិពន្ធដោយ សាលីស មានចំណងជើងថា «ជម្រៅបច្ចេកទេសសួរចម្លើយ» ។

៣៥) សៀវភៅនិពន្ធដោយ ហូដូ មានចំណងជើងថា «ការជំនុំជម្រះក្តីគ្រាន់តែឲ្យល្អមើល» ។ សូមមើលស្នាដៃនិពន្ធរួមរបស់ ឡេតថេស និង ប៉ែណូត មានចំណងជើងថា «របៀបទូទាត់» ទំព័រទី៣៥១-៨២ និងកិច្ចសម្ភាសន៍ឆ្នាំ១៩៩៧របស់ ស៊ីវ ជាមួយ មុី ម៉ាន់ ជាខ្មែរក្រហមដែលបានទៅសិក្សានៅទីក្រុងប៉ារីស ។ សៀវភៅនិពន្ធដោយ ម៉ូឡូនី មានចំណងជើងថា «សេរីភាពក្នុងការបញ្ចេញសភាវគតិទ្រង់ញាណ» ទំព័រទី៥៣-៦០ មានកិច្ចសម្ភាសន៍មួយដ៏គួរឲ្យចាប់អារម្មណ៍ជាមួយអ្នកជំនួយជនជាតិអាមេរិកាំងឈ្មោះ រ៉ូប៊ីត រ៉ូកល័រ ដែលត្រូវបានចោទប្រកាន់ថា ជាគិញចូលស៊ើបការណ៍នៅប្រទេសឆេកូស្លូវ៉ាគី នៅដើមទសវត្សរ៍ឆ្នាំ ១៩៥០ ហើយត្រូវបានអ្នកសួរចម្លើយសំអិតសំអាងរៀបចំយ៉ាងណាឲ្យបង្កើតជាចម្លើយសារភាពមួយមានលក្ខណៈពេញលេញតាមរបៀបជម្រះក្តីដែលរៀបចំឡើងឲ្យតែល្អមើល ។

៣៦) ចង់ជ្រាបពីការធ្វើវិសុទ្ធកម្មជនជាតិចិន សូមមើលស្នាដៃនិពន្ធរបស់ ខូមតុន មានចំណងជើងថា

«ប្រទេសចិនក្រោមការគ្រប់គ្រងរបស់ ម៉ៅ» ។ សៀវភៅនិពន្ធដោយ តេវ មានចំណងជើងថា «នយោបាយនិងវិសុទ្ធកម្មនៅប្រទេសចិន» ។ សៀវភៅនិពន្ធដោយ សេ បុល មានចំណងជើងថា «អំពើគួរឲ្យព្រឺខ្លាចនិងភាពដូចគ្នា» និងសៀវភៅនិពន្ធដោយ ដៃ ឈីង មានចំណងជើងថា «វ៉ាងស៊ីវី» និង «ម៉ាយលីលី» ។ ម៉េអេប៊ីហាវ៉ា បានឲ្យជាយោបល់ថា នៅក្នុងប្រទេសកម្ពុជាសម័យមុនបដិវត្តន៍ អតីតអ្នកប្រព្រឹត្តិបទល្មើសម្នាក់ក្រោយពីបានសុំទោសត្រឹមត្រូវនិងរៀនសូត្រតម្រង់ខ្លួនទៅតាមឥរិយាបទត្រឹមត្រូវហើយ មានពេលមួយនោះត្រូវបានគេឲ្យចូលធ្វើការជាថ្មីឡើងវិញនៅក្នុងជួរថ្នាក់ដឹកនាំសង្គម ។ ការចុះចូលរបស់ អៀង សារី នាឆ្នាំ១៩៩៧ ដែលធ្លាប់ត្រូវបានកាត់ទោសប្រហារជីវិតម្តងរួចមកហើយនៅឆ្នាំ១៩៧៩ គឺជាករណីជាក់ស្តែងទោះជា អៀង សារី មិនត្រូវនាំទៅអប់រំរៀនសូត្រយ៉ាងណាក៏ដោយ ។

៣៧) សៀវភៅនិពន្ធរួមដោយ ប៊ឺកគ័រ និង ឡាក់ម៉ែន មានចំណងជើងថា «ការកសាងការពិតរបស់សង្គម» ។ ក្រៅពីនេះសូមមើលសៀវភៅនិពន្ធដោយ ក្លាក មានចំណងជើងថា «របៀបរបបបដិវត្តន៍» ។ ចង់ជ្រាបពីវៀតណាម សូមមើលសៀវភៅនិពន្ធដោយ ម័យ មានចំណងជើងថា «ការកែទម្រង់ដីធ្លីនៅប្រទេសចិន និង វៀតណាម» និងស្នាដៃនិពន្ធរបស់ ប៊ូដារ៉េល មានចំណងជើងថា «បុប្ផាមួយរយទង» ទំព័រទី១៨៥-២៣១ ។

៣៨) ចង់ជ្រាបពីការលើកលែងទោស សូមមើល *CMR96.10* «សេចក្តីណែនាំរបស់មជ្ឈិមបក្សនៃបក្សកុម្មុយនិស្តកម្ពុជាស្តីពីនយោបាយរបស់បក្សចំពោះជនវង្វេងផ្លូវ» ។

៣៩) *CMR60.3* គិម ចិន ។

៤០) សៀវភៅកំណត់ហេតុរបស់ ចាន់ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៧៨ ។ ចម្លើយសារភាពដែលហៅមន្ទីរស-២១ ថាជា «សាលាកែប្រែ» មាននៅក្នុង*CMR17.5* ជ័យ រ៉ុង ។ *CMR36.10* ហ៊ីន ស៊ីណន និង*CMR67.27* លីវ ឆែម ។ ឯកសារទាំងនេះសុទ្ធតែធ្វើឡើងនៅឆ្នាំ១៩៧៨ទាំងអស់ ។ សៀវភៅកំណត់ហេតុ ទុយ-ប៉ុន ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៧៨ មាននិយាយពីការប្តូរឈ្មោះដែលរួមមាននិយាយអំពីវិធីសួរចម្លើយស្ងួតដែរ ។

៤១) ចង់ជ្រាបពី កាង សេង សូមមើលស្នាដៃនិពន្ធរួមរបស់ អាប់ធ័រ និង សៃ មានចំណងជើងថា «ការនិយាយស្តីបដិវត្ត»ទំព័រទី២៨០ ។ សៀវភៅនិពន្ធរួមដោយ បាយរ៉ូន និង ផែក មានចំណងជើងថា «ក្រញ៉ាំនាគរាជ» ។ សៀវភៅនិពន្ធដោយ ម៉ែក ហ្វាឈូហា មានចំណងជើងថា «ដើមកំណើតនៃបដិវត្តន៍វប្បធម៌» ទំព័រទី២៩១-៩៨ និងសៀវភៅនិពន្ធរួមដោយ ហ្វាលីហ្គោ និង កូហ៊័រ មានចំណងជើងថា «ភ្នាក់ងារសម្ងាត់ចិន» ដែលអះអាងដោយគ្មានបញ្ជាក់ប្រភពថា ប៉ុល ពត បានទៅរៀនក្នុងវគ្គសិក្សាពិសេសជាមួយ កាង សេង នៅឆ្នាំ១៩៦៥ និង៦៩ (ទំព័រទី៤១០) ។ បន្ថែមពីលើនេះទៀត សូមមើលសៀវភៅនិពន្ធដោយ ហ៊ួ យ៉ាវភីង មានចំណងជើងថា «បញ្ហាទាក់ទងនឹងការធ្វើវិសុទ្ធកម្មលើរូប កាង សេង» និងសៀវភៅនិពន្ធដោយ ស្កូអ៊ិន ត្រង់ជីពូក «ការស៊ើបអង្កេតដ៏ពិសេសរបស់ ម៉ៅៈ ក្រុមត្រួតពិនិត្យករណីជាក់ស្តែងរបស់មជ្ឈិម១៩៦៦-១៩៧៩» ដែលមាននៅក្នុងសៀវភៅមានចំណងជើងថា ច្បាប់និងរដ្ឋា-

ភិបាលចិន ខែឧសភា-មិថុនា ឆ្នាំ១៩៩៦ ។ ក្រុមត្រួតពិនិត្យករណីជាក់ស្តែងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ... នៅពេញ អំឡុងពេលនៃការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យអាចផ្តល់ការបំផុសគំនិតខ្លះៗដល់មន្ទីរ ស-២១ ។ កាង សេង ធ្វើការងារយ៉ាងជិតដិតនៅក្នុងក្រុមនេះរហូតដល់ថ្ងៃមរណភាពនាឆ្នាំ១៩៧៥ ។

៤២) ចង់ជ្រាបពីទំនាក់ទំនងមិត្តភាពរបស់ ប៉ុល ពត ជាមួយ កាង សេង សូមមើលកិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយអតីតមន្ត្រីជនជាតិចិនម្នាក់ដែលសូមនិយាយមិនបញ្ចេញឈ្មោះ ។ យោងតាមមន្ត្រីរូបនេះបានឲ្យដឹងថា ដំណើរទស្សនកិច្ចរបស់ ប៉ុល ពត នៅឆ្នាំ១៩៧១ ទៅកាន់ប្រទេសចិន គឺជាទស្សនកិច្ចសម្ងាត់ធ្វើមិនឲ្យសម្តេច សីហនុ ទ្រង់ជ្រាប (ចំពេលនោះសម្តេច សីហនុ កំពុងតែគង់ប្រថាប់នៅទីក្រុងប៉េកាំង) ។ ព្រះអង្គទើបតែឈ្វេងយល់ដឹងហេតុការណ៍នេះ នៅពេលគេយកខ្សែភាពយន្តមកចាក់ឲ្យព្រះអង្គទតនៅទីក្រុងភ្នំពេញកាលពីឆ្នាំ១៩៧៦ ។ ដំណើររឿងរបស់មន្ត្រីចិនរូបនេះពិបាកនឹងរកប្រភពមកផ្ទៀងផ្ទាត់ជាមួយណាស់ ។

៤៣) ការចងចាំសម្រែកធ្វើទារុណកម្មទៅលើជនរងគ្រោះមាននៅក្នុងកិច្ចសម្ភាសន៍របស់ ឌូក្លាស នីវិន ជាមួយ ញ៉ែម អេន និង គក ស្រស់, កិច្ចសម្ភាសន៍របស់ អាឡិចហ្សាន់ឌ័រ ហ៊ិនតុន ជាមួយ ខៀវ ល និង លីអូណោល ជាមួយ ផាន ថនចាន់ ។ បន្ថែមពីលើនេះទៀត សូមមើលសៀវភៅនិពន្ធដោយ ធីហ្វានី មានចំណងជើងថា «នៅយប់នោះខ្ញុំនៅតែឮសំឡេងស្រែក» ។ ចំណងជើងនេះបានមកពីសម្តីរបស់ អ៊ឹង ប៊ិច ដែលផ្តល់កិច្ចសម្ភាសន៍ដល់អ្នកនិពន្ធផ្ទាល់ ។ អ៊ឹង ប៊ិច និយាយប្រាប់ ធីហ្វានី ថា «ខ្ញុំគិតថា សំឡេងស្រែកយំឈឺចាប់ ឮស្ទើរតែបែកក្រដាសត្រចៀកទៅហើយ» ។ វ៉ាន់ ណាត និយាយទៅកាន់ ដេវីដ ហក នៅក្នុងកិច្ចសម្ភាសន៍ កាលពីឆ្នាំ១៩៨៣ថា «អ្នកឯងឮសំឡេងស្រែកយំគ្រប់ពេលៈ សម្រែកគួរឲ្យព្រឺក្បាល សម្រែកភ័យខ្លាចនិង សម្រែកស្ទះដង្ហើមត្រដររឿលជិតស្លាប់» ។

៤៤) សៀវភៅកំណត់ហេតុ ទុយ-ប៉ុន ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៧៨ ។

៤៥) សៀវភៅនិពន្ធដោយ អារីស្តូត មានចំណងជើងថា «សិល្បៈវោហាសាស្ត្រ» ទំព័រទី២៦ សរសេរថា «អ្នកដែលស្ថិតនៅក្រោមការបង្ខិតបង្ខំប្រហែលជាផ្តល់ភ័ស្តុតាងមិនពិតថាជាការពិត អ្នកខ្លះទៀតសុខចិត្តទ្រាំទ្រការលំបាកមិនប្រាប់ពីការពិតទេ ។ ចំណែកអ្នកខ្លះទៀតព្យាយាមរកនឹកផ្លាស់ប្តូរពត៌មានប្រឆាំងនឹងអ្នកដទៃដោយសង្ឃឹមថា គេនឹងដោះលែងខ្លួនក្រោយពេលធ្វើទារុណកម្មហើយ» ។ ម៉េល ល័រ ដែលនិយាយទាក់ទងនឹងអត្ថន័យនេះដែរ និងរៀបរាប់ពីការធ្វើទារុណកម្មតាមបែបបុរាណបានធ្វើការកត់សម្គាល់ថា គ្មានអ្នកនិពន្ធបុរាណណាម្នាក់សម្តែងពីការជំទាស់តាមផ្លូវសីលធម៌ទៅនឹងការអនុវត្តន៍ជាក់ស្តែងឡើយ («ទារុណកម្ម» ទំព័រទី៦៥) ។

៤៦) សៀវភៅនិពន្ធដោយ សហ្មុស្តី មានចំណងជើងថា «ប្រព័ន្ធភេរវកម្ម» ទំព័រទី២២៨ ។ សូមមើលសៀវភៅនិពន្ធដោយ ហ៊ុឹបសុន មានចំណងជើងថា «បង្រៀនមនុស្សឲ្យចេះរបៀបបង្កការឈឺចាប់» និងកិច្ចសម្ភាសន៍របស់ ដេវីដ ហក ជាមួយ ស៊ីវ ហេដឌ័រ ខែកញ្ញា ឆ្នាំ១៩៨២ ។ បន្ថែមពីលើនេះ សូមមើល CMR99.14 «សង្ខេបពីសន្តិបាល» ខែឧសភា ឆ្នាំ១៩៧៧ (ប្រជុំទិតៀន-ស៊ុយទិតៀន)ៈ «ចំណុចខ្វះខាតៈ

*យើងក្តាប់ស្មារតីអធនសមូហភាពមិនបាន ។ ឧទាហរណ៍ យើងធ្វើទារុណកម្ម ហើយអំពីសុខភាពក៏អឺចឹងដែរ ...ចំណុចមិនល្អគឺថា អ្នកទោសចេះតែស្លាប់បន្តបន្ទាប់ ។ បីខែចុងក្រោយនេះ(៥) ។*

*៨៧) **CMR69.30** ម៉ា មាងខេង ។ បន្ថែមពីលើនេះសូមមើល**CMR88.3** នៅកងហា អតីតអ្នកសួរចម្លើយដែលប្រកាសនៅក្នុងចម្លើយសារភាពខ្លួនថា របៀបធ្វើការនៅអង្គភាពនេះគឺត្រូវ "សួរឲ្យដឹងថា ខ្មាំងចូលសេ.អ៊ី.អា នៅពេលណា ហើយត្រូវវាយវាពីរបីខែ" ។ ស្រដៀងគ្នានេះដែរ សៀវភៅកំណត់ហេតុរបស់អ្នកសួរចម្លើយពីឆ្នាំ១៩៧៦(CMR99.7,65) មានសរសេរសារភាពត្រង់នៅក្នុងការប្រជុំស៊ុយទិតៀនថា "យើងបន្តវាយ ប៉ុន្តែយើងចាត់ទុកទារុណកម្មសំខាន់ជាងធ្វើនយោបាយ... ។ បញ្ហារបស់យើង គឺស្រែកគំហកខ្លាំងៗដាក់ខ្មាំង" ។*

*៨៨) ករណីប្រហាក់ប្រហែលគ្នានេះ សូមមើលសៀវភៅរបស់ លីន ជីង មានចំណងជើងថា "ផ្លូវរបស់ឆ្មាំក្រហមទៅកាន់អំពើឃោរឃៅ" ។ សៀវភៅនិពន្ធរួមដោយ វ៉ាលឌ័រ និង កុង សែវសៀ ដែលមានចំណងជើងថា "សង្គមវិទ្យានិងនរវិទ្យារបស់ចិន" និងសៀវភៅនិពន្ធដោយ ឌិតម័រ មានចំណងជើងថា "ការកែទម្រង់គំនិត និង បដិវត្តវប្បធម៌" ។ ចំនួនអ្នកទោសដែលត្រូវសម្លាប់នៅប្រទេសចិនប្រហែលជាមិនអាចច្រើនដូចជានៅសហភាពសូវៀតនៅក្រោមការគ្រប់គ្រងអំណាចរបស់ ស្តាលីន ឬនៅកម្ពុជាប្រជាធិប-តេយ្យឡើយ ។ អ្នកនិពន្ធ មែកហ្វាឈូហា ទាញហេតុផលនៅត្រង់ចំណុចនេះគួរឲ្យជឿជាក់នូវដើមកំណើតនៃបដិវត្តវប្បធម៌" (ទំព័រទី៤៧៣) ។*

*៨៩) ចង់ជ្រាបពីការពិភាក្សានៅលើចម្លើយសារភាពនេះ សូមមើលជំពូក៣ និងចំណាររបស់ ឌុច ទៅកាន់ ណៃ សារ៉ាន់ (ហៅយ៉ា) ដែលជាឯកសារមិនទាន់ចុះបញ្ជីចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦ តម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ពីរថ្ងៃក្រោយមក ឌុច សរសេរថា "ជាមួយ យ៉ា អាចប្រើវិធីក្តៅឲ្យយូរ ។ ប្រសិនបើក្ជាត់ស្ទៀតជ្រុលដៃធ្វើឲ្យវាស្លាប់ក៏មិនល្មើសនឹងវិន័យរបស់អង្គការដែរ" ។ ប៉ុន បានចារនៅតាមគែមទំព័រថា "បន្ទាញ យ៉ា ផង ក្រែងវាយកទៅគិតម្តងទៀត" (ឯកសារបកប្រែដោយ ស៊ីវ ហេងឌ័រ) ។*

*៥០) **CMR159.11** ។*

*៥១) ខ្សែភាពយន្តរឿង "អង្គការស្មីគេនោះ" ។ នៅក្នុងកិច្ចសម្ភាសន៍ជាមួយអ្នកនិពន្ធ វ៉ាន់ ណាត និយាយថា មានអ្នកទោសមួយចំនួននៅមន្ទីរស-២១ ត្រូវគេយកទៅដាក់ក្នុងអាងទឹកហើយឆក់ខ្សែភ្លើង ។*

*៥២) **CMR3.24** ប៊ុត ហេង ។ ប្រពន្ធរបស់ ហេង ឈ្មោះ ឆាយ ភឿន គឺជាសមាជិកបក្សពេញសិទ្ធិដែលប្រហែលជាត្រូវបានសម្លាប់ជាមួយប្តី ។ ឯកសារផ្ទាល់ខ្លួនរបស់គាត់មិនទាន់បាត់បង់ទៅណាទេ ។*

*៥៣) សៀវភៅកំណត់ហេតុរបស់ ចាន់ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៧៨ ។ "ការគ្តិច" ប្រហែលជាពាក្យប្រើសម្រាប់សម្គាល់ការរំខានតាមផ្លូវភេទ ។ ឧទាហរណ៍មួយបញ្ជាក់ពីការធ្វើជ្រុលហួសហេតុរបស់អ្នកសួរចម្លើយទៅលើអ្នកទោស (CMR183.27) ។ វង់ សំអាត សារភាពថា បានរុកឈើចូលក្នុងរន្ធយោនីអ្នកទោសស្រីនៅពេលសួរចម្លើយ ។ (CMR17.13) ជា ម៉ាយ សារភាពថាបានរួមភេទជាមួយអ្នកទោសស្រី*

ហើយនិយាយថា មេៗរបស់ខ្លួននៅក្នុងអង្គការក៏ប្រព្រឹត្តដូច្នេះដែរ ។

៥៤) កិច្ចសម្ភាសន៍របស់ ដេវីដ ហក ជាមួយ អ៊ឹង ប៉ិច ។

៥៥) ខ្សែភាពយន្តរឿង "អង្គការស្ដីគេនោះ" ។

៥៦) សម្ដីរបស់ វ៉ាន់ ណាត នៅក្នុងសៀវភៅមានចំណងជើងថា "វាលពិឃាត" និពន្ធរួមគ្នាដោយ នីវិន និង រីលី ទំព័រទី៩៦ ។ សូមមើលឯកសាររបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាមានចំណងជើងថា សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងៈ "ពួកវាប្រើមេដែកអគ្គិសនីដែលមានតង់ស្យុងខ្ពស់ ប៉ុន្តែអាំងតង់-ស៊ីតេខ្សោយបូចរន្តភ្លើង ៣៨០វ៉ុល ។ ខ្សែភ្លើងដាក់ឆក់ជើង ឬអណ្ដាតរបស់អ្នកទោស ឬត្រចៀក ម្រាមដៃ ឬប្រដាប់ភេទ(៤) ។ នៅក្នុងកិច្ចសម្ភាសន៍ជាមួយ ដេវីដ ហក, វ៉ាន់ ណាត និយាយថា គាត់ត្រូវបាន "ឆក់នឹងខ្សែភ្លើងអស់ជាច្រើនម៉ោង" ។ CMR13.5 ជៀក អី ក៏ត្រូវបានឆក់ខ្សែភ្លើងម្ដងហើយម្ដងទៀតដែរ ។ ចង់ជ្រាបពីការព្រមានដាស់តឿនអ្នកទោស សូមមើលខ្សែភាពយន្តមានចំណងជើងថា "អង្គការស្ដីគេនោះ" ។ ទិន ចាន់ អ្នកដែលមានឱកាសចាកផុតពីសេចក្ដីស្លាប់ដែលទទួលរងនូវការឆក់ខ្សែភ្លើងដែរនោះ បាននិយាយប្រាប់ គ្រីស រីលី និង ភីតធ័រ ម៉ាឃ្យៀ នៅឆ្នាំ១៩៩៤ថា "មានពេលខ្លះពួកវាឆក់ខ្ញុំ ។ ហេតុនេះហើយទើបសព្វថ្ងៃនេះ ខួរក្បាលខ្ញុំហាក់ដូចជាខុសពីធម្មតា" ។

៥៧) CMR46.5 កែត ចូ ។ CMR37.15 ហ៊ុន សំផូន ។ CMR64.5 លី ដេន ។ ចំណាររបស់ ឌុច ទៅកាន់ ហេង សួយ CMR35.4 និង CMR179.8 តែ ហ៊ុត ។ ពត៌មានបន្ថែមសូមមើល CMR24 ស៊ី យ៉ាន់ ដែលមានសំណេរដោយ ចាន់ ថា "ធ្វើទារុណកម្មវាឲ្យខ្លាំងពល់តែវាឈប់និយាយថា វាបានទៅវៀតណាម" ។

៥៨) កិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយ វ៉ាន់ ណាត នៅខែធ្នូ ឆ្នាំ១៩៩៥ ។ ការចងចាំរបស់ វ៉ាន់ ណាត មាននៅក្នុង CMR105.39, ផល ឡាក់ដេង ដែលក្នុងនោះអ្នកសួរចម្លើយសរសេរថា ខ្លួនបានបង្ហាញឲ្យអ្នកទោសនូវ "រូបភាពដែលមានខ្លួនឆ្កែ ក្បាលមនុស្ស" ។ ពត៌មានបន្ថែមសូមមើលCMR87.16, និន អ៊ីង ។ ស្នាដៃនិពន្ធរួមគ្នារបស់ រីតធិនបឹក និង បេណេត មានចំណងជើងថា "អ្នកដែលនៅពីក្រោយខ្នង" បានរំពុកឡើងវិញនូវពាក្យស្លោកមួយដែលត្រូវបានប្រើជាមួយអ្នកទោសនៅប្រទេសចិន នៅក្នុងសម័យបដិវត្តវប្បធម៌ៈ "បន្ទោនក្បាលឆ្កែរបស់ឯងចុះ" (៣៤០) ។ សូមមើលបន្ថែមនូវសៀវភៅមានចំណងជើងថា "ជញ្ជាំង" នៅក្នុងបដិវត្តវប្បធម៌ចិន និពន្ធដោយ ចាង ជីយ៉ាង ។

៥៩) សូមមើលស្នាដៃនិពន្ធរបស់ ម៉ាស្តូន មានចំណងជើងថា "កម្ពុជាឆ្នាំ១៩៩១-១៩៩៤" ទំព័រទី ៨៤ ។ ចង់ជ្រាបពីការអនុវត្តន៍ជាក់ស្ដែងនៅប្រទេសថៃ សូមមើលសៀវភៅនិពន្ធដោយ ឌី អ៊ីនស័រ មានចំណងជើងថា "ប្រទេសថៃៈ ការវិភាគសេដ្ឋកិច្ចសង្គម និងនយោបាយ" បោះពុម្ពផ្សាយនៅទីក្រុងញូវយ៉កឆ្នាំ១៩៦៣ ទំព័រទី៦៨-៦៩ ។

៦០) CMR77.21 មឿង ឌឿ និង CMR87.16 និន អ៊ីង ។

៦១) CMR158.26 ស្វាង គុម គឺជាប្រពន្ធរបស់ ឆែ សំអៀក (ហៅប៉ាង) សមាជិកជាន់ខ្ពស់នៃបក្សកុម្មុយនិស្តកម្ពុជានិងជាមនុស្សរបស់ ប៉ុល ពត ដែលត្រូវបានចាប់ខ្លួនកាលពីឆ្នាំ១៩៧៨ ។ នៅចំពេលនោះ

ហូ ជីមិញ ស្លាប់បានប្រាំបួនឆ្នាំហើយ ហើយ លីនដុន ចនសុន ក៏ឈប់ធ្វើការអស់មួយទសវត្សរ៍ហើយដែរ ។ បន្ថែមពីលើនេះ សូមមើល CMR33.11 ហៀង ស្រ៊ុន ។ CMR58.19 កុត ព្រំ និង CMR88.44 ញ៉ែម វ៉ាន់ ។

៦២) នៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៧៨ កំណត់ហេតុ ទុយ-ប៉ុន សរសេរថា អ្នកសួរចម្លើយមិនគួរធ្វើទារុណកម្មនៅពេលខ្លួនមានកំហឹងទេ ពីព្រោះបើអ្នកសួរចម្លើយ «ក្ដៅខ្លួន» អ្នកទោសច្បាស់ជាផ្ដល់ «ចម្លើយមិនច្បាស់» មិនខាន CMR99.7 ។

៦៣) CMR99.7 ។ ឯកសារបកប្រែបន្ទាប់មកទៀតដកស្រង់ចេញមកពីទំព័រទី៧០-៧៦ ។

៦៤) មកដល់កន្លែងនេះខ្ញុំនឹកឃើញដល់សៀវភៅនិពន្ធដោយ ហ្គាន់ធ័រ ឡេវី មានចំណងជើងថា «អាមេរិកាំងនៅលើទឹកដីវៀតណាម» (បោះពុម្ពផ្សាយដោយសាកលវិទ្យាល័យអុកស្វឺតប្រេស ឆ្នាំ១៩៧៨) ដែលដកស្រង់ក្បួនច្បាប់របស់អ្នកចូលរួមជនជាតិអាមេរិកនៅក្នុងកម្មវិធីហ្វូអេនិកនៅក្នុងសង្គ្រាមវៀតណាម ដែលមានគោលបំណង «ដើម្បីធ្វើឲ្យហេដ្ឋារចនាសម្ព័ន្ធរបស់ខ្មាំងលែងមានប្រសិទ្ធភាព៖ «[បុគ្គលិក] មិនអនុញ្ញាតឲ្យធ្វើឃាតកម្មឡើយ» ទំព័រទី២៨៣ ។ ការ «គ្រប់គ្រង» ដូចគ្នានេះដែរ ត្រូវបានអនុវត្តទៅលើកងម៉ារីនអាមេរិកនៅក្នុងប្រទេសវៀតណាម ។ សូមមើលសៀវភៅនិពន្ធដោយ សូលី មានចំណងជើងថា «សឺន ថាង» ។

៦៥) សៀវភៅកំណត់ហេតុរបស់ ចាន់ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៧៨ ។

៦៦) CMR99.10 ។

៦៧) សៀវភៅនិពន្ធដោយ បូមែន មានចំណងជើងថា «គំនិតសម័យថ្មី និងហាយនភាព» ទំព័រទី២១ ។ សៀវភៅនិពន្ធដោយ តូដូរ៉ូវ មានចំណងជើងថា «ប្រឈមមុខនឹងរឿងរ៉ាវហួសពីការនឹកស្មាន» ទំព័រទី១៥៨-៧៨ ។

៦៨) ស្នាដៃនិពន្ធរួមរបស់ ខែលម៉ាន និង ហាមីលតុន មានចំណងជើងថា «បទល្មើសនៃការគោរពឱវាទ» ។ បន្ថែមពីលើនេះទៀត សូមមើលស្នាដៃនិពន្ធរបស់ ហ៊ើបឺត ខែលមែន មានចំណងជើងថា «អំពើឃោរឃៅគ្មានព្រំដែនសីលធម៌» នៅក្នុងទិនានុប្បវត្តិសង្គម (ឆ្នាំ១៩៧៣) ទំព័រទី២៩-៦១ ។ សៀវភៅនិពន្ធដោយ បូមែន មានចំណងជើងថា «គំនិតសម័យទំនើប និងហាយនភាព» ទំព័រទី១៥១-៦៩ និងសៀវភៅនិពន្ធដោយ វ៉ាឡិនទីណូ មានចំណងជើងថា «ដំណោះស្រាយចុងក្រោយ» ។ ដោយទទួលបានគំនិតពីការអានសៀវភៅនិពន្ធដោយ មីលក្រាម, វ៉ាឡិនទីណូ ទាញហេតុផលថា ការអនុញ្ញាតឲ្យសម្លាប់ដែលចេញពីមនុស្សដែលគួរឲ្យគោរពគឺជាលក្ខខណ្ឌមិនអាចខ្វះបានដើម្បីក្លាយជាអំពើប្រល័យពូជសាសន៍សម័យទំនើបដែលមានរដ្ឋជាអ្នករ៉ាប់រងទទួលខុសត្រូវ ។

៦៩) ស្នាដៃនិពន្ធរួមដោយ ហ្គោដុង ប៉ែរណោ និង រ៉ូណាល់ ម៉ុងត្រាពែតូ មានចំណងជើងថា «ឆ្នាំ ក្រហម» ទំព័រទី២៨ ។

៧០) ស្នាដៃនិពន្ធរបស់ ឡិចដ័រវូដ មានចំណងជើងថា «សារមន្ទីរទួលស្លែងកម្ពុជា» ទំព័រទី៨៥ ។

៧១) កិច្ចសម្ភាសន៍របស់ ឌូក្លាស នីវិន ជាមួយ ញ៉ែម អេន ។ ទិន ចាន់ មានការចងចាំរឿងរ៉ាវចាស់ប្រហាក់ប្រហែលគ្នានេះដែរ (កិច្ចសម្ភាសន៍ជាមួយ ភីតធ័រ ម៉ាឃៀ និង គ្រីស រីលី) ។ បន្ថែមពីលើនេះទៀត

សូមមើលសៀវភៅនិពន្ធដោយ ឡេវី មានចំណងជើងថា «អ្នកលិចលង់ និងអ្នកដែលគេជួយសង្គ្រោះ» ទំព័រទី២៤ ។

៧២) កិច្ចសម្ភាសន៍របស់អ្នកនិពន្ធជាមួយ គក ស្រស់ ។

៧៣) ចង់ជ្រាបពីការរកឃើញជើងឯកនៅឆ្នាំ១៩៨០ សូមមើលកិច្ចសម្ភាសន៍របស់អ្នកស្រី សារ៉ាខូម និង ភីតធ័រ ម៉ាឃៀ ជាមួយ ម៉ៃ ឡាំ ។ ចំពោះការពិពណ៌នាបីងជើងឯកថា ជាមុខសញ្ញាទេសចរណ៍នៅទសវត្សរ៍ឆ្នាំ១៩៩០ សូមមើលសៀវភៅនិពន្ធដោយ កាដ្លែន មានចំណងជើងថា «ទីបញ្ចប់នៃដែនដី» ទំព័រទី ៤០៣-៤ ។

៧៤) សូមមើលស្នាដៃនិពន្ធរួមដោយ ម៉ូលីកា និង កាសភី-យ៉ាវិន មានចំណងជើងថា «ការវាយតម្លៃលើទារុណកម្ម» ។

៧៥) ស្នាដៃរបស់ អាមេរី មានចំណងជើងថា «ដែនកំណត់នៃចិត្ត» ទំព័រទី២៧ ។ ព្រីម៉ូ ឡេវី ដែលសរសេរអំពីអត្តឃាតរបស់ អាមេរី ប្រាំបីឆ្នាំក្រោយមកនិងមួយឆ្នាំមុនពេលធ្វើអត្តឃាតខ្លួនឯងដែរនោះ កត់សម្គាល់ថា អំពើនេះ «ពិតជាពិបាកពន្យល់ខ្លាំងណាស់» «អ្នកលិចលង់និងអ្នកដែលគេជួយសង្គ្រោះ»(ទំព័រទី១៣៦) ។ សូមមើលសៀវភៅនិពន្ធដោយ ដេភ័រណូ មានចំណងជើងថា «អត្តឃាតគឺជាការផ្លាស់ប្តូរទ្រង់ទ្រាយវប្បធម៌និងជាការបិទបាំង» ។

## ខណ្ឌទីប្រាំមួយ: បរិយាយអំពីមន្ទីរស-២១

១) ក្នុងការសរសេរវគ្គទី៦នេះ ខ្ញុំបានទាញយកគំនិតមួយចំនួនពីការសន្ទនាជាមួយ ជី យូសមែន, អេលីនន័រ ហែនខក់ និង អេរិក វើត ។ នៅក្នុងស្នាដៃរបស់ខ្លួនមានចំណងជើងថា «គំនិតបាបកម្ម» អ្នកនិពន្ធឈ្មោះ ប៊ែន បាននិយាយសំអាងទៅលើគំនិតរបស់ ស្តូដែនហូ ថា «ជាការរីករាយលើគំនរទុក្ខសោកអ្នកដទៃ» (ទំព័រទី៧៩៧) ។ ចំណារមួយចំនួនរបស់ ឌុច និង ប៉ុន ព្រមទាំងសំបុត្ររបស់ ទុយ ផ្ញើទៅ សៀត ឆែ (ហៅ ទុំ) ដែលចោទប្រកាន់ថា ខូចសីលធម៌ (ផ្លូវភេទ) គឺចូលក្នុងករណីនេះហើយ ។ នៅក្នុងសៀវភៅមានចំណងជើងថា «ប្រឈមមុខនឹងអំពើអាក្រក់» ទំព័រទី៧ ចន ខេក និយាយអំពីមនុស្សដែលធ្វើទុក្ខទោសដែលមិនគួរធ្វើជាទម្លាប់របស់ខ្លួន ។ ការប្រើពាក្យនេះហាក់ដូចជាត្រូវទៅនឹង សុន សេន, ឌុច និង ប៉ុន ដែលជាអ្នកផ្តើមគំនិតគោរពមជ្ឈិមបក្ស ។ បន្ថែមពីលើនេះ សូមមើលស្នាដៃនិពន្ធរបស់ ខូមជែក ដែលមានចំណងជើងថា «អំពើអាក្រក់ហួសវិស័យ» និងសៀវភៅនិពន្ធដោយ ដាន់ មានចំណងជើងថា *“Riffs and Reciprocity”* ទំព័រទី២២ ។

២) ចង់ជ្រាបពីការពិភាក្សាលើបញ្ហាទាំងនេះ សូមមើលសៀវភៅនិពន្ធដោយ ហ្គូរីក មានចំណងជើងថា «យើងសូមជម្រាបលោកអ្នក» ។ សៀវភៅនិពន្ធដោយ រ៉ូសិនបូម មានចំណងជើងថា «តើការសម្លាប់ជនជាតិជ្វីហ្វមានតែមួយឬ?» ។ សៀវភៅនិពន្ធដោយ ហ្វូរ៉ូវិត មានចំណងជើងថា «ឆក់យកជីវិត» ។ សៀវភៅនិពន្ធរួមដោយ ហាហ្វ និង ហ្គ័រ មានចំណងជើងថា «ឆ្ពោះទៅរកទ្រឹស្តីអនុវត្តជាក់ស្តែងនៃអំពើប្រល័យពូជសាសន៍និងប្រល័យនយោបាយ» និងសៀវភៅនិពន្ធដោយ វ៉ាឡិនទីណូ មានចំណងជើងថា «ដំណោះ

ស្រាយចុងក្រោយ» ។ បន្ថែមពីលើនេះទៀត សូមមើលសំណេរដ៏មានប្រយោជន៍របស់ ណាហ្សេនហ្គាស មានចំណងជើងថា «អំពើឃោរឃៅ គេរវកម្ម និងវិបត្តិរបស់រដ្ឋ» និងស្នាដៃនិពន្ធពីរច្បាប់របស់ ចន ដាលី មានចំណងជើងថា «អគ្គការសង្គមបង្កើតអំពើអាក្រក់» និង «ការស្ដាប់ទិវាទប្រកបដោយន័យស្ថាបនា និងការបំផ្លិចបំផ្លាញ» ។

៣) ស្នាដៃនិពន្ធរួមរបស់ ខូរ៉េហ្ស និង ហូរ៉េស មានចំណងជើងថា «Cambodge à deux voix» ទំព័រទី៧២ ។

៤) ដកស្រង់ចេញពីសៀវភៅនិពន្ធដោយ ចាក់ប៉័រ មានចំណងជើងថា «ស្តាលីននិយម» ទំព័រទី២១២ ។

៥) សៀវភៅនិពន្ធដោយ ស្ពេន មានចំណងជើងថា «ប្រព័ន្ធព្រហ្មទណ្ឌនៅប្រទេសចិន» ។

៦) សៀវភៅនិពន្ធដោយ ស្សូខា មានចំណងជើងថា «បាបធម៌ធម្មតា» ទំព័រទី៤៤ ។

៧) សៀវភៅនិពន្ធដោយ ស្សូខា មានចំណងជើងថា «បាបធម៌ធម្មតា» ទំព័រទី៧២ ។ បន្ថែមពីលើនេះទៀតសូមមើលសៀវភៅនិពន្ធដោយ ឡា ខាប្រា មានចំណងជើងថា «ប្រវត្តិសាស្ត្រនិងការចងចាំ» ទំព័រទី១៨២ ។

៨) សៀវភៅនិពន្ធដោយ ស័ររ៉េ-អូរ៉ូស្គូ មានចំណងជើងថា «វេយ្យាករណ៍នៃភេរវកម្ម» ។ សៀវភៅនិពន្ធដោយ ជូស៊ីង មានចំណងជើងថា «ប្រព័ន្ធសរសៃប្រសាទ» និងស្នាដៃនិពន្ធរួមដោយ រ៉ូបេន និង ណូតស្រ្តូម មានចំណងជើងថា «ការចុះទៅស្រាវជ្រាវផ្ទាល់ស្ថិតក្រោមការវាយប្រហារ» ដែលមាននិយាយអំពីអំពើហិង្សាដែលកើតឡើងរាល់ថ្ងៃ ។

៩) ស្នាដៃរបស់ ប្រោននីង មានចំណងជើងថា «ពលយុទ្ធជនសាមញ្ញ ឬជនជាតិអាល្លឺម៉ង់សាមញ្ញ» និងសៀវភៅនិពន្ធដោយ មីលក្រាម មានចំណងជើងថា «ការគោរពអំណាច» ទំព័រទី១០ៈ «ប្រជាហិង្សាកើតឡើងមិនចេះចប់មិនចេះហើយ ដោយមនុស្សផ្សេងៗគ្នា» ។

១០) កិច្ចសម្ភាសន៍របស់ ខូក្លាស នីវិន ជាមួយ គក ស្រស់ ។ និយាយទៅកាន់ សេង មីដាន នៅឆ្នាំ ១៩៩៩ អតីតឆ្មាំមន្ទីរស-២១ នាង គិន និយាយថា «គេបង្រៀនយើងឲ្យដើរតាមផ្លូវបដិវត្តន៍ត្រឹមត្រូវ ។ បើអ្នកឯងមិនជឿ គេនឹងសម្លាប់អ្នកឯងចោលភ្លាម» ស្នាដៃនិពន្ធដោយ មីដាន មានចំណងជើងថា «រឿងរ៉ាវរបស់ស្ត្រីខ្មែរម្នាក់» ។

១១) ស្នាដៃនិពន្ធរបស់ ស៊ីវ៉ានី មានចំណងជើងថា «នៅក្នុងភាពងងឹតអន្ធការ» ទំព័រទី២០០ ។ សូមមើលសៀវភៅរបស់ គូដូរ៉ូ មានចំណងជើងថា «ប្រឈមមុខនឹងរឿងរ៉ាវហួសពីការស្មាន» ទំព័រទី១៥៨-៧៨ ក្នុងវគ្គមួយមានចំណងជើងថា «ការបំបែកជាបំណែកតូចៗ» ។

១២) ស្នាដៃនិពន្ធរបស់ ស៊ីវ៉ានី មានចំណងជើងថា «នៅក្នុងភាពងងឹតអន្ធការ» ទំព័រទី១០១ ។ ស្ពាងហ្គុល ប្រាប់នាងថា «ផ្លូវមួយគត់ដែលខ្ញុំអាចរស់នៅបានគឺត្រូវបំបែកការគិតរបស់ខ្ញុំជាផ្នែកៗ» ទំព័រទី៦៤ ។ អតីតអ្នកធ្វើការនៅមន្ទីរស-២១ មួយចំនួនបានរៀបរាប់ទង្វើរបៀបនេះ ។ សូមមើលការពិភាក្សាស៊ីជម្រៅទៅលើសៀវភៅនិពន្ធដោយ ស៊ីវ៉ានី ដែលមាននៅក្នុងសៀវភៅនិពន្ធដោយ គូដូរ៉ូ មានចំណងជើងថា «ប្រឈមមុខនឹងរឿងរ៉ាវហួសពីការនឹកស្មាន» ទំព័រទី២៧៨-៨២ ។

១៣) សូមមើលសៀវភៅនិពន្ធដោយ ចូហ្ មានចំណងជើងថា «ហ្គោលហាជិន នៅប្រទេសអាល្លឺម៉ង់» ។

១៤) សៀវភៅនិពន្ធដោយ ឡេវី មានចំណងជើងថា «អ្នកលិចលង់និងអ្នកដែលត្រូវគេជួយសង្គ្រោះ» ទំព័រទី៧៧ និងសៀវភៅនិពន្ធដោយ សហ្វស្គី មានចំណងជើងថា «ប្រព័ន្ធភេរវកម្ម» ទំព័រទី១៣០-៤៤ ។ ស្នាដៃរបស់ ព្រោននីង មានចំណងជើងថា «ពលយុទ្ធជនសាមញ្ញ» ទំព័រទី៦៧ ។

១៥) សូមមើលស្នាដៃនិពន្ធរបស់ ហ្សីមបាដូ, ហានី និងអ្នកផ្សេងទៀត ដែលមានចំណងជើងថា «ចិត្តសាស្ត្រនៃការដាក់គុក» ។ សៀវភៅមួយទៀតនិពន្ធដោយ ហ្សីមបាដូ មានចំណងជើងថា «ចិត្តគឺជាអ្នកធ្វើឲ្យមនុស្សមកជាប់គុកដ៏គួរឲ្យខ្លាច» និងសៀវភៅនិពន្ធដោយ ហានី និងអ្នកផ្សេងទៀតមានចំណងជើងថា «កម្លាំងឪណាមិចសង្គម» ។ សហ្វស្គី ដែលសរសេរសៀវភៅ «ប្រព័ន្ធភេរវកម្ម» បញ្ជាក់ត្រង់ចំណុចនេះខ្លីហើយច្បាស់ថា «ឆ្មាំវាយដំ ធ្វើទារុណកម្ម និងសម្លាប់អ្នកទោស នេះមិនមែនមកពីអ្នកណាបង្គាប់នោះទេ គឺគេធ្វើដោយមានការអនុញ្ញាតគ្មានអ្នកណាឃាត់ឃាំងអ្វីឡើយ (ទំព័រទី១១៥) ។ ទោះបីជាបញ្ជារនោះ «ស្របច្បាប់» ឬមិនស្របច្បាប់ ក៏ជនដៃដល់ភាគច្រើននៅមន្ទីរស-២១ ហាក់ដូចជាមិនមានបញ្ហាដោយសារចំណុចដែលកំណត់ឲ្យចូលជាបទឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិអ្វីដែរ ។

១៦) សូមមើលសៀវភៅនិពន្ធដោយ មីលក្រាម មានចំណងជើងថា «ការគោរពអំណាច» ដែលធ្វើការប្រៀបធៀបរវាងការពិសោធន៍របស់គាត់ផ្ទាល់ជាមួយនឹងឥរិយាបថរបស់អ្នកធ្វើការនៅជំរំមរណៈណាហ្ស៊ី និងការសម្លាប់រង្គាលនៅមីឡាយ ប្រទេសវៀតណាមក្នុងឆ្នាំ១៩៦៨ ។ ការរកឃើញរបស់ មីក្រាម កាលពីពេលនោះទទួលរងបច្ច័យទាំងពីរ ពោលទាំងការសរសើរទាំងការរិះគន់ ។ ប៉ុន្តែឥឡូវ ការរកឃើញនេះភាគច្រើនហាក់ដូចជាមិនសូវជាបញ្ហាអ្វីទេ ។ សូមមើលសៀវភៅនិពន្ធដោយ មីលល័រ មានចំណងជើងថា «ការពិសោធន៍ទៅលើការគោរពបញ្ជា» និង សៀវភៅមួយទៀតនិពន្ធដោយ មីលល័រ និងអ្នកផ្សេងទៀតមានចំណងជើងថា «គំនិតស្តីពីការគោរពអំណាច» ។

១៧) ស្នាដៃនិពន្ធរបស់ ហ៊ីនតុន មានចំណងជើងថា «ហេតុអ្វីបានជាសម្លាប់មនុស្ស?» និង «ស្រមោលកម្ពុជា» ។ ហ៊ីនតុន ទាញហេតុផលថា សម្ពាធវប្បធម៌នានាបានធ្វើឲ្យប្រជាជនខ្មែរញាប់ៗឆាប់គោរពបញ្ជា (និងឆាប់ចេញបញ្ជា) ។ បន្ថែមពីលើនេះទៀតសូមមើលសៀវភៅនិពន្ធដោយ តានីនបូម មានចំណងជើងថា «តើអ្នកណាអាចប្រកួតប្រជែងជាមួយពិភពលោកបាន?» សៀវភៅនិពន្ធដោយ ម៉ាស្តុង មានចំណងជើងថា «កម្ពុជាឆ្នាំ១៩៩១-១៩៩៤» ជាពិសេសវគ្គទី៤ និយាយអំពីការគោរពឋានានុក្រមនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ។

១៨) សៀវភៅនិពន្ធដោយ ហ៊ីនតុន មានចំណងជើងថា «ស្រមោលកម្ពុជា» ។ សៀវភៅនិពន្ធដោយ ហ៊ីនតុន មានចំណងជើងថា «ហេតុអ្វីបានជាសម្លាប់មនុស្ស?» ទំព័រទី៩៩ ។ និងវគ្គមួយមានចំណងជើងថា «ច្បាប់» និងសង្គមកម្ពុជាមុនសម័យអាណានិគមនៅក្នុងសៀវភៅនិពន្ធដោយ ឆេនដល័រ មានចំណងជើងថា «ប្រឈមមុខនឹងអតីតកាលរបស់កម្ពុជា» ទំព័រទី៤៥-៦០ ។ មីលក្រាម សរសេរនៅក្នុងសៀវភៅមានចំណងជើងថា «ការគោរពអំណាច» ទំព័រទី២០៧ថាៈ «ការគោរពបញ្ជាកើតចេញពីភាពមិនស្មើគ្នានៃការប្រាស្រ័យទាក់ទងរបស់មនុស្សជាតិ» ។ សុន សេន, ឌុច, ចាន់, និង ប៉ុន សុទ្ធតែធ្លាប់ទទួលការបណ្តុះបណ្តាល

ជាគ្រូបង្រៀន ហើយទម្លាប់ស្ដាប់បុរ្ចូលរួមគំនិតតិចជាងចេញបញ្ហា ទាមទារឲ្យគេធ្វើតាម រៀបចំរបៀបវារៈ និងឲ្យគេស្ដាប់ច្រើនជាង ។

១៩) សូមមើលសៀវភៅនិពន្ធដោយ ហ្សីមបាដូ មានចំណងជើងថា «ចិត្តសាស្ត្រប៉ូលិសចំពោះការឆ្លើយសារភាព» ។

២០) សៀវភៅនិពន្ធដោយ ឡា ហុងតែន មានចំណងជើងថា «រឿងល្បើក» ទំព័រទី២២-២៣ ។ ឡា ហុងតែន បានលើកពាក្យចាស់មកប្រើថា «ហេតុផលរបស់អ្នកខ្លាំងតែងតែត្រឹមត្រូវជានិច្ច» ។ ន័យនេះប្រហែលជាមិនខុសពីបាវចនារបស់មន្ទីរស-២១ទេ ។ មជ្ឈិមបក្សបានយកហេតុផលថា ការប្រព្រឹត្តិរបស់ខ្លួនមកលើ «ខ្មាំង» មួយផ្នែកជាការការពារមិនឲ្យមានឥរិយាបថរបស់វៀតណាមរបៀបជាចចកឃើញកូនចៀម ដែលជាខ្មែរ ។

២១) សូមមើលសៀវភៅរបស់ ជូ មានចំណងជើងថា «ប្រឆាំងនឹងបដិវត្តន៍» ។ ឌីស ប៉ូ «ក្បាលម៉ាស៊ីនភេរវកម្ម» និងសៀវភៅនិពន្ធដោយ ប៉េកយ័រ មានចំណងជើងថា «បដិវត្តន៍បារាំង» ។ សូមមើលស្នាដៃនិពន្ធរបស់ ហ្គ្រីសហ៊ីន មានចំណងជើងថា «ទង្វើរបស់កុម្មុយនិស្តចិនទៅលើអ្នកប្រឆាំងបដិវត្តន៍» ដែលដកស្រង់សម្ដីពីអ្នកបដិវត្តជនជាតិចិនម្នាក់កាលពីទសវត្សរ៍ទី៣០ថា «ច្បាប់ប្រែប្រួលទៅតាមតម្រូវការបដិវត្តន៍ ហើយអ្វីដែលមានប្រយោជន៍ចំពោះបដិវត្តន៍គឺច្បាប់» ទំព័រទី១៤១ ។ ដល់ចំណុចនេះនាំឲ្យនឹកឃើញសំណេររបស់ ម៉ៅ ដែលថា «តើគំនិតត្រឹមត្រូវបានមកពីណា?» ក្នុងនោះគាត់អះអាងថា «គំនិតត្រឹមត្រូវគឺគំនិតដែលនាំឲ្យជោគជ័យ» ។

២២) សូមមើលពត៌មានខាងក្រោយនៃឯកសារCMR57.3 កែ ណាញ (ខសភា ១៩៧៨) ដែលមានរាយឈ្មោះយុទ្ធជនកងពលលេខ២៨០ ភូមិភាគបូព៌ាដែលត្រូវបានចោទប្រកាន់ថា មានឈាមជ័រយួន ។ អ្នកទាំងអស់នេះជាមុខសញ្ញាត្រូវបោសសម្អាត ។ លោក ឃៀរនិន ដែលជាអ្នកនិពន្ធសៀវភៅ «របប ប៉ុល ពត» ឲ្យហេតុផលថា នយោបាយប្រកាន់ពូជសាសន៍ជាបញ្ហាសំខាន់របស់កម្ពុជាប្រជាធិបតេយ្យពោលគឺមិនមែនជាការបកស្រាយគំនិតសង្គមនិយមខុសនោះទេ(២៦) ។ ការឲ្យហេតុផលរបស់ ឃៀរនិន មានលក្ខណៈទន់ខ្សោយ ប៉ុន្តែវាមិនជំទាស់ទៅនឹងការពិតដែលថា ប្រជាជនភាគច្រើនដែលត្រូវបានសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺជាខ្មែរ ។ សូមមើលសៀវភៅនិពន្ធដោយ សៅវ៉ូល មានចំណងជើងថា «ព្រះពុទ្ធសាសនានិងអំពើអាក្រក់», សៀវភៅនិពន្ធដោយ ប៉ុងសូ មានចំណងជើងថា «ការផ្លាស់ប្ដូរសង្គមនៅក្នុងគំនូចបដិវត្តន៍» និងសៀវភៅនិពន្ធដោយ ឃីយេ មានចំណងជើងថា «បដិវត្តន៍កុម្មុយនិស្តនិងអតីតភាព នៃព្រះពុទ្ធសាសនា» ទំព័រទី៤៣-៧៤ ។

២៣) សៀវភៅនិពន្ធដោយ ស៊ីវ ហេដឌ័រ មានចំណងជើងថា «សាសន៍និយម, ម៉ាក្សស៊ីសនិយមនិងការចាត់ជាពួក» ទំព័រទី១៥២ ។

២៤) សៀវភៅនិពន្ធដោយ ម៉ៃឃើល វីកឃ័រី មានចំណងជើងថា «កម្ពុជាឆ្នាំ១៩៧៥-១៩៨២» វគ្គចុងបញ្ចប់ និងសូមមើលសៀវភៅនិពន្ធដោយ វីកឃ័រី ដដែលមានចំណងជើងថា «អំពើឃោរឃៅនៅ

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ» និងសំណេររបស់ អានថននី បាណេត និង សឺច ធីយ៉ុង នៅក្នុងសៀវភៅនិពន្ធរួមដោយ ឆេនដល័រ និង ឃៀរនិន មានចំណងជើងថា «បដិវត្តន៍ និងលទ្ធផលចុងក្រោយ» ។ ក្នុងនោះ បាណេត អះអាងថា ការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យជាការគ្រប់គ្រងតាមបែបមជ្ឈិមសម័យច្រើនជាងម៉ាក្ស-ឡេនីន ។ ចំណែក ធីយ៉ុង អះអាងបញ្ច្រាសមកវិញ ។ វីកឃ័ររី ទាញជាការសន្និដ្ឋានថា អ្នកម៉ាក្ស-ឡេនីន ពិតប្រាកដមិនប្រព្រឹត្តសាហាវនិងមិនសមរម្យដូចជាខ្មែរក្រហមយ៉ាងដូច្នេះទេ ។ បញ្ហាទាំងពីរនេះមានពិភាក្សាយ៉ាងលម្អិតនៅក្នុងសៀវភៅនិពន្ធដោយ ឃៀរនិន មានចំណងជើងថា «របប ប៉ុល ពត» ។ សូមមើលសៀវភៅនិពន្ធដោយ អាស្កូលី មានចំណងជើងថា «សំឡេងរបស់ខ្មែរក្រហម» ទំព័រទី២៧ ។ ចលនាខ្មែរក្រហមប្រហែលជាក្លាយទៅជាកសិករនិយមពិតៗនៅទសវត្សរ៍ឆ្នាំ៩០ នៅពេល តាម៉ុក ក្លាយជាមេដឹកនាំដ៏មានប្រសិទ្ធភាពនៃចលនានេះ ។ ការកាត់ទោស ប៉ុល ពត នៅខែកក្កដា ឆ្នាំ១៩៩៧ ដោយមើលតាមផ្លូវនេះគឺជាវិធីបញ្ចេញកំហឹងកសិករ ។ ខ្ញុំសូមនិយាយថា កំហឹងកសិករគឺជាធាតុផ្សំដ៏សំខាន់នៃមនោគមវិជ្ជាកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែមិនមែនជាកម្លាំងជំរុំដើបរំជួលរបស់របបនេះទេ ។ បន្ថែមពីលើនេះទៀត សូមមើលសៀវភៅនិពន្ធដោយ ហ៊ីនតុន មានចំណងជើងថា «មនុស្សម្នាក់មានគំនិតមួយ» ដែលសង្កត់ធ្ងន់ទៅលើសារសំខាន់នៃការសងសឹកនៅក្នុងវប្បធម៌កម្ពុជា ។

២៥) ឯកសារមិនទាន់ចុះបញ្ជីនៅបណ្ណសារមន្ទីរស-២១ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៦ ។

២៦) សៀវភៅនិពន្ធដោយ បូមែន មានចំណងជើងថា «គំនិតសម័យទំនើបនិងហាយនភាព» ទំព័រទី១៥២ ។ សៀវភៅនិពន្ធដោយ លីហ្វតុន មានចំណងជើងថា «វេជ្ជបណ្ឌិត ណាហ្ស៊ី» ។ ជាការបន្ថែម សូមមើលសៀវភៅនិពន្ធដោយ ឡេន ហ៊ុកប៊ី មានចំណងជើងថា «យើងច្បាស់ជាពុក្នាយើងយំៈ មេរៀនបានមកពីអ្នករស់រានមានជីវិតពីរបប ប៉ុល ពត» ។ «អំពើប្រល័យពូជសាសន៍ សង្គ្រាម និងការត្រដររស់របស់មនុស្សលោក» និពន្ធដោយ ស្រ្តូសឹ និង លីន ទំព័រទី២៩៧-៣០៥ ។

២៧) សៀវភៅនិពន្ធដោយ មីលក្រាម មានចំណងជើងថា «ការគោរពអំណាច» ទំព័រទី១៣៤ ដែលមានសេចក្តីដកស្រង់នៅក្នុងសៀវភៅនិពន្ធដោយ ដាលី មានចំណងជើងថា «អង្គការសង្គម» ទំព័រ២០៧ ។ ដាលីនិយាយនៅទីនេះ និងនៅក្នុងសៀវភៅ «ការស្តាប់ឱវាទប្រកបដោយន័យស្តាបនា និងការបំផ្លិចបំផ្លាញ» ថាអ្វីដែលជាការផ្លាស់ប្តូរមួយរំពេច ឬការចាំតែស្រុះស្រួលតាមដូចដែល មីក្រាម សន្មតនោះ គឺជារឿយៗមានលក្ខណៈដូចគ្នាទៅនឹងការយកលំនាំតាម ឬការរីតបន្តឹងដូចដែល សឺរីនី, ប្រោននីង និង ហ៊ីនតុនពិពណ៌នាដែរ ។ ត្រង់កន្លែងនេះយើងនៅឆ្ងាយពីគំនិតបែបរំជួលរបស់ អេលៀស ទាក់ទងនឹង «ការឈឺចាប់ចេញពីការបញ្ជា» ។ អេលៀស យល់ថា ការឈឺចាប់ចេញពីការបញ្ជានេះជាហេតុនាំឲ្យគ្មានការស្តាប់ឱវាទនិងការរើបំរះគួរឲ្យសរសើរ ។ ដាលី កត់សម្គាល់ថា «នៅក្នុងអង្គការដែលសមាជិកខ្លួនយល់ថាស្របច្បាប់កម្លាំងនាំឲ្យមានការស្តាប់ឱវាទមានច្រើនជំរុញគ្នាទៅវិញទៅមក និងមាំទាំ («អង្គការសង្គម» ទំព័រទី២៨០) ។ ដាលី និយាយថា មនុស្សដូចជាយុទ្ធជននៅកងអនុសេនាតូចក្រោមបញ្ជារបស់អនុសេនីយ៍ទោ ខាលី នៅតំបន់មីឡាយ កាលពីសង្គ្រាមវៀតណាម គឺសុទ្ធតែត្រូវបានធ្វើឲ្យចូលជាក្រុមតែមួយរួមគ្នាប្រព្រឹត្ត

អំពើអាក្រក់ ។ អំពើអាក្រក់ទាំងអស់នេះមានក្នុងការចងចាំរបស់ សឺន ថាង ដែលរៀបរាប់នៅក្នុងសៀវភៅនិពន្ធដោយ សូលី ។ សៀវភៅនេះនិយាយពីការសម្លាប់រង្គាលរបស់យុទ្ធជនជើងទឹកអាមេរិកាំងទៅលើជនស៊ីវិលដែលរស់នៅតំបន់កណ្តាលភាគខាងជើងវៀតណាមកាលពីឆ្នាំ១៩៦៩ ។

២៨) សៀវភៅនិពន្ធដោយ ស្គូប មានចំណងជើងថា «ចិត្តសាស្ត្ររបស់ជនដៃដល់ និងអ្នកនៅជិតកន្លែងកើតហេតុ» ទំព័រទី៦៦ ។ សៀវភៅនិពន្ធរួមដោយ ហ្គោលហៀល, ម៉ូលីកា និងអ្នកផ្សេងទៀតមានចំណងជើងថា «ទារុណកម្មផ្លូវកាយ និងផ្លូវចិត្ត» ។

២៩) សៀវភៅនិពន្ធដោយ តូដូរ៉ូ មានចំណងជើងថា «ប្រឈមមុខនឹងរឿងរ៉ាវហួសពីការនឹកស្មាន» ទំព័រទី២៧៩ ។

# ចំណាប់អារម្មណ៍របស់អ្នកប្រែសម្រួល

*សៀវភៅ «សំឡេងពីមន្ទីរស-២១» មានសារប្រយោជន៍ណាស់ចំពោះប្រទេសកម្ពុជា និងចំពោះខ្លួនខ្ញុំផ្ទាល់ ។ ទោះបីជាប្រទេសកម្ពុជាយើងជួបប្រទះសោកនាដកម្មក្រោមរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) យ៉ាងណាក៏ដោយ ក៏អ្នកសិក្សាស្រាវជ្រាវកម្ពុជាមិនទាន់បញ្ចេញស្នាដៃនិពន្ធដ៏ពិស្តារដូចជាសំណេររបស់លោក ដេវីដ ឆេនដល័រ ដែលលោកអ្នកកំពុងតែអាននេះដែរ ។ ស្នាដៃនិពន្ធស្ដើរតែឥតខ្ចោះនេះ មិនត្រឹមតែរៀបរាប់ពីទិដ្ឋភាព និងដំណើរការទាំងមូលនៅមន្ទីរស-២១ តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការលើកមកប្រៀបធៀបពីអំពើឃោរឃៅ និងប្រព័ន្ធព្រហ្មទណ្ឌជាមួយបណ្ដាប្រទេសកាន់លទ្ធិកុម្មុយ-និស្ត និងសង្គមនិយមនានានៅលើពិភពលោក រួមមានជាពិសេសប្រទេសចិន ប្រទេសបារាំង ប្រទេសវៀតណាម និងប្រទេសឥណ្ឌូនេស៊ីទៀតផង ។*

*គំនិតសង្ស័យ មិនទុកចិត្តគ្នាទៅវិញទៅមក និងជម្លោះផ្ទៃក្នុងរវាងអ្នកដឹកនាំខ្មែរក្រហមអាចរំឭកដល់អ្នកអានខ្មែរឲ្យគិតទៅដល់សាវតាររបស់ខ្មែរនាសម័យក្រោយអង្គរ (ឬសម័យចាកចោលអង្គរ) ដែលនៅពេលនោះ ប្រជារាស្ត្រខ្មែរត្រូវទទួលរងនូវសោកនាដកម្មយ៉ាងខ្លោចផ្សា ដោយសារការបែកបាក់ក្នុងជួរអ្នកដឹកនាំខ្មែរ ហើយប្រទេសជិតខាងឆ្លៀតឱកាសវាយលុកកាន់កាប់ទឹកដីរបស់ខ្លួនថែមទៀត ។*

*ចំពោះរូបខ្ញុំផ្ទាល់សៀវភៅ «សំឡេងពីមន្ទីរស-២១» នេះជួយឲ្យខ្ញុំបាទដែលជាអតីតកុមាររងគ្រោះក្រោមសម័យខ្មែរក្រហមនិងជាអ្នកដែលមានវាសនាបានបកប្រែសៀវភៅនិយាយអំពីខ្មែរក្រហម មានលទ្ធភាពយល់ដឹងកាន់តែច្បាស់នូវអ្វីដែលប្រជាជនកម្ពុជាភាគច្រើនបានឆ្លងកាត់ ។ ខ្ញុំកើតមកមិនបានឃើញមុខជីដូនជីតារបស់ខ្ញុំឡើយ ។ នៅពេលធំដឹងក្ដី ខ្ញុំតែងសួរខ្លួនឯងថា តើមានរឿងអ្វីកើតឡើងនៅសម័យខ្មែរក្រហម និងមូលហេតុអ្វីបានជាមានរឿងរ៉ាវបែបនេះ ។ ចម្លើយទៅនឹងសំណួរនេះមិនទាន់ចេញជារូបរាងនៅឡើយទេ ។ រហូតមកដល់ឆ្នាំ១៩៩៧ ខ្ញុំចាប់ផ្ដើមយល់បន្តិចម្ដងៗពីអំពើឃោរឃៅរបស់ខ្មែរក្រហមនៅក្នុងខណៈដែលខ្ញុំធ្វើការងារជាអ្នកបកប្រែស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ខ្ញុំទទួលខុសត្រូវបកប្រែឯកសារនានាដែលបន្សល់ទុកដោយខ្មែរក្រហមដូចជា កំណត់ហេតុកម្មាភិបាល សៀវភៅរៀនសូត្រនយោបាយ សៀវភៅនិយាយអំពីជីវភាពសហករណ៍ និងកំណត់ហេតុប្រជុំទិតៀនស្វ័យទិតៀនជាដើម ។ ការងារដែលធំនិងសំខាន់ជាងនេះ គឺការបកប្រែសៀវភៅរបស់អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ដែលមានបទពិសោធន៍និពន្ធសៀវភៅខ្នាតអន្តរជាតិគឺលោក ដេវីដ ឆេនដល័រ ។ ស្នាដៃនិពន្ធបែបប្រវត្តិសាស្ត្រនេះ បានជួយខ្ញុំបាទឲ្យយល់ដឹងពីការប្រើឃ្លោងឃ្លានិងរបៀបសរសេរសៀវភៅជាលក្ខណៈអន្តរជាតិព្រមទាំងបានជួយឲ្យខ្ញុំយល់ជ្រាបកាន់តែច្បាស់ពីប្រព័ន្ធសន្តិសុខ របៀបធ្វើទារុណកម្មដើម្បីជម្រិតយកចម្លើយ និងវិធីសាស្ត្រឃោរឃៅផ្សេងៗទៀតដែលរបបកម្ពុជាប្រជាធិបតេយ្យបង្កើតឡើងសម្រាប់គ្រប់គ្រងប្រទេស ។ តើសៀវភៅនេះជួយផ្ដល់ជាប្រយោជន៍អ្វីខ្លះដល់ប្រវត្តិសាស្ត្រខ្មែរ?*

*មកទល់នឹងពេលនេះមានប្រជាជនកម្ពុជាតិចតួចបំផុតដែលនិពន្ធចេញជាស្នាដៃមុនដំបូងនិង*

លេចធ្លោ អំពីបញ្ហាខ្មែរក្រហម ។

សៀវភៅ «សំឡេងពីមន្ទីរស-២១» ដើរតួនាទីយ៉ាងសំខាន់នៅក្នុងប្រវត្តិសាស្ត្រកម្ពុជាក្នុងសតវត្សរ៍ទី២១នេះ ។ ស្នាដៃនិពន្ធនេះជួយបំពេញចន្លោះខ្វះខាតផ្នែកប្រវត្តិសាស្ត្រកម្ពុជាទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការសិក្សាស្រាវជ្រាវអំពីរបបខ្មែរក្រហមមិនមែនមានន័យថា ជាការកកូរកកាយ និងបង្កើនកំហឹងនោះទេ ផ្ទុយទៅវិញ វាជាការប្រាប់ដល់យុវវ័យខ្មែរជំនាន់ក្រោយដែលពុំធ្លាប់បានឆ្លងកាត់របបនេះទាល់តែសោះ ឲ្យយល់ជ្រួតជ្រាបពីឫសគល់នៃអំពើឃោរឃៅ ហើយអាចជួយឲ្យប្រជាជាតិដែលទទួលរងគ្រោះចូលរួមចំណែកកាត់បន្ថយលទ្ធភាព ឬឈានទៅដល់ការទប់ស្កាត់មិនឲ្យអំពើនេះកើតឡើងសាជាថ្មីទៀត ។

ម្យ៉ាងវិញទៀត ផ្នែកមួយចំនួននៃសៀវភៅ «សំឡេងពីមន្ទីរស-២១» អាចក្លាយជាប្រធានបទប្រវត្តិសាស្ត្រនិងផ្នែកច្បាប់សម្រាប់សិក្សានៅតាមវិទ្យាល័យនិងសាកលវិទ្យាល័យនានានៅក្នុងប្រទេសកម្ពុជានាថ្ងៃអនាគតផង ។ បរិបទដែលទាក់ទងនឹងប្រវត្តិច្បាប់ គឺមានផ្នែកព្រហ្មទណ្ឌនិងទារុណកម្មតាមបែបតុលាការ និងតាមបែបបុរាណនៅក្នុងសម័យអង្គរ សម័យអាណានិគមបារាំង សម័យសាធារណរដ្ឋខ្មែរ សម័យខ្មែរក្រហម សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា សម័យរដ្ឋកម្ពុជា និងសម័យបច្ចុប្បន្ន ។

ការងារបកប្រែគឺជាការងារមួយលំបាកដែលទាមទារឲ្យអ្នកបកប្រែមានការយល់ដឹងយ៉ាងទូលំទូលាយទាក់ទងនឹងប្រធានបទដែលខ្លួនកំពុងធ្វើ ។ ការប្រើប្រាស់ភាសារបស់ប្រជាជាតិមួយទៅប្រជាជាតិមួយមានលក្ខណៈខុសគ្នា ។ លក្ខណៈខុសគ្នានេះគឺមានកម្រិតតិចឬច្រើនកាលច្រើន ។ កាន់តែមានការលំបាកជាងនេះទៅទៀតនោះគឺន័យធៀប គ្រាមភាសានិងភាសាទាក់ទងនឹងចិត្តវិទ្យា ។ សៀវភៅ «សំឡេងពីមន្ទីរស-២១» មានលើកឡើងនូវប្រធានបទទាក់ទងនឹងចិត្តសាស្ត្រស៊ីជម្រៅរបស់អ្នកនិពន្ធក៏ដូចជាចិត្តវិទូល្បីៗ ។

ខ្ញុំយល់ថា ការបកប្រែទាមទារនូវការផ្តោតគំនិតនិងការផ្ចិតផ្ចង់ពិសោធន៍ ។ មានតែបទពិសោធន៍ខ្វះការផ្តង់គំនិតក៏អាចនាំឲ្យមានបញ្ហាដែរ ។ យ៉ាងណាមិញ ការប្រើពាក្យថា «បកប្រែ» នេះតិចឬច្រើនអាចឃ្លាតបរិបទដើមបាត់ទៅហើយ ។ ពាក្យដែលខ្ញុំប្រើនៅទីនេះគឺ «ប្រែសម្រួល» ដោយហេតុថា ភាសាមួយៗមិនអាចបកចេញដោយគ្មានការកែសម្រួលបន្ថែមបន្ថយឲ្យចូលជាភាសាកំណើតរបស់យើងបានទេ ។ មានន័យថា អ្នកប្រែសម្រួលភាសាមិនខុសពីជាងចម្លាក់រូបនោះទេ ពោលគឺជំនាញទាំងពីរនេះត្រូវការការផ្ចិតផ្ចង់ និងការចេះច្នៃប្រឌិត ។

ដោយមានជំនាញខាងអក្សរសាស្ត្រអង់គ្លេសផងនោះ ខ្ញុំអាចនិយាយបានថា ខ្ញុំមានលទ្ធភាពមួយភាគទៅហើយ ។ ថែមពីលើជំនាញនេះទៀត ខ្ញុំមានបទពិសោធន៍ប្រើប្រាស់សទ្ទានុក្រមច្រើនគួរសមដោយផ្អែកលើសំណេររបស់អ្នកសិក្សាជាន់ខ្ពស់លើបញ្ហាកម្ពុជា លើប្រធានបទខ្មែរក្រហម ។ ខ្ញុំសង្ឃឹមថាស្នាដៃប្រែសម្រួលរបស់ខ្ញុំនេះ នឹងជាទីពេញចិត្តរបស់អ្នកអានគ្រប់ៗរូប ។

ស្វ ប៊ុនស៊ូ

# ប្រវត្តិរូបសង្ខេបអ្នកប្រែសម្រួល

*សួ ប៊ុនស៊ូ កើតថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៧៦ នៅភូមិសៀមរាប ឃុំសៀមរាប ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។ សួ ប៊ុនស៊ូ មានប្អូនស្រីម្នាក់រស់នៅជាមួយម្ដាយ ។ នៅឆ្នាំ១៩៧៩ ម្ដាយ ប៊ុនស៊ូ និងប្អូនស្រីបានធ្វើដំណើរត្រឡប់មកពីខេត្តព្រះវិហារ ដើម្បីមករស់នៅស្រុកកំណើតវិញ ។ ដោយសារលក្ខខណ្ឌរស់នៅមិនអំណោយផល នៅឆ្នាំ១៩៨២ ក្រុមគ្រួសារ ប៊ុនស៊ូ បានផ្លាស់ប្ដូរលំនៅមករស់នៅខេត្តកំពង់ស្ពឺ ប្រកបរបរបន្តិចបន្តួចសម្រាប់ចិញ្ចឹមជីវិត ។*

*ទោះបីជាជីវភាពរស់នៅក្រីក្រលំបាកជាមួយម្ដាយ និង ប្អូនស្រីដែលនៅតូចនៅឡើយ និងនៅក្រោមការឃោឃៅពីសំណាក់ខ្មែរក្រហមយ៉ាងណាក៏ដោយ ប៊ុនស៊ូ ខិតខំរៀនសូត្ររហូតដល់ប្រឡងជាប់សញ្ញាប័ត្រទុតិយភូមិនៅឆ្នាំ១៩៩៣ នៅវិទ្យាល័យកំពង់ស្ពឺ ។ នៅឆ្នាំ១៩៩៥ ទទួលបានអាហារូបករណ៍សាកល-វិទ្យាល័យភូមិន្ទភ្នំពេញ ។ នៅពេលកំពុងសិក្សានៅឆ្នាំទីពីរ(ឆ្នាំ១៩៩៧) ប៊ុនស៊ូ បានចូលបម្រើការងារស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ទទួលបន្ទុកជាអ្នកបកប្រែពីភាសាខ្មែរមកភាសាអង់គ្លេស នូវឯកសារកំណត់ហេតុខ្មែរក្រហម និងឯកសារផ្សេងៗដែលទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ និងរបបសាធារណរដ្ឋខ្មែរ ។*

*នៅអំឡុងឆ្នាំ១៩៩៩ ប៊ុនស៊ូ ទទួលសញ្ញាប័ត្រថ្នាក់បរិញ្ញាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ជំនាញឯកទេស «បរិញ្ញាប័ត្រអប់រំភាសាអង់គ្លេស» ។*

*នៅដើមឆ្នាំ២០០០ ប៊ុនស៊ូ ត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជាបញ្ជូនឲ្យទៅទទួលការបណ្ដុះបណ្ដាលនៅសាកលវិទ្យាល័យញូសៅវែល ប្រទេសអូស្ត្រាលី ផ្នែកគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធកុំព្យូទ័រ ។ នៅឆ្នាំ១៩៩៧-២០០១ ប៊ុនស៊ូ បានក្លាយទៅជាអ្នកបកប្រែឯកសារទូទៅនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ នៅចុងឆ្នាំ២០០១ ប៊ុនស៊ូ ទទួលនាទីជានិពន្ធនាយករងទស្សនាវដ្ដី «ស្វែងរកការពិត» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។*

*មកដល់ពាក់កណ្ដាលឆ្នាំ២០០២ ប៊ុនស៊ូ បានទទួលការបណ្ដុះបណ្ដាលជំនាញ «បង្រៀនសិទ្ធិមនុស្ស» នៅរដ្ឋគូបិក ប្រទេសកាណាដា ។ នៅខែកុម្ភៈ ឆ្នាំ២០០៣ ប៊ុនស៊ូ ទទួលការបណ្ដុះបណ្ដាលផ្នែក «ប្រព័ន្ធផ្សព្វផ្សាយ» នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ។ នៅពាក់កណ្ដាលឆ្នាំ២០០៣ ប៊ុនស៊ូ ត្រូវបានតែងតាំងជាសហនិពន្ធនាយកនៃទស្សនាវដ្ដី «ស្វែងរកការពិត» បោះពុម្ពផ្សាយជាភាសាអង់គ្លេស ។*

# VOICE FROM S-21

## TERROR AND HISTORY IN POL POT'S SECRET PRISON

*Translated in to the Khmer Language*
*by Sour Bunsou*

*Edited by Youk Chhang, Huy Vannak and Tep Meng Khean*

*Translation Series No. 3 ◆ Documentation Center of Cambodia*